## សាកលវិទ្យាល័យភូមិន្ទកសិកម្ម
## មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ

# ការវិភាគគោលនយោបាយកសិកម្ម
# Agricultural Policy Analysis

សាស្ត្រាចារ្យរង បណ្ឌិត ឆាយ គន្ធា

ឧបត្ថម្ភដោយ

២០២១

សាកលវិទ្យាល័យភូមិន្ទកសិកម្ម
មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ

# ការវិភាគគោលនយោបាយកសិកម្ម

## Agricultural Policy Analysis

សាស្ត្រាចារ្យបណ្ឌិត ឆាយ គន្ធា

២០២១

# រក្សាសិទ្ធ

© ឆ្នាំ២០២១

**រក្សាសិទ្ធគ្រប់យ៉ាង**

គ្មានផ្នែកណាមួយនៃសៀវភៅនេះ អាចត្រូវបានថតចម្លង និងផលិតឡើងវិញ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកនិពន្ធ និងសាកលវិទ្យាល័យភូមិន្ទកសិកម្មឡើយ។

បោះពុម្ពលើកទី១ ដោយមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍(ស.គ.ន)នៃក្រសួងអប់រំ យុវជន និងកីឡា នៅព្រះរាជាណាចក្រកម្ពុជា។

**ទំនាក់ទំនងព័ត៌មាន:**

អ្នកនិពន្ធ៖ សាស្ត្រាចារ្យរង បណ្ឌិត **ឆាយ គន្ធា**

ទូរស័ព្ទ៖ (+៨៥៥) ១២ ៦៨៤ ៨២៨ / ៩៨ ៦៨៤ ៨២៨

អ៊ីមែល៖ chhaykongkea@gmail.com

© 2021 by Assoc. Prof. CHHAY Kongkea, Ph.D. All rights reserved. No part of this publication may be reproduced, stored in a retrieval system, or transmitted by any process without the prior written permission from the author and the Royal University of Agriculture.

First Edition

Printed by the Research Creativity and Innovation Fund (RCI Fund) of Ministry of Education, Youth and Sports, Kingdom of Cambodia

Enquiries about the book:

Author: Assoc. Prof. CHHAY Kongkea, Ph.D.
Mobile phone: (+855) 12 684 828 / 98 684 828
Email: chhaykongkea@gmail.com

# បុព្វកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយ ដែលចាប់ឫសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សារជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ៨% ក្នុងមួយឆ្នាំ។ លើសពីនេះទៀត អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣% នៅឆ្នាំ២០០៤ មកនៅទាបជាង១០% នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្រប់ដណ្ដប់ក៏កំពុងលេចរូបរាងឡើង ដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោកនិងតំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្ដល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តពង្រឹងនិងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវនិងនវានុវត្តន៍ ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជា ឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ត្រូវតែមានការកែលម្អ។

បណ្ដាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាងហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផលប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក មានប្រមាណ៥%នៃការវិនិយោគទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង២នេះមានប្រជាជនប្រមាណ២០%នៃប្រជាជនពិភពលោក។ ប្រទេសចំនួន៦ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ៧០%នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះ

ចាំបាច់តម្រូវឱ្យពលរដ្ឋកម្ពុជា ត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ ២០០២នូវបម្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labour and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការផលិត ជ្រើសរើស បន្សាំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះ អាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាសក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវ ការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទាក្នុងបុព្វហេតុនៃមនុស្សជាតិនិងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជាមូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណភ្ជាប់ បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្ត គឺជាចលករនៃការរៀនរបស់សិស្ស។ ធាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយពុទ្ធិគឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំ គឺជានវានុវត្តន៍នៃវិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ជាពិសេសគឺគ្រឹះស្ថានឧត្តមសិក្សាត្រូវមានតួនាទីដែលប្រកបដោយការឆ្លើយតប ចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ច តាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយជាស្ពាននៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបពុទ្ធិ ក៏ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិកនិងសារគមនាគមន៍ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរេខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ទនគីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក។ លក្ខណៈសម្បត្តិ

នៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាដំបូងពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយគុណាធិបតេយ្យ និងជាពិសេសគឺការបណ្តុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្ស និងនិស្សិតអាចទទួលបានពីគ្រូនៅគ្រឹះស្ថានសិក្សា ដែលធ្វើឱ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ក្នុងមួយឆ្នាំ មានសៀវភៅជាង២,២លានចំណងជើង ត្រូវបានសរសេរនិងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន៤៤០ពាន់ ចំណែកឯសហរដ្ឋអាមេរិកមាន៣០៥ពាន់ និងប្រទេសរុស្ស៊ីមាន១២០ពាន់ចំណងជើង។

ខណៈពេលដែលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើនជម្រើសសម្រាប់សិស្ស-និស្សិត និងសាធារណៈជន រួមមានការអានសៀវភៅ ការអានលើឧបករណ៍អេឡិចត្រូនិក ការអានដោយប្រើទូរសព្ទវៃឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយសំខាន់ៗដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើប ចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស-និស្សិត និងសាធារណៈជនកម្ពុជាដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជាបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀត បច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្ទែមនៃការអប់រំ ជាពិសេសការអប់រំតាមប្រព័ន្ធអេឡិចត្រូនិកនិងការអប់រំពីចម្ងាយ ដើម្បីលើកកម្ពស់អំណាន តាមរយៈការផលិតមាតិកាឌីជីថលដែលមានភាពចំរុះ ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំជាមួយការចែកសន្លឹកកិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្តុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សា ឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ និងផ្តល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស និស្សិត និងសាធារណៈជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

១. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា

២. គ្រឹះស្ថានឧត្តមសិក្សា សូមផ្តល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាពជាមួយធនធានអំណាន ជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ
៣. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យ ត្រូវរៀបចំដំណើរការរៀនបង្រៀន និងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យដែលតម្រូវឱ្យនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន
៤. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថលជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់និងនិស្សិតគ្រប់កម្រិតសិក្សាអាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណានកាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន
៥. និស្សិតគ្រប់កម្រិតសិក្សាត្រូវខិតខំនិងចំណាយពេលវេលាដើម្បីអាន និងចាត់ទុកវប្បធម៌និងអកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ
៦. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែច្រើនថែមទៀត ជាពិសេសការលៃលកចំណាយនៅក្នុងគ្រួសារសម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការវិនិយោគមួយដ៏សំខាន់ សម្រាប់ បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា "មូលនិធិ ស.គ.ន." និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា "RCI Fund"។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន. បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន៣ រួមមានឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម៤.០ (Digitalization for IR.4.0) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម (Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី២១ ($21^{st}$ Century Pedagogy Research)។

ដោយមានការធ្វើអាទិភាពូបនីយកម្មទៅលើទិសដៅ នៃការប្រើប្រាស់ថវិកាមូលនិធិសម្រាប់ឆ្នាំ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការគាំទ្រដល់ការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា (Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូនដល់និស្សិត

ដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះទៀត ការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា មានគោលដៅដូចខាងក្រោម ៖

១. ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិតនៅកម្រិតឧត្តមសិក្សា
២. លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀននិងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់
៣. បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈនិងបទពិសោធន៍សម្រាប់បានៈសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ
៤. រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិត ត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច២ច្បាប់នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំថវិកាមូលនិធិ ស.គ.ន រួច សូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំថវិកាមូលនិធិ ដើម្បីរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា សូមរួសរាន់ចូលរួមដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទូចនិងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

# សេចក្តីបញ្ជាក់
# នៃមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោងរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ ឬរូបភាព ដែលមាននៅក្នុងសៀវភៅនេះ គឺជាជំហរនិងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡាឡើយ។

# សេចក្តីថ្លែងអំណរគុណ

សៀវភៅ "**ការវិភាគគោលនយោបាយកសិកម្ម**" នេះអាចប្រសូត្រចេញបានក៏ដោយសារមានការចូលរួម និងការផ្តល់វិភាគទានយ៉ាងធំធេងពីបណ្តាអ្នកវិទ្យាសាស្ត្រ និងឥស្សរជនដែលមានបទពិសោធន៍នៅក្នុងផ្នែកស្រាវជ្រាវកសិកម្មជាច្រើនរូប។

ខ្ញុំសូមថ្លែងអំណរគុណជាអនេកប្បការដល់ការពិនិត្យ ជួយកែលម្អ អក្ខរាវិរុទ្ធ ឃ្លាប្រយោគ ខ្លឹមសារអត្ថបទ លះបង់ពេលវេលាដ៏មានតម្លៃមិនខ្លាចនឿយហត់ និងផ្តល់ជាមតិល្អៗក្នុងការរៀបចំសៀវភៅនេះដល់៖

- ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ង៉ោ ប៊ុនថាន** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ក៏ដូចជាអង្គភាពសាមី(សាកលវិទ្យាល័យភូមិន្ទកសិកម្ម)
- ឯកឧត្តមបណ្ឌិត **សាន វឌ្ឍនា** អនុរដ្ឋលេខាធិការនៃក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍
- សាស្ត្រាចារ្យរងបណ្ឌិត **ហួន ថាវរៈ** សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- លោក **ឧខ សុជាតិ** នាយករងផ្នែកស្រាវជ្រាវនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- គណៈកម្មការត្រួតពិនិត្យមហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ និងគណៈកម្មការត្រួតពិនិត្យសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដែលបានជួយជ្រុមជ្រែងក្នុងការស្រាវជ្រាវ
- គណៈកម្មការត្រួតពិនិត្យ៖ លោកបណ្ឌិត សឺន សុទ្ធ លោកបណ្ឌិត ម៉ក់ ពុទ្ធី លោកបណ្ឌិត ឆាំង ហ៊ុយ លោកបណ្ឌិត ហែម ឡាច លោកបណ្ឌិត វង្ស ឪណា លោក អេង លេង លោកស្រី ហ៊ូ ផល្លា លោកស្រី ឆាយ ស្រីល័ក្ខ និងលោកស្រី ឆាយ ស្រីមុំ
- អ្នកផ្តល់យោបល់នានា ក៏ដូចជាអ្នកផ្តល់ជាឯកសារយោងទាំងភាសាជាតិ និងភាសាបរទេសនានា
- ភរិយា និងកូនស្រីទាំងពីរជាទីស្រឡាញ់របស់ខ្ញុំ ព្រមទាំងមិត្តភក្តិដែលបានជួយជ្រោមជ្រែងទាំងអស់

ខ្ញុំសូមថ្លែងអំណរគុណជាអនេកប្បការដល់៖

- Prof. Dr. Joon-Keun Park, Professor Emeritus, Department of Agricultural Economics, Graduate School, Chonnam National University (CNU), Gwangju City, South Korea.
- លោកស្រី យ៉ែម ម៉ុយហ៊ួង
- កញ្ញា គង្គា សុជាតា និស្សិតឆ្នាំទី៤ ផ្នែកឱសថការីឧត្តម សាលាអន្តរជាតិ មហាវិទ្យាល័យឱសថការីនៃសាកលវិទ្យាល័យជិនណាន សាធារណរដ្ឋប្រជាមានិតចិន (International School, College of Pharmacy, Jinan University, China)។

- កញ្ញា គង្គា សិរីល័ក្ខ សិស្សថ្នាក់ទី៩ នៃសាលារៀនប៊ែលធីអន្តរជាតិ សាខាទី៩ នៃព្រះរាជាណាចក្រកម្ពុជា។

ដែលបានជួយផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធ និងឃ្លាប្រយោគ ការវាយអត្ថបទ ការរចនារូបភាព ដ្យាក្រាម និងក្រាភិចមួយចំនួនតាមកម្មវិធីកុំព្យូទ័រសម្រាប់ជាឧទាហរណ៍នៅក្នុងការគណនា និងការវិភាគទិន្នន័យនានានៅក្នុងវិធីសាស្ត្ររៀបចំតាមកម្មវិធីកុំព្យូទ័រនានាដូចជា៖ SPSS, SAS, MiniTab, GAME, ...។ល។

# អារម្ភកថា

បច្ចុប្បន្ននេះមុខវិជ្ជា "ការវិភាគគោលនយោបាយកសិកម្ម" (Agricultural Policy Analysis) គឺគោលគំនិតមួយដ៏សំខាន់ ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍន៍គោលនយោបាយកសិកម្មសំដៅឆ្ពោះទៅរកភាពជោគជ័យនៃការសម្រេចបាននូវស្បៀងគ្រប់គ្រាន់ និងសុវត្ថិភាពស្បៀងជូនសង្គមជាតិ ការកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍សម្រាប់ដឹកផលិតផលកសិកម្មពីកសិដ្ឋានមកទីផ្សារកសិកម្មដើម្បីលក់ភោគផលកសិផលឱ្យទាន់ពេលវេលា។ ទន្ទឹមនឹងនេះដែរ ការបណ្តុះបណ្តាលធនធានមនុស្ស និងការគ្រប់គ្រងធនធានមនុស្ស ការរៀបចំយុទ្ធសាស្ត្រ និងការគៀងគរនូវប្រភពធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងធនធានសម្ភារៈរូបវន្ត ការធ្វើទំនើបកម្មកសិកម្ម ការបង្កើនចំណូលនៅទីជនបទ ការធ្វើម៉ាយីតជីងកសិកម្ម ការវិភាគការងារកសិកម្ម ការវិភាគថ្លៃនៃផលិតផលកសិកម្ម ការអភិវឌ្ឍន៍ជនបទ ការកសាងគោលនយោបាយភូមិមួយផលិតផលមួយ ស្រុកមួយផលិតផលមួយ ខេត្តមួយផលិតផលមួយ ការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មកសិកម្ម ការធ្វើកសិអាជីវកម្ម និងកសិឧស្សាហកម្ម ជាបញ្ហាគ្រឹះនិងចម្បងបំផុតនៃមុខវិជ្ជាការវិភាគគោលនយោបាយកសិកម្ម ព្រោះវាជាយុទ្ធសាស្ត្រដ៏សំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍បដិវត្តបៃតងនៅកម្ពុជាដែលធ្វើឱ្យជីវភាពប្រជាជននៅទីជនបទមានភាពធូរជារ និងបង្កើតឱកាសការងារនៅទីជនបទផងដែរ។

ដើម្បីចូលរួមចំណែកក្នុងការឆ្លើយតបទៅនឹងសំណូមពររបស់មិត្តអ្នកអាន ជាពិសេសអ្នកដែលមានចំណង់ចំណូលចិត្តទៅលើកិច្ចការគ្រប់គ្រង និងការវិភាគគោលនយោបាយកសិកម្ម។ ខ្ញុំសង្ឃឹមថាព័ត៌មាន និងការណែនាំដែលមាននៅក្នុងសៀវភៅនេះ អាចជាជំនួយដល់អ្នកដែលមានចំណង់ចំណូលចិត្តស្វែងយល់ពីការគ្រប់គ្រង ការអភិវឌ្ឍន៍ ការស្រាវជ្រាវវិស័យកសិកម្ម ហើយជាពិសេសជាងនេះទៅទៀតគឺអ្នកដែលមានគំនិតចង់ចាប់យកមុខរបរធ្វើកសិអាជីវកម្មផ្ទាល់ខ្លួនជាអាជីពនៅពេលដ៏ខ្លីខាងមុខទុកជាឯកសារ។

ម្យ៉ាងទៀតសព្វថ្ងៃនេះ បរិមាណបញ្ញាវ័ន្ត គឺកាន់តែកើនឡើងច្រើន បើប្រៀបធៀបទៅនឹងប៉ុន្មានឆ្នាំកន្លងមក ក៏ប៉ុន្តែយើងពុំសូវឃើញមានសៀវភៅសិក្សា សៀវភៅបច្ចេកទេស និងឯកសារស្រាវជ្រាវពីសកម្មភាពសេដ្ឋកិច្ចផ្សេងៗឯទៀតជាភាសាខ្មែរឱ្យច្រើនសំបូរនៅឡើយទេ។

ខ្ញុំជឿជាក់ថា អ្នកខ្លះមានចិត្តចង់សសេរដែរ តែកង្វះខាតជីវភាពរស់នៅ និងថវិកា អ្នកចេះដឹង និងបញ្ញវ័ន្តជាច្រើនជាប់រវល់មមាញឹកធ្វើការឱ្យអង្គការឯកជន ក្រុមហ៊ុនអាជីវកម្មនានា អង្គការមនុស្សធម៌ ដើម្បីអ្វី គឺ ដើម្បីរកប្រាក់មកចិញ្ចឹមគ្រួសាររបស់គេ គេពុំបានយកចិត្តទុកដាក់ក្នុងការចងក្រងជាសៀវភៅ ឯកសារបច្ចេកទេស សម្រាប់ទុកឱ្យក្មេងជំនាន់ក្រោយនៅឡើយ។ បញ្ហាមួយទៀតអ្នកដែលទើបនឹង បញ្ចប់ថ្នាក់ឧត្តម (បរិញ្ញាបត្រ) ភាគច្រើន មានបទពិសោធន៍ផ្នែកបច្ចេកទេស និងចំណេះដឹង

ផ្នែកភាសាបរទេស ពុំទាន់បានជ្រៅជ្រះនៅឡើយ ដែលជាបញ្ហាមួយពិបាកដល់ការស្រាវជ្រាវរកឯកសារបច្ចេកទេស។

ដើម្បីចូលរួមចំណែកក្នុងការឆ្លើយតបទៅនឹងសំណូមពររបស់មិត្តអ្នកអាននានា ជាពិសេសអ្នកដែលមានចំណាប់ចំណូលចិត្តទៅលើកិច្ចការស្រាវជ្រាវអំពីវិស័យសេដ្ឋកិច្ចនោះ ខ្ញុំសង្ឃឹមថា ព័ត៌មាន និងការណែនាំដែលមាននៅក្នុងសៀវភៅនេះ អាចជាជំនួយដល់អ្នកដែលមានចំណាប់ចំណូលចិត្តស្វែងយល់ពីសេដ្ឋកិច្ចវិទ្យា អ្នកស្រាវជ្រាវ និស្សិត ហើយជាពិសេសជាងនេះទៅទៀត គឺអ្នកដែលមានគំនិតចង់វិភាគពីគម្រោងអាជីវកម្មមុននឹងគេចាប់ផ្តើមប្រកបមុខរបរធ្វើអាជីវកម្មផ្ទាល់ខ្លួនជាអាជីពនៅពេលដ៏ខ្លីខាងមុខទុកជាមាគ៌ាបង្ហាញផ្លូវនៃការគិតជាមុន និងទុកជាឯកសារផងដែរ។

អ្វីដែលសព្វថ្ងៃនេះមាន វានឹងអាចប្រែប្រួលនៅថ្ងៃស្អែក ស្នាដៃនេះជាជំហានដំបូងរបស់ខ្ញុំ ជាពន្លឺនាំមុខមួយដើម្បីត្រួសត្រាយផ្លូវនៃផ្នែកឯកសារទាក់ទងនឹងជំនាញសេដ្ឋកិច្ច ធុរកិច្ចកសិកម្ម សំដៅដោះស្រាយនូវបញ្ហាមួយចំនួនក្នុងចំណោមបញ្ហាដែលកំពុងជួបប្រទះ ទោះបីជាពុំបានទាំងស្រុងក៏ដោយ។

ខ្ញុំបាទនឹងរង់ចាំទទួលនូវការរិះគន់កែលម្អក្នុងន័យស្ថាបនា និងការអភិវឌ្ឍន៍ ដើម្បីធ្វើឱ្យឯកសារនេះកាន់តែមានភាពសុក្រិតថែមទៀត។ ខ្ញុំបាទសូមអភ័យទោសដល់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី បញ្ញវន្ត និស្សិត អ្នកស្រាវជ្រាវ និងប្រជាជនទាំងអស់ ព្រមទាំងមិត្តអ្នកអានទាំងអស់ផងដែរ ប្រសិនបើមានការខុសឆ្គងដោយអចេតនាក្នុងការប្រើឃ្លាប្រយោគ ឬកំហុសអក្ខរាវិរុទ្ធ ដែលកើតមាននៅក្នុងសៀវភៅនេះ។

ជាអវសានសេចក្តី ខ្ញុំបាទសូមជូនពរ ដល់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាង អ្នកស្រាវជ្រាវ បញ្ញវន្ត និស្សិត និងមិត្តអ្នកអានទាំងអស់សូមជួបតែនឹងពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ ព្រមទាំងមានសុភមង្គលល្អប្រពៃទាំងក្នុងជីវិតផ្ទាល់ខ្លួន និងក្នុងជីវិតក្រុមគ្រួសារ ថែមទាំងមានសំណាងល្អ និងទទួលបាននូវសេចក្តីចម្រុងចម្រើនគ្រប់ពេលវេលាជានិច្ច។

ថ្ងៃសុក្រ ០១កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១
**អ្នកនិពន្ធ**

**សាស្ត្រាចារ្យរង បណ្ឌិត ឆាយ គង្គា**
Assoc. Prof. CHHAY Kongkea, Ph.D.

# អំពីអ្នកនិពន្ធ



**នាម និងគោត្តនាម** ៖ សាស្ត្រាចារ្យរង បណ្ឌិត**ឆាយ គង្គា**
(Assoc. Prof. CHHAY Kongkea, Ph.D.)

**អាស័យដ្ឋាន** ៖ ភូមិសំបួរ សង្កាត់ជង្កា ខណ្ឌដង្កោ រាជធានីភ្នំពេញ

**ស្ថាប័នការងារ** ៖ មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

**ឯកទេស ឬមុខជំនាញ** ៖ បណ្ឌិតផ្នែក វិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញសេដ្ឋកិច្ចកសិកម្ម

**ប្រវត្តិការសិក្សា៖**

- 2003-2006 Ph.D. Degree in Economics, Major in Agricultural Economics Chonnam National University, Gwangju City, South Korea.
- 2001–2003 Master's Degree in Economics, Major in Agricultural Economics Chonnam National University, Gwangju City, South Korea.
- 1993-1998 Bachelor's Degree in Economics, Major in Enterprise Management
  Faculty of Law and Economics, Phnom Penh, Cambodia
  [Present: Royal university of Law and Economics (RULE)]
- 1993-1996 Diplôme de Baccalauréat en sciences économiques, Faculté de droit et des sciences économiques, Royaume du Cambodge.
- 1990-1992 Diplima Up-Grading of Psychogical Pedagogy, Major in Mathematics,
  Battambang Psychogical Pedagogy School, Battamabng Province.
- 1992-1993 Certificate of Preparatory Class, Institute of Economic Sciences (Present: National University of Management), Cambodia.
- 1990-1992 Diplima of Sinor Hight School, Battambang Secondary School, Battambang Province, Kingdom of Cambodia.

**បទពិសោធន៍ការងារ៖**

- 2007 - បច្ចុប្បន្ន៖ព្រឹទ្ធបុរសរង (Vice Dean) មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ព្រះរាជាណាចក្រកម្ពុជា
- 2012 - បច្ចុប្បន្ន៖សាស្ត្រាចារ្យរង (Associate Professor) តាមអនុក្រឹត្យលេខ ៥៤៤ អនក្រ.ត.ក ស្តីពីការតែងតាំងឋានៈជាសាស្ត្រាចារ្យរងជូនមន្ត្រីរាជការ និងគ្រូបង្រៀនថ្នាក់ឧត្តម ក្នុងវិស័យកសិកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ2012

- 1990 - 1992៖ជាប្រធានគណនេយ្យ នៃការិយាល័យគណនេយ្យ និងហិញ្ញវត្ថុ នៃក្រុមហ៊ុនជានីម៉ិច រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
- 1998 - បច្ចុប្បន្ន៖គ្រូបង្រៀនតាមសាកលវិទ្យាល័យនានា៖ NUM, BBU, NIB, HRU, UME, …

# មាតិកា

បុព្វកថា និងសេចក្តីបញ្ជាក់នៃមូលនិធិ

**ទំព័រ**


សេចក្តីថ្លែងអំណរគុណ.......................................................................................i
អារម្ភកថា.....................................................................................................iii
មាតិកា.........................................................................................................vi


**មេរៀនទី ១**

**ប្រវត្តិនៃការអភិវឌ្ឍន៍គោលនយោបាយវិស័យកសិកម្ម**

(The Background of Agricultural Policy)


១.១.សេចក្តីផ្តើម............................................................................................ ១
១.១.១.ប្រព័ន្ធសេដ្ឋកិច្ចបូរាណ (Traditional System).......................................២
១.១.២.ប្រព័ន្ធសេដ្ឋកិច្ចបញ្ជា ឬប្រព័ន្ធសេដ្ឋកិច្ចផែនការ.......................................៣
១.១.៣.ប្រព័ន្ធសេដ្ឋកិច្ចចម្រុះ (Mixed Economy System) ...............................៧
១.១.៤.ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ (Free Market Economic System)...................... ៨
១.២.ពាណិជ្ជកម្មសេរី និងកិច្ចការពារ(Free Trade and Protection).......................... ១៣
១.៣. បញ្ហាប្រឈមចម្បងៗនៃគោលនយោបាយកសិកម្ម........................................... ១៤
១.៤.កម្មវត្ថុនៃគោលនយោបាយកសិកម្ម(The Objective of Agricultural Policy) ........ ១៦
១.៥.ប្រភេទសំខាន់ៗនៃគោលនយោបាយកសិកម្ម.................................................... ១៦
១.៦.ការអភិវឌ្ឍន៍គោលនយោបាយសេដ្ឋកិច្ច និងលទ្ធិ ............................................. ១៨
១.៧.ប្រព័ន្ធនៃការបែងចែក .................................................................................២១
១.៨.ការមិនមានការផ្លាស់ប្តូរនៃការផ្គត់ផ្គង់ ..............................................................២១
១.៩.អចល័តភាពនៃកត្តាផលិតកម្ម.........................................................................២៣
១.១០.ការចាត់តាំងលក្ខណៈពិសេសនៃកសិកម្ម........................................................២៤
១.១១.ឥទ្ធិពលនៃកត្តាធម្មជាតិ .............................................................................២៤
១.១២.លក្ខណៈពិសេសនៃតម្រូវការ .......................................................................២៥


**មេរៀនទី២**

**គោលនយោបាយនៃការជម្រុញឡើងសេដ្ឋកិច្ចជាតិ**

(Economic Foundations of Policy)


២.១. សញ្ញាណនៃសេដ្ឋកិច្ច.................................................................................២៨
២.១.១ ប្រភព និងអត្ថន័យនៃពាក្យសេដ្ឋកិច្ច...............................................................២៨
(The Source and Meaning of Economics) .............................................២៨

២.១.២ តើសេដ្ឋកិច្ចជាអ្វី? (What is Economics? ) ..... ៣០
២.២. តម្រូវការ និងផ្គត់ផ្គង់ ..... ៣៦
២.២.១. លំនាំដើមនៃទីផ្សារ (An Introduction to The Market) ..... ៣៦
២.២.២. តម្រូវការកសិផល (Demand of Agriculture Products) ..... ៣៧
២.៣. ទីផ្សារ និងសមតាក្រុមហ៊ុន ..... ១៣៣
២.៣.១.សមតាទីផ្សារ (Market Equilibrium) ..... ១៣៣
២.៣.២. ការកំនត់សមតាទីផ្សារ (Determining the market equilibrium) ..... ១៣៣
២.៣.៣. ស្ថានភាពលើស និងស្ថានភាពខ្វះ (Surplus and Shortage) ..... ១៣៥
២.៣.៤. ការប្រែប្រួលសមតា (Change in Equilibrium) ..... ១៣៧
២.៤. ដែនកំណត់នៃសេដ្ឋកិច្ច ..... ១៣៨
២.៤.១. ព្រំដែនថ្លៃខាងក្រោម (Price Floor) ..... ១៣៨
២.៤.២. ព្រំដែនថ្លៃខាងលើ (Price Ceiling) ..... ១៣៩
២.៤.៣. ផ្សារងងឹត (Black Market) ..... ១៤០
២.៥. គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ..... ១៤១
២.៦. ទ្រឹស្តីពាណិជ្ជកម្មកសិកម្ម ..... ១៤៣

**មេរៀនទី ៣**

**គម្រោងគោលនយោបាយកសិកម្ម**

(Agricultural Policy Framework)

៣.១.យុទ្ធសាស្រ្ត និងគោលនយោបាយ ..... ១៤៨
៣.១.១. យុទ្ធសាស្រ្តតាមវិស័យ ..... ១៤៨
៣.១.២. ហេតុអ្វីគោលនយោបាយកសិកម្ម? ..... ១៥១
៣.២ សញ្ញាណនៃឧបករណ៍គោលនយោបាយកសិកម្ម ..... ១៥៣
៣.២.១ ប្រភេទនៃគោលនយោបាយកសិកម្ម ..... ១៥៤
៣.២.២ និតិវិធីសាស្រ្តនៃគោលនយោបាយកសិកម្ម ..... ១៥៦
៣.២.៣ គោលនយោបាយ កម្មវិធី និងគម្រោង ..... ១៥៧
៣.៣ កម្មវត្ថុនៃគោលនយោបាយកសិកម្ម ..... ១៥៨
៣.៤ តួនាទីរដ្ឋាភិបាលក្នុងវិស័យកសិកម្ម ..... ១៦០
៣.៥ ការអនុវត្តន៍យុទ្ធសាស្រ្ត និងគោលនយោបាយ ..... ១៦៣
៣.៦. គោលនយោបាយស្រាវជ្រាវកសិកម្មជាតិ ..... ១៦៥
៣.៦.១.យុទ្ធសាស្រ្ត និងគោលនយោបាយជាតិ និង គោលបំណងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងវិស័យកសិកម្ម ..... ១៦៥
៣.៦.២. ទស្សនវិស័យ និងបេសកកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១៦៩

៣.៦.៣. សមាសភាគនៃប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិ ...................................... ១៧០
៣.៦.៤. ទស្សនវិស័យ និង គោលបំណងនៃប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិ............ ១៧២
៣.៦.៥. បញ្ហាប្រឈមមុខរបស់ប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិក្នុងពេល ១០ ឆ្នាំខាងមុខ១៧៣
៣.៦.៦.អនុវិស័យកសិកម្ម និង កម្មវិធីរបស់ប្រពន្ធ័ស្រាវជ្រាវកសិកម្មជាតិ ........... ១៧៦
៣.៦.៧. សហប្រតិបត្តិការរវាងអង្គភាពស្រាវជ្រាវកម្ពុជា.....................................១៨៤
៣.៦.៨. ទំនាក់ទំនងរវាងវិទ្យាស្ថានស្រាវជ្រាវ សេវាកម្មផ្សព្វផ្សាយ និង កសិករ......១៨៥
៣.៦.៩. លទ្ធភាពថវិកា ធនធានមនុស្ស មធ្យោបាយស្រាវជ្រាវ សំភារៈនិងបណ្តេញពត៌មានសំរាប់វិទ្យាស្ថានស្រាវជ្រាវធនធានមនុស្សៈ.............................................. ១៨៧
៣.៦.១០.បទពិសោធន៍នៃប្រទេសជទៃនៅអាស៊ីក្នុងការពង្រឹងការស្រាវជ្រាវកសិកម្មជាតិ១៩២

## មេរៀនទី៤
## តួនាទីកសិកម្មក្នុងការអភិវឌ្ឍន៍ខឿនសេដ្ឋកិច្ចជាតិ

៤.១.ការអភិវឌ្ឍន៍៖ អត្ថន័យ និងការវាស់វែង.............................................................១៩៦
៤.១.១.ទស្សនៈឈានទៅមុខនៃការចូលរួមនៅជនបទ ..................................... ១៩៧
៤.១.២.វិភាគគោលនយោបាយកសិកម្ម ........................................................ ១៩៧
៤.១.៣.គ្រោះថ្នាក់នៃការផ្លាស់ប្តូរតម្លៃនៅក្នុងទីផ្សារ ...........................................១៩៨
៤.២ អត្ថន័យនៃការអភិវឌ្ឍន៍.................................................................................. ២០០
៤.៣ អត្ថន័យនៃកំណើនសេដ្ឋកិច្ច............................................................................ ២០០
៤.៤ បម្រែបម្រួលតម្រូវការអតិថិជន និងកំណើនប្រាក់ចំណូល ................................ ២០១
៤.៤.១.ប្រាក់ចំណូលប្រជាជនក្នុងម្នាក់ ............................................................ ២០១
៤.៤.២. ការកើនឡើងយ៉ាងលឿននៃចំនួនប្រជាជនសរុប................................ ២០២

## មេរៀនទី៥
## យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍កសិកម្មៈ ដំណើរការ និងរចនាសម្ព័ន្ធ

៥.១. តួនាទីនៃយុទ្ធសាស្រ្តកសិកម្ម ......................................................................... ២០៤
៥.១.១ យុទ្ធសាស្រ្តជាចក្ខុវិស័យនិងឯកសារឯកភាពគ្នា ..................................... ២០៤
៥.១.២ កញ្ចប់ដែលមានតុល្យភាពនៃកំណែទម្រង់............................................ ២០៥
៥.១.៣ តួនាទីអប់រំនៃយុទ្ធសាស្រ្ត ................................................................... ២០៦
៥.២ ដំណើរការការចូលរួមសម្រាប់យុទ្ធសាស្រ្តនៃការអនុវត្តន៍................................... ២០៨
៥.៣ ការអភិវឌ្ឍន៍ជនបទ និងការកាត់បន្ថយភាពក្រីក្រ ............................................ ២០៩
៥.៤.ការលើកស្ទួយវិស័យកសិកម្ម........................................................................... ២១១

## មេរៀនទី៦
## គោលនយោបាយអភិវឌ្ឍន៍ជនបទ

៦.១.ទំហំនៃគោលនយោបាយអភិវឌ្ឍន៍ជនបទ ....................................................២២៣
៦.២ សន្និទានភាពនៃបទអន្តរាគមន៍របស់រដ្ឋាភិបាល..............................................២២៣
៦.៣ ស្ថានភាពនៅទីជនបទ.......................................................................... ២២៤
៦.៣.១បញ្ហាក្នុងការអភិវឌ្ឍន៏នៅជនបទ.................................................... ២២៤
៦.៣.២.បណ្តុំនៃអត្រាប្រជាជននៅជនបទមានលក្ខណៈមិនរៀបរយ ................. ២២៤
៦.៣.៣.សេដ្ឋកិច្ចមិនឃ្លាតឆ្ងាយទេ............................................................ ២២៥
៦.៣.៤.ភាពស្មើគ្នានៃមធ្យោបាយសេវាកម្មសាធារណៈ .................................. ២២៥
៦.៣.៥.ការកំណត់គោលដៅកម្មវិធីនៅជនបទ.............................................. ២២៦
៦.៣.៦.សុវត្ថិភាពចំពោះប្រជាជន និងទីកន្លែងសម្រាប់ការរស់នៅ .................... ២២៦
៦.៣.៧.គុណសម្បត្តិក្នុងការបំពេញប្រាក់ក្នុងពាណិជ្ជកម្ម................................ ២២៦
៦.៣.៨.ការទប់ទល់ក្នុងការបង្កើតហេដ្ឋារចនាសម្ព័ន្ធសង្គម ...............................២២៧
៦.៤ កសិដ្ឋាន/ជនបទ.....................................................................................២២៧
៦.៥ រឿងរ៉ាវអភិវឌ្ឍន៍ជនបទ ........................................................................ ២២៨
៦.៦ ការកំណត់និយមន័យនៃការអភិវឌ្ឍន៍ជនបទ ............................................. ២២៩
៦.៧ ជម្រើសនៃគោលនយោបាយអភិវឌ្ឍន៍ជនបទ ............................................. ២២៩
៦.៧.១.ការអប់រំ ...........................................................................................២៣០
៦.៧.២.សាលាហិរញ្ញវត្ថុប្រពៃណី.....................................................................២៣០
៦.៧.៣.សុខភាពជនបទ...................................................................................២៣១
៦.៨. ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត........................................២៣៤
៦.៩.ការអភិវឌ្ឍផ្នែកឯកជននិងការបង្កើតការងារ...............................................២៣៩
៦.១០.ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស .................................. ២៤៥
៦.១១.សកម្មភាពនិងយុទ្ធសាស្ត្រ .................................................................... ២៥០

**មេរៀនទី៧**

**ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យកសិកម្ម**

៧.១.ការយល់ដឹងពីការលើកទឹកចិត្ត ................................................................ ២៥៥
៧.១.១.សញ្ញាណទូទៅ................................................................................. ២៥៥
៧.១.២.ទ្រឹស្តីទូទៅបួននៃការជំរុញទឹកចិត្ត ( Fell-Know Theoriesof motivation )២៥៦
៧.២.ការសិក្សាពីបុគ្គលិកធ្វើការក្នុងអង្គភាព .......................................................២៥៧
៧.៣.ការទទួលស្គាល់បុគ្គលិកក្នុងអង្គភាព............................................................ ២៥៩
៧.៤.ការបង្កើនសមត្ថភាពជំនាញ.......................................................................២៦៧
៧.៤.១.ការបង្កើនសមត្ថភាពជំនាញ..................................................................២៦៧
៧.៥.ការបង្កើតជំនឿចំពោះអង្គភាព...................................................................២៧៣

៧.៥.១.ការទទួលស្គាល់,............................................................................ ២៧៥
៧.៥.២.ការដឹងគុណ........................................................................................ ២៧៥
៧.៥.៣. ការយល់ព្រម ....................................................................................... ២៧៥
៧.៥.៤.ការកោតសរសើរ,................................................................................... ២៧៦
៧.៥.៥.ការយកចិត្តទុកដាក់ ................................................................................ ២៧៦
៧.៦.វិធីសាស្ត្រ និងនីតិក្នុងការរៀបចំបុគ្គលិកតាមលក្ខណៈវិទ្យាសាស្ត្រ ........................ ២៧៨
៧.៦.១.និងនំ និងមិនភ័យខ្លាច ........................................................................... ២៧៨
៧.៦.២.ធ្វើខ្លួនជាមេដឹកនាំដែលមន្ត្រីគោរព និងជឿទុកចិត្ត,.......................................... ២៧៨
៧.៦.៣.ការបង្កើត និងបង្កើនអំណាច,..................................................................... ២៧៩
៧.៦.៤.ប្រសិទ្ធភាពបែងចែកទិសដៅការងារ ............................................................ ២៧៩
៧.៦.៥.បន្ថយអំណួត មោទនភាព និងបក្សពួក .......................................................... ២៨០
៧.៦.៥.តាំងចិត្តបង្កើនការទទួលខុសត្រូវ................................................................. ២៨១
៧.៦.៦.ឆ្លើយតបសេចក្តីត្រូវការរបស់មន្ត្រី,............................................................. ២៨១
៧.៦.៧.ផ្តល់ឱកាសមន្ត្រីទទួលបានព័ត៌មាន.............................................................. ២៨២
៧.៦.៨.ការប្រគល់សិទ្ធិ និងអំណាច,...................................................................... ២៨២
៧.៦.៧.បង្កើត និងការពារកេរ្តិ៍ឈ្មោះផ្ទាល់ខ្លួន.......................................................... ២៨៣
៧.៦.១០.បង្កើនកម្លាំង និងអភិវឌ្ឍន៍ថាមពលដើម្បីការងារ,............................................ ២៨៤

## មេរៀនទី៨
## ផែនការធនធានមនុស្សក្នុងវិស័យកសិកម្ម

៨.១ សារៈសំខាន់នៃផែនការធនធានមនុស្ស..................................................................... ២៨៥
៨.២.ដំហាននៃដំណើរការផែនការធនធានមនុស្ស............................................................... ២៨៧
៨.២.១ វិភាគបរិដ្ឋានខាងក្រៅ និងស្ថានភាពក្នុងអង្គភាព.................................................. ២៨៧
៨.២.២ ព្យាករណ៏តម្រូវការបុគ្គលិក ........................................................................ ២៨៨
៨.២.៣.វិភាគពីការផ្គត់ផ្គង់កម្លាំងពលកម្មក្នុងអង្គភាព ..................................................... ២៩០
៨.២.៤.ផែនការបំណោះស្រាយ................................................................................ ២៩១

## មេរៀនទី៩
## ការវិភាគការងារលើវិស័យកសិកម្ម

៩.១.គម្រោងអង្គការចាត់តាំង .......................................................................................... ២៩៥
៩.២.ទំនាក់ទំនងយុទ្ធសាស្ត្រអង្គការចាត់តាំងទៅនឹងផែនការធនធានមនុស្ស................................. ២៩៦
៩.២.១.ផ្សារភ្ជាប់ផែនការយុទ្ធសាស្ត្រទៅផែនការធនធានមនុស្ស ......................................... ២៩៧
៩.៣ ការកំណត់តម្រូវការពលកម្ម.................................................................................... ២៩៨

៩.៤ ការព្យាករណ៍ពលកម្មនាពេលអនាគត ........................................ ២៩៨
៩.៥ ការវិភាគការងារ ........................................ ២៩៩
៩.៥.១. អ្វីទៅជាការវិភាគការងារ ? ........................................ ២៩៩
៩.៥.២. អត្ថប្រយោជន៍ និងគុណវិបត្តិនៃការវិភាគការងារ ........................................ ៣០០
៩.៥.៣. ការប្រើប្រាស់លទ្ធផលនៃការវិភាគការងារ ........................................ ៣០៣
៩.៥.៤.របៀបក្នុងការប្រមូលព័ត៌មាននិងវិភាគការងារ (Job analysis Methods) ៣០៤
៩.៥.៥.សេចក្តីពណ៌នាពីការងារ និងសំណូមពរការងារ (Job Description and Specification) ........................................ ៣០៦
៩.៦. ការតាក់តែងការងារ (Job Design) ........................................ ៣០៧
៩.៦.១. ចក្ខុវិស័យរបស់អ្នកគ្រប់គ្រង ........................................ ៣០៨
៩.៦.២. ឥរិយាបថ និងសក្តានុពលនិយោជិត ........................................ ៣០៨
៩.៦.៣. បច្ចេកវិជ្ជា ........................................ ៣០៨
៩.៦.៤. កត្តាច្បាប់ និយ័តកម្មផ្សេងៗ ........................................ ៣០៨
៩.៦.៥. កត្តាសហជីព ........................................ ៣០៩
៩.៦.៦. សេដ្ឋកិច្ច ........................................ ៣០៩
៩.៦.៧. វិធីក្នុងការតាក់តែងការងារ (Approaches to Job Design) ........................................ ៣០៩

**មេរៀនទី១០**

**គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយអភិវឌ្ឍន៍កសិកម្ម**

១០.១ គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងកសិកម្ម ........................................ ៣១៣
១០.១.១ ការពិពណ៌នាពីម៉ាក្រូសេដ្ឋកិច្ច ........................................ ៣១៤
១០.១.២ គោលនយោបាយសារពើពន្ធ និងគោលនយោបាយរូបីយវត្ថុ ........................................ ៣១៦
១០.១.៣ គោលនយោបាយម៉ាក្រូថ្លៃ និងកសិកម្ម ........................................ ៣១៨
១០.១.៤ អត្រាប្តូរប្រាក់ ........................................ ៣១៩
១០.១.៥ អត្រាការប្រាក់ ........................................ ៣២០
១០.១.៦ អត្រាប្រាក់ឈ្នួល ........................................ ៣២២
១០.១.៧ ថ្លៃផលិតផលកសិកម្ម និងដីថ្លី ........................................ ៣២៣
១០.២.ហេតុអ្វីបានជារដ្ឋាភិបាលត្រូវតែជានាំឲ្យមានស្ថេរភាពនយោបាយម៉ាក្រូសេដ្ឋកិច្ច?៣២៣
១០.៣.ចំណាយចម្លងការ និងសកម្មភាពប្រមូល ........................................ ៣២៤
១០.៤.ទំនាក់ទំនងនៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចក្នុងពិភពលោក? ........................................ ៣២៥
១០.៤.១.ការផ្លាស់ប្តូរការប្រៀបធៀបជាអន្តរជាតិ និង គុណសម្បត្តិប្រៀបធៀប .... ៣២៦
១០.៤.២.បញ្ហាបំណុលផ្តេរ, ការគ្មានផល និង សក្តានុពលនៃដំណោះស្រាយ : .... ៣២៧
១០.៤.៣.ប្រសិទ្ធភាពនៃកម្មវិធីកែប្រែរចនាសម្ព័ន្ធក្រីក្រ ........................................ ៣៣៧

១០.៥ ការកែទម្រង់គោលនយោបាយ..........................................................................៣៣៨

**មេរៀនទី១១**
**តួនាទីម៉ាឃីតធីងក្នុងវិស័យកសិកម្ម**

១១.១.បេសកកម្មម៉ាឃីតធីង.......................................................................... ៣៤១
១១.២ ការវាយតម្លៃប្រព័ន្ធម៉ាឃីតធីង.......................................................................... ៣៤១
១១.២.១.តម្រូវការជាមុនសម្រាប់ប្រព័ន្ធសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាព.......... ៣៤១
១១.២.២.លក្ខណៈវិនិច្ឆ័យដែលប្រើដើម្បីវាយតម្លៃការអនុវត្ត ...........................៣៤៣
១១.២.៣.គំរូរចនាសម្ពន្ធ័-ឥរិយាបថ ..........................................................៣៤៣
១១.៣.ដំណោះស្រាយជម្លោះនៃម៉ាឃីតធីងៈតម្រូវការអតិថិជន និងអ្នកផ្គត់ផ្គង់........... ៣៤៥
១១.៣.១.ដំណោះស្រាយតាមរយៈក្រុមហ៊ុន និង ការប្រកួតប្រជែង (Organization and competitive Issues) .......................................................................... ៣៤៦
១១.៣.២.ដំណោះស្រាយតាមរយៈសម្របសម្រួល និង ត្រួតពិនិត្យ (Coordination and Control Issues).......................................................................... ៣៤៦
១១.៣.៣.បញ្ហាទីផ្សារកសិករ (Farmer Marketing Problems) ................... ៣៤៦
១១.៣.៤.ដំណោះស្រាយអតិថិជន (Consumer Issues)............................៣៤៧
១១.៤ តួនាទីម៉ាឃីតធីងក្នុងវិស័យសេដ្ឋកិច្ច..........................................................៣៤៧
១១.៤.១.ឧបសគ្គទាំង ៥ ចំពោះការបំពេញភាពពេញចិត្តរបស់អ្នកប្រើប្រាស់.......៣៤៧
១១.៤.២.មុខងារ ទាំង ៩ នៃម៉ាឃីតធីង.......................................................... ៣៤៨
១១.៤.៣. ផលប្រយោជន៍ទាំង ៤ នៃម៉ាឃីតធីង.......................................... ៣៤៩
១១.៥ ម៉ាឃីតធីងស្រាវជ្រាវ .......................................................................... ៣៥០
១១.៥.១. ការស្រាវជ្រាវម៉ាឃីធីង.......................................................... ៣៥០
១១.៥.២. ការកាត់ចំណែកទីផ្សារ និងកំណត់ទីផ្សារគោលដៅ.......................... ៣៥៤
១១.៥.៣.វិធីសាស្ត្របែបវិទ្យាសាស្ត្រឬ ៥ ជំហាននៃការនៃការស្រាវជ្រាវ marketing៣៦២
១១.៥.៤.ការវិភាគចំណែកទីផ្សារដោយប្រើវិធីវិភាគតាមតារាងខ្វែង(Analysing market segment using Cross Tabulations) ................................................... ៣៧៣
១១.៥.៥. តួនាទីសំខាន់នៃការស្រាវជ្រាវទីផ្សារកសិកម្ម ..................................៣៧៥
១១.៥.៦.ការរក្សាស្ថានភាពនៅលើទីផ្សារ (Market positioning)...................៣៧៦

**បណ្ណាល័យសាស្ត្រ**(Bibliography)

# បញ្ជីទិចិត្ររូប

## ក្រាភិច

ក្រាភិច ៤.១ ........................................................................................................២០៤
ក្រាភិច ៤.២ ........................................................................................................២០៥
ក្រាភិច ៩.១. គ្រប់គ្រងអង្គភាព ......................................................................................២៧៧
ក្រាភិច ៩.២ ដំណើរការធ្វើផែនការធនធានមនុស្ស ...............................................................២៨០
ក្រាភិច៩.៣ ការវិភាគការងារ .........................................................................................២៨២
ក្រាភិច៩.៤ តួនាទីការវិភាគការងារ ..................................................................................២៨៤
ក្រាភិច ៩.៥. ការជ្រើសរើសបុគ្គលិក..................................................................................២៨៥
ក្រាភិច៩.៦.ទំនាក់ទំនងនិងលទ្ធផលនៃការតាក់តែងការងារ .......................................................២៩០
ក្រាភិច ១០.១.ការពិពណ៌នាបីរបៀបនៃម៉ាក្រូសេដ្ឋកិច្ច ...........................................................២៩៧
ក្រាភិ១០.២. ទំនាក់ទំនងរវាងគោលនយោបាយម៉ាក្រូពិភពលោក............................................. ៣០៣
ក្រាភិច១១.១៖ ការបង្កើតប្រយោជន៍ (The Creation of Utility) ..........................................៣៣៣
ក្រាភិច១១.២.ការកាត់ចំណែកទីផ្សារ ............................................................................. ៣៣៩
ក្រាភិច១១.៣.ដំណើរការការកាត់ចំណែកទីផ្សារ .....................................................................៣៤១
ក្រាភិច ១១.៤.កត្តាសំខាន់ៗនៃការកាត់ចំណែកទីផ្សារ ៣៤៣

## តារាង

តារាង២.១៖. បរិមាណតម្រូវការចំពោះផលិតផលមួយ និងថ្លៃផ្សេងៗគ្នា..........................៤០
តារាង២.២៖តម្រូវការសាច់គោ(Demand Schedule for Beef).................................៤១
តារាង៤.១.ការរបស់ប្រជាជនរបស់ប្រទេសមួយចំនួន..............................................២០៨
តារាង៤.២.កំណើននៃចំនួន ប្រជាជនសរុបរបស់ប្រទេសមួយចំនួនពីឆ្នាំ 1980ដល់ឆ្នាំ1997២០៩
តារាង ៥.១ គោលដៅក្នុងវិស័យកសិកម្មឆ្នាំ ២០១០ ...........................................២១៩
តារាង៥.២. ចំណុចគោលដៅឆ្នាំ២០១០ សម្រាប់ការអភិវឌ្ឍជនបទ ..........................២២៦
តារាង ១០.១.សន្ទស្សន៍ថ្លៃបំណុលខាងក្រៅចំពោះប្រទេសកំពុងអភិវឌ្ឍន៍.................. ៣១៣
តារាង ១១.១ ការជ្រើសរើសទីផ្សារគោលដៅសម្រាប់ភោជនីយដ្ឋានភ្នំពេញ .................៣៤៥
តារាងទី១១.២ សំណួរស្រាវជ្រាវ.......................................................................៣៥៥
តារាង ១១.៣៖គម្រូវិភាគតារាងខ្វែងទាំងពីរបែបអំពីទំនាក់ទំនងរវាងអាយុនៃអ្នកដឹកនាំគ្រួសារ និង ការផ្គត់ផ្គង់ម្ហូបអាហារពីភោជនីយដ្ឋានភ្នំពេញ ៣៥៩

## រូបភាព

រូបភាព២.១៖ ធនធានខ្សត់កម្រក្នុងការបំពេញសេចក្ដីពេញចិត្តរវាងចំណង់ឥតព្រំដែនរបស់មនុស្ស និង ផលិតកម្ម(The Scarce Resources Attempt to Satisfy Unlimited Wanted via Production) ............................................ ៣៣
រូបភាព២.២៖ មូលដ្ឋានគ្រឹះទាំងបី (The Three Basic Questions) ........................... ៣៧
រូបភាព២.៣៖ ខ្សែកោងតម្រូវការសាច់គោ (Demand Curve for Beef) ....................... ៤៣
រូបភាព២.៤៖ ខ្សែកោងតម្រូវការ Pizza (Demand Curve for Pizza) ......................... ៤៤
រូបភាព២.៥៖ តារាងតម្រូវការកប្បាស និងខ្សែកោងតម្រូវការកប្បាស ............................. ៤៥

# មេរៀនទី ១
# ប្រវត្តិនៃការអភិវឌ្ឍន៍គោលនយោបាយវិស័យកសិកម្ម
( The Background of Agricultural Policy )

ក្រោយពីបានបញ្ចប់ជំពូកនេះ លោកអ្នកនឹងយល់ដឹងពី៖
- ទំហំគោលនយោបាយកសិកម្ម និងអន្តរាគមន៍នានា
- បញ្ហាប្រឈមចម្បងៗនៃគោលនយោបាយកសិកម្ម
- គោលបំណងនៃគោលនយោបាយកសិកម្ម
- ប្រភេទសំខាន់ៗនៃគោលនយោបាយកសិកម្ម
- កំណើនសេដ្ឋកិច្ច និងដំណើការបម្លែងលើវិស័យកសិកម្ម
- វដ្តក្រីក្រក្នុងវិស័យកសិកម្ម

## ១.១.សេចក្តីផ្តើម
សេដ្ឋកិច្ចទីផ្សារសេរី និងសេដ្ឋកិច្ចទីផ្សារផែនការ យកលំនាំតាមអ្នកសេដ្ឋវិទូជនជាតិអាមេរិក ជាអ្នកវិភាគបញ្ហាសេដ្ឋកិច្ចទូទៅជាច្រើន។ យើងអាចនិយាយបានថា មានបញ្ហាលើវិស័យកសិកម្មជាមូលដ្ឋានចំនួន ៣ ជាសំខាន់ ដែលជារឿងស្មុគស្មាញ ធ្វើការពិភាក្សាដូចនៅជំពូកខាងក្រោម ៖

១.តើគេគួរតែផលិតផលិតផលកសិកម្មអ្វី ហើយផលិតវាចំនួនប៉ុន្មាន? (The produce mix)

២.តើផលិតកម្មប្រើវិធីអ្វីខ្លះក្នុងការផលិត? តើគេគួរតែប្រើនិងជួលអ្វីខ្លះ? ឧទាហរណ៍៖ កសិដ្ឋានតូចឬធំ? ដាំដុះជាប្រពលវប្បកម្មឬអត់? ប្រើកម្លាំងអូសទាញប្រភេទណា? (Resources combination)

៣.តើចំណូលជាតិត្រូវបែងចែកទៅតាមវិស័យទាំងនោះក្នុងអាជីពអ្វីខ្លះ?

(Income distribution)

បញ្ហាទាំង ៣ នេះ ជាបញ្ហារួមនៃគ្រប់ប្រព័ន្ធសេដ្ឋកិច្ចទាំងអស់ ប៉ុន្តែវាបានផ្តល់នូវចម្លើយខុសៗគ្នាក្នុងប្រព័ន្ធសេដ្ឋកិច្ចនីមួយៗ។ ទំនៀមទម្លាប់ប្រពៃណីរបស់សង្គមមួយគឺជានិច្ចកាលគេតែងតែសួរសំណួរឬជាមូលដ្ឋានបីគឺតើត្រូវផលិតអ្វី? ផលិតយ៉ាងម៉េច? និងផលិតដើម្បីនរណា?

ប្រព័ន្ធសេដ្ឋកិច្ច គឺជាវិធីដែលសង្គមមួយប្រើធនធានកម្រដើម្បីបំពេញ ចំណង់គ្មានព្រំដែនរបស់មនុស្ស វាជាយន្តការសម្រាប់ដោះស្រាយបញ្ហា រវាងភាពកម្រនៃធនធាន និង ការជ្រើសរើស។ គេអាចសម្គាល់ប្រព័ន្ធសេដ្ឋកិច្ចដោយផ្អែកលើលក្ខណៈវិនិច្ឆ័យសំខាន់ពីរ:

- កម្មសិទ្ធិលើធនធានសេដ្ឋកិច្ច ឬលើកត្តាផលិតកម្ម
- យន្តនិងការគ្រប់គ្រង និងសម្របសម្រួលសកម្មភាពសេដ្ឋកិច្ច

តាមរយៈកត្តាទាំងពីរខាងលើគេអាចកំណត់បានប្រព័ន្ធសេដ្ឋកិច្ចផ្សេងៗគ្នា។ មានគំរូប្រព័ន្ធសេដ្ឋកិច្ចជាមូលដ្ឋានបួនគឺ៖ ប្រព័ន្ធសេដ្ឋកិច្ចបុរាណ ឬប្រពៃណី(Traditional Economic system)

ប្រព័ន្ធសេដ្ឋកិច្ចបញ្ជា ឬសេដ្ឋកិច្ចផែនការ(Command Economy or Planned Economy System) ប្រព័ន្ធសេដ្ឋកិច្ចចម្រុះ(Mixed Economy System) និងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី(Free Market Economy System)។

### ១.១.១.ប្រព័ន្ធសេដ្ឋកិច្ចបុរាណ (Traditional System)

សេដ្ឋកិច្ចប្រពៃណី គឺជាប្រព័ន្ធសេដ្ឋកិច្ចមួយដែលគ្រួសារ, កុលសម្ព័ន្ធ ធ្វើការសម្រេចចិត្តលើមូលដ្ឋាននៃទម្លាប់ និង ជំនឿ ដែលបានប្រកាន់យកពីជំនាន់ មួយទៅជំនាន់មួយ។ គោលដៅមួយរបស់សង្គមនេះ គឺ មានជីវិតរស់នៅ។ មនុស្សម្នាក់ៗមានការកំណត់តួនាទីសម្រាប់ការងារ រៀងៗខ្លួន។ មនុស្សប្រុស ជានិច្ចជាកាល ជាអ្នកប្រមាញ់ និង ឃ្វាលសត្វ។ មនុស្សស្រីថែទាំដំណាំ និង ចិញ្ចឹមកូន។ ក្មេងៗ ជួយការងារផ្ទះប្រចាំថ្ងៃ នៅពេលដែលពួកគេកំពុងហាត់រៀន ជំនាញដែលគេត្រូវការសម្រាប់តួនាទីយុវវ័យរបស់គេ។ គ្មានអ្វីដែលធ្វើឲ្យពួក គេងាកចេញពីទម្រង់នេះទេ។

#### ក.លក្ខណរបស់សេដ្ឋកិច្ចប្រពៃណី

នៅសម័យមុន គ្រប់សង្គមទាំងអស់សុទ្ធតែឆ្លងកាត់ សេដ្ឋកិច្ចប្រពៃណី។ ប្រព័ន្ធនេះបម្រើបានល្អនូវ គោលដៅសំខានរបស់សង្គមប្រពៃណីគឺការរស់រាន មានជីវិត។ ទោះបីជាដូច្នោះក៏ដោយ ប្រព័ន្ធសេដ្ឋកិច្ចប្រពៃណីមាននិន្នាការ គ្មានប្រសិទ្ធភាព និង មិនសម្របខ្លួនទៅតាមការផ្លាស់ប្តូរទេ។

#### ខ គុណសម្បត្តិ និងគុណវិបត្តិ

គុណសម្បត្តិធំមួយរបស់សេដ្ឋកិច្ចប្រពៃណីគឺវាជាប្រព័ន្ធដែលផ្តល់ចម្លើយច្បាស់លាស់ទៅនិងសំណួរសេដ្ឋកិច្ចទាំង៣ខាងលើ។ សង្គមប្រពៃណីផលិតនូវអ្វីដែលធានាបានយ៉ាងប្រសើរបំផុតសំរាប់ការរស់នៅរបស់គេ។ វិធីសាស្ត្រផលិតមានលក្ខណៈដដែលៗដូចអ្វីដែលគេធ្លាប់បានធ្វើពីមុន។ ប្រព័ន្ធនៃកាចែកចាយ ក៏ត្រូវបានកំណត់តាមទំលាប់ និង ប្រពៃណី។

សេដ្ឋកិច្ចប្រពៃណីក៏មានគុណវិបត្តិចំបងៗជាច្រើនដែរ។ ដោយសារតែប្រព័ន្ធនេះផ្អែកទៅលើទំនៀមទម្លាប់ នោះសេដ្ឋកិច្ចប្រពៃណីមានភាពមានៈទៅលើកាផ្លាស់ប្តូរ។ . ដូច្នេះប្រព័ន្ធនេះមិនសូវមានភាពសកម្មក្នុងការសំរបទៅតាមស្ថានភាពថ្មីទេ។ . ជាងនេះទៀត គេមានទំលាប់លុបបំបាត់នូវកាប៉ះទង្គិចផ្សេងៗតាមរយៈរាំងពលរដ្ឋពីការធ្វើអ្វីមួយដែលគេចង់ធ្វើឬពេញចិត្តនឹងធ្វើបំផុត។ បុគ្គលណាដែលធ្វើការងារ "ខុស" ជំនាញ វានឹងផ្តល់ផលអោយទាប។ ផលិតភាពទាបនៅក្នុងសេដ្ឋកិច្ចប្រពៃណីមានន័យថាពលរដ្ឋមិនបាន ទទួលទ្រព្យសំភារៈដូចពលរដ្ឋក្នុងសង្គមដទៃបានទទួលទេ។ . ដោយហេតុនេះ ពលរដ្ឋក្នុងសេដ្ឋកិច្ចប្រពៃណីមានកំរិតជីវភាពទាបខ្លាំង។

#### គ.ក្រោមសំពាធនៃការផ្លាស់ប្តូរ

នៅជុំវិញពិភពលោក សេដ្ឋកិច្ចប្រពៃណីស្ថិតនោក្រោមសំពាធពីកំលាំងនៃការផ្លាស់ប្តូរ។ ឧទាហរណ៍ ប្រជាជនតំបន់ Kavango នៃប្រទេសណាមីប៊ី ដែលស្ថិតនៅក្នុងទ្វីបអាហ្វ្រិកខាងត្បូង

មានជីវភាពរស់នៅជាកសិករដែលរកបានសម្រាប់តែចិញ្ចឹមជីវិត អស់រយៈពេលជាយូរយារណាស់មកហើយ។ (ជីវិតជាកសិករដែលរកបានសំរាប់តែចិញ្ចឹមជីវិត គឺមានន័យថាកាដាំដុះរបស់គេទទួលបានផលគ្រប់គ្រាន់ដើម្បីចិញ្ចឹមគ្រួសារតែប៉ុណ្ណោះ) ។ ទោះបីជាយ៉ាងនោះក៏ដោយ តាមរយៈប្រព័ន្ធគមនាគមន៍ទំនើប បានធ្វើអោយតំបន។ Kavangoឃើញពីរូបភាពដ៏អស្ចារ្យនៃពិភពលោក។ ដោយហេតុនេះ យុវវ័យkavangoជាច្រើនចង់បានអ្វីៗថែមទៀតលើសពីជីភាពរស់នៅជាកសិករដែលរកបានសំរាប់តែចិញ្ចឹមជីវិត។

ប្រជាជនរាប់ពាន់នាក់បានចាកចេញពីស្រុកកំណើតរបស់ខ្លួនទៅទីក្រុង។ វិធីសាស្រ្តបង្កបង្កើនផលតាមរបៀបចាស់ ចាប់ផ្តើមផ្លាស់ប្តូរ។ . ប៉ុន្តែប្រជាជននៅតំបន់ ភាគច្រើននៅតែមានជីវភាពរស់នៅជាកសិករដែលរកបានសំរាប់ចិញ្ចឹមជីវិត។ ទោះជាយ៉ាងណាក៏ដោយ មានប្រជាជនមួយចំនួនបានវិលត្រឡប់ទៅធ្វើកសិកម្មពាណិជ្ជកម្ម. គឺគេបង្កបង្កើនផលមិនមែនសំរាប់តែប្រើប្រាស់ផ្ទាល់ខ្លួនគេទេ. គឺសំរាប់លល់ផងដែរ។

សរុបសេចក្តីមក ប្រព័ន្ធសេដ្ឋកិច្ចបូរាណគឺជាប្រព័ន្ធនីមួយៗដែលការប្រព្រឹត្តពឹងផ្អែកជាមូលដ្ឋានទៅលើប្រពៃណី ទំនៀមទំលាប់ និងទម្លាប់។ កូនប្រុសដើរតាមគន្លងឪពុក និងនារីធ្វើតាមនូវអ្វីដែលម្តាយរបស់គេបានធ្វើ។ វាមានការផ្លាស់ប្តូរតិចតួចនៅក្នុងការផលិតផលិតផលពីមួយឆ្នាំទៅមួយឆ្នាំ។ បច្ចេកទេសក្នុងការផលិតគឺធ្វើតាមប្រពៃណីវៀលែងតែឥទ្ធិពលម្តងម្កាលនៃវត្ថុបង្កើតថ្មី។

## ១.១.២.ប្រព័ន្ធសេដ្ឋកិច្ចបញ្ជា ឬប្រព័ន្ធសេដ្ឋកិច្ចផែនការ

(Command Economy or Planning Economy System)

នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចបញ្ជា ឬប្រព័ន្ធសេដ្ឋកិច្ចផែនការ រដ្ឋជាម្ចាស់កម្មសិទ្ធលើធនធាន ឬកត្តាផលិតកម្មស្ទើរតែទាំងអស់ ហើយយន្តការគ្រប់គ្រង និង សម្របសម្រួលសកម្មភាពក្នុងសេដ្ឋកិច្ច គឺធ្វើទៅតាមផែនការកំណត់របស់រដ្ឋ។ ក្នុងប្រព័ន្ធសេដ្ឋកិច្ចនេះ សហគ្រាសជាកម្មសិទ្ធរបស់រដ្ឋ ហេតុនេះ សកម្មភាពដែលទាក់ទងទៅនិងការផលិត,បែងចែក និង ប្រើប្រាស់ ត្រូវបានគ្រប់គ្រង និងអនុវត្តទៅតាមផែនការដែលបានកំណត់របស់រដ្ឋ។ មានន័យថា ក្នុងផែនការដេលមានការចាត់ចែង និង ត្រួតពិនិត្យដោយរដ្ឋ បានកំណត់រួចជាស្រេចថាតើត្រូវផលិតអ្វី?ផលិតយ៉ាងដូចម្តេច?និងផលិតសម្រាប់អ្នកណា? នៅក្នុងសេដ្ឋកិច្ចបញ្ជា មន្រ្តីរដ្ឋាភិបាលពិនិត្យទៅលើធនធាន និងសេចក្តីត្រូវការរបស់ប្រទេសជាតិ និង បែងចែកធនធានទាំងនោះទៅតាមការវិនិច្ឆ័យរបស់ខ្លួន។ នៅក្នុងករណីនេះចំណង់របស់អ្នកប្រើប្រាស់ម្នាក់ៗត្រូវ បានគេយកចិត្តទុកដាក់តិចតួច។ រដ្ឋាភិបាលជាទូទៅជាម្ចាស់នៃមធ្យោបាយផលិតកម្ម មានធនធាន និងរោងចក្រ។

ឧទាហរណ៏ ប្រទេសកូរ៉េខាងជើង និងគុយបា សព្វថ្ងៃនេះ កំពុងអនុវត្តន៍ប្រព័ន្ធសេដ្ឋកិច្ចបញ្ជានេះ។ មុនពេលដែលលទ្ធិកុម្មុយនីស្តត្រូវបានដួលរលំនៅក្នុងបណ្តាប្រទេសអ៊ឺរ៉ុបមួយចំនួន ដូចជាសហភាពសូវៀត ប្រទេសប៉ូឡូញ និងប្រទេសអាល្លឺម៉ង់ខាងកើតក៏អនុវត្តប្រព័ន្ធសេដ្ឋកិច្ចបញ្ជានេះដែរ។

### ក.ការត្រួតពិនិត្យរបស់រដ្ឋ

នៅក្នុងសេដ្ឋកិច្ចបញ្ជាអ្នកដឹកនាំសម្រេចចិត្តថាតើត្រូវផលិតអ្វី និងតើត្រូវផលិតវាតាមវិធីណា ពួកគេក៏ជាអ្នកសម្រេចផងដែរថា តើត្រូវផលិតអ្វីដើម្បីអ្នកណា ដែលវាជាផ្នែកមួយទាក់ទងទៅនឹងការកំណត់ថ្លៃឈ្នួល តាមរយៈការកំណត់ថាតើនរណាជាអ្នកណាទទួលបានថ្លៃឈ្នួលខ្ពស់ជាងគេបំផុត? និងអ្នកណាជាអ្នកទទួលបានថ្លៃឈ្នួលទាបជាងគេបំផុត? អ្នកដឹកនាំធ្វើការសម្រេចទៅតាមលទ្ធភាពលុយក្នុងការទិញផលិតផល ប្រព័ន្ធមួយដែលអ្នកដឹកនាំសង្គម ជាទូទៅមានសមាជិករបស់រដ្ឋាភិបាលជាអ្នកសម្រេចចិត្តលើបញ្ហាសេដ្ឋកិច្ចទាំងអស់ ត្រូវបានគេឲ្យឈ្មោះថាជាសេដ្ឋកិច្ចផែនការប្រមូលផ្តុំ (Centrally Planned Economy)។

### ខ.ការធ្វើផែនការរបស់រដ្ឋ

ឧទាហរណ៍យើងគិតថាតើរដ្ឋាភិបាល មានឥទ្ធិពលមកលើអ្នកយ៉ាងណាខ្លះ បើសិនជាអ្នកធ្វើការ នោះអ្នកត្រូវតែបង់ពន្ធ បើសិនជាអ្នកមានអាយុដប់ប្រាំបីឆ្នាំ អ្នកត្រូវតែនៅ ទៅ ចុះឈ្មោះនៅស្ថាប័នរដ្ឋ រដ្ឋាភិបាល បានអនុវត្តបន្ថែម នូវការត្រួតពិនិត្យទៅលើការរស់នៅរបស់អ្នកពីមួយថ្ងៃទៅមួយថ្ងៃ ច្បាប់របស់រដ្ឋបានដាក់កំណត់ទៅលើកម្រិតល្បឿនបើកបរ និងអាយុរបស់អ្នកបើកបរ មានច្បាប់ដែលកំណត់នៅកម្រិតស្អាតស្តង់ដារ នៅក្នុងហាងនិងភោជនីយដ្ឋាននិងសម្រាប់អង្គភាពល្បីៗខ្លះ។ ពន្ធរដ្ឋទាំងនេះត្រូវបានប្រមូលមកដើម្បីជួយទ្រទ្រង់ទៅលើសេវាកម្មរបស់រដ្ឋដូចជានាយកដ្ឋាននគរបាល នាយកដ្ឋានអគ្គិភ័យ និងការសិក្សាសាធារណៈ។ ល។ ទោះបីជាដូច្នោះក៏ដោយ តើរដ្ឋាភិបាលត្រូវធ្វើអ្វីទៀត ឧបមាថាការិយាល័យរដ្ឋាភិបាលមានអំណាចនៅក្នុងការសម្រេចថាតើអាជីវកម្មណាមួយដែលអាចដំណើរការនៅក្នុងទីក្រុង បន្ថែមលើសនេះទៀត ការិយាល័យរដ្ឋមិនគ្រាន់តែសម្រេចចិត្តថាតើអាជីវកម្មនីមួយៗត្រូវផលិតអ្វីទេថែមទាំងកំណត់ថាតើផលិតផលប៉ុន្មានដែលពួកគេត្រូវផលិតជារៀងរាល់ខែ ចុងក្រោយពួកគេធ្វើការសម្រេចចិត្តថាតើនរណាអាចទទួលបានការងារ និងកំណត់រយៈពេលធ្វើការនឹងកម្រិតប្រាក់ឈ្នួលសម្រាប់កម្មករទាំងនោះ។ រដ្ឋាភិបាលត្រូវត្រួតពិនិត្យ ទៅតាមរបៀបនេះមានលក្ខណៈជាសេដ្ឋកិច្ចបញ្ជាឬជាសេដ្ឋកិច្ចផែនការប្រមូលផ្តុំ។

### គ.សង្គមនិយម និងកុម្មុយនីស្តនិយម

សង្គមទំនើបដែលបានប្រកាន់យកសេដ្ឋកិច្ចបញ្ជាគឺដោយសារតែការជះឥទ្ធិពលនៃគំនិតរបស់លោក **កាល់ម៉ាក្ស** ដែលជាទស្សនវិទូ ប្រវត្តិវិទូនិងសេដ្ឋវិទូជនជាតិអាល្លឺម៉ង់នៅសតវត្សរ៍ទីដប់ប្រាំបួន យោងទៅតាមការវិភាគ ក្រុមប្រវត្តិសាស្ត្រទាំងអស់សុទ្ធតែមានការតស៊ូរវាងវណ្ណៈ នៅក្នុងជំនាន់របស់គាត់ការតស៊ូកើតមានរវាងម្ចាស់រោងចក្រឧស្សាហកម្ម និងកម្មករដែលធ្វើការដោះដូរពលកម្មដើម្បីថ្លៃឈ្នួល នៅពេលដែលម្ចាស់រោងចក្រឧស្សាហកម្ម កាន់តែមាន លោក កម្មករនៅតែក្រ។ លោកកាល់ម៉ាសទាយថា ដល់ពេលមួយកម្មករ និងផ្តួលរលំប្រព័ន្ធនេះ ហើយធ្វើការផ្លាស់ប្តូររោងចក្រទាំងនេះមកក្នុងដីសាធារណៈវិញ នៅពេលដែលមធ្យោបាយផលិតកម្មត្រូវបានគ្រប់គ្រងកាន់កាប់ដោយរដ្ឋាភិបាល

នោះការតស៊ូវណ្ណៈត្រូវបានដោះស្រាយ ហើយប្រជាពលរដ្ឋទាំងអស់នឹងត្រូវបានបែងចែកទ្រព្យសម្បត្តិគ្នា។

តាមទស្សនវិទ្យារបស់កាល់ម៉ាក្ស លទ្ធិសង្គមនិយម ជាប្រព័ន្ធសេដ្ឋកិច្ចមួយដែលរដ្ឋាភិបាលកាន់កាប់កត្តាផលិតកម្មមួយភាគ ឬក៏ទាំងអស់។ លទ្ធិកុម្មុយនីស្តដែលជាទម្រង់មួយមានកម្រិតខ្ពស់ជាងគេ លទ្ធិសង្គមនិយម គ្មានទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិឯកជនទេ ហើយក្នុងរបបនេះប្រជាពលរដ្ឋត្រូវបានផ្តល់សេរីភាពនយោបាយតែបន្តិចបន្តួចឬគ្មានសោះ។ គំនិតនេះកកើតឡើងពីគំនិតរបស់លោកកាល់ម៉ាក្សដែរ។ ប្រព័ន្ធនៃអំណាចផ្តាច់ការ(Authoritarian )ទាមទារដាច់ខាតនូវការអនុវត្តទៅតាមការកំណត់របស់រដ្ឋអំណាច។

សព្វថ្ងៃគ្មានសេដ្ឋកិច្ចបញ្ជាសុទ្ធទេ។ កម្លាំងដែលនាំឲ្យមានការផ្លាស់ប្តូរសេដ្ឋកិច្ចប្រពៃណី វាក៏ធ្វើឲ្យផ្លាស់ប្តូរសេដ្ឋកិច្ចបញ្ជាដែរ។ ទោះបីជាយ៉ាងណាក៏ដោយប្រទេសមួយចំនួនដូចជាប្រទេសកូរ៉េខាងជើង នៅតែជាសេដ្ឋកិច្ចដែលភាគច្រើនរងឥទ្ធិពលនៃការបញ្ជា។

### ប្រទេសកូរ៉េខាងជើង

បន្ទាប់ពីស្ថិតនៅក្រោមអំណាចត្រួតត្រារបស់ប្រទេសចិន និងក្រោយមកទៀតប្រទេសជប៉ុន ប្រទេសកូរ៉េបានបំបែកខ្លួនជាពីរទៅជាប្រទេសកូរ៉េខាងជើងនិងប្រទេសកូរ៉េខាងត្បូងនៅក្រោយសង្គ្រាមលោកលើកទីពីរ ប្រទេសកូរ៉េខាងជើងបានស្ថិតនៅក្រោមការត្រួតត្រារបស់លទ្ធិកុម្មុយនីស្ត រដ្ឋាភិបាលគ្រប់គ្រងលើរាល់ការសម្រេចចិត្ត ផ្នែកសេដ្ឋកិច្ចទាំងអស់ ឧទាហរណ៍រដ្ឋាភិបាលបានបង្វែររាល់ នៅរាល់ នៅរាល់ នៅរាល់ ធនធានជាច្រើនរបស់ប្រទេសជាតិឲ្យនៅក្រោមអំណាចយោធា គេបង្កើតកងទ័ពជាងមួយលាននាក់ក្នុងចំណោមប្រជាជន២២លាននាក់ រដ្ឋាភិបាលក៏បានបង្កើតនូវកម្មវិធីអាវុធនុយក្លេអ៊ែ។ ទោះបីជាយ៉ាងណាក៏ដោយការបង្កើតកងទ័ពទាំងនោះ ទាំងអស់នោះ ក៏ត្រូវមានការចំណាយលើតម្រូវការចាំបាច់ផងដែរ។ ក្នុងអំឡុង ចុងបណ្តាឆ្នាំ១៩៩០និងដើមបណ្តាឆ្នាំ២០០០ម្ហូបអាហារមានកង្វះខាតដែលបញ្ហានេះបានធ្វើឲ្យប្រជាជនកូរ៉េ រាប់លាននាក់ត្រូវបានស្លាប់ដោយសារភាពអត់ឃ្លាន និងកង្វះជីវជាតិ។ ប្រជាជនកូរ៉េខាងជើងភាគច្រើនអាចរស់រានមានជីវិតបានដោយសារតែជំនួយពីបណ្តាប្រទេសផ្សេងផ្សេង ដែលភាគច្រើនជំនួយពីប្រទេសកូរ៉េខាងត្បូង។

ភាពបរាជ័យនៅក្នុងការផ្គត់ផ្គង់ម្ហូបអាហារនិងផលិតផលចាំបាច់ផ្សេងទៀត គឺជាលទ្ធផលមួយដែលកើតចេញពីគុណវិបត្តិនៃការសេដ្ឋកិច្ចនៃផែនការសេដ្ឋកិច្ច នៅក្នុងបណ្តាឆ្នាំ១៩៩០ប្រទេសកូរ៉េខាងជើងផលិតផល ផលិតផលិតផល កាន់តែតិចទៅៗ ហើយសេដ្ឋកិច្ចរបស់ខ្លួនបានធ្លាក់ចុះយ៉ាងខ្លាំង ទោះបីជាយ៉ាងណាក៏ដោយនៅក្នុងឆ្នាំ២០០៣អ្នកធ្វើផែនការប្រមូលផ្តុំបានបាញ់ឈប់ការដាក់កំហិតទៅលើម្ចាស់កម្មសិទ្ធិឯកជននិងសកម្មភាពទីផ្សារ ប្រទេសកូរ៉េខាងជើងសង្ឃឹមថាតាមរយៈការពិសោធជាមួយនឹងទីផ្សារសេរីនេះ អាចធ្វើឲ្យសេដ្ឋកិច្ចរបស់ប្រទេសខ្លួនមានជីវិតឡើងវិញ។

### ឃ.ផលប៉ះពាល់របស់សេដ្ឋកិច្ចបញ្ជា

នៅក្នុងទ្រឹស្តីសេដ្ឋកិច្ចបញ្ជាផ្តល់នូវអត្ថប្រយោជន៍មួយចំនួន។ ឧទាហរណ៍ពួកគេខិតខំរកវិធីផ្គត់ផ្គង់ដល់មនុស្សឲ្យបានគ្រប់គ្រប់គ្នា បើទោះបីជាអ្នកនោះជាមនុស្សឈឺ ឬមនុស្សចាស់មិនអាចធ្វើការបានក៏ដោយ។ ក្នុងនោះផងដែរអ្នកដឹកនាំនៅក្នុងសេដ្ឋកិច្ចបញ្ជាអាចប្រើប្រាស់ធនធានរបស់ប្រទេសជាតិដើម្បីផលិតផលិតផលដែលគេមិនអាចរកកម្រៃបាននៅលើទីផ្សារឧទាហរណ៍មានដូចជាឱសថជាដើម។

ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្តជាក់ស្តែងសេដ្ឋកិច្ចបញ្ជាក៏នាំមកនូវគុណវិបត្តិមួយចំនួនផងដែរ។

អ្នកធ្វើផែនការតែងតែចាប់ផ្តើមជាមួយនឹងការយល់ដឹងពីលក្ខខណ្ឌ បន្តិចបន្តួចតែប៉ុណ្ណោះ។ ដោយសារតែហេតុផលនេះការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចតែងតែនាំខុសផ្លូវ។ ក្នុងនោះផងដែរកម្មករតែងតែមានការលើកទឹកចិត្តតិចតួចឲ្យមានការបង្កើនផលិតភាព នៅពេលដែលគេដឹងថាពួកគេនឹងទទួលបានការទូទាត់ដូចគ្នាដោយមិនគិតថាអ្នកណាផលិតបានប៉ុន្មាននោះទេ។ បន្ថែមលើនេះទៀតដោយសារតែមិនមានកម្មសិទ្ធិឯកជននោះវាជាហេតុបណ្តាលឲ្យកម្មករគ្មានទឹកចិត្តនិងជំរុញខ្លួនឯង ឲ្យប្រើប្រាស់ធនធានឲ្យបានសមស្របទេ។

សេដ្ឋកិច្ចផែនការប្រមូលផ្តុំ តែងតែកំណត់ថ្លៃទាបជាងថ្លៃដែលបង្កើតដោយប្រព័ន្ធទីផ្សារ។ ជាលទ្ធផល សេដ្ឋកិច្ចបញ្ជាប្រឈមទៅនឹងភាពខ្វះខាត។ ទស្សនីយភាពមួយដែលបង្ហាញក្នុងសេដ្ឋកិច្ចបញ្ជាគឺការឈរតម្រៀប គ្នាយ៉ាងវែងដើម្បីទិញទំនិញ។ កង្វះខាតបែបនេះតែងតែនាំទៅរកឥរិយាបថប្រឌិត។ ឧទាហរណ៍នៅអតីតសហភាពសូវៀតគេមិនអាច ទិញអំពូលភ្លើងយកទៅប្រើប្រាស់នៅផ្ទះបានទេ។ ទោះបីជាដូច្នោះក៏ដោយអំពូលភ្លើងដែលខូចនៅក្នុងរោងចក្រគេអាចធ្វើការផ្លាស់ប្តូរបាន។ ប្រជាជនមួយចំនួនតែងតែយកអំពូលភ្លើងដែលខូចនេះទៅលក់។ មូលហេតុអ្វីបានជាដូច្នោះ? ប្រជាជនមួយចំនួនអាចទិញអំពូលភ្លើងដែលខូចនេះហើយយកវាទៅប្តូរយកអំពូលភ្លើងនៅក្នុងរោងចក្ររួចយកអំពូលរោងចក្រនោះមកបំភ្លឺផ្ទះ។

អាចដោយសារតែភាពបរាជ័យនៃប្រព័ន្ធសេដ្ឋកិច្ចបញ្ជាដ៏តឹងរ៉ឹងនេះ វាបានបណ្តាលឲ្យមានភាពលំបាកនៅក្នុងការរស់នៅរបស់ប្រជាជន។ ការអនុវត្តគោលនយោបាយសេដ្ឋកិច្ចផែនការប្រមូលផ្តុំវាទាមទារឲ្យមានសិទ្ធបុគ្គល ទោះជាស្ថិតនៅក្នុងការរស់រានមានជីវិតក៏ដោយដែលវាជាផ្នែកបន្ទាប់បន្សំមួយចំពោះភាពចាំបាច់របស់រដ្ឋ។ ប្រជាជនរាប់លាននាក់បានស្លាប់បាត់ ក្នុងការប្រឹងប្រែងបង្កើតកសិដ្ឋាន សមូហភាពធំៗ នៅប្រទេសចិននិងសហភាពសូវៀត។ ច្រើនលាននាក់ត្រូវបានឃុំឃាំងដោយសារតែគេអនុវត្តសិទ្ធិនយោបាយនិងសេដ្ឋកិច្ចរបស់ពួកគេ។ ការប៉ាន់ស្មានបានឲ្យដឹងថា គុណវិបត្តិនៃគោលនយោបាយរបស់សេដ្ឋកិច្ចបញ្ជានេះបានបណ្តាលឲ្យមានប្រជាជនស្លាប់ច្រើនជាងសង្គ្រាមលោកលើកទីពីរទៅទៀត។

សរុបសេចក្តីមក ខឿនសេដ្ឋកិច្ចបញ្ជាសុទ្ធ(Pure Command Economy)គឺជាខឿនសេដ្ឋកិច្ចដែលពឹងផ្អែកទាំងស្រុងទៅលើរដ្ឋាភិបាលក្នុងការបែងចែកធនធាន។ ប្រភេទនៃខឿនសេដ្ឋកិច្ចនេះគឺរដ្ឋាភិបាលជាអ្នកសម្រេចលើគ្រប់តំណាក់កាលទាំងអស់នៃការបែងចែកធនធាន។ នៅទីរដ្ឋាភិបាលជា

អ្នកកំណត់ចំពោះបុគ្គលម្នាក់ៗថាតើមុខទំនិញណាដែលត្រូវបាន គេប្រើប្រាស់ ហើយត្រូវផលិតវាប៉ុន្មាន និងកំណត់បរិមាណប្រើប្រាស់សម្រាប់មុខទំនិញនីមួយៗ។ នៅក្នុងប្រព័ន្ធបញ្ជាការប្រព្រឹត្តនៃខឿនសេដ្ឋកិច្ចគឺកំណត់ដោយអាជ្ញាធរកណ្តាល(ជាទូទៅរដ្ឋាភិបាល) ដែលធ្វើការសម្រេចដ៏ចាំបាច់បំផុតទៅលើថាតើត្រូវផលិតអ្វី ផលិតយ៉ាងដូចម្តេច ហើយនៅណាជាអ្នកទទួល។ ខឿនសេដ្ឋកិច្ចដូច្នេះត្រូវបានកំណត់លក្ខណៈប្រមូលផ្តុំការធ្វើសេចក្តីសម្រេចចិត្ត។

### ១.១.៣.ប្រព័ន្ធសេដ្ឋកិច្ចចម្រុះ (Mixed Economy System)

**ប្រព័ន្ធសេដ្ឋកិច្ចចម្រុះ**គឺជាប្រព័ន្ធសេដ្ឋកិច្ចដែលប្រើប្រាស់ទាំងសញ្ញាណទីផ្សារ និងសញ្ញាណមិនមែនទីផ្សារក្នុងការការបែងចែកទំនិញ និងសេវាកម្ម(Mixed economy system: An economy that uses both market and nonmarket signals to allocate goods and services.)។ ខឿនសេដ្ឋកិច្ចចម្រុះគឺជាសេដ្ឋកិច្ចមួយក្នុងចំណោមសេដ្ឋកិច្ចសាធារណៈដែលជះឥទ្ធិពលទៅលើការងារទីផ្សារសេរី។ វាអាចជាការរួមបញ្ចូលគ្នារវាងកម្មសិទ្ធរដ្ឋ និងកម្មសិទ្ធឯកជន(A **mixed economy is one** with some public influence over the workings of free markets. There may also be some public ownership mixed in with private property.)។ ខឿនសេដ្ឋកិច្ចចម្រុះគឺជាសេដ្ឋកិច្ចដែលរដ្ឋាភិបាលសហការគ្នាជាមួយក្រុមហ៊ុនអាជីវកម្មក្នុងការបង្កើតឲ្យបានជាទំនិញនិងសេវា(Mixed Economy: An economy in which governments as well as business firms provide goods and services.)។ ក្នុងខឿនសេដ្ឋកិច្ចចម្រុះរដ្ឋាភិបាលកំណត់ទីផ្សារជាតុចូលនិងទីផ្សារផលិតផលក្នុងការទទួលបាននូវធនធាននិងផលិតផលនានាដែលពួកគេត្រូវការដើម្បីផ្គត់ផ្គង់ទំនិញនិងសេវាកម្ម។ រដ្ឋាភិបាលទទួលបាននូវមូលនិធិដើម្បីធ្វើហិរញ្ញប្បទាននូវប្រតិបត្តការដោយកំណត់ពន្ធពីគ្រួសារនិងក្រុមហ៊ុនអាជីវកម្ម និងសុំខ្ចីលុយពីទីផ្សារឥណទាន(In a mixed economy, governments compete in input markets and product markets to obtain the resources and products they need to supply goods and services. Governments obtain funds to finance their operations by taxing households and business firms and by borrowing in credit markets.)។ រដ្ឋាភិបាលប្រើប្រាស់ចំណូលខ្លះរបស់ខ្លួនដើម្បីផ្តល់ការគាំទ្រចំណូលចំពោះមនុស្សចាស់ជរា អ្នកក្រីក្រ និងក្រុមផ្សេងទៀត អ្នកកើតជម្ងឺ Covid 19 អ្នកកើតជម្ងឺធ្ងន់ផ្សេងៗ និងផ្តល់ជំនួយផងដែរចំពោះក្រុមហ៊ុនអាជីវកម្មនានា(Governments use some their revenues to provide income support to elderly, the poor, Covid virus 19's effective people and other groups and also to subsidize some business firms.)។

ប្រទេសអភិវឌ្ឍន៍ ក៏ដូចជាប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន បានប្រើប្រាស់ខឿនសេដ្ឋកិច្ចចម្រុះដើម្បីដឹកនាំដំណើរការទីផ្សាររបស់ខ្លួនពីព្រោះប្រព័ន្ធមួយនេះ មានវិស័យឯកជនផង និងវិស័យសាធារណៈផង។ ជាង 90% នៃទំនិញនិងសេវាកម្ម ត្រូវបានគេផលិតដោយវិស័យឯកជន ហើយរដ្ឋាភិបាលបានតែងតាំងសមាជិកគណៈកម្មការក្នុងការគ្រប់គ្រងផលិតកម្មទាំងនេះដើម្បីប្រើប្រាស់ដោយខ្លួនឯងផងដែរ។ ថ្វីបើសេដ្ឋកិច្ចទំនើបទាំងអស់ជាសេដ្ឋកិច្ចចម្រុះ ជានិច្ចកាលគេយកចិត្តទុកដាក់ទៅប្រភេទនៃ

ប្រព័ន្ធណាមួយ។ ក្នុងឧទាហរណ៍ខាងលើ តើមួយណាជាមូលដ្ឋានសេដ្ឋកិច្ចអាមេរិក គឺសេដ្ឋកិច្ចទីផ្សារ លុបលើប្រព័ន្ធផ្សេងៗ។ ថ្វីបើវាមានសមាសភាពប្រពៃណី និងសមាសភាពបញ្ជា តែកម្លាំងដឹកនាំរបស់សេដ្ឋកិច្ចអាមេរិកគឺម្ចាស់កម្មសិទ្ធិឯកជន និងទីផ្សារ។ ដូច្នេះ សហរដ្ឋអាមេរិកអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារជាសំខាន់។

ប្រទេសនៅអឺរ៉ុបជាច្រើន មានសេដ្ឋកិច្ចចម្រុះនៃសេដ្ឋកិច្ចទីផ្សារ និងសេដ្ឋកិច្ចបញ្ជា។ ប្រទេសបារាំងបានខិតខំរកផ្លូវកណ្ដាលរវាងសង្គមនិយម និងមូលធននិយម។ ទៅក្រោយសង្គ្រាមលោកលើកទីពីរ សេដ្ឋកិច្ចរបស់គេបានយកចិត្តទុកដាក់ទៅលើប្រព័ន្ធសេដ្ឋកិច្ចបញ្ជា ដែលរដ្ឋាភិបាលធ្វើជាម្ចាស់កម្មសិទ្ធិលើឧស្សាហកម្មសំខាន់ៗ។ ទោះជាដូច្នោះក៏ដោយ នៅបញ្ចាឆ្នាំ១៩៨០ បានបង្ហាញឱ្យឃើញថាប្រជាពលរដ្ឋជាច្រើនមិនទទួលបាននូវការបំពេញជាមួយនឹងការអនុវត្តន៍ឧស្សាហកម្មដែលជាកម្មសិទ្ធិរបស់រដ្ឋទេ។ ដោយហេតុនេះ រដ្ឋាភិបាលរបស់ប្រទេសបារាំងបានផ្ទេរត្រឡប់មកវិញពីតួនាទីជាកម្មសិទ្ធិក្នុងសេដ្ឋកិច្ចធ្វើឯកជនភាវូបនីយកម្ម ហើយឧស្សាហកម្មមួយចំនួន ជាពិសេសមានផ្នែកធនាគារ និងការធានារ៉ាប់រង។ ទោះជាដូច្នោះក៏ដោយ វានៅតែមានចំណែកជាម្ចាស់កម្មសិទ្ធិ គ្រប់គ្រងក្នុងឧស្សាហកម្មមួយចំនួន រួមមាន ផ្នែកថាមពល រថយន្ត ការដឹកជញ្ជូន ទូរគមនាគមន៍ និងវិស័យការពារជាតិ។ បន្ថែមលើនេះ វាផ្ដល់នូវការរៀបចំសេវាសង្គម រួមមាន ការថែទាំសុខភាព និងការអប់រំចំពោះប្រជាពលរដ្ឋបារាំង។

## ១.១.៤.ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ (Free Market Economic System)

ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរីគឺជាប្រព័ន្ធសេដ្ឋកិច្ចដែលធនធានសេដ្ឋកិច្ចឬកត្តាផលិតកម្មមួយភាគធំ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភ្នាក់ងារឯកជននីតិបុគ្គល និងរូបវន្តបុគ្គល។ ចំពោះយន្តការគ្រប់គ្រងនិងសម្របសម្រួលក្នុងសេដ្ឋកិច្ចគឺអាស្រ័យទៅនឹងយន្តការទីផ្សារ។ មានន័យថារាល់ការសម្រេចចិត្តសំខាន់សំខាន់របស់ភ្នាក់ងារឯកជនក្នុងសេដ្ឋកិច្ចដូចជាត្រូវផលិតអ្វី?ផលិតយ៉ាងដូចម្ដេច? នឹងផលិតសម្រាប់អ្នកណា?ត្រូវបានកំណត់តាមរយៈទីផ្សារក្រោមឥទ្ធិពលនៃកម្លាំងពីរគឺកម្លាំងផ្គត់ផ្គង់ និងកម្លាំងតម្រូវការ។ រដ្ឋមានតួនាទីតិចតួចបំផុតក្នុងសេដ្ឋកិច្ច។ ប្រព័ន្ធសេដ្ឋកិច្ចនេះផ្អែកទៅលើការជ្រើសរើសរបស់បុគ្គលមិនមែនតាមរយៈការបង្គាប់របស់រដ្ឋាភិបាលទេ។ តាមន័យម្យ៉ាងទៀតនៅក្នុងប្រព័ន្ធនេះអ្នកប្រើប្រាស់និងអ្នកផលិតជាអ្នកដឹកនាំសេដ្ឋកិច្ច។ អ្នកប្រើប្រាស់មានសិទ្ធិនៅក្នុងការចំណាយលុយរបស់ពួកគេទៅតាម បងពួកគេអាចប្រើប្រាស់លុយរបស់គេធ្វើអាជីវកម្មឬក៏មានសិទ្ធលក់នូវកម្លាំងពលកម្មរបស់ខ្លួនឲ្យទៅនរណាក៏បាន។

អ្នកផលិតធ្វើការ សម្រេចចិត្តថាតើទ្រព្យ ឬសេវាកម្ម អ្វីដែលពួកគេត្រូវផលិតនិងផ្គត់ផ្គង់ឲ្យទៅទីផ្សារ។ ពួកគេធ្វើការសម្រេចចិត្តថាតើពួកគេត្រូវប្រើប្រាស់ធនធានដែលមានកម្រិតរបស់ពួកគេយ៉ាងណា ដើម្បីទទួលបានផលច្រើនបំផុតតាមដែលអាចធ្វើបាន។

ដូច្នេះនៅក្នុងសេដ្ឋកិច្ចទីផ្សារ បុគ្គលគ្រប់រូបធ្វើសកម្មភាពដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនរបស់គេនៅពេលដែលពួកគេធ្វើការជ្រើសរើសសេដ្ឋកិច្ច។ ទោះជាយ៉ាងណាក៏ដោយក្នុងខណៈដែលគេស្វែងរកផលប្រយោជន៍ឲ្យខ្លួនគេនោះគេក៏បង្កើត ផលប្រយោជន៍ឲ្យអ្នកដទៃផងដែរ។ ក្នុងនាមជាអ្នកប្រើ

ប្រាស់គេធ្វើការជ្រើសរើសទិញផលិតផលដែលត្រូវបំផុតទៅនឹងចំណង់របស់គេ ទន្ទឹមនឹងនោះអ្នកផលិតករទទួលបានផលប្រយោជន៍ពីការទិញរបស់អ្នកប្រើប្រាស់ផងដែរ។ លោក Adam Smith បានលើកឡើងក្នុងអត្ថបទរបស់គាត់ The Wealth of Nation(1776) ថានៅពេលដែលអ្នកធ្វើការសម្រេចចិត្តសេដ្ឋកិច្ចអ្នកធ្វើសកម្មភាពដើម្បីទទួលបានផលប្រយោជន៍របស់ខ្លួនផ្ទាល់ប៉ុន្តែអ្នកត្រូវបានដឹកនាំដោយបាតដៃអរូបី ដែលធ្វើឲ្យអ្នកដទៃទទួលបានផលប្រយោជន៍ផងដែរ។

### ក.មូលដ្ឋានគ្រឹះរបស់សេដ្ឋកិច្ចទីផ្សារ

សេដ្ឋកិច្ចទីផ្សារមានលក្ខណៈបែងចែកមួយចំនួន នៅផ្នែកខាងលើយើងបានដឹងខ្លះហើយអំពីលក្ខណៈមូលដ្ឋានរបស់សេដ្ឋកិច្ចទីផ្សារគឺជាសេដ្ឋកិច្ចដែលឥរិយាបថរបស់ពលរដ្ឋត្រូវបានជំរុញដោយផលប្រយោជន៍ផ្ទាល់ខ្លួនឥរិយាបថនៃផលប្រយោជន៍ផ្ទាល់ខ្លួនស្ថិតនៅពីក្រោយលក្ខណៈពិសេស២ទៀតរបស់សេដ្ឋកិច្ចទីផ្សារ។ ទីមួយគឺសិទ្ធិកម្មសិទ្ធិឯកជន វាជាសិទ្ធិបុគ្គល និងក្រុមចំពោះកម្មសិទ្ធិផ្ទាល់។ ក្នុងពាក្យសេដ្ឋកិច្ចកម្មសិទ្ធិមានន័យថាអ្វីអ្វីទាំងអស់ដែលបុគ្គលធ្វើជាម្ចាស់។ វារួមមាន រោងចក្រការិយាល័យធ្វើការ សម្លៀកបំពាក់ សង្ហារឹម ផ្ទះ រថយន្ត និងអ្វីផ្សេងទៀតលុយ និងកម្មសិទ្ធិបញ្ញាមានដូចជាចម្រៀង ឬគំនិតអភិវឌ្ឍន៍សម្រាប់ការប្រឌិតថ្មី។ វាក៏រួមមានទាំងពលកម្មដែលបុគ្គលផ្គត់ផ្គង់ដើម្បីរកលុយ។ លក្ខណពិសេសមួយទៀតដែលកើតមកពីផលប្រយោជន៍ផ្ទាល់គឺទីផ្សារវាជាកន្លែង ឬជាស្ថានភាពដែលពលរដ្ឋទិញ និងលក់ ធនធាននិង ទ្រព្យសេវា។ ទីផ្សារគឺជាកន្លែងដែលពលរដ្ឋអាចដោះដូរទ្រព្យសម្បត្តិឯកជនជាមួយអ្នកដទៃ។

- **លក្ខណៈពិសេសទី១: កម្មសិទ្ធិឯកជន និងទីផ្សារ(Private Property and Markets)**

ដើម្បីឱ្យទីផ្សារដំណើរការទៅមានប្រសិទ្ធិភាពនោះ វាទាមទារឱ្យមានការកំណត់បានច្បាស់លាស់ និងទទួលស្គាល់ដោយច្បាប់។ ប្រសិនបើអ្នកធ្លាប់ទិញឡាននោះ អ្នកដឹងថាផ្នែកសំខាន់នៃការទិញគឺទទួលបានក្រដាសបញ្ជាក់ពីកម្មសិទ្ធិ។ អ្នកត្រូវការភស្តុតាងពីភាគីម្ខាងថា គេជាម្ចាស់ឡាន និងមានសិទ្ធិលក់វា។ នៅពេលដែលការប្តូរកម្មសិទ្ធិមានសារៈសំខាន់ចំពោះការលក់ និងដោះដូរនោះ សិទ្ធិនៃកម្មសិទ្ធិឯកជនមានភាពចាំបាច់ដើម្បីឱ្យទីផ្សារដំណើរការបានត្រឹមត្រូវ។ ប្រសិនបើអ្នកទិញមិនអាចជឿថាអ្នកលក់មានសិទ្ធិក្នុងការផ្តល់ផលិតផល របស់គេលើទីផ្សារនោះ ការដោះដូរនឹងមិនត្រូវបានធ្វើទេ។ ជាងនេះទៀត ឧបមាថា អ្នកជាអ្នកលេងភ្លេងម្នាក់ ប៉ុន្តែអ្នកដឹងថាចំរៀងរបស់អ្នកអាចយកចេញពីអីនធឺណេតដោយមិនអស់លុយ បញ្ហានេះវាដកហូតសិទ្ធិរបស់អ្នកក្នុងការដោះដូរអ្វីដែលជារបស់អ្នកដើម្បីទទួលបានកម្រៃ។ ក្នុងស្ថានភាពនេះ វាមិនប្រាកដថា អ្នកមានចិត្តថតភ្លេងតទៅទៀតនោះទេ។ ដើម្បីការពារសិទ្ធិនៃកម្មសិទ្ធិឯកជនដើម្បីធ្វើការលើកទឹកចិត្តដល់ផលិតករ និងដើម្បីបង្កើនការជឿជាក់ដល់អ្នកប្រើប្រាស់ រដ្ឋាភិបាលត្រូវអនុវត្តន៍តួនាទីសំខាន់ក្នុងសេដ្ឋកិច្ចទីផ្សារ។

- **លក្ខណៈពិសេសទីពីរ: ការដាក់កាលនៃការចាក់ព័នរបស់រដ្ឋ**(Limited G Involvement)

មានពេលខ្លួន តួនាទីរបស់រដ្ឋ គឺឈរនៅខាងក្រៅទីផ្សារ។ គោលការណ៍ដែល រដ្ឋាភិបាលមិនត្រូវជ្រៀតជ្រែកទៅក្នុងសេដ្ឋកិច្ចត្រូវបានហៅថា laissez faire, វាជាពាក្យក្នុង ភាសាបារាំងមានន័យថា "ទុកឱ្យវាដំណើរការដោយខ្លួនឯង"។ សញ្ញាណ Laissez Faire ជានិច្ចកាលគូជាមួយមូលធននិយម (Capitalism)ដែលវាជាប្រព័ន្ធសេដ្ឋកិច្ចដែលឈរលើមូលដ្ឋាននៃម្ចាស់កម្មសិទ្ធិឯកជននៃមធ្យោបាយផលិតកម្ម។ មូលធននិយមដែលជាគ្រឹះនៃសេដ្ឋកិច្ចទីផ្សារ វាដំណើរការលើការជឿជាក់ថា ផលិតករនឹងផលិតទ្រព្យ និងសេវាដែលអ្នកប្រើប្រាស់ត្រូវការ។ ដោយហេតុនេះយោលទៅលើ Laissez Faire មូលធននិយម វាមិនមានតម្រូវការអន្តរាគមន៍ណាមួយរបស់រដ្ឋាភិបាលក្នុងទីផ្សារទេ។ Laissez Faire មូលធននិយមគឺជាសេដ្ឋកិច្ចទីផ្សារក្នុងទម្រង់សុទ្ធ។ ទោះជាដូច្នោះក៏ដោយ វាគ្មានសេដ្ឋកិច្ចទីផ្សារណាមួយសុទ្ធទេគ្រប់សេដ្ឋកិច្ចទីផ្សារទាំងអស់សុទ្ធតែមានកម្រិតខ្លះនៃការជាប់ពាក់ព័ន្ធជាមួយរដ្ឋាភិបាល។

- **លក្ខណៈពិសេសទីបី: ការស្ម័គ្រចិត្តដោះដូរលើទីផ្សារ**(Voluntary Exchange in Markets)

នៅពេលដែលអ្នកទិញម្នាក់ និងអ្នកលក់ម្នាក់ឯកភាពគ្នាធ្វើការដោះដូរជាមួយគ្នានោះ គេដំណើរការដោះដូរដោយស្ម័គ្រចិត្ត។ វាជាការដោះដូរមួយដែលភាគីពាក់ព័ន្ធទាំងសងខាងគិតថា ទទួលបានផលប្រយោជន៍ធំជាងការខាតបង់។ ភាគីទាំងពីរដែលធ្វើការដោះដូរដោយស្ម័គ្រចិត្តជឿថា អ្វីដែលគេទទួលបានមានតំលៃធំជាងអ្វីដែលគេបានបោះបង់។ ក្នុងសេដ្ឋកិច្ចទីផ្សារ ការធ្វើជំនួញទាំងអស់ ត្រូវបានធ្វើឡើងលើមូលដ្ឋាននៃការដោះដូរផលិតផលដើម្បីលុយមិនមែនដើម្បីផលិតផលដទៃទេ។

ផលប្រយោជន៍ផ្ទាល់ខ្លួនជាអ្នកដឹកនាំអោយមានការដោះដូរដោយស្ម័គ្រចិត្ត។ ឧបមាថា អ្នកទិញហ្គីតាថ្មីមួយ។ ថ្វីបើអ្នកបានចំណាយមួយចំណែកនៃការសន្សំរបស់អ្នក តែផលប្រយោជន៍ផ្ទាល់របស់អ្នកត្រូវបានផ្តល់ឱ្យព្រោះអ្នកចង់បានប្រភេទហ្គីតានេះ។ ផលប្រយោជន៍របស់អ្នកលក់ត្រូវបានផ្តល់តាមរយៈប្រាក់ចំណេញលើដែលវាជាផលចំណេញ ហិរញ្ញវត្ថុពីការធ្វើអាជីវកម្ម។ ដូច្នេះក្នុងការដោះដូរស្ម័គ្រចិត្តភាគីទាំងសងខាងត្រូវជឿថាបានចំណេញតាមរយៈការដោះដូរ។

- **លក្ខណៈពិសេសទី៤: ការប្រកួតប្រជែង និងអធិបតេយ្យភាពអ្នកប្រើប្រាស់**

(Competition and Consumer Sovereignty)

សេដ្ឋកិច្ចទីផ្សារក៏មានលក្ខណៈប្រកួតប្រជែងដែរ វាជាការប្រឹងប្រែងរបស់មនុស្សពីរនាក់ ឬច្រើននាក់ធ្វើសកម្មភាពដោយឯករាជ្យនឹងគ្នាដើម្បីដណ្តើមយកបានការធ្វើអាជីវកម្មរបស់អ្នកដទៃតាមរយៈការផ្គត់ផ្គង់ទំនិញបានល្អបំផុត។ អ្នកអាចជ្រើសរើសថ្ងៃនេះរវាងផលិតផលរបស់ក្រុមហ៊ុនផ្សេងៗដោយសារតែការប្រកួតប្រជែងលើទីផ្សារ។ ក្នុងការប្រកួតប្រជែងនេះ ផលិតផលនីមួយៗមានលក្ខណៈពិសេសផ្សេងគ្នាត្រង់ចំណុចណាមួយ ប៉ុន្តែអនុវត្តន៍នូវមុខងារដូចគ្នា។ អ្នកមានសេរីភាពក្នុងការសម្រេចចិត្តទៅលើអ្វីដែលអ្នកចូលចិត្តលើមូលដ្ឋាននៃការបញ្ចូលគ្នានៃថ្លៃ និងតម្លៃដែលអ្នកវិនិច្ឆ័យថាទទួល

បានផលប្រយោជន៍ច្រើន។ នៅពេលដែលអ្នកទិញថ្នាំ អ្នកអាចឃើញយ៉ាងច្បាស់ពីទិដ្ឋភាពប្រកួតប្រជែងរបស់ទីផ្សារ។ ចំពោះផលិតផលដែលល្បីដូចគ្នាអ្នកនឹងឃើញថាផលិតផលមានមួយដែលមានជាតុផ្សំដូចគ្នា មានការវិចខ្ចប់ប្រហែលគ្នា ប៉ុន្តែមានឈ្មោះខុសគ្នា និងមានតម្លៃថោកជាង។ ផលិតករដែលលក់នៅថ្លៃថោកជាងធ្វើការប្រកួតប្រជែងក្នុងអាជីវកម្មដើម្បីការទទួលការស្គាល់ម៉ាកផលិតផលរបស់ខ្លួន។ ប្រសិនបើ ផលិតករដែលមានម៉ាកផលិតផលល្បី ឬចង់រក្សាការធ្វើអាជីវកម្មរបស់ខ្លួន គេត្រូវបញ្ចុះថ្លៃផលិតផលរបស់គេ ឬរកវិធីបង្កើនតម្លៃនៃការប្រើប្រាស់ផលិតផលរបស់គេ។

នោះគឺដោយសារតែអ្នកប្រើប្រាស់ប្រកាន់យកនូវអំណាចពិតក្នុងទីផ្សារ។ **អធិបតេយ្យភាពអ្នកប្រើប្រាស់** គឺជាគំនិតដែលកើតឡើងដោយសារតែអ្នកប្រើប្រាស់មានសេរីភាពក្នុងការទិញនូវអ្វីដែលគេចង់ និងបដិសេធទៅលើអ្វីដែលគេមិនចង់។ គេជាអ្នកមានឥទ្ធិពលទៅលើអ្វីដែលត្រូវបានផលិត។

អធិតេយ្យភាពមានន័យថាជាអំណាចខ្ពស់បំផុត(Supreme Authority)ដែលអ្នកប្រើប្រាស់ប្រើក្នុងនាមអ្នកសំរេចចិត្តសេដ្ឋកិច្ចដ៏សំខាន់។ បើពិនិត្យមើលការទិញថ្នាំម្តងទៀត ប្រសិនបើគ្មានការប្រកួតប្រជែងទេ នោះគេនឹងលក់នៅតម្លៃខ្ពស់។ គេនឹងទទួលបានផលប្រយោជន៍ផ្ទាល់ពីការលក់នៅតម្លៃខ្ពស់តាមដែលអាចធ្វើបាន។ ទោះដូច្នោះក៏ដោយ ការប្រកួតប្រជែងធ្វើសកម្មភាពដូចជាការត្រួតពិនិត្យមើលទៅលើឥរិយាបថនៃផលប្រយោជន៍ផ្ទាល់វាដឹកនាំទីផ្សារឆ្ពោះទៅរកតុល្យភាពរវាងតម្លៃខ្ពស់ និងតម្លៃទាប។ ជាជាងបាត់បង់ការធ្វើអាជីវកម្ម ផលិតករនឹងធ្វើការបញ្ចុះថ្លៃ ឬបង្កើនការឱ្យតម្លៃទៅលើផលិតផលរបស់គេ។ ដោយសារតែផលិតករត្រូវធ្វើការប្រកួតប្រជែងដើម្បីការចំណាយរបស់អ្នកប្រើប្រាស់នោះ គេត្រូវធ្វើការដើម្បីបំពេញចិត្តអ្នកប្រើប្រាស់។

- **លក្ខណៈពិសេសទី៥: ការធ្វើឯកទេសកម្ម និងទីផ្សារ** (Specialization and Markets)

សេដ្ឋកិច្ចទីផ្សារលើកទឹកចិត្តឱ្យមានការប្រើប្រាស់ធនធានមានប្រសិទ្ធិភាព ដោយអនុញ្ញាតិឱ្យប្រជាពលរដ្ឋ និងអាជីវករធ្វើឯកទេសកម្មទៅលើអ្វីដែលគេអាចធ្វើបានល្អបំផុត។

ឯកទេសកម្ម(Specialization)គឺជាស្ថានភាពដែលប្រជាពលរដ្ឋប្រមូលផ្តុំនូវការប្រឹងប្រែងរបស់គេទៅលើអ្វី ដែលគេធ្វើទៅទទួលបានអត្ថប្រយោជន៍។ វាអនុញ្ញាតិឱ្យធ្វើជំនួញទៅលើអ្វីដែលគេអាចផលិតបានដោយមានប្រសិទ្ធិភាពខ្ពស់ជាងអ្នកដទៃផលិត។

ឯកទេសកម្ម ធ្វើឱ្យសេចក្តីត្រូវការរបស់គ្រួសារមានភាពគ្រប់គ្រាន់ដោយខ្លួនឯង ហើយទីផ្សារអនុញ្ញាតិឱ្យគ្រួសារដោះដូរបាននូវអ្វីដែលគេមានតម្រូវការ។

ឧបមាថាមនុស្សម្នាក់នៅក្នុងផ្ទះរបស់អ្នកជាអ្នកធនាគារ និងម្នាក់ទៀតជាជាងផ្សារ។ គ្មានការងារធនាគារ និងការងារដែលត្រូវផ្សារណាមួយដែលត្រូវការក្នុងផ្ទះរបស់អ្នកទេ ប៉ុន្តែគ្រួសាររបស់អ្នកត្រូវការគ្រឿងផ្សំម្ហូបអាហារ។ ដោយការធ្វើឯកទេសកម្មទៅលើអ្វីដែលគេអាចធ្វើបានល្អបំផុត គេអាចរកលុយពីការងាររបស់ គេក្នុងសេដ្ឋកិច្ចទីផ្សារដើម្បីយកទៅទិញអ្វីដែលអ្នកផ្សេងបានធ្វើឯកទេសកម្ម។ តែបើសិនជាគេធ្វើការងារដាំដុះនោះ គេនឹងទទួលបានប្រសិទ្ធិភាពទាបជាងប្រសិទ្ធិភាពដែលកសិករបានធ្វើ។ ក៏ដូចគ្នាដែរ ពេលដែលគេធ្វើការដាំដុះមួយម៉ោង នោះគេនឹងបាត់បង់ចំណូលពីការងាររបស់

គេមួយម៉ោងដែរ។ ដូចនេះការធ្វើឯកទេសកម្ម វានឹងធ្វើឱ្យទទួលបានគុណភាពខ្ពស់ និងថ្លៃផលិតផលទាប។

**ខ.ផលប៉ះពាល់របស់សេដ្ឋកិច្ចទីផ្សារ( Impact of Market Economy )**

នៅចន្លោះពីចុងបណ្តាឆ្នាំ១៩៤០ និងដើមឆ្នាំ១៩៩០ មានប្រជាជនចន្លោះពីមួយភាគបួន និងមួយភាគបីនៃប្រជាជនពិភពលោករស់នៅក្រោមប្រព័ន្ធសេដ្ឋកិច្ចបញ្ជា។ សហភាពសូវៀត ប្រទេសមួយចំនួននៅអឺរ៉ុបខាងកើត ចិន ប្រទេសនៅអាស៊ីអាគ្នេយ៍ គុយបា និងកូរ៉េខាងជើង បានអនុវត្តន៍សេដ្ឋកិច្ចផែនការប្រមូលផ្តុំ។ ទោះជាដូច្នោះនក៏ដោយ ជាមួយនឹងការដួលរលំនៃលទ្ធិកុម្មុយនីស្តនិយមនៅដើមទសវត្សទី៩០ ប្រទេសកុម្មុយនីស្តភាគច្រើនបានសម្របខ្លួនទៅរកទម្រង់សេដ្ឋកិច្ចទីផ្សារ។ ហេតុអ្វីបានជាប្រទេសទាំងនេះ វិលមករកប្រព័ន្ធសេដ្ឋកិច្ចទីផ្សារវិញ?

- **គុណសម្បត្តិ**

នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៨៩ ជញ្ជាំងនៅទីក្រុងប៊ែរឡាំងដែលនិមិត្តតំណាងការបែងចែករវាងប្រទេសកុម្មនីស្ត និងប្រទេសប្រជាធិតេយ្យនៅប្រទេសអាឡឺម៉ង់ត្រូវបានចំហ។ ពីរបីថ្ងៃបន្ទាប់ប្រជាជនរាប់រយពាន់នាក់នៅអាឡឺម៉ង់ខាងកើតបានចាប់ផ្តើមចូលទៅក្នុងប្រទេសអាឡឺម៉ង់ខាងលិចដែលជាប្រទេសសេរីតាមច្រកទ្វារដែលបានបើកនោះ តើអ្វីដែលធ្វើអោយប្រជាជនអាឡឺម៉ង់ខាងកើតចូលទៅអាឡឺម៉ង់ខាងលិច? ទាំងអស់គ្នាបានឆ្លើយថា **សេរីភាព**។

សេរីភាពគឺជាគុណសម្បត្តិនាំមុខគេមួយរបស់សេដ្ឋកិច្ចទីផ្សារ។ សេដ្ឋកិច្ចទីផ្សារមួយ ទាមទារឱ្យបុគ្គលទាំងឡាយមានសេរីភាពក្នុងការសម្រេចចិត្តរបស់គេផ្ទាល់ នៅពេលដែលវា ចំណីទៅលើសិទ្ធិរបស់អ្នកប្រើប្រាស់ក្នុងការទិញ ឬបដិសេធផលិតផលដើម្បីកំណត់ថាអ្វីដែលត្រូវផលិត។ បុគ្គលទាំងឡាយក៏មានសេរីភាពក្នុងពង្រីកផលប្រយោជន៍ និង ការប៉ិនប្រសប់ក្នុង ការងារដើម្បីបំពេញចិត្ត។

ក៏ដូចគ្នាដែរ នៅពេលដែលរដ្ឋាភិបាល មិនធ្វើការគ្រប់គ្រងតឹងរ៉ឹងដល់ការធ្វើសេដ្ឋកិច្ច នារដំណើរនយោបាយអាចមានសេរីភាពជាងជាមួយនឹងទស្សនៈផ្សេងៗ ហើយការជ្រើសរើស ត្រូវបានបើកចំហ។ ច្បាប់ទំលាប់របស់រដ្ឋ ជាទូទៅមិនសូវទើសទែង និងមានការចំណាយតិចជាងក្នុងសេដ្ឋកិច្ចបញ្ជាដោយសាររដ្ឋមានការពាក់ព័ន្ធតិចតួច។ សេដ្ឋកិច្ចទីផ្សារក៏អាចមានប្រសិទ្ធិភាព ក្នុងការផ្លាស់ប្តូរលក្ខខណ្ឌ និងតម្រូវទៅនឹងការផ្លាស់ប្តូរបានឆាប់រហ័សផងដែរ។

ជាងនេះទៀត បុគ្គលដែលរស់នៅក្នុងសហគមន៍ មានសេរីភាពក្នុងការសម្រេចចិត្តសេដ្ឋកិច្ចផ្ទាល់ដោយគ្មានការជ្រៀតជ្រែកពីរដ្ឋាភិបាលទេ។ ការយល់ដឹងជាមុនរបស់បុគ្គលទាំងនេះ អំពីធនធាននិងសក្តានុពលនៅតំបន់របស់គេធ្វើឱ្យពួកគេធ្វើការសម្រេចបានល្អជាង និងទទួលបានផលិតភាពខ្ពស់ជាង។

ផលចំណេញជាហេតុមួយ វាជាលក្ខណៈពិសេសសំខាន់មួយរបស់សេដ្ឋកិច្ចទីផ្សារដែលវាបញ្ជាក់អោយឃើញច្បាស់ថា ធនធាននឹងត្រូវបានបែងចែកយ៉ាងមានប្រសិទ្ធិភាព ព្រោះការប្រើប្រាស់គ្មានប្រសិទ្ធិភាពធ្វើអោយទទួលបានផលចំណេញតិច។ ផលចំណេញត្រូវបានចាត់ទុកដូចជាការផ្តល់

រង្វាន់ដល់ការខិតខំប្រឹងប្រែង និងការបង្កើតថ្មី។ អ្នកដឹងថា អ្នកអាចរកលុយបាន ប្រសិនបើអ្នកមានគំនិតល្អៗ នេះជាការលើកទឹកចិត្តអោយធ្វើដូច្នេះ ហើយបើប្រជាជនកាន់តែមានគំនិតល្អៗនោះសេដ្ឋកិច្ចកាន់តែរីកចំរើន។ ការលើកទឹកចិត្តដើម្បីបង្កើតឱ្យមានគំនិតល្អចទាក់ទងទៅនឹងគុណសម្បត្តិផ្សេងទៀតរបស់សេដ្ឋកិច្ចទីផ្សារ វាជំរុញឱ្យមានការប្រកួតប្រជែង។ ការប្រកួតប្រជែងធ្វើឱ្យផលិតផលមានគុណភាពខ្ពស់នៅថ្លៃទាប។ វាក៏ជួយឱ្យបង្កើតបាននូវផលិតផលផ្សេងៗលើទីផ្សារផងដែរ។

- **គុណវិបត្តិ**

ទោះជាដូច្នោះក៏ដោយ សេដ្ឋកិច្ចទីផ្សារក៏មានគុណវិបត្តិផងដែរ។ ក្នុងសេដ្ឋកិច្ចទីផ្សារសុទ្ធ ទំនិញសេដ្ឋកិច្ចរបស់បុគ្គលគឺជាបញ្ហាដែលត្រូវយកចិត្តទុកដាក់ដំបូង។ សេដ្ឋកិច្ចទីផ្សារសុទ្ធគ្មានយន្តការសម្រាប់ការផ្តល់ទំនិញ និងសេវាសាធារណៈទេ ដូចជាការការពារជាតិជាដើម ព្រោះវាមិនមានទទួលបានប្រាក់ចំណេញបើឈរលើទស្សនៈសេដ្ឋកិច្ចទាំងស្រុង។

គុណវិបត្តិផ្សេងទៀត គឺថាសេដ្ឋកិច្ចទីផ្សារសុទ្ធមិនអាចផ្តល់សុវត្ថិភាពដល់អ្នកមិនធ្វើសកម្មសេដ្ឋកិច្ច ដោយសារតែគាត់មានជំងឺ និងចាស់ជរា។ វាថែមទាំងមិនអាចរារាំងបាននូវវិសមភាពក្នុងការបែងចែកទ្រព្យសម្បត្តិ ទោះបីជាគម្លាតកើតចេញពីវិសមភាពនៃការផ្តល់ឱកាសក៏ដោយ។

ភាពរីកចំរើនលូតលាស់ខ្លាំងនៃឧស្សាហកម្មនៅសហរដ្ឋអាមេរិកនៅចុងបណ្តាឆ្នាំ១៨០០ និងដើមបណ្តាឆ្នាំ១៩០០ បានបង្ហាញពីបញ្ហាទាំងឡាយដែលអាចកើតឡើងក្នុងសេដ្ឋកិច្ចទីផ្សារដែលមានច្បាប់ទំលាប់រដ្ឋតិចតួច។ ក្នុងអំឡុងពេលនោះ អ្នកដឹកនាំអាជីវកម្មមួយចំនួនតូចបានក្លាយជាអ្នកមាន។ ក្នុងពេលនោះដែរ អ្នកធ្វើការសឹងតែទាំងអស់ត្រូវបានទូទាត់នៅថ្លៃឈ្នួលទាប(តែមានការកើនឡើង)។ ជាងនេះទៀត អ្នកដឹកនាំអាជីវកម្មសឹងតែទាំងអស់បានដោះស្រាយតិចតួចទៅលើផលអវិជ្ជមាននៃការធ្វើឧស្សាហូបនីយកម្ម បរិស្ថានជាដើម។ បញ្ហាអស់ទាំងនេះ បានធ្វើឱ្យសង្គមឧស្សាហកម្មសឹងតែទាំងអស់ តម្រូវឱ្យមានការចូលរួមរបស់រដ្ឋាភិបាលក្នុងសេដ្ឋកិច្ចនៅកម្រិតណាមួយ។ លទ្ធផលគឺទទួលបានប្រព័ន្ធសេដ្ឋកិច្ចមួយដែលចម្រុះបញ្ចូលគ្នានៃសមាសភាព សេដ្ឋកិច្ចទីផ្សារសេរី និងសេដ្ឋកិច្ចបញ្ជា។

ជាសរុបមក ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី គឺជាខឿនសេដ្ឋកិច្ចដែលពឹងផ្អែកទាំងស្រុងទៅលើទីផ្សារដើម្បីធ្វើការបែងចែកធនធាន។ នៅទីនោះ រដ្ឋាភិបាលជាអ្នកកំណត់ចំពោះបុគ្គលម្នាក់ៗ ថាតើមុខទំនិញណា ហើយចំនួនប៉ុន្មានដែលគេអាចប្រើប្រាស់បាន? តើគេអាចផលិតបាន និងកំណត់បរិមាណធនធាននីមួយៗដែលគេប្រើសម្រាប់ផលិតមុខទំនិញនីមួយៗ? ប្រព័ន្ធខឿនសេដ្ឋកិច្ចទីផ្សារសេរី ការសម្រេចចិត្តអំពីការបែងចែកធនធានត្រូវបានធ្វើដោយគ្មានទិសដៅកណ្តាលណាមួយទេ។ ការសម្រេចចិត្តធ្វើឡើងដោយឯករាជ្យពីសំណាក់ផលិតករ និងអ្នកប្រើប្រាស់នីមួយៗ។ ប្រព័ន្ធសេដ្ឋកិច្ចនេះគេហៅថា ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី។

## ១.២.ពាណិជ្ជកម្មសេរី និងកិច្ចការពារ( Free Trade and Protection )

ពាណិជ្ជកម្មសេរី និងកិច្ចការពារការបែងចែកតំបន់រវាងពាណិជ្ជកម្មសេរី និងការគាំពារពាណិជ្ជកម្មសេរីអន្តរជាតិ បញ្ហាធំៗនឹងលំហូរចូលនៃទំនិញដោយឆ្លងកាត់ព្រំដែនអន្តរជាតិ ដោយហេតុតែការ

ការពារនៃបញ្ហាធំៗដែលនាំចូល គឺត្រូវតែយល់ព្រមបង់ពន្ធជាមុនសិន ឬការដកពន្ធជាលក្ខខណ្ឌធម្មជាតិកាត់បន្ថយការប្រកួតប្រជែងជាមួយនឹងផលិត ផលផ្សេងៗ ទម្រង់បែបលក្ខណៈប្រពៃណីការគាំពារការដកពន្ធការនាំចូលវាផ្តល់ឱ្យពួកគេការប្រកួតប្រជែងពីបរទេស តាំងពីឆ្នាំ ១៩៣០ ទោះជាយ៉ាងណាក៏ដោយនៅក្នុងវិស័យកសិកម្មបរិមាណភាគជាច្រើន អាចផ្លាស់ប្តូរបានការយកពន្ធនឹងជំនួយជាប្រាក់មានការកើនឡើងខ្ពស់ នៅអ្នកមានការងារធ្វើដែលរួមបញ្ចូលអ្នកប្រកួតប្រជែងបរទេស ធ្វើឱ្យថ្លៃឈ្នួលនៅក្នុងសេដ្ឋកិច្ចផែនការកណ្តាល គឺអ្វីៗខ្លួនជាអ្នកបញ្ជា វាគឺជាផលពិបាកដែលថាមានវិសាលភាពនៃគោនយោបាយការពារ គឺចាប់ផ្តើមដូចតទៅអំពីពាណិជ្ជកម្មអន្តរជាតិ នៅក្នុងកណ្តាប់ដៃនៃរដ្ឋ។ យ៉ាងណាក៏ដោយ អំណាចផ្តាច់ការនៅតែមានក្នុងការកំណត់ការបែងចែកធនធានរវាងឧស្សាហកម្មជាច្រើន នៅក្នុងសេដ្ឋកិច្ចទីផ្សារសេរី រកដំណោះស្រាយច្រើនដោយប្រព័ន្ធថ្លៃ ឧទាហរណ៍នៅក្នុងប្រមាណឆ្នាំថ្មីៗនេះ មានការកើនឡើងដែលទាក់ទងទៅនឹងផលប្រយោជន៍នៃការដាំដុះនៅតាមផ្ទះ ហើយនឹងការនាំចេញដោយផលិតផលដោយការដោះដូរពីផលិតផលទៅជារូបិយវត្ថុបរទេស។

ទិសដៅគោលនយោបាយវិស័យកសិកម្មទិដ្ឋភាពវាដូចទៅនឹងគោលនយោបាយសេដ្ឋកិច្ចដែរ

អាស្រ័យនឹងមធ្យោបាយចុងក្រោយបំផុត នៃគោលនយោបាយយ៉ាងពិតប្រាកដ ទិសដៅទីមួយនៅក្នុងការការពារចំនួនខ្ពស់បំផុតនៃមនុស្សចូលធ្វើកសិកម្មក៏ដូចជាចំនួនកសិកម្មកើនឡើង។ ទិសដៅទីពីរ ធ្វើឱ្យមានជំនួយការគ្រប់គ្រាន់នៅពេលមានសង្រ្គាម ឬកាត់បន្ថយការនាំចូលផ្គត់ផ្គង់សម្រាប់ប្រជាជន ឬក៏ការចំណាយមានតុល្យទិសដៅទីបីនៅក្នុងប្រទេសអភិវឌ្ឍន៍នៅក្នុងប្រមាណឆ្នាំចុងក្រោយបានយកចិត្តទុកដាក់ទៅលើសហគមន៍ជុំវិញ ប្រសិទ្ធិភាពកសិកម្មនឹងទីផ្សារទិសដៅចុងក្រោយ កើតឡើង ពីព្រោះភាពខ្វះចន្លោះនៅសេដ្ឋកិច្ចទីផ្សារ នៅក្នុងវិស័យកសិកម្មបញ្ហាសេដ្ឋកិច្ចជាមូលដ្ឋានគ្រឹះទាំង ៣ product mix, ការរៀបចំធនធានមានការបែងចែកចំណូលការងារសេដ្ឋកិច្ចទីផ្សារ ពិតជាល្អសម្រាប់ទិសដៅទីមួយមិនគ្រាប់គ្រាន់សម្រាប់ទិសដៅទីពីរ ហើយនឹងមិនល្អប្រមាណទេសម្រាប់ទិសដៅទីបី។

មូលហេតុនៃផលិតផលកសិកម្មត្រូវបានកំណត់ដោយអ្នកប្រើប្រាស់តាមចំណង់ចំណូលចិត្តរបស់គេ ព្រោះក្នុងក្របខណ្ឌនៃទីផ្សារសេរីគឺអតិថិជនជាស្តេច។

## ១.៣. បញ្ហាប្រឈមចម្បងៗនៃគោលនយោបាយកសិកម្ម

បញ្ហាសំខាន់ពីរនៃវិស័យកសិកម្មដែលអោយរដ្ឋធ្វើអន្តរាគមន៍គឺ:

1. ប្រាក់ចំណូលទាប
2. ស្ថេរភាពនៃចំណូល

ការសិក្សារសំរាប់ប្រទេសជាច្រើននិងកំឡុងពេលផ្សេងៗគ្នាបានបង្ហាញពីចំនូលវិស័យកសិកម្ម គឺកំពុង ស្ថិតនៅក្រោមបញ្ហាទាំងនេះថាតើការប្រៀបធៀបគឺត្រូវបានធ្វើឡើងជាមួយនិងការងារផ្ទាល់ខ្លួនឬការងារដែលទទួលបានប្រាក់ខែការប្រៀបធៀបចំណូលនៃវិស័យកសិកម្មជាមួយនិងការងារផ្សេងៗគឺត្រូវបានបញ្ជាក់យ៉ាងច្បាស់។ វាគឺជាការលំបាក់ក្នុងការវាស់វែងចំនួលវិស័យកសិកម្ម។

ដូចជាម្ហូបអាហារដែលបានផលិតក្នុងកសិដ្ឋាននិងដើមទុនគឺប ង្កអោយមានបញ្ហាយ៉ាងធ្ងន់ធ្ងរ។ លើសពីនេះ ទៅទៀតចំនួលដែលបានមកពីវិស័យកសិកម្មគឺជាការសំខាន់មួយ។ ចុងក្រោយភាព

ខុសគ្នានៃចំនូលនៅក្នុង វិស័យកសិកម្មគឺមានចំនួនច្រើន។ ភាពខុសគ្នារវាងចំណូលមធ្យមវិស័យកសិកម្មនិងការងារផ្សេងៗ។

សំរាប់មូលហេតុទាំងនេះទំងន់ដែលច្រើនហួសប៉ុន្មានត្រូវបានផ្តល់ទៅក្នុងវិស័យកសិកម្មទេ ប៉ុន្តែការឆ្លុះមួយ នៃមុខតំណែងហិរញ្ញវត្ថុនៃវិស័យកសិកម្មត្រូវទទួលបានពីការស៊ើបអង្កេតផ្សេងៗ ហើយ បញ្ហាទាំងនេះដែល បង្ហាញថាគ្មានតំលៃបច្ចុប្បន្នគាំទ្រវាស់វែងទេវិស័យកសិកម្មជាច្រើនជួបការលំបាក់។ នៅក្នុងពេលនេះយ៉ាងហោចណាស់មានបញ្ហាមួយនៃភាពខុសគ្នានៃប្រាក់ចំនូលនៃវិស័យកសិកម្មនិងការងារផ្សេងៗទៀត។

នៅក្នុងប្រទេសអភិវឌ្ឍន៍ជាច្រើនបញ្ហានៃភាពខុសគ្នាប្រាក់ចំនូលគឺមានភាពខុសគ្នាដែលមានការកើតឡើង ដែលអ្នកបច្ចេកទេសក្នុងផលិតកម្មកសិកម្ម។ អ្នកទ្រឹស្តីវិទ្យាសាស្រ្តតាំងពីសង្គ្រាមលោកលើកទី២បានកើតនៃមុក ចេញជួនកាលមានការកើនឡើងតម្រូវការ ហើយដូចនេះនាំទៅរកការធ្លាក់ថ្លៃនៃផលិតផលកសិកម្មក្នុងទំនាក់ទំ នងឧស្សាហកម្មទោះប្បីមានភាពចាំបាច់ក្នុងទំនាក់ទំនងរបស់គ្រួសាររបស់កសិករផងដែរ។ ការប្រៀបធៀប មួយបានធ្វើឡើងនៅអាឡឺម៉ង់ខាងលិចរវាងចំនូលកសិកម្មហើយនៅក្នុងកាងារផ្សេងៗ ដែលបានប្រៀបធៀប ប្រចាំឆ្នាំចង្អុលបង្ហាញថាចំនូលនៃវិស័យកសិកម្មនៅក្នុងឆ្នាំថ្មីៗមានការកើនឡើងនៅក្នុងអត្រាដូចគ្នានៃ ចំនូល នៅក្នុងកត្តាផ្សេងៗប៉ុន្តែបានកើតឡើងប្រហែលជាពាក់វិតនៅក្នុងចក្រភពអង់គ្លេសស្ថិតិចំនូលជាតិបានបង្ហាញថា ប្រាក់ចំនូលកសិករបានកើនឡើងអំឡុងពេលនៃសង្គ្រាមប៉ុន្តែបានធ្លាក់ចុះនៅដើមឆ្នាំ១៩៥០។ តាំងពីឆ្នាំ១៩៧៥ហាក់បីដូចជាមានការធ្លាក់ចុះបន្ថែមទៀតហើយនៅក្នុងឆ្នាំ១៩៧៨ដល់១៩៨០មានការប្របាច់យ៉ាងខ្លាំងទៅលើ ការអភិវឌ្ឍន៍ចំនូលកសិករឈានទៅរកស្លេភាព។

បញ្ហានៃប្រាក់ចំនូលទាបជាក់ស្តែងទាំងនេះក្នុងវិស័យកសិកម្មគឺជាលទ្ធិផលដ៏សំខាន់ដែលមិនអាចខ្លួនរបស់ វាផ្ទាល់អោយល្បឿនគ្រប់គ្រាន់ក្នុងលក្ខ័ណដែលបានប្រែប្រួលនោះទេ។ ខណៈពេលដែលប្រាក់ចំកើនឡើងតម្រូវការម្ហូអាហារឡើងទេទោះប្បីយ៉ាងណាក៏ដោយប្រទេសអភិវឌ្ឍន៍ជាច្រើនដែលមានការលូតលាស់ ផ្នែកបច្ចេក ទេស បង្កអោយមានមុកចេញកើនឡើងជាបន្តបន្ទាប់។ កសិករមួយចំនួនគឺត្រូវការម្ហូបអាហារដែលគេត្រូវការប៉ុន្តែ ដោយមានភាពថយចុះនៃចំនួនកសិករគឺមិនអាចទាញយកទីតាំងនៃល្បឿនដែលត្រូវការនោះទេគឺវាកំពុងទៅ រក ទីផ្សារដែលផ្គត់ផ្គង់តំរូវការតម្លៃធ្លាក់ទាបអតុល្យភាពនៃមនុស្សម្នាក់ចំនូលធ្លាក់ទាបនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ទោះប្បីជាមានហេតុផលខុសគ្នាមួយចំនួន។ ប្រទេសអភិវឌ្ឍន៍ជាទូទៅ៣០ទៅ១៥%ហើយជួនកាលអាច តិច ជាងនេះនៅប្រទេសអភិវឌ្ឍន៍សព្វថ្ងៃនោះទេតាំងពីមុនដែលប្រទេសអភិវឌ្ឍន៍ មានចំនូលទាបតាំងពីមុនការចាប់ផ្តើមនៃយុកសម័យឧស្សាហកម្ម។

កន្លងមកការផ្លាស់ប្តូរចំណាយដែលគួរអោយកត់សំគាល់ជាពិសេសសមត្ថភាពនៃការរៀបចំរបស់កសិករនៃកំលាំងពលកម្មដ៏ច្រើន គឺជាការបត់បែនល្អការចំនាយសមរម្យដៃរួមគ្នាជាសង្វាក់ផលិតកម្មជាមួយបរទេស។ គិតទៅការរួបរួមជាក្រុមមានលក្ខណខ្ពស់នៃការឆ្ពោះទៅមុខ ហើយជាក់ស្តែងមានការកើនឡើង មានភាពលំ អៀងមានទំហំឃើតតិចៗ។ ក្នុងកសិដ្ឋានទាំងនេះមានទំហំលាតសន្ធឹងធំទូលាយ យ៉ាងសមរម្យលើចំនាយដើម គឺការរួមគំនិតគ្នាច្រើន រឺ តិចជាង បើនិយាយទៅដល់

មាត្រដ្ឋានរបស់កសិដ្ឋាន វាពិបាកក្នុងការធ្វើឲ្យប្រសើរឡើង។ ប៉ុន្តែជាពិសេសពេលវេលាដែលអាចទៅរួចនិងសេចក្តីសំរេចពេញលេញការផ្តល់ដោយរបរកសិកម្ម ជា ច្រើនប្រភេទ ការគណនាទំហំសេដ្ឋកិច្ចជាអតិប្បរមានៃការផលិតវាមិនអាចផ្តល់នៅអ្វីដែលអ្នកប្រើប្រាស់ចង់បានទេ។

## ១.៤.កម្មវត្ថុនៃគោលនយោបាយកសិកម្ម ( The Objective of Agricultural Policy )

គោលនយោបាយកសិកម្មក៏ដូចជាទិដ្ឋភាពផ្សេងៗទៀតនៃគោលនយោបាយសេដ្ឋកិច្ចដែរគឺវាពឹងផ្អែកទៅនឹងកម្មវត្ថុនៃគោលនយោបាយជាក់ស្តែងរបស់ប្រទេស។ ជារួមកម្មវត្ថុនៃគោលនយោបាយកសិកម្មគឺមានដូចខាងក្រោម៖

1. ថែរក្សាស្ថេរភាពនៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដើម្បីជំរុញកំណើននិរន្តភាពកសិកម្មឲ្យធំទូលាយជាមួយនឹងតួនាទីដឹកនាំក្នុងវិស័យឯកជន
2. ជំរុញតួនាទីកសិកម្មក្នុងខឿនសេដ្ឋកិច្ចជាតិ និងជំរុញវលកថ្មីនៃកសិកម្មក្នុងបរិបទនៃសេរីភាវូបនីយកម្មកសិកម្ម
3. ថែរក្សាអតិបរិមានៃកម្លាំងពលកម្មក្នុងវិស័យកសិកម្ម
4. ថែរក្សាកម្រិតជាក់លាក់នៃស្វ័យគ្រប់គ្រាន់នៃស្បៀងអាហារ
5. ថែរក្សាការលើកស្ទួយចំណូលតាមជនបទ
6. ជំរុញឲ្យមានប្រសិទ្ធភាពផលិតកម្មកសិកម្ម និងម៉ាឃីតជីង និងម៉ាឃីតជីងក្នុងឱកាសថ្មីជាមួយអង្គការពាណិជ្ជកម្មពិភពលោក និងតីផ្សាររបស់សហគមន៍សេដ្ឋកិច្ច
7. លើកកម្ពស់ការអភិវឌ្ឍន៍តាមជនបទ និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា

## ១.៥.ប្រភេទសំខាន់ៗនៃគោលនយោបាយកសិកម្ម

ការបែងចែករវាងផ្នែកកសិកម្ម និងមិនមែនកសិកម្ម។ ទីផ្សារ និងផលិតកម្មនឹងផ្នែកផ្សេងដែលតម្រូវឱ្យការវិនិយោគប្រជាកសិករមានចំណូលប្រែប្រួលទទួលបានចំណូលទាប។ នៅក្នុងបណ្តាប្រទេសអភិវឌ្ឍន៍ដូចជា អឺរ៉ុបបែកខាងលិច និងអាមេរិចខាងជើងមានការជឿនលឿន ផ្នែកបច្ចេកទេសខ្លាំងទៅនឹងផលិតកម្ម វាលឿនជាងតម្រូវការដែលនាំឱ្យមានថ្លៃទាប ហើយនឹងចំណូលច្រើន នៅក្នុងករណីខ្លះ ធម្មជាតិជីវសាស្ត្រធ្វើមានភាពមិនទៀងទាត់នៅ ក្នុងផលិតកម្មដែលជាហេតុនាំឱ្យចំណូលប្រែប្រួល ហេតុនេះចំណូលរបស់ប្រជាកសិករប្រែប្រួលទៅតាមនោះដែរ នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍មិនសូវមានថវិកានៅដៃច្រើនដែលជាបញ្ហាប្រសិនបើផលិតកម្មកសិកម្ម។

ប្រភេទគោលនយោបាយកសិកម្ម រដ្ឋាភិបាលបានផ្តល់គោលនយោបាយកសិកម្មចំនួន ៣ ៖

១.គោលនយោបាយថ្លៃ

២.គោលនយោបាយរចនាសម្ព័ន្ធ

៣.គោលនយោបាយទីផ្សារ

**គោលនយោបាយថ្លៃកសិកម្ម** គឺជាប់ទាក់ទងទៅនឹងតម្លៃប្រជាកសិករទទួលបាន សម្រាប់ផលិតផលរបស់គាត់ និងតម្លៃនៅជំហានផ្សេងក្នុងការបែងចែក។ ទិសដៅគោលនយោបាយថ្លៃអាចផ្សេងៗគ្នា ហើយនឹងទំនិញផ្សេងៗគ្នា។ យើងអាចមានបំណងប្រាថ្នាទៀងទាត់ ការកើនឡើងថ្លៃ ចំណូល និងតម្លៃលក់រាយធ្លាក់ចុះចំពោះអ្នកប្រើប្រាស់។ ហេតុផលផ្សេងៗពិពណ៌នាដូចខាងក្រោម។

តម្លៃផលិតផលកសិកម្ម អាចប្រែប្រួលដែលជាហេតុនាំឱ្យប្រែប្រួលចំណូលកសិករ ឬក្នុងករណីខ្លះទៀត នៅក្នុងប្រទេសខ្លះទៀតអាស្រ័យការនាំចេញដើម្បីដោះដូររូបិយវត្ថុ។ ដំណើរប្រែប្រួលបម្រើឱ្យគោលបំណងសេដ្ឋកិច្ច។ ទោះជាយ៉ាងណាក៏ដោយ គឺស្ថិតនៅទាបសម្រាប់ការលក់រាយ។ តម្លៃការលក់រាយបានកំណត់នូវចំណូលកសិដ្ឋាន តម្លៃឧបត្ថម្ភ គឺតែងតែមិនសម្រេចគោលដៅនោះទេ នៅក្នុងបណ្តាប្រទេសអភិវឌ្ឍន៍ វាអាចជាស់តឿនហេតុផលនៃការផលិត នៅចក្រភពអង់គ្លេស នូវតម្លៃទាបបំផុតស្របទៅតាមលក្ខខណ្ឌការរស់នៅប្រជាកសិករ និងអ្នកធ្វើការនៅក្នុងវិស័យកសិកម្ម និងវាគ្រប់គ្រាន់សម្រាប់ការផ្តល់មូលធនវិនិយោគក្នុងវិស័យឧស្សាហកម្ម។ វិស័យកសិកម្មនៅអាឡឺម៉ង់ខាងលិច នៅក្នុងឆ្នាំ ១៩៥៥ រដ្ឋបានអះអាងថា កសិកម្មមានតួនាទីការអភិវឌ្ឍនៃសេដ្ឋកិច្ចប្រទេសអាឡឺម៉ង់។ ហើយប្រជាជនអាចមានលទ្ធិភាពផ្គត់ផ្គង់កសិផលជាច្រើន សម្រាប់អាហារ និងលក្ខខណ្ឌកសិកម្ម និងសេដ្ឋកិច្ច និងគុណសម្បត្តិច្រើន ប្រៀបធៀបទៅនឹងវិស័យដទៃ និងជួយឱ្យបានផលិតភាពរបស់ខ្លួន។ ប្រទេសខ្លះកាត់បន្ថយសម្រាប់គោលនយោបាយកសិកម្ម។ កសិកម្មនៅប្រទេសស្វីសនៅឆ្នាំ១៩៥២ រដ្ឋថាគួរតែថ្លៃគម្រូការចំណាយជាមធ្យម នៅតម្លៃទ្រព្យសម្បត្តិប្រជាកសិករ នៅក្រោមលក្ខខណ្ឌធម្មតា។ សហរដ្ឋអាមេរិកចាប់ប្រើតម្លៃនៅក្នុងប្រវត្តិកាលដូចជាមូលដ្ឋាននៃតម្លៃកសិកម្មរបស់ខ្លួន គឺរវាងតម្លៃកសិកម្ម និងឧស្សាហកម្ម នៅអំឡុងឆ្នាំ ១៩១០ ទៅ ១៩១៤។ នៅក្នុងការអនុវត្ត ទោះជាយ៉ាងណា ក៏ដោយ នេះជាគំនិតអះអាងថាភាពដូចគ្នារវាងតម្លៃកសិកម្ម និងឧស្សាហកម្ម ដែលមាននៅមុនពេល សង្គ្រាមលោកលើកទី ១ ដែលយកលំនាំគោលដៅជាច្រើនមានការថែរក្សា។

**គោលនយោបាយរចនាសម្ព័ន្ធ** គឺគម្រូទាំងនោះធ្វើឱ្យប្រសើរឡើងនូវរចនាសម្ព័ន្ធវិស័យកសិកម្ម។ ទំហំប្លង់ និងសំភារៈកសិកម្ម, ហេដ្ឋារចនាសម្ព័ន្ធជនបទ អគ្គិសនី ការផ្គត់ផ្គង់ទឹក ការអប់រំ និងសេវាក្រុមប្រឹក្សាមធ្យោបាយសម្រួលផ្សេងៗ នៅតាមទីជនបទ។ ស្រដៀងគ្នានេះដែរ គោលនយោបាយវិស័-យកសិកម្ម គឺមិនដឹងទូលំទូលាយនៅក្នុងបណ្តាឧស្សាហកម្ម។ ទោះបីជាយ៉ាងណាក៏ដោយ បណ្តាឧស្សាហកម្មភាគច្រើនធ្វើការកែតម្រូវទៅតាមកាលៈទេសៈថ្មីៗ គឺភាគច្រើនតាមរយៈការរុញច្រានដោយសេដ្ឋកិច្ច។ នៅក្នុងវិស័យកសិកម្មវិធីជាច្រើន គឺបង្ហាញពីភាពពិបាក និងភាពខុសគ្នាផ្សេងៗនៃ "Business of family" កសិកម្មតាមបែបធម្មជាតិ និងម្យ៉ាងទៀតកសិដ្ឋានភាគច្រើន ធ្វើកសិកម្ម ត្រូវការប្រើប្រាស់តំបន់ដែលមានផ្ទៃដីធំទូលាយ។

**គោលនយោបាយទីផ្សារ** វាជាប់ទាក់ទងទៅនឹងការបែងចែងរវាងកសិករ និងអតិថិជន។ គោលដៅជាច្រើនដើម្បីពង្រីក ១ទីតាំងថ្លៃនៃកិច្ចព្រមព្រៀងរបស់ប្រជាកសិករ។ ឧទាហរណ៍លើកទឹកចិត្តក្នុងការជំរុញបណ្តាអង្គភាពត្រួតពិនិត្យ ទីផ្សារអ្នកផលិត ឬជំរុញគុណភាព និងអនាម័យផលិតផលជំរុញ

ប្រសិទ្ធភាពលក់ដុំ និងលក់រាយគ្មានវិធីណាមានប្រសិទ្ធភាពជាងការជុំរុញក្នុងផ្នែកសេដ្ឋកិច្ច (See chapter 9)

នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ប្រព័ន្ធនៃការបែងចែកចំណីអាហារ គឺមិនមានប្រសិទ្ធភាព បើប្រៀបធៀបជាមួយបណ្តាប្រទេសនូវបច្ចឹមប្រទេស (North-West Europe) និងអាមេរិចខាង ជើង។ ប្រទេសអភិវឌ្ឍន៍ទាំងនោះ មានការប្រព័ន្ធនៃការបែងចែកយ៉ាងពិតប្រាកដនៅលើវិធីការបែង ចែក។ នៅក្នុងករណីខ្លះរដ្ឋត្រូវតែលូកដៃជាចាំបាច់ក្នុងការ ផ្តល់ជំនួយ និងរៀបចំដើម្បីប្រមូលទិញពី កសិករ។ ការដឹកនាំវាដូចជានៅពេលលក់នូវបសុសត្វ ទឹកដោះគោ ឬបន្លែ ធ្វើលិខិតអនុញ្ញាត្តិផងដែរនៅលើទីផ្សារ។ ភាពខុសគ្នារវាងថ្លៃ និងគោលនយោនបាយទីផ្សារ នៅក្នុងការអនុវត្ត គឺមិនតែងតែត្រឹមត្រូវនោះទេ តាំងពីអង្គការចាត់តាំងនូវការបែងចែកនូវតួនាទីនានា ដូចជាទីផ្សារកសិកម្មអង្កេសវាក៏ប្រើប្រាស់នូវគោលនយោបាយថ្លៃឧបករណ៍កសិកម្ម។ វាពិតជាសារៈសំខាន់ ទោះជាយ៉ាងណា ភាពល្បីល្បាញនៅក្នុងគោលការ នៃថ្លៃគម្រូ និងការតំឡើងថ្លៃ ជាធម្មតានៅក្នុងមធ្យោបាយខ្លះ ការដាក់ព្រំដែននូវការផ្គត់ផ្គង់ និងថ្លៃគម្រូដើម្បីជំរុញប្រសិទ្ធភាពនៃទីផ្សារ។

## ១.៦.ការអភិវឌ្ឍន៍គោលនយោបាយសេដ្ឋកិច្ច និងលទ្ធិ

គោលនយោបាយកសិកម្ម មិនអាចក្នុងការដាច់ចេញពីគោលនយោបាយសេដ្ឋកិច្ចទូទៅ។ ក្នុងពេលបច្ចុប្បន្ន "mixed" បណ្តាប្រព័ន្ធសេដ្ឋកិច្ចនៅក្នុងបណ្តាប្រទេសនានា។

គោលការណ៍ការអភិវឌ្ឍន៍គោលនយោបាយសេដ្ឋកិច្ច និងកសិកម្ម គឺមិនមានភាពទាក់ទិន្នគ្នាទៅនឹងការចូលរួមការចូលរួមបញ្ចូលអំពីគោលនយោបាយសេដ្ឋកិច្ចជាទូទៅទេ។ បច្ចុប្បន្នភាពនៃប្រពន្ធ័សេដ្ឋកិច្ចដាក់បញ្ចូលក្នុងប្រទេសជាច្រើននៃសហភាពអឺរ៉ុបខាលិច គឺជាលទ្ធិផលទស្សនៈវិស័យអភិវឌ្ឍន៍ហើយនោះ គឺទម្រង់ផ្សេងៗគ្នានៃប្រពន្ធ័សេដ្ឋកិច្ច ដែលទទួលបានភាពជោគជ័យ។ ក្នុងការអភិវឌ្ឍន៍នេះ លទ្ធិសេដ្ឋកិច្ចបច្ចុប្បន្ន គឺជាផ្នែកមួយដែលបានឆ្លុះបញ្ចាំងប្រព័ន្ធដែលមានស្រាប់។ ការចាប់ផ្តើមនៃសម័យទំនើបក្នុងសតវត្សន៍ទី ១៧ ដល់ ១៨ លទ្ធិដែលមានក្នុងប្រទេសអឺរ៉ុបជាច្រើន គឺជាពាណិជ្ជកម្ម (MERCANTILISM) លទ្ធិនេះបានត្រួតត្រារបស់រដ្ឋទៅលើសេដ្ឋកិច្ច ដែលមានគោលបំណងបង្កើតសហគ្រាសក្នុងប្រទេសរបស់ខ្លួន ក្នុងគោលបំណងផ្សេងៗទៀត។ ចំនួននៃគោលការណ៍នៃអំឡុងពេលនោះ គឺមានកម្លាំងចលករដ៏ទំនើប។ ឧទាហរណ៍ នៅក្នុងប្រទេសអង់គ្លេស cornlawsបានការពារជាស្រូវសាលី ដោយវិធីជាច្រើននៃតម្រូវការដ៏សំខាន់មួយ នៅពេលប្រមូលទាបហើយតម្លៃដែលឆ្លើយតបខ្ពស់តម្រូវការត្រូវបានបោះបង់ចោលនៅពេលដែលតម្លៃទាប ការនាំចេញ ត្រូវបានធ្វើ ឡើង។ បញ្ហានៃទីផ្សារសម្រាប់នៃគ្រឿងធុញជាតិ ត្រូវបានណែនាំនៅក្នុងឆ្នាំ ១៩៦២ នៅក្នុង សមាគមន៍អឺរ៉ុប (CEI) ហើយបានលើកឡើងគោលការណ៍ដូចៗគ្នា មិនមែនដោយសារគ្មានភាពស្មើៗគ្នាដែលអ្នកសេដ្ឋកិច្ចវិទូបានបង្កើតក្នុងពាណិជ្ជកម្មទំនើប (neo-mercantilism)។ ពាណិជ្ជកម្ម(mercantilism) គឺតែងតែគាំទ្រ សហគ្រាសនៃការចំណាយទៅលើផ្នែកកសិកម្មហើយជាការប្រតិកម្មមួយនៅទីនោះដែលបានធ្លាក់មកដល់ប្រទេសបារាំង នៅចុងសតវត្សទី ១៨ នៃលទ្ធិ Physiocrats គឺជាអ្នកដែលបានទាក់ទិន្នទៅនឹងផ្នែកកសិកម្ម ក៏ដូចជាការងារដែលផលិតតែឯង។ សកម្មភាពសេដ្ឋកិច្ចផ្សេងៗទៀតជាពិសេស

ពាណិជ្ជកម្ម គឺបានផ្តោតទៅលើផលិតដែលបានបដិសេធន៍ដោយសេដ្ឋកិច្ចសម័យទំនើប ប៉ុន្តែនៅតែមានការយល់ដឹងក្នុងហេតុការណ៍លើគោលការណ៍កសិកម្ម។

ការចាប់ផ្តើមនៃបដិវត្តន៍ឧស្សាហកម្មលទ្ធិសេដ្ឋកិច្ចសេរីនិយម ត្រូវបានអនុម័តយ៉ាងគួរឱ្យកោតសរសើរជនជាតិអង់គ្លេស ត្រូវបានបម្រុងសម្រាប់ប្រទេសជាច្រើន។ រវាងការបំបាត់ច្បាប់ Cornlaws នៅក្នុងឆ្នាំ ១៨៤៦ ហើយនឹងការគេចពន្ធនៃគ្រឿងធុញជាតិដោយប្រទេសអាឡឺម៉ង់ ដែលពាណិជ្ជកម្មអន្តរជាតិស្ទើរតែមិនបានទទួលអ្វីទាំងអស់ ហើយសកម្មភាពសេដ្ឋកិច្ចរបស់រដ្ឋត្រូវបានកាត់បន្ថយ។ យោងទៅតាមសេដ្ឋកិច្ចវិទូនិយម អ្វីដែលល្អបំផុតនោះ គឺត្រូវបានបម្រើនៅពេលអ្នកប្រើប្រាស់ត្រូវការរបស់ពួកគេដូចជា សម្ភារៈឧស្សាហកម្មក្នុងតម្លៃទីផ្សារមួយដ៏ទាបបំផុត មិនថាក្នុងប្រទេសក្រៅប្រទេសទេ។ ដូចនេះពួកគេមានភាពតឹងរឹងប្រឆាំងទៅនឹងពាណិជ្ជកម្មអន្តជាតិ និងការចលាចលនៅក្នុង ទីផ្សារ។

ទ្រឹស្តីនៃពាណិជ្ជកម្មនេះត្រូវបានបង្កើតដោយសេដ្ឋកិច្ចវិទូ Friedrich List (១៧៨៩ ដល់ ១៨៤៦)។ គាត់បានពីតម្រូវការនៃសហគ្រាសមួយទៅក្នុងប្រទេសមួយ សម្រាប់ការពារប្រឆាំងការបង្កើតសហគ្រាសបរទេស ហើយនឹងទំនួលខុសត្រូវរបស់រដ្ឋ អំពីការបង្កើតហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម។ គំនិតនេះបានបន្តទៅដល់ចុងនៃស.តទី ១៩ នៅពេលដែលប្រទេសអាឡឺម៉ង់បានធ្វើការណែនាំពន្ធនាំចូលសម្រាប់ផលិតផលសហគ្រាស និងម្ហូបអាហារ។ ដែលរឹងមាំជាងនេះទៅទៀត List ខ្លួនរបស់គាត់បានគាំទ្រពាណិជ្ជកម្មសេរីសម្រាប់វិស័យកសិកម្មមួយ ដែលមានវត្តមានក្នុងប្រទេសហើយមិនចាំបាច់បង្កើតឡើងទេ។

អំឡុងពេលគ្មានសកម្មភាពសេដ្ឋកិច្ចឆ្នាំ ១៩៣៣ បានធ្វើការណែនាំដំណាក់កាលថ្មីមួយ ក្នុងគោលនយោបាយសេដ្ឋកិច្ច ជាពិសេសគោននយោបាយនៃប្រទេសខាងលិចជាច្រើន។ ជាមួយនឹងភាពលើកឡើងនៃចក្រភពអង់គ្លេសប្រទេសជាច្រើន បានណែនាំអ្នកការពារគោលការណ៍កសិកម្ម ប៉ុន្តែបញ្ហាទាំងនេះត្រូវបានផ្ទុកដោយពន្ធនូវការនាំចូល។ ភាពគ្មានសកម្មភាពសេដ្ឋកិច្ចនេះ មិនបាននាំទៅដោយការអន្តរាគមន៍ទៅរដ្ឋក្នុងទីផ្សារកសិកម្ម ទោះបីក្នុងប្រទេសជាច្រើន ដែលមានប្រពៃណីសេរីនិយមដូចជា អង់គ្លេស អាមេរិច ឬហៅថាលោកខាងលិច។ ការនាំចូលផលិតផលកសិកម្ម ត្រូវបានត្រួតត្រាយ៉ាងតឹងរឹងដោយមធ្យោបាយពាណិជ្ជកម្មដោយផ្តាច់មុខរបស់រដ្ឋ Quotas នាំចូល និងនាំចេញគឺត្រូវបានធ្វើឡើងនៅក្នុងទីផ្សារក្នុងប្រទេសតម្លៃត្រូវបានរក្សាតាមរយៈការគាំទ្រ ការទិញដោយភ្នាក់ងាររបស់រដ្ឋភ្នាក់ងាររបស់ក្រុមហ៊ុន ហើយជួនកាល គឺជាបញ្ហារបស់សហគ្រិនដែលស្របច្បាប់ ក្នុងការប្រើប្រាស់ផ្នែកភាគហ៊ុនមួយដ៏ជាក់លាក់នូវការផលិតក្នុងស្រុក។ ផលិតកម្មកសិកម្ម គឺត្រូវបានត្រួតត្រាដោយមធ្យោបាយនៃការកំណត់របស់ Quotas អំឡុងពេលឆ្នាំ ១៩៣៩ ដល់ ១៩៤៥ ផលធៀបហើយនិងត្រួតត្រារបស់រដ្ឋនៃទីផ្សារម្ហូបអាហារ ត្រូវបានអនុវត្តហើយបានបន្តរហូតមកដល់សង្គ្រាមទៀត។ វាត្រូវបានបន្តរហូតមកដល់ចក្រភពអង់គ្លេស កន្លែងដែលធ្វើផលធៀបដោយភាពជាសង្វាក់ គឺត្រូវបានចាត់ទុកជារឿងមួយ ពិបាកជាងការប្រៀបធៀបដោយការសរុបលុយ។ នៅក្នុងឆ្នាំ ១៩៤៥ ការធ្វើផលធៀបនេះត្រូវបានបញ្ចប់ ហើយពាណិជ្ជកម្មផលិតផលម្ហូបអាហារត្រូវបានងាកទៅរកក្រុមហ៊ុនឯកជនក្នុងករណីមួយស្ថិតក្រោមកាត្រួតត្រារបស់ទីផ្សារ។ កសិកម្មអង់គ្លេស ត្រូវបានបន្តការពារដ៏សំខាន់

ដោយមធ្យោបាយកង្វះការចំណាយដែលបង្កើតដោយភាពផ្សេងៗគ្នា រវាងតម្លៃដែលបានធានាហើយតម្លៃទីផ្សារបច្ចុប្បន្ន។

ការផ្លាស់ប្តូរនៅពាក់កណ្តាលឆ្នាំ ១៩៥០ ពីគ្រប់គ្រងទៅលើសម្ភារៈអាហារនៃទីផ្សារសេរី គឺជារឿងរាវដ៏ជោគជ័យមួយ នៃប្រវត្តសាស្ត្រសេដ្ឋកិច្ចក្រោយសង្គ្រាមរបស់អង់គ្លេស។ អ្នកប្រើប្រាស់បានទទួលសេរីភាពជាច្រើន នៃជម្រើសហើយអ្នកផលិតបានសិក្សាដើម្បីផលិតសម្រាប់តម្រូវការទីផ្សារ។

ទោះបីយ៉ាងណាក៏ដោយ ការងារដោយជោគជ័យនៃការរួមបញ្ចូលគ្នារវាងទីផ្សារសេរី ការចំណាយខ្វះខាត គឺមានគោលបំណង ដើម្បីហេតុការណ៍បច្ចុប្បន្នចក្រភពអង់គ្លេស គឺជាអ្នកចូលដ៏ ធំមួយនៃផលិតផលកសិកម្មស្ទើរគ្រប់ប្រភេទ ហើយទីផ្សារពិភពលោក ត្រូវបានងាកពីភាពភ័យខ្លាចបន្ទាប់ពីសង្គ្រាមទៅលើការកើនឡើងផលិតផល។ ខណៈដែលលក្ខខណ្ឌបានបង្ហាញលើទីផ្សារពិភពលោកវាបានបង្ហាញយ៉ាងច្បាស់ទៅលើការចំណាយ។ ដីខ្វះខាតក៏ព្រោះតែគ្រោះថ្នាក់នៃការធានាយ៉ាងបើកចំហរ មួយការធ្លាក់ទៅនឹងតម្លៃទីផ្សារក៏អាចឈានទៅរក ការបាត់បង់ថវិកាយ៉ាងមុតស្រួចនៅក្នុងការចំណាយ។ គោលបំណងនេះ បានចាប់ផ្តើមបង្កើតដើម្បីកំណត់តម្លៃទីផ្សារ ដោយការណែនាំអំពី Quotas នាំចូលដ៏ការអនុវត្តតម្រូវការទៅលើការនាំចូល ប្រសិនបើថ្លៃនៅក្រោយ កម្រិតអាប្បបរិមា។ រវាងឆ្នាំ ១៩៦២ និងឆ្នាំ ១៩៦៤ ចំណុចក្រិតនៅលើបន្ទាត់នេះ ត្រូវបានណែនាំសម្រាប់ butter, bacon, and cereals។

គោលនយោបាយអង់គ្លេស បានឆ្លងកាត់នៅការផ្លាស់ប្តូរជាច្រើន នៅពេលវាបានចូលរួម សហគមន៍អឺរ៉ុប នៅក្នុងឆ្នាំ ១៩៧០ ហើយការផ្លាស់ប្តូរបន្តិចម្តងៗ ជម្រុញសមាគមន៍នេះប្រទេសសមាជិកដំបូងតែងតែអាស្រ័យយ៉ាងខ្លាំង ទៅលើពន្ធនាំចូល និងការត្រួតពិនិត្រជាងការចំណាយដ៏ខ្វះខាតដើម្បីផ្គង់ផ្គង់ថ្លៃហើយគោលការណ៍រួមរបស់កសិកម្មបានអនុវត្តឆ្នាំ ១៩៦០ ត្រូវបានពឹងផ្អែកយ៉ាងសំខាន់ទៅលើតម្រូវការនាំចូលហើយអន្តរាគមន៍ទៅលើការទិញ។ ទោះបីយ៉ាងណាក៏ដោយ ជាតិឬ សហគមន៍នៃការចំណាយ ក៏ខ្វះខាតនេះត្រូ វបានបង្កើតសម្រាប់ទំនិញមួយ ចំនួននៃការកើនឡើងនៃ សំណួររបស់ (cap)។

ការវិភាគថ្លៃ ដែលស្ថិតនៅក្រោមគោលការណ៍ផ្សេងៗគ្នា នៃវិស័យកសិកម្ម ប្រទេសជាច្រើនប្រភេទផ្សេងៗ នៃការបង្កើតវិស័យកសិកម្ម។ មានផលិតផលដែលថ្លៃ របស់វាមានតម្លៃស្ថិតថេរដោយសាររដ្ឋហើយ និងទីផ្សារត្រូវបានត្រួតត្រាយ៉ាងតឹងរឹង ដោយអង្គការផ្តាច់មុខ។ សកម្មភាពនេះ គឺរួមនៅក្នុងយុទ្ធកណ្តាលនៃសេដ្ឋកិច្ច ប៉ុន្តែភាពស្រដៀងទៅនឹងស្ថានភាពនេះ សម្រាប់ទីផ្សារទឹកដោះគោ របស់ចក្រភពអង់គ្លេស។ មានផលិតផលជាច្រើនប្រភេទ អេឡិចត្រូនិច គ្មានការអន្តរាគមន៍ពីរដ្ឋទេ។ មានផលិតផលដែលតម្លៃទីផ្សារត្រូវបានរក្សាដោយការនាំចូល ហើយនឹងអន្តរាគមន៍ហើយការទិញ។ ផលិតផលដែលអ្នកផលិតថ្លៃនៃអ្នកផលិត គឺបានរក្សាចំណាយតិចតួច។

ដំណើរនៃការបង្កើតតម្លៃនៅក្នុងប្រភេទផ្សេងៗ នៃស្ថានភាពនេះអាចត្រូវបានបញ្ជាក់ ដោយជំនួយពីការវិភាគនៃទស្សនៈទាន ក្នុងមេរៀនតទៅនេះ។ ការវិភាគអាចផ្តើមជាមួយទីផ្សារសេរី ដើម្បីពន្យល់អំពីគោលការណ៍ទូទៅ ប៉ុន្តែគោលនយោបាយនៃភ្នាក់ងាររដ្ឋ និងមន្ត្រីទីផ្សារ ត្រូវបានត្រួតពិនិត្យជាមួយវិភាគដូចគ្នា។ ទោះជាយ៉ាងណា ការវិវត្តយ៉ាងល្អនៃការវិភាគថ្លៃកសិកម្ម គឺជាការវិភាគតម្រូវការ

ដែលបានអភិវឌ្ឍន៍ទៅការពិសោធផ្ទាល់ និងទ្រឹស្តី។ ការវិភាគតម្រូវការប្រើប្រាស់បច្ចេកទេសស្ថិតិ ដើម្បីប្រមាណទំនាក់ទំនងរវាងការប្រើប្រាស់ដើមទុន នៃផលិតផលជាក់លាក់ជាលក្ខខណ្ឌទំនាក់ទំនង់នេះភាពឈឺថ្លៃហើយចំណូលត្រូវបានប្រើប្រាស់ក្នុងជំនួញនៃការប៉ាន់ប្រមាណទៅ ថ្ងៃអនាគត។ នៃការផ្លាស់ប្តូរជាច្រើនផ្សេងៗគ្នា ក្នុងរបៀបដែលមិនអាចរំពឹងទុកដែលគំពោងទាំងនេះតែងតែមានបំណងទៅនឹងផ្នែកដែលខុសឆ្គង។

## ១.៧.ប្រព័ន្ធនៃការបែងចែក

ការរៀបចំផលិតផលកសិកម្មនៅរងផលវិបាកតិចតួចដែរ ក្នុងសេដ្ឋកិច្ចសម័យថ្មី។ ប្រព័ន្ធនៃការបែងចែកគឺការប្រមូលផ្តុំប្រភេទនៃដំណើរការនិងផលិតផលកសិដ្ឋានដែលរើសជាសមាជិកពួកគេទាំងមូល និងពួកគេតម្រង់ទៅលើពាណិជ្ជកម្មលក់រាយ។ កត្តាជាច្រើនទាំងនេះផងដែរ ត្រូវតែអនុវត្តន៍សម្រាប់ការផលិតផលិតផល ប៉ុន្តែជាញឹកញាប់នៅក្នុងការផលិតក្នុងសហគ្រាសបាននាំយកពីកន្លែងដោយខ្លួនឯង។ ការធ្វើការតាម ប្រពៃណីបានអនុវត្តន៍ដោយកសិករផ្ទាល់ ដែលបានធ្វើដំណើរចូលទៅជិតក្នុងការបញ្ចាលក់ផលិតផល។ ទោះជាសព្វថ្ងៃនេះប្រទេសកំពង់អភិវឌ្ឍន៍ជាច្រើនបានធ្វើរួចហើយ ប៉ុន្តែនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចវាគឺមានការចុះខ្សោយកម្លាំងពលកម្មផងដែរ និងទំនងជាការទុកផលិតផល ពីរឬបី ប្រភេទដូចជាស៊ុត។ ប្រព័ន្ធនៃការបែងចែកទាំងនេះបានអភិវឌ្ឍន៍ផលិតផលកសិកម្មផ្សេងពីគ្នា ជាញឹកញាប់មិនមែនផលិតករ។ ករណីជាច្រើន ផលិតករបាន ចូលរួមជាមួយគ្នានៅរបៀបរៀបរយបង្កើតការសហកាណ៍ការរៀបចំលក់ ប៉ុន្តែមានគំនិតខ្វែងគ្នាពីការរៀបចំលក់ នៃសហគ្រាសឧស្សាហ៍កម្ម ដូចនេះរបរកសិកម្មរបស់ពួកគាត់មានការជះឥទ្ធិពលតិចតួចនៅក្នុងកម្រិតនៃការផលិត។ បន្ថែមលើនេះការបង្កើតទ្រង់ទ្រាយក្រុមដោយកសិករស្ម័គ្រចិត្ត ការរៀបចំត្រូវបានធ្វើអន្តរាគមន៍នៅក្នុង ដំណើរការទីផ្សារ។ ប្រហែលនេះជាការរៀបចំគ្រាន់តែបង្ហាញដោយផលិតករក្នុងករណីផ្សារចក្រភពអង់គ្លេស និងបារាំង "ការបង្កើតក្រុមផលិតករ" ឬពួកគេអាចបង្ហាញពីផលិតករអ្នកចែកចាយនិងអ្នកប្រើប្រាស់ក្នុងករណី ការចញ្ចឹមសត្វនៅចក្រភពអង់គ្លេស ឬប្រទេសហូឡង់ "ផលិតផលកើតឡើង" ឬពួកគេអាចក្លាយពីពាក់កណ្តាល រដ្ឋាភិបាល ដូចជាករណីសិក្សានៅទំនិញសាជីវកម្មឥណទាននៅ សហរដ្ឋអាមេរិច។ ក្នុងការអនុវត្តន៍ការសហការណ៍គ្នា ឬ កំណត់ដោយល័ក្ខខណ្ឌន្តិកៈ ការបង្កើតក្រុមចំនួនដ៏ធំនៃការប្រកួតប្រជែងរបស់កសិករ ប្រឈមមុខ នូវចំនួននៃចំនួនការបែងចែក ហើយប្រហែលអាចមានការចុះខ្សោយនៅស្ថានភាពបញ្ចុះថ្លៃ។

## ១.៨.ការមិនមានការផ្លាស់ប្តូរនៃការផ្គត់ផ្គង់

ការរងផលពិបាកបន្ថែមនៃការរៀបចំពាណិជ្ជកម្មខ្នាតតូចនៃកសិកម្មគឺមិនមានការផ្លាស់ប្តូរនៃការផ្គត់ផ្គង់ ឆ្លើយតបទៅនឹងការផ្លាស់ប្តូរថ្លៃ និងជាពិសេសការធ្លាក់ចុះថ្លៃ។ ភាពមិនជាក់លាក់នៃកសិផលរបស់កសិករមានលក្ខណៈជាឯកជន ដូចច្នេះថ្លៃគឺគ្រាន់តែផ្តល់ឲ្យការសំរេចចិត្តទោះចំណាយជាច្រើន ឬតិចជាង ផលិតផលទាំងនោះមានចំនួនដូចគ្នា។ នេះគឺមិនមែនគ្រាន់តែជាករណី សហគ្រាស

ឧស្សាហកម្ម ដែលជាញឹកញាប់មានការចែកចាយជាច្រើន និងភាពគ្រប់គ្រងដែលអាចធ្វើឱ្យមានឥទ្ធិពលលើថ្លៃនៃទីផ្សារ។

កសិករបានផ្លាស់ប្តូរនូវគុណភាពផលិតផលតិចតួចនៃការផ្តល់ថ្លៃ ប៉ុន្តែការតបតរបស់គាត់គឺលំអៀង អាចមានគុណភាពខុសគ្នាយោងទៅតាមការផ្លាស់ប្តូរថ្លៃទោះជាផលិតផលលក្ខណៈឯកជនឬផលិតផលទាំងមូល។ នៅពេលថ្លៃនៃផលិតផលមួយកើនឡើងនិងការធ្លាក់ចុះផ្សេងទៀត កសិករចាប់ផ្តើមផលិតផលដែលមាន សក្តានុពលមានកំណត់ ដូចជាកសិដ្ឋានលើកូនភ្នំ ដែលគ្រាន់តែអាចបង្កើនឃ្លាំងចិញ្ចឹមសត្វចៀមនិងគោក្របី។ ប៉ុន្តែជាទូទៅគឺការកែប្រែការនាំចេញរបស់កសិដ្ឋានអាចទៅរួច និងប្រឈមមុខនឹងការផ្លាស់ប្តូរនូវសមាសភាពនៃផលិតផលកសិកម្មមានការកើនឡើងយ៉ាងសំបើម។

ទោះបីជាយ៉ាងណាក៏ដោយស្ថានភាពខុសគ្នានៅពេល ដែលកម្រិតថ្លៃទូទៅផលិតផលកសិកម្មធ្លាក់ចុះ ឬកម្រិតថ្លៃដែលបង្ហាញតាមក្រោយសំណួរក្នុងករណីនេះគឺមិនមែន គ្រាន់តែជាសមាភាពនៃផលិតកម្មប៉ុន្តែទោះជាវាចំណាយទៅផលិតផលទាំងអស់និងប្រសិនបើចំនួនដូចនេះ។ វាមិនមែនគ្រាន់តែជាសហគ្រាសនៃកសិកម្ម ដែលមានសំណើររបស់ពួកគេខ្លួនឯង នូវសំណួរទាំងនេះមានស្ថានភាពប្លែក គឺចំណាយប្រែប្រួល របស់ពួកគេដែលទិន្នផលតិចមិនធម្មតា។ ដោយហេតុថាលទ្ធផលនៃចំណាយ លើប្រាក់ឈ្នួលធំជាងមុខទំនិញក្នុងបញ្ជីសហគ្រាសឧស្សាហកម្ម។ ភាគច្រើនសហគ្រាសកសិកម្មមិនបានជួលអ្នកធ្វើការទាំងអស់ទេ ដូចនេះមិនមែនកាត់បន្ថយការផ្តល់ចំណាយដោយដកចេញម្លាំងពលកម្ម។

ថ្លៃដើមថេរ កសិកម្មមានគ្រឿងយន្តនិងការសាងសង់នៅរយៈពេលខ្លីតាំងពីប្រើប្រាស់គ្រឿងយន្តកសិកម្មបានថ្លៃតិចតួច ណាស់(ជាពិសេសនៅពេលមិនល្អ) កំឡុងពេលសាងសង់មិនអាចលក់ទាំងអស់ទេ។ អញ្ចឹង"តម្លៃទ្រព្យលែងប្រើ"នៃទ្រព្យនៃកសិកម្មគឺខ្សោយប្លែកពីធម្មតា។ ចំណាយប្រែប្រួលមានក្នុងរយៈពេលខ្លីគ្រាន់តែមានការចំណាយ លើមុខទំនិញការផ្គត់ផ្គង់វត្ថុ មានជីនិងការជួសជុល ការចំណាយលើទំនិញទាំងនេះមានការចុះថយ។ នៅពេលកសិដ្ឋានមានចំណូលធ្លាក់ចុះ និងមានការប្រឈមមុខជាធម្មតាក្នុងការស្រុតចុះសម្រាប់កសិករ ដោយធ្វេសប្រហែសក្នុងការជួសជុលនិងជីក្នុងដីថយចុះបណ្តើរ។ ប៉ុន្តែរយៈពេលដ៏វែងទទួលបានពីអាជីវកម្មច្រើនជាងការ ជានាទល់និងចំណាយប្រែប្រួលវាគឺផលិតកម្មផ្តល់ផលចំណេញឥតឈប់ឈរនៃពាណិជ្ជកម្ម អញ្ចឹងសម្រាប់កសិករ ភាគច្រើននៅចន្លោះផលិតកម្ម បន្តមិនផ្លាស់ប្តូរដោយគ្មានអ្វីជាក់លាក់និង ការបោះបង់ការធ្វើកសិកម្មទាំងអស់គ្នា។ កន្លងមកកសិករភាគច្រើនចូលចិត្តកសិកម្មតាមប្រពៃណី និងលើសពីនេះទៅទៀតការស្វែងរកដោយការលំបាកឬមិនអាចធ្វើបានជម្រើសផ្សេងអ្នកជិតខាងក្នុងកសិដ្ឋានជាទូទៅពួកគេចូលចិត្តរឹតបន្តឹងជុំវិញបន្តការផលិតរបស់ពួកគាត់។

ផលវិបាកគឺនៅពេលថ្លៃធ្លាក់ចុះយ៉ាងខ្លាំង នៅពេលដែលតម្រូវការរបស់ផលិតផលកសិកម្មធ្លាក់ចុះឬលទ្ធផល នៃបច្ចេកទេសជឿនលឿនការផ្គត់ផ្គង់កើនឡើងជាងតម្រូវការ។ នេះជាលក្ខណៈពិសេសដែលគួរឲ្យកត់សំគាល់ ក្នុងការស្រុតចុះនៅសត្សវត្សរ៍ ១៩៣០ នៅពេលលទ្ធផលភាគច្រើននៃផលិតផលកសិកម្មមានកម្រិតថេរ។ ថ្លៃនៃកសិកម្មជាច្រើនធ្លាក់ចុះបន្ទាប់ពីផលិតកម្មឧស្សាហកម្មនិងទិន្នផលបានថយចុះយ៉ាងខ្លាំង។

បញ្ហាស្រដៀងទៅនិងទម្រង់ខាងលើផងដែរ អាចត្រួតពិនិត្យមើលការប្រើប្រាស់ទុនឧស្សាហកម្មច្រើន ដូចជាជាតិគីមីនិងដែក ដែលបានទទួលបន្ទុកដោយចំណាយថ្លៃដើមថេរខ្ពស់ផងដែរ។ នៅក្នុងឧស្សាហកម្មវាមានការចំណាយច្រើនផងដែរ សម្រាប់កសិដ្ឋានលក្ខណៈឯកជនទៅបន្តការផលិតនៅពេលថ្លៃទាបបន្ទាប់ពីការបញ្ឈប់ ការផលិតទាំងអស់គ្នា ដូចនេះឱកាសនៅពេលដែលលទ្ធភាពតម្រូវការលើសយ៉ាងខ្លាំង ចាប់ផ្តើមការប្រកួត ប្រជែងការបញ្ចុះតម្លៃ។ ក្នុងការកម្មង់ ទៅកិច្ចខិតខំដើម្បីបង្ការថ្លៃ លប់បំបាត់ការកាត់បន្ថយប្រាក់ចំណេញក្នុង កសិដ្ឋានយ៉ាងធ្ងន់ធ្ងរក្នុងនេះវិស័យឧស្សាហកម្មជារឿយៗ បានបញ្ចូលក្នុងការចែងយ៉ាងជាក់លាក់ឬកិច្ចព្រម ព្រៀងទាំងស្រុងនៅការកំណត់ថ្លៃនិង រក្សាទិន្នផល(ទោះបីជានិយាយសំដៅរកបទពិសោធន៍ នៅពេលដែលការ ប្រកួតប្រជែងអន្តរជាតិ និងសមត្ថភាពលើសខ្លាំង កម្រិតនៃការថយចុះថ្លៃមួយចំនួនតែងកើនឡើង ឧទាហរណ៍ៈ ឧស្សាហកម្មដែកលើពិភពលោក នៅកំឡុងពេល ១៩៦៥-១៩៦៧ និងម្តងទៀតឆ្នាំ ១៩៧៥-១៩៨០)។ ក្នុងវិស័យកសិកម្មចំនួននៃសហគ្រាស គឺដូចគោលនយោបាយកកើតក្រោយយ៉ាងច្រើន លើកលែងការឆ្លងកាត់ការ សាកល្បងដែលកំនត់ដោយអំណាចច្បាប់។

## ១.៩.អចល័តភាពនៃកត្តាផលិតកម្ម

ភាពនឹងថ្កល់នៃការអនុវត្តន៍កម្លាំងពលកម្មយ៉ាងសំខាន់របស់កសិករខ្លួនគាត់វាបន្តពង្រីកអនុវត្តន៍ ដែលអន់ជាងសមាជិកគ្រួសារ និង នៅតែបន្តពង្រីកនូវអ្វីៗ ដែលទាបជាងការជួលម្លាំងពលកម្ម។ មើលទៅចំនួនបរិមាណផលិតផលនៅអឺរ៉ុបនៅឆ្នាំថ្មីៗនេះមានការធ្លាក់ចុះគួរឱ្យយកចិត្តទុកដាក់។ វាគឺជំនួសជាមួយកម្លាំងម៉ាស៊ីនសមរម្យអាចប្រើបានយ៉ាងងាយស្រួល នៅពេលដីមានគ្រប់គ្រាន់ដែលអាចបំពេញនៃការប្រើប្រាស់ម៉ាស៊ីន។ កសិដ្ឋាន ១៥០អារ នៅស.តទី១៩ ប្រហែលមាននយោជិកធ្វើការ ១០នាក់ អាចមានការរៀបចំជាថ្មី របស់កសិដ្ឋានលក្ខណៈគ្រួសារធំមួយ ត្រឹមតែកម្មករម្នាក់ក្នុងនោះបន្ថែមកសិករម្នាក់និងប្រពន្ធរបស់គាត់ម្នាក់ទៀត។ ប៉ុន្តែដែលបញ្ហាចោទជាចំនោទនៃការរៀបចំជាថ្មី កសិដ្ឋាន ៣០អារ គឺមានបញ្ហា៥ដែលពិបាកខ្លាំងបំផុត។ ជាបឋមគឺកសិករមានការស្ទាក់ស្ទើរដោយការបោះបង់ដីដែលជារបៀបរស់នៅរបស់ពួកគាត់ ពេលចុងក្រោយដែលកសិដ្ឋានឆ្លងកាត់បញ្ឈប់ការកាន់កាប់ ទីបញ្ចប់កសិដ្ឋានជិតខាងប្រហែលមិនអាចគ្រប់គ្រងស្ថានភាពបានដែរ។ ប្រទេសជាច្រើនមិនបានគិតពីការពន្យារពេល បញ្ហាធ្ងន់ធ្ងរជាច្រើន នៅក្នុងចក្រភពអង់គ្លេស គឺធ្វើឲ្យស្មុគស្មាញដោយគ្រាប់អំបែងជាច្រើនក្នុងកសិដ្ឋាន។ ដូចច្នេះពេលវេលាសម្ព័ន្ធក្នុងប្រទេស ឬតំបន់ដែលខុសគ្នានោះគឺអស្ចារ្យ ឬផ្តល់អ្វីដែលអន់ជាង ពីអ្វីដែលបានប្រសើរបំផុតក្នុងការអនុវត្តបច្ចេកទេសបន្តិចម្តងៗ។ នេះជាភាពខុសគ្នារវាងក្នុងប្រសិទ្ធភាព នៃការប្រើប្រាស់រចនាសម្ព័ន្ធកសិដ្ឋាន និង សារៈសំខាន់នៃសក្តានុពលលើការដឹកជញ្ជូននិងគោលការណ៍ផ្គត់ផ្គង់ថ្លៃរបស់ជាតិ។ ប្រទេសដែលមានកសិដ្ឋានមានប្រសិទ្ធភាពធ្វើឱ្យលំអៀងថ្លៃផលិតករធ្លាក់ចុះ ដោយគ្មានអ្វីជាក់លាក់និងចូលចិត្តក្នុងជំនួយផ្សេងទៀត ប្រទេសដែលគ្មានរចនាសម្ព័ន្ធជាក់លាក់គ្មានប្រសិទ្ធភាពល្អ ភាពលំអៀងមានតម្លៃខ្ពស់ហើយមិនជាក់លាក់និងបំណងជាទូទៅគឺរក្សាលក្ខខណ្ឌការនាំចូល ក្នុងការរក្សាថ្លៃ។

## ១.១០.ការចាត់តាំងលក្ខណៈពិសេសនៃកសិកម្ម

យើងអាចសង្កេបបានក្រោយពីការពិភាក្សាខាងលើ។ កន្លងមកកសិកម្មភាគច្រើនមិនដូចឧស្សាហកម្មទេ គឺជាអាទិ៍ការរៀបចំក្នុងកសិដ្ឋានលក្ខណៈគ្រួសារសេមាមាត្រនិងបរិមាណប្រែប្រួលនៃថ្លៃគឺជាទូទៅអន់ជាងការផលិតឧស្សាហកម្ម។ ដូចនេះគ្រាន់តែនៅរយៈពេលដ៏វែង(ប្រព័ន្ធកសិកម្មលក្ខណៈប្រពៃណីគឺតូចជាងគេ)តម្លៃទីផ្សារនៃផលិតផលកសិកម្មបន្តិចបន្តួចមានតិចឬច្រើនដែលទាក់ទិនទៅដល់ថ្លៃដើមនៃផលិតកម្មមានភាពមិនជាក់លាក់។ នៅក្នុងកសិដ្ឋានកម្រិតនៃការផ្គត់ផ្គង់គឺមិនមែនភ្ជាប់ដោយផ្ទាល់ទៅថ្លៃដើមដែលមានទំនាក់ទំនងការ ផលិតឧស្សាហកម្មថ្លៃនៃការផលិតផលិតកម្មគឺបានភ្ជាប់យ៉ាងជិតស្និទ្ធជាមួយថ្លៃដើមនៃផលិតផលកសិកម្មទាំងនោះជាច្រើនដែលទាក់ទងទៅនឹងស្ថានភាពនៃតម្រូវការនៃការផ្គត់ផ្គង់បច្ចុប្បន្ន។ ដូចនេះលក្ខណៈពិសសនៃ តម្លៃផលិតផលកសិកម្មមានការធ្លាក់ចុះយ៉ាងខ្លាំងនៅពេលដែលការផ្គត់ផ្គង់ធំជាងតម្រូវការ។

## ១.១១.ឥទ្ធិពលនៃកត្តាធម្មជាតិ

លក្ខណៈពិសេសបន្ថែមនៃផលិតផលកសិកម្ម គឺក្នុងការចាត់តាំងបន្ថែមនៃសហគ្រាសខ្នាតតូចគឺពឹងផ្អែកលើធម្មជាតិ។ ថ្វីបើមានដំណើរការបច្ចេកទេសក៏ដោយ ក៏ទិន្នផលប្រចាំឆ្នាំនៅតែមានឥទ្ធិពលប៉ះពាល់យ៉ាងច្រើនដោយអាកាសធាតុ។ កន្លែងចញ្ចឹមសត្វទំនើប ការចញ្ចឹមសត្វគឺពឹងផ្អែកលើអាកាសធាតុតិចតួច ប៉ុន្តែលំបាកនៅរដូវត្រជាក់ឬរដូវក្តៅកម្រិតតុល្យការភាពនៅតែមានឥទ្ធិពលលើផលិតកម្មនិងគឺមានការរាលដាលដល់ សក្តានុពលដល់ការចិញ្ចឹមសត្វ។ ការប្រែប្រួលនៅក្នុងផលិតកម្ម ដូចនេះដែរមានការកើនឡើងដែលកសិករមិនមានគំរោង ឬការគ្រោងទុកជាមុន។ ការប្រែប្រួលបរិមាណនាំឱ្យមានស្ថេរភាពក្នុងការផ្គត់ផ្គង់ និងថ្លៃផលិតផលមួយចំនួន ឧទាហរណ៍៖ ស្រូវសាលីមួយចំនួនបានបន្តពង្រីកទទួលជោគជ័យ មធ្យោបាយដឹកទំនិញការស្តុកទំនិញសម្រាប់ផលិតផលផ្សេងៗទៀត ដូចជាដំឡូងបារាំង នៅមានការលំបាកជាច្រើនទៀត។

ប្រភេទនៃបញ្ហាទាំងនោះក៏មានឧស្សាហកម្មដែលមានបទពិសោធន៍។ លក្ខណៈជីវសាស្ត្រមានផលវិបាកយ៉ាងខ្លាំងនៃផលិតកម្មកសិកម្មគឺការបង្កើតក្រុមផលិតផលអាស្រ័យតាមរដូវ។ អញ្ចឹងការប្រមូលផលនៃធញ្ញជាតិមានការកើនឡើង នៅអឺរ៉ុបនិងអាមេរិចខាងត្បូងគឺយឺតនៅរដូវក្តៅនិងសទរដូវ។ ក្នុងនោះផ្សេងទៀតផលិតផល ជ្រូក មាន់ ទា ក្ងាន នៅសម័យថ្មីមិនអាស្រ័យលើអាកាសធាតុ ទោះបីជាមេមាន់នៅតែបន្តខិតខំផ្តល់ស៊ុតជាច្រើន។ គោក្របីអាចធ្វើឱ្យជាត់ នៅពេលអាកាសៈផ្សេងៗ ក្នុងរដូវរងារ និងអាចផ្តល់ការផលិតទឹកដោះគោនៅរដូវរងារផងដែរ ប៉ុន្តែករណីទាំងពីរគឺមានថ្លៃខ្ពស់។ អញ្ចឹងផលិតផលនៃ ស្បៀងអាហារជាច្រើនគឺវត្ថុប្រែប្រួលអាស្រ័យតាមរដូវ ដែលកម្រមានការទាក់ទងនិងការប្រកួតប្រជែងការប្រែប្រួលតាមតម្រូវការ។ ជាទូទៅតម្រូវការបរិមាណផលិតផលនៅថេរយ៉ាងសមរម្យរាល់ឆ្នាំដាច់ចេញពីគ្នា ការប្រែប្រួលអាកាសធាតុ ឬទំលៀមទំលាប់រយៈពេលការលក់ទឹកដោះគោកើនឡើងមានបញ្ហាធំ និងនៅប្រទេសទូគឺមានតម្រូវការខ្ពស់ នៅពេលបុណ្យគ្រិះស្មាក់។ មានវិធីខុសគ្នាបីយ៉ាងរវាងការផ្គត់ផ្គង់តម្រូវការមានកិច្ចព្រមព្រៀង៖

១ នៅពេលដែលការផ្គត់ផ្គង់មានកម្រិតខ្ពស់បំផុត ត្រឹមតែធ្វើឱ្យថ្លៃមានការធ្លាក់ចុះដូចនេះគឺជំរុញឲ្យមានការ លើកទឹកចិត្តការប្រើប្រាស់នៅពេលមានផលិតផលខុសរដូវ។

២ អាចមានការបង្កើនច្បាប់ នៅពេលដែលការផ្គត់ផ្គង់មានកម្រិតខ្ពស់បំផុតដោយការប្រើប្រាស់យឺត។ ទោះបីជាយ៉ាងណាក៏ផលិតផលកសិកម្មដែលអាចរលួយ ធ្វើឲ្យផលិតផលមួយចំនួនអាចដំណើរការថ្លៃ។

៣ នៅពេលបិទរដូវការផ្គត់ផ្គង់ការនាំចូលពីអឌ្ឍគោលខាងត្បូង ឬទឹកដីខាងត្បូង( vice versa របស់ប្រទេសអឌ្ឍគោលខាងត្បូង) ក្នុងការអនុវត្តនមានវិធីបីយ៉ាងដូចគ្នាសម្រាប់ប្រើប្រាស់វត្ថុធាតុដើម និងជាមួយគ្នានេះដែរមានពីរឬបី។ ជាក់ស្តែងកម្រិតនៃការចិញ្ចឹមសត្វជាទូទៅមានច្រើនករណីគួរឲ្យកត់សម្គាល់។ សម្រាប់ផលិតផលមួយចំនួនដូចជាធញ្ញជាតិ និងការចំណាយលើថ្លៃស្តុកទំនិញនិងបាត់បង់គុណភាព។ ប៉ុន្តែសម្រាប់ផលិតផល សាច់ទឹកដោះគោ និងបន្លែចំណាយថ្លៃខ្ពស់និងបាត់បង់គុណភាពច្រើនជាង(ទោះបីជាបញ្ហាគុណភាពគឺបានការកើនឡើង កំពុងរកដំណោះស្រាយដោយបច្ចេកទេសទំនើប)។

ការនាំចូលពីប្រទេសដែលមានរដូវខុសគ្នាជារឿយៗងាយស្រួលអនុវត្តន៍ ឬ ដែលទទួលផលចំណេញប៉ុន្តែសម្រាប់ ផ្លែឈើនិងបន្លែមួយចំនួនគឺដើរតួនាទី ឧទាហរណ៍ អឺរ៉ុបខាងជើងឈៀងខាងលិច ដំឡូងបារាំងថ្មីមកពីតំបន់មេឌីទែរ៉ានេ ឬ ផ្លែប៉មមកពីអូស្ត្រាលី។ ករណីទាំងអស់នេះមានតម្លៃទាបជាងពេលនៃការផ្គត់ផ្គង់មានកម្រិតខ្ពស់ សម្រាប់ផលិតផលមួយចំនួនការប្រើប្រាស់គឺមានការកើនឡើងនិងក្នុងករណីជាច្រើនធ្វើឲ្យការស្តុកទំនិញមានផលចំណេញច្រើន។ បរិមាណការប្រែប្រួលផលិតផលដែលកើនតាមរដូវពិសេសកសិកម្ម នៅក្នុងការស្វែងរកយ៉ាងលំបាកពីឧស្សាហកម្មជាច្រើន។ ពួកគេត្រូវមានការចាំបាច់ការរៀបចំការស្ទុគស្មាញការស្តុកទំនិញនិងជាក់ស្តែង អស្ថេរភាពនៃផលិតផលនៅពេលដែលបរិមាណប្រែប្រួលជារឿយៗមិនអាចធ្វើការព្យាករណ៍បាន។

## ១.១២.លក្ខណៈពិសេសនៃតម្រូវការ

លើផ្នែកតម្រូវការស្មៀងកម្រិតនៃផលិតផលកសិកម្ម ដូចច្នេះជាក់ស្តែងការបង្ហាញពិលក្ខណៈពិសេសដែល គួរឲ្យកត់សំគាល់ជាច្រើន នៃនិន្នាការនៃការប្រើប្រាស់ដូចជាការកើនចំណូល។ អាដាមស្មីតបានសំគាល់រួចមក ហើយ៖

អ្នកប្រើប្រាស់អ្នកមានមិនមានអាហារច្រើនជាងអ្នកជិតខាងដែលក្រ។ ហើយគុណភាពវាប្រហែលជា ជ្រើសរើសខុសគ្នានិង ប្រៀបធៀបប្រហែលជាត្រូវនិងសិល្បៈនៃម្លាំងពលកម្មប៉ុន្តែបរិមាណរបស់វាប្រហែលជាជិតដូចគ្នា។ ប៉ុន្តែបើប្រៀបធៀបទីកន្លែងធំទូលាយនិងទូសំលៀកបំពាក់ដែលធំ ជាមួយខ្ទមនិងកន្ទបអ្នក និងមានហេតុផល២ឬ៣ ផ្សេងទៀតដែលខុសគ្នារវាងសំលៀកបំពាក់របស់ពួកគេ ផ្ទះលំហែកាយ និង គ្រឿង សង្ហារឹមក្នុងគ្រួសារស្ទើរតែអស្ចារ្យទាំងបរិមាណនិង គុណភាព។ សេចក្តីប្រាថ្នានៃអាហារដែលមានកំណត់ធ្វើការ ដោយសមត្ថភាពគឺក្រពះតូចនៃមនុស្ស៖ ប៉ុន្តែសេចក្តីប្រាថ្នានៃការសមរម្យនិងគ្រឿងតុបតែងឬការសាងសង់ សំលៀកបំពាក់ បរិក្ខា និង គ្រឿងសង្ហារឹមក្នុងផ្ទះ ហាក់បីដូចជាមានកំណត់ឬព្រំដែនជាក់លាក់។

វាគឺនៅតែជាការពិតដែលនៅខាងលើនេះដាក់ស្តែងកម្រិតនៃការកើនឡើងនៃចំណូល មិនមែននាំអ្នកប្រើប្រាស់កើនឡើងនៃចំនួនកាឡូរី។ ទោះបីជាយ៉ាងណាវាមិនមែនជាគម្រូពិតនៃការមិនផ្លាស់ប្តូរការប្រើប្រាស់ វត្ថុនៅសល់។ ជាមួយនឹងការកើនចំណូលទាំងនោះគឺបំលាស់ប្តូរពីម្ហូបអាហារដែលថោកដូចជាធញ្ញជាតិនិង ដំឡូងបារាំងច្រើនជាងអាហារថ្លៃដូចជាសាច់និងផ្លែឈើ។

ពីមួយសប្តាហ៍ទៅមួយសប្តាហ៍និងមួយខែទៅមួយខែ នៅជំនួយដទៃផ្សេងទៀត តម្រូវការស្បៀងអាហារ ឥតប្រើប្រាស់វត្ថុនៅសល់និងទទួលរងការប្រែប្រួលរដូវតិចជាងរបស់ប្រើប្រាស់ដូចជាការស្លៀកពាក់ ធ្យូង ទំនិញ កីឡាឬ សូម្បីតែម៉ូតូ។ បន្ថែមពីនេះនៅស្ថិតស្ថេរនៃការផលិតទំនិញឥតប្រែប្រួល ដូចជាឡានឬ ទូរទស្សន៍អាចនាំ ទៅរយៈពេលដ៏វែងនៅក្នុងវដ្តនៃតម្រូវការ។ ទោះបីជាស្បៀងអាហារមានការប្រើប្រាស់រាល់ថ្ងៃ និង នេះជាអត្ថប្រយោជន៍សម្រាប់អាហារក្នុងទីផ្សារ កន្លងមកមធ្យោបាយស្តុកទំនិញនៅមានកម្រិតទាបនិង ម្លាំងពលកម្មនិង ទីកន្លែងដែលមានប្រយោជន៍យ៉ាងពេញលេញ។ នៅសហរដ្ឋអាមេរិចអ្នកកាន់កាប់ឧស្សាហកម្មអាហារចូលះ

វត្ថុអស្ចារ្យអំពីអាហារយើងចង្អុលបង្ហាញពីរ ឬ បីចំណុចគឺមនុស្សម្នាក់ៗប្រើវា និងគ្រាន់តែបានប្រើវាម្តង។

## សង្ខេប

ជារឿយៗឧស្សាហកម្មនៃកសិកម្មបានទទួលរងការប្រែប្រួលនិងចំណូលទាប។ ចំណូលទាបជាញឹកញាប់បានបង្ហាញពីលក្ខ័ខណ្ឌនៃអតុល្យភាពនៃរចនាសម្ព័ន្ធ នៅក្នុងនោះដែរចលនានៃម្លាំងពលកម្មរបស់ពួក យើងគឺរឿងក្តីឧស្សាហកម្ម។ ការប្រែប្រួលនៃបរិមាណចំណូលផលិតផលមានការរងផលវិបាកពីលក្ខណៈជីវសាស្ត្រនៃធម្មជាតិ ដែលនាំទៅមិនមានផែនការនៃការប្រែប្រួល បានរួមបញ្ចូលជាមួយនឹងរចនាសម្ព័ន្ធនៃបុគ្គលិក លក្ខណៈនៃឧស្សាហកម្ម ដែលប្រហែលទៅ "ការប្រកួតប្រជែងយ៉ាងពេញលេញ"។ «កសិដ្ឋានលក្ខណៈគ្រួសារ» គឺស្ទើរតែជាប្រភេទនៃផលិតកម្មសាមញ្ញ នៅពាសពេញពិភពលោក លើកលែងតែនៅក្រោមប្រព័ន្ធកុម្មុនិស្ត ទោះបីជាយ៉ាងណាក៏ដោយភាពចាំបាច់ក្នុងដំណើរការនិងប្រព័ន្ធការបែងចែកផ្សេងពីគ្នាដូចគ្នាការបង្កើតការស្រាវជ្រាវ ហិរញ្ញវត្ថុជាសាធារណៈ។ ភាពខុសគ្នាមួយចំនួនការបាត់នៃកសិកម្មប្រពៃណីរវាងឧស្សាហកម្ម ប៉ុន្តែកសិកម្មនៅតែរក្សាទុកជាច្រើន លក្ខណៈពិសេសនៃការចាត់តាំងដែលផ្តល់ឱ្យកើនបញ្ហានៃគោលនយោបាយ។

## សម្គាល់

១ "ការរឹតត្បិតចំណូលនៅកសិដ្ឋាន" ជានាគារសេដ្ឋកិច្ចLloyd'sប៊ូឡាទីន លេខថ្ងៃ១៨ខែឧសភា ឆ្នាំ១៩៨០

២ លោកចនសាន់គ្លេន បញ្ហាមួយចំនួនបានលេចឡើងនៃអ្នកសេដ្ឋកិច្ច អ្នកវិភាគស្ថិតិពីគោលនយោបាយ កសិកម្មUSអ្នកវិទ្យាសាស្ត្រស្ថិតិ Manchester.

៣ Galbrith,K.KandBlack, J. D "ការរំលឹកឡើងវិញពីការពន្យល់ថេរទាំផលិតកម្មកសិកម្មកំឡុង ពេលការថយចុះ"ទស្សនាវដ្តីនៃគោលនយោបាយសេដ្ឋកិច្ច។ Vol.46,No.3,1938,p.305.

៤ Hanau, A. ´ស្តេរភាពថ្លៃខុសគ្នាស្រលះនៃកសិដ្ឋាននិងក្រៅកសិដ្ឋាន ´របាយការណ៍អង្គប្រជុំនៃ អន្តរជាតិទី១១សេដ្ឋកិច្ចវិទូនៃកសិកម្ម ទីក្រុងឡុងដុង ឆ្នាំ១៩៦០ ទំព័រ ១២៤។

# មេរៀនទី២
# គោលនយោបាយនៃការជម្រុញកំណើនសេដ្ឋកិច្ចជាតិ

( Economic Foundations of Policy )

ក្រោយពីបានបញ្ចប់ជំពូកនេះ លោកអ្នកនឹងយល់ដឹងពី៖

- សញ្ញាណនៃសេដ្ឋកិច្ច
- តម្រូវការ និងផ្គត់ផ្គង់
- ទីផ្សារ និងសមតាក្រុមហ៊ុន
- ប្រភេទនៃគោលនយោបាយ
- ដែនកំណត់នៃសេដ្ឋកិច្ច
- ទ្រឹស្តីនៃពាណិជ្ជកម្មកសិកម្ម
- គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច
- តួនាទីនៃសេដ្ឋវិទូក្នុងការកំណត់គោលនយោបាយ
- ជម្រើសជាសាធារណៈនៃទ្រឹស្តីសេដ្ឋកិច្ច
- ការវិភាគអតិរេករបស់អ្នកប្រើប្រាស់ និងផលិតករ

## ២.១. សញ្ញាណនៃសេដ្ឋកិច្ច

### ២.១.១ ប្រភព និងអត្ថន័យនៃពាក្យសេដ្ឋកិច្ច

( The Source and Meaning of Economics )

បើយោងទៅតាមវចនានុក្រមរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត នោះ ពាក្យ "សេដ្ឋកិច្ច" កើតឡើងពីវាក្យសម្ព័ន្ធ " សេដ្ឋ " និង " កិច្ច"។ ពាក្យ "សេដ្ឋ" ប្រែថា "ប្រសើរ រុងរឿង ថ្លៃថ្លា ឧត្តុង្គឧត្តម ថ្កុំថ្កើង" និង ពាក្យ "កិច្ច" ប្រែថា "ការងារ ឬកិច្ចការ"។ ដូច្នេះ បើតាមន័យត្រង់របស់សម្តេចព្រះសង្ឃរាជ ជួន ណាត នោះ ពាក្យ "សេដ្ឋកិច្ច" មានន័យថា "កិច្ចការដែលធ្វើឱ្យប្រសើរ ឬកិច្ចការដែលរុងរឿង ឬការងារទាំងឡាយណាដែលល្អប្រពៃ ឬការងារទាំងឡាយណាដែលធ្វើឱ្យរីកចម្រើន ថ្លៃថ្លា ឧត្តុង្គឧត្តម ឬការងារដែលល្អថ្លៃថ្នូរចម្រុងចម្រើន ឬការងារនាំមកនូវផលប្រយោជន៍ តែបើតាមអត្ថន័យនៃពាក្យ" សេដ្ឋកិច្ច"គឺជាវិទ្យាសាស្ត្រនៃការវិភាគពិចារណាទៅលើការប្រើប្រាស់នូវប្រភពធនធានដែលមានកំណត់( ធនធានខ្សត់កម្រ ) ដើម្បីឆ្លើយតបនឹងវត្ថុបំណងឥតព្រំដែនរបស់មនុស្សជាតិ។ អត្ថន័យនៃពាក្យ "សេដ្ឋកិច្ច" ជាវិទ្យាសាស្ត្រសង្គម ដែលសិក្សាស្វែងយល់នូវវិធីសាស្ត្រឆ្លើយតបនឹងតម្រូវការរបស់មនុស្ស ឆ្លងកាត់ការចែកចាយ ឬចាត់ចែងនូវធនធានខ្សត់កម្រ។

ក្នុងពាក្យជាភាសាអង់គ្លេស ពាក្យថា"សេដ្ឋកិច្ច( Economics )" នេះមានដើមកំណើតចេញពីភាសាក្រិច( GREEK )ដែលមានពាក្យដើមទាំងស្រុងថា "អិចកូណូម៉ូស( Oikonomous )" ដែលប្រែថា "ការថែរក្សាផ្ទះសំបែង( House-keeping )"គឺជាភារកិច្ចចំបងមួយរបស់ស្ត្រីជាមេផ្ទះ ដែលចេះលៃលក

ច្នៃប្រឌិតប្រើប្រាស់ធនធានគ្រប់ប្រភេទតាមលទ្ធភាពដែលអាចធ្វើទៅបានដើម្បីនាំមកនូវផល ប្រយោជន៍ប្រចាំគ្រួសារ។

ម្យ៉ាងទៀត ពាក្យថា "អិចកូណូម៉ូស(Oikonomous)" គឺមកពីពាក្យពីរម៉ាត់គឺពាក្យ "អិចកូ(Oiko)" ដែលមានន័យជាភាសាអង់គ្លេសថា "គ្រួសារ(Household)" និងពាក្យ "ណូម៉ូស(Nomous)" ដែលមានន័យជាភាសាអង់គ្លេសថា "ការគ្រប់គ្រង(Management)"។ ដូចនេះបើយោងទៅតាមភាសាក្រិចពាក្យសេដ្ឋកិច្ច(Economics) មានន័យថា "ការគ្រប់គ្រងគ្រួសារ(The Management of Households)" (N. Gregory Mainkiw, 2012)។

ប៉ុន្តែបើយោងទៅតាមទស្សនាទានភាគច្រើនរបស់សេដ្ឋវិទូបានឲ្យនិយមន័យជាទូទៅថា "សេដ្ឋកិច្ច(Economics)" គឺវិទ្យាសាស្ត្រសង្គម ដែលទាក់ទងទៅនឹងការប្រើប្រាស់ប្រភពធនធានខ្សត់កម្រ(Scares Resources) ដើម្បីបំពេញនូវសេចក្តីពេញចិត្តអតិបរមានៃចំណង់ឥតព្រំដែនរបស់មនុស្ស (Economics is a social science concerned with using scare resources to obtain the maximum satisfaction of the unlimited human wants)។

អត្ថន័យនៃពាក្យ "សេដ្ឋកិច្ច(Economics)" គឺជាវិទ្យាសាស្ត្រសង្កេត(Observation Science) សម្រាប់ធ្វើការសម្រេចចិត្តដើម្បីធ្វើការពន្យល់ពីរឿងរ៉ាវអ្វីមួយក្នុងពិភពជាក់ស្តែង (Economics is an observation science that make the decision to explain something in the real world)។ វិទ្យាសាស្ត្រសង្កេត(Observation science) នៅទីនេះ មានន័យថា វាគឺជាវិទ្យាសាស្ត្រដែលប្រមូលនៃការព័ត៌មាន(to gather the information) រួចយកព័ត៌មានដែលប្រមូលបានមកធ្វើការត្រួតពិនិត្យ(Examine the information) បន្ទាប់មកយកព័ត៌មានដែលបានធ្វើការពិនិត្យរួចមកវិភាគយ៉ាងល្អិតល្អន់ រួចយកព័ត៌មានទាំងនោះមករៀបតាមលេខលំដាប់(Order the information) ដើម្បីផ្តល់អាទិភាពថាតើ ព័ត៌មានណាត្រូវធ្វើមុនហើយព័ត៌មានណាត្រូវធ្វើក្រោយ និងចុងក្រោយធ្វើបទបង្ហាញ(show or presence)ពីលទ្ធផលនៃការវិភាគព័ត៌មានទាំងនោះប្រាប់ម្ចាស់ទុនដើម្បីធ្វើការសម្រេចចិត្តក្នុងការងារធុរកិច្ច ឬកិច្ចការប្រកបការងារអាជីវកម្មអ្វីមួយក្នុងពិភពជាក់ស្តែង(Observation science is a science that gather the information, next check these information, and then verify these information, and the last one, they explain these information to let shareholder understand these in order to make their decision for doing something in their businesses)។

អត្ថន័យនៃពាក្យ "សេដ្ឋកិច្ច(Economics)" គឺពិតជាការសិក្សាពីអត្តចរិកសកម្មភាពរបស់មនុស្សក្នុងការផលិត ការបែងចែក ការប្រើប្រាស់វត្ថុធាតុដើម ទំនិញ និងសេវាកម្ម ក្នុងពិភពជាក់ស្តែងនៃធនធានខ្សត់កម្រ(McConnell, 1993)។

អត្ថន័យនៃពាក្យ "សេដ្ឋកិច្ច(Economics)" គឺជាការសិក្សាអំពីកត្តាផលិតកម្ម ការបែងចែក និងការប្រើប្រាស់ទំនិញ និងសេវាកម្មនានា នៅក្នុងសង្គមជាតិ។ សេដ្ឋកិច្ចគឺពិតជាការសិក្សាអំពីរបៀបដែលមនុស្សធ្វើការជ្រើសរើស និងការបែងចែកនូវធនធានកម្រ ដើម្បីបំពេញសេចក្តីត្រូវការ និងសេចក្តីប៉ងប្រាថ្នា។ អត្ថន័យផ្សេងមួយទៀត សេដ្ឋកិច្ចគឺជាវិទ្យាសាស្ត្រនៃការសម្រេចចិត្ត ឬការជម្រើស ដែល

ស្ថិតក្នុងស្ថានភាពធនធានកម្រ។ មនុស្សភាគច្រើនគិតថា សេដ្ឋកិច្ចគឺមានទំនាក់ទំនងតែនឹងរូបិយវត្ថុតែប៉ុណ្ណោះ។ ប៉ុន្តែវាពិតជារឿងមិនពិតត្រឹមហ្នឹងនោះទេ សេដ្ឋកិច្ចគឺជាការសិក្សាអំពីបុគ្គលិកលក្ខណៈរបស់បុគ្គល និងសង្គមជាតិ ដែលមានទំនាក់ទំនងទៅនឹងធនធានកម្រ។ តើអ្វីធនធានខ្សត់កម្រ (Scarce resources) ?

ធនធានខ្សត់កម្រ (Scarce resources) គឺជាស្ថានភាពនៃភាពចង់បាន និងប្រភពធនធានដែលមានដែនកំណត់។ ធនធានខ្សត់កម្រគឺសំដៅទៅលើធនធានសេដ្ឋកិច្ច ដែលខាងផ្នែកតម្រូវការធំជាងខាងផ្នែកផ្គត់ផ្គង់។ ប្រសិនបើ ធនធានសេដ្ឋកិច្ចគឺគ្មានដែនកំណត់នោះ វានឹងមិនមានបញ្ហាសេដ្ឋកិច្ចឡើយ ហើយក៏គ្មានសេដ្ឋកិច្ចដែរ។ ដូច្នេះធនធានខ្សត់កម្រជាធនធានមិនគ្រប់គ្រាន់នោះទេសម្រាប់មនុស្សជាតិគ្រប់គ្នា។ ហេតុនេះ ការសិក្សាពីធនធានខ្សត់កម្ររបស់សេដ្ឋកិច្ចត្រូវបានជ្រើសរើសគឺជាបញ្ហាសេដ្ឋកិច្ច។ តើអ្វីជម្រើស (Choice) នោះ ?

ធនធានសេដ្ឋកិច្ចពិតជាមានដែនកំណត់ ចំណែករីឯ តម្រូវការរបស់មនុស្សវិញគ្មានដែនកំណត់ទេ វាបានបង្ខំឱ្យយើងធ្វើជម្រើស។ ជម្រើសគឺជាបញ្ហាសេដ្ឋកិច្ច ដែលជួយយើងឱ្យទទួលបានសេចក្ដីពេញចិត្តជាអតិបរមា។

រហូតមកដល់ពេលបច្ចុប្បន្ននេះ ការពិភាក្សាពីអត្ថន័យនៃពាក្យថា "សេដ្ឋកិច្ច" នៅមានមលក្ខណៈស្មុគស្មាញដដែល។ បច្ចុប្បន្ននេះមានទស្សនៈសេដ្ឋវិទូជាច្រើន នៅមានភាពចង្អៀតចង្អល់ខ្វែងគំនិតគ្នានៅឡើយ ទាក់ទងនឹងលក្ខណៈជាក់ស្ដែងនៃបញ្ហាសេដ្ឋកិច្ច។ ការពិភាក្សាទៅលើពាក្យថាសេដ្ឋកិច្ច និងបាតុភូតសេដ្ឋកិច្ចជាអ្វីនោះ វានៅតែមានជាបន្តបន្ទាប់។ ដូចនេះ អត្ថន័យនៃពាក្យ "សេដ្ឋកិច្ច" ត្រូវបានគេធ្វើការពន្យល់បកស្រាយដោយសេដ្ឋវិទូល្បីចំនួន៥រូប ចាប់តាំងពីសម័យ សេដ្ឋកិច្ចក្លាស៊ីក (Classic Economics) សេដ្ឋកិច្ចណេអូក្លាស៊ីក (សេដ្ឋកិច្ចណេអូក្លាសិច) (Neo-classical economics) សេដ្ឋកិច្ចទំនើបតាមលោកKeynes (Keynesian economics) សេដ្ឋកិច្ចទំនើបណេអូតាមលោក Keynes (Neo-Keynesian economics) និងមីក្រូសេដ្ឋកិច្ចក្លាសិចថ្មី (New classical microeconomics)។

ការកំណត់អត្ថន័យនៃពាក្យ "សេដ្ឋកិច្ច" កាន់តែមានលក្ខណៈប្រសើរឡើងគឺស្ថិតក្នុងសម័យកាលរបស់សេដ្ឋវិទូ ជាជនជាតិអង់គ្លេស លោក អាល់ហ្វ្រេដ ម៉ាហ្សាល (Alfred Marshall)។ ទោះជាយ៉ាងនេះក្តី អត្ថន័យនៃពាក្យ "សេដ្ឋកិច្ច" របស់លោក អាល់ហ្វ្រេដ ម៉ាហ្សាល នៅតែមិនមានភាពច្បាស់លាស់នៅឡើយ។ ហេតុនេះ នៅតែបន្តមានសេដ្ឋវិទូបន្តបន្ទាប់ បានឱ្យអត្ថន័យនៃពាក្យ "សេដ្ឋកិច្ច" ដូចជា លោកសាស្ត្រាចារ្យ A.C. Dhas (2011) ជាដើម។

### ២.១.២ តើសេដ្ឋកិច្ចជាអ្វី ? (What is Economics ? )

នៅក្នុងការសិក្សាស្វែងយល់ពីប្រទេសមួយ គឺគេចង់ដឹងថា តើប្រទេសនោះ មានគោលនយោបាយបែបណា ? និងសេដ្ឋកិច្ចដើរដោយរបៀបណាពោលគឺចង់ដឹងថា វាជាប្រទេសអភិវឌ្ឍន៍ (Developed countries) ឬជាប្រទេសកំពុងអភិវឌ្ឍន៍ (Developing countries) ហើយការចង់ដឹងនេះ គេមិនបានមកវិភាគគ្រប់ជ្រុងជ្រោយនោះទេ គឺគេគ្រាន់តែមើលពីដំណើរការសង្គម តើវាមាន

ស្ថេរភាពនិងសុវត្ថិភាពឬទេ? ហើយប្រជាជនរស់នៅក្នុងជីវភាពធូរធារ ឬប្រជាជនរស់នៅដោយប្រឈមមុខនឹងការខ្វះខាត អសន្តិសុខ និងជីវភាពខុសគ្នាស្រឡះពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតតែប៉ុណ្ណោះ។

បញ្ហាទាំងអស់នេះ គឺជាកាតព្វកិច្ចរបស់អ្នកសេដ្ឋកិច្ច និងអ្នកដឹកនាំប្រទេសដែលត្រូវខិតខំដោះស្រាយដើម្បីជួយឱ្យប្រទេស និងប្រជាជនរបស់ខ្លួនរស់នៅក្នុងភាពរុងរឿងតាមបែបជីវភាពមួយដែលមានអ្វីៗគ្រប់យ៉ាងទាំងអស់ពោលគឺកំណើនជីវភាពមានសន្តិសុខ និងគ្រប់ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងប្រទេស។ ហេតុនេះ មុខវិជ្ជាសេដ្ឋកិច្ចសម្រាប់វិស័យកសិកម្មគឺជាមុខវិជ្ជាវិទ្យាសាស្ត្រមួយដែលត្រូវបានគេសិក្សានៅតាមវិទ្យាសាស្ត្រជំនាញជាច្រើនដូចជា សេដ្ឋសាស្ត្រ នីតិសាស្ត្រ ពាណិជ្ជសាស្ត្រ ទេសចរណ៍ និងស្ទើរគ្រប់ស្ថាប័ន គ្រប់តំបន់ និងគ្រប់ប្រទេសនៅលើពិភពលោក។

កាលពីមុន យើងបានកត់សម្គាល់នូវបញ្ហាដ៏មានសារៈសំខាន់នាពេលបច្ចុប្បន្ននេះតែបន្តិចបន្តួចនូវអ្វីដែលសេដ្ឋកិច្ចអាចបង្ហាញនូវពន្លឺខ្លះៗ។ វិធីមួយដើម្បីកំណត់ន័យសេដ្ឋកិច្ចគឺហៅវាថា វាជាវិទ្យាសាស្ត្រសង្គមដែលផ្សាភ្ជាប់ជាមួយបញ្ហាដូច្នេះ។ និយមន័យផ្សេងទៀតហើយប្រហែលជាបានដឹងទូទៅគឺ Alfred Marshall ឱ្យនិយមន័យថា "សេដ្ឋកិច្ចសិក្សាអំពីមនុស្សជាតិនៅក្នុងជំនួញធម្មតានៃជីវិតរស់នៅ"។

សេដ្ឋកិច្ចសិក្សាអំពីប្រើប្រាស់បណ្តាធនធានដ៏កម្រ ដើម្បីបំពេញសេចក្តីត្រូវការរបស់មនុស្សដែលគ្មានព្រំដែន។ ភាពកម្រគឺជៀសពុំរួច ហើយគឺជាចំណុចសំខាន់នៃបណ្តាបញ្ហាសេដ្ឋកិច្ច។ តើបណ្តាធនធានរបស់សង្គម គឺជាអ្វី? ហេតុអ្វីបានជាភាពកម្រមិនអាចជៀសរួច? តើលទ្ធផល (វិបាក) នៃភាពកម្រគឺជាអ្វី? តើសេដ្ឋកិច្ចជាអ្វី? តើអ្វីជាកម្មវត្ថុសិក្សានិងខ្លឹមសាររបស់វា?

តាមការវិវត្តន៍នៃសង្គមនិងតាមគោលគំនិតរបស់អ្នកនិពន្ធផ្សេងៗគ្នា។ សេដ្ឋកិច្ចត្រូវបានគេអោយនិយមន័យផ្សេងៗគ្នាជាច្រើនផងដែរ។ ដោយខ្លះប្រើពាក្យខុសគ្នាថែមទៀតផងដូចជាថាសេដ្ឋកិច្ចជាវិទ្យាសាស្ត្រសេដ្ឋកិច្ចសេដ្ឋកិច្ចនយោបាយនិងការវិភាគសេដ្ឋកិច្ច។ ល។

និយមន័យទូទៅ សេដ្ឋកិច្ចគឺជាការប្រើប្រាស់ធនធានកម្រឲ្យមានប្រសិទ្ធភាពក្នុង ផលិតកម្មដើម្បីបំពេញសេចក្តីចង់បានរបស់មនុស្សក្នុងសង្គមដែលគ្មានព្រំដែន។ ហេតុអ្វី បានជាគេថាដូច្នេះ? យើងបែងចែកនិយមន័យនេះជា ២ផ្នែក គឺធនធានកម្រ និងសេចក្តីចង់បានរបស់ មនុស្សក្នុងសង្គមដែលគ្មានព្រំដែន។

- ធនធានកម្រ៖ ក្នុងផលិតកម្មមានន័យថាប្រភពធនធានយើងប្រើប្រាស់សំរាប់ផលិត ទំនិញនិង សេវាកម្ម។

- សេចក្តីចង់បានរបស់មនុស្សក្នុងសង្គមដែលគ្មានព្រំដែនមានន័យថា កំណើនមនុស្សពី មួយថ្ងៃទៅមួយថ្ងៃចេះតែកើនឡើង ដូចនេះតំរូវការចំពោះទំនិញនិង សេវាកម្មក៏កើនឡើងដែរតែបរិមាណនៃមុខចេញទាំងអស់នេះគឺមានកំនត់ហើយមិនអាច បំពេញនូវរាល់ការចង់បានរបស់ មនុស្សក្នុងសង្គមទេព្រោះវាជាធនធានកម្រ។ ដូច្នេះការ បំពេញសេចក្តីចង់បានរបស់យើងបានតិច ឬច្រើនគឺអាស្រ័យលើចំណូល។

តាមទស្សនៈរបស់បណ្ឌិតសាស្ត្រាចារ្យ LIONEL ROBBINS គាត់បានឱ្យនិយមន័យសេដ្ឋកិច្ចថា ជាវិទ្យាសាស្ត្រសិក្សាពីចំណង់ចំណូលចិត្តរបស់មនុស្សក្នុងទំនាក់ទំនង រវាងឱនភាព(ភាពបញ្ចប់) និងគុណភាព(ភាពកំរ) ទៅលើជំរើសវិធីប្រើប្រាស់មានន័យថាជាទំនាក់ទំនងរវាង៖

ក. ការសម្រេចចិត្ត និងការជ្រើសរើសវិធីប្រើប្រាស់ប្រភពធនធានដែលមានកំណត់

ខ. ការបំពេញបំណង និងសេចក្តីត្រូវការរបស់មនុស្សគ្រប់មជ្ឈដ្ឋានដែលមានបំណងខុសៗគ្នាហើយច្រើន លើសលុបដោយឥតគណនាបាន

គ. ការរួមចំណែក និងការសំរេចចិត្តរបស់មនុស្សលើមធ្យោបាយដ៏ល្អប្រសើ ដើម្បីប្រើប្រាស់ធនធានតាម លទ្ធភាពដែលអាចប្រើប្រាស់បានគឺប្រើប្រាស់ធនធានឲ្យអស់លទ្ធភាព(ការបង្ហាញបញ្ហាទូទៅនៃសេដ្ឋកិច្ចវិទ្យា)។




**រូបភាព២១.៖ ធនធានខ្សត់កម្រក្នុងការបំពេញសេចក្តីពេញចិត្តរវាងចំណង់ឥតព្រំដែនរបស់មនុស្ស និង ផលិតកម្ម)**The Scarce Resources Attempt to Satisfy Unlimited Wanted via Production(

គំលាតរវាងអ្វីដែលមនុស្សចង់បាន និងអ្វីដែលមនុស្សអាចរកបានពិតប្រាកដនោះ គឺជាខ្លឹមសារជាសារវន្ត នៃសេដ្ឋកិច្ច។ ភាពបាត់បង់នូវគំលាតរវាងសេចក្តីសង្ឃឹមនឹងសេចក្តីសំរេចបំណង សេដ្ឋកិច្ចមិនត្រូវបានលើក យកមកសិក្សាលំអិត អោយគ្រប់ជ្រុងជ្រោយពេកទេ ប៉ុន្តែក្នុងស្ថានភាពនៃជីវភាពជាក់ស្តែងប្រចាំថ្ងៃគំលាតនេះកើត ឡើងជាប្រចាំហើយជាក្តីកង្វល់ (Preoccupation) របស់សេដ្ឋកិច្ចវិទូគ្រប់រូប ដើម្បីស្វែងរកមធ្យោបាយ ដោះស្រាយ និងប្រើប្រាស់វិធានការក្នុងគោល បំណងបន្ថយចុះអតិបរមានូវគម្លាត។

ក្នុងភាសាសាមញ្ញ ពាក្យថា សេដ្ឋកិច្ច ត្រូវបានគេនិយមហៅថាជា វិទ្យាសាស្ត្រអនុវត្តន៍នូវទ្រឹស្តីសេដ្ឋកិច្ច ដោយយកចិត្តទុកដាក់ ដើម្បីដោះស្រាយទៅលើរាល់បញ្ហាដែលកើតមានឡើង និងទាក់ទងទាំងស្រុង នៅក្នុង វិស័យកសិកម្ម មានន័យថា ជួយប្រជាកសិករអោយចេះសម្រេចចិត្តក្នុងការជ្រើសរើសថាតើ ប្រភេទស្បៀងអាហារ អ្វីដែលគាត់ផលិតបានគួរកំណត់ក្នុងកម្រិតណា ហើយប្រភេទដំណាំ ឬសត្វចិញ្ចឹមមួយណាដែលគាត់ ប្រត្តិបត្តិដើម្បីសមល្មម។ យ៉ាងនេះហើយទើបគេសន្និដ្ឋានថា សេដ្ឋកិច្ច

កសិកម្ម គឺជាវិទ្យាសាស្ត្រសង្គមទាក់ទង ផ្ទាល់ទៅនឹងកាត់ចាត់ចែង ឬបែងចែកធនធានកម្រក្នុងការប្រើប្រាស់ សំដៅធ្វើការផលិត ធ្វើការកែច្នៃ និងលក់ដូរនូវ ភោគផលរបស់ខ្លួន។

លោកសាស្ត្រាចារ្យ Gray បានពោលថា សេដ្ឋកិច្ចគឺជាវិទ្យាសាស្ត្រដែលអនុវត្តន៍នូវច្បាប់ គ្រឹះ និងវិធីសាស្ត្រនៃសេដ្ឋកិច្ចវិទ្យា ដើម្បីប្រើប្រាស់ក្នុងលក្ខខណ្ឌចាំបាច់ និងពិសេសនៃ កសិ-ឧស្សាហកម្ម" ។ លោក A.W Ashby បានកំណត់និយមន័យថា "សេដ្ឋកិច្ចកសិកម្ម គឺជាវិទ្យាសាស្ត្រអនុវត្តន៍សំដៅស្វែង រកវិធីសាស្ត្រ ដ៏ល្អប្រសើរក្នុងពុទ្ធិវិទ្យាសាស្ត្រសេដ្ឋកិច្ច ដើម្បីធ្វើការកែច្នៃ និងរៀបចំផលិតកម្មកសិកម្មក្នុងគោល បំណងធ្វើអោយ មានស្ថេរភាព និរន្តរភាព និងកែលំអរបែបផែនផលិតកម្ម ក្នុងកសិកម្ម ហើយក្នុងករណីចាំបាច់ គេធ្វើអោយមានការ កែទំរង់ផលិតកម្មទាំងស្រុង"។

លោក Hibbard បានឱ្យនិយមន័យថាសេដ្ឋកិច្ចកគឺជាការសិក្សាស្រាវជ្រាវនូវទំនាក់ទំនង ដែលកើតមានឡើងរវាងសកម្មភាពរៀបចំទ្រព្យសម្បត្តិនិងការប្រើប្រាស់ទ្រព្យសម្បត្តិទាំងអស់របស់មនុស្សក្នុងវិស័យកសិកម្ម "មានន័យថា សេដ្ឋកិច្ចកសិកម្ម មិនត្រឹមតែជាវិទ្យាសាស្ត្រផ្តោតអារម្មណ៍ទៅលើអាជីវកម្មនៃដីធ្លី តែមួយមុខសុទ្ធសាធប៉ុណ្ណោះទេ ជាសកម្មភាពសេដ្ឋកិច្ចពេញលេញ នឹងជាក់លាក់ក្នុងការស្វែងរកសុខុមាលភាព (Well-Being) ជូនប្រជាកសិករទៀតផង។

ចំពោះ លោក Jouzier វិញ សេដ្ឋកិច្ចគឺជាមែកធាងមួយនៃវិទ្យាសាស្ត្រកសិកម្មដែលបកស្រាយនូវរបៀប របបនៃទំនាក់ទំនងតាមលំដាប់ថ្នាក់នៃធនធានផ្សេងៗ របស់ប្រជាកសិករ ធនធានទាំងនោះមានទំនាក់ទំនងទៅវិញ ទៅមកក្នុងការប្រើប្រាស់ជាផលប្រយោជន៍របស់មនុស្ស ហើយមានលទ្ធភាពរកបានជាអតិបរមានឹងប្រកបដោយ វិបុលភាព (prosperty) សំរាប់សហគ្រាសផលិតកម្មកសិកម្ម។

សង្ខេបសេចក្តីមក យើងកំណត់និយមន័យដូចតទៅ "សេដ្ឋកិច្ចគឺជាវិទ្យាសាស្ត្រអនុវត្តន៍សំខាន់ស្តីពី បញ្ហាសេដ្ឋកិច្ចដែលទាក់ទងផ្ទាល់ទៅនឹងការខិតខំប្រឹងប្រែងរបស់ប្រជាកសិករក្នុងការប្រកបរបរចិញ្ចឹម ជីវិត"។ បញ្ហាជា ច្រើនរាប់មិនអស់ហើយប្រកបដោយភាពស្មុគស្មាញតែងតែកើតមានឡើងជាញឹកញាប់ចំពោះ កសិករ តែទោះជាយ៉ាងនេះក្តី ឈរលើមូលដ្ឋាននៃលក្ខណៈវិនិច្ឆ័យជាក់លាក់ យើងអាចប្រមូលផ្តុំបញ្ហាទាំងឡាយ ខាងលើអោយនៅត្រឹមបីកម្រិតសំខាន់ៗគឺ៖

ក. ផលិតកម្ម (Production)

ខ. ការងារទីផ្សារ (Marketing)

គ. ហិរញ្ញប្បទាន (Financing)

ជាងនេះទៅទៀតសេដ្ឋកិច្ចកសិកម្មបានបញ្ជាក់យ៉ាងច្បាស់លាស់ អំពីការវិវត្តន៍សមស្របនៃមូលដ្ឋាន នៃអភិបាល ទំហំផ្ទៃដីផលិតកម្ម ចំនួនកម្លាំងពលកម្ម និងទ្រង់ទ្រាយទ្រព្យធនដែលប្រជាកសិករទាំងឡាយគួរ គប្បីប្រើប្រាស់ ដើម្បីទាញយកផលប្រយោជន៍ដ៏លើសលុបក្នុងមុខរបររបស់ខ្លួន។ សេដ្ឋកិច្ចកសិកម្មក៏បាន បង្ហាញច្បាស់ផងដែរនូវវិធីសាស្ត្រផ្សេងៗ ជាអានុភាពជះឥទ្ធិពលទៅលើថ្លៃនៃភោគផល គ្រប់ប្រភេទដែលកសិករ ត្រូវទិញចូលលក់ចេញ ឬ ដោះដូរ។ ពិសេសគឺទំនាក់ទំនងរវាងកសិកម្ម និងប្រសិទ្ធិភាពសេដ្ឋកិច្ច ក្នុងផលិតកម្ម កសិកម្ម។

ឈរលើមូលដ្ឋាននៃវិទ្យាសាស្ត្រអនុវត្តន៍ អ្នកសេដ្ឋកិច្ចកសិកម្ម មានតួនាទីដ៏សំខាន់ និងចាំបាច់ត្រូវរៀប អោយបានជាក់លាក់ (formulate) នូវវិធីសាស្ត្រ (methods) បច្ចេកទេស (Tecniques)

និងទំរង់ការផ្សេងៗ (Procedures) ដើម្បីផ្តើមគំនិតដោះស្រាយរាល់បញ្ហាក្នុងកសិកម្ម។ តែទោះជាយ៉ាងណាក្តីប្រការទាំងឡាយដូច ដែលបានពោលខាងលើ គឺពិតជាមុខងារដ៏សែនលំបាកសំរាប់អ្នកសេដ្ឋកិច្ចកសិកម្មយកទៅប្រតិបត្តិ។

ដូច្នេះ សរុបសេចក្តីមក យើងអាចកំណត់បានថា "សេដ្ឋកិច្ចគឺជាវិទ្យាសាស្ត្រអនុវត្តន៍ស្តីអំពី ការកំណត់អត្តសញ្ញាណកម្ម ការពិពណ៌នា និងការធ្វើ ឋានានុក្រម នូវរាល់បញ្ហាសេដ្ឋកិច្ច (The economic problems) ដែលកើត មានឡើងក្នុងកសិកម្ម ហើយធំបំផុតបញ្ហាទាំងនោះត្រូវបាន ដោះស្រាយ"។

ភាពស្មុគស្មាញនៃការពិចារណានិងបែងចែកធនធានក្រខ្សត់សំរាប់ផលប្រយោជន៍សំបូរបែបក្នុង ផលិតកម្ម កសិកម្ម គឺជាបញ្ហាចំបងដែលប្រជាកសិករតែងតែជួបប្រទះពិសេសគឺធនធានដីធ្លីដែលជាមូលដ្ឋាន នៃផលិតកម្ម កសិកម្ម ព្រោះធនធានដីធ្លីមានកំរិត និងមានព្រំដែនច្បាស់លាស់។ សេដ្ឋកិច្ចកសិកម្មអនុវត្តន៍ទ្រឹស្តី និងបទពិសោធន៍សមស្របទៅនិងលក្ខណៈពិសេសនៃផលិតកម្មកសិកម្មតាមស្ថានភាពជាក់ស្តែង ពិសេសគឺ ប្រចាំ តំបន់ក្នុងបំណង ជំរុញទិន្នផលផលិកម្ម និងប្រសិទ្ធភាពសេដ្ឋកិច្ចកើនឡើងខ្ពស់។

បញ្ហាក្នុងសេដ្ឋកិច្ច គឺយើងមិនមានប្រភពធនធានគ្រប់គ្រាន់សំរាប់ផលិតទំនិញនិង សេវាកម្មដែលយើងចង់បាន។ ប្រភពធនធានជាអ្នកកំណត់ចំណង់មិនមានព្រំដែនរបស់យើង។ យើងនឹងសិក្សាទស្សនទាននៃប្រភពធនធានសេដ្ឋកិច្ច ធនធាន កម្រ និងភាពពេញចិត្តរបស់ចំណង់មនុស្ស។ ត្រូវចងចាំថាយើងមិនអាចផលិតនូវរាល់អ្វីៗ ដែលយើងចង់បាននោះគឺដោយសារបញ្ហាធនធានកម្រ ដូច្នេះត្រូវប្រើប្រាស់វាឲ្យមាន ប្រសិទ្ធិភាពជាកំរិតអតិបរមា។ លោក ហ្វ្រង់ស័រហ្គេសណេ (Francois Quesnay) ពោលថា « ដើម្បីរក្សាស្ថេរភាពនៃភាពរីករាយជាមួយនឹង ផលិតភាពដ៏ស្តួចស្តើងយើងចាំបាច់ត្រូវ ផ្តោតលើសេដ្ឋកិច្ច»។ លោក F.V Meyer « សេដ្ឋកិច្ចវិទ្យា គឺជា វិទ្យាសាស្ត្រនៃភាព លោភលន់»។

សេដ្ឋកិច្ចគឺជាការសិក្សានៃការប្រើប្រាស់ធនធានផលិតកម្មមានកំណត់នៅក្នុងសង្គមដើម្បីបំពេញសេចក្តីពេញចិត្ត នៃចំណង់ឥតព្រំដែនរបស់មនុស្ស ( Economics is the study of the use of limited productive in a society to satisfy the unlimited desires of its members.)។

សេដ្ឋកិច្ចជាវិទ្យាសាស្ត្រសង្គម ដែលសិក្សាអំពីការបែងចែកធនធានសម្រាប់ ផលិតកម្មទំនិញ និង សេវាកម្ម ដើម្បីបំពេញចំណង់គ្មានព្រំដែន (Unlimited Wants) របស់អ្នកប្រើប្រាស់ (Consumers)។

សេដ្ឋកិច្ច (Economics) ជាវិទ្យាសាស្ត្រសង្កេត (Observation) ដើម្បីធ្វើការសម្រេចចិត្តក្នុងការបកស្រាយពន្យល់អ្វីមួយ។ សង្កេត (Observation) គឺជាការប្រមែលប្រមូលព័ត៌មាននានា ដែលគេចង់សិក្សាបន្ទាប់មកយកព័ត៌មានដែលប្រមូលបានមកពិនិត្យរួចយកវាទៅរៀបតាមលំដាប់ថ្នាក់ហើយធ្វើការបកស្រាយបង្ហាញនូវរាល់ព័ត៌មានទាំងនោះដើម្បីធ្វើការសម្រេចចិត្តអ្វីមួយ។

Observation = To Collect + To Examine / to verify + To order + To present

ការបែងចែក (Allocation) គឺជាដំណើរចែកចាយធនធានសម្រាប់ផលិតកម្មទំនិញ និង សេវាកម្មនិងការចែកចាយទំនិញនិងអ្នកប្រើប្រាស់ (Users)។

ធនធានសេដ្ឋកិច្ច (Economic Resources) គឺជាការប្រើប្រាស់ Inputs ក្នុងដំណើរការផលិតកម្ម។ (Economic Resource is the inputs used in the process of production.)ផលិតកម្ម (Production) គឺជាដំណើរការនៃការប្រើប្រាស់វត្ថុធាតុដើម និង Inputs ពលកម្មដើម្បីបង្កើតជាទំនិញ និង សេវាកម្មនានា(Production is the process of using material and labor inputs to create goods and services)។

ធាតុចូល(Inputs) គឺជាធនធានផលិតកម្មនៃខឿនសេដ្ឋកិច្ចជាតិមួយ ដែលគេប្រើប្រាស់ធាតុចូលទាំងនេះដើម្បីផលិតនូវផលិតផល(Inputs are the productive resources an economy uses to produce its outputs.)។

ផលិតផល ឬធាតុចេញ(Outputs)គឺជាផលិតផលជាទំនិញ និងសេវាកម្មនានារបស់ខឿនសេដ្ឋកិច្ចជាតិមួយ(Outputs are the goods and services an economy produces.)។

ខឿនសេដ្ឋកិច្ចជាតិ(Economy)គឺជាយន្តការនៃការឆ្លងកាត់ការប្រើប្រាស់ ពលកម្ម(Labor), ដីធ្លី(Land) រចនាសម្ព័ន្ធ(Structure) យានយន្តផ្សេងៗ(Vehicle) សម្ភារៈបរិក្ខា (Equipment) និងធនធានធម្មជាតិ(Natural Resources)ទាំងឡាយ ត្រូវបានរៀបចំឡើងដើម្បីបំពេញសេចក្ដីពេញចិត្តនៃបំណងប្រាថ្នានៃជីវភាពរស់នៅរបស់មនុស្សក្នុងសង្គមជាតិ(Economy is the mechanism through which the use of labor, land, structures, vehicle, equipment, and natural resources is organized to satisfy the desires of those who live in a society.)។

ក្នុងខឿនសេដ្ឋកិច្ចទីផ្សារសេរី អ្នកផលិតត្រូវគិតថា

- តើផលិតអ្វី?(What gets produced?)
- ផលិតយ៉ាងដូចម្ដេច?(How is it produced?)
- ផលិតសម្រាប់នរណា(who gets what is produced?)។




រូបភាព២២.៖ មូលដ្ឋានគ្រឹះទាំងបី )The Three Basic Questions)

## ២.២. តម្រូវការ និងផ្គត់ផ្គង់

### ២.២.១. លំនាំដើមនៃទីផ្សារ( An Introduction to The Market )

#### ក.ទីផ្សារ

ទីផ្សារ ជាអង្គភាពដោះដូរផលិតផលរវាងអ្នកទិញ និងអ្នកលក់ក្នុងក្របខ័ណ្ឌតំបន់ភូមិសាស្ត្រមួយ និងនៅក្នុងរយៈពេលមួយជាកំណត់។ ផលិតផលប្រើប្រាស់ទាំងឡាយដែលគេដោះដូរនៅក្នុងទីផ្សារអាចជា ទំនិញ សេវាកម្ម ឬអាចជាធនធាន។

សរុបសេចក្តីមក គេអាចកំណត់និយមន័យទីផ្សារយ៉ាងសាមញ្ញថា ទីផ្សារគឺជាកន្លែងដែលទំនិញត្រូវបានទិញនិងលក់។ នៅខណៈពេលដែលទ្រឹស្តីនៃចរិតទីផ្សារត្រូវបានអភិវឌ្ឍទ្រឹស្តីទាំងនេះត្រូវបានពង្រីកគ្រាប់ដណ្តប់លើបណ្តាទំនិញទាំងឡាយដូចជាស្រូវសាឡី។ ស្រូវសាឡីបានផលិតឡើងនូវពាក្យពេញកន្លែងនៅក្នុងពិភពលោកហើយអាចទិញបានស្ទើរតែគ្រប់ទីកន្លែងនៅក្នុងពិភពលោក ហើយតម្លៃបងវាមាននិន្នាការស្ទើរតែស្មើៗគ្នា។ នៅពេលដែលយើងនិយាយអំពីទីផ្សារស្រូវសាលីសញ្ញាណនៃទីផ្សារមួយត្រូវបានពង្រីកយ៉ាងល្អនៅពីក្រោយគំនិតនៃកន្លែងមួយដែលអ្នកផលិត អ្នកស្តុក និងគ្រួសារនៅលក់ និងទិញ។

ដូចគ្នានេះដែរ ទីផ្សាររូបិយប័ណ្ណគ្មានទីតាំងជាក់លាក់ទេ។ វាធ្វើប្រតិបត្តិការឆ្លងតាមទូរសព្ទអន្តរជាតិនិងបណ្តាញកុំព្យូទ័រដែលធ្វើឱ្យឈ្មួលអាចទិញ និងលក់ ដុល្លា ស្ទែលិង និងរូបិយវត្ថុជាតិដទៃទៀត។ ទីផ្សារទាំងឡាយអាចប្រើប្រាស់ឧបករណ៍ទាំងអស់ដែលអាចនឹកស្មានដល់នៃគមនាគមន៍រួមមានសារព័ត៌មាននៅក្នុងករណីនៃទីផ្សារសម្រាប់ទំនិញប្រើរួច( Second hand )ដូចជារថយន្ត។

ប្រសិនបើអ្នកមានរថយន្តសម្រាប់លក់ ឬក៏ចង់ទិញអ្នកនឹងរកឃើញមាននៅក្នុងសារព័ត៌មានក្នុងស្រុក និងការបិទប្រកាសទស្សនាវដ្តីជំនាញ និងឈ្មួញរថយន្តប្រើរួច។

នៅក្នុងនៃសម័យថ្មី ទីផ្សារមួយសំដៅទៅលើស្ថានភាពណាដែលអ្នកទិញ និងអ្នកលក់អាចចូលចិត្តរបស់ដូចមាត់ផលខ្លះ។

#### ខ.តួនាទីរបស់ថ្លៃនៅក្នុងទីផ្សារ (The important role of price in the market)

ថ្លៃគឺជាបរិមាណប្រាក់ ឬផលិតផលដទៃទៀត ដែលចំណាយដើម្បីទិញផលិតផល ណាមួយនៅលើទីផ្សារ។ តាមនិយមនេះ យើងឃើញថា ថ្លៃគឺជាអ្វីដែលអ្នកទិញបង់ទៅឲ្យអ្នកលក់នៅក្នុងការដោះដូរ។ នៅក្នុងខឿនសេដ្ឋកិច្ចទំនើបបច្ចុប្បន្ន គឺទំនិញត្រូវបានគេដោះដូរតាមរយៈប្រាក់។ តែតាមការពិតប្រាក់ខ្លួនវានោះគ្មានតម្លៃទេ វាគ្រាន់តែប្រើដើម្បីសម្តែងថ្លៃប៉ុណ្ណោះ។ នៅក្នុងប្រវត្តិសេដ្ឋកិច្ចបុរាណគឺការដោះដូរបានប្រព្រឹត្តទៅដោយយកវត្ថុមួយទៅដូរយកវត្ថុមួយផ្សេងទៀត។

ឆ្លងកាត់តាមការដោះដូរផលិតផលនៅលើទីផ្សារ គឺថ្លៃមានតួនាទីសំខាន់ពីរ : ទីមួយគឺវាផ្តល់ដំណឹងទៅឲ្យអ្នកលក់ និងអ្នកទិញ, ទីពីរ គឺថ្លៃជាអ្នកលើកទឹកចិត្តដល់អ្នកទិញ និងអ្នកលក់។

**គ.ទីផ្សារជាយន្តការនៃការបែងចែកធនធាន**(A market as an allocative mechanism)

មុខងារថ្លៃទាំងពីរខាងលើជាឧបករណ៍យ៉ាងសំខាន់ក្នុងការបែងចែកធនធាន។ ការពិតទីផ្សារជាអ្នកឆ្លើយតបចំពោះសំណួរទាំងបីនៃការបែងចែកធនធានគឺៈ

តើទំនិញអ្វីដែលត្រូវផលិត? (What to prouce?)

ទីផ្សារជាអ្នកកំណត់ផលិតផលអ្វីខ្លះ ដែលគេត្រូវផលិតដើម្បីឆ្លើយតបទៅនឹងទំនាក់ទំនងថ្លៃ។ ប្រសិនបើថ្លៃផលិតផលមួយខ្ពស់ ឬកើនឡើងដោយធៀបទៅនឹងថ្លៃនៃផលិតផលដទៃទៀត ពេលនោះវាជំរុញឲ្យអ្នកផ្គត់ផ្គង់បន្ថែមការលក់ផលិតផលរបស់ខ្លួន ហើយបន្ទាប់មកក៏លើកទឹកចិត្តដល់ផលិតករបង្កើតការផលិតផល ហើយនាំឲ្យគេត្រូវការធនធាន (Resource) បន្ថែមទៀតដើម្បីបង្កើនការផលិតនោះ។ ក៏ប៉ុន្តែនៅពេលមានការបន្ថែមធនធាននោះ ទាមទារឲ្យមានការបែងចែកធនធានឡើងវិញ ពីការផលិតផលិតផលមួយដើម្បីទៅផលិតផលមួយទៀត។ ជាឧទាហរណ៍ប្រសិនបើថ្លៃពោតកើនឡើង គឺជំរុញឲ្យកសិករបង្កើនផលិតផលពោតថែមទៀត ដោយធ្វើការប្រមូលបន្ថែមនូវ ផ្ទៃដី គោយន្ត និងសម្ភារៈផ្សេងទៀត ហើយនឹងពលកម្ម ពីការផលិតកសិផលផ្សេងទៀតដូចជា កប្បាសជាដើម ព្រោះកប្បាសវាមានទំនាក់ទំនងថ្លៃទាបជាង។

តើត្រូវផលិតដោយវិធីណា? (How to produce?)

ប្រសិនបើធនធានមួយមានតម្លៃធៀបខ្ពស់ជាងធនធានមួយទៀត ពេលនោះផលិតករនឹងធ្វើការជំនួសយកធនធានណាដែលមានតម្លៃធៀបតិចជាងមកប្រើប្រាស់វិញ។ ជាឧទាហរណ៍ បើយើងប្រៀបធៀបឈ្នួលពលកម្មនៅប្រទេសអាមេរិក គឺ ខ្ពស់ជាងឈ្នួលពលកម្មនៅប្រទេសកម្ពុជា។ ដូច្នេះនៅក្នុងការផលិតកសិផល គឺនៅអាមេរិក គឺមានការប្រើប្រាស់ពលកម្មតិច តែចំណាយទៅលើគ្រឿងម៉ាស៊ីនច្រើន ចំណែកនៅកម្ពុជាវិញគឺគេប្រើកម្លាំងមនុស្សច្រើន តែបន្ថយកត្តាមូលធន ដូចគោយន្តជាដើម ក្នុងការបង្កបង្កើតកសិផល។

តើត្រូវផលិតសម្រាប់អ្នកណា? (For whom to produce)

ទីផ្សារក៏ត្រូវតែជាអ្នកកំណត់ថា តើអ្នកណាដែលត្រូវទទួលយកផលិតផលដែលគេផលិតបាន។

ទីផ្សារធ្វើការបែងចែក(allocation)ផលិតផលទៅអ្នកទិញទាំងឡាយណា ដែលមានចំណង់ (Willing) និងលទ្ធភាព(able) ចំណាយចំពោះថ្លៃខ្ពស់ជាងគេ។ ជាឧទាហរណ៍ឧបមាថាសក្តានុពលរបស់អ្នកទិញម្នាក់ហ៊ានចំណាយប្រាក់ ៥០០០ ដុល្លា សម្រាប់ទិញឡានម៉ាក Camaro តែប្រសិនបើមានអ្នកដទៃទៀតហ៊ានឲ្យតម្លៃលក់ ៧០០០ ដុល្លានោះ ឈ្មួញអ្នកលក់ឡាននឹងលក់ទៅឲ្យអ្នកដែលហ៊ានថ្លៃខ្ពស់ជាង។

## ២.២.២. តម្រូវការកសិផល (Demand of Agriculture Products)

**ក.អត្ថន័យនៃពាក្យតម្រូវការ**

ពាក្យ "តម្រូវការ" វាមានន័យខុសគ្នាក្នុងជីវភាពប្រចាំថ្ងៃ និងក្នុងន័យសេដ្ឋកិច្ចដែលកំណត់ដោយសេដ្ឋវិទូ។

នៅក្នុងជីវភាពប្រចាំថ្ងៃគេប្រើពាក្យតម្រូវការនេះសម្រាប់បញ្ជាក់ពីបំណងរបស់គេដែលចង់បានអ្វីមួយដោយគ្មាគោរពទៅតាមគោលការណ៍អ្វីឡើយ។ ជាឧទាហរណ៍ដូចជា៖ ខ្ញុំត្រូវការសម្រាកនៅម៉ោង១០យប់។ គាត់ត្រូវការម៉ូតូមួយគ្រឿងពីពូសំជាដើម។

ចំណែកឯនៅក្នុងន័យរបស់សេដ្ឋវិទូវិញ ពាក្យ "តម្រូវការ" គោរពទៅតាមគោលការណ៍របស់សេដ្ឋកិច្ច ដូចដែលយើងអាចឱ្យនិមយមន័យដូចខាងក្រោមនេះ៖

តម្រូវការគឺជាគោលការណ៍មួយដែលបង្ហាញពីទំនាក់ទំនងផ្ទុយគ្នារវាងថ្លៃទំនិញ និងសេវាទៅនឹងបរិមាណរបស់ទំនិញ និងសេវានោះដែលគេចង់ និងលទ្ធភាពទិញនៅក្នុងរយៈពេលមួយជាកំណត់ក្នុងលក្ខខណ្ឌដែលកត្តាដទៃទៀតនៅថេរ។

ពាក្យតម្រូវការត្រូវបានកំណត់ន័យដូចជាតារាងកំណត់ដែលបានបង្ហាញនូវចំនួនផលិតផលផ្សេងៗគ្នាជាច្រើនដែលអ្នកប្រើប្រាស់មានបំណង និងមានលទ្ធភាពទិញត្រង់ថ្លៃជាកលាក់នីមួយៗនៅក្នុងស៊េរីតម្លៃអាចទទួលយកបាននៅក្នុងរយៈពេលមួយជាកលាក់។ តម្រូវការពណ៌នាអំពីស៊េរីនៃលទ្ធភាពចម្លាស់ជាច្រើនដែលអាចកំណត់ក្នុងតារាងខាងក្រោម៖

| ថ្លៃ ($) / ថង់ | បរិមាណតម្រូវការ / សប្តាហ៍ |
|---|---|
| ៥ | ១០ |
| ៤ | ២០ |
| ៣ | ៣៥ |
| ២ | ៥៥ |
| ១ | ៨០ |

**តារាង២ .១៖.បរិមាណតម្រូវការចំពោះផលិតផលមួយ និងថ្លៃផ្សេងៗគ្នា**

ការសម្រេចចិត្តរបស់ក្រុមគ្រួសារមួយទៅលើបរិមាណទំនិញ និងសេវាជាក់លាក់មួយដែលពួកគេមានតម្រូវការគឺអាស្រ័យទៅនឹងកត្តាមួយចំនួនដូចជា៖

- ថ្លៃនៃផលិតផលនោះ
- ប្រាក់ចំណូលរបស់គ្រួសារ
- ចំនួនកំណើនទ្រព្យរបស់គ្រួសារ
- ថ្លៃផលិតផលជំនួស ឬផលិតផលដ៏ទៃទៀត
- ចំណង់ចំណូលចិត្តរបស់ក្រុមគ្រួសារ
- ការរំពឹងទុករបស់គ្រួសារអំពីចំណូលទ្រព្យសម្បត្តិ និងថ្លៃនាពេលអនាគត

ក្នុងការវិភាគអត្តចរិករបស់អ្នកទិញនៅលើទីផ្សារ យើងត្រូវគិតអំពីផលនៃដេទៃមីណង់នីមួយៗ។ យើងយកចិត្តទុកដាក់ជាពិសេសលើទំនាក់ទំនងរវាងថ្លៃរបស់ទំនិញ និងបរិមាណដែលអ្នកទិញនឹងអាចទិញបាន។ បរិមាណតម្រូវការនៃទ្រព្យមួយគឺជាបរិមាលាមួយដែលអ្នកទិញមានបំណង និងអាចទិញនូវកម្រិតថ្លៃណាមួយក្នុងរយៈពេលមួយកំណត់។

តម្រូវការ គឺជាទំនាក់ទំនងរវាងថ្លៃនៃទ្រព្យមួយនិងបរិមាណដែលត្រូវការ។ ពាក្យតម្រូវការដែលប្រើនៅក្នុងសេដ្ឋកិច្ចគឺមិនមែនជាចំនួនថេរទេ។ វាបង្ហាញថាតើបរិមាណដែលអ្នកទិញ និងអ្នកទិញប្រែប្រួលជាមួយថ្លៃយ៉ាងដូចម្តេចដោយសន្មតថាកត្តាផ្សេងៗទៀតក្រៅពីថ្លៃគឺនៅថេរ?

**ខ.តារាងតម្រូវការ(Demand Schedule for Agriculture Products)**

តារងតម្រូវការបង្ហាញពីបរិមាណផលិតផលដែលអ្នកប្រើប្រាស់ម្នាក់អាចនឹងមានបំណងទិញ និងមានលទ្ធភាពទិញក្នុងកម្រិតថ្លៃផ្សេងៗគ្នា។

តារាងតម្រូវការគឺជាតារាងមួយដែលបង្ហាញថា តើបរិមាណតម្រូវការនៃទ្រព្យមួយនឹងប្រែប្រួលជាមួយថ្លៃយ៉ាងដូចម្តេចបើអ្វីៗទៀតនៅថេរ?

តារាងតម្រូវការគឺជាតារាងមួយដែលបង្ហាញពីបរិមាណតម្រូវការនៃផលិតផលមួយចំនួនជាមួយការប្រែប្រួលនៃថ្លៃ ក្នុងរយៈពេលមួយកំណត់ ដោយសន្មតិថាអ្វីៗក្រៅពីថ្លៃនៅថេរ(A demand schedule is a table showing how the quantity demanded of some product during a specified period of time changes as the price of that product changes, holding all other determinants of quantity demanded constant.)។

តារាងតម្រូវការនៃផលិតផលកសិកម្មគឺជាវិធីបង្ហាញទំនាក់ទំនងរវាងបរិមាណតម្រូវការផលិតផលកសិកម្ម និងថ្លៃនៃផលិតផលកសិកម្មនោះដោយសន្និតថាបញ្ហាដទៃទៀតក្រៅពីថ្លៃនៅថេរ។ ពោលវាគឺជាតារាងបង្ហាញពីតួលេខរវាងបរិមាណផលិតផលកសិកម្ម នៅត្រង់ថ្លៃនៃផលិតផលកសិកម្មដែលបានជ្រើសរើស។

ឧទាហរណ៍ប្រសិនបើសាច់គោថ្លៃ ៦.៩០ ដុល្លា នោះបរិមាណតម្រូវការសាច់គោគឺ ៧៥ ឯកតា ហើយប្រសិនបើថ្លៃសាច់គោកើនដល់ ៧.៥០ ដុល្លា នោះបរិមាណតម្រូវការនឹងថយចុះមក ៤៥ ឯកតា។ ខ្សែកោងតម្រូវការមានស្លូប(Slope)អវិជ្ជមានគឺនៅពេលថ្លៃកាន់តែខ្ពស់នាំឱ្យបរិមាណតម្រូវការកាន់តែតិច។

**តារាង២២៖តម្រូវការសាច់គោ.(Demand Schedule for Beef)**

| ចំណុចនៃបន្ទំទីផ្សារ | ថ្លៃសាច់គោ (ដុល្លា) | បរិមាណសាច់គោ(គីឡូក្រាម) |
|---|---|---|
| a | ៧.៥០ | ៤៥ |
| b | ៧.៤០ | ៥០ |
| c | ៧.៣០ | ៥៥ |
| d | ៧.២០ | ៦០ |
| e | ៧.១០ | ៦៥ |
| f | ៧.០០ | ៧០ |
| g | ៦.៩០ | ៧៥ |

តារាងតម្រូវការកសិផល(Demand Schedule for Agricultural Products)គឺជាបញ្ជីនៃបរិមាណតម្រូវការកសិផលនៅត្រង់កម្រិតថ្លៃកសិផលផ្សេងៗគ្នា។ នៅពេលដែលអ្វីៗផ្សេងទៀតដែលជះឥទ្ធិពលនៃគម្រោងនៃការទិញរបស់អ្នកប្រើប្រាស់ផលិតផលកសិកម្មនៅថេរដូចជា៖ ថ្លៃនៃទំនិញកសិផលដែលទាក់ទង ចំណូលរបស់អ្នកប្រើប្រាស់កសិផល ការរំពឹងទុកទៅអនាគតនៃថ្លៃកសិផល ចំនួនអ្នកប្រើប្រាស់កសិផល និងចំណង់ចំណូលចិត្តរបស់អ្នកប្រើប្រាស់កសិផល(A demand schedule for agricultural commoditiy lists the quantities demanded for agricultural productsat each different price for agricultural goods, when all the other influences on consumers´ planned for agricultural product purchases – such as the price for agricultural product of the related goods, income, expected future prices for agricultural commodities, population, and prefences for agricultural products – remain the same.)។

ឧទាហរណ៍៖ ទំនាក់ទំនងរវាងថ្លៃ Pizza និងបរិមាណ Pizza បង្កើតបានជាតារាងតម្រូវការ Pizza។

ប្រសិនបើសាច់គោថ្លៃ ៦ ដុល្លា នោះបរិមាណតម្រូវការ Pizza គឺ ៥០ ឯកតា ហើយប្រសិនបើថ្លៃ Pizza ថយចុះមកដល់ ១ ដុល្លា នោះបរិមាណតម្រូវការនឹងកើនឡើងចុះមក ៣០០ ឯកតា។ ខ្សែកោងតម្រូវការមានស្លូប(Slope)អវិជ្ជមានគឺនៅពេលថ្លៃ Pizza កាន់តែចុះនោះនាំឱ្យបរិមាណតម្រូវការ Pizza កាន់តែច្រើន។

**តារាង២.៣៖តម្រូវការ Pizza(Demand Schedule for Pizza)**

| ចំណុចនៃបន្សំទីផ្សារ | ថ្លៃ Pizza (ដុល្លា) | បរិមាណ Pizza (ដុំ) |
|---|---|---|
| a | ១ | ៣០០ |
| b | ២ | ២៥០ |
| c | ៣ | ២០០ |
| d | ៤ | ១៥០ |
| e | ៥ | ១០០ |
| f | ៦ | ៥០ |

### គ.ខ្សែកោងតម្រូវការកសិផល (Demand Curve for Agriculture Products)

ខ្សែកោងតម្រូវការជាក្រាភិចតំណាងឱ្យច្បាប់តម្រូវការ។ ខ្សែកោងតម្រូវការបានសង់ឡើងដោយផ្អែកលើទំនាក់ទំនងរវាងថ្លៃ និងបរិមាណនៃទំនិញនោះ(A demand curve is a graphical representation of the demand schedule, another way of showing the relationship between the quantity demanded and price)។

ខ្សែកោងតម្រូវការគឺជាក្រាភិចមួយដែលពណ៌នាពីតារាងតម្រូវ។ វាបង្ហាញពីបរិមាណតម្រូវការនៃផលិតផលមួយចំនួនជាមួយនឹងការប្រែប្រួលនៃថ្លៃក្នុងរយៈពេលមួយកំណត់ដោយសន្មតិថាអ្វីៗក្រៅពីថ្លៃនៅថេរ( A demand curve is a graphical depiction of a demand schedule. It shows how the quantity demanded of some product will change as the price of that product changes during a specified period of time, holding all other determinants of quantity demanded constant )។

ឧទាហរណ៍រូបភាពខាងក្រោមគឺជាទំនាក់ទំនងរវាងថ្លៃសាច់គោ និងបរិមាណសាច់គោដែលបង្ហាញពីតារាងតម្រូវការសាច់គោនោះ វានឹងគូសបានខ្សែកោងតម្រូវការសាច់គោ។ ប្រសិនបើសាច់គោថ្លៃ ៧.៤០ ដុល្លា នោះបរិមាណតម្រូវការសាច់គោគឺ ៥០ ឯកតា ហើយប្រសិនបើថ្លៃសាច់គោចុះមកដល់ ៦.៩០ ដុល្លា នោះបរិមាណតម្រូវការនឹងកើនឡើងមកដល់ ៧៥ ឯកតា។ ខ្សែកោងតម្រូវការមានស្លូប( Slope )អវិជ្ជមានគឺនៅពេលថ្លៃកាន់តែចុះនោះនាំឱ្យបរិមាណតម្រូវការកាន់តែច្រើន។




**រូបភាព២.៣៖ ខ្សែកោងតម្រូវការសាច់គោ ( Demand Curve for Beef )**

តាមតារាងតម្រូវការទាំងពីរនៃផលិតផលសាច់គោ និងផលិតផល Pizza គឺជាសម្មតិកម្មតារាងតម្រូវការនៃផលិតផលសាច់គោ និងផលិតផល Pizza។ បើយោងទៅតាមព័ត៌មានដែលបានបង្ហាញនៅក្នុងតារាងតម្រូវការនៃផលិតផលសាច់គោ និងផលិតផល Pizzaនោះ គេសង្កេតឃើញថា បើថ្លៃនៃផលិតផលសាច់គោ និងផលិតផល Pizza កើនឡើងនោះ បរិមាណតម្រូវការនៃផលិតផលសាច់គោ និងផលិតផល Pizza នឹងមានចំនួនថយចុះ ផ្ទុយទៅវិញបើថ្លៃនៃផលិតផលសាច់គោ និងផលិតផល Pizza ថយចុះវិញនោះ បរិមាណនៃផលិតផលសាច់គោ និងផលិតផល Pizza នឹងមានចំនួនកើនឡើ

ង។ ជាទូទៅគេដៅអ័ក្សថ្លៃ(P)នៅលើអ័ក្សអាប់ស៊ីស(Vertical Axis) ហើយគេដៅបរិមាណផលិតផលនៅលើអ័ក្សអរដោនេ(Horizontal Axis)។

ម្យ៉ាងទៀត តាមការបង្ហាញជាហេតុផលនោះ គេបានបរិមាណផលិតផលសាច់គោ និងផលិតផល Pizza ជាអថេរដែលរងឥទ្ធិពលពីថ្លៃរបស់វា ឬអថេរដែលត្រូវបានគេកំណត់ ឬអថេរដែលត្រូវបានគេធ្វើការព្យាករណ៍គេហៅថាអថេរមិនឯករាជ្យ(Dependent Variable) រីឯថ្លៃនៃផលិតផលសាច់គោ និងថ្លៃនៃផលិតផល Pizza គឺជាអថេរដែលធ្វើការកំណត់ឱ្យគេ ឬអថេរធ្វើការព្យាករណ៍គេ ឬអថេរមិនចំណុះគេនោះ ហៅថាអថេរឯករាជ្យ(Independent Variable)។




រូបភាព២.៤៖ ខ្សែកោងតម្រូវការ Pizza (Demand Curve for Pizza)

ឧទាហរណ៍រូបភាពខាងលើគឺជាទំនាក់ទំនងរវាងថ្លៃ Pizza និងបរិមាណ Pizza ដែលបង្ហាញពីតារាងតម្រូវការ Pizza នោះ វានឹងគូសបានខ្សែកោងតម្រូវការ Pizza។ បើយោងទៅតាមទិន្នន័យនៃតារាងតម្រូវការ Pizza នោះ ប្រសិនបើថ្លៃ Pizza ស្មើនឹង ១ ដុល្លា នោះបរិមាណតម្រូវការ Pizza ស្មើនឹង ៣០០ ដុំ ចំណែករីឯថ្លៃ Pizza ស្មើនឹង ៦ ដុល្លា នោះបរិមាណតម្រូវការ Pizza នឹងថយចុះមកត្រឹមតែនឹង ៥០ ដុំ។

ម្យ៉ាងទៀត រូបភាពខាងក្រោមនេះគឺបង្ហាញពីទំនាក់ទំនងរវាងថ្លៃកប្បាសនិងបរិមាណកប្បាស ហើយវាបង្កើតបានជាតារាងតម្រូវការកប្បាស និងខ្សែកោងតម្រូវការកប្បាស ដូចដែលបានបង្ហាញដូចខាងក្រោម។ ជាទូទៅគេសង្កេតឃើញថា បើថ្លៃកប្បាសចុះថោកនោះ បរិមាណតម្រូវការកប្បាសនឹងកើនឡើង ផ្ទុយទៅវិញ បើថ្លៃកប្បាសកាន់តែកើនឡើង នោះបរិមាណតម្រូវការកប្បាសកាន់តែតិចៗទៅ ទាំងអស់នេះវាគោរពទៅតាមច្បាប់នៃតម្រូវការនៃផលិតផលកប្បាសនៅលើទីផ្សារជាក់ស្តែង។




Demand Schedule for Cotton

| Price of cotton (per pound) | Quantity of cotton demanded (billions of pounds) |
|---|---|
| $2.00 | 7.1 |
| 1.75 | 7.5 |
| 1.50 | 8.1 |
| 1.25 | 8.9 |
| 1.00 | 10.0 |
| 0.75 | 11.5 |
| 0.50 | 14.2 |

រូបភាព២.៥៖ តារាងតម្រូវការកប្បាស និងខ្សែកោងតម្រូវការកប្បាស

A Demand Schedule for Carrots

| Reference Point | Price ($ per tonne) | Quantity Demanded (tonnes per year when average annual income is $50 000) |
|---|---|---|
| *U* | 20 | 110 |
| *V* | 40 | 85 |
| *W* | 60 | 65 |
| *X* | 80 | 50 |
| *Y* | 100 | 40 |

A Demand Curve for Carrots




Both the table and the graph show the total quantity of carrots that would be demanded at various prices, *ceteris paribus*. For example, row *W* indicates that if the price of carrots were $60 per tonne, consumers would desire to purchase 65 tonnes of carrots per year, holding constant the values of the other variables that affect quantity demanded. The demand curve, labelled *D*, relates quantity of carrots demanded to the price of carrots; its negative slope indicates that quantity demanded increases as price falls.

### ឃ.ច្បាប់តម្រូវការកសិផល (Law Demand for Agricultural Products)

ជាទូទៅនិងអ្វីៗផ្សេងទៀតនៅថេរ ច្បាប់តម្រូវការចែងថាបើថ្លៃធ្លាក់ចុះកាន់តែទាបនោះ បរិមាណទំនិញដែលអ្នកទិញនឹងទិញក្នុងរយៈពេលមួយកំណត់កាន់តែកើនឡើង។ ផ្ទុយមកវិញ ប្រសិនបើថ្លៃកើនឡើងក្នុងខណៈដែលអ្វីៗទៀតនៅថេរនោះ អ្នកទិញនឹងទិញតិចជាងមុន។

ច្បាប់តម្រូវការគឺជាគោលការមួយដែលបង្ហាញពីទំនាក់ទំនងផ្ទុយគ្នារវាងថ្លៃនៃផលិតមួយទៅនឹងបរិមាណនៃផលិតផលនោះ ដែលអ្នកទិញចង់ )Willing) និងមានលទ្ធភាព )able) ទិញនៅក្នុងរយៈពេលមួយជាកំណត់ ក្នុងលក្ខខ័ណ្ឌដែលកត្តាដទៃទៀតមិនប្រែប្រួល។

ឥឡូវនេះអ្នកសន្មតខ្លួនឯងថាជាអ្នកទិញនោះ អ្នកជឿថាច្បាប់តម្រូវការពិតជាត្រឹមត្រូវសមហេតុសមផល។ អ្នកទិញសំលៀកបំពាក់ច្រើន ទិញទំនិញផ្សេងៗទៀតជាច្រើននៅពេលដែលថ្លៃរបស់ធ្លាក់ចុះហើយអ្វីទៀតអត់ប្រែប្រួល។ ហើយនៅពេលថ្ងៃកើនឡើងនោះអ្នកនិងបន្ថយនូវការទិញ។ ប្រសិនបើថ្ងៃ ទស្សនាភាពយន្តឡើងថ្លៃពី $4 ទៅ $8 នោះអ្នកនិងប្រហែលជាបន្ថយការទៅមើលភាពយន្ត ហើយរកការកំសាន្តផ្សេងវិញ។

ដើម្បីឲ្យយល់ពីច្បាប់តម្រូវការយើងពិនិត្យលើឧទាហរណ៍មួយ។ ឧបមាថាអ្នកចង់ទទួលទានអាហារក្រៅពេលមួយ ហើយអ្នកដឹងថាស្ករគ្រាប់សូកូឡា ១ ប្រអប់ថ្លៃ ០១ ដុល្លា នោះអ្នកនឹងត្រូវការ.វា ៥ ប្រអប់ តែបើអ្នកដឹងថាថ្លៃរបស់ស្ករសូកូឡា ០៦ដុល្លានោះ ប្រហែលជាអ្នកបន្ថយការទិញស្ករនោះ.។

ច្បាប់តម្រូវការភ្ជាប់មកជាមួយនូវការពិចារណាលើបញ្ហាពីរ៖

ទីមួយៈប្រសិនបើថ្លៃនៃទំនិញមួយកើនឡើង គឺអ្នកទិញនឹងបន្ថយការទិញទំនិញនោះ ហើយទៅវិញទំនិញដទៃទៀតដែលបណ្តាលមកពីឥទ្ធិពលជំនួស (Substitute effect) ឥទ្ធិពលជំនួស គឺជាការប្រែប្រួលក្នុងបរិមាណតំរូវការ ដែលបណ្តាលមកពីថ្លៃទំនិញមួយប្រែប្រួលដោយធៀបទៅនឹងថ្លៃទំនិញដទៃទៀត។

ឧបមាថា នៅពេលថ្លៃស្ករសូកូឡាកើន គឺគេទិញការ៉េមជំនួសវិញ។ ប្រសិនបើការ៉េមលក់ ០,៤០ ដុល្លា គឺនឹងបង្កើតការចំណាយប្រៀបធៀបមួយចំពោះថ្លៃ ០,១ ដុល្លា របស់ស្ករសូកូឡា។ ទោះជាអ្នកចូលចិត្តការ៉េមជាងស្ករសូកូឡាក៏ដោយ គឺអ្នកនឹងមានបំណងទំនិញស្ករសូកូឡា ៤ ជំនួសអោយការ៉េម ១។ តែបើស្ករសូកូឡាកើនដល់ ០,២ ដុល្លា អ្នកនឹងមានបំនងទិញស្ករសូកូឡា ២ ជំនួសអោយការ៉េម ១។ ជាទូទៅ បើស្ករសូកូឡាកាន់តែថោកជាងការ៉េម គឺថ្លៃស្ករសូកូឡានឹងកើនដោយធៀបជាមួយថ្លៃការ៉េម ដូច្នេះអ្នកនឹងទិញស្ករសូកូឡាជំនួសអោយការ៉េម។

ទីពីរ ៖ ដោយចំណូលមានព្រំដែន គឺអ្នកទិញនឹងទិញទំនិញតិចជាងនៅពេលថ្លៃកើនឡើង។ ឥទ្ធិពលចំណូល (Income effect) គឺជាការប្រែប្រួលបរិមាណតំរូវការដែលបណ្តាលពីការប្រែប្រួលថ្លៃវាផ្តល់នូវចំណូលជាក់ស្តែង (Real Income) ដល់អ្នកទិញថែមទៀតទោះជាប្រាក់ចំណូលមិនប្រែប្រួលក៏ដោយ។

សរុបសេចក្តីមក ច្បាប់តម្រូវការ(Law of Demand)ចែងថា បើថ្លៃនៃទំនិញមួយមានតម្លៃកាន់តែខ្ពស់នោះ បរិមាណតម្រូវការនៃទំនិញនោះគេទិញកាន់តែតិច។ ផ្ទុយទៅវិញ បើបើថ្លៃនៃទំនិញមួយមានតម្លៃកាន់តែចុះថ្លៃ(ថ្លៃទាប)នោះ បរិមាណតម្រូវការនៃទំនិញនោះគេទិញកាន់តែច្រើន(The Law demand states that other things remaining the same, the higher the price of a good, the smaller is the quantity demanded)។

ច្បាប់តម្រូវការបានចែង ជាទូទៅបើថ្លៃរបស់ទំនិញ ឬសេវាមួយកើនឡើង ហើយកត្តាដទៃមិនប្រែប្រួល នោះបរិមាណតម្រូវការរបស់អតិថិជន(អ្នកទិញ)លើទំនិញនោះនឹងថយចុះ។ តែបើថ្លៃទំនិញ ឬសេវាមួយធ្លាក់ចុះ(ចុះថោក) និងកត្តាដទៃទៀតនៅថេរ(មិនប្រែប្រួល) នោះបរិមាណតម្រូវការរបស់អតិថិជន(អ្នកទិញ)នឹងកើនឡើង។

មានន័យថា បើសិនថ្លៃរបស់ទំនិញមួយកើនឡើង គឺអ្នកទិញនឹងបន្ថយការទិញទំនិញនោះ ហើយទៅទិញទំនិញដទៃទៀតដែលអាចជំនួសទំនិញនោះបាន(សាច់គោអាចជំនួសសាច់ជ្រូកបាន) មូលហេតុនេះគឺវាបណ្តាលមកពីឥទ្ធិពលជំនួស។

**ឥទ្ធិពលជំនួស**គឺជាការប្រែប្រួលក្នុងបរិមាណតម្រូវការ ដែលបណ្តាលមកពីថ្លៃទំនិញមួយប្រែប្រួលដោយ ធៀបទៅនឹងថ្លៃដទៃទៀត។ ក្នុងករណីដោយចំណូលរបស់សង្គមមានព្រំដែនគឺអ្នកទិញទំនិញអាចទិញទំនិញតិចជាងមុន នៅពេលដែលថ្លៃកើនឡើងដោយឥទ្ធិពលចំណូល។

**ឥទ្ធិពលចំណូល**គឺជាការប្រែប្រួលបរិមាណតម្រូវការដែលបណ្តាលមកពីការប្រែប្រួល។ ម្យ៉ាងវិញទៀត ពេលដែលថ្លៃទំនិញមួយចុះថោក ហើយថ្លៃទំនិញដទៃទៀតនៅដដែល និងចំណូលថេររបស់សង្គម(អតិថិជន)នានា មនុស្សមានអារម្មណ៍ថា ខ្លួនឯងហាក់ដូចជាមានលទ្ធភាពទិញច្រើនជាងមុន

ហើយគេនឹងប្រើប្រាស់នូវកំណើនលទ្ធភាពទិញផ្ទុរផលិតផលដែលគេសម្រាប់ទិញទំនិញផ្សេងៗតែជាពិសេសគឺគេអាចទិញទំនិញដែលចុះថោកនោះតែម្តង។

**ង.ការប្រែប្រួលបរិមាណតម្រូវការ** (Change in the Quantity Demanded for Agricultural Products )

ជាទូទៅខ្សែរកោងតម្រូវការមានចំណោតចុះ។ ចំណោតអវិជ្ជមានឆ្លុះបញ្ចាំងពីទំនាក់ទំនង ផ្ទុយគ្នារវាងថ្លៃ និងបរិមាណតម្រូវការ ដោយយោលទៅតាមច្បាប់តម្រូវការ។ បរិមាណតម្រូវការកើន ឡើងនៅពេលដែលថ្លៃធ្លាក់ចុះ។

ការប្រែប្រួលបរិមាណតម្រូវការ គឺជាការប្រែប្រួលបរិមាណតម្រូវការផលិតផលមួយដែលអ្នកទិញមានបំណង និងមានលទ្ធភាពអាចទិញដោយឆ្លើយតបទៅនឹងការប្រែប្រួលថ្លៃ។ ការប្រែប្រួលបរិមាណតម្រូវការគឺតាងដោយការប្រែប្រួលនៅលើខ្សែរកោងតម្រូវការដែលបណ្តាលមកពីការកើនឡើងរឺធ្លាក់ចុះនៃថ្លៃរបស់ផលិតផលនោះ។

ការប្រែប្រួលថ្លៃទំនិញធ្វើឱ្យមានការប្រែប្រួលបរិមាណតម្រូវការ។ ការប្រែប្រួលបរិមាណតម្រូវការគឺជាចលនារត់លើខ្សែកោងតំរូវការដែលបណ្តាលពីការប្រែប្រួលថ្លៃទំនិញ។ ក្នុងក្រាភិចនៃផលិតផលសាច់គោយើងឃើញនៅពេលថ្លៃកើនធ្វើឱ្យមានចលនារត់ចំណុច H ទៅ A នៅខ្សែកោងតម្រូវការសាច់គោ(D)។ ការប្រែប្រួលថ្លៃជាកត្តាតែមួយគត់ដែលធ្វើឱ្យមានការប្រែប្រួលបរិមាណតម្រូវការ។

បរិមាណតម្រូវការសាច់គោគឺជាប់ទាក់ទងនឹងការរងឥទ្ធិពលនៃថ្លៃសាច់គោ។ ការប្រែប្រួលដែលបណ្តាលមកពីការប្រែប្រួលនៃចំនួនអ្នកទិញសាច់គោ ចំណូលអ្នកប្រើប្រាស់សាច់គោ និងចំណង់ចំណូលចិត្តនៃអ្នកប្រើប្រាស់សាច់គោ ថ្លៃនៃទំនិញកសិផលផ្សេងទៀតដូចជាសាច់ជ្រូក និងសាច់ត្រី វាគឺជាសញ្ញាណមួយនៃការប្រែប្រួលបរិមាណប្រើប្រាស់សាច់គោ បើទោះបីជាថ្លៃរបស់សាច់គោមិនប្រែប្រួល(ថ្លៃសាច់គោនៅថេរ)ក៏ដោយ(The quantity of beef demanded is subject to a variety of influences other than the price of beef. Changes in population size and characteristics, consumer incomes and tastes, and the prices of alternative products such as pork and fish presumably change the quantity of beef demanded, even if the price of beef does not change.)។

ដោយសារតែខ្សែកោងតម្រូវការសាច់គោពណ៌នាមិនត្រឹមតែពីទំនាក់ទំនងរវាងបរិមាណសាច់គោ និងថ្លៃសាច់គោដោយគេសន្មតិថាកត្តាអ្វីៗក្រៅពីថ្លៃនៅថេរនោះ គេហៅថាការប្រែប្រួលនេះថា វាគឺការប្រែប្រួលសាច់គោ(Because the demand curve for beef depicts only the relationship between the quantity of beef demanded and the price of beef, holding all other factors constant, a change in beef)។

តារាងតម្រូវការស៊ុត(Demand Schedule for Egg)

| ចំណុចនៃបន្សំទីផ្សារ | ថ្លៃស៊ុត (សេន | បរិមាណស៊ុត (ឡូ) |
|---|---|---|

| | ដុល្លា ) | |
|---|---|---|
| a | 0 | ៨0.000 |
| b | ៥ | ៧0.000 |
| c | ១0 | ៦0.000 |
| d | ១៥ | ៥0.000 |
| e | ២0 | ៤0.000 |
| f | ២៥ | ៣0.000 |
| g | ៣0 | ២0.000 |
| h | ៣៥ | ១0.000 |
| e | ៤0 | 00.000 |




រូបភាព៖ ខ្សែកោងតម្រូវការស៊ុត( Demand Curve for Egg )

ការប្រែប្រួលថ្លៃនៃផលិតផលកសិផលមួយដែលធ្វើចលនារត់នៅលើខ្សែកោងតម្រូវការតែមួយ ដោយមិនធ្វើការផ្លាស់ប្តូរទីតាំងខ្សែកោងតម្រូវការដោយសន្ទតិថាកត្តាអ្វីៗក្រៅពីថ្លៃនៅថេរនោះ គេហៅថាការប្រែប្រួលបរិមាណតម្រូវការកសិផលនោះ ផ្ទុយទៅវិញការប្រែប្រួលនៃអថេរដទៃទៀតក្រៅពីថ្លៃនៃផលិតផលនោះគេហៅថាការប្រែប្រួលតម្រូវការកសិផល(A change in the price of a good produces a movement along a fixed demand curve. By contrast, a change in any

other variable that influences quantity demanded produces a shift of the entire demand curve.)។




រូបភាព៖ ការប្រែប្រួលបរិមាណតម្រូវការ និងការប្រែប្រួលតម្រូវការកប្បាស

ការប្រែប្រួលបរិមាណតម្រូវការ(Change in Quantity Demanded) គឺជាការប្រែប្រួលបរិមាណទំនិញកសិផល ដែលអ្នកប្រើប្រាស់មានបំណង និងមានលទ្ធភាពអាចទិញបានដោយឆ្លើយតបទៅនឹងការប្រែប្រួលថ្លៃរបស់វា។ ការប្រែប្រួលបរិមាណតម្រូវការកសិផលគឺតាងដោយការប្រែប្រួលនៅលើខ្សែកោងតម្រូវការកសិផលដែលបណ្តាលមកពីការកើនឡើង ឬការធ្លាក់ចុះនៃថ្លៃរបស់កសិផលនោះ។




រូបភាព៖ ការប្រែប្រួលបរិមាណតម្រូវការ និងការប្រែប្រួលតម្រូវការ

ការប្រែប្រួលថ្លៃនៃផលិតផលកសិផលមួយដែលធ្វើចលនារត់នៅលើខ្សែកោងតម្រូវការតែមួយ ដោយមិនធ្វើការផ្លាស់ប្តូរទីតាំងខ្សែកោងតម្រូវការដោយសន្មតិថាកត្តាអ្វីៗក្រៅពីថ្លៃនៅថេរនោះ គេហៅថាការប្រែប្រួលបរិមាណតម្រូវការកសិផលនោះ ផ្ទុយទៅវិញការប្រែប្រួលនៃអថេរដទៃទៀតក្រៅពីថ្លៃនៃផលិតផលនោះគេហៅថាការប្រែប្រួលតម្រូវការកសិផល(A change in the price of a good produces a movement along a fixed demand curve. By contrast, a change in any other variable that influences quantity demanded produces a shift of the entire demand curve.)។




រូបភាព៖ ការប្រែប្រួលតម្រូវការ(Change in Demand)

ការប្រែប្រួលបរិមាណតម្រូវការ(Change in Quantity Demanded) គឺជាការប្រែប្រួលបរិមាណទំនិញកសិផល ដែលអ្នកប្រើប្រាស់មានបំណង និងមានលទ្ធភាពអាចទិញបានដោយឆ្លើយតបទៅនឹងការប្រែប្រួលថ្លៃរបស់វា។ ការប្រែប្រួលបរិមាណតម្រូវការកសិផលគឺតាងដោយការប្រែប្រួលនៅលើខ្សែកោងតម្រូវការកសិផលដែលបណ្តាលមកពីការកើនឡើង ឬការធ្លាក់ចុះនៃថ្លៃរបស់កសិផលនោះ។




| Price of rape seed Per tonne | Quantity of rape seed demanded (000s tonnes) |
|---|---|
| €0.00 | 10 |
| 0.50 | 9 |
| 1.00 | 8 |
| 1.50 | 7 |
| 2.00 | 6 |
| 2.50 | 5 |
| 3.00 | 4 |
| 3.50 | 3 |
| 4.00 | 2 |
| 4.50 | 1 |
| 5.00 | 0 |

រូបភាព៖ ការប្រែប្រួលបរិមាណតម្រូវការ(Change in Quantity Demanded)

### ច.ការប្រែប្រួលតម្រូវការកសិផល (Change in Demand for Agricultural Products)

តម្រូវការទីផ្សារនៃផលិតផលមួយគឺជាផលបូកនៃតម្រូវការបុគ្គលដែលមានតម្រូវការផលិតផលនោះក្នុងទីផ្សារជាក់ស្តែង។




រូបភាព៖ តម្រូវការទីផ្សារ

ឧទាហរណ៍៖ ផលបូកនៃតម្រូវការរបស់លោក Hanse ចំពោះផលិតផល Red Seed និងតម្រូវការលោក Michelle ចំពោះផលិតផល Red Seed បង្កើតបានជាតម្រូវការទីផ្សារផលិតផល Red Seed មួយ ដូចដែលបានបង្ហាញក្នុងតារាងតម្រូវការ ផលិតផល Red Seed ដូចខាងក្រោម។

| ថ្លៃ Red Seed | តម្រូវការ Hense | តម្រូវការ Michelle | តម្រូវការទីផ្សារ |
|---|---|---|---|
| ០.០០ | ១០ | ២០ | ៣០ |
| ០.៥០ | ៩ | ១៨ | ២៧ |
| ១.០០ | ៨ | ១៦ | ២៤ |
| ១.៥០ | ៧ | ១៤ | ២១ |
| ២.០០ | ៦ | ១២ | ១៨ |
| ២.៥០ | ៥ | ១០ | ១៥ |
| ៣.០០ | ៤ | ៨ | ១២ |
| ៣.៥០ | ៣ | ៦ | ៩ |
| ៤.០០ | ២ | ៤ | ៦ |
| ៤.៥០ | ១ | ២ | ៣ |
| ៥.០០ | ០ | ០ | ០ |

តារាង៖ តារាងតម្រូវការបុគ្គល និងទីផ្សារផលិតផល Red Seed

ខ្សែកោងតម្រូវការលោក Michelle ចំពោះផលិតផល Red Seed បង្កើតបានជាតម្រូវការទីផ្សារផលិតផល Red Seed មួយ ដូចដែលបានបង្ហាញក្នុងខ្សែកោងតម្រូវការចំពោះផលិតផល Red Seed និងខ្សែកោងតម្រូវការទីផ្សារចំពោះផលិតផល Red Seed ដូចខាងក្រោម៖




តារាង៖ ខ្សែកោងតម្រូវការបុគ្គល និងទីផ្សារផលិតផល Red Seed

ដូចដែរយើងបានសង្កេតពីមាន ទំនាក់ទំនងរវាងថ្លៃនៃទ្រព្យមួយហើយនិងបរិមាណតម្រូវការនៃផលិតផលនោះវាពឹងផ្អែកទៅលើឥទ្ធិពលមួយចំនួនដូចជាចំនូលដែលមានសម្រាប់ចំណាយទ្រព្យធនថ្លៃនៃទ្រព្យផ្សេងទៀត សេចក្តីសង្ឃឹមថាថ្លៃប្រែប្រួល ចំណង់ចំណូលចិត្តរបស់អ្នកទិញនិងចំនួនអ្នកទិញនៅលើទីផ្សារ។ បរិមាណផលិតផលដែលអ្នកទិញមានបំណង និងអាចទិញក្នុងកម្រិតថ្លៃណានោះ នឹងប្រែប្រួលប្រសិនបើឥទ្ធិពលមួយក្នុងចំណោមឥទ្ធិពលខាងលើនេះប្រែប្រួល។

ការប្រែប្រួលតម្រូវការគឺជាការប្រែប្រួលទំនាក់ទំនងរវាងថ្លៃនៃផលិតផលមួយនិ ងបរិមាណតម្រូវការដែលបណ្តាលមកពីការប្រែប្រួលអ្វីៗផ្សេងទៀតក្រៅពីថ្លៃនៃខ្សែកោងតម្រូវការទាំងស្រុង។ តារាងតម្រូវការថ្មីត្រូវតែបង្កើតឡើងព្រោះបរិមាណដែលត្រូវការដោយ អ្នកប្រើប្រាស់នៅកម្រិតថ្លៃនីមួយៗនឹងប្រែប្រួល។ សូមប្រយ័ត្នកុំច្រឡំរវាងការប្រែប្រលតម្រូវការនិងការប្រែប្រួលបរិមាណតម្រូវការ។ ការប្រែប្រួលតម្រូវការគឺឆ្លើយតបទៅនឹងការប្រែប្រួលនៃឥទ្ធិពលមួយក្រៅពីថ្លៃនៃផលិតផលនោះ ចំណែកឯការប្រែប្រួលបរិមាណតម្រូវការគឺឆ្លើយតបទៅនឹងការប្រែប្រួលថ្លៃផ្ទាល់របស់ផលិតផលនោះ។

| Price per Bushel | Quantity Demanded: Joe | | Quantity Demanded: Jen | | Quantity Demanded: Jay | | Total Quantity Demanded per Week |
|---|---|---|---|---|---|---|---|
| $5 | 10 | + | 12 | + | 8 | = | 30 |
| 4 | 20 | + | 23 | + | 17 | = | 60 |
| 3 | 35 | + | 39 | + | 26 | = | 100 |
| 2 | 55 | + | 60 | + | 39 | = | 154 |
| 1 | 80 | + | 87 | + | 54 | = | 221 |




ការកើនឡើងនៃតំរូវការចំពោះទំនិញមួយអាចបណ្តាលមកពីការកើនឡើងនៃចំណូល ឬទ្រព្យសម្បត្តិប្រសិនបើទំនិញនោះជាទំនិញធម្មតា( Normal goods) ប្រសិនបើជាទំនិញ( Inferior goods)ការកើនឡើងនៃចំណូលនឹងធ្វើឱ្យតម្រូវការធ្លាក់ចុះ។

- ការកើនឡើងថ្លៃនៃទំនិញជំនួស (Substitute)
- ការធ្លាក់ចុះថ្ងៃនៃទំនិញបំពេញ (Complement):
- សេចក្តីសង្ឃឹមថាថ្ងៃកើនឡើងក្នុងពេលខាងមុខ
- ការផ្លាស់ប្តូរចំណូលចិត្ត ឬម៉ូតដែលធ្វើអោយទំនិញគឿនកាន់តែមានប្រជាប្រិយភាព
- ការកើនឡើងនៃចំនួនអ្នកទិញ

| Determinant | Examples |
|---|---|
| Change in buyer tastes | Physical fitness rises in popularity, increasing the demand for jogging shoes and bicycles; patriotism rises, increasing the demand for flags. |
| Change in number of buyers | A decline in the birthrate reduces the demand for children's toys. |
| Change in income | A rise in incomes increases the demand for normal goods such as restaurant meals, sports tickets, and necklaces while reducing the demand for inferior goods such as cabbage, turnips, and inexpensive wine. |
| Change in the prices of related goods | A reduction in airfares reduces the demand for bus transportation (substitute goods); a decline in the price of DVD players increases the demand for DVD movies (complementary goods). |
| Change in consumer expectations | Inclement weather in South America creates an expectation of higher future prices of coffee beans, thereby increasing today's demand for coffee beans. |

ដ្យាក្រាម៖ Determinants of Demand: Factors Shift in Demand Curve

ម្យ៉ាងទៀត យើងនឹងបង្ហាញពីការធ្លាក់ចុះនៃតម្រូវការដែលធ្វើអោយខ្សែរកោងតម្រូវការទាំងមូលផ្លាស់ទីមកខាងឆ្វេង។ នៅត្រង់ថ្លៃនីមួយៗបរិមាណទំនិញដែលត្រូវការដោយអ្នកប្រើប្រាស់មានការធ្លាក់ចុះ។

ការធ្លាក់ចុះនៃតម្រូវការរបស់អ្នកទិញមួយអាចបណ្តាលមកពីការធ្លាក់ចុះនៃចំណូល ឬក៏ទ្រព្យសម្បត្តិប្រសិនបើទ្រព្យនោះជាទ្រព្យធម្មតា(Normal goods) ប្រសិនបើទំនិញអន់វិញ ការធ្លាក់ចុះចំណូលនាំឱ្យកើនតម្រូវការ។

- ការធ្លាក់ចុះថ្លៃនៃទ្រព្យជំនួស
- ការកើនឡើងថ្លៃនៃទ្រព្យបំពេញ
- សេចក្តីសង្ឃឹមថាថ្លៃនិងធ្លាក់ចុះក្នុងពេលខាងមុខ
- ការប្រែប្រួលចំណូលចិត្តរឺម៉ូតដែលធ្វើអោយទ្រព្យនោះមិនសូវមានប្រជាប្រិយភាព
-ការធ្លាក់ចុះចំនួនអ្នកទិញនៅលើទីផ្សារ

- . **ចំណូល(Income)**

នៅពេលចំណូលអ្នកប្រើប្រាស់កើន ធ្វើឱ្យតម្រូវការកើន និង ខ្សែកោងតម្រូវការរដូរទីតាំងមកខាងស្តាំ ចំពោះទំនិញធម្មតា (Normal goods) និងផ្ទុយមកវិញក្នុងករណីចំណូលថយចុះ។ នៅពេលចំណូលអ្នកប្រើប្រាស់កើន បណ្តាលឱ្យតម្រូវការថយចុះ ហើយខ្សែកោងតម្រូវការដូរទីតាំងមកឆ្វេង ចំពោះទំនិញគុណភាពអន់ (Inferior goods) និងផ្ទុយមកវិញក្នុងករណីចំណូលថយចុះ។

ចំណូល ឬទ្រព្យធនគឺជាប្រាក់សន្សំដែលបូកបញ្ចូលគ្នានៅក្នុងប្រទេសមួយ។ ទ្រព្យធនរួមមានអចលនវត្ថុ អសង្ហារឹម សន្និធិនិងប័ណ្ណខ្ចីប្រាក់ លុយនៅក្នុងធនាគារ និងទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត។ ការធ្លាក់ចុះតម្លៃអចលនវត្ថុនិងតំលៃសន្និធិ(stocks)នៅឆ្នាំ១៩៩០បណ្តាលឱ្យមានការធ្លាក់ចុះនូវទ្រព្យធនដែល ធ្វើឱ្យប្រជាជនកាត់បន្ថយចំណាយរបស់គេនិងកាត់តម្រូវការទៅលើទ្រព្យដូចជាផ្ទះថ្មី គ្រឿងសង្ហារិម និងរថយន្តជាដើម។ ទំនិញខ្លះគឺវាគ្មានការប្រែប្រួលអ្វីទេ ជាមួយនឹងការប្រែប្រួលទ្រព្យធន។ ឧទាហរណ៍ ដូចជា តម្រូវការក្រដាស់អនាម័យក្នុងបន្ទប់ទឹកវាទំនងនឹងមិនត្រូវបានប៉ះពាល់ដោយការប្រែប្រួលទ្រព្យធនទេ។ តម្រូវការ ចំពោះទ្រព្យខ្លះអាចកើនឡើងនៅពេលដែលទ្រព្យធនមានការធ្លាក់ចុះ។ ឧទាហរណ៍ប្រជាជនដែលមានចំណូល ធ្លាក់ចុះនិងបង្កើនតម្រូវការរបស់គេដោយទិញឡានមានតម្លៃថោក ឬក៏ឡានជជុះពីព្រោះគេមិនអាចមានលទ្ធភាពទិញឡានទំនើបៗទៀតបានទេ។

Demand Schedules

| Price ($ per tonne) $p$ | Quantity Demanded (tonnes per year when average annual income is $50 000) $D_0$ | Quantity Demanded (tonnes per year when average annual income is $60 000) $D_1$ |
|---|---|---|
| 20 | 110 *U* | 140 *U′* |
| 40 | 85 *V* | 115 *V′* |
| 60 | 65 *W* | 95 *W′* |
| 80 | 50 *X* | 80 *X′* |
| 100 | 40 *Y* | 70 *Y′* |

Demand Curves




An increase in annual household income increases the quantity demanded at each price (for all normal goods). This is shown by the rightward shift in the demand curve, from $D_0$ to $D_1$. When average income rises from $50 000 to $60 000 per year, quantity demanded at a price of $60 per tonne rises from 65 tonnes per year to 95 tonnes per year. A similar rise occurs at every other price.

- **.ថ្លៃទំនិញផ្សេងទៀត**

ឆន្ទៈរបស់យើងក្នុងការទិញទំនិញដោយឡែកណាមួយក៏អាស្រ័យ ទៅលើថ្លៃនៃទ្រព្យទាក់ទិនដែរ។ ការជ្រើសរើសផ្លូវផ្សេងទៀត គឺទំនិញដែលបម្រើនូវគោលបំណងដូចគ្នាទៅនឹងទំនិញដែលគេកំណត់គឺជាទំនិញជំនួស។ ឧទាហរណ៍ បើសិនជាថ្លៃស្រាបៀរកើនឡើងនោះបរិមាណស្រាដែលផលិតក្នុងស្រុងទំនងនឹងកើនឡើងពីព្រោះគេ អាចជំនួសស្រាបៀរដោយស្រាផលិតក្នុងស្រុកបាន។

**ចំពោះទំនិញជំនួស** (Substitute Goods)នៅពេលថ្លៃទំនិញទី ១ កើនធ្វើឱ្យតម្រូវការទំនិញទី២ កើនហើយខ្សែកោងផ្លាស់ទីតាំងទៅស្តាំ។ ឧទាហរណ៍នៅពេលថ្លៃទូរស័ព្ទឆ្លងប្រទេសកើនធ្វើឱ្យតម្រូវការផ្ញើលិខិតកើនឡើង។

ផ្ទុយទៅបើសិនថ្លៃស្រាបៀរធ្លាក់ចុះនោះបរិមាណតម្រូវការស្រា ក្នុងស្រុកនឹងធ្លាក់ចុះដែរ។ ថ្លៃនៃទំនិញបំពេញរបស់ទំនិញមួយក៏មានឥទ្ធិពល ទៅលើ តម្រូវការរបស់ទំនិញនោះដែរ។

**ទំនិញបំពេញ**(Complentary Goods)គឺជាទំនិញដែលការប្រើប្រាស់រួមគ្នារបស់វាធ្វើឱ្យប្រសើរឡើងនៅសេចក្តីពេញចិត្តដែលអ្នកប្រើប្រាស់ទទួលបានពីទំនិញនីមួយៗនោះ។ ឧទាហរណ៍ប្រសិនបើថ្លៃថាសចំរៀង CD ធ្លាក់ចុះនោះ តម្រូវការថាសម៉ាស៊ីនCD នឹងកើនឡើងដោយសារតែទំនិញទាំងពីរនេះបំពេញគ្នា។ ដូចគ្នាដែរប្រសិនបើថ្លៃប្រេងសាំងគឺជាទំនិញបំពេញគ្នា។

ចំពោះទំនិញបំពេញឱ្យគ្នានៅពេលថ្លៃទំនិញទី១ កើនធ្វើឱ្យទំនិញទី២ មានតម្រូវការថយចុះហើយខ្សែកោងតម្រូវការវាដូរទីតាំងទៅខាងឆ្វេង។

ឧទាហរណ៍ក្នុងល្បែង Tennis គឺជងវាយសី និងសីជាទំនិញបំពេញគ្នា។ នៅពេលថ្លៃជងវាយសីកើនធ្វើឱ្យតម្រូវការថយ ហើយខ្សែកោងតម្រូវការដូរទីតាំងមកខាងឆ្វេង។

ចំពោះទំនិញជំនួស (Complement Goods)នៅពេលថ្លៃទំនិញទី ១ កើនធ្វើឱ្យតម្រូវការទំនិញទី២ កើនហើយខ្សែកោងផ្លាស់ទីតាំងទៅស្តាំ។



- **រសជាតិ និង ការនិយមចូលចិត្ត**(Taste and Preferences)

ការចង់បានទំនិញមួយរបស់អ្នកទិញអាចប្រែប្រួលយូរៗម្តង។ ប្រសិនបើ ចំណូលចិត្តរបស់អ្នកប្រែប្រួលនោះតម្រូវការទិញក៏ធ្លាក់ចុះដែរ ព្រោះអ្នកគ្មានបំណងទិញ វាក្នុងកម្រិតថ្លៃណាមួយនោះទេ។

ឧទាហរណ៍តម្រូវការថាសចំរៀងធំៗពណ៌ខ្មៅធ្លាក់ចុះយ៉ាងខ្លាំងនៅប៉ុន្មានឆ្នាំនេះ នៅពេលដែលអ្នកនឹងអ្នកទិញដទៃទៀតត្រូវបានទាក់ទាញដោយ CD មានគុណភាពដ៏ល្អ។ អ្នកក៏ដឹងដែរពីឥទ្ធិពលនៃម៉ូតសំលៀកបំពាក់ទៅលើតម្រូវការរបស់វា។ នៅពេលដែលគេប្តូរម៉ូតសំលៀកបំពាក់នោះ អ្នកកាន់តែស្ទាក់ស្ទើរក្នុងការទិញសំលៀកបំពាក់ហួសសម័យទៅក្នុងថ្លៃទាបយ៉ាងណាក៏ដោយ។

ការចង់បានទំនិញមួយរបស់អ្នកទិញអាចប្រែប្រួលយូរៗម្តង។ ប្រសិនបើចំណូលចិត្តរបស់អ្នកប្រែប្រួលនោះតម្រូវការទិញក៏ធ្លាក់ចុះដែរ ព្រោះអ្នកគ្មានបំណងទិញ វាក្នុងកម្រិតថ្លៃណាមួយនោះទេ។ ឧទាហរណ៍តម្រូវការថាសចំរៀងធំៗពណ៌ខ្មៅធ្លាក់ចុះយ៉ាងខ្លាំងនៅប៉ុន្មានឆ្នាំនេះនៅពេលដែលអ្នកនិងអ្នកទិញដទៃទៀតត្រូវបានទាក់ទាញដោយ CD មានគុណភាពដ៏ល្អ។ អ្នកក៏ដឹងដែរពីឥទ្ធិពលនៃម៉ូតសំលៀកបំពាក់ទៅលើតម្រូវការរបស់វា។ នៅពេលដែលគេប្តូរម៉ូតសំលៀកបំពាក់នោះ អ្នកកាន់តែស្ទាក់ស្ទើរក្នុងការទិញសំលៀកបំពាក់ហួសសម័យ ទៅក្នុងថ្លៃទាបយ៉ាងណាក៏ដោយ។

រសជាតិនិងការនិយមចូលចិត្តវាមានឥទ្ធិពលទៅលើចំណង់មនុស្ស ហើយវាក៏ប្រែប្រួលទៅតាមពេលវេលា។ នៅក្នុងរូបខាងក្រោមយើងថា ក្រោយពេលទស្សនាភាពយន្តដែលសំដែងដោយតួឯកឪស្កូ ធ្វើឱ្យតម្រូវការសំលៀកបំពាក់ឪស្កូកើនឡើង ហើយខ្សែរកោងតម្រូវការវាងដូរទីតាំងពី D ទៅ D′។

តែក្រោយពេលទស្សនាភាពយន្តដែលសំដែងដោយតួឯកខូវប៊យ ធ្វើឱ្យគេនិយមសំលៀកបំពាក់ឪស្កូក៏ថយចុះ នាំឱ្យខ្សែរកោងតម្រូវការសំលៀកបំពាក់ឪស្កូដូរទីតាំងមក D″ វិញ។




- **ការសង្ឃឹម** (Expectation)

តម្រូវការនៃទ្រព្យមួយក៏ពឹងផ្អែកទៅលើការសង្ឃឹមដែលអ្នកទិញដឹងថា នៅពេលអនាគតថ្លៃនិងប្រែប្រួល។ ជាពិសេស ប្រសិនបើអ្នកពអ្នកទិញហើយសង្ឃឹមថាថ្លៃនៃទំនិញមួយនឹងធ្លាក់ ចុះនៅសប្តាហ៍ក្រោយនោះអ្នកប្រាកដជាទិញតិចនៅសប្តាហ៍នេះ។

ផ្ទុយទៅវិញ ប្រសិនបើអ្នកសង្ឃឹមថាថ្លៃនៃទំនិញមួយនិងកើនឡើងនៅសប្តាហ៍ក្រោយនោះអ្នកនឹងបន្ថែមការទិញរបស់អ្នកយ៉ាងច្រើននៅសប្តាហ៍នេះ។

ប្រសិនបើទំនិញអាចស្តុកបានដូចជាសាប៊ូនោះ អ្នកនិងបង្កើនតម្រូវការនឹងស្តុករបស់អ្នក។ ការសង្ឃឹមថាថ្លៃកើនឡើងនៅពេលអនាគតនឹងនាំឱ្យខ្សែរកោងតម្រូវការផ្លាស់ទីទៅខាងស្តាំ។

ផ្ទុយមកវិញបើការសង្ឃឹមថា ថ្លៃនិងធ្លាក់ចុះនៅ ពេលអនាគតនោះនាំឱ្យខ្សែរកោងតម្រូវការផ្លាស់ទីមកខាងឆ្វេង។

ការប្រែប្រួលតម្រូវការអាចកើតឡើងនៅពេលដែលអ្នកប្រើប្រាស់ទាំងឡាយសង្ឃឹមអំពីអ្វីដែលនឹងកើតឡើងនៅពេលអនាគត។ ជាឧទាហរណ៍ឧបមាថាអ្នកមានផែនការថានឹងទិញឡានមួយនៅក្នុងខែក្រោយ តែបន្ទាប់មកក៏មានដំណឹងមិនល្អអំពីខឿនសេដ្ឋកិច្ចដែលនឹងអាចធ្វើឱ្យអ្នកអាចបាត់បង់ការងារធ្វើ។ ពេលនោះអ្នកក៏ផ្អាកការទិញនោះសិន។

ហើយប្រសិនបើអ្នកដ៏ទៃទៀតធ្វើការប្លឹងថ្លែងដូចអ្នកដែរនោះ នឹងធ្វើឱ្យថយចុះតម្រូវការឡានក្នុងពេលបច្ចុប្បន្ន។ ហើយខ្សែរកោងតម្រូវការដូរទីតាំងមកខាងឆ្វេង។

**Shifts in the Demand Curve**

In part (a), the demand curve shifts rightward from $D_A$ to $D_B$. This shift represents an increase in demand. At each price, the quantity demanded is greater than it was before. For example, the quantity demanded at $20 increases from 500 units to 600 units. In part (b), the demand curve shifts leftward from $D_A$ to $D_C$. This shift represents a decrease in demand. At each price, the quantity demand is less. For example, the quantity demand at $20 decreases from 500 units to 400 units.




- **ចំនួនអ្នកទិញ** (Number of buyers)

បើចំនួនអ្នកទិញកើនឡើងគឺខ្សែរកោងដូរទីតាំងមកខាងស្តាំ និងផ្ទុយមកវិញ។

ឧទាហរណ៍ នៅខែបវេសនកាលធ្វើអោយចំនួនអ្នកទិញសៀវភៅសរសេរកើនឡើង។ ហើយខ្សែរកោងតម្រូវការសៀវភៅដូរទីតាំងទៅខាងស្តាំ។

បរិមាណតម្រូវការសរុបនៃទំនិញនៅកម្រិតថ្លៃណាមួយនោះ ក៏អាស្រ័យទៅលើចំនួនអ្នកទិញដែលមានបំណងទៅទំនិញនោះនៅក្នុងកម្រិតតថ្លៃនោះដែរ។

ចំនួនអ្នកទិញកាន់តែច្រើន និងនាំឱ្យតម្រូវការនៃទំនិញនោះក៏កាន់តែកើនឡើងដែរ។




ក្រៅពីដេទែមីណង់ខាងលើក៏អាចមានកត្តាដទៃទៀតដែលជះឥទ្ធិពលធ្វើឱ្យប្រែប្រួលតម្រូវការ ដូចជាលក្ខខ័ណ្ឌឥណទាន(Credit Terms) និងការផ្សាយពាណិជ្ជកម្ម (Advertising)។




រូបភាព៖ ការផ្សព្វផ្សាយពាណិជ្ជកម្ម( Advertising )

**ឆ.ការផ្គត់ផ្គង់កសិផល** ( Supply for Agricultural Products )

ការផ្គត់ផ្គង់ជាកំរិតបរិមាណផលិតផលដែលអ្នកលក់ចង់ ( willing ) និងមានលទ្ធភាព ( ability ) លក់ក្នុងថ្លៃផ្សេងៗគ្នាទៅក្នុងរយៈពេលមួយជាកំណត់( Supply is the range of quantities of a commodity that sellers are willing and able to sell at different prices in a given period of time. )។

បរិមាណទ្រព្យនិងសេវាដែលអ្នកលក់មានបំណងនៅលើទីផ្សារត្រូវប៉ះពាល់ដោយឥទ្ធិពលមួយចំនួន ឬដេទែរមីណង់មួយចំនួន៖

1- ថ្លៃរបស់វា
2- ថ្លៃនៃInputបច្ចុប្បន្នដែលត្រូវការដើម្បីផលិតនិងលក់ទ្រព្យមួយ
3- បច្ចេកវិទ្យាដែលមានសំរាប់ផលិតទ្រព្យ
4- ថ្លៃទ្រព្យផ្សេងទៀតដែលអាចត្រូវបានផលិតជាមួយInputsដែលប្រើដោយអ្នកលក់
5- សេចក្តីសង្ឃឹមពីថ្លៃនៅអនាគត
6- ចំនួនអ្នកលក់នៅលើទីផ្សារ

ក្នុងការវិភាគបរិមាណទ្រព្យសំរាប់លក់ក្នុងរយៈពេលមួយកំនត់យើងត្រូវតែញែកអោយដាច់រវាងផលនៃឥទ្ធិពលនីមួយៗ។ យើងនិងយកចិត្តទុកដាក់ជាពិសេសនៃឥទ្ធិពលថ្លៃទៅលើបរិមាណដែលអ្នកលក់មានបំណងលក់។ បរិមាណផ្គត់ផ្គង់គឺជាបរិមាណទ្រព្យដែលអ្នកលក់មានបំណងនិងអាចធ្វើអោយមាននៅលើទីផ្សារក្នុងរយៈពេលមួយ កំនត់នៅកំរិតនៃថ្លៃមួយ , អ្វីៗផ្សេងទៀតនៅថេរ។ ទស្សនៈផ្គត់ផ្គង់ដែលបានប្រើនៅក្នុងសេដ្ឋកិច្ចគឺជាទំនាក់ទំនង រវាងថ្លៃនៃទ្រព្យមួយនិងបរិមាណដែលត្រូវផ្គត់ផ្គង់។ ដូចជាតំរូវការ , ផ្គត់ផ្គង់មិនមែនជាបរិមាណថេរទេ។ ផ្ទុយទៅវិញវាបង្ហាញថាតើបរិមាណដែលអ្នក

លក់និងផ្គត់ផ្គង់ប្រែប្រួលជាមួយថ្លៃយ៉ាងដូចម្តេច។ បរិមាណដែលអ្នកលក់ នាំទៅទីផ្សារក្នុងរយៈពេលណាមួយនោះ អាស្រ័យទៅលើថ្លៃនៃផលិតផលនិងឥទ្ធិពលផ្សេងៗទៀត។ ខ្សែកោងផ្គត់ផ្គង់ទីផ្សារនិងច្បាប់ផ្គត់ផ្គង់ ថ្លៃគឺជាការបង់ប្រាក់ដែលអ្នកលក់ទទួលបានពីការលក់ផលិតផលក្នុងមួយឯកតា។ ព័ត៌មាននេះបង្ហាញនូវទំនាក់ទំនងរវាងថ្លៃ និងបរិមាណផ្គត់ផ្គង់ បើថ្លៃកាន់តែកើនឡើងនោះបរិមាណដែលដែលត្រូវផ្គត់ផ្គង់ក៏កាន់តែកើនឡើងដែរ។

តារាងខាងក្រោម ផ្តល់នូវព័ត៌មានជាសម្មតិកម្មស្តីអំពីថ្លៃ និងបរិមាណស៊ុត ដែលត្រូវផ្គត់ផ្គង់នៅលើទីផ្សារមួយក្នុងសប្តាហ៍(ឥទ្ធិពលដ៏ទៃទៀតសន្មតថាមិនប្រែប្រួលនៅពេលថ្ងៃប្រែប្រួល)។ ព័ត៌មាននោះរួមមានតារាងផ្គត់ផ្គង់ដែលបង្ហាញថាតើបរិមាណដែលត្រូវផ្គត់ផ្គង់ទាក់ទងទៅនឹងថ្លៃយ៉ាងដូចម្តេច?កូឡោនទី១នៃតារាងបង្ហាញពីថ្លៃស៊ុតក្នុងឡូ។ ព័ត៌មាននេះ បង្ហាញនូវទំនាក់ទំនងរវាងថ្លៃ និងបរិមាណផ្គត់ផ្គង់បើថ្លៃកាន់តែកើនឡើងនោះ បរិមាណដែលដែលត្រូវផ្គត់ផ្គង់ក៏កាន់តែកើនឡើងដែរ។

ឧទាហរណ៍៖ នៅពេលដែលថ្លៃស៊ុតកើនឡើងពី $1 ទៅ $1.25 ក្នុងឡូ បរិមាណដែលត្រូវផ្គត់ផ្គង់កើនឡើងពី 5000 ទៅ 6 000ឡូ។

| ថ្លៃស៊ុត($/ឡូ) | បរិមាណស៊ុត( ឡូ / សប្តាហ៍) |
|---|---|
| ២.០០ | ៩,០០០ |
| ១.៧៥ | ៨,០០០ |
| ១.៥០ | ៧,០០០ |
| ១.២០ | ៦,០០០ |
| ១.០០ | ៥,០០០ |
| ០.៧៥ | ៤,០០០ |
| ០.៥០ | ៣,០០០ |
| ០.២៥ | ២,០០០ |

រូបភាព៖ តារាងផ្គត់ផ្គង់ស៊ុត

តារាងផ្គត់ផ្គង់(Suppy Schedule)គឺជាការបង្ហាញនូវបញ្ជីនៃទំនាក់ទំនងរវាងថ្លៃ និងបរិមាណផ្គត់ផ្គង់នៃផលិតផលមួយ ដោយសន្មតិកត្តាដទៃទៀតនៅថេរ ក្នុងរយៈពេលមួយកំណត់។

តារាងផ្គត់ផ្គង់(Supply Curve)គឺជាការបង្ហាញដោយក្រាភិចនៃតារាងផ្គត់ផ្គង់នៃផលិតផលមួយ ដោយសន្មតិកត្តាដទៃទៀតនៅថេរ មួយក្នុងរយៈពេលមួយកំណត់។

ខ្សែកោងផ្គត់ផ្គង់មានស្លូបវិជ្ជមាន ដូច្នេះខ្សែកោងផ្គត់ផ្គង់ជាអនុគមន៍កើនជាមួយថ្លៃផ្គត់ផ្គង់។




**Supply Schedule for Cotton**

| Price of cotton (per pound) | Quantity of cotton supplied (billions of pounds) |
|---|---|
| $2.00 | 11.6 |
| 1.75 | 11.5 |
| 1.50 | 11.2 |
| 1.25 | 10.7 |
| 1.00 | 10.0 |
| 0.75 | 9.1 |
| 0.50 | 8.0 |

រូបភាព៖ តារាងផ្គត់ផ្គង់កប្បាស និងខ្សែកោងផ្គត់ផ្គង់កប្បាស

ផ្គត់ផ្គង់របស់បុគ្គលគឺជាការផ្គត់ផ្គង់នៃបុគ្គលម្នាក់ ឬក្រុមហ៊ុនមួយដែលបានផលិតនូវផលិតផលសម្រេចមួយជាមួយនឹងថ្លៃ និងបរិមាណផ្គត់ផ្គង់នៃផលិតផលនោះ ក្នុងរយៈពេលមួយជាក់លាក់ដែលបានកំណត់។




ផ្គត់ផ្គង់ទីផ្សារគឺជាផលបូកនៃផ្គត់ផ្គង់របស់បុគ្គលនីមួយៗនៃលិតផលមួយនៅក្នុងទីផ្សារនៃផលិតផលនោះ នៅក្នុងរយៈពេលមួយជាក់លាក់ដែលបានកំណត់។

**Deriving a Market Supply Schedule and a Market Supply Curve**

Part (a) shows four supply schedules combined into one table. The market supply schedule is derived by adding the quantities supplied at each price. In (b), the data points from the supply schedules are plotted to show how a market supply curve is derived. Only two points on the market supply curve are noted.

| | Quantity Supplied | | | | | | |
|---|---|---|---|---|---|---|---|
| Price | Brown | | Alberts | | Other Suppliers | | All Suppliers |
| $10 | 1 | | 2 | | 96 | | 99 |
| 11 | 2 | + | 3 | + | 98 | = | 103 |
| 12 | 3 | + | 4 | + | 102 | = | 109 |
| 13 | 4 | | 5 | | 106 | | 115 |
| 14 | 5 | | 6 | | 108 | | 119 |
| 15 | 6 | | 7 | | 110 | | 123 |

(a)




(b)

រូបភាព៖ ផ្គត់ផ្គង់ទីផ្សារនៃផលិតផលមួយ

## ជ.ច្បាប់នៃការផ្គត់ផ្គង់ (The law of supply)

ជាទូទៅនៅពេលដែលអ្វីៗទៀតថេ នោះ ច្បាប់ផ្គត់ផ្គង់ចែងថាថ្លៃនៃទំនិញមួយកើនឡើងនឹងនាំឲ្យបរិមាណនៃទំនិញនោះដែលមានអ្នកលក់មានបំណងនិង អ្នកបង្កើតឲ្យមានក្នុងរយៈពេលកំណត់ក៏កើនឡើងដែរ។

ខ្សែកោងផ្គត់ផ្គង់គឺជាក្រាហ្វដែលបង្ហាញពីរបៀបដែលបរិមាណផ្គត់ផ្គង់ប្រែប្រួលជាមួយនិងថ្លៃនៃទ្រព្យមួយ។

ច្បាប់នៃការផ្គត់ផ្គង់ គឺជាគោលការណ៍មួយដែលបញ្ជាក់ពីអត្ថិភាពទំនាក់ទំនងស្របគ្នារវាងថ្លៃផលិតផល និងបរិមាណផលិតផល ដែលអ្នកលក់ចង់ និងមានលទ្ធភាពផ្គត់ផ្គង់រយៈពេលមួយជាកំណត់ និងក្នុងលក្ខខ័ណ្ឌដែលកត្តាផ្សេងៗទៀតមិនប្រែប្រួល។

ច្បាប់ផ្គត់ផ្គង់កើតមានឡើងដោយសារមូលហេតុពីរ គឺ៖

- ទី១៖គឺបណ្តាលមកពីចំណាយផលិតកម្មនៅពេលផលិតករចង់ផលិតបន្ថែមផលិតផលទាប ទាមទារអោយគេត្រូវបន្ថែមកត្តាផលិតកម្មដទៃទៀត។ តែថ្លៃដើមមួយឯកត្តារបស់សំភារៈដែលបន្ថែមនោះវាអាចកើតឡើង។ ដូច្នេះធ្វើអោយគេត្រូវបង្កើនថ្លៃថែមទៀតក្នុងពេលដែលបរិមាណផ្គត់ផ្គង់ត្រូវកើនឡើង។

○ ទី២៖ នៅពេលថ្លៃទំនិញមួយកើនខ្ពស់ក៏តំរូវអោយផលិតករបង្កើនការផលិតទំនិញនោះ ព្រោះថាការឡើងថ្លៃទំនិញមួយធ្វើអោយអ្នកផលិតទំនិញនោះសង្ឃឹមថាគេនឹងបានចំណេញច្រើន តែក៏ទាមទារអោយគេត្រូវតែបង្វែរធនធានពីផលិតកម្មទំនិញដទៃទៀតដើម្បីយកមកផលិតទំនិញនោះ។ ហើយជាទូទៅវាតម្រូវការឱ្យបង្កើនថ្លៃទំនិញនោះ។

| Supply of Corn | |
|---|---|
| Price per Bushel | Quantity Supplied per Week |
| $5 | 60 |
| 4 | 50 |
| 3 | 35 |
| 2 | 20 |
| 1 | 5 |







## ឈ. ការប្រែប្រួលបរិមាណផ្គត់ផ្គង់ (Change in the Quantities supplied for Agricultural Products)

ចំណោតកើនឡើងនៃខ្សែកោងផ្គត់ផ្គង់ឆ្លុះបញ្ចាំងពីច្បាប់ផ្គត់ផ្គង់។ នៅពេលថ្លៃកើនឡើងបរិមាណផ្គត់ផ្គង់ក៏កើនឡើងដែរ។ ការប្រែប្រួលបរិមាណផ្គត់ផ្គង់គឺជាការប្រែប្រួលបរិមាណដែលអ្នក

លក់មានបំណងលក់ក្នុងរយៈពេលមួយដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលថ្លៃនៃទ្រព្យនោះ។ ការប្រែប្រួលបរិមាណផ្គត់ផ្គង់តំណាង អោយខ្សែរកោងផ្គត់ផ្គង់ដើម្បីឆ្លើយតប ទៅនិងការប្រែប្រួលថ្លៃក្នុងខណៈដែលកត្តាដ៏ទៃទៀតមិនប្រែប្រួល។

ឧទាហរណ៍តាមតារាងស្តីពីការផ្គត់ផ្គង់ស៊ុតខាងលើ ប្រសិនបើថ្លៃស៊ុតធ្លាក់ចុះពី $2 មក $1.75 ក្នុងឡូនោះ នឹងនាំឱ្យមានការធ្លាក់ចុះបរិមាណដែលត្រូវផ្គត់ផ្គង់ ហើយបរិមាណដែលអ្នកលក់និងបង្កើតអោយមាននៅលើទីផ្សារនឹងធ្លាក់ចុះពី 9 000ឡូ មក 8 000ឡូ ក្នុងសប្តាហ៍។ ដូចគ្នាដែរបើសិនជាថ្លៃកើនឡើងពី 1 ទៅ $1.25ក្នុងឡូនោះនឹងនាំឱ្យមានការកើនឡើងបរិមាណដែលត្រូវផ្គត់ផ្គង់គឺកើន ពី 5 000ឡូ ទៅ 6 000ឡូ ក្នុងសប្តាហ៍។

ការប្រែប្រួលផ្គត់ផ្គង់គឺជាការប្រែប្រួលទំនាក់ទំនងរវាងថ្លៃនៃផលិតផលមួយនិងបរិមាណដែលត្រូវផ្គត់ផ្គង់ដើម្បីឆ្លើយតបទៅនឹងការប្រែប្រលនៃឥទ្ធិពលផ្សេងៗទៀតក្រៅពីថ្លៃនៃផលិតផលនោះ។ ការប្រែប្រផ្គត់ផ្គង់បង្ហាញដោយការផ្លាស់ទីតាំងនៃខ្សែរកោងផ្គត់ផ្គង់ទាំងមូល។

តារាងផ្គត់ផ្គង់ថ្មីត្រូវបានគេបង្កើតឡើងពីព្រោះបរិមាណដែលត្រូវផ្គត់ផ្គង់ដោយអ្នកលក់នៅគ្រង់ថ្លៃនីមួយៗនឹងប្រែប្រួល។

ការប្រែប្រួលថ្លៃនៃទំនិញមួយធ្វើឱ្យមានការប្រែប្រួលបរិមាណផ្គត់ផ្គង់។ ការប្រែប្រួលបរិមាណផ្គត់ផ្គង់ដែលបណ្តាលមកពីថ្លៃទំនិញប្រែប្រួល។



នៅក្នុងរូបយើងឃើញនៅលើខ្សែកោងផ្គត់ផ្គង់ S គឺមានចលនាពីចំណុច A ទៅចំណុច B។ នៅពេលដែលថ្លៃកើនពី ៣ ដុល្លា ទៅ ៤ ដុល្លា គឺបរិមាណផ្គត់ផ្គង់កើនឡើងពី ៥ ទៅ ១០។

- កត្តាកំណត់ទាំងឡាយនៃការផ្គត់ផ្គង់ Determinants of supply) វាក៏មានឥទ្ធិពលទៅលើការផ្គត់ផ្គង់។ ការប្រែប្រួលការកត្តាកំនត់ទាំងនោះវាបណ្តាលអោយមានការប្រែប្រួលការផ្គត់ផ្គង់។ ការប្រែប្រួលការផ្គត់ផ្គង់ ជាការផ្លាស់ប្តូរទីតាំងខ្សែកោងផ្គត់ផ្គង់ទាំងមូលដែលបណ្តាលមកពី Determinants of supply ប្រែប្រួល។ នៅក្នុងរូបខាងក្រោមឧទាហរណ៍នៃការប្រែប្រួលការផ្គត់ផ្គង់ នៅពេលដែលកត្តាកំណត់របស់ការផ្គត់ផ្គង់ប្រែប្រួល នាំឱ្យខ្សែកោងផ្គត់ផ្គង់ដូរទីតាំងពី $S_1$ ទៅ $S_2$ និងដូរទីតាំងពី $S_1$ ទៅ $S_3$។




រូបភាព៖ ការប្រែប្រួលផ្គត់ផ្គង់

**៣.ការប្រែប្រួលការផ្គត់ផ្គង់** (Change in supply for Agricultural Products)

ការធ្លាក់ចុះនៃការផ្គត់ផ្គង់ត្រូវបានបង្ហាញដោយការផ្លាស់ទីនៃខ្សែកោងផ្គត់ផ្គង់ទៅខាងឆ្វេង។ ចំណែករីឯ ការកើនឡើងនៃការផ្គត់ផ្គង់ត្រូវបានបង្ហាញដោយការផ្លាស់ទីនៃខ្សែកោងផ្គត់ផ្គង់ទៅខាងស្តាំ។

ការប្រែប្រួលផ្គត់ផ្គង់នៃផលិតផលមួយអាចបណ្តាលមកពី៖

- ការប្រែប្រួលថ្លៃនៃ Inputsដែលបានប្រើប្រាស់ដើម្បីផលិតទំនិញ៖ ការកើនឡើងថ្លៃ Inputs នៅផ្គត់ផ្គង់ធ្លាក់ចុះរីឯការធ្លាក់ថ្លៃ Inputs នាំឱ្យការផ្គត់ផ្គង់ទំនិញកើនឡើង។

- ការប្រែប្រួលបច្ចេកវិទ្យា៖ ការកែលម្អបច្ចេកវិទ្យានាំឱ្យផ្គត់ផ្គង់កើនឡើង រីឯការយ៉ាប់យ៉ឺននៃបច្ចេកវិទ្យាដែលបណ្តាលមកពីគ្រោះមហន្តរាយផ្សេងៗនាំឱ្យផ្គត់ផ្គង់ធ្លាក់ចុះ។

- ការប្រែប្រួលថ្លៃទំនិញផ្សេងទៀត៖ ការកើនឡើងថ្លៃនៃទំនិញផ្សេងដែលអាចត្រូវបានផលិតជាមួយនឹងធនធានដ៏ដែលធ្វើឱ្យការផ្គត់ផ្គង់ទំនិញទីធ្លាក់ចុះ ចំណែកឯការធ្លាក់ចុះថ្លៃនៃទំនិញផ្សេងធ្វើអោយការផ្គត់ផ្គង់ទំនិញទី១កើនឡើង។

- ការប្រែប្រួលចំនួនអ្នកលក់នៅលើទីផ្សារ៖ ការធ្លាក់ចុះចំនួនអ្នកលក់នាំឱ្យការផ្គត់ផ្គង់ធ្លាក់ចុះ ចំណែករីឯ ការកើនចំនួនអ្នកលក់នឹងនាំអោយការផ្គត់ផ្គង់កើនឡើង។




រូបភាព៖ ការប្រែប្រួលផ្គត់ផ្គង់

| Determinant | Examples |
|---|---|
| Change in resource prices | A decrease in the price of microchips increases the supply of computers; an increase in the price of crude oil reduces the supply of gasoline. |
| Change in technology | The development of more effective wireless technology increases the supply of cell phones. |
| Changes in taxes and subsidies | An increase in the excise tax on cigarettes reduces the supply of cigarettes; a decline in subsidies to state universities reduces the supply of higher education. |
| Change in prices of other goods | An increase in the price of cucumbers decreases the supply of watermelons. |
| Change in producer expectations | An expectation of a substantial rise in future log prices decreases the supply of logs today. |
| Change in number of suppliers | An increase in the number of tatoo parlors increases the supply of tatoos; the formation of women's professional basketball leagues increases the supply of women's professional basketball games. |

ដ្យាក្រាម៖ Determinants of Supply: Factors Shift in Supply Curve

- . កត្តាថ្លៃ( Factor of price)

វាជាថ្លៃនៃធនធានដែលគេត្រូវទិញដើម្បីផលិត ឬដើម្បីបែងចែកផលិតផល។ ថ្លៃរបស់ផលិតករម្នាក់ៗដែលចង់ និងមានលទ្ធភាពលក់ផលិតផលរបស់ខ្លួន គឺត្រូវផ្អែកលើចំណាយផលិតកម្មរបស់ខ្លួន ដូចជាប្រាក់ឈ្នួលកម្មករ សំភារៈវត្ថុធាតុដើម...។ ល។

ប្រសិនបើកត្តាថ្លៃនោះកើនឡើងគឺបន្ទាប់មកថ្លៃដើមផលិតចំពោះបរិមាណទំនិញនោះក៏កើនដែរ។ ដូច្នេះផលិតករត្រូវចំណាយក្នុងថ្លៃមួយខ្ពស់ជាងដើម្បីផលិតបរិមាណទំនិញដដែលនោះ។ ជាឧទាហរណ៍ឈើជាកត្តាសំខាន់មួយក្នុងសំណង់ផ្ទះ។ ប្រសិនបើថ្លៃឈើកើន អ្នកសង់ផ្ទះនឹងគ្មានចំនង់រក្សាទុកថ្លៃឈើកើន អ្នកសង់ផ្ទះនឹងគ្មានចំនង់រក្សាទុកថ្លៃងដែលចំពោះបរិមាណផ្ទះដដែលនោះទេ។ នៅក្នុងក្រាហ្វិកយើងឃើញថានៅពេលថ្លៃឈើកើន ធ្វើអោយខ្សែរកោងផ្គត់ផ្គង់ផ្ទះថយចុះដោយដូរទីតាំងមកខាងឆ្វេង។




Supply Schedules for Cotton

| Price of cotton (per pound) | Quantity of cotton supplied (billions of pounds) | |
|---|---|---|
| | Before new technology | After new technology |
| $2.00 | 11.6 | 13.9 |
| 1.75 | 11.5 | 13.8 |
| 1.50 | 11.2 | 13.4 |
| 1.25 | 10.7 | 12.8 |
| 1.00 | 10.0 | 12.0 |
| 0.75 | 9.1 | 10.9 |
| 0.50 | 8.0 | 9.6 |

- **បច្ចេកវិទ្យា** (Technology)

ការប្រើប្រាស់បច្ចេកវិទ្យាខ្ពស់នៅក្នុងផលិតកម្មធ្វើអោយទិន្នផលពលកម្មកើន ពោលគឺគេអាចផលិតផលិតផលកើនជាងមុនដោយប្រើកត្តាផលិតកម្មដដែលឬក្នុងបរិមាណផលិតផលដដែលគេផលិតគឺប្រើប្រាស់រាល់កត្តាផលិតកម្មតិចជាងពីមុន។ នៅពេលបច្ចេកវិទ្យាកើន គឺខ្សែកោងផ្គត់ផ្គង់ដូរទីតាំងទៅខាងស្តាំ។

- **.ថ្លៃទំនិញដទៃទៀត** (Price of other goods)

- ប្រសិនបើនៅក្នុងការផលិតទំនិញពីរ ប្រើនូវធនធានប្រភេទតែមួយដូចគ្នានៅក្នុងផលិតកម្ម គឺថាបើថ្លៃនៃទំនិញណាមួយប្រែប្រួល វាធ្វើអោយខ្សែកោងផ្គត់ផ្គង់ទំនិញផ្សេងទៀតប្រែប្រួល។ ឧទាហរណ៍៖ ផលិតផលពោត និងផលិតផលកប្បាស។ បើពោតឡើងថ្លៃ ធ្វើអោយផលិតករបង្កើនការដាំពោត ហើយគេក៏ពង្រីកផ្ទៃដីដាំពោត ធ្វើអោយថ្លៃដីដាំកប្បាសថយចុះ ហើយទីបំផុតខ្សែកោងផ្គត់ផ្គង់កប្បាសក៏ដូរទីតាំងមកខាងឆ្វេង។

- ទំនិញក៏អាចជាការបំពេញអោយគ្នានៅក្នុងផលិតកម្មដែរ។ ឧទាហរណ៍នៅពេលថ្លៃសាច់គោកើនឡើង នាំអោយគោដែលគេកាប់យកសាច់កើនឡើង ធ្វើអោយបរិមាណស្បែកគោក៏កើនឡើងដែរ ហើយទីបំផុតខ្សែកោងផ្គត់ផ្គង់ស្បែកគោក៏ដូរទីតាំងទៅខាងស្តាំ។




- Expectations: ការសង្ឃឹម

ជាទូទៅប្រសិនបើផលិតករសង្ឃឹមថា ទំនិញដែលគេផលិតនឹងកើនថ្លៃនៅពេលអនាគត ធ្វើអោយគេផ្តល់ទំនិញតិចចំពោះថ្លៃបច្ចុប្បន្ន។ តែបើគេសង្ឃឹមថាថ្លៃនឹងធ្លាក់ចុះនាពេលអនាគត ធ្វើអោយបន្ថែមការផ្តល់ទំនិញសំរាប់លក់ក្នុងពេលបច្ចុប្បន្ន។ ក្នុងករណីទាំងពីរគឺគេព្យាយាមផ្គត់ផ្គង់ទំនិញបន្ថែមនៅពេលថ្លៃខ្ពស់។




- ចំនួនអ្នកលក់ ( Number of Sellers )

បើចំនួនអ្នកលក់កើននៅក្នុងទីផ្សារ គឺខ្សែកោងផ្គត់ផ្គង់ជួរទៅខាងស្តាំ។




**ដ.ពន្ធ និងគោលនយោបាយឧបត្ថមរបស់រដ្ឋាភិបាល** (Government tax and subsidy politics)

ការបង្កើនពន្ធរបស់ផលិតផលមួយ នឹងធ្វើអោយខ្សែកោងផ្គត់ផ្គង់ប្តូរទីតាំងទៅខាងឆ្វេង (shift to left)។ ហើយការផ្តល់ជំនួយរបស់រដ្ឋាភិបាលក្នុងការផលិតទំនិញណាមួយនោះធ្វើអោយខ្សែកោងផ្គត់ផ្គង់ទំនិញនោះជួរទីតាំងទៅខាងស្តាំ។




- **ពន្ធនៅលើទីផ្សារ** (A tax on the market): មានប្រភេទពន្ធពីរ :

+ ពន្ធតាមឯកតា (Per Unit Tax) : គឺជាបរិមាណថេរនៃការហូតពន្ធនៅលើឯកតាលក់នីមួយៗ។

+ ពន្ធតាមភាគរយ (Ad Valorem Tax): ជាការហូតពន្ធតាមភាគរយថ្លៃ។

- **ការរំលែកពន្ធ** (Tax Incidence)

ការរំលែកពន្ធគឺជាការបែងចែកពន្ធរវាងអ្នកទិញ និងអ្នកលក់។




រូបភាព៖ ពេលរដ្ឋាភិបាលដាក់ពន្ធ(Incedent of a Tax)

ក្នុងការគណនាជាលំហាត់គេអាចសរសេរជារូបបមន្តទូទៅបាន ពេលរដ្ឋាភិបាលផ្តល់ជំនួយគឺ ៖

## Figure. A Tax on Buyers ពន្ធលើអ្នកទិញ




## Figure. A Tax on Sellers ពន្ធលើអ្នកលក់




$$Q^D = f(P_b)$$

$$Q^S = f(P_s)$$
$$Q^D = Q^S$$
$$P_b - P_s = Tax$$

ក្នុងរូបនេះតំណាងអោយទីផ្សារជាមួយនឹងពន្ធឯកតា។ បើគ្មានពន្ធ គឺទីផ្សារស្ថិតនៅត្រង់សមតាដែលជាអន្តរអំពើនៃខ្សែរកោងផ្គត់ផ្គង់និងតំរូវការគឺ

ចំណុច E ជាចំណុចសមតាមុនបង់ពន្ធដែលមានកូរអរដោនេ $E(140,3)$ ប៉ុន្តែនៅពេលដែលរដ្ឋាភិបាលដាក់ពន្ធ ១ ដុល្លាក្នុងមួយឯកតានោះ អ្នកទិញនឹងទិញទំនិញក្នុងតម្លៃ ៣.៤៥ ដុល្លា (មានន័យថាអ្នកទិញចូលរួមបង់ពន្ធលើថ្លៃទំនិញនោះឱ្យរដ្ឋាភិបាលចំនួន០.៤៥ដុល្លាបន្ថែម) រីឯអ្នកលក់(អ្នកផ្គត់ផ្គង់)ទទួលបានទឹកប្រាក់ក្នុងមួយឯកតាតែ ២.៤៥ ដុល្លាប៉ុណ្ណោះតិចជាងមុនពេលរដ្ឋាភិបាលដាក់ពន្ធលើទំនិញក្នុងទីផ្សារ (មានន័យថាអ្នកលក់ចូលរួមបង់ពន្ធរដ្ឋាភិបាលចំនួន ០.៥៥ ដុល្លាកនុងមយយឯកតា)។




រូបភាព៖ ពេលរដ្ឋាភិបាលដាក់ពន្ធ ១ ដុល្លា លើទីផ្សារផលិតផល

នៅពេលនោះយើងអាចសង់ខ្សែរកោងផ្គត់ផ្គង់ S។ តែនៅពេលថ្លៃដល់ ២០ ឯកតាទំនិញនោះទេ ពោលគឺអ្នកទិញនឹងកាត់បន្ថយតំរូវការនៅថ្លៃ ៦ ដុល្លា។ ដូច្នេះវាក៏បង្កើតអោយមានស្ថានភាពលើស (Surplus) ហើយបង្កើតជាសំពាធរុញថ្លៃទំលាក់ចុះមក ៥,៧៥ ដុល្លា ហើយក៏បង្កើតអោយមានសមតាទីផ្សារ E′ មួយទៀត។ នៅពេលថ្លៃកើនពី ៥ ទៅ ៥,៧៥ ដុល្លានេះ មានន័យថាអ្នកទិញចំណាយ ៥,៧៥ ដុល្លា សំរាប់១ឯកតាទំនិញ នៅក្រោយពេលបង់ពន្ធ។ ដូច្នេះអ្នកទិញបានចំណាយបន្ថែម ០,៧៥ ដុល្លា។ ក៏ប៉ុន្តែអ្នកផ្គត់ផ្គង់មិនបានទទួលយក ០,៧៥ ដុល្លានោះទេ ព្រោះគេត្រូវបង់ពន្ធអោយរដ្ឋដល់ ១ដុល្លា ដែលគេត្រូវបន្ថែម ០,២៥ ដុល្លា ថែមពីលើអ្នកទិញបន្ថែមដើម្បីបង់អោយរដ្ឋ។ ដូច្នេះក្នុង ១៥ ឯកតាដែលលក់ គឺអ្នកផ្គត់ផ្គង់ទទួលបានត្រឹមតែ ៤,៧៥ ដុល្លា ក្នុង១ឯកតាទំនិញប៉ុណ្ណោះ។




**ឋ.ជំនួយរបស់រដ្ឋាភិបាល (Subsidy)**

ជំនួយរបស់រដ្ឋាភិបាលគឺស្រដៀងគ្នានឹងការដាក់ពន្ធដែរ។ តាមពិតគេអាចគិតថាជំនួយគឺអវិជ្ជមាននៃពន្ធ។ ពេលរដ្ឋាភិបាលផ្តលជាជំនួយថ្លៃរបស់អ្នកលក់នៅពីលើថ្លៃរបស់អ្នកទិញ។ មានន័យថាជំនួយគឺជាផលសងរវាងថ្លៃអ្នកលក់ និងថ្លៃអ្នកទិញ។

ក្នុងការគណនាជាលំហាត់គេអាចសរសេរជារូបបមន្តទូទៅបាន ពេលរដ្ឋាភិបាលផ្តលជំនួយគឺ៖

$$Q^D = f(P_b)$$

$$Q^S = f(P_s)$$
$$Q^D = Q^S$$
$$P_s - P_b = Subsidy$$




រូបភាព៖ ពេលរដ្ឋាភិបាលផ្ដល់ជំនួយ(Subsidy)

- **ពន្ធលើប្រាក់បៀវត្សរ៍**

ពន្ធលើប្រាក់បៀវត្សរ៍គឺជាពន្ធផ្ទាល់ដែលត្រូវយក ឬត្រូវបង់ជាប្រចាំខែ ដោយកំណត់លើប្រាក់ចំណូលសរុបរបស់បុគ្គលម្នាក់ៗ ឬសំដៅដល់លាភការ (Remuneration)ប្រាក់បំណាច់, បុព្វលាភ (Bonus), ប្រាក់ម៉ោងបន្ថែម, ប្រាក់ថែមម៉ោង, ប្រាក់ប៉ះប៉ូវនានា និងលើអត្ថប្រយោជន៍បន្ថែមជាច្រើនទៀត ដែលបានទូទាត់ឱ្យដល់និយោជិក ឬបានទូទាត់ដើម្បីជាប្រយោជន៍ផ្ទាល់ ឬប្រយោជន៍ដល់និយោជិកចំពោះការបំពេញសកម្មភាពបម្រើការងារនៅតាមសហគ្រាសសាធារណៈ សហគ្រាសឯកជន អង្គការក្រៅរដ្ឋាភិបាល ស្ថាប័នស្វ័យត និងសាលារដ្ឋ-ឯកជន។

ប្រភេទពន្ធលើប្រាក់ចំណូល(Type of Income Tax)

**❶ចំណូលជាអចិន្ត្រៃយ** (Permanent Income):

ជាចំណូលដែលកើតឡើងជាប្រចាំថ្ងៃស្មើៗគ្នា និងមានស្ថេរភាព (ប្រាក់បៀវត្សរ៍ ថ្លៃឈ្នួលពលកម្ម ខ្ទង់ឧបត្ថម្ភផ្សេងៗ)។

**❷ចំណូលជាបណ្ដោះអាសន្ន** (Temporary Income):

ជាចំណូលគ្មានស្ថេរភាពជួនកាលមាន ជួនកាលគ្មាន កើតមិនទៀងទាត់ (ប្រាក់ម៉ោង បន្ថែម បុព្វលាភ បៀវត្សប្រភពបរទេស ប្រាក់ឱ្យខ្ចី....)។

**១ចំណូលផ្សេងៗ** (Other Income):

ជាចំណូលដែលបានពីការងារបំពេញបេសកកម្ម ឬប្រាក់ឧបត្ថម្ភនៅពេលមានគ្រោះថ្នាក់ ឬប៉ះពាល់ដល់សុខភាព និងប្រាក់រង្វាន់អំពីការកែច្នៃបច្ចេកទេសរកឃើញទាំងឡាយ។

Figure. A Payroll Tax ពន្ធលើប្រាក់បៀវត្សរ៍




**២ និយមន័យនៃភាពយឺត** (Elasticity Definition)

នៅក្នុងមេរៀននេះ យើងនឹងធ្វើការពិនិត្យដោយយកចិត្តទុកដាក់លើការងាររកវិធីសាស្ត្រដើម្បីធ្វើជារង្វាស់សម្រាប់ប៉ាន់មើលពីការប្រែប្រួលរបស់ថ្លៃ ដែលមានឥទ្ធិពលទៅលើបរិមាណតម្រូវការនិងការផ្គត់ផ្គង់ដែលត្រូវបានគេសម្គាល់ថាជាភាពយឺត(Elasticity)។ តាមពិតយើងនឹងសិក្សាពីទស្សនានៃតម្រូវការ និងផ្គត់ផ្គង់ និងការពិភាក្សាពីការប្រែប្រួលបរិមាណនៃតម្រូវការ(Change in quantity demanded) និងការប្រែប្រួលបរិមាណនៃផ្គត់ផ្គត់ផ្គង់(Change in quantity supply)។ ខ្សែកោងតម្រូវការ(Demand Curve)មានស្លូប(មេគុណប្រាប់ទិស)ជាចំនួនអវិជ្ជមាន និងអនុគមន៍ចុះ មានន័យថា បើថ្លៃចុះនោះ បរិមាណតម្រូវការនៃការប្រើប្រាស់ទំនិញនោះនឹងកើនឡើង និងបើថ្លៃកើនឡើងនោះ បរិមាណតម្រូវការនៃការប្រើប្រាស់ទំនិញនោះនឹងកើនថយចុះ។ ចំណែករីឯ ខ្សែកោងផ្គត់ផ្គង់(Supply Curve)វិញមានស្លូប(មេគុណប្រាប់ទិស)ជាចំនួនវិជ្ជមាន បើថ្លៃកើនឡើងនោះ បរិមាណផ្គត់ផ្គង់នឹងកើនឡើងដែរ និងបើថ្លៃរបស់វាថយចុះនោះ បរិមាណផ្គត់ផ្គង់វានឹងថយចុះដែរ។ ដូច្នេះយើងនឹងសិក្សាលម្អិតពីការប្រែប្រួលនៃថ្លៃដែលបណ្តាលឱ្យមានការប្រែប្រួលនៃបរិមាណតម្រូវការ និងការប្រែប្រួលបរិមាណផ្គត់ផ្គង់។ តាមធម្មតារង្វាស់នេះគឺគេគិតជាភាគរយដែលគេហៅថាភាពយឺតនៃថ្លៃរបស់តម្រូវការ(Price elasticity of demand) និងភាពយឺតនៃថ្លៃរបស់ផ្គត់ផ្គង់(Price elasticity of supply)។

ឧទាហរណ៍ថា ពូសំជាអ្នកពិសាជំឡូងផ្វាជារៀងរាល់ថ្ងៃ គាត់មានទស្សនាទានថា នៅពេលដែលថ្លៃ ជំឡូងផ្វាចុះថោកនោះ គាត់នឹងទទួលទានបរិមាណជំឡូងផ្វាច្រើនជាងមុន។ ប៉ុន្តែនេះមិនមែនគ្រាន់តែជាទស្សនាទាននៃការវាស់ភាពយឺតរបស់ពូសំមួយប៉ុណ្ណោះទេ យើងនឹងពិនិត្យពិភាក្សាពីហេតុផលផ្សេងទៀតដែលទាក់ទងនឹងផ្នត់គំនិតរបស់លោកពូសំដែលវាទាក់ទងទៅនឹងពីចំណូលរបស់គាត់ និងការប្រែប្រួលនៃថ្លៃទំនិញផ្សេងទៀតដូចជា ការប្រែប្រួលថ្លៃនៃជំឡូងគរ ជំឡូងឈាមមាន់ ជំឡូងបាស ចេក ការ៉ុត ពោត...។ ល។ ដែលយើងនឹងលើកយកវាមកធ្វើការពិភាក្សានៅក្នុងមេរៀននេះ។

យើងនឹងពង្រីកវិសាលភាពនៃការពិភាក្សារហូតដល់ទស្សនាទាននៃភាពយឺតនៃចំណូល (Income Elasticity of Demand) ភាពយឺតខ្វែងគ្នានៃថ្លៃ (Cross-Price Elasticity of Demand) និងភាពយឺតនៃផ្គត់ផ្គង់ (Price Elasticity of Supply) ជាដើម។

ក្នុងករណីទូទៅ យើងអាចកំណត់អត្ថន័យនៃពាក្យថា "ភាពយឺត (Elasticity)" គឺជាផលធៀបនៃបម្រែបម្រួលគិតជាភាគរយនៃទំនាក់ទំនងរវាងអថេរពីរ។

ភាពយឺត (Elasticity) គឺជាការងារវាស់វែងនៃភាពទទួលខុសត្រូវរបស់អថេរមួយទៅលើអថេរមួយទៀត។ វានឹងបង្ហាញយើងថា ប្រសិនបើមានការផ្លាស់ប្តូរបន្តិចបន្តួចរបស់អថេរមួយ តើនឹងមានការផ្លាស់ប្តូរប៉ុន្មានចំពោះអថេរមួយទៀតដោយសារផ្លាស់ប្តូរដូរនេះ។ ការផ្លាស់ប្តូរនេះនេះត្រូវបានគេធ្វើការវាស់វែងគិតជាភាគរយនៃបរិមាណផលិតផលមួយដោយគិតក្នុងបម្រែបម្រួលនៃថ្លៃគិតក្នុង១ភាគរយ។

ដូចនេះ ភាពយឺត (Elasticity) គឺជាការវាស់វែងនូវទំហំ ឬភាគរយនៃការផ្លាស់ប្តូរអថេរមួយទៅនឹងទំហំ ឬភាគរយនៃការផ្លាស់ប្តូរមួយផ្សេងទៀត។

ភាពយឺត (Elasticity) គឺបម្រែបម្រួលគិតជាភាគរយនៃផលធៀបរវាងទំហំពីរ។ បើសរសេរជាទម្រង់គណិតវិទ្យាគឺ៖

$$\text{មេគុណនៃភាពយឺត} = \frac{\text{បម្រែបម្រួលគិតជាភាគរយនៃអថេរមួយ}}{\text{បម្រែបម្រួលគិតជាភាគរយនៃអថេរមួយទៀត}}$$

$$\text{Coefficient of Elasticity} = \frac{\text{Percent charge in A}}{\text{Percent charge in B}}$$

ភាពយឺតនៃតម្រូវការ (The elasticity of demand) គឺជាសញ្ញាមួយសម្រាប់វាស់ថា តើបរិមាណតម្រូវការមានប៉ុន្មានឆ្លើយតបទៅនឹងការប្រែប្រួលតម្លៃទំនិញនីមួយៗខុសគ្នានៅត្រង់កម្រិតបរិមាណដែលបានទិញនឹងឆ្លើយតបទៅនឹងការប្រែប្រួលតម្លៃរបស់ពួកវានីមួយៗ? ស្រូវសាឡីដែលត្រូវការអាចកើនឡើងតិចជាង ១% ចំពោះការកាត់បន្ថយតម្លៃស្រូវសាឡីចុះ ១%។ ការលក់សំបុត្រប្រើផ្លូវ Express ឱ្យអ្នកធ្វើដំណើរអាចកើនច្រើនជាង ១% ចំពោះការកាត់បន្ថយតម្លៃចុះ ១%។

## ៧ ភាពយឺតនៃថ្លៃរបស់តម្រូវការ (The Price Elasticity of Demand)

ភាពយឺតនៃថ្លៃ (Price Elasticity of Demand) ជាទំហំនៃការប្រែប្រួលគិតជាភាគរយក្នុងបរិមាណតម្រូវការក្នុងរយៈពេលមួយកំណត់មួយដែលបណ្តាលមកពីការប្រែប្រួលគិតជាភាគរយនៃថ្លៃក្នុងរយៈពេលមួយកំណត់។ ដោយសារតែថ្លៃ និងបរិមាណមានទំនាក់ទំនងផ្ទុយគ្នាគឺជម្មតាមេគុណនៃភាពយឺតនៃតម្រូវការជាចំនួនវិជ្ជមាន។

ភាពយឺតនៃថ្លៃនៃតម្រូវកាគឺជាសញ្ញាមួយសម្រាប់ថា តើបរិមាណតម្រូវការប្រែប្រួលប៉ុន្មានភាគរយនៅពេលដែលថ្លៃប្រែប្រួលមួយភាគរយនោះ?

$$\text{ភាពយឺតនៃថ្លៃរបស់តម្រូវការ} = \frac{\text{បម្រែបម្រួលគិតជាភាគរយនៃបរិមាណតម្រូវការ}}{\text{បម្រែបម្រួលគិតជាភាគរយនៃថ្លៃ}}$$

$$\text{Price elasticity of demand} = \frac{\text{\% chage in quantity demanded}}{\text{\% chage in price}}$$

$$E_p^D = \frac{\%\Delta \text{ Quantity}}{\%\Delta \text{ Price}} = \frac{\frac{\Delta Q^D}{Q^D}}{\frac{\Delta P_b}{P_b}} = \frac{\Delta Q^D}{\Delta P_b} \cdot \frac{P_b}{Q^D} = 0 \sim |-\infty|$$

$$E_p^D = \frac{\frac{dQ^D}{Q^D}}{\frac{dP_b}{P_b}} = \frac{dQ^D}{dP_b} \cdot \frac{P_b}{Q^D} = 0 \sim |-\infty|$$

ដែល៖ $e_p^D$ =ភាពយឺតនៃថ្លៃរបស់តម្រូវការរបស់ផលិតផលមួយ

(Price elasticity of demand of a product)

$Q^D$ =បរិមាណតម្រូវការនៃផលិតផលមួយ (Quantity of a product)

$P_b$ =ថ្លៃនៃផលិតផលមួយ (Price of a product)

$\Delta Q^D$ =បម្រែបម្រួលនៃបរិមាណតម្រូវការនៃផលិតផលមួយ

(Change in quantity demanded of a product)

$\Delta P_b$ =បម្រែបម្រួលនៃថ្លៃនៃផលិតផលមួយ (Change in price of a product)

$$e_p^D > 1 \Leftrightarrow \text{Elasic Demand}$$

$$e_p^D = 1 \Leftrightarrow \text{Unitary Elastic Demand}$$

$$e_p^D < 1 \Leftrightarrow \text{Inelasic Demand}$$

**តារាង ៣.១៖ អត្ថន័យនៃភាពយឺតនៃតម្រូវការដោយសារថ្លៃ**

| ភាពយឺត $\lvert e_p^D \rvert$ ជាតម្លៃដាច់ខាត | ពាក្យស័ព្ទ Terminology | អត្ថន័យ Meaning |
|---|---|---|
| $\lvert e_p^D \rvert > 1$ | តម្រូវការមានភាពយឺត Elastic Demand | បម្រែបម្រួលនៃបរិមាណតម្រូវការធំជាងបម្រែបម្រួលនៃថ្លៃ( គិតជាភាគរយ ) |
| $\lvert e_p^D \rvert = 1$ | តម្រូវការមានភាពយឺតឯកត្តា Unitary Elastic Demand | បម្រែបម្រួលនៃបរិមាណតម្រូវការស្មើបម្រែបម្រួលនៃថ្លៃ( គិតជាភាគរយ ) |
| $\lvert e_p^D \rvert < 1\lvert$ | តម្រូវការគ្មានភាពយឺត Inelastic Demand | បម្រែបម្រួលនៃបរិមាណតម្រូវការតូចជាងបម្រែបម្រួលនៃថ្លៃ( គិតជាភាគរយ ) |

- បើ $\lvert e_p^D \rvert > 1$ហៅថា Elastic demand ( តម្រូវការមានភាពយឺត ) មានន័យថាកាលណាថ្លៃប្រែប្រួលមួយភាគរយ នោះនាំអោយបរិមាណតម្រូវការរបស់វាប្រែប្រួលលើសពី ១ ភាគរយ។ ហើយប្រសិនបើទំហំដែលប្រែប្រួលខិតទៅជិត $\infty$ គេឱ្យឈ្មោះថា Perfectly Elastic demand។ មានន័យថា កាលណាថ្លៃទំនិញប្រែប្រួលមួយភាគរយ បរិមាណតម្រូវការរបស់វាប្រែប្រួលមិនកំណត់។ ដែលខ្សែកោងរបស់ Perfectly Elastic demand មានលក្ខណៈស្របទៅនឹងអ័ក្សអាប់ស៊ីស ឬ អ័ក្សបរិមាណផលិតផល។

- បើ $\lvert e_p^D \rvert < 1$ហៅថាជា Inelastic demand មានន័យថាប្រសិនបើថ្លៃផលិតផលប្រែប្រួលមួយភាគរយនោះនឹងនាំឱ្យបរិមាណតម្រូវការទំនិញប្រែប្រួលតិចជាងមួយភាគរយ ហើយប្រសិនបើ Ed ខិតទៅជិតសូន្យ នោះគេហៅថា Perfectly Inelastic demand មានន័យថា ទោះបីជាថ្លៃប្រែប្រួលមួយភាគរយក៏បរិមាណតម្រូវការរបស់វាហាក់បីដូចជាគ្មានផ្លាស់ប្តូរ។ ដែលខ្សែកោងរបស់ Perfectly Inelastic demand ស្របនឹងអ័ក្សអរដោនេ ឬ អ័ក្សថ្លៃទំនិញ។

- បើ $\lvert e_p^D \rvert = 1$ហៅថាជា Unitary elastic demand មានន័យថាកាលណាថ្លៃទំនិញប្រែប្រួលមួយភាគរយនិងនាំអោយបរិមាណតម្រូវការប្រែប្រួលស្មើនឹងមួយភាគដែរ។




$$\text{Price elasticity of demand} = \frac{\%\text{ chage in quantity demanded}}{\%\text{ chage in price}}$$

$$E_p^D = \frac{\%\Delta\text{ Quantity}}{\%\Delta\text{ Price}} = \frac{\frac{\Delta Q^D}{Q^D}}{\frac{\Delta P_b}{P_b}} = \frac{\Delta Q^D}{\Delta P_b} \cdot \frac{P_b}{Q^D}$$

$$E_p^D = \frac{\frac{dQ_{Ave}^D}{Q_{Ave}^D}}{\frac{dP_{Ave}}{P_{Ave}}} = \frac{\frac{2}{10}}{\frac{1}{20}} = \frac{2}{10} \times \frac{20}{1} = 4$$




- **ភាពយឺតនៃថ្លៃរបស់តម្រូវការរវាងចំណុចពីរ( Arc Elasticity of Demand )**

មេគុណភាពយឺតនៃថ្លៃរបស់តម្រូវការរវាងចំណុចពីរនៅលើខ្សែកោងតម្រូវការមួយត្រូវបានគេហៅថាភាពយឺតនៃថ្លៃរបស់តម្រូវការដោយប្រើមធ្យមភាគ( Arc Elasticity of Demand )។ យើងនឹងគណនាភាពយឺតនៃថ្លៃរបស់តម្រូវការដោយប្រើមធ្យមភាគ( Arc Elasticity of Demand )នៅក្នុងតារាងតម្រូវការផ្លែល្មើខាងក្រោម បន្ទាប់មកយើងនឹងបានឃើញថាមេគុណនៃភាពយឺតនៃថ្លៃរបស់តម្រូវការ។ ដូចនេះយើងអាចនិយាយថា ភាពយឺតនៃថ្លៃរបស់តម្រូវការដោយប្រើមធ្យមភាគ( Arc Elasticity of Demand )គ្រាន់តែជាការប៉ាន់ស្មានប៉ុណ្ណោះ។ ការព្យាករណ៍( ការប៉ាន់ស្មាន )នេះត្រូវបានធ្វើវាកាន់តែតូចទៅៗ ហើយខិតទៅរកលីមីតនៃចំណុចមួយ។ ភាពយឺតត្រង់ចំណុចមួយនៃតម្រូវការអាចត្រូវគេគណនាតាមគណិតវិទ្យាដូចឧទាហរណ៍នៃតារាងតម្រូវការផ្លែល្មើខាងក្រោម។

ភាពយឺតនៃថ្លៃរបស់តម្រូវការដោយប្រើមធ្យមភាគ( Arc Elasticity of Demand )ជាការប្រែប្រួលថ្លៃ និងបរិមាណត្រូវបានវាស់ដោយថ្លៃមធ្យម។ ថ្លៃមធ្យមត្រូវបានប្រើដើម្បីជៀសវាងភាពមិនច្បាស់លាស់ដែលបណ្តាលដោយហេតុការណ៍ដែលពេលថ្លៃ ឬបរិមាណផ្លាស់ប្តូរ ការផ្លាស់ប្តូរគឺជាភាគរយផ្សេងគ្នានៃថ្លៃដើមចាស់ខុសពីថ្លៃថ្មី។ ឧទាហរណ៍ការប្រែប្រួលនៃថ្លៃផ្លែល្មើ២ដុល្លា ពីក្នុងតារាងខាងក្រោមគឺជាខុសគ្នាថ្លៃផ្លែល្មើចាស់១២ដុល្លាខុសពីថ្លៃផ្លែល្មើថ្មី១៤ដុល្លា។

ដើម្បីគណនាភាពយឺតអាចឃើញថា ពិនិត្យលើការប្រែប្រួលពីសមតាដើមជាមួយថ្លៃ $P_1$ និងបរិមាណដើម $Q_1$ ទៅសមតាថ្មីបានមកដោយបម្លាស់ទីជាមួយថ្លៃ $P_2$ និងបរិមាណ $Q_2$។ រូបមន្តសម្រាប់គណនាភាពយឺតនៃថ្លៃរបស់តម្រូវការដោយប្រើមធ្យមភាគគឺ៖

$$e_p^D = \frac{\dfrac{Q_2 - Q_1}{\dfrac{(Q_1 + Q_2)}{2}}}{\dfrac{P_2 - P_1}{\dfrac{(P_1 + P_2)}{2}}}$$

$$e_p^D = \frac{Q_2 - Q_1}{(Q_1 + Q_2)/2} \div \frac{P_1 - P_2}{(P_1 - P_2)/2}$$

ដែល៖ $e_p^D$ =ភាពយឺតនៃថ្លរបស់តម្រូវការដោយប្រើមធ្យមភាគរបស់ផលិតផលមួយ

(Arc price elasticity of demand of a product)

$Q_1$ =បរិមាណតម្រូវការដើម(Original quantity of a product)

$Q_2$ =បរិមាណតម្រូវការថ្មី(New quantity of a product)

$P_1$ = ថ្លៃនៃផលិតផលដើម(Original price of a product)

$P_1$ = ថ្លៃនៃផលិតផលថ្មី(New price of a product)



| ថ្លៃផ្លែល្មើ(P) (ឯកតាគិតជាដុល្លា$) | បរិមាណផ្លែល្មើ(Q)(ឯកតាគិតជាគីឡូក្រាម) |
|---|---|
| ១៨ | ០ |
| ១៧ | ២ |
| ១៦ | ៤ |
| ១៥ | ៦ |
| ១៤ | ៨ |
| ១៣ | ១០ |
| ១២ | ១២ |
| ១១ | ១៤ |
| ១០ | ១៦ |
| ៩ | ១៨ |
| ៨ | ២០ |
| ៧ | ២២ |
| ៦ | ២៤ |
| ៥ | ២៦ |

តារាង៣.២៖ តារាងតម្រូវការផ្លែល្មើ

$$e_p^D = \frac{Q_2 - Q_1}{(Q_1 + Q_2)/2} \div \frac{P_1 - P_2}{(P_1 - P_2)/2} = \frac{12 - 14}{(12 + 14)/2} \div \frac{12 - 11}{(11 + 12)/2}$$

$$\Rightarrow e_p^D = \frac{-2}{13} \div \frac{1}{11.5}$$

$$\Rightarrow e_p^D = \frac{-2}{13} \times \frac{11.5}{1}$$

$$\Rightarrow e_p^D = \frac{-2.3}{13}$$

$$\Rightarrow e_p^D = -1.77$$

មូលហេតដែលគេរូបមន្តនៃភាពយឺតនៃថ្លៃរបស់តម្រូវការដោយប្រើមធ្យមភាគរយៈ(Arc price elasticity of demand)គឺគេប្រើសម្រាប់មធ្យមនៃតម្លៃការចាប់ផ្តើម និងតម្លៃចុងក្រោយដែលយើងអាចមលឃើញយ៉ាងច្បាស់។ ប្រសិនបើយើងប្រើតម្លៃចាប់ផ្តើមនោះ គេអាចគណនាមេគុណដូចខាងក្រោមនេះ៖

$$e_p^D = \frac{12-14}{14} \div \frac{12-11}{11}$$

$$\Rightarrow e_p^D = \frac{-2}{14} \div \frac{1}{11}$$

$$\Rightarrow e_p^D = \frac{-1}{7} \times \frac{11}{1}$$

$$\Rightarrow e_p^D = \frac{-11}{7}$$

$$\Rightarrow e_p^D = -1.57$$

សន្មតិថា បើថ្លៃធ្លាក់ចុះពី១២ដុល្លា មកដល់១១ដុល្លា នោះបរិមាណតម្រូវការនឹងកើនទោះឡើងពី១២ឯកតា ទៅ១៤ឯកតា។ ការប្រើប្រាស់តម្លៃចាប់ផ្តើមបណ្តាលឱ្យមេគុណស្មើ - 2 (លោកអ្នកអាចនឹងគណនាចម្លើយនេះដោយខ្លួនឯង)។ ដូចនេះ ឯកតាដូចគ្នានៃការប្រែប្រួលក្នុងថ្លៃ និងបរិមាណដែលបានផ្តល់ខុសគ្នានៃតម្លៃនៃភាពយឺត វាអស្រ័យនឹងការកើនឡើង ឬការធ្លាក់ចុះនៃថ្លៃ។

ចំនួនតារាងតម្រូវការបង្ហាញថាបរិមាណតម្រូវការ និងថ្លៃនៃការប្រែប្រួលដែលបណ្តាលមកពីការប្រែប្រួលបរិមាណទៅលើ Range of the Schedule។ សន្មតិថា យើងគណនាភាពយឺតនៃថ្លៃរបស់ប្រែប្រួលពី១២ដុល្លាទៅ៣០ដុល្លា(Arc price elasticity for change a price from \$12 to \$30) នោះគឺ៖

$$e_p^D = \frac{12-14}{(16+12)/2} \div \frac{12-10}{(10+12)/2}$$

$$\Rightarrow e_p^D = \frac{-4}{14} \div \frac{2}{11}$$

$$\Rightarrow e_p^D = \frac{-4}{14} \times \frac{11}{2}$$

$$\Rightarrow e_p^D = \frac{-44}{28}$$

$$\Rightarrow e_p^D = -1.57$$

- **ភាពយឺតនៃថ្លៃរបស់តម្រូវការតាមចំណុច (Point Elasticity of Demand)**

ភាពយឺតនៃថ្លៃរបស់តម្រូវការតាមចំណុច (Point Elasticity of Demand)ត្រូវបានគណនាតាមរូបមន្តដូចខាងក្រោម៖

$$E_p^D = \frac{\frac{dQ^D}{Q^D}}{\frac{dP_b}{P_b}} = \frac{dQ^D}{dP_b} \cdot \frac{P_b}{Q^D} = 0 \sim |-\infty|$$

ឧទាហរណ៍ពីតារាងតម្រូវការនៃផ្លែល្មើ មានសមីការ៖

$$Q^D = 36 - 2P$$

ការគណនាភាពយឺតនៃថ្លៃរបស់តម្រូវការតាមចំណុច (Point Elasticity of Demand)គឺ៖

$$E_p^D = \frac{\frac{dQ^D}{Q^D}}{\frac{dP_b}{P_b}} = \frac{dQ^D}{dP_b} \cdot \frac{P_b}{Q^D} = 0 \sim |-\infty|$$

$$\Rightarrow E_P^D = -2 \times \frac{12}{12}$$

$$\Rightarrow E_P^D = \frac{-24}{12}$$

$$\Rightarrow E_P^D = -2$$

ប្រសិនបើគេឱ្យសមីការអិចស្ពូណង់ស្យែល៖

$$Q = aP^{-b}$$

ដែល៖

$Q$ =បរិមាណតម្រូវការ

$a$ =ចំនួនថេរ

$-b$ =ភាពយឺតនៃថ្លៃរបស់តម្រូវការ

$P$ =ថ្លៃផលិតផល

សមីការមិនមេនលីនេអ៊ែរអាចតម្រូវបានបម្លែងជាសមកីការលោការីត៖

$$Q = log(a) - b \cdot log(P)$$

ខ្សែកោងតម្រូវកាដែលសមការនៃបន្ទាត់ត្រង់(Plot as a Straight line))នៅលើខ្សែកោងលោការីតទ្វេ(Double log or log-log graph) ដែលមានភាពយឺតនៃថ្លៃរបស់តម្រូវការស្មើ (- b)។

ឧទាហរណ៍៖ សមីការអនុគមន៍តម្រូវការ៖

$$Q = 100P^{-1.7}$$

តាមរយៈសមីការនេះគេបានតារាងតម្រូវការដូចខាងក្រោម៖

| Quantity | 10 | 12.5 | 15 | 17.5 | 20 | 22.5 | 25 | 27.5 | 30 |
|---|---|---|---|---|---|---|---|---|---|
| Price | 3.875 | 3.398 | 3.052 | 2.788 | 2.577 | 2.405 | 2.260 | 2.137 | 2.030 |
| Log(*Q*) | 1.0 | 1.10 | 1.18 | 1.24 | 1.30 | 1.35 | 1.40 | 1.44 | 1.48 |
| Log(*P*) | 0.59 | 0.53 | 0.48 | 0.45 | 0.41 | 0.38 | 0.35 | 0.33 | 0.31 |

ខាងក្រោមនេះមានក្រាភិចពីរដែលតំណាងឱ្យខ្សែកោងតម្រូវការគឺ៖ ខ្សែកោងតម្រូវការទី១ តំណាងឱ្យអនុគមន៍ដែលប្រើប្រាសទំហំពីជគណិតធម្មតាគឺជាបន្ទាត់កោង និងខ្សែកោងមួយទៀតតំណាងឱ្យអនុគមន៍លោការីតតែជាបន្ទាត់ត្រង់។



(*a*) (*b*)

| | | Elasticity | | | Marginal Revenue | |
|---|---|---|---|---|---|---|
| Price | Quantity | Arc, $E_P$ | Point, $\epsilon_P$ | Total Revenue | Arc | Point |
| $14 | 8 | | −3.5 | $112 | | $10 |
| | | −3.0 | | | $9 | |
| 13 | 10 | | −2.6 | 130 | | 8 |
| | | −2.3 | | | 7 | |
| 12 | 12 | | −2.0 | 144 | | 6 |
| | | −1.8 | | | 5 | |
| 11 | 14 | | −1.6 | 154 | | 4 |
| | | −1.4 | | | 3 | |
| 10 | 16 | | −1.3 | 160 | | 2 |
| | | −1.1 | | | 1 | |
| 9 | 18 | | −1.0 | 162 | | 0 |
| | | −0.89 | | | −1 | |
| 8 | 20 | | −0.80 | 160 | | −2 |
| | | −0.71 | | | −3 | |
| 7 | 22 | | −0.64 | 154 | | −4 |
| | | −0.57 | | | −5 | |
| 6 | 24 | | −0.50 | 144 | | −6 |
| | | −0.44 | | | −7 | |
| 5 | 26 | | −0.38 | 130 | | −8 |
| | | −0.33 | | | −9 | |
| 4 | 28 | | −0.29 | 112 | | −10 |

Elasticity Coefficient $e_p^D < 1$ => Relatively Inelastic

Elasticity Coefficient $e_p^D = 1$ => Unit-Elastic

Elasticity Coefficient $e_p^D > 1$ => Relatively Elastic

Elasticity Coefficient $e_p^D = 0$ => Perfectly Inelastic

Elasticity Coefficient $e_p^D = \infty$ => Perfectly Elastic

- បើ $e_p^D > 1$ ហៅថា Elastic Demand (តម្រូវការមានភាពយឺត) មានន័យថាកាលណាថ្លៃប្រែប្រួលមួយភាគរយ នោះនាំឱ្យបរិមាណតម្រូវការរបស់វាប្រែប្រួលលើសពី ១ ភាគរយ។

- ហើយប្រសិនបើទំហំដែលប្រែប្រួលខិតទៅជិត $\infty(e_p^D = \infty)$ គេឱ្យឈ្មោះថា Perfectly Elastic Deamnd។ មានន័យថា កាលណាថ្លៃទំនិញប្រែប្រួលមួយភាគរយ បរិមាណតម្រូវការរបស់វាប្រែប្រួលមិនកំណត់។ ដែលខ្សែកោងរបស់ Perfectly Elastic មានលក្ខណៈស្របទៅនឹងអ័ក្សអាប់ស៊ីស ឬ អ័ក្សបរិមាណផលិតផល។

- បើ $e_p^D < 1$ ហៅថាជា Inelastic Demand មានន័យថាប្រសិនបើថ្លៃផលិតផលប្រែប្រួលមួយភាគរយនោះនឹងនាំឱ្យបរិមាណតម្រូវការទំនិញប្រែប្រួលតិចជាងមួយភាគរយ ហើយប្រសិនបើ Ed ខិតទៅជិតសូន្យ $(e_p^D = 0)$ នោះគេហៅថា Perfectly Inelastic Deamnd មានន័យថា ទោះបីជាថ្លៃប្រែប្រួលមួយភាគរយក៏បរិមាណតម្រូវការរបស់វាហាក់បីដូចជាគ្មានផ្លាស់ប្តូរ។ ដែលខ្សែកោងរបស់ Perfectly Inelastic ស្របនឹងអ័ក្សអរដោនេ ឬអ័ក្សថ្លៃទំនិញ។

- បើ $e_p^D = 1$ ហៅថាជា Unitary Elastic Demand មានន័យថាកាលណាថ្លៃទំនិញប្រែប្រួលមួយភាគរយនិងនាំអោយបរិមាណតម្រូវការប្រែប្រួលស្មើនឹងមួយភាគដែរ។

### ណ. ភាពយឺតនៃចំណូលរបស់តម្រូវការ( Income Elasticity of Demand )

ភាពយឺតនៃចំណូលរបស់តម្រូវការ( Income Elasticity of Demand )គឺជាការវាស់ប្រសិទ្ធភាពនៃបរិមាណតម្រូវការទៅលើការប្រែប្រួលនៃចំណូល។ ភាពយឺតនៃចំណូលរបស់តម្រូវការប្រាប់យើងអំពីបរិមាណប៉ុន្មាននៃការប្រែប្រួលតម្រូវការជាមួយនឹងការប្រែប្រួលចំណូល។ ជាទូទៅ ការកើនឡើងនូវចំណូល នឹងនាំឱ្យមានការកើនឡើងនូវតម្រូវការគ្រប់ផលិតផល។ តែទោះជាយ៉ាងណាក៏ដោយក៏ការកើនឡើងនូវតម្រូវការទៅលើផលិតផលមួយចំនួន មានលក្ខណៈច្រើនជាងផលិតផលមួយចំនួនទៀត។

### រូបមន្តគណនាភាពយឺតនៃចំណូលរបស់តម្រូវការ( Income Elasticity of Demand )

ភាពយឺតនៃចំណូលរបស់តម្រូវការ( Income Elasticity of Demand )គឺជាផលចែករវាងភាគរយនៃបរិមាណតម្រូវការដែលបានប្រែប្រួលជាមួយនឹងភាគរយនៃការប្រែប្រួលចំណូល៖

$$\text{ភាពយឺតនៃចំណូលរបស់តម្រូវការ} = \frac{\text{បម្រែបម្រួលគិតជាភាគរយនៃបរិមាណតម្រូវការ}}{\text{បម្រែបម្រួលគិតជាភាគរយនៃចំណូល}}$$

$$e_M = \frac{\text{Percentage Change in Quantity Demanded}}{\text{Percentage Change in income}} = \frac{\%\Delta Q^D}{\%\Delta M}$$

$$\text{Income elasticity of demand} = \frac{\text{\% chage in quantity demanded}}{\text{\% chage in income}}$$

$$\mathrm{e_M} = \frac{\%\Delta\,\text{Quantity}}{\%\Delta\,\text{Income}} = \frac{\frac{\Delta Q^D}{Q^D}}{\frac{\Delta M}{M}} = \frac{\Delta Q^D}{\Delta M}\cdot\frac{M}{Q^D}$$

$$e_M = \frac{\Delta Q}{\Delta M}\frac{M}{Q} = \frac{\Delta \ln Q}{\Delta \ln M}$$

$$e_M = \frac{\Delta Q}{\Delta M}\frac{M}{Q}$$

$$e_M > 0 \Leftrightarrow \text{Normal Goods}\begin{cases} 0 \le e_M \le 1 \Leftrightarrow \text{Necessity Goods or Commodities} \\ e_M > 1 \Leftrightarrow \text{Luxury Goods or Superior Goods} \end{cases}$$

$$e_M < 0 \Leftrightarrow \text{Inferior Goods}$$

- **ភាពយឺតនៃចំណូលរបស់តម្រូវការរវាងចំណុច២ (Arc income elasticity)**

$$E_M = \frac{Q_2 - Q_1}{(Q_1 + Q_2)/2} \div \frac{M_2 - M_1}{(M_1 + M_2)/2}$$

$$E_M > 0 \Leftrightarrow \text{Normal Goods} \begin{cases} 0 \le E_M \le 1 \Leftrightarrow \text{Necessity Goods or Commodities} \\ E_M > 1 \Leftrightarrow \text{Luxury Goods or Superior Goods} \end{cases}$$

$$E_M < 0 \Leftrightarrow \text{Inferior Goods}$$




❖ ករណីសិក្សា៖

**ភាពយឺតនៃចំណូលរបស់តម្រូវការផលិតផលស្រូវ (Income Elasticity of Demand for Rice )**

$$e_M^D = \frac{\frac{\Delta Q_{Rice}^D}{Q_{Rice}^D}}{\frac{\Delta M}{M}} = \frac{\Delta Q_{Rice}^D}{\Delta M} \times \frac{M}{Q_{Rice}^D}$$

ដែល $e_M^D$៖ភាពយឺតនៃថ្លៃនៃតម្រូវការរបស់ផលិតផលដំណាំស្រូវ

$Q_{Maize}^D$៖បរិមាណតម្រូវការនៃផលិតផលដំណាំស្រូវ

$\Delta Q_{Rice}^D$៖បម្រែបម្រួលបរិមាណតម្រូវការនៃផលិតផលដំណាំស្រូវ

$M$ ៖ចំណូលរបស់មនុស្សម្នាក់ក្នុងមួយឆ្នាំ

$\Delta M$ ៖បម្រែបម្រួលចំណូលរបស់មនុស្សម្នាក់ក្នុងមួយឆ្នាំ

(ប្រភព៖ William M. Tomex and Kenneth L. Robinson, 2003, *Agricultural Product Prices*, 4th Edition, Cornell University Press, pp. 35 – 36.)

**ភាពយឺតនៃចំណូលនៃផលិតផលស្រូវ**

ភាពយឺតនៃចំណូលរបស់តម្រូវការ គឺជារង្វាស់នៃការឆ្លើយតបនៃបរិមាណ ដើម្បីផ្លាស់ប្តូរនៃប្រាក់ចំណូល និងកត្តាផ្សេងទៀតកំពុងស្ថិតថេរ។ ជាការពិតទំនាក់ទំនងបរិមាណអាចត្រូវបានគណនាតាមរយៈទម្រង់ពិជគណិត។ ទំនាក់ទំនងនេះជួនកាលត្រូវបានគេហៅថា ការប្រើប្រាស់ ឬមុខងារនៃភាពយឺត។ ភាពយឺយនៃចំណូលត្រូវបានកំណត់នៅចំណុចមួយនៅលើមុខងារ ហើយជាទូទៅប្រែប្រួលតាមជួរនៃខ្សែកោង។ ភាពយឺតនៃចំណូលរបស់បរិមាណស្រូវដែលត្រូវការអាចត្រូវបានបកស្រាយថាការផ្លាស់ប្តូរភាគរយនៃបរិមាណស្រូវដែលត្រូវនឹងការផ្លាស់ប្តូរ ១ភាគរយ នៃប្រាក់ចំណូលក្នុងមនុស្សម្នាក់ និងកត្តាផ្សេងទៀតមានភាពស្ថិតថេរ។

$$e_M = \frac{\frac{\partial RQD_t}{RQD_t}}{\frac{\partial PCI_t}{PCI_t}} = \frac{\partial RQD_t}{\partial PCI_t} \times \frac{PCI_t}{RQD_t}$$

$$e_M = 0 > 002 \times \frac{1/993 > 4074074}{133 > 9620671} = \frac{3 > 986814815}{133 > 9620671} = 0 > 029760774 \approx 0 > 03$$

លទ្ធផលភាពយឺតនៃចំណូលរបស់បរិមាណស្រូវដែលត្រូវការគឺ ០.០៣ ឬ $e_M = 0.03$ មានន័យថាបើប្រាក់ចំណូលកើនឡើង ឬថយចុះ ១% នោះការប្រើប្រាស់ស្រូវនឹងកើនឡើង ឬថយចុះ ០.០៣% នៅកម្ពុជា។ ដូច្នេះស្រូវ គឺជាតម្រូវការចាំបាច់ យោងតាមទិន្នន័យនៅក្នុងតារាងទី៤.៥ ប្រាក់ចំណូលប្រចាំឆ្នាំសម្រាប់មនុស្សម្នាក់បានកើនឡើងពី ៧១០ដុល្លារ ទៅ ៤,៣២០ដុល្លារ និងការប្រើប្រាស់អង្ករសម្រាប់មនុស្សម្នាក់ៗបានចាប់ផ្តើមថយចុះពី ១៥១.៣គីឡូក្រាម មកនៅត្រឹម ១១២.៦ គីឡូក្រាមក្នុងអំឡុងឆ្នាំ១៩៩៣ ដល់ ឆ្នាំ២០១៩ ខណៈដែលប្រាក់ចំណូលសម្រាប់មនុស្សម្នាក់បានកើនឡើងជាបន្តបន្ទាប់។

**គ. ភាពយឺតនៃថ្លៃខ្វែងគ្នានៃតម្រូវការ (Cross-Price Elasticity of Demand)**

មេគុណភាពយឺតខ្វែងគ្នានៃថ្លៃរបស់តម្រូវការ គឺជាផលធៀបនៃបម្រែបម្រួលគិតជាភាគរយនៃបរិមាណនៃទំនិញមួយជាមួយនឹងបម្រែបម្រួលគិតជាភាគរយនៃថ្លៃទំនិញមួយផ្សេងទៀត។

$$\text{ភាពយឺតនៃថ្លៃរបស់តម្រូវការ} = \frac{\text{បម្រែបម្រួលគិតជាភាគរយនៃបរិមាណតម្រូវការ}}{\text{បម្រែបម្រួលគិតជាភាគរយនៃថ្លៃទំនិញជំនួសឬទំនិញបំពេញ}}$$

$$\text{Cross} - \text{price elasticity of demand} = \frac{\%\ \text{chage in quantity demanded}}{\%\ \text{chage in price of a substitution or complement}}$$

$$\text{Cross}-\text{price elasticity of demand}=\frac{\%\ \text{chage in quantity demanded of good X}}{\%\ \text{chage in price of good Y}}$$

$$e^{p}_{XY}=\frac{\%\Delta\ \text{Quantity of X}}{\%\Delta\ \text{Price of Y}}=\frac{\frac{\Delta Q^D_X}{Q^D_X}}{\frac{\Delta P_Y}{P_Y}}=\frac{\Delta Q^D_X}{\Delta P_Y}\cdot\frac{P_Y}{Q^D_X}$$

$$e^p_{XY}>0\Leftrightarrow \text{X and Y are Substitute}$$

$$e^p_{XY}=0\Leftrightarrow \text{X and Y are Independent Commodities}$$

$$e^p_{XY}<0\Leftrightarrow \text{X and Y are Complement}$$

ឧទាហរណ៍៖ មេគុណភាពយឺតខ្វែងគ្នានៃថ្លៃរបស់តម្រូវការសាច់គោ គឺជាផលធៀបនៃបម្រែបម្រួលគិតជាភាគរយនៃបរិមាណសាច់គោជាមួយនឹងបម្រែបម្រួលគិតជាភាគរយនៃថ្លៃសាច់ជ្រូក។

$$e^p_{bp}=\frac{\text{Percentage Change in Beef Quantity Demanded}}{\text{Percentage Change in Pork Price}}$$

$$e^p_{bp}=\frac{\frac{\Delta Q^{Beef}}{Q^{Beef}}}{\frac{\Delta P^{Pork}}{P^{Pork}}}=\frac{\Delta Q^{Beef}}{\Delta P^{Pork}}\frac{P^{Pork}}{Q^{Beef}}$$

$$e^p_{bp}>0\Leftrightarrow \text{Beef and Pork are Substitute}$$

$$e^p_{b}=0\Leftrightarrow \text{Independent Commodities}$$

$$e^p_{bp}<0\Leftrightarrow \text{Beef \& Prok are Complement}$$

Arc cross-elasticity

$$E^p_{AB}=\frac{Q_{2A}-Q_{1A}}{(Q_{1A}+Q_{2A})/2}\div\frac{P_{2B}-P_{1B}}{(P_{1B}+P_{2B})/2}$$

$$E^p_{XY}>0\Leftrightarrow \text{X and Y are Substitute}$$

$$E^p_{XY}=0\Leftrightarrow \text{X and Y are Independent Commodities}$$

$$E^p_{XY}<0\Leftrightarrow \text{X and Y are Complement}$$

Point cross-elasticity

$$E_{bp}^{P} = \frac{\Delta Q_b}{Qb} \div \frac{\Delta P_p}{P_p}$$

$$E_{bp}^{p} > 0 \Leftrightarrow \text{Beef and Pork are Substitute}$$

$$E_{b}^{p} = 0 \Leftrightarrow \text{Independent Commodities}$$

$$E_{bp}^{p} < 0 \Leftrightarrow \text{Beef \& Prok are Complement}$$




A burger is a *substitute* for pizza. When the price of a burger rises, the demand for pizza increases and the demand curve for pizza shifts rightward from $D_0$ to $D_1$. The cross elasticity of demand is *positive*.

A soft drink is a *complement* of pizza. When the price of a soft drink rises, the demand for pizza decreases and the demand curve for pizza shifts leftward from $D_0$ to $D_2$. The cross elasticity of demand is *negative*.

❖ .ករណីសិក្សា៖

ភាពយឺតខ្វែងគ្នានៃថ្លៃរបស់តម្រូវការផលិតផលស្រូវ (Cross-Price Elasticity of Demand for Rice)

$$e_p^D = \frac{\frac{\Delta Q_{Rice}^D}{Q_{Rice}^D}}{\frac{\Delta P_{Maize}}{P_{Maize}}} = \frac{\Delta Q_{Rice}^D}{\Delta P_{Rice}} \times \frac{P_{Maize}}{Q_{Maize}^D}$$

ដែល$e_p^D$៖ភាពយឺតនៃថ្លៃនៃតម្រូវការរបស់ផលិតផលដំណាំស្រូវ

$Q_{Rice}^D$៖បរិមាណតម្រូវការនៃផលិតផលដំណាំស្រូវ

$\Delta Q_{Rice}^D$៖បម្រែបម្រួលបរិមាណតម្រូវការនៃផលិតផលដំណាំស្រូវ

$P_{Maize}$៖ថ្លៃផលិតផលពោត

$\Delta P_{Maize}$៖បម្រែបម្រួលថ្លៃនៃផលិតផលពោត

| ឆ្នាំ | ការប្រើប្រាស់អង្ករក្នុងមនុស្សម្នាក់ (គីឡូក្រាម/ម្នាក់) | តម្លៃអង្ករសម្រាប់អ្នកប្រើប្រាស់ (រៀល/គីឡូក្រាម) | តម្លៃពោតសម្រាប់អ្នកប្រើប្រាស់ (រៀល/គីឡូក្រាម) | ប្រាក់ចំណូលប្រចាំឆ្នាំក្នុងមនុស្សម្នាក់ (ដុល្លារ) |
|---|---|---|---|---|
| ១៩៩៣ | ១៥១.៣ | ៨១០ | ៩៣០ | ៧១០ |
| ១៩៩៤ | ១៥០.០ | ៨២០ | ៥៧៥ | ៧៤២ |
| ១៩៩៥ | ១៥៩.៦ | ៨៤០ | ៤៩៥ | ៧៨០ |
| ១៩៩៦ | ១៥៤.៧ | ៨៥០ | ៦៦០ | ៨១០ |
| ១៩៩៧ | ១៥០.៦ | ៨៧០ | ៥៦០ | ៨៤០ |
| ១៩៩៨ | ១៥៥.៤ | ៩០០ | ៦២០ | ៨៦០ |
| ១៩៩៩ | ១៥៥.២ | ៩៦០ | ៧៩៥ | ៩៥០ |
| ២០០០ | ១៥៤.៣ | ១,០០០ | ៦២៥ | ១,០៤០ |
| ២០០១ | ១៤១.២ | ១,០៣០ | ៥១៥ | ១,១២០ |
| ២០០២ | ១៣៩.២ | ១,០៦១ | ៥៣០ | ១,១៨០ |
| ២០០៣ | ១៣៧.៣ | ១,០៩៣ | ៥៤៦ | ១,២៩០ |
| ២០០៤ | ១៣៥.៤ | ១,១២៦ | ៥៦៣ | ១,៤៤០ |
| ២០០៥ | ១៣៣.៥ | ១,២១៤ | ៦០៧ | ១,៦៤០ |
| ២០០៦ | ១៣១.៦ | ១,១២១ | ៥៦១ | ១,៨៥០ |
| ២០០៧ | ១២៩.៧ | ១,៤៥១ | ៧២៦ | ២,០៨០ |
| ២០០៨ | ១២៧.៩ | ១,១២៣ | ៥៦២ | ២,២២០ |
| ២០០៩ | ១២៦.១ | ៩០៧ | ៤៥៤ | ២,២០០ |
| ២០១០ | ១២៤.៤ | ១,០០៨ | ៥០៤ | ២,៣២០ |
| ២០១១ | ១២៣.០ | ១,០២៧ | ៥១៤ | ២,៤៩០ |
| ២០១២ | ១២១.៦ | ១,០៤៧ | ៥២៣ | ២,៧២០ |
| ២០១៣ | ១២០.៣ | ១,០៦៧ | ៥៣៣ | ២,៩២០ |
| ២០១៤ | ១១៩.០ | ១,៧១៨ | ៨៥៩ | ៣,០២០ |
| ២០១៥ | ១១៧.៧ | ១,៤៨៨ | ៦៧២ | ៣,១៨០ |
| ២០១៦ | ១១៦.៤ | ១,៥២៩ | ៦២៣ | ៣,៤៥០ |
| ២០១៧ | ១១៥.១ | ១,៥៩៥ | ៦១១ | ៣,៦៨០ |
| ២០១៨ | ១១៣.៨ | ១,៦៥៩ | ៦៦៧ | ៣,៩៧០ |
| ២០១៩ | ១១២.៦ | ១,៧៤៥ | ៦៨៤ | ៤,៣២០ |

**ប្រភព៖** - វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ របាយការណ៍របស់ប្រទេសកម្ពុជាការស្ទង់មតិសេដ្ឋកិច្ចសង្គមឆ្នាំ ២០២០

### ភាពយឺតខ្វែងគ្នានៃថ្លៃរបស់តម្រូវការផលិតផលស្រូវ

ភាពយឺតខ្វែងគ្នានៃថ្លៃរបស់តម្រូវការស្រូវ គឺជារង្វាស់នៃតម្រូវការស្រូវឆ្លើយតបទៅនឹងការផ្លាស់ប្តូរតម្លៃពោត។ ច្បាស់ជាងនេះទៅទៀតភាពយឺតខ្វែងគ្នានៃថ្លៃរបស់តម្រូវការស្រូវទាក់ទងនឹងពោតត្រូវបានកំណត់ថា៖

$$e_{cp} = \frac{\frac{\partial RQD_t}{RQD_t}}{\frac{\partial MP_t}{MP_t}} = \frac{\partial RQD_t}{\partial MP_t} \times \frac{MP_t}{RQD_t}$$

$$e_{cp} = 0 > 002 \times \frac{611 > 6153755}{133 > 9620671} = \frac{1 > 223230751}{133 > 9620671} = 0 > 009131 \approx 0 > 0091$$

នេះអាចត្រូវបានបកស្រាយថា ជាការផ្លាស់ប្តូរនៃភាគរយបរិមាណស្រូវដែលបានធ្វើឱ្យមានការផ្លាស់ប្តូរតម្លៃពោត ១% ដែលជាកត្តាដទៃទៀតនៅតែថេរ។ នៅក្នុងការសិក្សានេះភាពយឺតនៃថ្លៃស្រូវនៅកម្ពុជាគឺ ០.០០៩១ ឬ $e_{cp} = 0.0091$។ មានន័យថាប្រសិនបើតម្លៃពោតឡើងថ្លៃ ឬថយចុះ ១ ភាគរយនោះការប្រើប្រាស់ស្រូវនឹងថយចុះ ឬកើនឡើង ០.០០៩១% ដែលមានន័យថាស្រូវ និងពោតគឺជាទំនិញជំនួសគ្នាបាន។ ជាលទ្ធផលតម្លៃពោតប្រហែលជាមិនមានឥទ្ធិពលលើតម្រូវការតម្លៃស្រូវទេ។

| Product | Estimated $\epsilon_{Q,P}$ |
|---|---|
| Cigars | −0.756 |
| Canned and cured seafood | −0.736 |
| Fresh and frozen fish | −0.695 |
| Cheese | −0.595 |
| Ice cream | −0.349 |
| Beer and malt beverages | −0.283 |
| Bread and bakery products | −0.220 |
| Wine and brandy | −0.198 |
| Cookies and crackers | −0.188 |
| Roasted coffee | −0.120 |
| Cigarettes | −0.107 |
| Chewing tobacco | −0.105 |
| Pet food | −0.061 |
| Breakfast cereal | −0.031 |

*Source:* Emilio Pagoulatos and Robert Sorensen, "What Determines the Elasticity of Industry Demand," *International Journal of Industrial Organization*, 4 (1986): 237–250.

រូបភាព៖ ការប៉ាន់ស្មាននៃភាពយឺតនៃថ្លៃរបស់តម្រូវការនៃទំនិញស្បៀង ថ្នាំជក់ និងទឹកផលិតផល

(Estimate of the Price Elasticity of Demand for Selected Food, Tobacco, and Liquor Products)

**ថ. ទំនាក់ទំនងរវាងភាពយឺតនៃថ្លៃរបស់តម្រូការ និងប្រាក់ចំណូល**

វិធីចំណូលសរុបគឺជាវិធីសាស្ត្រសាមញ្ញមួយដើម្បីកំណត់ថាតើតម្រូវការមានភាពយឺត ឬគ្មានភាពយឺត ឬក៏ជាឯកត្តាភាពយឺត។ ចំនួនទឹកប្រាក់ដែលអ្នកប្រើប្រាស់(គ្រួសារ) បានចំណាយសម្រាប់ទំនិញ និងសេវាកម្ម $TR = P * Q$ (ក្នុងបរិមាណណាមួយដែលទិញតាមតម្លៃទីផ្សារ) ពេលខ្លះគេហៅថា ជាចំណាយរបស់អតិថិជន ហើយចំនួននេះក៏ទាក់ទងទៅនឹងប្រាក់ដែលទទួលបានដោយក្រុមហ៊ុន $TR = P * Q$។


Price (dollars per pizza)
25.00
20.00
15.00
12.50
10.00
5.00
0
25
50
Quantity (pizzas per hour)
Elastic demand
Unit elastic
Inelastic demand
(a) Demand
Total revenue (dollars)
350.00
312.50
250.00
200.00
150.00
100.00
50.00
Maximum total revenue
When demand is elastic, a price cut increases total revenue
When demand is inelastic, a price cut decreases total revenue
(b) Total revenue

តារាង២៣.៖ ទំនាក់ទំនងភាពយឺតតម្រូវការ និងប្រាក់ចំណូល

| ភាពយឺត | ពាក់ព័ន្ធ | TR នៅពេលបញ្ចុះ P | TR នៅពេលបង្កើន P |
|---|---|---|---|
| $e_p^D > 1$ | តម្រូវការមានភាពយឺត | TR កើន | TR ថយ |
| $e_p^D = 1$ | តម្រូវការមានភាពយឺតឯកត្តា | TR មិនប្រែប្រួល | TR មិនប្រែប្រួល |
| $e_p^D < 1$ | តម្រូវការគ្មានភាពយឺត | TR ថយ | TR កើន |




រូបភាព៖ ទំនាក់ទំនងរវាងភាពយឺតនៃថ្លៃរបស់តម្រូការ និងប្រាក់ចំណូល

គេដឹងថា៖

$$TR = P \cdot Q$$

ដែល៖

$TR$ =ចំណូលសរុប

$P$ =ថ្លៃលក់ក្នុងមួយឯកតានៅលើទីផ្សារ
$Q$ =បរិមាណផលិតផលលក់ដាច់
$MR$ =ចំណូលលំអៀង
តាមរូបមន្តគេបាន៖

$$MR = (TR)' = \frac{dTR}{dQ}$$

$$\Rightarrow MR = \frac{dTR}{dQ} = \frac{d(PQ)}{dQ}$$

$$\Rightarrow MR = \frac{(PdQ + QdP)}{dQ}$$

$$\Rightarrow MR = \frac{PdQ}{dQ} + \frac{QdP}{dQ}$$

$$\Rightarrow MR = P + \frac{QdP}{dQ}$$

$$\Rightarrow MR = P + \frac{QdP}{dQ} \cdot \frac{P}{P}$$

$$\Rightarrow MR = P + \frac{PdP}{dQ} \cdot \frac{Q}{P}$$

$$\Rightarrow MR = P\left(1 + \frac{dP}{dQ} \cdot \frac{P}{Q}\right)$$

$$\Rightarrow MR = P\left(1 + \frac{1}{\frac{dQ}{dP}\frac{P}{Q}}\right)$$

$$\Rightarrow MR = P\left(1 + \frac{1}{e}\right)$$

ដែល $e$ =ភាពយឺតនៃថ្លៃរបស់តម្រូវការ

ហើយ $e = \frac{dQ}{dP}\frac{P}{Q} \Rightarrow \frac{1}{e} = \frac{dP}{dQ}\frac{Q}{P}$







**Demand Schedule and Total Revenue for a Linear Demand Curve**

| Price | Quantity demanded | Total revenue |
|---|---|---|
| $0 | 10 | $0 |
| 1 | 9 | 9 |
| 2 | 8 | 16 |
| 3 | 7 | 21 |
| 4 | 6 | 24 |
| 5 | 5 | 25 |
| 6 | 4 | 24 |
| 7 | 3 | 21 |
| 8 | 2 | 16 |
| 9 | 1 | 9 |
| 10 | 0 | 0 |

The upper panel shows a demand curve corresponding to the demand schedule in the table. The lower panel shows how total revenue changes along that demand curve: at each price and quantity combination, the height of the bar represents the total revenue generated. You can see that at a low price, raising the price increases total revenue. So demand is inelastic at low prices. At a high price, however, a rise in price reduces total revenue. So demand is elastic at high prices.


$Q = a - bP$
or
$P = \frac{a}{b} - \frac{Q}{b}$
$\frac{a}{b}$
$\varepsilon_{Q,P} = -\infty$
Elastic region
$\varepsilon_{Q,P}$ between $-\infty$ and $-1$
$\frac{a}{2b}$
$M$
$\varepsilon_{Q,P} = -1$
Inelastic region
$\varepsilon_{Q,P}$ between $-1$ and 0
$D$
$\varepsilon_{Q,P} = 0$
Price (dollars per unit)
0
$\frac{a}{2}$
$a$
Quantity (units per year)


P $
18
16
14
12
10
8
6
4
2
0
Elastic (|∈| > 1)
Unitary elasticity (|∈| = 1)
Inelastic (|∈| < 1)
4
8
12
16
20
24
28
32
36
Q




រូបភាព៖ Total Revenue Curve




**Demand curve in (a) indicates consumers will demand all that is offered at the given price, p. If the price rises above p, quantity demanded drops to zero ➔ *perfectly elastic demand curve*.**

**Demand curve in (b) is vertical, quantity demanded does not vary when the price changes ➔ no matter how high the price, consumers will purchase the same quantity ➔ *perfectly inelastic demand curve*.**

**(c) shows a *unit-elastic demand curve* where any percent change in price results in an identical offsetting percent change in quantity demanded.**

| Price | Quantity | Elasticity: Arc, $E_P$ | Elasticity: Point, $\epsilon_P$ | Total Revenue |
|---|---|---|---|---|
| $18 | 0 | | −∞ | $0 |
| 17 | 2 | −35.00 | −17.00 | 34 |
| 16 | 4 | −11.00 | −8.00 | 64 |
| 15 | 6 | −6.20 | −5.00 | 90 |
| 14 | 8 | −4.10 | −3.50 | 112 |
| 13 | 10 | −3.00 | −2.60 | 130 |
| 12 | 12 | −2.30 | −2.00 | 144 |
| 11 | 14 | −1.77 | −1.57 | 154 |
| 10 | 16 | −1.40 | −1.25 | 160 |
| 9 | 18 | −1.12 | −1.00 | 162 |
| 8 | 20 | −0.89 | −0.80 | 160 |
| 7 | 22 | −0.71 | −0.64 | 154 |
| 6 | 24 | −0.57 | −0.50 | 144 |
| 5 | 26 | −0.44 | −0.38 | 130 |
| 4 | 28 | −0.33 | −0.29 | 112 |
| 3 | 30 | −0.24 | −0.20 | 90 |
| 2 | 32 | −0.16 | −0.13 | 64 |
| 1 | 34 | −0.09 | −0.06 | 34 |
| 0 | 36 | −0.03 | 0 | 0 |

$$e_p = \frac{dQ}{dP} \cdot \frac{P}{Q} = 0 \sim |-\infty|$$

$$E_P = \frac{Q_2 - Q_1}{(Q_1 + Q_2)/2} \div \frac{P_1 - P_2}{(P_1 - P_2)/2}$$

## ២.៦ ករណីសិក្សាទី១.

### ក. គំរូវិភាគអំពីតម្រូវការស្រូវ

សន្មតិថា តម្រូវការស្រូវក្នុងមនុស្សម្នាក់ គឺជាមុខងារនៃប្រាក់ចំណូលរបស់មនុស្សម្នាក់ៗ តម្លៃស្រូវ និងតម្លៃនៃការជំនួសស្រូវដូចជាតម្លៃពោតជាដើម។ លើសពីនេះទៀតវាត្រូវបានសន្មតថាអតិថិជន តំណាងឱ្យការប្រើប្រាស់ ឧបករណ៍ប្រើប្រាស់អតិបរមារបស់ពួកគេដោយផ្តល់ប្រាក់ចំណូលថេរ។ ការប្រើប្រាស់ស្រូវភាគច្រើនរងផលប៉ះពាល់ពីតម្លៃស្រូវ និងប្រាក់ចំណូលរបស់អ្នកប្រើប្រាស់។ ជាពិសេសដើម្បីឆ្លុះបញ្ចាំងពីការកើនឡើង និង/ឬការថយចុះ និន្នាការនៃតម្រូវការអង្ករនៅ កម្ពុជាក្នុងពេលតែមួយ តម្លៃស្រូវ តម្លៃពោត និងប្រាក់ចំណូលរបស់មនុស្សម្នាក់ៗត្រូវបានគេរាប់បញ្ចូលជាពីរទម្រង់ មួយជាទំរង់ចម្រាស់ និងមួយទៀតជាទម្រង់លោការីត។

មុខងារតម្រូវការអង្ករដែលត្រូវប៉ាន់ស្មានមានដូចខាងក្រោម៖

**ទម្រង់គណិតវិទ្យា** (Mathematical Model)

$$RQD = f(RP, MP, PCI)$$

ឬទម្រង់ Regression (Regression Model)

$$RQD = \beta_0 + \beta_1 RP + \beta_2 MP + \beta_3 PCI + \varepsilon_t$$

ដែល $RQD$ ៖ តម្រូវការស្បៀងអាហារ (គីឡូក្រាម/មនុស្សម្នាក់)

$RP$ ៖ តម្លៃស្រូវ (រៀល/គីឡូក្រាម)

$MP$ ៖ តម្លៃពោត ឬតម្លៃជំនួស (រៀល/គីឡូក្រាម)

$PCI$ ៖ ប្រាក់ចំណូលប្រចាំឆ្នាំ (ដុល្លារ)

$\varepsilon_t$៖ សំណល់ ឬ កម្រិតលម្អៀង

**ខ. ទិន្នន័យ**

ទិន្នន័យសម្រាប់ការប្រើប្រាស់អង្ករប្រចាំឆ្នាំសម្រាប់មនុស្សម្នាក់ៗ តម្លៃស្រូវប្រចាំឆ្នាំ និងតម្លៃពោតប្រចាំឆ្នាំត្រូវបានដកស្រង់ចេញពី ***របាយការណ៍ប្រចាំឆ្នាំស្តីពីការស្រាវជ្រាវសេដ្ឋកិច្ចសង្គមកម្ពុជា*** នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ***ព្រឹត្តិប័ត្រកសិកម្មប្រចាំឆ្នាំ*** របស់នាយកដ្ឋានផែនការស្ថិតិ និងកិច្ចសហប្រតិបត្តិអន្តរជាតិ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ***របាយការណ៍ប្រចាំឆ្នាំស្តីពីការស្ទង់មតិប្រាក់ចំណូល និងចំណាយគ្រួសារ*** របស់ទីស្តីការគណៈរដ្ឋមន្ត្រី។ ទិន្នន័យស្តីពីប្រាក់ចំណូលប្រចាំឆ្នាំរបស់មនុស្សម្នាក់ៗត្រូវបានដកស្រង់ចេញពី ***របាយការណ៍ប្រចាំឆ្នាំស្តីពីការអង្កេតប្រាក់ចំណូល និងចំណាយគ្រួសារ*** របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ***របាយការណ៍ប្រចាំឆ្នាំស្ថិតិស្តីពីចំណូលនៅតំបន់ជនបទ*** នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ***របាយការណ៍ប្រចាំឆ្នាំស្តីពីចំណូលគ្រួសារ និងចំណាយការស្ទង់មតិនៅកម្ពុជា*** នៃធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក។

## តារាង២.៤៖បរិមាណអង្ករដែលបានប្រើប្រាស់តម្លៃអង្ករតាមកម្រិតកសិផល និងចំណូលក្នុងបុគ្គលម្នាក់ៗ

| ឆ្នាំ | ការប្រើប្រាស់អង្ករក្នុងមនុស្សម្នាក់ (គីឡូក្រាម/ម្នាក់) | តម្លៃអង្ករសម្រាប់អ្នកប្រើប្រាស់ (រៀល/គីឡូក្រាម) | តម្លៃពោតសម្រាប់អ្នកប្រើប្រាស់ (រៀល/គីឡូក្រាម) | ប្រាក់ចំណូលប្រចាំឆ្នាំក្នុងមនុស្សម្នាក់ (ដុល្លា) |
|---|---|---|---|---|
| ១៩៩៣ | ១៥១.៣ | ៨១០ | ៩៣០ | ៧១០ |
| ១៩៩៤ | ១៥០.០ | ៨២០ | ៥៧៥ | ៧៤២ |
| ១៩៩៥ | ១៥៩.៦ | ៨៤០ | ៤៩៥ | ៧៨០ |
| ១៩៩៦ | ១៥៤.៧ | ៨៥០ | ៦៦០ | ៨១០ |
| ១៩៩៧ | ១៥០.៦ | ៨៧០ | ៥៦០ | ៨៤០ |
| ១៩៩៨ | ១៥៥.៤ | ៩០០ | ៦២០ | ៨៦០ |
| ១៩៩៩ | ១៥៥.២ | ៩៦០ | ៧៩៥ | ៩៥០ |
| ២០០០ | ១៥៤.៣ | ១,០០០ | ៦២៥ | ១,០៤០ |
| ២០០១ | ១៤១.២ | ១,០៣០ | ៥១៥ | ១,១២០ |
| ២០០២ | ១៣៩.២ | ១,០៦១ | ៥៣០ | ១,១៨០ |
| ២០០៣ | ១៣៧.៣ | ១,០៩៣ | ៥៤៦ | ១,២៩០ |
| ២០០៤ | ១៣៥.៤ | ១,១២៦ | ៥៦៣ | ១,៤៤០ |
| ២០០៥ | ១៣៣.៥ | ១,២១៤ | ៦០៧ | ១,៦៤០ |
| ២០០៦ | ១៣១.៦ | ១,១២១ | ៥៦១ | ១,៨៥០ |
| ២០០៧ | ១២៩.៧ | ១,៤៥១ | ៧២៦ | ២,០៨០ |
| ២០០៨ | ១២៧.៩ | ១,១២៣ | ៥៦២ | ២,២២០ |
| ២០០៩ | ១២៦.១ | ៩០៧ | ៤៥៤ | ២,២០០ |
| ២០១០ | ១២៤.៤ | ១,០០៨ | ៥០៤ | ២,៣២០ |
| ២០១១ | ១២៣.០ | ១,០២៧ | ៥១៤ | ២,៤៩០ |
| ២០១២ | ១២១.៦ | ១,០៤៧ | ៥២៣ | ២,៧២០ |
| ២០១៣ | ១២០.៣ | ១,០៦៧ | ៥៣៣ | ២,៩២០ |
| ២០១៤ | ១១៩.០ | ១,៧១៨ | ៨៥៩ | ៣,០២០ |
| ២០១៥ | ១១៧.៧ | ១,៤៨៨ | ៦៧២ | ៣,១៩០ |
| ២០១៦ | ១១៦.៤ | ១,៥២៩ | ៦២៣ | ៣,៤៥០ |
| ២០១៧ | ១១៥.១ | ១,៥៩៥ | ៦១១ | ៣,៦៨០ |
| ២០១៨ | ១១៣.៨ | ១,៦៥៩ | ៦៦៧ | ៣,៩៧០ |
| ២០១៩ | ១១២.៦ | ១,៧៤៥ | ៦៨៤ | ៤,៣២០ |

អនុគមន៍តម្រូវការដំណាំស្រូវ៖

**ទម្រង់គណិតវិទ្យា** (Mathematical Model)

$Q_{Rice}^{D} = f(P_{Rice}, P_{Maize}, GDP\ \ Per\ Capita)$

**ឬ ទម្រង់** Regression (Regression Model)

$Q_{Rice}^{D} = \beta_0 + \beta_1 P_{Rice} + \beta_2 P_{Maize} + \beta_3 GDP\ Per\ Capita + \varepsilon$

ដែល$Q_{Rice}^{D}$៖ បរិមាណតម្រូវការស្រូវ

$P_{Rice}$៖ តម្លៃស្រូវតាមកម្រិតអ្នកប្រើប្រាស់ (តម្លៃអ្នកប្រើប្រាស់)

$P_{Maize}$ ៖ តម្លៃពោត (កម្រិតអ្នកប្រើប្រាស់)

$GDP$ ⇄⇄ $Per\ Capita$ ៖ ផលិតផលក្នុងស្រុកសរុបក្នុងមួយឯកត្តា

**ឬ ទម្រង់ OLS (Ordinary Least Squares Model)**

$$\hat{Q}^{D}_{Rice} = \hat{\beta}_0 + \hat{\beta}_1 P_{Rice} + \hat{\beta}_2 P_{Maize} + \hat{\beta}_3 GDP\ Per\ Capita$$

(ប្រភព៖ William M. Tomex and Kenneth L. Robinson, 2003, ***Agricultural Product Prices***, 4th Edition, Cornell University Press, pp. 30 – 54.)

### គ. លទ្ធផលប៉ាន់ស្មាន

ការអនុវត្តគោលនយោបាយ គឺជាកិច្ចការទាមទារហើយសម្រាប់ហេតុផលនេះវាសមនឹងទទួលបានការយកចិត្តទុកដាក់យ៉ាងល្អិតល្អន់និងវិធីសាស្ត្រជាប្រព័ន្ធ។ សមត្ថភាពអនុវត្តជាញឹកញាប់គឺជាធនធានដ៏កម្រមួយនៅក្នុងវិស័យសាធារណៈ។ បើគ្មានការអនុវត្តជោគជ័យទេសូម្បីតែគោលនយោបាយដែលបានរចនាឡើងល្អបំផុតក៏គ្មានតម្លៃដែរ។

## ៣.៦. គោលនយោបាយស្រាវជ្រាវកសិកម្មជាតិ

### ៣.៦.១.យុទ្ធសាស្ត្រ និងគោលនយោបាយជាតិ និង គោលបំណងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងវិស័យកសិកម្ម

ការដោះស្រាយបញ្ហានៅក្នុងវិស័យកសិកម្ម គឺជាគន្លឹះដើម្បីកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា។ ប្រជាជនជាង ៨០% រស់នៅក្នុងតំបន់ជនបទ ហើយភាគច្រើន (៧០% ឬច្រើនជាង) នៃកំលាំងពលកម្មក្នុងប្រទេស ប្រកបរបរកសិកម្ម។ ទោះបីជាគេមានសមត្ថភាពដើម្បីផលិតស្បៀងអាហារដោយខ្លួនឯងក៏ដោយក៏ ៨៦% នៃចំនួន ប្រជាជននៅជនបទ ស្ថិតនៅក្រោមបន្ទាត់នៃភាពក្រីក្របើប្រៀបធៀបជាមួយ ១៥% នៅក្នុងរាជធានីភ្នំពេញ (OPCV, 2002; NPRS, 2002; MOP, 2003)។ រាជរដ្ឋាភិបាលយល់ឃើញថា ការរីកចំរើនក្នុងវិស័យកសិកម្ម គឺជាធាតុមួយដ៏សំខាន់ក្នុងការអភិវឌ្ឍប្រទេស។ ជាលទ្ធផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានខិតខំ រៀបចំគោលនយោបាយយុទ្ធសាស្ត្រ ដើម្បីជំរុញវិស័យកសិកម្មដោយផ្អែកលើយុទ្ធសាស្ត្រចតុកោណ (RGC. ២០០៤) គោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជា (MOP, 2003) ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមលើកទី២ (SEDPII, 2002) និង យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NPRS, 2002)។ ជាលទ្ធផល យុទ្ធសាស្ត្រនិង គោលនយោបាយអភិវឌ្ឍន៍កសិកម្មត្រូវបានបង្កើតឡើងដូចការសង្ខេបខាងក្រោម

(ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រ ក្នុងវិស័យកសិកម្មសំរាប់ ២០០៦-២០១០. ASDP, 2005) ដែលក្នុងនោះរាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញា :

១/ ផ្តល់ការវិនិយោគ ដោយរាជរដ្ឋាភិបាលក្នុងការជំរុញពិធីកម្ម និង ប្រពលវប្បកម្មនៃវិស័-យកសិកម្ម

២/ បង្កើនល្បឿននៃការបែងចែកដីធ្លី និង ការចេញនូវសិទ្ធិកាន់កាប់ដីនៅក្នុងគំរោងសម្បទានដីសង្គមកិច្ច

៣/ធ្វើអោយប្រសើរឡើង និងបង្កើនផ្ទៃដីប្រព័ន្ធស្រោចស្រព

៤/ធ្វើអោយប្រសើរឡើងដល់ការគ្រប់គ្រងធនធានទឹក តាមរយៈការបង្កើននិងពង្រឹកក្រុមអ្នកប្រើប្រាស់ទឹក

៥ ជំរុញការស្រាវជ្រាវ និងការផ្សព្វផ្សាយកសិកម្ម អភិវឌ្ឍន៍ទីផ្សារកសិកម្ម ចែកចាយនូវសំភារៈកសិកម្មដូចជា ពូជ ជី និងឥណទានជនបទ

៦/ ផ្តល់ជូនក្រុមប្រឹក្សាឃុំនូវការទទួលខុសត្រូវក្នុងការផ្ទេរចំណេះដឹងនិងចែករំលែកពត៌មានជាមួយកសិករ

៧/ការវិនិយោគផ្ទាល់ដោយវិស័យសាធារណៈនិងជំរុញវិស័យឯកជនអោយវិនិយោគទៅលើវិស័យកកសិកម្ម

៨/បន្តការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលចាំបាច់សំរាប់តំបន់តាមព្រំដែន និងដាច់ស្រយាល

៩/លើកទឹកចិត្តដល់ចលនា "ភូមិមួយ ផលិតផលមួយ ដើម្បីបង្កើនភាពជឿជាក់ និង គំនិតច្នៃប្រឌិតរបស់ប្រជាជនជនបទ។

គោលនយោបាយកសិកម្ម និង ការដែលកម្ពុជាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (Wr ជាការប្រាប់អោយដឹងនូវប្រភេទស្រាវជ្រាវដែលចាំបាច់ សំរាប់ឆ្លើយតបទៅនឹងការផ្លាស់ប្តូរបរិយាកាសទាំង៣... បញ្ហាចាំបាច់មួយចំនួនមានសង្ខេបនៅក្នុងការវិភាគ ភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមគំហែង (

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ កំពុងតែរៀបចំយុទ្ធសាស្ត្រដើម្បីជួយដល់រាជរដ្ឋាភិបាលកម្ពុជា សំរេចបាននូវផែនការអភិវឌ្ឍន៍ជាតិ។ យុទ្ធសាស្ត្រដែលបានលើកឡើងមានបង្ហាញជូនក្នុងសេចក្តីព្រាងនៃឯកសារ | ASDP (២០០៥) ដែលក្នុងនោះមានការដាក់ចេញនូវគោលបំណង ៨ចំនុចដូចខាងក្រោម :

១/បង្កើនសុវត្ថិភាពស្បៀង ផលិតភាព និង ពិពិធកម្ម

២/ធ្វើអោយប្រសើរឡើងដល់ទីផ្សារសំរាប់ផលិតផលកសិកម្ម

៣/បង្កើន និង ពង្រឹងក្របខ័ណ្ឌការងារអង្គភាព និង នីតិកម្ម

៤/ ធ្វើអោយប្រជាជនក្រីក្រនៅតាមជនបទមានមានលទ្ធភាពទទួលបាន និងប្រើប្រាស់ដីធ្លីតាមរយៈដំណើរការនៃកំណែទំរង់ដីធ្លីសំរាប់ដីកម្មសិទ្ធិ និង ការអភិវឌ្ឍទីផ្សារដីធ្លី

៥/បង្កើតលទ្ធភាពអោយប្រជាជនក្រីក្រ មានដីធ្លីតាមរយៈការធ្វើអោយប្រសើរឡើងដល់ស្ថេរភាពកម្មសិទ្ធិដីធ្លី និងទីផ្សារដីធ្លីដែលជាលទ្ធផលនៃការកាត់បន្ថយជំលោះដីធ្លី

៦/ធ្វើអោយប្រជាជនក្រីក្រនៅតាមជនបទអាចប្រកបរបរនេសាទប្រកបដោយចិរភាពតាមរយៈ ការលើក ទឹកចិត្តដល់កំណែទំរង់ជលផល

៧/ ជំរុញកំណែទំរង់ព្រៃឈើ ដើម្បីធានាដល់ការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព និង អោយប្រជាជនក្រីក្រនៅតាមជនបទអាចប្រើប្រាស់ផលិតផលព្រៃឈើបាន។ បង្កើនគំរបព្រៃអោយ បាន ៦០% នៅឆ្នាំ ២០១០ និង បង្កើនទំហំផ្ទៃដីការពារអោយបាន ១.៥លានហិកតា

៨/ធានាអោយមានការគ្រប់គ្រងសមស្របនូវព្រៃធម្មជាតិដែលត្រូវបានការពារ (រួមបញ្ចូលទាំងព្រៃកោងកាង) តាមរយៈការបង្កើននូវទិន្នន័យអំពីការប្រើប្រាស់ដី គំរបព្រៃ ហេដ្ឋារចនាសម្ព័ន្ធ និង តំបន់ការពារ។

គោលបំណងទាំង៨ចំណុចខាងលើ ត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងបញ្ហាវិស័យកសិកម្ម ដែល មាន៣៩ ចំណុច។ ផែនការសកម្មភាពចំនួន ៩៦ត្រូវបានស្នើឡើងដើម្បីដោះស្រាយបញ្ហាទាំងនោះ។ ក្នុងរយៈ ពេល៥ឆ្នាំខាងមុខ (២០០៦-២០១០) ជាឧទាហរណ៍ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានបំណងបង្កើន ផ្ទៃដីស្រោចស្រពអោយបាន ១០០,០០០ហិកតាបន្ថែមទៀត រៀបចំសហគមន៍អភិវឌ្ឍន៍កសិករនៅក្នុងបណ្តាខេត្ត ទាំង២៤ ធ្វើយ៉ាងណាអោយមានស្ត្រីចូលរួមក្នុងវគ្គសិក្សាអោយបាន ៣០% អនុវត្តកម្មវិធីគ្រប់គ្រងទឹកដោយមាន ការចូលរួមពីកសិករអោយបាន ២០% នៃផ្ទៃដីដែលមានប្រព័ន្ធស្រោចស្រព និង ជំរុញការដាំព្រៃឈើក៏ដូចជាការស្តារឡើងវិញនូវផ្ទៃដីព្រៃឈើដែលវិចវិល។ សំរាប់ប្រព័ន្ធស្រាវជ្រាវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ នឹងជំរុញ ការអភិវឌ្ឍនូវបច្ចេកវិទ្យាសំរាប់បង្កើនជីជាតិដីនៅក្នុងប្រទេស បង្កើនផលិតភាពដំណាំស្រូវក៏ដូចជាដំណាំដទៃទៀត តាមរយៈវិធានការកំចាត់កត្តាចង្រៃ ដីសមស្របសំរាប់ដំណាំ និង បច្ចេកទេសក្រោយការប្រមូលផល។ ក្រសួងនឹង ដោះស្រាយអោយបាននូវបញ្ហាមួយចំនួនដូចជា កង្វះទិន្នន័យអំពីកសិកម្ម ការកែច្នៃផលនេសាទនៅមាន ក៏រិតទាប កង្វះខាតច្បាប់កសិកម្មនិងច្បាប់ជលផល បច្ចេកទេសកែច្នៃផលនេសាទនៅទាប សមត្ថភាពស្រាវជ្រាវ និងកង្វះៈ ខាតពត៌មានអំពីការប្រើប្រាស់ផលិតផលព្រៃឈើ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទផ្តល់អាទិភាពខ្ពស់ ដល់ការបង្កើនសមត្ថភាពនៅតាមអង្គភាពក្នុងការដោះស្រាយបញ្ហាទាំងនេះ។ ការរៀបចំផែនការមេនេះក៏បានឆ្លុះៈ បងការប៉ង់ប្រាថ្នាទាំងនេះដែរ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប៉ាន់ស្មានថាថវិកាប្រមាណ ១១៧.២២៦,០៥០ ដុល្លាអាមេរិកនៃថវិកាសរុប ១២៧,៤៩៨.០៥០_សំរាប់ឆ្នាំ ២០០៦-២០១០ នឹងត្រូវប្រើ ប្រាស់ក្នុងការបង្កើនផលិតភាព និង ពិពិធកម្មនៃវិស័យកសិកម្ម។ ថវិកាដែលសល់ នឹងត្រូវប្រើសំរាប់កំណែទំរង់ដីធ្លី ការដោះមីន និង កំណែទំរង់ជលផល និង ព្រៃឈើ។

មួយភាគធំនៃបញ្ហាដែលមាននៅក្នុងផែនការយុទ្ធសាស្ត្ររបស់ក្រសួងកសិកម្ម ត្រូវបានឆ្លុះបញ្ចាំងក្នុងផ្នែក ទី២.២ អំពីទស្សនៈវិស័យ និង បេសកកម្មរបស់ក្រសួង។

គោលនយោបាយបច្ចុប្បន្នរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អំពីការស្រាវជ្រាវ និងផ្សព្វ ផ្សាយមានសរសេរក្នុងឯកសារ "គោលនយោបាយស្រាវជ្រាវនិងផ្សព្វផ្សាយកសិកម្មកម្ពុជា" ដែលបានរៀបចំឡើង តាំងពីឆ្នាំ ១៩៩៨។ ចំនុចសំខាន់ៗពីរនៃគោលនយោបាយគឺៈ

ក.ញែកការស្រាវជ្រាវនិងផ្សព្វផ្សាយ ចេញពីនាយកដ្ឋានជំនាញ និង ផ្តល់អោយសេវាកម្មទាំងនេះនូវថវិកាដោយឡែក។

ខ. រៀបចំយុទ្ធសាស្ត្ររយៈពេលវែង ដើម្បីអភិវឌ្ឍន៍ប្រព័ន្ធគោលនយោបាយស្រាវជ្រាវ និងផ្សព្វផ្សាយប្រកបដោយនិរន្តរភាព។

ការស្រាវជ្រាវមានមូលដ្ឋានដាច់ដោយឡែកពីនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដកសកម្មក្នុងអំឡុង ពេលនៃការរៀបចំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងឆ្នាំ ២០០០ បន្ទាប់ពីវិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍កសិកម្មកម្ពុជាត្រូវបានបង្កើតឡើង។ ដូចគ្នានេះដែរ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ត្រូវបានបំបែក ចេញពីអគ្គនាយកដ្ឋានចំការកៅស៊ូ។ ឱកាសដែលស្ថិតនៅចំពោះមុខ គឺការពិចារណាពីលទ្ធភាពនៃការបំបែកវិទក) ស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍ជលផលទឹកសាប ពីនាយកដ្ឋានជលផល មជ្ឈមណ្ឌលជាតិស្រាវជ្រាវសុខភាព និង ផលិតកម្មសត្វ ពីនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល និង វិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រព្រៃឈើ និង សត្វព្រៃពីរដ្ឋបាលព្រៃឈើ។ ពុំមានវិទ្យាស្ថានណាមួយក្នុងចំណោមវិទ្យាស្ថានទាំងនេះមានថវិកាដោយឡែកពីថវិកា របស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទឡើយ បើទោះជាវិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍កសិកម្មកម្ពុជា និង វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា មានខ្ទង់ថវិកាផ្ទាល់ខ្លួនក៏ដោយ។ ដំណើរការនៃវិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍ជលផលទឹកសាប មជ្ឈមណ្ឌលជាតិស្រាវជ្រាវសុខភាព និងផលិតកម្មសត្វ និង វិទ្យាស្ថានស្រាវជ្រាវ វិទ្យាសាស្ត្រព្រៃឈើ និង សត្វព្រៃ ស្ថិតនៅក្រោមខ្ទង់ថវិកានាយកដ្ឋានរបស់គេ។

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា និង វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា មានក្រុម ប្រឹក្សាភិបាល ដែលជាអ្នកកំណត់អាទិភាពស្រាវជ្រាវក្នុងកំរិតវិទ្យាស្ថាន និង ទទួលខុសត្រូវក្នុងការរៀបចំសំណើ សំរាប់អភិវឌ្ឍវិទ្យាស្ថាន។ ក្រុមប្រឹក្សាភិបាលនេះមានតំណាងមកពីស្ថានប័នពាក់ព័ន្ធច្រើន។ ទោះជាយ៉ាងនេះ ក៏ដោយក្នុងអំឡុងឆ្នាំ ១៩៩៩ និង ២០០០ ដែលជាពេលដែលចេញអនុក្រឹត្យស្តីពីក្រុមប្រឹក្សាភិបាលទាំងនោះពុំមានយន្តការក្នុងការបញ្ចូលតំណាងមកពីស្ថាប័នក្រៅរដ្ឋាភិបាលទៅក្នុងក្រុមប្រឹក្សាភិបាលឡើយ។ ដោយមូលហេតុនេះ សមាជិករបស់គណៈកម្មការនាយករបស់វិទ្យាស្ថានទាំងពីរសុទ្ធតែជាមន្ត្រីរបស់រដ្ឋាភិបាល ដែលជាហេតុធ្វើអោយ មានការលំបាកសំរាប់ក្រុមប្រឹក្សាភិបាលទាំងពីរក្នុងការបញ្ចូលទស្សនៈរបស់វិសយ័ឯកជន ក៏ដូចជាការទាក់ទាញ ថវិកាមានប្រភពពុំមែនរដ្ឋដើម្បីដំណើរការវិទ្យាស្ថានទាំងនោះ។

គោលនយោបាយផ្សព្វផ្សាយ និងស្រាវជ្រាវកសិកម្មកម្ពុជាបានស្នើឡើងថា ក្រុមប្រឹក្សាស្រាវជ្រាវដែល ផ្សំឡើងពីរដ្ឋាភិបាល វិស័យឯកជន . អង្គការក្រៅរដ្ឋាភិបាល និងវិស័យដទៃទៀតនៃសង្គមស៊ីវិលនឹងជួយលើក អាទិភាពសំរាប់ការស្រាវជ្រាវកសិកម្ម។ ក្នុងពេលបច្ចុប្បន្នអនុក្រឹត្យសំរាប់ការបង្កើតក្រុមប្រឹក្សាស្រាវជ្រាវ និង អភិវឌ្ឍកសិកម្ម (1) កំពុងស្ថិតនៅក្នុងទំរង់ជាសេចក្តីព្រាងដែលបានបញ្ជូនទៅដល់គណៈរដ្ឋមន្ត្រី ដើម្បីស្នើសុំការ អនុម័ត។

មានការរីកចំរើនយឺត ក្នុងការរៀបចំយុទ្ធសាស្ត្រយូរអង្វែងសំរាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនូវ ប្រពន្ធ័ស្រាវជ្រាវនិងផ្សព្វផ្សាយដែលមានស្រាប់។ ការអះអាងនេះផ្អែកលើ ក) ពុំអាចការកាត់

បន្ថយចំនួនបុគ្គលិក ស្រាវជ្រាវនិងផ្សព្វផ្សាយ ខ) ក្រៅពីវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា វិទ្យាស្ថានដទៃទៀតពុំទាន់មានយុទ្ធសាស្រ្តជាក់ស្តែងក្នុងការបង្កើនចំណូល ដើម្បីរំលោលើចំណាយខាងផ្នែកសេវាកម្ម ៧) ពុំទាន់មានការ បែងចែកការទទួលខុសត្រូវខាងផ្នែកបុគ្គលិក និង ហិរញ្ញវត្ថុក៏ដូចជាគណនីទៅអោយប្រធានក្រុមស្រាវជ្រាវ និង ផ្សព្វផ្សាយ។ ពុំទាន់មានលទ្ធភាពគិតគូរនូវល័ក្ខខ័ណ្ឌការងារសំរាប់រក្សាទុកនូវបុគ្គលិកដែលមានសមត្ថភាព និង បទពិសោធន៍។ ទោះជាយ៉ាងនេះក៏ដោយម្ចាស់ជំនួយបាននិងកំពុងឧបត្ថម្ភដល់ការអភិវឌ្ឍធនធានមនុស្សគួរអោយ កត់សំគាល់។ បុគ្គលិកមានសមត្ថភាពត្រូវបានផ្តល់តួនាទីស្រាវជ្រាវថ្នាក់ខ្ពស់តាមមជ្ឈមណ្ឌស្រាវជ្រាវនាយកដ្ឋាន និង សាកលវិទ្យាល័យ។ មន្រ្តីទាំងនេះនឹងមានតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំកម្មវិធីស្រាវជ្រាវសមស្របទៅ ពេលអនាគតបើសិនជាពួកគេទទួលបាននូវល័ក្ខខ័ណ្ឌការងារសមស្រប (ផ្នែក ២.៩)។

ស្ទើរតែទាំងអស់នៃអនុសាសន៍របស់គោលនយោបាយផ្សព្វផ្សាយ និង ស្រាវជ្រាវកសិកម្មកម្ពុជាសំរាប់ ប្រព័ន្ធផ្សព្វផ្សាយត្រូវបានដាក់អោយដំណើរការតាំងពីដើមឆ្នាំ ២០០៥។ កិច្ចការនេះរួមមានៈ ក) ការតាំង មូលដ្ឋាននិងការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយនៅក្នុងខេត្ត ខ) ការផ្តល់សេវាកម្មចំពោះក្រុមជាជាងកសិករម្នាក់ៗ និង គ)ការជំរុញអោយមានការចូលរួមពីវិស័យឯកជន។ ក្រុមហ៊ុនធំៗ ដូចជាក្រុមហ៊ុនស៊ីភីផលិតចំណីសត្វ ក្រុមហ៊ុន ថ្នាំជក់អង់គ្លេស - អាមេរិកកាំង កម្ពុជា និង ក្រុមហ៊ុនជីរ៉ូយ៉ាល់សុទ្ធតែមានកម្មវិធីផ្សព្វផ្សាយរបស់គេ។ កម្មវិធី សហគមន៍កសិកររបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងការិយាល័យទីផ្សារកសិកម្មរបស់នាយកដ្ឋានផែនការ ស្ថិតិដើរតួនាទីជាអ្នកសំរបសំរួលអោយមានអន្តរកម្ម រវាងកសិករ សេវាកម្មផ្សព្វផ្សាយ និង អ្នកស្រាវជ្រាវ និង ជាអ្នកផ្តល់អោយក្រុមទាំងនេះនូវពត៌មានពាក់ព័ន្ធនឹងតម្លៃ និង ពត៌មានទីផ្សារ។ ផ្នែកទាំងពីរនេះបច្ចុប្បន្នមាន ធនធានមិនគ្រប់គ្រាន់ឡើយ។

មិនបានបញ្ជាក់នៅក្នុងគោលនយោបាយផ្សព្វផ្សាយនិងស្រាវជ្រាវកសិកម្មកម្ពុជា គឺតួនាទីរបស់សាកលវិទ្យាលយ័ភូមិន្ទកសិកម្ម សាលាកសិកម្មជាតិព្រែកលាប និងសាលាកសិកម្មជាតិកំពង់ចាម ដែលអង្គភាពទាំង អស់នេះស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។ អង្គភាពទាំងអស់នេះៈ ធ្វើការស្រាវជ្រាវក្នុងអំឡុងនៃការអប់រំថ្នាក់បរិញ្ញាប័ត្រ និង ថ្នាក់ក្រោយឧត្តម។ ការស្រាវជ្រាវរបស់គេត្រូវបាន បន្ថែមតាមរយៈការសិក្សាវិទ្យាសាស្រ្តធ្វើឡើងនៅសាកលវិទ្យាល័យឥសីវេទ និង ដោយអង្គការក្រៅរដ្ឋាភិបាល ដូចជា CelAgrid និង CEDAC។ អង្គភាពទាំងអស់នេះមានសក្តានុពលជាអ្នកដើរតួនាទីយ៉ាងសំខាន់ក្នុងការ ស្រាវជ្រាវកសិកម្មទៅអនាគត។

## ៣.៦.២. ទស្សនវិស័យ និងបេសកកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ទស្សនវិសយ័យូរអង្វែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ គឺធានាអោយបាននូវៈ

- ការមានស្បៀងអាហារគ្រប់គ្រាន់ និង សុវត្ថិភាពស្បៀងសំរាប់ប្រជាជនទាំងអស់
- ការកាត់បន្ថយភាពក្រីក្រ និង ការបង្កើនផលិតផលក្នុងស្រុកសរុបសំរាប់ប្រជាជនម្នាក់ៗ
- អភិរក្ស និង ការពារធនធានធម្មជាតិ។

បេសកម្មរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺ "ជួយដល់កំនើនសេដ្ឋកិច្ច នៃកម្ពុជាដោយស្ថេរភាពនិងសុវត្ថិភាព បង្កើនផលិតផលកសិកម្ម និងបន្ថែមតំលៃមូលដ្ឋានដល់វិសយ័កសិកម្ម ជលផល និងពេល ដោយមាននិរន្តរភាព និងស្ថេរភាព "។

### ៣.៦.៣. សមាសភាគនៃប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិ

ប្រពន្ធ័ស្រាវជ្រាវកសិកម្មជាតិដើរតួនាទីយ៉ាងធំ ក្នុងការអភិវឌ្ឍបច្ចេកទេសសំរាប់បង្កើនផលិតភាពតាម អនុវិសយ័ និង ពិពិធកម្មក្នុងវិសយ័កសិកម្ម ដែលបានកំណត់នៅក្នុងគោលបំណងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។ វាក៏មានតួនាទីក្នុងការអភិវឌ្ឍនូវទំនាក់ទំនងដើម្បីធ្វើអោយប្រសើរឡើងដល់ទីផ្សារសំរាប់ផលិត ផលកសិកម្ម ផ្តល់ជំរើសក្នុងការធ្វើអោយប្រសើរឡើងដល់ធនធានជលផល និង នៅក្នុងការបង្កើតនូវវិធីសាស្រ្ត ក្នុងការធ្វើអោយប្រសើរឡើងដល់ការគ្រប់គ្រង និងអភិរក្សព្រៃឈើ និង តំបន់ការពារធម្មជាតិ។

ប្រពន្ធ័ស្រាវជ្រាវកសិកម្មជាតិបច្ចុប្បន្ន ដែលដឹកនាំដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងលើកឡើកពីការអភិវឌ្ឍកសិកម្មតាមរយៈការស្រាវជ្រាវតាមអនុវិសយ័។ ប្រពន្ធ័ស្រាវជ្រាវសំខាន់ៗនៅក្នុង ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទមាន:

(i) វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជាសំរាប់ការស្រាវជ្រាវដំណាំ (

(ii)វិទ្យាស្ថានស្រាវជ្រាវដំណាំកៅស៊ូកម្ពុជា សំរាប់ការស្រាវជ្រាវដំណាំកៅស៊ូ

(iii)/មជ្ឈមណ្ឌលជាតិស្រាវជ្រាវសុខភាព និងផលិតកម្មសត្វនៅក្រោមនាយកដ្ឋានផលិតកម្ម និងបសុព្យាបាលសំរាប់ការស្រាវជ្រាវអំពីសុខភាពនិងផលិតកម្ម។

(iv)/ វិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្រ្តព្រៃឈើ និង សត្វព្រៃ នៅក្រោមរដ្ឋបាលព្រៃឈើ សំរាប់ការស្រាវជ្រាវរុក្ខកម្ម។

(v) វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍ជលផលទឹកសាប នៅក្រោមនាយកដ្ឋានជលផល សំរាប់ការស្រាវជ្រាវជលផល។

(vi)/នាយកដ្ឋានកសិ-ឧស្សាហកម្ម សំរាប់ធ្វើអោយប្រសើរឡើងនៅក្នុងវិស័យឧស្សាហកម្ម។

វិទ្យាស្ថានទាំងនេះ នឹងបន្តដឹកនាំជំនាញផ្នែកលើកម្មវិធីស្រាវជ្រាវនៅក្នុងការសហការជាមួយសាកលវិទ្យា ល័យភូមិន្ទកសិកម្ម និង សាលាជាតិកសិកម្មពីរទៀត។ ជាបន្ថែម នាយកដ្ឋាននៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមមាន នាយកដ្ឋានក្សេត្រសាស្រ្តនិងកែលំអដីកសិកម្ម នាយកដ្ឋានគ្រឿងយន្តកសិកម្ម នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និង នាយកដ្ឋានផែនការនិងស្ថិតិ និង អង្គភាពដទៃទៀតនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក៏អាចធ្វើការ ស្រាវជ្រាវដែរ។

វិស័យមិនមែនសាធារណៈនៃការស្រាវជ្រាវកសិកម្ម ជារឿយៗ មានជំនួយពហុភាគី និង ឧបតោភាគី ដោយអង្គការមិនមែនរដ្ឋាភិបាល សាកលវិទ្យាល័យឯកជនឬពាក់កណ្តាលឯកជន និង សហគ្រាសឯកជន។ ការ ស្រាវជ្រាវដែលគាំទ្រដោយជំនួយ គឺជាទូទៅធ្វើឡើងក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គភាពរដ្ឋាភិបាលដែលជា រឿយៗឆ្លងកាត់ជំនាញឯកទេសជាច្រើន។ រួមបញ្ចូលនៅក្នុងផ្នែកនេះមាន FAO (Food & Agriculture Organization), សាលារៀន IPM (Integrated

Pest_Management) លើស្រែកសិករ និង IFAD (International Fund for Agricultural Development) ឬ ធនាគារពិភពលោក (WB) ដែលឧបត្ថម្ភថវិកា សំរាប់កម្មវិធីអភិវឌ្ឍន៍ជនបទ។ រដ្ឋាភិបាលអូស្ត្រាលី ឧបត្ថម្ភថវិកាសំរាប់គំរោងជំនួយវិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI-AP) និង គំរោងកម្មវិធីផ្សព្វផ្សាយកសិកម្មកម្ពុជា-អូស្ត្រាលី (CAAEP) និង គាំទ្រផងដែរនូវសកម្មភាពស្រាវជ្រាវតាមរយៈវិទ្យាស្ថានស្រាវជ្រាវ និង នាយកដ្ឋាននានារបស់រដ្ឋាភិបាល។

ការស្រាវជ្រាវគាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាល គឺធ្វើឡើងទាំងនៅក្នុងនិងក្រៅនៃប្រព័ន្ធរដ្ឋាភិបាល។ វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កម្ពុជាស្រាវជ្រាវវិភាគបញ្ហាការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។ មជ្ឈមណ្ឌលសំរាប់ ការចិញ្ចឹមសត្វ និង អភិវឌ្ឍន៍កសិកម្ម (CelAgrid) ធ្វើការស្រាវជ្រាវពាក់ព័ន្ធចំពោះការចិញ្ចឹមសត្វ ដំណាំយកស្លឹក និង ការប្រើប្រាស់ប្រភពធនធាន។ អង្គការទស្សនៈពិភពលោក (WVI) និង អង្គការ CARE ធ្វើការសិក្សាអំពី សង្គមដាច់ដោយឡែកពីគ្នាសំរាប់កម្មវិធីអភិវឌ្ឍន៍កសិកម្មរបស់គេ។ ក៏ដូចគ្នានេះដែរ មជ្ឈមណ្ឌលជាតិសំរាប់ការ សិក្សានិងអភិវឌ្ឍន៍កសិកម្ម (CEDAC) និង អង្គការជំនួយអភិវឌ្ឍន៍អាត់វែនទីស្ទកម្ពុជា (ADRA) បានធ្វើការ ស្រាវជ្រាវក្សេត្រសាស្ត្រដែលជាផ្នែកមួយនៃកម្មវិធីរបស់គេ។

ការស្រាវជ្រាវដែលគាំទ្រដោយសហគ្រាសឯកជន ក៏ជាដៃគូសំរាប់អង្គភាពរដ្ឋាភិបាលផងដែរ។ ក្រុមហ៊ុន ផលិតចំណីសត្វ (CP Group Ltd) ធ្វើការជាមួយសាកលវិទ្យាល័យភូមិន្ទកសិកម្មលើផ្នែកសេនេទិចជ្រូក និងការ ស្រាវជ្រាវបសុបក្សីគឺជាឧទាហរណ៍មួយ។ ក្រុមហ៊ុនដទៃទៀត ឧបត្ថម្ភថវិកា និង អនុវត្តកម្មវិធីស្រាវជ្រាវដោយ ខ្លួនគេផ្ទាល់។ ក្រុមហ៊ុនថ្នាំជក់អង់គ្លេស-អាមេរិកាំងកម្ពុជា (BATC) គ្រប់គ្រងកម្មវិធីស្រាវ ជ្រាវថ្នាំជក់ដោយខ្លួនគេផ្ទាល់ និង ក្រុមហ៊ុនម៉ុងរិទ្ធីគ្រុប ពិនិត្យអត្ថប្រយោជន៍នៃកាកសំណល់ដូងប្រេង និង ដំឡូងមីធ្វើជាចំណីសត្វ។

ការបរិយាយយ៉ាងខ្លីនៃជំរើសសំរាប់វិទ្យាស្ថានទាំងឡាយរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍កសិកម្មកម្ពុជា មជ្ឈមណ្ឌលជាតិស្រាវជ្រាវសុខភាព និងផលិតកម្មសត្វ វិ ស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលទឹកសាប) នាយកដ្ឋានមួយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលចូលរួមនៅក្នុងការស្រាវជ្រាវ (នាយកដ្ឋានកសិ-ឧស្សាហកម្ម) សាកលវិទ្យាល័យមួយ (សាកលវិទ្យាលយ៍ ភូមិន្ទកសិកម្ម) និង សហគ្រាសឯកជនមួយ (BATC)។ សេចក្តីសង្ខេបនេះ៖ មានៈ អាណត្តិរបស់អង្គភាព ចំនួននិងគុណភាពមន្ត្រី/បុគ្គលិក ការភ្ជាប់ទំនាក់ទំនងជាមួយអង្គភាពដទៃទៀត ថវិកាគាំទ្រ និង កម្មវិធីនៃការស្រាវជ្រាវ។ ភាពខ្លាំង ភាពខ្សោយ ឱកាស និងភាពគំរាមកំហែងសំរាប់អង្គភាព ស្រាវជ្រាវមួយចំនួនដែលបានជ្រើសរើស។ ក្រសួងដទៃទៀតរបស់រដ្ឋាភិបាលដែលធ្វើការស្រាវជ្រាវ ហើយអាចមានឥទ្ធិពលលើការអភិវឌ្ឍបចេក វិទ្យាសំរាប់កសិកម្មរួមមាន ក្រសួងធនធានទឹក និង ឧតុនិយម ក្រសួងបរិស្ថាន និង ក្រសួងផែនការ។

## ៣.៦.៤. ទស្សនវិស័យ និង គោលបំណងនៃប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិ

**ទស្សនវិស័យ**: ប្រព័ន្ធនាំមុខក្នុងការបង្កើត និង ផ្ទេរនូវបច្ចេកវិទ្យាកសិកម្មសមស្រប ដោយសហការជាមួយដៃគូនិងអតិថិជនដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការកាត់បន្ថយភាពក្រីក្រ។

**បេសកកម្ម**: ចូលរួមក្នុងការបង្កើនសុខមាលភាពនៃប្រជាជនកម្ពុជា និង អភិរក្សមូលដ្ឋានធនធានធម្មជាតិតាមរយៈការប្រើប្រាស់ និង បង្កើនផលិតភាពដំណាំ បសុសត្វ ត្រី និង ព្រៃឈើ ដោយធ្វើ អោយប្រសើរឡើងនូវចំណេះដឹងវិទ្យាសាស្ត្រកសិកម្ម និង ការពង្រីក ការទទួលយក និងការផ្ទេរនូវបច្ចេកវិទ្យាកសិកម្ម វិធីសាស្ត្រ និង គោលនយោបាយ។

**គោលបំណង**:គោលបំណងនៃប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិកម្ពុជា នៅក្នុងដំណើរការទំនើបភាវូបនីយកម្ម និងក្នុងការប្រណាំងប្រជែងទៅថ្ងៃអនាគតក្នុងការអភិវឌ្ឍកសិកម្មគឺ:

"បង្កើនទាំងបរិមាណ និង គុណភាពនៃបច្ចេកវិទ្យា វិធីសាស្ត្រ និង ការណែនាំគោលនយោបាយ ដើម្បីធ្វើ អោយកសិកម្មកាន់តែមានប្រសិទ្ធភាព និង មានផលចំណេញក្នុងពេលដែលសន្តិសុខ សុវត្ថិភាពស្បៀង សមធម៌ និង និរន្តរភាពនៃធនធានធម្មជាតិត្រូវបានបង្កើនឡើង"។

**ផ្នែកនៃយុទ្ធសាស្ត្រប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិ** យុទ្ធសាស្ត្រ នៃប្រពន្ធ័ស្រាវជ្រាវកសិកម្មជាតិនៅកម្ពុជា មាន៥ ផ្នែកសំខាន់ៗ ដូចខាងក្រោម :

(i)ធ្វើអោយប្រសើរឡើងនូវសមត្ថភាព និងប្រសិទ្ធភាពនៃការអភិវឌ្ឍក៏ដូចជាការផ្ទេរនូវបច្ចេកវិទ្យា តាមរយៈការចូលរួមដ៏ធំធេងនៃផលិតករក្នុងគ្រប់ដំណាក់កាលទាំងអស់នៃការស្រាវជ្រាវ , និងដំណើរការផ្សព្វផ្សាយមានគោលដៅកាន់តែប្រសើរក្នុងការប្រើប្រាស់ធនធានស្រាវជ្រាវ និង មានទំនាក់ទំនងកាន់តែរឹងមាំជាមួយប្រភពនៃចំណេះដឹងទាំងអស់។

(ii)ពង្រីកមូលដ្ឋានថវិកា និង ការបង្កើនការចូលរួមនៃវិស័យឯកជនក្នុងការផ្តល់ថវិកា និង ការផ្តល់ការស្រាវជ្រាវកសិកម្ម និងសេវាកម្មពាក់ព័ន្ធ។

(iii)បញ្ចូលសមធម៌សង្គម យេនឌ័រ និង បញ្ហាបរិស្ថាន ទៅក្នុងគ្រប់ចំណុចនៃការអភិវឌ្ឍ និងការផ្ទេរបច្ចេកវិទ្យា។

(iv)បង្កើន និងរក្សាទុកនូវមូលដ្ឋានចំណេះដឹង តាមរយៈការស្រាវជ្រាវ អនុវត្ត និង ការស្រាវជ្រាវបន្សាំ ក៏ដូចជាអន្តរកម្មជាមួយវិទ្យាស្ថានអន្តរជាតិ សំរាប់ពត៌មានអំពីការស្រាវជ្រាវមូលដ្ឋាន និង ការស្រាវជ្រាវយុទ្ធសាស្ត្រ។

(v) ពង្រឹងសមត្ថភាពប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិ ដើម្បីអនុវត្តយុទ្ធសាស្ត្រទាំងនេះក្នុងលក្ខណៈចិរភាព ជាពិសេសទាក់ទងនឹងសមត្ថភាពរបស់ប្រព័ន្ធក្នុងការទាក់ទាញការអភិវឌ្ឍ និងរក្សាទុកនូវមន្ត្រីមានគុណភាព ក៏ដូចជាការអភិវឌ្ឍធនធាន និង វិមជ្ឈការនៃសកម្មភាពក្នុងសេវាកម្មអភិវឌ្ឍន៍កសិកម្មទូទាំងប្រទេសកម្ពុជា។

### ៣.៦.៥. បញ្ហាប្រឈមមុខរបស់ប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិក្នុងពេល ១០ ឆ្នាំខាងមុខ

ប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិកម្ពុជា ប្រឈមមុខនឹងការប្រកួតប្រជែងជាច្រើនក្នុងរយៈពេល ១០ឆ្នាំខាង មុខនៃផែនការមេ។ កិច្ចការនេះរួមមានៈ ការបង្កើតនូវបច្ចេកវិទ្យាថ្មី ដើម្បីឆ្លើយតបទៅនឹងការកើនខ្លាំងនៃការ ប្រណាំងប្រជែងដែលជាលទ្ធផលបណ្តាលមកពីការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក វិធីសាស្ត្រថ្មីនៃ ការស្រាវជ្រាវ ដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃការវិនិយោគរបស់ឯកជនក្នុងវិស័យកសិកម្ម ការចូលរួម របស់កសិករទៅក្នុងសកម្មភាពគ្រប់គ្រងសហគមន៍ និង ការកើនឡើងនៃការធ្វើពិពិធកម្ម និង ប្រពលវប្បកម្មដែល ទាមទារអោយមានប្រព័ន្ធស្រាវជ្រាវមួយដ៏ធំ។

ការចូលទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក នឹងបើកអោយកម្ពុជាបង្កើនការប្រណាំងប្រជែងទាំងតម្លៃ និងគុណភាព។ ផលិតផលកសិកម្មក្នុងស្រុកត្រូវតែមានស្តង់ដារអន្តរជាតិ សំរាប់ការប្រើប្រាស់ក្នុងស្រុក និង សំរាប់ ការនាំចេញ។ វានឹងជាយុទ្ធសាស្ត្រដ៏សំខាន់ផងដែរសំរាប់អ្នកស្រាវជ្រាវ ដើម្បីពង្រឹងស្មារតីលើការធ្វើអោយប្រសើរ ឡើងនូវផលិតភាពនៃផលិតផលកសិកម្ម ដែលនៅក្នុងនោះកម្ពុជាទទួលបាននូវផលប្រយោជន៍ជាច្រើនបើប្រៀប ធៀបជាមួយប្រទេសជិតខាងរបស់ខ្លួននៅពេលដែលសន្តិសុខស្បៀងត្រូវបានធានាចំពោះប្រជាជនក្រីក្រ។ ការជំរុញ ដោយរាជរដ្ឋាភិបាលលើចលនា " ភូមិមួយ ផលិតផលមួយ " នឹងនាំទៅដល់ការកំណត់តំបន់ក្សេត្របរិស្ថានសំរាប់ផលិតកម្ម ដែលធ្វើអោយតំរូវការស្រាវជ្រាវកាន់តែមានភាពជាក់លាក់។

អនុវិស័យកសិកម្មដែលមានសក្តានុពលទាក់ទាញការវិនិយោគពីវិស័យឯកជន សំរាប់ការនាំចេញមានស្រូវ ត្រីទឹកសាប កៅស៊ូ ការចិញ្ចឹមសត្វ និង ដំណាំឈើហូបផ្លែដែលមាន ស្វាយ និង ស្វាយចន្ទីជាដើម និងផលិតផល ដទៃទៀតដូចជា សូត្រ ស្ករត្នោត និងផលិតផលធ្វើពីឬស្សី (MOC, 2002, 2005)។

តំបន់ដែលជាដើមកំណើតពូជស្រូវក្រអូប "ផ្កាម្លិះ៖ មានទីតាំងនៅទិសពាយព្យនៃប្រទេសកម្ពុជានិងនៅ ទិសឥសាននៃប្រទេសថៃ។ ល័ក្ខខណ្ឌស្រែអាស្រយ័ទឹកភ្លៀងនៅតំបន់នេះអំណោយផលដល់ផលិតកម្មស្រូវក្រអូប មានគុណភាពខ្ពស់ ដែលជាតំរូវការទីមួយក្នុងទីផ្សារអន្តរជាតិ។ ដើម្បីបង្កើនផលិតកម្ម ទាមទារអោយមានការ វិនិយោគលើការបង្កាត់ និងផលិតកម្មគ្រាប់ពូជ ដើម្បីធានាអោយកសិករមានគ្រប់គ្រាន់នូវគ្រាប់ពូជដែលមាន គុណភាពខ្ពស់។ បង្កើនផលិតកម្មដោយពុំប៉ះពាល់ដល់គុណភាពអង្ករ ក៏ជាកិច្ចការស្រាវជ្រាវសំខាន់មួយដែរ។ នេះអាចជាករណីសំរាប់ប្រទេសកម្ពុជាក្នុងការផលិតស្រូវដើម្បីផ្គត់ផ្គង់ដល់ទីផ្សារផលិតផលសរីរាង្គ" ជាទីផ្សារ មួយដែលកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្តល់បើគិតទៅលើកំរិតនៃធាតុគីមីដ៏តិចតួចដែលប្រើក្នុងពេល បច្ចុប្បន្នទៅលើវាលស្រែវស្សាធំធេងនៅប្រទេសយើង។ នាពេលបច្ចុប្បន្ន ផលិតកម្មស្រូវដែលមានគុណភាពខ្ពស់ គ្មានភាពប្រមូលផ្តុំ ហេតុនេះអ្នកផ្គត់ផ្គង់ (សហគមន៍កសិករ និង ម្ចាស់រោងម៉ាស៊ីនកិនស្រូវ) គួរតែប្រមូលផ្តុំដើម្បីធានាអោយរោងកិនស្រូវមានប្រភេទអង្ករដែលមានគុណភាពខ្ពស់ជាប្រចាំក្នុងបរិមាណធំមួយ។

ការវិនយោគដោយវិសយ័ឯកជនជាការចាំបាច់ ក្នុងការបង្កើនគុណភាពអង្ករអោយក្លាយជាគុណភាពសំរាប់នាំចេញ។

បឹងទន្លេសាប ជាបឹងទឹកសាបមួយដែលធំជាងគេបំផុតនៅអាស៊ីអាគ្នេយ៍ និង មានផ្ទៃក្រឡាស្មើនឹង ១០$ នៃផ្ទៃប្រទេសនារដូវវស្សា។ ក្នុងរយៈពេលទឹកលិច មានតែផ្ទៃដី ១៥-២០% នៃផ្ទៃប្រទេសប៉ុណ្ណោះដែលលិចទឹក។ យើងមានសក្តានុពលធំណាស់ក្នុងការផលិតត្រីទឹកសាបក្នុងបរិស្ថាននេះៈ ដើម្បីបង្កើនទីផ្សារពិភពលោក។ បច្ចេក វិទ្យាត្រូវតែសំរិតសំរាំងសំរាប់ផលិតកម្មក្នុងបែរ និងក្នុងស្រះ ហើយបច្ចេកវិទ្យាគ្រប់គ្រងបែរ និង ធនធានធម្មជាតិ នឹងផ្សព្វផ្សាយដល់កសិករ។ ការវិនិយោគរបស់ឯកជនក្នុងការកែច្នៃ មានភាពចាំបាច់សំរាប់ធ្វើអោយផលិតផល មានស្តង់ដារអង្គការពាណិជ្ជកម្មពិភពលោក។

ឧស្សាហកម្មកៅស៊ូនៅកម្ពុជាអំណោយផលជាងប្រទេសជិតខាងដោយសារឧស្សាហកម្មនេះមានដដែលមានដីជាតិ និងមានកំពស់ទឹកភ្លៀងសមស្រប។ ជាលទ្ធផលកៅស៊ូផ្តល់ទិន្នផល និងគុណភាពខ្ពស់។ ទោះជា យ៉ាងនេះក៏ដោយ ការបញ្ជាក់គុណភាពនៅលើទីផ្សារអន្តរជាតិមានភាពយឺតយ៉ាវ។ ជាលទ្ធផលតំលៃទំនិញ បានបញ្ចុនពី ១០-១៥%។ ការបញ្ជាក់គុណភាពមានការរីកចំរើនយឺត ក្នុងពេលដែលចំការកៅស៊ូរដ្ឋចាប់ផ្តើមធ្វើ អវិនិយោគក្នុងឆ្នាំ ២០០៦ ដើម្បីតំរង់ទិសឧស្សាហកម្មនេះទៅរកការរីកលូតលាស់នៃសេដ្ឋកិច្ចដ៏មានប្រសិទ្ធភាព។ តំរូវការនៃការស្រាវជ្រាវនាពេលអនាគត គឺការផលិតកៅស៊ូកូន និង ការអភិវឌ្ឍប្រព័ន្ធដាំដុះដែលផ្តល់ផលចំណេញច្រើនដល់ចំការកៅស៊ូដែលគេកំពុងតែដាំជំនួសនូវដើមកៅស៊ូចាស់ៗ។

ការដែលប្រទេសកម្ពុជាមានដង់ស៊ីតេប្រជាជនទាប ជាពិសេសតំបន់ខ្ពង់រាបផ្តល់សក្តានុពលក្នុងការបង្កើន ចំនួនសត្វចិញ្ចឹមដើម្បីបំពេញតំរូវការសត្វរស់នៅទីផ្សារក្នុងតំបន់។ ការចិញ្ចឹមសត្វក្នុងកសិដ្ឋាន ឬ ដីឡូត៍នៅ កម្ពុជាពុំមានការអភិវឌ្ឍឡើយ ដូចនេះយើងមានសក្តានុពលខ្ពស់ក្នុងការជំរុញឧស្សាហកម្មនេះអោយលូតលាស់ទៅ អនាគត។ ការប្រណាំងប្រជែងមួយទៀតគឺការផ្តល់នូវចំណីសត្វដែលមានតំលៃថោក និង មានគុណភាពខ្ពស់។

ការបែងចែកដីទៅអោយវិសយ័ឯកជន តាមគំរោងដីសម្បទាន នឹងបង្កើនសំពាធទៅលើអ្នកស្រាវជ្រាវ អោយបង្កើតនូវបច្ចេកវិទ្យាថ្មីសំរាប់ប្រើលើផ្ទៃដីទាំងនោះក្នុងការបង្កើនផលិតកម្ម និង កាត់បន្ថយការរេចរិលនៃធន! ធន។ ការបង្កើតនូវបច្ចេកទេសក្នុងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព នឹងក្លាយជារបៀបវារៈ ក្នុងការស្រាវជ្រាវកាន់តែសំខាន់ឡើង១។ ផ្ទៃដីធំនឹងប្រែក្លាយជាចំការដំណាំឈើហូបផ្លែ និង យកគ្រាប់ ជាពិសេស ដំណាំស្វាយ ក្រូច ស្វាយចន្ទី និងដំណាំដទៃទៀតដែលមានការលូតលាស់ល្អនៅកម្ពុជា ហើយមានគុណភាពខ្ពស់ សំរាប់ទីផ្សារក្នុងស្រុក។ ដំណាំមននឹងត្រូវបានដាំដុះដើម្បីជាវត្ថុធាតុដើមដល់ផលិតកម្មសូត្រនៅកម្ពុជា។ ការ ប្រណាំងប្រជែងចំពោះមុខគឺធ្វើយ៉ាងណាអោយផលិផលនេះអាចមានតំលៃថោកល្មម តែមានស្តង់ដារសំរាប់ទីផ្សារអន្តរជាតិ។ ការដាំដុះដំណាំចំការទាមទារការស្រាវជ្រាវ ដែលមានការចូលរួមពីជំនាញច្រើន ដូច្នេះទាមទារអោយ មានសហប្រតិបត្តិការរវាងនាយកដ្ឋានខុសៗគ្នា ឬ រវាងវិទ្យាស្ថានស្រាវជ្រាវខុសៗគ្នា។

ដីនិងអាកាសធាតុនៅកម្ពុជា មានអំណោយផលដល់ការដុះលូតលាស់នៃដើមត្នោត។ ដើមត្នោតត្រូវបាន គេទទួលស្គាល់ថាជារុក្ខជាតិពិសេសសំរាប់សំគាល់ប្រទេសកម្ពុជា និង មាននៅគ្រប់ទិសទីនៅក្នុងប្រទេស។ កម្ពុជា អាចទាញយកផលប្រយោជន៍ពីដើមត្នោតក្នុងការផលិតនូវផលិតផលដែល "ពិសេសសំរាប់កម្ពុជា" សំរាប់ទាក់ទាញ ទេសចរណ៍ និង ការនាំចេញ។ ផលិតផលទាំងនោះអាចជាម្ហូក កង ឬ ស្ងួត ដែលធ្វើពីស្លឹក និង ស្ករត្នោត ឬ ទឹកត្នោតជូរ ពីទឹកជមរបស់ផ្កាត្នោត។ វាជាការប្រណាំងប្រជែងមួយសំរាប់កសិ-សិប្បករក្នុងការប្រើប្រាស់អោយ មានប្រសិទ្ធភាពនូវផលិតផលធ្វើពីរុក្ខជាតិត្នោត។

កម្ពុជាមិនមានភាពច្បាស់លាស់ក្នុងលក្ខណៈជាប្រទេសឧស្សាហកម្ម កសិ-កែច្នៃ ឬ កសិ-ពាណិជកម្មដ៏រឹង មាំឡើយ។ យុទ្ធសាស្ត្ររាជរដ្ឋាភិបាលក្នុងការបង្កើនការវិនិយោគរបស់វិស័យឯកជនក្នុងការស្រាវជ្រាវកសិកម្ម នឹងពង្រឹងការចូលរួមរបស់វិស័យមិនសាធារណៈក្នុងឧស្សាហកម្មនេះ៖។ តំរូវការស្រាវជ្រាវរបស់វិស័យឯកជនដែល ខុសពីតំរូវការរបស់សហគមន៍ដាំដុះតាមរបៀបប្រពៃណីគួរតែលើកឡើង។ ទន្ទឹមនឹងនេះ៖ ការរួមវិភាគទានដ៏តិច តួចរបស់ក្រុមហ៊ុនថ្នាំជក់ អ្នកកាន់កាប់សិប្បកម្មចំណីអាហារ ម្ចាស់កសិដ្ឋាន និង មជ្ឈមណ្ឌលចិញ្ចឹមសត្វនាពេល បច្ចុប្បន្ននឹងកើនឡើងដើម្បីឆ្លុះបញ្ចាំងពីការចាប់អារម្មណ៍របស់គេក្នុងផលិតកម្មកសិកម្ម និង ការកែច្នៃផលិតផល កសិកម្ម។

ការផ្តល់ថវិការដល់ប្រព័ន្ធស្រាវជ្រាវសាធារណៈគឺជាការប្តេជ្ញាចិត្តមួយសំរាប់ប្រទេសទាំងអស់ ហើយ ការផ្តល់ថវិកាដល់ប្រព័ន្ធស្រាវជ្រាវសាធារណៈ ប្រទេសកម្ពុជាក៏មិនខុសពីបណ្តាប្រទេសទាំងនោះដែរ។ ថវិការាជរដ្ឋាភិបាលដែលមានកំរិតនិងបង្កើនគណនេយ ភាពនៃអង្គភាពស្រាវជ្រាវសាធារណៈអោយមានប្រសិទ្ធិភាព និងមានការទទួលខុសត្រូវក្នុងការប្រើប្រាស់ថវិកា សាធារណៈ។ រាជរដ្ឋាភិបាលសង្ឃឹមថា អង្គភាពសាវជ្រាវនឹងសំរេចបាននូវការបង្កើនផលិតភាព និងគុណភាពនៃ ការស្រាវជ្រាវកសិកម្ម។ វានឹងក្លាយទៅជាការបង្កើនសារៈសំខាន់សំរាប់អង្គភាពស្រាវជ្រាវ ដែលមិនត្រឹមតែការងារស្រាវជ្រាវ និង សរសេររបាយការណ៍តែប៉ុណ្ណោះទេ ប៉ុន្តែក៏ជានាផងដែរនូវលទ្ធផលដែលត្រូវបានប្រើប្រាស់។ ដោយកសិករ និង អ្នកចូលរួមដទៃទៀត។ អ្នកប្រើប្រាស់ចុងក្រោយត្រូវតែចូលរួមនៅក្នុងការកំណត់បញ្ហា និង រៀបចំអាទិភាពស្រាវជ្រាវ ដើម្បីជានាថាកម្មវិធីស្រាវជ្រាវស្ថិតនៅក្នុងការតំរង់ទិសរបស់អតិថិជន។ ដំណើរការ ក្រុមការងារចំរុនជំនាញក្នុងការរៀបចំអាទិភាពក្នុងអំឡុងនៃការរៀបចំផែនការមេនេះនឹងត្រូវបានបន្តអនុវត្ត ដើម្បី រៀបចំផែនការមេសំរាប់ការស្រាវជ្រាវទៅអនាគត។

ដោយសារប្រទេសកម្ពុជាមានចំនួនប្រជាជនតិច និងទើបឈានចូលដំណាក់កាលដំបូងនៃការអភិវឌ្ឍ សេដ្ឋកិច្ច សមត្ថភាពដើម្បីធ្វើការស្រាវជ្រាវទំនើបនៅមានកំរិត។ យ៉ាងហោចណាស់សំរាប់ទសវត្សខាងមុខកម្ពុជា នឹងអាស្រ័យលើប្រភពសំខាន់ៗពីខាងក្រៅសំរាប់ការអភិវឌ្ឍបច្ចេកទេស។ - ចំណេះដឹងទាំងនេះត្រូវបានអភិវឌ្ឍ ឡើងដោយប្រើប្រាស់បច្ចេកទេសទំនើបៗ ដូចជាបច្ចេកវិជ្ជាជីវកសិកម្ម ដែលបានយកមកប្រើប្រាស់នៅមជ្ឈមណ្ឌល ស្រាវជ្រាវ អន្តរជាតិ សាកលវិទ្យាល័យដែលមានការផ្គត់ផ្គង់ថវិកាបានល្អ និង វិទ្យាស្ថានស្រាវជ្រាវនានានៅក្នុង ពិភពលោក។ បច្ចេកទេសខ្លួនអាចជាគោលដៅដើម្បីដោះស្រាយបញ្ហាដោយឡែកចំពោះនកម្ពុជា ប្រសិនបើអង្គភាព ស្រាវជ្រាវក្នុងស្រុក រក្សាបាននូវ

ទំនាក់ទំនងល្អជាមួយវិទ្យាស្ថានស្រាវជ្រាវខាងក្រៅ និង ចូលរួមជាមួយអង្គការក្នុង តំបន់ដែលធ្វើការលើបញ្ហាដូចគ្នា។

ការស្រាវជ្រាវបន្សាំ (adaptive research) និងការស្រាវជ្រាវអនុវត្ត (applied research) មានវិសាល ភាពយ៉ាងធំ ដើម្បីសំរេចអោយបាននូវការធ្វើអោយប្រសើរឡើងនៃផលិតភាពនៅក្នុងប្រទេសកម្ពុជា។ ថវិកា រដ្ឋាភិបាលត្រូវបានគេរំពឹង ដើម្បីគាំទ្រសកម្មភាពទាំងនេះស្ទើរតែទាំងអស់។ ការសហការជាមួយអ្នកផ្តល់ជំនួយ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និង វិស័យឯកជន នឹងឧបត្ថម្ភបន្ថែមចំពោះកម្មវិធីទាំងនោះ។ ផ្តល់ថវិកាស្ទើរតែទាំងអស់សំរាប់ការស្រាវជ្រាវអនុវត្តន៍។ ស្ថាប័នស្រាវជ្រាវរដ្ឋាភិបាលគួរតែធានាថា របស់គេបំពេញបាននូវតំរូវការសំរាប់ការស្រាវជ្រាវទាំងពិសោធន៍បធំ១ និង ការរៀបចំកម្មវិធីនៃការអនុវះ ការងារស្រាវជ្រាវ។ តំរូវការថវិកា កិរិតសមត្ថភាពនៃមន្ត្រីរាជការ សម្ភារៈ ឧបករណ៍ ទំនាក់ទំនង និង ក និងបច្ចេកវិទ្យាដែលចាំបាច់សំរាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រពន្ធស្រាវ។ ក្នុងការសំរេចបាននូវទស្សនវិស័យ និង គោលបំណងនាពេល ១០ឆ្នាំក្នុងខាងមុខ ត្រូវបានលើកយកមកពិភាក្សានៅក្នុងជំពូកជាបន្តបន្ទាប់។

## ៣.៦.៦.អនុវិស័យកសិកម្ម និង កម្មវិធីរបស់ប្រពន្ធ័ស្រាវជ្រាវកសិកម្មជាតិ

### ក. អនុវិស័យដំណាំ

ផលិតកម្មដំណាំស្រូវបានលប់លើវិស័យដំណាំ បើគិតលើផ្ទៃដីដាំដុះ សន្តិសុខស្បៀង និងការបង្កើត ការងារ។ ការដាំស្រូវបានគ្របដណ្តប់លើ ៨៥% នៃផ្ទៃដី ២.៧ លានហិកតាដែលជាផ្ទៃដីកសិកម្មនៅក្នុងប្រទេស កម្ពុជា។ តិចជាង ១៣% នៃផ្ទៃដីទាំងនេះមានប្រព័ន្ធស្រោចស្រព ចំណែកឯទិន្នផលស្រូវ ២.១ តោន/ហិកតា គឺ ទាបជាងបណ្តាប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ទោះបីជាទិន្នផលទាបយ៉ាងនេះក៏ដោយកម្ពុជាគឺជាប្រទេស មួយដែលមានស្រូវហូបគ្រប់គ្រាន់ក្នុងកំរិតជាតិតាំងពីឆ្នាំ១៩៩៥។ ការធ្វើអោយប្រសើរឡើងនូវផលិតភាពគឺជា! លទ្ធផលដែលបានមកពីការយកចិត្តទុកដាក់នៃការស្រាវជ្រាវរយៈពេល៧ឆ្នាំ ដើម្បីធ្វើអោយប្រសើរឡើងនូវពូជ និង ការអនុវត្តកសិកម្មនៅក្នុងប្រទេសកម្ពុជា (CIAP, 2001)។ អតិរេកមានទំនាក់ទំនងទៅនឹងកំពស់ទឹកភ្លៀង និង ភាពរាំងស្ងួត។ ទឹកជំនន់ និង ភាពរាំងស្ងួត កាត់បន្ថយអតិរេកស្រូវសំរាប់ការផ្គត់ផ្គង់ក្នុងស្រុក។ អតិរេកស្រូវ ដែលបានប៉ាន់ស្មានក្នុងឆ្នាំ ២០០០ មានប្រហែល ៤០.០០០ តោន។ បរិមាណអតិរេក ស្រូវក្នុងឆ្នាំ ២០០៤ និង ២០០៥ មានប្រមាណជា ៦៥០.០០០ តោន។ អតិរេកស្រូវត្រូវបានលក់ទៅប្រទេសជិតខាងដោយមិនបានឆ្លងកាត់ ប្រព័ន្ធផ្តល់សិទ្ធសំរាប់ការនាំចេញ។

ពុំទាន់មានការយកចិត្តទុកដាក់នៅឡើយទៅលើការស្រាវជ្រាវដំណាំស្បៀងប្រចាំឆ្នាំ ដែលគ្របដណ្តប់ ប្រហែល ៨% នៃផ្ទៃដីកសិកម្មសរុប។ ផ្ទៃដីប៉ាន់ប្រមាណសំរាប់ការដាំដុះនៃដំណាំស្បៀងប្រចាំឆ្នាំមាន ពោត ៩៣.០០០ ហិកតា ដំឡូងឈើ ២៦.០០០ ហិកតា ដំឡូងជ្វា ៩.០០០ ហិកតា បន្លែ ៣៦. ០០០ ហិកតា និង សណ្តែកបាយៈ ៤៥. ០០០ហិកតា ( ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ, ២០០៤)។ ទិន្នផលពោតជាមធ្យម គឺ ៣,៣ តោន/ហិកតា ហើយស្ទើរតែទាំងអស់នៃផលិតផលសរុបប្រមាណជា ៣០០.០០០ តោន ត្រូវបាន នាំចេញទៅប្រទេសថៃ និង វៀតណាម ដែលគេមានឧបករណ៍

កែច្នៃប្រកបដោយប្រសិទ្ធភាព។ ក្រុមហ៊ុនផលិត ចំណីសត្វ (CP Pty Ltd) ជួនកាលនាំពោតចូល ក្នុងពេលដែលការផ្គត់ផ្គង់ក្នុងស្រុកមិនគ្រប់គ្រាន់។ កម្ពុជាមាន សក្តានុពលក្នុងការបង្កើនការលក់ធញ្ញជាតិក្នុងបរិមាណច្រើន បើសិនជាគេអភិវឌ្ឍកសិកែច្នៃ។ ការផ្គត់ផ្គង់សណ្តែក បាយ និង សណ្តែកសៀងតែងតែខ្វះខាតដោយសារផលិតផលទាំងនេះត្រូវបានគេនាំចេញសំរាប់សំងួត។ ដំឡូងមី ប្រមាណ ៣៥០.០០០ តោន ត្រូវបាននាំចេញសំរាប់ជាអាហារ ហើយបរិមាណដែលសេសសល់នៅក្នុងស្រុកអាចប្រើជាល្បែងសំរាប់មនុស្ស និង សត្វ។ ការកែច្នៃដំឡូងមីអោយទៅជាម្សៅមានសក្តានុពលពាណិជ្ជកម្មគួរអោយ កត់សំគាល់ ហើយបើសិនជារោងចក្រទាំងនេះត្រូវបានបង្កើត កសិករនឹងត្រូវបានជំរុញអោយដាំដំណាំនេះ។ ដំឡូងជ្វា និង បន្លែត្រូវបានដាំដើម្បីផ្គត់ផ្គង់ក្នុងស្រុក។

ដំណាំឈើហូបផ្លែ គ្របដណ្តប់ប្រហែល ៣.៥% នៃផ្ទៃដីកសិកម្ម។ ផ្ទៃដីដាំដុះ ចំពោះដំណាំឈើហូបផ្លែក្នុង ឆ្នាំ ២០០៣/២០០៤ មាន ចេក ២៧.០០០ហិកតា ស្វាយចន្ទី ៣៧.០០០ ហិកតា ដូង ២៧.០០០ហិកតា និង ស្វាយ ១៤.០០០ហិកតា។ ផលិតផលទាំងអស់នៃដូងចេក និងស្វាយ ផលិតដើម្បីផ្គត់ផ្គង់ទីផ្សារក្នុងស្រុក ក្នុងពេលដែលស្វាយចន្ទីត្រូវបានផលិតដើម្បីលក់ក្នុងស្រុក និងនាំចេញ។ គ្រាប់ស្វាយចន្ទីផលិតក្នុងស្រុកមានគុណ ភាពទាបសំរាប់ទីផ្សារអន្តរជាតិ ដោយសារការប្រើប្រាស់ពូជអន់ និង ការកែច្នៃអន់ថយ។ យើងមានសក្តានុពល ក្នុងការបង្កើនផលិតកម្មឧស្សាហកម្មនេះតាមរយៈការស្រាវជ្រាវអនុវត្ត។ ឈើហូបផ្លែ និង ដំណាំដទៃទៀតដែល ដាំដុនសំរាប់ការប្រើប្រាស់ក្នុងស្រុកមាន មៀន ទឹកដោះគោ ឈុត ខ្នុរ ទៀប ក្រូច កាហ្វេ សារម៉ាវ ត្របែក ម្នាស់។ ដោយសារកំរៃពលកម្ម និងតម្លៃដីនៅក្នុងស្រុកទាប កម្ពុជាមានសក្តានុពលក្នុងការក្លាយជាប្រទេសផលិតករសំខាន់ នៃដំណាំស្បៀង និង ផ្លែឈើប្រចាំឆ្នាំ។ ដំណាំចំរុះនឹងមិនត្រឹមតែជួយបង្កើនចំណូលប៉ុណ្ណោះទេ ប៉ុន្តែអាចនាំអោយ ក្រុមកសិករដែលងាយរងគ្រោះនក្លាយជាចរន្តដ៏សំខាន់នៃការអភិវឌ្ឍកសិកម្ម។

ដំណាំឧស្សាហកម្ម (ថ្នាំជក់ ក្រចៅ សណ្តែកសៀង ល្ង សណ្តែកដី អំពៅ ជាដើម។ល។) គ្របដប់លើ ( ៣,៥% នៃផ្ទៃដីកសិកម្ម។ ការប៉ាន់ប្រមាណនូវផ្ទៃដីដាំដុនក្នុងឆ្នាំ ២០០៤ គឺមានដូចតទៅ… សណ្តែកសៀង ៥២.០០០ ហិកតា អំពៅ ៨.៥០០ ហិកតា ល្ង ៣២.០០០ហិកតា និង ថ្នាំជក់ ៦៤.០០ ហិកតា។ ដោយកម្ពុជាមាន ឱកាសក្នុងការពង្រីកផ្ទៃដីកសិកម្ម ផលិតកម្មនៃដំណាំទាំងនេះ ត្រូវបានគ្រោងថានឹងកើនឡើងក្នុងពេលអនាគត។ ទិន្នផលនៃដំណាំអាចមានភាពប្រសើរឡើងផងដែរជាមួយការស្រោចស្រព និងការទទួលយកនូវបច្ចេកវិទ្យាល្អៗ។ មានការនាំចេញសំរាប់ដំណាំ អំពៅល្ង និង សណ្តែកសៀង ទោះជាផលិតផលទាំងនេះនៅមានគុណភាពអន់ ក៏ដោយ ការធ្វើអោយប្រសើរឡើងដល់ឧស្សាហកម្មកែច្នៃ នឹងបង្កើនតំលៃសំរាប់នាំចេញនូវផលិតផលទាំងនេះក៏ ដូចជាជំរុញដល់ការដាំដុះ៖។

ការវិភាគភាពខ្លាំង ភាពខ្សោយ ឱកាស និង ការគំរាមកំហែង (SWOT) បានធ្វើទៅលើវិស័យកសិកម្ម ក្នុងអំឡុងឆ្នាំ ២០០៥ ដោយក្រុមការងារពិសេសមួយនៃអនុវិស័យដំណាំ និងដោយសមាជិកនៃក្រុមការងារ បង្កើតឡើងនៅតាមសិក្ខាសាលាថ្នាក់តំបន់ក្នុង ខេត្តកណ្តាល បាត់ដំបង កំពង់ចាម និង ក្រុងព្រះសីហនុ កណាពជា ភាពរឹងមាំខ្លាំងបំផុតនៃវិស័យដំណាំនៅកម្ពុជា ពាក់ព័ន្ធទៅនឹងផ្ទៃដីដំណាំ អាកាសធាតុ និង សក្តានុពលសំរាបភាព ចំរុះ (មើលតារាង ក១.១ ក្នុងឧបសម្ពន្ធ័ ១ សំរាប់

លំអិត)។ គោលនយោបាយដើម្បីគាំទ្រកសិកម្ម ត្រូវបាន វាយតម្លៃថាជាផ្នែកមួយនៃចំណុចខ្លាំង។ បញ្ហីរាយនាមនៃភាពខ្សោយគន្លឹះៗ ទទួលស្គាល់ដោយក្រុមការងារ ភាពវែងអន្លាយ ប៉ុន្តែភាគច្រើនគេអាចជៀសវាងបាន តាមរយៈការធ្វើអោយប្រសើរឡើងនូវទំនាក់ទំនងបន្ត រវាងការស្រាវជ្រាវជាមួយនិងការផ្សព្វផ្សាយ ទីផ្សារ និងផលិតករ។ ការស្រាវជ្រាវគួរផ្តោតទៅលើភាពអន់ថយនៃពូជក្នុងស្រុក ភាពមានកំរិតនៃបច្ចេកវិទ្យាដាំដុះ ភាពខ្វះខាតក្នុងការកំណត់តំបន់កសិកម្ម សត្វល្អិតនឹងជំងឺ បច្ចេក វិទ្យាទុកដាក់ក្រោយពេលប្រមូលផលមានកំរិតទាប និងដីខ្វះជីជាតិ។ កម្ពុជាមានឱកាសក្នុងការបង្កើនផលិតកម្ម ដំណាំតាមរយៈការពង្រីកផ្ទៃដីដាំដុះសរុប និងពង្រីកផ្ទៃដីស្រោចស្រព។ ភាពតំរាមកំហែងចំពោះការដាំដុះគឺ ពាក់ព័ន្ធនឹងការចុះបញ្ជីកម្មសិទ្ធិដីធ្លីមិនបានទូលំទូលាយ និង ច្បាប់នៃការផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិដីធ្លី ផ្លូវនៅជនបទ មិនគ្រប់គ្រាន់ និង រចនាសម្ពន្ធ័ដែលរារាំងចំពោះការរកទីផ្សារ និង ការបង្កើនតម្លៃ ផលិតកម្ម ការរក្សាទុកដាក់មិន ត្រូវតាមបទដ្ឋាន និង គ្រោះធម្មជាតិ។

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ដែលជា វិទ្យាស្ថានស្រាវជ្រាវនាំមុខនៅក្នុងវិស័យដំណាំ បានលើកឡើងនូវបញ្ហាក្នុងការធ្វើអោយប្រសើរឡើងដល់ផលិតកម្ម ដំណាំស្រូវ ពោត ប៉េងប៉ោះ ឪឡឹក សណ្តែកបាយ សណ្តែកសៀង ចេក ស្វាយ ដំឡូងមី និង សណ្តែកអង្រែ។ វិទ្យាស្ថានក៏បានសិក្សាផងដែរនូវលក្ខណៈក្សេត្រសាស្ត្រនៃដំណាំជាច្រើន ប្រព័ន្ធកសិកម្ម សេដ្ឋកិច្ចសង្គម ការការពារដំណាំ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រដី និង ទឹក។ ការស្រាវជ្រាវបន្សំ លើដំណាំក៏មានធ្វើផងដែរនៅអង្គភាព នាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្ម និង សាកលវិទ្យាលយ័ភូមិន្ទ កសិកម្ម ក្នុងពេលដែលក្រុមហ៊ុនថ្នាំជក់អង់គ្លេស-អាមេរិកកាំងកម្ពុជាសិក្សាទៅលើពូជ និង លក្ខណៈ ក្សេត្រសាស្ត្ររបស់ថ្នាំជក់។ ស្ថាប័នរដ្ឋ និង មិនមែនរដ្ឋ ដទៃទៀតដែលធ្វើការស្រាវជ្រាវលើ ដំណាំមាន សាលាជាតិកសិកម្មព្រែកលៀប សាលាជាតិកសិកម្មកំពង់ចាម និង មជ្ឈមណ្ឌលជាតិសំរាប់ការសិក្សា និងអភិវឌ្ឍន៍កសិកម្ម។

នាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្ម មានស្ថានីយ៍ស្រាវជ្រាវចំនួន ១២ និង មានមជ្ឈមណ្ឌ អភិវឌ្ឍន៍តំណាងអោយគ្រប់ប្រព័ន្ធបរិស្ថានដាំដុះដូចជា ស្រូវវស្សា ស្រូវស្រោចស្រព ស្ថានីយ៍ដំណាំចំការ (សំរាប់ ពោត សណ្តែកជាដើម។ល។ ស្ថានីយ៍បន្លែ ម្រេច និង ឈើហូបផ្លែ។ ទោះជាកន្លែងទាំងនេះឈ្មោះថាជាស្ថានីយ៍ ស្រាវជ្រាវ ឬ មជ្ឈមណ្ឌអភិវឌ្ឍន៍ក៏ដោយ រចនាសម្ព័ន្ធរបស់វាមានកំរិតទាបដែលភាគច្រើនគេប្រើសំរាប់ផលិត កម្មគ្រាប់ពូជ។ ទោះជាយ៉ាងនេះក៏ដោយ ការដែលវាតំណាងអោយគ្រប់ប្រព័ន្ធបរិស្ថានដាំដុះផ្តល់ផលប្រយោជន៍ សំរាប់អោយវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា និង វិទ្យាស្ថានស្រាវជ្រាវដទៃអាចប្រើកន្លែងទាំង នោះសំរាប់ការស្រាវជ្រាវ។

## ខ. អនុវិស័យកៅស៊ូ

ក្នុងឆ្នាំ ២០០៤ ក្រុមហ៊ុនកៅស៊ូចំនួន ៧ របស់រដ្ឋមានផ្ទៃដី ៣៨.៥០០ ហិកតា និង ផលិតបាន ២៦.០០០ តោននៃជ័រកៅស៊ូស្ងួតដែលមានតម្លៃច្រើនជាង ៣០,៥ លានដុល្លាអាមេរិក។ ចំការកៅស៊ូឯកជនខ្នាតតូចមានផ្ទៃ ដីប្រមាណ ១០.០០០ ហិកតា។ ចំការកៅស៊ូទាំងអស់ លាតសន្ធឹងលើដីក្រហម កំអែភ្នំភ្លើងនៅប៉ែកខាងកើតនៃប្រទេសកម្ពុជា ជាពិសេសនៅក្នុងខេត្តកំពង់ចាម។

ការសិក្សាជាច្រើនបានបញ្ជាក់ថាប្រទេសកម្ពុជា មានលក្ខខណ្ឌសមស្រប សំរាប់ផលិតកម្មដំណាំកៅស៊ូ។ និង ល័ក្ខខ័ណ្ឌអាកាសធាតុសមស្រប ជាបន្ថែមទៅលើកំលាំងពលកម្មថោក (មើលតារាង ក៣.២ ក្នុង ឧបសម្ព័ន។ សំរាប់ការវិភាគ SWOT)។ កម្ពុជាមានសក្តានុពលក្នុងការបង្កើនផ្ទៃដីដំណាំកៅស៊ូ រហូតដល់ ១៥០,០០ ហិកតា តាមរយៈការកាប់ និង សំអាត ផ្ទៃដីព្រៃធម្មជាតិដែលមានស្រាប់។ ជាមួយទិន្នផលសមស្រប ផលិតករ អាចកើនរហូតដល់ ២២០.០០០ តោន នៅពេលដែលមានការអភិវឌ្ឍពេញលេញ។ ការកើននៃផលិតកម្មកើន អាចសំរេចបានផងដែរ តាមរយៈការដាំកូនដែលកែរួច និង ការគ្រប់គ្រងបានល្អជាងមុន។

សហគ្រាសដែលរដ្ឋជាម្ចាស់កម្មសិទ្ធិ មានប្រហែល ៨០% នៃផលិតកម្មដំណាំកៅស៊ូ ហើយសល់ពី ជាកសិដ្ឋានខ្នាតតូច។ តួលេខនេះមានទំហំធំ បើប្រៀបធៀបនឹង ១៨% ដែលរដ្ឋធ្វើជាម្ចាស់នៅក្នុងប្រទេស ម៉ាឡេស៊ី និង ៨% នៅក្នុងប្រទេសឥណ្ឌូនេស៊ី។ ផែនការដែលកំពុងតែធ្វើនៅក្នុងឆ្នាំ ២០០៥ មានគំពោងបើ អវិនិយោគចំការកៅស៊ូរដ្ឋរបស់កម្ពុជា។ កិច្ចការនេះនឹងបង្កើនលទ្ធភាពដល់ទីផ្សារសេរីដើម្បីអោយមានការវិវឌ្ឍ យោគកាន់តែច្រើនទៅលើបច្ចេកវិទ្យាថ្មីៗចុងក្រោយ និងដើម្បីបង្កើនតំរូវការសំរាប់សកម្មភាពនៃការស្រាវជ្រាវ អនុវត្ត និង ការស្រាវជ្រាវបន្សា។ កង្វះប្រសិទ្ធិភាពនៃសហគ្រាសរដ្ឋ ត្រូវបានគេចាត់ទុកថាជាចំណុចខ្សោយនៃ វិស័យកៅស៊ូដែលជាលទ្ធផលនាំអោយមានការវិនិយោគតិចតួច។ ឧស្សាហកម្មនេះត្រូវការផងដែរនូវការវិនិយោគ សំរាប់ការដាំឡើងវិញដំនួសដើមកៅស៊ូចាស់ៗ។ កិច្ចការនេះទាមទារការធ្វើផែនការយុទ្ធសាស្ត្រទូលំទូលាយ និង ការធ្វើអោយប្រសើរឡើងក្នុងការផ្សព្វផ្សាយ។ កង្វះខាតនៃអ្នកឯកទេសអាចកំរិត ការអភិវឌ្ឍសំរាប់រយៈពេលខ្លី និង មធ្យម។

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា (CRRI) បានលើកឡើងនូវផលវិបាកទាក់ទងនឹងការបង្កើតពូជមាន ទិន្នផលខ្ពស់ ការធ្វើអោយប្រសើរឡើងនូវវិធីសាស្ត្រចំរៀច ការដាំចន្លោះរងដើម្បីជួយអ្នកធ្វើផលិតកម្មខ្នាតតូច និង ក្នុងការធ្វើអោយប្រសើរឡើងនូវផលិតផលកៅស៊ូដែលចេញពីរោងចក្រកែច្នៃ។

## គ. អនុវិស័យចិញ្ចឹមសត្វ

ចំនួនសត្វចិញ្ចឹមនៅកម្ពុជាបានកើនឡើងជាលំដាប់ក្នុង ២ ទសវត្សកន្លងមក។ នៅក្នុងឆ្នាំ ២០០៣ សត្វគោក្របីមាន ៣,៦៥ លានក្បាលជ្រូក ២.៣លានក្បាល និង សត្វស្លាប ១៦ លានក្បាល។ គោនិងក្របីត្រូវបានប្រើប្រាស់ជាសត្វអូសទាញ ជាជាងសំរាប់សំលាប់យកសាច់។ ក្នុងឆ្នាំ ២០០៣ ចំណូលបានមកពីការចិញ្ចឹមសត្វស្មើនឹង ៦.១% នៃផលិផលក្នុងស្រុកសរុប (ផ.ស.ស) របស់ជាតិ និង មានតសេ ប្រមាណ ៣០៦ លានដុល្លាអាមេរិក។ ក្នុងឆ្នាំដដែលនេះ៖ ចំនួនសត្វគោក្របីមានចំនួនសរុប ១ ក្នុងពេលដែលតំរូវការក្នុងស្រុកមានតែ ១.៨ លានក្បាល ដូច្នេះកម្ពុជាមានលទ្ធភាពនាំចេញនូវសត្វគោក្របីពី៥០១០០ ពាន់ក្បាល។

តំរូវការសាច់នៅប្រទេសជិតខាងត្រូវបានគ្រោងទុកថានឹងកើនឡើង ហើយវានឹងអាចអោយកម្ពុជាបាន ផលចំណេញពីឱកាសនៃការពង្រីកទីផ្សារទាំងនេះ។ ប្រទេសថៃ ឥណ្ឌូនេស៊ី និង ម៉ាឡេស៊ី បាននាំចូលសត្វរស់ក្នុងបរិមាណដ៏ច្រើន។ វៀតណាមក៏ប្រឈម ! មុខនឹងកង្វះសាច់ហើយបច្ចុប្បន្នកំពុង

មានការធ្វើចរាចរសត្វ គោ-ក្របីរស់ឆ្លងកាត់ព្រំដែនពីកម្ពុជាទៅវៀតណាម។ ក្នុងរយៈពេលវែងខាងមុខ ទស្សនវិស័យសំរាប់ការចិញ្ចឹមសត្វពាហណៈជ្រូក និង សត្វស្លាប ដោយកិច្ចសន្យានឹង មានជោគជ័យ បំផុត។ ដើម្បីសំរេចកិច្ចការនេះ៖ សមាហរណកម្មប្រព័ន្ធកសិពាណិជ្ជកម្មផ្នែកលើដំណាំ ការចិញ្ចឹម សត្វ និង ផលិតផលត្រីក្នុងស្រុកត្រូវតែអភិវឌ្ឍ។ កិច្ចការនេះមានការទទួលយកនូវប្រព័ន្ធផលិតកម្មរុក្ខ ជាតិចំណី សត្វ និង ការត្រៀមបង្កើតអោយមានការបូកបញ្ចូលទាំងកំរៃ រោងចក្រកែច្នៃ ចំណីសត្វ និង ចំណីត្រី ដើម្បីផ្គត់ផ្គង់ ផ្នែកផលិតកម្មបសុព្យាបាលជាមួយនឹងរូបមន្តចំណីផ្សំក្នុងស្រុក។ ស្ថាបន័ពាក់ព ន្ធ័វិស័យចិញ្ចឹមសត្វយល់ឃើញថា តម្លៃវត្ថុធាតុដើមក្នុងស្រុកសំរាប់ផលិតកម្មចិញ្ចឹមសត្វនៅថោក បើ ប្រៀបធៀបនឹងទីផ្សារអន្តរជាតិ ប៉ុន្តែសេវាកម្មគាំទ្រ និង រចនាសម្ពន្ធ័ជនបទត្រូវតែធ្វើអោយប្រសើរ ឡើងដើម្បីធ្វើអោយ ប្រព័ន្ធចិញ្ចឹមសត្វអាចដើរតួសំខាន់ក្នុងសេដ្ឋកិច្ច។ ការស្រាវជ្រាវបណ្ដិតគឺជាការ ចាំបាច់ ដើម្បីបង្កើនចំណេះដឹងក្នុង ស្រុកលើការចិញ្ចឹមសត្វពាហណៈ និង ការត្រួតពិនិត្យជំងឺ។ ការ ផ្ទេរចំណេះដឹងទៅអោយអ្នកផលិតប្រកបដោយ ប្រសិទ្ធភាព អាស្រ័យលើទំនាក់ទំនងដែលមានភាព រឹងមាំ។

មជ្ឈមណ្ឌលជាតិស្រាវជ្រាវសុខភាព និងផលិតកម្មសត្វ និងនាយកដ្ឋានផលិតកម្មនិង បសុព្យាបាល មិនអាចដោះស្រាយបញ្ហាផលិតកម្ម ចិញ្ចឹមសត្វបានទាំងអស់ឡើយជាមួយនឹងថវិកា មានកំរិតដែលគេមានសំរាប់ការស្រាវជ្រាវ។ កម្មវិធីស្រាវជ្រាវរបស់គេបច្ចុប្បន្នជាប្រភេទគំរោងតូចៗ ដូចជាការ ផ្ដល់វ៉ាក់សាំងសំរាប់ជំងឺ Newcastle និង ពិសោធន៍ជំងឺ Hemorrhagic និង គំរោងសហ ការជាមួយមជ្ឈមណ្ឌល អូស្រ្តាលីសំរាប់ការស្រាវជ្រាវអន្តរជាតិ (ACIAR) លើការត្រួតពិនិត្យ fasciolosis។ ជាបន្ថែម CelAgrid បានធ្វើការតាមដានលើប្រភេទចំណីសំរាប់ការ ចិញ្ចឹមសត្វ។

### ឃ. អនុវិស័យជលផល

ជាប្រពៃណី ត្រីគឺជាប្រភពដ៏សំខាន់នៃប្រូតេអ៊ីន សំរាប់ប្រជាជនកម្ពុជាស្ទើរតែទាំងអស់ និង ប្រមាណជា ២៧ នៃចំនួនប្រជាជនចាប់យកការនេសាទត្រីជាមុខរបរទី ២។ ប្រទេសកម្ពុជាសំបូរទៅ ដោយធនធានជលផល ហើយការប្រមូលផលក្នុងឆ្នាំ ២០០៣ មានប្រមាណជា ៣០៩.000 តោន សំ រាប់ជលផលទឹកសាប និង ៥៥. 000 តោនជលផលទឹកប្រៃ។ ការនាំចេញត្រីក្នុងឆ្នាំ ២000 មានតំលៃ ទឹកប្រាក់សរុបប្រមាណ ៧,២លានដុល្លាអាមេរិក។ ការនេសាទត្រីទឹកសាបនិងទឹកប្រៃមិនមានការកើន ឡើងទេ ដោយសារការធ្វើអាជីវកម្មហស ការបំលែងព្រៃលិចទឹកអោយទៅជាផ្ទៃដីដាំស្រូវប្រដេញទឹក ការគ្រប់គ្រងមិនបានល្អ និង ការបន្តបំផ្លិចបំផ្លាញ បរិស្ថាន។ ទោះបីជាយ៉ាងណាក៏ដោយ ការលូត លាស់ក្នុងស្ថេរភាពនៃផលិតកម្មជលផលទឹកសាបអាចសំរេ តាមរយៈការគ្រប់គ្រងបានល្អ និង វិធាន ការការពារធនធានក្នុងទឹក ជាមួយនឹងការពង្រីក និង ការធ្វើអោយប្រសើរ ឡើងដល់ការចិញ្ចឹមត្រីក្នុង ស្រែ និង ការធ្វើវារីវប្បកម្ម។ ចំណេះដឹង សហគមន៍នេសាទត្រូវតែបង្កើនឡើងសំរាប់ការអនុវត្តន៍ច្បាប់ និងបទបញ្ញតិដើម្បីការពារឧស្សាហកម្មសង ជលផល។ បច្ចេកទេសសំរាប់វារីវប្បកម្មត្រូវតែអភិវឌ្ឍន៍ ប្រសិនបើការចិញ្ចឹមត្រីរបៀបទំនើបនឹងត្រូវបានយក មកប្រើប្រាស់នាពេលអនាគត។

ការស្រាវជ្រាវជលផលសមុទ្រ ទទួលបានការគាំទ្រតិចតួចនៅក្នុងប្រទេសកម្ពុជា ហើយការនេសាទ មានការប៉ាន់ប្រមាណនៅសើរ ដោយសារភាគរយដ៏ធំ នៃផលិតផលនេះត្រូវបានលក់នៅតាមឆ្នេរ។ មានភសភា បញ្ជាក់ថា ការនេសាទលើសកំរិតដោយទូកពីប្រទេសជិតខាង បានកាត់បន្ថយជលផលសមុទ្រក្នុងឆ្នាំថ្មី១នេះ៖ "។ ការ យកចិត្តទុកដាក់ក្នុងការស្រាវជ្រាវ ទាមទារអោយមានការចង្អុលបង្ហាញភស្តុតាង សំរាប់ការសន្និដ្ឋានទាំងនេះ និង ការអនុវត្តបទបញ្ញាតិដើម្បីកសាងឡើងវិញនូវឧស្សាហកម្មជលផល។ ពត៌មាន និង ការជំរុញលើកទឹកចិត្តដល់ សហគមន៍នេសាទ ទាំងទឹកសាបនិងទឹកប្រៃដើម្បីទទួលបានជោគជ័យក្នុងវិស័យនេះនឹងបានមកពីមជ្ឈមណ្ឌ ពត៌មានបច្ចេកទេស និង វិទ្យាស្ថានស្រាវជ្រាវ។ ការផ្ទេរដ៏មានប្រសិទ្ធភាពនូវពត៌មាននេះ៖ ទាមទារអោយមាន ការពង្រឹង និង ការភ្ជាប់ទំនាក់ទំនងទៅនឹងសហគមន៍នេសាទ។

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប បានទទួលការឧបត្ថម្ភថវិកា ថ្នាក់តំបន់ពីគណៈកម្មាធិការទន្លេមេគង្គ និង DANIDA សំរាប់កម្មវិធីស្រាវជ្រាវពាក់ព័ន្ធនឹងស្ថេរភាពនៃចំនួន ត្រីទឹកសាបធម្មជាតិ និងជលផលទឹកសាប។ វិទ្យាស្ថានមានថវិកាតិចតួច សំរាប់ការស្រាវជ្រាវផ្ទាល់របស់គេ។ កម្មវិធីស្រាវជ្រាវរបស់គេទទួលការឧបត្ថម្ភថវិកាទាំងស្រុងពីគណៈកម្មាធិការទន្លេមេគង្គ ដែលមានមូលដ្ឋាននៅក្នុងប្រទេសឡាវ ហើយវាបែងចែកជា៣ផ្នែក។

ក) វាយតំលៃបរិមាណជលផលនេសាទនៅតាមទន្លេមេគង្គ

ខ). ការគ្រប់គ្រងជលផលទន្លេ និងអាង

គ) វារីវប្បកម្ម និងប្រភេទត្រីទន្លេមេគង្គ។

## ង. អនុវិស័យរុក្ខកម្ម

ធនធានព្រៃឈើរបស់កម្ពុជា រួមមានអនុផលព្រៃឈើ (ឧទាហរណ៍ : ផ្តៅ ឬស្សី សត្វព្រៃ និង រុក្ខជា ឬ រុក្ខជាតិអាចបរិភោគបានជាដើម។ល។) បានទទួលរងការបាត់បង់ជាបន្តបន្ទាប់។ ក្នុងពេលថ្មីៗនេះ ការ ខ្លាំងបណ្តាលមកពីការធ្វើអាជីវកម្មព្រៃឈើខុសច្បាប់។ ជាមួយទំរង់គោលនយោបាយត្រឹមត្រូវ ការត្រួតពិនិត្យដែលប្រកបដោយប្រសិទ្ធភាពនូវធនធានព្រៃឈើ ការគ្រប់គ្រងត្រឹមត្រូវ និង ការអនុវត្តកិច្ចការអភិរក្សឧស្សាហកម្មព្រៃឈើ អាចរកចំណូលថវិកាដល់រាជរដ្ឋាភិបាល ប្រកបដោយស្ថេរភាពពី ២៥-៥០ លានដុល្លាអាមេរិកជា! រៀងរាល់ឆ្នាំ (OPCV, 2002)។ ការបង្កើតចំការព្រៃឈើដោយដាំប្រភេទឈើលូតលាស់លឿន និង ពូជឈើក្នុង ស្រុកនឹងធ្វើអោយការផ្គត់ផ្គង់កាន់តែប្រសើរឡើង។ ការដាំព្រៃឈើឡើងវិញនឹងមិនត្រឹមតែបន្ថែមនូវធនធាន ព្រៃឈើរបស់ប្រទេសប៉ុណ្ណោះទេ ក៏ប៉ុន្តែក៏បានផ្តល់ឱកាសការងារ និងបង្កើនចំណូលជនបទផងដែរ។

កំណែទំរង់ព្រៃឈើ គឺជាផ្នែកដ៏សំខាន់នៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយការធ្វើ ដូច្នេះនឹងធ្វើអោយវិស័យព្រៃឈើទទួលបានការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលក្នុងអំឡុងទស្សវត្សបន្ទាប់។ ការ ដាំព្រៃឈើឡើងវិញត្រូវបានជំរុញស្របជាមួយការអភិវឌ្ឍឧស្សាហកម្មព្រៃឈើដើម្បីបង្កើនតម្លៃផលិតផលព្រៃឈើ។ មន្ត្រីរដ្ឋាភិបាលយល់ច្បាស់ថា ការថយចុះនៃផ្ទៃដីព្រៃឈើប៉ះពាល់ដោយផ្ទាល់លើសេដ្ឋកិច្ចជាតិតាមរយៈការ បាត់បង់នៃស្ថេរភាពចំណូល និងមិនផ្ទាល់តាមរយៈការ

ប៉ះពាល់របស់វាទៅលើផលផល និង សកម្មភាពកសិកម្មដទៃ ទៀត។ ចំណុចទន់ខ្សោយនៃវិស័យព្រៃឈើ មានកង្វះសមត្ថភាព ដើម្បី ជំរុញការអនុវត្តច្បាប់ព្រៃឈើដែលមានស្រាប់ ទំនាក់ទំនងមិនល្អ និងកិច្ចសហការ មិនបានល្អជាមួយអ្នកប្រើប្រាស់ ក្នុងស្រុក ការគាំទ្រថវិកាមានកំរិត និង ភាពមិនច្បាស់លាស់សំរាប់ព្រៃឈើ និង ដីសម្បទានសង្គមកិច្ច។ ទោះបី ជាយ៉ាងណាក៏ដោយកម្ពុជាមានឱកាសគ្រប់គ្រាន់ដើម្បីធ្វើអោយប្រសើរឡើងវិញនូវវិស័យព្រៃឈើ មុនពេលមានការប្រែប្រួលនៃបរិស្ថានដែលប៉ះពាល់ដល់សេដ្ឋកិច្ច។ ឱកាសជាច្រើនទាមទារការ គាំទ្រពីទំរង់កម្មវិធីស្រាវជ្រាវ ការដាក់បញ្ចូលនូវកម្មវិធីផ្សព្វផ្សាយដ៏មានប្រសិទ្ធភាព និងភាពរឹងមាំ និងពហុទំនាក់ ទំនងជាមួយអ្នកពាក់ព័ន្ធនឹងព្រៃឈើ អ្នកធ្វើអាជីវកម្មព្រៃឈើ សហគមន៍កសិកម្មជិតខាងក្នុងមូលដ្ឋាន។ ភាព គំរាមកំហែងចំពោះអនុវិសយ័ព្រៃឈើមានតម្លៃឈើខ្ពស់លើទីផ្សារអន្តរជាតិ ដែលជំរុញអោយមានការកាប់ឈើ ការពង្រីកផ្ទៃដីដាំដុន អំពើពុករលួយ ការប្រែប្រួលអាកាសធាតុ និង ការមិនអាចត្រួតពិនិត្យបាននូវភ្លើងឆេះព្រៃ។

រដ្ឋបាលព្រៃឈើមានឧបករណ៍ GIS ( ប្រពន្ធ័ពត៌មានភូមិសាស្ត្រដ៏ធំមួយដើម្បីអនុវត្តសកម្មភាព សំខាន់ ក្នុងការគ្រប់គ្រងព្រៃឈើ។ វិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រព្រៃឈើ និង សត្វព្រៃដែលស្ថិតនៅក្រោម រដ្ឋបាលព្រៃឈើមិនមានថវិកាជំជុំដើម្បីដំណើរការកម្មវិធីស្រាវជ្រាវឡើយ ហើយការស្រាវជ្រាវរបស់គេនៅឆ្នាំ ២០០៤ គឺគ្រាន់តែបំពេញលើតួនាទីបន្ទាប់បន្សំជាមួយនឹងគំរោងផ្គត់ផ្គង់ថវិកាដោយប្រទេសជប៉ុនលើការផ្លាស់ប្តូរ របបទឹកនៅក្នុងអាងស្តុកទឹកទន្លេមេគង្គ (ឧបសម្ពន្ធ័ក២.៥) ។ ទំហំដ៏តូចនៃកម្មវិធីស្រាវជ្រាវរបស់វិទ្យាស្ថាន ស្រាវជ្រាវវិទ្យាសាស្ត្រព្រៃឈើ និងសត្វព្រៃ ជាផលវិបាកដ៏សំខាន់នៃវិទ្យាស្ថាន។

## ច. អនុវិស័យកសិឧស្សាហកម្ម

ជាអនុវិសយ័ដ៏សំខាន់ដែលរួមចំណែកដល់សេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា។ ផលិតផលកសិកម្មស្ទើរតែទាំងអស់នៅពេលបច្ចុប្បន្នត្រូវបានលក់និងចែកចាយនៅក្នុងទំរង់មិនទាន់កែច្នៃដូចជាវត្ថុធាតុដើម។ ការពង្រឹងអនុវិស័យ កសិឧស្សាហកម្មនឹងជួយកសិករ និងអ្នកកែច្នៃ បង្កើនចំណូលរបស់គេ និងបង្កើតឱកាសការងារ។ ការធ្វើអោយគោលបំណងសំខាន់របស់ ប្រសើរឡើងនូវបរិយាកាសវិនិយោគនឹងនាំមកនូវការអភិវឌ្ឍន៍វិស័យឯកជន។ រដ្ឋាភិបាល គឺគាំទ្រការបង្កើនគុណភាពនៃផលិតផលកសិកម្ម និង លើកស្ទួយពិពិធកម្មអោយក្លាយជាអាជីវករ សេដ្ឋកិច្ចថ្មីមួយតាមរយៈផលិតកម្មដំណាំមានតម្លៃខ្ពស់ និងបង្កើនការទទួលយកផលិតផលកម្ពុជានៅក្នុងទី៣ ពិភពលោក ដើម្បីស្រូបយកផលិតផលលើសនៅកម្ពុជា ដែលកើតឡើងពីការបង្កើនផលិតភាព។

ប្រហែល ៧០% នៃកម្លាំងពលកម្មកម្ពុជា ប្រកបរបរកសិកម្ម ហើយកំរៃពលកម្មក្នុងស្រុកមានកំរិតទា , ល័ក្ខខ័ណ្ឌាំងនេះត្រូវបានចាត់ទុកថាជាចំណុចខ្លាំងនៃវិស័យកសិឧស្សាហកម្ម ស្របជាមួយភាពជាក់ស្តែងដែល រដ្ឋាភិបាលមិនយកពន្ធដារជាផ្លូវការលើផលិតផលកសិកម្ម។ ឱកាសសំរាប់ ការពង្រីកអនុវិស័យនេះ តាមរយៈការធ្វើអោយប្រសើរឡើងនូវរចនាសម្ពន្ធ័ចំរុះ ការនាំចេញរួមបញ្ចូលទាំងការ បង្កើនផ្ទៃដីដាំដុនសុទ្ធតែមានការទទួលស្គាល់ទូលំទូលាយ។ ទោះបីជាយ៉ាងណាក៏ដោយមានផលវិបាកជាច្រើនដែល វិស័យនេះត្រូវតែជំនះ ឬ ជានារាំងមុនពេលដែលការបង្កើនផលិតភាពទំរង់ធំ

មួយអាចកើតមានឡើង។ ភាគច្រើននៃកិច្ចការទាំងនេនពាក់ពន្ធ័នឹងការធ្វើអោយប្រសើរឡើងជាទូទៅលើសេដ្ឋកិច្ចជាតិ និងការចាត់ចែង (បញ្ហា នៃការយកកម្រៃមិនផ្លូវការ តម្លៃដឹកជញ្ជូន ការអនុវត្តច្បាប់ការរត់ពន្ធ ទុនរកស៊ី)។ ភាពខ្សោយ និង ការគំរាម កំហែងដទៃទៀត ចំពោះឧស្សាហកម្មនេះអាចដោះស្រាយបានតាមរយៈការធ្វើអោយប្រសើរឡើងក្នុងការកំណត់ តំបន់ក្សេត្របរិស្ថាន ការអភិវឌ្ឍបច្ចេកវិទ្យាផលិតកម្មថ្មី១ វិធានការទប់ទល់នឹងការបាត់បង់ដីជាតិដី (ដំណោះ៖ ស្រាយចំពោះបញ្ហាសត្វល្អិត និងជម្ងឺ ការធ្វើអោយប្រសើរឡើងនូវពត៌មានអំពីទីផ្សារ, និងការរកទីផ្សារ និងការ ពង្រីកសមត្ថភាពផ្សព្វផ្សាយសាធារណៈ និង ឯកជន។ ទាំងអស់នេះត្រូវការការស្រាវជ្រាវ និង អភិវឌ្ឍន៍ជាមុន។

នាយកដ្ឋានកសិឧស្សាហកម្ម ទទួលខុសត្រូវក្នុងការរៀបចំគោលនយោបាយ និង ការរៀបចំគំរោងដើម្បី អភិវឌ្ឍន៍ដំណាំកសិឧស្សាហកម្ម និង សហគ្រាសចំណីអាហារ។ នាយកដ្ឋ។ នេះត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០២ ប៉ុន្តែរហូតមកទល់នឹងឆ្នាំ២០០៤ នៅតែមិនទាន់អភិវឌ្ឍកម្ម។ ស្រាវជ្រាវសំរាប់ប្រមូលព័ត៌មានដើម្បីរៀបចំគោលនយោបាយនៅឡើយ។ កង្វះខាតការគាំទ្រផ្នែកថវិកាសំរាប់សកម្មភាព ត្រូវបានមើលឃើញថាជាផលវិបាកនៃនាយកដ្ឋានកសិឧស្សាហកម្ម។

### ឆ. ការស្រាវជ្រាវដែលពុំផ្តោតលើអនុវិស័យកសិកម្ម

មិនមានវិទ្យាស្ថានណាមួយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវបានបង្កើតឡើងដើម្បីស្រាវជ្រាវដែលមិនផ្អែកលើអនុវិស័យកសិកម្មឡើយ។ វិទ្យាសាស្ត្រសង្គម ប្រពន្ធ័កសិកម្ម យេនឌ័រ សេដ្ឋកិច្ចកសិកម្ម និង បញ្ហាពាក់ពន្ធ័ដទៃទៀត ជាទូទៅត្រូវបានធ្វើការស្រាវជ្រាវដោយអង្គភាពស្រាវជ្រាវជាច្រើន។ ឧទាហរណ៍ការសិក្សាវិទ្យាសាស្ត្រសង្គមក្នុងវិសយ័ដំណាំ គឺធ្វើឡើងដោយវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍកសិកម្ម កម្ពុជា សាកលវិទ្យាលយ័ភូមិន្ទកសិកម្ម អង្គការមិនមែនរដ្ឋាភិបាល ឬ វិស័យឯកជន។ កិច្ចការនៅក្នុងវិស័យ ជលផលគឺធ្វើឡើងដោយវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលទឹកសាប។ ការអនុវត្តដូចគ្នានេះដែរធ្វើឡើង សំរាប់យេនឌ័រ និង បញ្ហាបរិស្ថាននៅក្នុងជំនាញនិមួយៗ។ ការសិក្សាអំពីសេដ្ឋកិច្ចកសិកម្មជាផ្នែកមួយនៃកម្មវិធីស្រាវជ្រាវរបស់វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កម្ពុជា ប៉ុន្តែជាទូទៅសេដ្ឋកិច្ចនៃការធ្វើកសិកម្មគឺជាផ្នែកមួយនៃ កម្មវិធីស្រាវជ្រាវរបស់ស្ថាប័នស្រាវជ្រាវ។

ជាទូទៅគោលនយោបាយកសិកម្ម ត្រូវបានរៀបចំឡើងដោយថ្នាក់ដឹកនាំក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទោះបីជានាយកដ្ឋានផែនការនិងស្ថិតិ និង នាយកដ្ឋាន ឬ វិទ្យាស្ថានស្រាវជ្រាវដទៃទៀតមានតួនាទី ជាអ្នកប្រមូលពត៌មានចាំបាច់សំរាប់បង្កើតជាគោលនយោបាយក៏ដោយ។ នាយកដ្ឋានរបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ អាចទាក់ទងជាមួយក្រសួងដទៃទៀត ដូចជាក្រសួងធនធានទឹកនិងឧតុនិយម និង ក្រសួង បរិស្ថាន ដើម្បីធ្វើកាស្រាវជ្រាវលើធនធានទឹក ឬ បរិស្ថាន។

### ៣.៦.៧. សហប្រតិបត្តិការរវាងអង្គភាពស្រាវជ្រាវកម្ពុជា

វិទ្យាស្ថានស្រាវជ្រាវកសិកម្មដ៏សំខាន់ៗចំនួន៥ វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា វិទ្យា ស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា មជ្ឈមណ្ឌលជាតិស្រាវជ្រាវសុខភាពនិងផលិតកម្មសត្វ វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍ជលផលទឹកសាប វិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រព្រៃឈើ និងសត្វព្រៃ)ត្រូវបានបង្កើតឡើងដើម្បីស្រាវ ជ្រាវអនុស័យខុសៗគ្នា និង ជារឿយគ្មានទំនាក់ទំនងរវាងគ្នាលើមូលដ្ឋានវិទ្យាសាស្ត្រឡើយ។ ប៉ុន្តែកិច្ចសហការ អាចកើតមានឡើងតាមរយៈគំរោងស្រាវជ្រាវណាមួយ។ ឧទាហរណ៍នៃការសហការនេះមានដូចជា ការស្រាវ ជ្រាវលើប្រព័ន្ធចិញ្ចឹមត្រីក្នុងស្រែ ដែលធ្វើរួមគ្នាដោយអ្នកក្សេត្រសាស្ត្រ និង អ្នកឯកទេសវារីវប្បកម្មពីនាយកដ្ឋាន ជំនាញ។ លទ្ធផលនៃការសិក្សានេះមានបោះពុម្ពក្នុងសៀវភៅណែនាំស្តីពីការចិញ្ចឹមត្រីក្នុងស្រែ (Ricefield Fisheries Handbook, 1997)។ ឧទាហរណ៍ដទៃទៀតរួមមានៈ ការសិក្សារួមគ្នាទៅលើសត្វពាហណៈក្នុងប្រព័ន្ធ បរិស្ថានស្រូវ ដែលលទ្ធផលមានក្នុងឯកសារបោះពុម្ព "ការចិញ្ចឹមសត្វនៅក្នុងប្រព័ន្ធដំណាំស្រូវនៅកម្ពុជា(Mclean, 1998)។ គំរោងបច្ចុប្បន្នដែលកំពុងដំណើរការស្ថិតនៅក្នុងការលើកសំណើរួមមានៈ ឬ កិច្ចសហការរវាងរដ្ឋបាលព្រៃឈើ និង វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជាសំរាប់ការស្រាវជ្រាវកសិ-រុក្ខកម្ម ដោយសហការជាមួយ មជ្ឈមណ្ឌលព្រៃឈើពិភពលោក (World Forestry Center) កិច្ចសហការរវាងវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍកសិកម្មកម្ពុជា ជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មសំរាប់ការស្រាវជ្រាវពីវិធានការកំចាត់កញ្ជ្រៃ ដោយមាន ការចូលរួមពីកសិករ និងកិច្ចសហការរវាងវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ជាមួយនាយកដ្ឋាន ក្សេត្រសាស្ត្រនិងកែលំអដីកសិកម្មសំរាប់ដំណាំបន្លែ។ គំរោងទាំងនេនទទួលការឧបត្ថម្ភថវិកាដោយ ACIAR។ នាយកដ្ឋានបច្ចេកទេស និងវិទ្យាស្ថានស្រាវជ្រាវទាំងអស់សហការជាមួយសាកលវិទ្យាលយ័ភូមិន្ទកសិកម្ម សាលា ជាតិកសិកម្មព្រែកលៀប សាលាជាតិកសិកម្មកំពង់ចាម សាកលវិទ្យាលយ័ឥសីវេទ និងគ្រឹះស្ថានឧត្តមសិក្សា៥៤ ទៀត ដើម្បីជួយសកម្មភាពស្រាវជ្រាវរបស់និស្សិត។ ជាបន្ថែម ការស្រាវជ្រាវកិច្ចសន្យាគឺជារឿយៗធ្វើឡើងជំនួស អោយក្រុមហ៊ុនស្រាវជ្រាវកសិកម្មឯកជន ដោយវិទ្យាស្ថានស្រាវជ្រាវរបស់រដ្ឋាភិបាល។

វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា អាស្រ័យយ៉ាងខ្លាំងលើមធ្យោបាយស្រាវជ្រាវរបស់ ស្ថានីយ៍ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្ម និងរបស់មន្ទីរ កសិកម្មខេត្ត។ ការប្រើប្រាស់ដីរបស់ស្ថានីយ៍ក្រោមឱវាទនាយកដ្ឋានសំរាប់ការស្រាវជ្រាវ គឺជារឿយៗស្ថិតក្នុង ការប្រណាំងប្រជែងជាមួយសកម្មភាពផលិតកម្មគ្រាប់ពូជរបស់ស្ថានីយ៍ ហើយកិច្ចសន្យាជាផ្លូវការអាចជាការចាំ បាច់នៅក្នុងពេលអនាគតសំរាប់ការងារស្រាវជ្រាវ។ ការសហការរវាងអង្គភាពស្រាវជ្រាវ _ គឺជារឿយរឹងមាំ ល្អនៅកំរិតថ្នាក់ខេត្ត។ បុគ្គលិកមន្ទីរកសិកម្មខេត្តដែលតំណាងអោយនាយកដ្ឋានផ្សេងៗ ទាក់ទងជាមួយកសិករ ឬ វិទ្យាស្ថានដោយផ្ទាល់ខ្លួនក្នុងការបំពេញទិន្នន័យប្រព័ន្ធកសិកម្មត្រឡប់ទៅវិទ្យាស្ថានស្រាវជ្រាវ ដែលមានមូលដ្ឋាន នៅភ្នំពេញវិញ។

ដំណោះស្រាយដែលគួរតែគិតគូរសំរាប់វិទ្យាស្ថានស្រាវជ្រាវ គឺការចែករំលែកឬប្រើប្រាស់រួមគ្នានូវសម្ភារៈ មន្ទីរពិសោធន៍ និង ធនធានដទៃទៀត។ ទោះបីជាវិទ្យាស្ថានស្រាវជ្រាវកសិកម្មសំខាន់ៗរបស់រដ្ឋាភិបាលស្ថិត នៅក្រោមក្រសួងតែមួយក៏ដោយ ក៏ប្រព័ន្ធនៃការទូទាត់ថវិកាតាមរយៈការផ្ទេរ

ថវិការវាងគ្នាមិនមានកើតឡើងទេ។ ឧទាហរណ៍ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាត្រូវការទូទាត់ជាសាច់ប្រាក់សំរាប់ការវិភាគដីដែលធ្វើនៅមន្ទីរ ពិសោធន៍នៃនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្ម។ ការផ្ទេរថវិកាពីខ្ទង់មួយទៅកន្លែងមួយទៀតនឹងជួយ ! សំរួលដល់ការលំបាកទាំងនេះ និង ធ្វើអោយប្រសើរឡើងនូវប្រសិទ្ធភាព ហើយនឹងកាត់បន្ថយតំរូវការនៃ មធ្យោ បាយស្រាវជ្រាវដូចៗគ្នាចំពោះនាយកដ្ឋានទាំងអស់នោះ។

### ៣.៦.៨. ទំនាក់ទំនងរវាងវិទ្យាស្ថានស្រាវជ្រាវ សេវាកម្មផ្សព្វផ្សាយ និង កសិករ

វិទ្យាស្ថានស្រាវជ្រាវបច្ចុប្បន្ន ពឹងផ្អែកលើនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និង អង្គការក្រៅរដ្ឋាភិបាល មួយចំនួនដើម្បីបញ្ជូនពត៌មានបច្ចេកទេសទៅដល់កសិករ និង ដើម្បីឆ្លើយតបនឹងតំរូវការរបស់កសិករ។ ទោះ យ៉ាងណាក៏ដោយ ក្នុងពេលបច្ចុប្បន្ននេះគ្មានទំនាក់ទំនងផ្លូវការកើតមានរវាងវិទ្យាស្ថានស្រាវជ្រាវ និង នាយកដ្ឋានផ្សព្វផ្សាយកសិកម្មឡើយ។ វិទ្យាស្ថានស្រាវជ្រាវស្ទើរតែទាំងអស់ ទាក់ទងដោយផ្ទាល់ជាមួយសេវាកម្មផ្សព្វផ្សាយ របស់រដ្ឋាភិបាលនៅកំរិតថ្នាក់ខេត្ត។ វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា បានដាក់ការពិសោធន៍ និងស្រែបង្ហាញដោយសហការជាមួយមន្ត្រីថ្នាក់ខេត្តនិងស្រុក។ បន្ទាប់មកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្ម កម្ពុជាបានផ្តល់នូវបច្ចេកទេសបន្ថែមក្នុងអំឡុងនៃការគ្រប់គ្រងការពិសោធន៍ និងស្រែបង្ហាញដើម្បីពង្រីកបច្ចេក វិទ្យា។ នាយកដ្ឋានជលផលវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលទឹកសាប នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល និង មជ្ឈមណ្ឌលជាតិស្រាវជ្រាវសុខភាពនិងផលិតកម្មសត្វ ក៏បានទាក់ទងជាមួយមន្ទីរកសិកម្មខេត្ត នានាតាមរបៀបនេះដែរ។ រដ្ឋបាលព្រៃឈើមូលដ្ឋានមាននៅក្នុងខេត្តមួយចំនួន ហើយការិយាល័យទាំងនេនក៏ទាក់ ទងជាមួយមន្ទីរកសិកម្មខេត្តលើការផ្សព្វផ្សាយដែរ។

ការធ្វើទំនាក់ទំនងផ្ទាល់ រវាងវិទ្យាស្ថានស្រាវជ្រាវ និង នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ជាទូទៅកើតមាន តាមរយៈគំរោងនានា។ ក្នុងឆ្នាំ ២០០៥ សម្ភារៈផ្សព្វផ្សាយសំរាប់ប្រើប្រាស់ដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម គឺបានរៀបចំដោយនាយកដ្ឋានជលផល នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល នាយកដ្ឋានក្សេត្រសាស្ត្រនិង កែលំអដីកសិកម្ម វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា និង អង្គការស្បៀងនិងកសិកម្ម។ គំរោងស្រាវ ជ្រាវ ផ្សព្វផ្សាយដែលពឹងផ្អែកលើសហគមន៍ ដូចជាគំរោងកំចាត់សត្វករ និង ការអភិវឌ្ឍគំរូសំរាប់កំចាត់ fasciolosis នៅក្នុងសត្វគោ និងក្របីនៅក្នុងប្រទេសកម្ពុជា (គំរោងទាំងពីរនេះផ្តល់ថវិកាដោយ ACIAR) ទាមទារអោយមានអន្តរកម្មរវាងនាយកដ្ឋានបច្ចេកទេស វិទ្យាស្ថានស្រាវជ្រាវ និងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។ កម្មវិធីកំចាត់ខ្ទងដួងតាមរបៀបជីវសាស្ត្របាននិងកំពុងរៀបចំ និងស្ថិតនៅក្រោមកិច្ចសហការរវាងនាយកដ្ឋាន ក្សេត្រសាស្ត្រនិងកែលំអដីកសិកម្ម នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និង សាកលវិទ្យាល័យរុក្ខកម្មនិងកសិកម្មទីក្រុង ហូជីមីញ។

សហប្រតិបត្តិការជិតស្និទ្ធតាមរយៈទំនាក់ទំនងដ៏រឹងមាំរវាងវិទ្យាស្ថានស្រាវជ្រាវ ស្ថាប័នពាក់ព័ន្ធជាមួយ វិស័យនានា ពាណិជ្ជករ អ្នកផលិតពូជ ម្ចាស់ម៉ាស៊ីនកិនស្រូវ ផលិតករ និង សហគ្រាសឯកជន

ដទៃទៀតបង្ហាញ ភស្តុតាងថាជាវិធីសាស្រ្តដ៏មានប្រសិទ្ធភាពក្នុងផលិតកម្ម និង ការពង្រីកបច្ចេកវិទ្យាទៅដល់កសិករនៅក្នុងប្រទេស កម្ពុជា។ សហគ្រាសឯកជនដែលមានការលើកទឹកចិត្តពាណិជ្ជកម្មមានទំនាក់ទំនងរឹងមាំជាមួយផលិតករ និង កំពុងព្យាយាមពង្រីកបណ្តាញរបស់គេ។ ឧទាហរណ៍ អ្នកផលិតពូជតាមរយៈគំរោងបង្កើនគុណភាពកសិកម្ម (AQIP) លក់គ្រាប់ពូជទៅអោយម្ចាស់ម៉ាស៊ីនកិនស្រូវដែលចុះកិច្ចសន្យាអោយកសិករដាំពូជនោះសំរាប់ផលិតកម្មស្រូវចំណី។ ទំនាក់ទំនងនេះនាំអោយម្ចាស់ម៉ាស៊ីនកិនស្រូវទទួលបានផលិតផលដោយជាប់លាប់ ហេតុនេះ៖ វាបង្កើននូវភាគរយនៃការកិន និង ផលចំណេញដល់គ្រប់ផ្នែកនៃផលិតកម្មគ្រាប់ពូជ ផលិតកម្មធញ្ញជាតិ និង ការ លក់អង្ករ។

លទ្ធផលនៃការងាររបស់វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍកសិកម្មកម្ពុជា ក្នុងការកំណត់សារៈប្រយោ នៃថ្មផូស្វាតដែលផលិតនៅកន្លែងពីរខុសគ្នាត្រូវបានផ្សព្វផ្សាយទៅដល់កសិករ ដោយការចំណាយរបស់ក្រុមហ៊ុច ផូស្វាត។ ឧទាហរណ៍ដទៃទៀតនៃកិច្ចសហការប្រកបដោយជោគជ័យរួមមានកិច្ចការរបស់វិទ្យាស្ថានស្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប ជាមួយអ្នកផលិតកូនត្រី និង វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍កសិកម្មកម៥ ជាមួយអ្នកផលិតពូជដំណាំ។ អង្គការមិនមែនរដ្ឋាភិបាលក៏មានមុខងារជាអ្នកសំរបសំរួលដ៏សំខាន់ក្នុងការផ្គត់ផង សំភារៈកសិកម្ម ជាពិសេសនៅក្នុងការផ្តល់ពូជថ្មី ការអនុវត្ត និង បច្ចេកវិទ្យា។ ភ្នាក់ងារជាច្រើន (ឧទាហរណ៍ អង្គការក្រៅរដ្ឋាភិបាល សហគ្រាសខ្នាតតូច និងមធ្យមនៅកម្ពុជា និងធនាគារអេស៊ីលីដា) មានឥណទានគ្រប់គ្រាន់ ឬកម្មវិធីអភិវឌ្ឍន៍ ហើយបានប្រើប្រាស់ឥណទាន និងកម្មវិធីទាំងនេះ៖ សំរាប់ជាស្ពានដើម្បីដោះស្រាយបញ្ហាសំភា កសិកម្មដែលចោទឡើងដោយកង្វះឥណទាន និង កម្មវិធីណែនាំ។

តាំងពីដើមឆ្នាំ ១៩៩០ អង្គការមិនមែនរដ្ឋាភិបាលបានដើរតួនាទីយ៉ាងសំខាន់ ពិសេសនៅក្នុងការទេ នាយកដ្ឋានរបស់រដ្ឋាភិបាលក្នុងការផ្សព្វផ្សាយបច្ចេកវិទ្យាបង្កើតឡើងដោយវិទ្យាស្ថានស្រាវជ្រាវ។គេបានវិធី យោគគួរអោយកត់សំគាល់លើការអភិវឌ្ឍអង្គភាព និងសកម្មភាពពង្រឹងសមត្ថភាពក្នុងរង្វង់កសិករ។ ក្រុមកសិករ សមាគមអ្នកផលិត ឥណទានសង្គម និង សមាគមនារី គឺជាឧទាហរណ៍នៃក្រុមដែលបង្កើតឡើង និង គាំទ្រដោយ អង្គការមិនមែនរដ្ឋាភិបាល។ អង្គការមិនមែនរដ្ឋាភិបាល គឺជាប្រភពនិងជាអ្នកសំរបសំរួលពត៌មានបច្ចេកទេស ផ្តល់យោបល់ និងដំបូន្មានដល់កសិករក្នុងពេលដែលកសិករទាំងនោះបំរុងនឹងទទួលយកបច្ចេកទេសពីវិទ្យាស្ថានស្រាវជ្រាវ។ អង្គការក្រៅរដ្ឋាភិបាលតែងតែត្រូវបានបញ្ចូលយ៉ាងទៀងទាត់ទៅក្នុងកម្មវិធីបណ្តុះបណ្តាលរបស់មជ្ឈ មណ្ឌលស្រាវជ្រាវ ដើម្បីបង្កើននូវជំនាញបច្ចេកទេសរបស់គេ ក៏ដូចជាអោយពួកគេចូលរួមក្នុងដំណើរការនៃការលើកអាទិភាពស្រាវជ្រាវ។ អង្គការក្រៅរដ្ឋាភិបាលដែលទទួលបានថវិកាផ្គត់ផ្គង់គ្រប់គ្រាន់ដើម្បីចំណាយលើវិស័យ កសិកម្មនៅក្នុងប្រទេសកម្ពុជារួមមាន ទស្សនៈពិភពលោកអន្តរជាតិ (WVI), CARE, អង្គការជំនួយអភិវឌ្ឍន៍អាត់វែនទីស្តកម្ពុជា (ADRA), ភ្នាក់ងារកាតូលិកសំរាប់ទ្រទ្រង់ និងអភិវឌ្ឍន៍ក្រៅប្រទេស (CARITAS), សេវា ជំនួយកាតូលិក (CRS), គណៈកម្មការសេវាកម្មមិត្តអាមេរិកកាំង (AFSC), សហព័ន្ធឡូតេនពិភពលោក (LWF), និង ពេទ្យសត្វគ្មានព្រំដែន (VSF) ធ្វើកិច្ចការជាសំខាន់លើដំណាំ និងការបង្កើនការចិញ្ចឹមសត្វ ជា បន្ថែមទៅលើបញ្ហាសហគមន៍។ ពត៌មានលំអិតពីស្ថាប័នពាក់ព័ន្ធវិស័យកសិកម្មមានសរសេរលំអិតនៅក្នុងគេហទំព័រដូចតទៅ:

http://www.dac.org.kh/affiliates/affiliates-summaries/wvi-c-print.hu http://www.careinternational.org.uk/cares work/where/cambodia, http://www.adracambodia.org/, http://www.afsc.org/asia/cambodia.htm.

WWW.Iwfcam.org.kh/, និង www.lwfcam.org.kh/

អ្នកស្រាវជ្រាវទទួលបានផលប្រយោជន៍ពីការចូលរួម ក្នុងការបង្កើតនូវសំភារៈសំរាប់ប្រើប្រាស់ក្នុងការ ផ្សព្វផ្សាយបច្ចេកវិទ្យាថ្មី។ សំភារៈទាំងនោះអាចជា "ព្រឹត្តិប័ត្របច្ចេកទេស" ដូចព្រឹត្តិប័ត្រដែលវិទ្យាស្ថានស្រាវ ជ្រាវនិងអភិវឌ្ឍកសិកម្មកម្ពុជាបានធ្វើកន្លងមកនឹងជាពិតមានគ្រប់គ្រាន់ ក្នុងការផ្តល់ប្រតិកម្មអោយអ្នកស្រាវជ្រាវ អំពីការអនុវត្តនូវបច្ចេកវិទ្យាដែលបង្កើតថ្មី។ ព្រឹត្តិប័ត្របច្ចេកទេសទាមទារការប្រើនូវរចនាបទមួយដែលសម ស្របមុនពេលដែលត្រូវបានបញ្ជូនទៅអោយកសិករ ឬភ្នាក់ងារផ្សព្វផ្សាយរបស់ខេត្តនិងស្រុក ហើយព្រឹត្តិប័ត្រទាំង នោះនគួរមាន "នីតិវិធីនៃការអនុវត្តបច្ចេកទេស (TIPs)" ដែលរៀបរៀងដោយ អ្នកឯកទេសនៅក្នុងក្រុមស្រាវជ្រាវ ក្រោមការឧបត្ថម្ភពីនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។ អ្នកឯកទេស និង អ្នកផ្សព្វផ្សាយនៅក្នុងនាយកដ្ឋានជំនាញ នានារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងវិទ្យាស្ថានស្រាវជ្រាវត្រូវ តែធ្វើការជាមួយគ្នាយ៉ាងជិតស្និទ្ធ ដើម្បីធានាអោយមានបច្ចេកវិទ្យាថ្មីដល់កសិករ។ ការផ្សព្វផ្សាយលទ្ធផល ពិសោធន៍ទៅអោយកសិករគួរតែត្រូវបញ្ចូលទៅក្នុងគំរោងស្រាវជ្រាវ ដើម្បីធានាថារាល់ការស្រាវជ្រាវមានការ ទាក់ទងទៅនឹងការផ្សព្វផ្សាយ។

យន្តការទំនាក់ទំនងដែលជួយដល់ការភ្ជាប់ទំនាក់ទំនងបានរឹងមាំរវាងការការស្រាវជ្រាវ និងការផ្សព្វផ្សាយ មាន៖

ក) ការអង្កេតសិក្សារួមគ្នារវាងអ្នកស្រាវជ្រាវ និង អ្នកផ្សព្វផ្សាយនូវបញ្ហារបស់កសិករ
ខ) ការប្រជុំជាប្រចាំ អំពីការស្រាវជ្រាវ និង ការផ្សព្វផ្សាយ (២ ឬ ៣ឆ្នាំម្តង)
គ) ការបោះពុម្ពជាប្រចាំនូវអត្ថបទសរសេរដោយអ្នក ស្រាវជ្រាវ និង អ្នកផ្សព្វផ្សាយ
ឃ) ការបង្ហាញតាមរយៈសិក្ខាសាលានូវសំភារៈដែលបង្កើតឡើងដោយភ្នាក់ងារ ទាំងពីរ
ង) វគ្គបណ្តុះបណ្តាល និង
ច) ទស្សនៈកិច្ចតាមមូលដ្ឋានជាក់ស្តែង។

## ៣.៦.៩. លទ្ធភាពថវិកា ធនធានមនុស្ស មធ្យោបាយស្រាវជ្រាវ សំភារៈនិងបណ្តេញពត៌មានសំរាប់វិទ្យាស្ថានស្រាវជ្រាវធនធានមនុស្ស

ក្នុងឆ្នាំ ២០០៤ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានបុគ្គលិកសរុបទាំងអស់ ៨.៦៩៩ នាក់។ បុគ្គលិកមន្ត្រីទាំងនោះធ្វើការនៅទីស្តីការ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាយកដ្ឋាន វិទ្យាស្ថានស្រាវជ្រាវ_ច្រើនស្ថានសាធារណៈ និងនៅ តាមខេត្ត-ក្រុង។ ៦៦% (៥. ១៨៦ នាក់) ធ្វើការនៅក្នុងមន្ទីរកសិកម្មខេត្ត-ក្រុងហើយសល់ពីនោះគឺស្ថិតនៅក្នុង អង្គភាពនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលស្ទើរតែទាំងអស់មានទីតាំងនៅរាជធានីភ្នំពេញ។ ក្នុងចំណោម បុគ្គលិកសរុបទាំងនេះ៖ ០,៣%, មានសញ្ញាប័ត្របណ្ឌិត ២.៦% អនុបណ្ឌិត ១៧% មានបរិញ្ញាប័ត្រ ២៧%

មាន សញ្ញាប័ត្រមធ្យម និង ៥១,៩% មិនមានសញ្ញាប័ត្រ។ សមាមាត្រដ៏ខ្ពស់នៃអ្នកមានសញ្ញាប័ត្របណ្ឌិតគឺបច្ចុប្បន្ន កំពុងធ្វើការនៅវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា។ ភាគច្រើននៃអ្នកមានសញ្ញាប័ត្រ អនុបណ្ឌិត (២២២នាក់) ធ្វើការនៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅការិយាល័យថ្នាក់កណ្តាលលើការងារគ្រប់គ្រង និង កិច្ចការរដ្ឋបាល។ មានត្រឹមតែ ២២ នាក់ប៉ុណ្ណោះនៃអ្នកមានសញ្ញាប័ត្រអនុបណ្ឌិត បំពេញការងារ នៅថ្នាក់ខេត្ត។

ចំនួនដ៏ខ្ពស់ នៃអ្នកមានសញ្ញាប័ត្របណ្ឌិតនៅវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា បើប្រៀប ធៀបជាមួយវិទ្យាស្ថានដទៃទៀត គឺជាលទ្ធផលនៃការផ្តត់ផ្គង់ថវិកា ប្រមូលផ្តុំដោយគំរោងអភិវឌ្ឍន៍ក្នុងទសវត្ស ១៩៩០ ដើម្បីបង្កើតឡើងនូវការស្រាវជ្រាវដំណាំនិងការអភិវឌ្ឍ។ អ្នកមានសញ្ញាប័ត្រក្រោយឧត្តមស្ទើរតែទាំងអស់របស់ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា និង នាយកដ្ឋានដទៃទៀត របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានបញ្ចប់ការសិក្សាថ្នាក់ក្រោយឧត្តមរបស់គេតាមរយៈការស្រាវ ជ្រាវជាជាងការសិក្សាមេរៀន។ ចំនួននិងគុណភាពបុគ្គលិករបស់វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍកសិកម្មកម្ពុជា គឺមានគ្រប់គ្រាន់ដើម្បីដឹកនាំការស្រាវជ្រាវកសិកម្មលើអនុវិស័យដំណាំនៅពេលអនាគត។ ទោះបីជាយ៉ាងណាក៏ ដោយអង្គភាពស្រាវជ្រាវកម្ពុជាដទៃទៀតត្រូវការជួល ឬ បណ្តុះបណ្តាលបុគ្គលិកអោយមានសញ្ញាប័ត្រខ្ពស់ ដើម្បី លើកស្ទួយកំរិតបទពិសោធន៍នៃការស្រាវជ្រាវ។ ទិន្នន័យបានមកពីនាយកដ្ឋានបុគ្គលិក និង អភិវឌ្ឍធនធានមនុស្ស បង្ហាញនូវកង្វះអ្នកមានសញ្ញាប័ត្រខ្ពស់ក្នុងវិទ្យាស្ថានស្រាវជ្រាវក្រៅពីវិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍កសិកម្ម កម្ពុជា។

ជំរើសដទៃទៀតដើម្បីធ្វើអោយប្រសើរឡើងនូវប្រសិទ្ធភាពនៃប្រពន្ធ័ស្រាវជ្រាវ គឺធ្វើយ៉ាងណាអោយ អង្គភាពស្រាវជ្រាវតូច១បង្កើនទំនាក់ទំនងជាមួយអង្គភាព ដែលមានបុគ្គលិកប្រកបដោយគុណភាពដើម្បីជួយក្នុង ការរៀបចំការងារស្រាវជ្រាវ វិភាគ និង ធ្វើរបាយការណ៍។

ប្រាក់បៀវត្សរដ្ឋាភិបាលដែលប្រែប្រួលពី ២០ ទៅ៤០ដុល្លាក្នុងមួយខែ គឺមិនគ្រប់គ្រាន់ដើម្បីរក្សាទុក បុគ្គលិកស្រាវជ្រាវដែលមានគុណភាពខ្ពស់បានឡើយ។ អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិអោយប្រាក់បៀវត្សដល់ បុគ្គលិករបស់គេពី ២០០ ទៅ ៣០០ ដុល្លាក្នុងមួយខែសំរាប់បុគ្គលិកស្រាវជ្រាវដែលមានបទពិសោធន៍ និងពី ៣០០ ទៅ ៤៥០ ដុល្លាក្នុងមួយខែសំរាប់បុគ្គលិកគ្រប់គ្រង។ នេះជាកិរិតមួយសមស្របសំរាប់រក្សាបានទាំងបុគ្គលិកស្រាវ ជ្រាវ និង បុគ្គលិកគ្រប់គ្រង។ បុគ្គលិករដ្ឋខ្លួនទទួលការឧបត្ថម្ភប្រាក់បៀវត្សបន្ថែមពីគំរោង និង កម្មវិធីអភិវឌ្ឍន៍ | មួយចំនួន។ ថវិកាឧបត្ថម្ភបន្ថែមគឺអាចរកបាននៅតាមគ្រឹះស្ថានសាធារណៈដូចជាវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា សាកលវិទ្យាលយ័ភូមិន្ទកសិកម្ម សាលាជាតិកសិកម្មព្រែកលៀប និង សាលាជាតិកសិកម្មកំពង់ចាម។ បើគ្មានការឧបត្ថម្ភបន្ថែមលើប្រាក់បៀវត្ស ឬ ក៏បង្កើនកំរិតប្រាក់បៀវត្ស រដ្ឋាភិបាល បុគ្គលិកអាចនឹងស្វែងរកការងារនៅកន្លែងដទៃទៀត។

ការស្រាវជ្រាវកសិកម្មធ្វើនៅខាងក្រៅវិទ្យាស្ថានរបស់រដ្ឋាភិបាល រាប់បញ្ចូលការងារទាំងអស់ដែលបានធ្វើ ដោយវិសយ័ឯកជន អង្គការក្រៅរដ្ឋាភិបាល និង តាមរយៈគំរោងអភិវឌ្ឍន៍។ បុគ្គលិក CelAgrid ដែលមាន អតីតភាពការងារនៅសាកលវិទ្យាល័យកសិកម្មត្រូពិកដឹកនាំសារណានិស្សិតអនុបណ្ឌិត និងទទួលថវិកាពីវិទ្យាស្ថាន បណ្តុះបណ្តាលអន្តរជាតិដើម្បីគាំទ្រសកម្មភាពទាំងនេះ៖ "។

បុគ្គលិកអង្គការក្រៅរដ្ឋាភិបាលជាទូទៅទទួលប្រាក់បៀ វត្សខ្ពស់ជាងបុគ្គលិករដ្ឋាភិបាល។ បុគ្គលិកសហគ្រាសឯកជនក៏ទទួលបាននូវអត្ថប្រយោជន៍បន្ថែមទៀតដែរ។

**សម្ភាររដ្ឋបាល** វិទ្យាស្ថានស្រាវជ្រាវរបស់រដ្ឋាភិបាលសំរាប់ដំណាំ (វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ កសិកម្មកម្ពុជា) ការចិញ្ចឹមសត្វ ( មជ្ឈមណ្ឌលជាតិស្រាវជ្រាវសុខភាពនិងផលិតកម្មសត្វ) ជលផល (វិទ្យាស្ថាន ស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលទឹកសាប) កៅស៊ូ (វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា) ការអប់រំ (សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មព្រែកលៀប និង សាលាជាតិកសិកម្មកំពង់ចាម) មានអគារចាប់ផ្តើម ពីកំរិតល្អ (សាលាកសិកម្មជាតិកំពង់ចាម)ទៅល្អប្រសើរ វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា) សំរាប់ គ្រប់គ្រងតំរូវការនៃការស្រាវជ្រាវ។ អង្គភាពស្ទើរតែទាំងអស់នេះ៖ ) បានកសាងអគារថ្មី ក្នុងរយៈពេល ៥-១០ ឆ្នាំកន្លងមក។ អគាររដ្ឋបាលថ្មីនឹងមិនត្រូវការសាងសង់បន្ថែមទៀតឡើយចំពោះនអង្គភាពទាំងនេះក្នុងពេលអនាគត ដ៏ខ្លីខាងមុខ។ សម្ភារៈនៅនាយកដ្ឋានកសិ-ឧស្សាហកម្មនៅមានកំរិត ប៉ុន្តែអាចគ្រប់គ្រាន់សំរាប់បុគ្គលិក ២៥ នាក់ របស់នាយកដ្ឋាន។ តំរូវការបន្ទប់បន្ថែមអាចនឹងមានការកើនឡើងទៅអនាគតនៅពេលដែលព្រីនស្ថានទាំងនេះ៖ ពង្រីកកម្មវិធីស្រាវជ្រាវរបស់ខ្លួន។

**សម្ភារៈមន្ទីរពិសោធន៍** បច្ចុប្បន្នមន្ទីរពិសោធន៍ទាំងអស់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលរងនូវវិបត្តិខ្លះៗពី ២) កង្វះខបុគ្គលិកដែលមានការបញ្ចុះបណ្តាល ខ) កង្វះ៖ឧបករណ៍ ៨) សម្ភារៈមន្ទីរពិសោធន៍ មិនល្អ និង ឃ) កង្វះខាតថវិកាដំណើរការ។ មន្ទីរពិសោធន៍របស់វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជាជាឧទាហរណ៍ គឺស្ថិតនៅក្នុងអគារថ្មី ទាមទារអោយដាក់តម្លើងឧបករណ៍បឺតចំហាយ និង ឧបករណ៍សុវត្ថិភាព។ វិទ្យាស្ថានក៏មិនមានបុគ្គលិកដែលទទួលការបញ្ចុះបណ្តាល និងមានសមត្ថភាពដើម្បីដំណើរការឧបករណ៍ថ្មីៗ ប. សារជាតុគីមីវិភាគគ្រប់គ្រាន់សំរាប់ការវិភាគ។ នាយកដ្ឋានក្សេត្រសាស្រ្តនិងកែលំអដីកសិកម្មមានបុគ្គលិកបព. បណ្តាលល្អៗ ប៉ុន្តែមានឧបករណ៍ចាស់បាក់បែក ហើយវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលទឹកសាបមាន, ពិសោធន៍ធំទូលាយ ប៉ុន្តែគ្មានឧបករណ៍ដាក់បំពេញ។ វិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្រ្តព្រៃឈើ និងសត នាយកដ្ឋានគ្រឿងយន្តកសិកម្ម និងនាយកដ្ឋានកសិ-ឧស្សាហកម្ម គ្មានមន្ទីរពិសោធន៍ធំ និង គ្មានឧបករណ៍ពិសោធន៍។

មន្ទីរពិសោធន៍មាននៅគ្រប់នាយកដ្ឋានបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង វិទ្យាស្ថានស្រាវជ្រាវ លើកលែងតែវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្រ្តព្រៃឈើ និងសត្វព្រៃ នាយកដ្ឋានគ្រឿងយន្ត កសិកម្ម និងនាយកដ្ឋានកសិ-ឧស្សាហកម្ម។ វាមិនជាការចាំបាច់សំរាប់នាយកដ្ឋានគ្រឿងយន្តកសិកម្ម និង នាយកដ្ឋានកសិ-ឧស្សាហកម្ម ត្រូវមានមន្ទីរពិសោធន៍សំរាប់វិភាគ ដើម្បីឆ្លើយតបនឹងកំរិតការស្រាវជ្រាវបច្ចុប្បន្ន នៅនាយកដ្ឋានទាំងពីរនេះ ប៉ុន្តែឧបករណ៍មូលដ្ឋានមួយចំនួនដែលចាំបាច់សំរាប់វិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្រ្ត ព្រៃឈើនិងសត្វព្រៃត្រូវតែមានដើម្បីដំណើរការប្រកបដោយប្រសិទ្ធភាព។ សម្ភារៈទាំងនោះអាចជាមីក្រូទស្សន៍ និងឧបករណ៍ដទៃទៀតសំរាប់វាស់វែងកំរិតលូតលាស់របស់ដើមឈើ និងដង់ស៊ីតេឈើ។ បន្លះសាច់ឬគ្រោងឆ្អឹង សត្វព្រៃ ក្រោយពីការស្លាប់អាចធ្វើការវិភាគពិសោធន៍បាននៅមជ្ឈមណ្ឌលជាតិស្រាវជ្រាវសុខភាពនិងផលិតកម្ម សត្វ។ នាយកដ្ឋាន

កសិ-ឧស្សាហកម្មអាចត្រូវការសាងសង់មន្ទីរពិសោធន៍ក្នុងពេលអនាគត ប្រសិនបើកម្មវិធីស្រាវ ជ្រាវរបស់គេត្រូវពង្រីកដូចការគ្រោងទុក។

ទាំងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្ម និង វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ក្នុងពេលថ្មីៗនេះ សុទ្ធតែ ឬ កំពុងសាងសង់មន្ទីរពិសោធន៍សំរាប់ធ្វើតេស្តគ្រាប់ពូជ ដី និងទឹក។ មធ្យោបាយ ពិសោធន៍ដូចគ្នានេះក៏មានដែរនៅសាកលវិទ្យាលយ័ភូមិន្ទកសិកម្ម ប៉ុន្តែក្នុងកំរិតខ្នាតតូច ,។ សេចក្តីត្រូវការមធ្យោ បាយស្រាវជ្រាវដូចគ្នាអាចចៀសវាងបាន បើសិនជាសំណាកមកពីគ្រប់វិស័យត្រូវបានបញ្ជូនទៅមន្ទីរពិសោធនមួយ សំរាប់ធ្វើវិភាគ។ ដំណោះស្រាយរបៀបនេះនក៏អាចអនុវត្តបានដែរសំរាប់ការវិភាគថ្នាំពុល និងកាកសំណលថ្នា"

ការចំណាយយ៉ាងធំលើអគារ និង សម្ភារៈនាទសវត្សកន្លងមក ពុំបានធ្វើអោយប្រព័ន្ធមន្តពលោក ភាពគ្រប់គ្រាន់ និង មានប្រសិទ្ធភាពសំរាប់ការស្រាវជ្រាវនិងអភិវឌ្ឍន៍ឡើយ។ កង្វះថវិកាដំណើរការបង្កជ ដល់គ្រប់សកម្មភាពនៃមន្ទីរពិសោធន៍ទាំងអស់នៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើកលេ ស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាដែលអាចទាមទារអោយឧស្សាហកម្មកៅស៊ូបង់ថវិកានិងរក្សាថវិកាអោយវិទ្យា សំរាប់សេវាកម្មរបស់គេ។ មន្ទីរពិសោធន៍ដទៃទៀតទាំងអស់មិនមានសារធាតុគីមីវិភាគគ្រប់គ្រាន់ដើម្បីដំណើរអោយបានសមស្របនូវសេវាកម្មរបស់ខ្លួនឡើយ។ មន្ទីរពិសោធន៍ស្ទើរតែទាំងអស់ពឹងផ្អែកថវិកានៃគំរោងពិសេស ណាមួយដើម្បីទិញនូវសារធាតុគីមីចាំបាច់។ បញ្ហាទាំងនេះនាំអោយមានការពន្យាពេលកង្វះខាតនូវភាពបន្តនឹង ស្ថេរភាព និងមិនអាចសំរេចនូវកិច្ចការពិសោធន៍ខ្លួន។ កង្វះខាតថវិកាសំរាប់ដំណើរការក៏កំរិតផងដែរនូវចំនួន សំណាកដែលត្រូវបញ្ជូនមកមន្ទីរពិសោធន៍ និងបន្ថយប្រសិទ្ធភាពនៃដំណើរការនៃមន្ទីរពិសោធន៍។ បញ្ហានេះអាច ដោះស្រាយបានប្រសិនបើមន្ទីរពិសោធន៍អាចយកថ្លៃសំរាប់សេវាកម្ម ហើយកំរនេះត្រូវបានយកមកវិនិយោគឡើង វិញទៅក្នុងមន្ទីរពិសោធន៍។

ការប្រើរួមគ្នានូវមធ្យោបាយស្រាវជ្រាវរវាងវិទ្យាស្ថានអាចកើនឡើងបាន។ ក្នុងពេលបច្ចុប្បន្នគេអាចផ្ទេរ ថវិកាពីនាយកដ្ឋានមួយទៅនាយកដ្ឋានមួយទៀតក្នុងក្រសួងតែមួយ ដោយប្រើលិខិតបទដ្ឋានមានស្រាប់របស់រាជ រដ្ឋាភិបាល ក្រសួង។ ទោះជាយ៉ាងនេះក៏ដោយ ការផ្ទេរថវិការបៀបនេះច្រើនមានភាពយឺតយ៉ាវជាងការបង់ប្រាក់ ដោយផ្ទាល់ដើម្បីទិញភ្លាម១នូវធាតុគីមី ឬ ឧបករណ៍ដែលចាំបាច់សំរាប់វិភាគសំណាកដែលរង់ចាំ។ ការបង់ប្រាក់ គឺជាការចាំបាច់សំរាប់មន្ទីរពិសោធន៍ជាច្រើន។ ជាឧទាហរណ៍ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាត្រូវបង់ប្រាក់ ទៅអោយនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្មសំរាប់ការវិភាគដី។ ស្តង់ដារនៃការបង់ប្រាក់សំរាប់ការ វិភាគនិងត្រូវពិចារណារៀបចំជាចំហ។ វិទ្យាស្ថានរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងធ្វើសនិទាន កម្មទៅលើការវិភាគមួយចំនួនដែលធ្វើឡើងនៅក្នុងមន្ទីរពិសោធន៍និមួយៗ ហើយរៀបចំប្រព័ន្ធគិតកំរៃដើម្បីបង្កើន ប្រសិទ្ធភាព និង កាត់បន្ថយមធ្យោបាយស្រាវជ្រាវដែលមានដូចៗ គ្នានៅតាមអង្គភាពនីមួយៗ។

**ឧបករណ៍បន្ទីរពិសោធន៍** បន្ទាប់ពីឧបករណ៍ថ្មីៗដែលទិញដោយ វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍកសិកម្ម កម្ពុជា និងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្ម ត្រូវបានតំឡើងនៅក្នុងមន្ទីរពិសោធន៍របស់គេ ឧបករណ៍ សំរាប់មន្ទីរពិសោធន៍និងកែវពិសោធន៍សំរាប់ការវិភាគកំរិតស្តង់ដារ គឺ

គ្រប់គ្រាន់សំរាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការវិភាគដទៃទៀតដូចជាការកំណត់ពេគ វិនិច្ឆ័យនៃជម្ងឺផ្តាសាយបក្សីថ្មីៗនេះអាចធ្វើនៅវិទ្យាស្ថាន ប៉ាស្ទ័រ វិទ្យាស្ថានជាតិសុខភាពសាធារណៈ ឬ ក៏ធ្វើទៅក្រៅប្រទេស។ នៅចុងឆ្នាំ ២០០៥ ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ នឹងមាន ឧបករណ៍គ្រប់គ្រាន់សំរាប់ធ្វើពេគវិនិច្ឆ័យនៃជម្ងឺសត្វនិងត្រី ការវិភាគគុណភាពទឹក ចំណីអាហារគ្រាប់ ពូជ ដី ថ្នាំសំលាប់សត្វល្អិត និង ការវិភាគដីនិងកាកសំណល់នៅក្នុងដី។ អាស្រ័យទៅលើចំនួន សំណាកនៃការវិភាគក្នុងពេលបច្ចុប្បន្ននៅតាមមន្ទីរពិសោធន៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទមិនចាំ បាច់មានឧបករណ៍វិភាគទំនើប ស្វ័យប្រវត្តិ និង ឧបករណ៍ថ្លៃៗ ដទៃទៀតក្នុងចំនួនដ៏ ច្រើននោះឡើយ លើកលែងតែ កំរិតនៃការស្រាវជ្រាវមានការកើនឡើង។

**បណ្តាញពត៌មានៈ** អាចជាប្រពន្ធ័ធម្មតា (ឧទាហរណ៍ សំបុត្រ បណ្ណាល័យ) អេឡិចត្រូនិក (ទូរស័ព្ទ ទូរស័ព្ទចលត័ វិទ្យុ ទូរទស្សន៍ ឧបករណ៍ផ្ញើសារ) ឬ កុំព្យូទ័រ (ឧទាហរណ៍ : សារអេឡិចត្រូ និក គេហទំព័រ) សំរាប់ព័ត៌មានទំនាក់ទំនង។

នៅលើមូលដ្ឋានថ្នាក់ជាតិ កម្ពុជាមិនមានធនធានគ្រប់គ្រាន់សំរាប់ពត៌មាន និង បច្ចេកវិទ្យា ទំនាក់ទំនង ការចំណាយលើបណ្តាញព័ត៌មាន បើប្រៀបធៀបជាមួយប្រទេសដទៃទៀតលើពិភពលោ ក។ ឧទាហរណ៍ ប្រជា កម្ពុជាចំនួន ១000នាក់ ប្រើប្រាស់ទូរស័ព្ទខ្សែ២គ្រឿង ដែលសមាមាត្រនេះគឺ សំរាប់មនុស្ស ៥០២នាក់ នៅមាន ខាងកើតនិងប៉ាស៊ីហ្វិកខាងត្បូង។ សមាមាត្ររវាងប្រជាជន ១000 នាក់ ជាមួយនឹងចំនួនសម្ភារៈដទៃទៀត +

ប្រៀបធៀបកម្ពុជាទៅនឹងអាស៊ីខាងកើតនិងប៉ាស៊ីហ្វិកគឺៈ ចំនួនកុំព្យូទ័រ (កម្ពុជា : អាស៊ីខាង កើតនិងប៉ាស៊ីហិត, ១.៥:១៩ វិទ្យុ- ១១៩:២៨៧ និង ទូរទស្សន៍- ៨:២៦៦ (ធនាគារពិភពលោក ២០០២)។

២ (ទោះបីជាមានស្ថិតិដ៏អន់ថយក៏ដោយ បុគ្គលិកវិទ្យាស្ថានស្រាវជ្រាវនិងផ្សព្វផ្សាយ ប្រើ ប្រាស់ទូរស័ព្ទចល័ត សំរាប់កិច្ចការប្រចាំថ្ងៃរបស់គេ។ ទំនាក់ទំនងដោយពាក្យសំដីរវាងអ្នកស្រាវជ្រាវគឺ មិនមានការលំបាកឡើយ។ អ្នកស្រាវជ្រាវស្ទើរតែទាំងអស់ចេះប្រើកុំព្យូទ័រ ហើយពួកគេក៏មានកុំព្យូទ័រ និងប្រើសារអេឡិចត្រូនិក , និងមិន ជីណែត .។ ម្យ៉ាងទៀតសេវាទាំងនេះអាចទូទាត់ដោយតម្លៃថោក (ដោយស្តង់ដារអន្តរជាតិ) តាមរយៈការប្រើ ប្រាស់អ៊ិនធឺណែតនៅតាមហាងអិនធឺណែតកាហ្វេ ដែល មាននៅក្នុងទីក្រុង និងទីប្រជុំជនរបស់ខេត្ត។

ទោះបីជាមានចំនួនតិចតួច ការផ្សាយរបស់របស់វិទ្យុ និងទូរទស្សន៏ មានភាពទូលំទូលាយនៅ កម្ពុជា ហើយព្រឹត្តិការណ៍សំខាន់ៗនៅវិទ្យាស្ថានស្រាវជ្រាវ ឬ ការផ្សព្វផ្សាយនៃទិវាស្រែបង្ហាញ ក៏ដូចជា ការបណ្តុះបណ្តាល ទទួលបានការផ្សាយយ៉ាងល្អពីបណ្តាញវិទ្យុ ឬ ទូរទស្សន៍ ត្រួតពិនិត្យដោយរដ្ឋាភិ បាល ឬ ឯកជន។

បណ្តាញបណ្ណាល័យជារបៀបប្រពៃណី ដែលបង្កើតនៅតាមនាយកដ្ឋានរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងអំឡុងដើមទសវត្ស ១៩៩០ មានការរៀបចំនិងថែទាំមិនបានល្អ ប៉ុន្តែក្នុង ពេលបច្ចុប្បន្នគ្រប់ឯកសារ ពីវិស័យកសិកម្មទាំងអស់ត្រូវបានទុកនៅក្នុងមជ្ឈមណ្ឌលឯកសារដែលទើប បង្កើតឡើងថ្មីនៅក្នុងទីស្តីការក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ វិទ្យាស្ថានស្រាវជ្រាវនិង

អភិវឌ្ឍន៍កសិកម្មកម្ពុជាមានបណ្ណាល័យមួយយ៉ាង ធំសំរាប់ប្រទេសកម្ពុជាអំពីដំណាំស្រូវ និងដំណាំក្សេត្រសាស្ត្រដទៃទៀត។ ទោះបីជាយ៉ាងណាក៏ដោយការថត ចម្លងឌីជីថលនៃឯកសារ និងព័ត៌មានដទៃទៀតកំពុងពេញនិយម ហើយវានឹងជំនួសឯកសារក្រដាសក្នុងពេលឆាប់ៗខាងមុខ។

កំរិតនៃអក្ខរកម្មគឺប្រហែល ៧០% ទូទាំងប្រទេស ហើយផ្ទាំងបដារួមទាំងឯកសារដែលចែកផ្សាយ ផ្នែកមួយនៃប្រពន្ធ័ផ្សព្វផ្សាយដែលប្រើប្រាស់នៅជនបទនៃប្រទេសកម្ពុជា។

## ៣.៦.១០.បទពិសោធន៍នៃប្រទេសដទៃនៅអាស៊ីក្នុងការពង្រឹងការស្រាវជ្រាវកសិកម្មជាតិ

ផ្អែកលើប្រវត្តិសាស្ត្រថ្មីៗ កន្លងមក កម្ពុជាមិនបានចូលរួមពេញលេញនៅក្នុងព្រឹត្តិការណ៍សំខាន់ៗ ជាច្រើនពាក់ពន្ធ័ទៅនឹងការស្រាវជ្រាវកសិកម្មនៅក្នុងតំបន់ហើយលើសពីនេះទៅទៀតនៅក្នុងកិច្ចអភិវឌ្ឍន៍ដែលបានដំណើរ ការជាងកន្លះសតវត្សកន្លងមក។ ប្រទេសកម្ពុជាមានឱកាសក្នុងការទាញផលចំណេញពីបទពិសោធន៍នៃប្រពន្ធ័ ស្រាវជ្រាវកសិកម្មជាតិរបស់ប្រទេសដទៃ ក៏ដូចជាការជ្រើសរើសវិធីសាស្ត្រ និងទំរង់ដែលឆ្លើយតបយ៉ាងល្អបំផុត ទៅនឹងតំរូវការសមត្ថភាពរបស់ប្រទេស។

ព្រឹត្តិការណ៍ក្នុងវិស័យកសិកម្មដែលបានកើតមានឡើងជាង ៤០ ឆ្នាំកន្លងមកមានការវិវត្តគួរអោយកត់ សំគាល់។ ទសវត្ស ១៩៦០ និង ១៩៧០ ត្រូវបានកត់សំគាល់ដោយការគាំទ្រជាថវិកាដោយអ្នកផ្តល់ជំនួយ និង ទទួលការដឹកនាំបច្ចេកទេសដោយមជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មអន្តរជាតិ។ ការគាំទ្រនៅតែបន្តចំពោះប្រពន្ធ័ ! ស្រាវជ្រាវកសិកម្មជាតិក្នុងអំឡុងទសវត្ស ១៩៨០។ នាទសវត្ស ១៩៩០ ម្ចាស់ជំនួយខ្លួនដូចជាភ្នាក់ងារអភិវឌ្ឍន៍ អន្តរជាតិសហរដ្ឋអាមេរិក (USAID) បានប្រានចោលជំនួយសំរាប់វិស័យកសិកម្ម។ ក្នុងពេលថ្មីៗនេះមានការចាប់ អារម្មណ៍ឡើងវិញដល់ការគាំទ្រការស្រាវជ្រាវកសិកម្ម ប៉ុន្តែការផ្លាស់ប្តូរដែលគួរអោយកត់សំគាល់គឺការងាកចេញ ពីវិធីសាស្ត្រដែលផ្តោតតែទៅលើ អនុវិសយ័កសិកម្មណាមួយ មកជាការផ្តោតទៅលើប្រពន្ធ័កសិកម្ម។ Cheema et al. (2003) បង្ហាញនូវលក្ខណៈរួមនៃប្រពន្ធ័ស្រាវជ្រាវនាពេលបច្ចុប្បន្នដូចខាងក្រោម :

១. អនុវត្តន៍ការពិភាក្សាផ្តល់ទឡ្ហីករណ៍ល្អ១ (ធ្វើឯកជនភាវូបនីយកម្មក្នុងករណីមានលទ្ធភាពទៅលើការងារស្រាវជ្រាវដែលឧបត្ថម្ភថវិកាដោយរដ្ឋាភិបាល និង ការបំបែកចេញនូវខ្ទង់ថវិកាសំរាប់ស្រាវជ្រាវកំណត់អាទិភាព និង អនុវត្តន៍ផែនការ។

២. ការធ្វើវិមជ្ឈការនៃការស្រាវជ្រាវកសិកម្មទៅតាមលក្ខណភូមិសាស្ត្រ និង ការសំរេចចិត្ត

៣. ការចូលរួមនៃស្ថាប័នពាក់ពន្ធ័ទាំងការរៀបចំការអនុវត្ត ការត្រួតពិនិត្យថវិកា និង លទ្ធភាពនៃសហហិរញ្ញប្បទានសំរាប់ការងារស្រាវជ្រាវ

៤. ការផ្តោតលើការផ្តល់ហិរញ្ញប្បទាន ឬ សហហិរញ្ញប្បទាន ដោយអ្នកទទួលផលប្រយោជន៍ដោយផ្ទាល់ (ថវិកាត្រូវបង់ គំរោងថវិកាជំនួយឥតសំណង។ល។) និងថវិកាសំរាប់ស្រាវជ្រាវតាមរយៈការប្រកួតប្រជែង។

៥. ពង្រឹងការចងសម្ពន្ធ័ភាពរវាងទីភ្នាក់ងារស្រាវជ្រាវ (ជាតិ តំបន់ និងអន្តរជាតិ) រវាងការស្រាវជ្រាវផ្សព្វផ្សាយ និង កសិករ (តំរូវនៃចំណេះដឹងកសិកម្មនិងប្រពន្ធ័ព័ត៌មាន-AKIS) និងរវាងដៃគូ

ទាំងអស់ដែលអាចមាននៅក្នុងដំណើរការនៃការច្នៃប្រឌិតបង្កើតថ្មីរួមមាន អង្គការសង្គមស៊ីវិល ពាណិជ្ជករ ឧស្សាហកម្មផលិតកម្ម និង ឧស្សាហកម្មសម្ភារៈកសិកម្ម និងឧស្សាហកម្មកែច្នៃ (គំរូនៃ ប្រពន្ធ័ជាតិសំរាប់ការបង្កើតថ្មី- NS)។

មេរៀនសំខាន់ៗពីព្រឹត្តការណ៍នៃទសវត្សចុងក្រោយនេះ៖ បង្ហាញថារដ្ឋាភិបាលនៃប្រទេសកំពុងអភិវឌ្ឍន៍ គួរតែប្រុងប្រយត្ន័ក្នុងការចូលរួមនៅក្នុងតំពេងដែលត្រូវការចំណាយខ្ពស់ទៅលើហេដ្ឋារចនាសម្ពន្ធ័។ ការអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងធ្វើឡើងសំរាប់ការចាំបាច់ក្នុងពេលបច្ចុប ជាជាងតំរូវការនាពេលអនាគត។

បញ្ហាដែលគួរយកចិត្តទុកដាក់ដល់ការអភិវឌ្ឍប្រព័ន្ធស្រាវជ្រាវ នៅក្នុងករណីនៃប្រទេសកម្ពុជាគឺទំហំនៃ ប្រទេស។ ប្រទេសកម្ពុជាគឺជាប្រទេសតូចដែលមានប្រពន្ធ័ស្រាវជ្រាវកសិកម្មជាតិក្មេងខ្ចី បើប្រៀបធៀបទៅ បណ្តាប្រទេសក្នុងតំបន់ (អាស៊ីភាគខាងត្បូង និង ខាងកើត) ដែលជាប្រទេសធំមានប្រជាជនច្រើន និង មានប្រ ស្រាវជ្រាវចំណាស់។ សេដ្ឋកិច្ចនៃប្រទេសកម្ពុជាត្រូវតែគាំទ្រសេវាកម្មស្រាវជ្រាវរបស់ខ្លួន ហើយ ៨. ស. ស គួរតែ មានឥទ្ធិពលទៅលើទំហំនៃប្រពន្ធ័ស្រាវជ្រាវកសិកម្មជាតិ។ ក្នុងឆ្នាំ ២០០៣ ភាគរយនៃ ផ.ស.ស ដែលចំណាយ ទៅលើវិស័យកសិកម្មនៅក្នុងប្រទេសកម្ពុជាគឺ ០. ២៣% (World Bank, ២០០៤ )។ ការចំណាយរបស់បណា ប្រទេសនៅអាស៊ីអាគ្នេយ៍ទៅលើវិស័យកសិកម្មគឺ ០.៥៨% នៃ ផ.ស.ស ជាតិ។ ផ្អែកលើតួលេខនេះរាជរដ្ឋាភិបាល កម្ពុជាគួរវិនិយោគបន្ថែមលើការអភិវឌ្ឍវិស័យកសិកម្ម។ ការវិនិយោគបន្ថែមនេះពុំត្រូវគិតដល់ថវិកាជំនួយដែល ទទួលបានពីប្រទេសម្ចាស់ផ្តល់ជំនួយឡើយ។ បច្ចុប្បន្នថវិកាប្រតិបត្តិការសំរាប់ការងារស្រាវជ្រាវមិនគ្រប់គ្រាន់ឡើយ និង អាចបង្កើនតាមរយៈការប្រើប្រាស់សំភារៈ ឧបករណ៍ និង បុគ្គលិកមន្ត្រីមានស្រាប់បច្ចុប្បន្ន។

វាកាន់តែមានភាពសុក្រឹតបើគេពិចារណាដល់ ការខ្ចី/ចំលង * បច្ចេកវិទ្យា និង ការអនុវត្តដែលបានធ្វើ អោយល្អប្រសើររួចទៅហើយដោយប្រពន្ធ័ស្រាវជ្រាវកសិកម្មជាតិ មជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មអន្តរជាតិ និង ប្រភពផ្សេងៗទៀតនៃពត៌មានបែបនេះ៖ រហូតដល់ពេលដែលរដ្ឋាភិបាលមានលទ្ធភាពគាំទ្របានទាំងស្រុងដល់ប្រព័ន្ធ ស្រាវជ្រាវនេះ៖។ អ្នកផ្តល់ជំនួយទំនងជាមិនអាចជួយជាថវិកាសំរាប់ការចំណាយស្នូលក្នុងកំរិតជាដុំកំភួនបានឡើយ ( ដោយឡែកពីការផ្តល់ថវិកាចំណាយដោយប្រយោលនៅក្នុងកិច្ចសន្យា និងជំនួយឥតសំណងសំរាប់គំពេងស្រាវ ! ជ្រាវជាក់លាក់ណាមួយ) ប៉ុន្តែអាចផ្តលវិភាគទានដល់ចំណាយប្រតិបត្តិការ។

ប្រទេសបង់ក្លាដែស បានទទួលយកនូវបច្ចេកវិទ្យាដែលមានចរិតលក្ខណៈជាបដិវត្តន៍បែតងតាមរយៈ ប្រពលវប្បកម្ម និង ការប្រើប្រាស់យ៉ាងទូលំទូលាយនូវបច្ចេកវិទ្យាដែលល្អប្រសើរ ដោយសារប្រទេសនេះមិន ផ្ទៃដីនៅសល់សំរាប់ផលិតកម្មកសិកម្ម។ នៅប្រទេសដទៃទៀត បទពិសោធន៍បង្ហាញថា ការស្រាវជ្រាវ។ គួរតែធ្វើឡើងនៅកំរិតក្នុងមូលដ្ឋាន ដោយមានការចូលរួមពីអតិថិជន អ្នកផលិត អ្នកកែច្នៃ។ល។

វិមជ្ឍការគឺជាមធ្យោបាយមួយនៃការដោះស្រាយភាពចំរុះ។ ទោះជាយ៉ាងនេះក្តី វិមជ្ឍការដើមប្រសិទ្ធភាពនៃប្រពន្ធ័ស្រាវជ្រាវកសិកម្មទាមទារនូវមជ្ឈមណ្ឌលដ៏រឹងមាំមួយដើម្បីសំរបសំរួល និងដឹ ស្រាវជ្រាវ។ ប្រទេសថៃ និងឥណ្ឌូណេស៊ី ផ្តល់នូវបទពិសោធន៍ផ្ទុយស្រឡះពីគ្នាចំពោះវិមជ្ឈការ។ ប្រទេសថៃ

ទទួលបានជោគជ័យបង្គួរក្នុងការគ្រប់គ្រងប្រពន្ធ័រមជ្ឈការជំទូលាយ តាមរយៈការមានមជ្ឈមណ្ឌលរឹងមាំ។ ជួយ ទៅវិញនៅប្រទេសឥណ្ឌូណេស៊ីមិនមានមជ្ឈមណ្ឌលរឹងមាំណាមួយឡើយ ហើយទំនាក់ទំនងដែលជាភាពចាំបាច់ ដើម្បីការសំរបសំរួល និង ស្ថេរភាពការងារនៃផ្នែកផ្សេង១ គឺមានភាពទន់ខ្សោយ ឬ ក៏មិនមានតែម្តង។

មានការប៉ុនប៉ងនៅក្នុងប្រទេសជាច្រើន ជាពិសេសនៅក្នុងបណ្តាប្រទេសនៃអាមេរិកឡាទីន និង ថ្មីៗនេះ នៅក្នុងប្រទេសអាហ្វ្រិកខាងលិចក្នុងការធ្វើអោយប្រពន្ធ័ស្រាវជ្រាវកសិកម្មជាតិអាចទ្រទ្រង់ខ្លួនឯងបាន។ ការប៉ុន ប៉ឹងទាំងនេះច្រើនតែបរាជ័យដោយសារប្រពន្ធ័ស្រាវជ្រាវកសិកម្មជាតិមានការលំបាកក្នុងការឆ្លងអន្តរកាលនេះ។ ជា! ទូទៅបុគ្គលិកជាន់ខ្ពស់នៅក្នុងអង្គភាពប្រពន្ធ័ស្រាវជ្រាវកសិកម្មជាតិមិនមានចំណេះដឹងជំនាញ និង ការតំរង់ទិស ចំពោះទីផ្សារ ផលិតផល និង សេវាកម្ម ហើយគេមើលមិនឃើញខ្លួនឯងថាជាអ្នកទទួលខុសត្រូវក្នុងការឆ្លើយតប នឹងតំរូវការទាំងនោះឡើយ។ បុគ្គលិកមានសមត្ថភាពដែលអាចជួយអោយឆ្លងអន្តរកាលនេះភាគច្រើនគឺជាអ្នក ដែលនឹងចាកចេញ។ លើសពីនេះ ការប្រឹងប្រែងដើម្បីអាចផ្គត់ផ្គង់ខ្លួនឯងបានជារឿយៗជំរុញអោយអង្គភាពនៃ ប្រពន្ធ័ស្រាវជ្រាវកសិកម្មជាតិ ផ្លាស់ប្តូរជំហរទៅបំរើអោយពាណិជ្ជករ និង ងាកចេញឆ្ងាយពីការបំរើអោយប្រជា ជនក្រីក្រ។

ផ្អែកលើបទពីសោធន៍ទាំងនេះ ប្រពន្ធ័ស្រាវជ្រាវកសិកម្មជាតិនៅកម្ពុជានឹងត្រូវបានបង្កើតឡើងដើម្បីម្ចាស់ការទៅលើ

ក. ទំហំកម្មវិធីស្រាវជ្រាវដែលស្របទៅនឹង ផ.ស.ស ជាតិ ក៏ដូចជាសមត្ថភាពក្នុងការអនុវត្ត។ ខ. ប្រពន្ធ័ស្រាវជ្រាវមជ្ឈការដែលផ្អែកលើអនុវិស័យ។

គ. កម្មវិធីស្រាវជ្រាវដែលមានមូលដ្ឋានជាប្រភេទស្រាវជ្រាវបន្សាំ ឬ ប្រភេទស្រាវជ្រាវអនុវត្តន៍។

ឃ. ការនាំចូលនូវបច្ចេកវិទ្យាសមស្របពីប្រពន្ធ័ស្រាវជ្រាវថ្នាក់ជាតិនៃប្រទេសដទៃ មជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មអន្តរជាតិ និងមជ្ឈមណ្ឌលដទៃទៀត។

ង. កម្មវិធីស្រាវជ្រាវដែលអាស្រ័យលើតំរូវការអតិថិជន។

ច. ការចូលរួមរបស់អតិថិជនក្នុងការរៀបចំ និង អនុវត្តន៍កម្មវិធីស្រាវជ្រាវ។

ឆ. សហហិរញ្ញប្បទានក្នុងការស្រាវជ្រាវ

ជ. ទំនាក់ទំនងរឹងមាំរវាងមជ្ឈមណ្ឌលស្រាវជ្រាវ និង រវាងការស្រាវជ្រាវ ការផ្សព្វផ្សាយ កសិករ និងស្ថាបន័ពាក់ពន្ធ័។

ឈ. ហេដ្ឋារចនាសម្ពន្ធ័ដែលទាមទារការថែទាំទាប តែសមស្របទៅនឹងទំហំកម្មវិធីស្រាវជ្រាវ។ ញ. ការចែករំលែកមធ្យោបាយស្រាវជ្រាវ។

**កំណត់សំគាល់**

- **ការស្រាវជ្រាវបន្សាំ** នៅក្នុងឯកសារនេះ សំដៅទៅលើការវាយតម្លៃនៅក្នុងល័ក្ខខ័ណ្ឌទីវាលនូវលទ្ធផល ស្រាវជ្រាវអនុវត្តន៍។ ឧទាហរណ៍ ការពិសោធន៍គ្មានសារទៅលើពូជស្រូវណាមួយនៅក្នុងស្រែកសិករ។

- **ការស្រាវជ្រាវអនុវត្តន៍** សំដៅទៅលើការវាយតម្លៃលទ្ធផលនៃការស្រាវជ្រាវយុទ្ធសាស្រ្តក្នុងប្រពន្ធ័បរិសា ណាមួយ។ ជាឧទាហរណ៍ ការវាយតម្លៃលើការពិសោធន៍មានសារនៃពូជស្រូវធន់ទៅនឹងការរាំងស្ងួតទៅតា ស្ថានីយ៍ស្រាវជ្រាវ។
- **ការស្រាវជ្រាវយុទ្ធសាស្រ្ត** ជាការបង្កើតនូវបច្ចេកវិទ្យាក្នុងគោលបំណងដោះស្រាយបញ្ហាសំខាន់អ្វីមួយ។ ជាឧទាហរណ៍ ដូចជាការបង្កើតនូវពូជស្រូវមួយដែលធន់ទៅនឹងលក្ខខណ្ឌរាំងស្ងួត។
- **ការស្រាវជ្រាវមូលដ្ឋាន** សំដៅលើកត្តាផ្សំ (parameters) នៃការស្រាវជ្រាវយុទ្ធសាស្រ្ត។ ជាឧទាហរណ៍ ដូចជាការស្រាវជ្រាវទៅលើធាតុ (elements) ទាំងឡាយនៃពូជស្រូវធន់ទ្រាំនឹងភាពរាំងស្ងួត។

# មេរៀនទី៤
# តួនាទីកសិកម្មក្នុងការអភិវឌ្ឍន៍ខឿនសេដ្ឋកិច្ចជាតិ

ក្រោយពីបានបញ្ចប់ជំពូកនេះ លោកអ្នកនឹងយល់ដឹងពីៈ

- ការអភិវឌ្ឍន៍ៈ អត្ថន័យ និងការវាស់វែង
- អត្ថន័យនៃការអភិវឌ្ឍន៍
- អត្ថន័យនៃកំណើនសេដ្ឋកិច្ច
- បម្រែបម្រួលតម្រូវការអតិថិជន និងកំណើនប្រាក់ចំណូល

## ៤.១.ការអភិវឌ្ឍន៍ៈ អត្ថន័យ និងការវាស់វែង

ការធ្លាក់ចុះនូវអត្រាប្រជាជនជនបទបញ្ហាក្នុងការអភិវឌ្ឍន៏នៅជនបទដ៏ធំបំផុតគឺទាក់ទងក្នុងការរៀបចំ នូវគម្រោងសម្រាប់ជាមូលដ្ឋានគ្រឹះនៃហិរញ្ញវត្ថុនៅពេលអនាគត។ ដូចនេះនៅទីប្រជុំជនជួបនូវបញ្ហាហិរញ្ញវត្ថុបែប នេះហើយសហគមន៏នៅជនបទត្រូវមានទំនាក់ទំនងក្នុងការបែងចែងនូវហិរញ្ញវត្ថុ។

លំអិតពីបញ្ហានានា និងផលវិបាករបស់ពួកគេមានដូចខាងក្រោមៈ

➢ ការអភិវឌ្ឍន៏ និងគំរោងបច្ចេកទេស សកម្មភាពក្នុងការរៀបចំទីក្រុង និងជនបទគឺមានចំនុចប្រសព្វនៃសកម្មភាពរបស់រាជរដ្ឋាភិបាល។ សកម្មភាពសេដ្ឋកិច្ចជនបទគឺពង្រីកនូវទីកន្លែងជាំ ដំណាំឆ្លាស់ដូច្នេះការអភិវឌ្ឍន៏សេដ្ឋកិច្ចនៅក្នុងស្រុកនានា និងសភានៃរាជរដ្ឋាភិបាលត្រូវ បង្កើតនៅក្នុងការ , ដោះស្រាយ និងពង្រីកនូវគំរោងមូលនិធិនៅជនបទ។ មូលនិធិនេះដូចជាទិញ គ្រឿងយន្ត និងផ្តល់នូវបច្ចេកទេសនៅក្នុងគម្រោងនៃសហគមន៏ និងការរៀបចំនៅជនបទ។ ប្រសិទ្ធភាពនៃគំរោងគឺអាស្រ័យ និងការជាប់ទាក់ទងនិងប្រជាជន និងមូលនិធិ។ ផលវិបាកនៃ គម្រោងដែលទទួលបានជោគជ័យ ការពិចារណាក្នុងការគ្រប់គ្រងនៃមូលនិធិ និងបង្កើន ឳកាសក្នុងការទទួលបានជោគជ័យនូវការផ្គត់ផ្គង់មូលនិធិ។

➢ ហិរញ្ញវត្ថុផ្ទាល់ខ្លួនជាប់ទាក់ទងនិងន័យផ្សេងៗទៀតនៃការកើនឡើងនូវចំណូលដែលមានដូច ជាៈការបង់ពន្ធ ការប្រើប្រាស់លុយ និងសេវាកម្មសាធារណៈផ្សេងៗទៀត។ បន្ថែមពីនេះទៅ ទៀតតម្លៃនៃការផ្តល់សេវាកម្មនានាក្នុងគោលបំណងដើម្បីអភិវឌ្ឍន៏ហេដ្ឋារចនាសម្ព័ន្ធនៅជន បទ។ ហិរញ្ញវត្ថុផ្ទាល់ខ្លួនគឺជាមធ្យោបាយផ្ទាល់ខ្លួនដែលមិនអាចទៅរួច។ ផលវិបាកដែលចំបង ជាងគេគឺជាការគេចចេញពីការជំពាក់បំណុល និងការពន្យាពេលក្នុងការអភិវឌ្ឍន៏ហូតដល់ មូលនិធិធ្លាក់ចុះមក។

➢ ប្រាក់កំចី និងការផ្តល់នូវប្រាក់កំរៃគឺមានការប្រែប្រួលមួយចំនួនពីការកសាងហេដ្ឋារចនាសម្ព័ន្ធ ដែលមានតម្លៃថ្លៃពេក និងគោលដៅដ៏ជាក់លាក់សម្រាប់ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ស្ពានប្រព័ន្ធស្រោចស្រព ការពារភ្លើងឆេះ ចំណតរថយន្ត ភាពងាយស្រួលក្នុងការលំហែកាយ ចំនុចចាប់ផ្តើមភាគច្រើនគឺពិបាកក្នុងសហគមន៏ជនបទដើម្បីផ្តល់ឲ្យ និងដើម្បីឲ្យ អភិវឌ្ឍន៏សេដ្ឋកិច្ច។ ប្រភពនៃប្រាក់កំចៃសាធារណៈគួរយកចិត្តទុកដាក់លើការប្រាក់តិចតួច ប៉ុណ្ណោះ។ ផលវិបាកនៃប្រាក់កំចីសាធារណៈ

គឺការបង្កើននូវការអភិវឌ្ឍន៍សេដ្ឋកិច្ច។ មូលដ្ឋាន គ្រឹះសម្រាប់ការផ្តល់សេវាកម្មសាធារណៈចាំបាច់ដូចជាឧបករណ៏ក្នុងការអភិវឌ្ឍន៍នូវគម្រោង ការអភិវឌ្ឍន៍លើវិស័យសេដ្ឋកិច្ច។ ការងារទូទៅ និងចំណូលគឺជាបំណុលឬឥណទាននៃហិរញ្ញ វត្ថុឬបដិធាននៅក្រោមអង្គាធរសម្រាប់គោបំណង ដូចជាការបង្កើតហេដ្ឋារចនាសម្ព័ន្ធ។ ផលវិ បាកនានាគឺជាសមត្ថភាពនៃកំណើនក្នុងការប្រតិបត្តិនៃគម្រោងអភិវឌ្ឍន៍ និងសេវាកម្មផ្តល់ ប្រាក់កំចីនៅអនាគត។

➢

### ៤.១.១.ទស្សនៈឈានទៅមុខនៃការចូលរួមនៅជនបទ

នៅជំពូកនេះដែរគឺត្រូវកំណត់បាននូវចំណុចប្រសព្វនៃគោលនយោបាយអភិវឌ្ឍន៏ជនបទ អង្គការ កសិករ និងកសិដ្ឋាននូវកម្រិតបន្តិចបន្តួចពីបញ្ហាគោលនយោបាយអភិវឌ្ឍន៏សេដ្ឋកិច្ចជនបទនៅសម័យ នេះ។ នៅក្នុងសៀវភៅនេះយើងអាចសន្និដ្ឋានបានថាយើងអាចធ្វើបាននូវការការពារសម្រាប់ការចំណាយរបស់រាជរដ្ឋាភិ បាលលើគម្រោងកសិដ្ឋាន គឺគ្មានផលប្រយោជន៏ល្អនោះទេ។ បន្ថែមពីនេះទៅទៀតការពិភាក្សាគោលនយោលើ គោលនយោបាយប្រកពធនជាន (ជំពូក១៣)បានបង្ហាញឱ្យឃើញថាមានការកើនឡើងគឺចាប់ផ្តើមពីកសិ កម្មធ្វើការបំផ្លាញដូចគ្នានេះដែរគឺចាប់ផ្តើមបង្កើតសហគមន៏ និងទំនាក់ទំនងពាណិជ្ជកម្មក្នុងការពង្រីក ការចែក ចាយ។ ភាពច្បាស់លាស់ពីគោលបំណងនៃការអប់រំសុខភាព ទំនាក់ទំនង ហេដ្ឋារចនាសម្ព័ន្ធ អ្នកស្រុកទាំង អស់នេះជាកសិករ។ ទោះបីជាគំពោងពាណិជ្ជកម្មនៅជនទកសិករភាគច្រើនគឺអាស្រ័យលើពាណិជ្ជកម្មមិនមែន កសិកម្មដែលជាចំណូលរបស់ពួកគាត់។ ចំនួននៃការធ្លាក់ចុះនូវឱកាសការងារក្រៅកសិកម្មដូចជាមិនកើនឡើងទេ

វាសមហេតុផលដែរសម្រាប់អ្នកស្រុកទាំងអស់រាប់បញ្ចូលទាំងកសិករ អ្នកដឹកនាំគោលនយោបាយក្នុង សហគមន៏ ពាណិជ្ជករ អ្នកអប់រំ អ្នកធ្វើការក្នុងមណ្ឌលសុខភាព និងនយោជិកផ្សេងៗទៀត និងអ្នកចូលនិវត្តន៏ ហើយអ្វីដែលល្អបំផុតសម្រាប់ពួកគេដូចជាការអភិវឌ្ឍន៏ក្នុងក្រុមនូវកិច្ចការត្រូវធ្វើការពិភាក្សារបស់ពួកគេផ្ទាល់។ កិច្ចពិភាក្សាផ្តោតលើគោលនយោបាយកសិកម្ម និងគោលនយោបាយអភិវឌ្ឍន៏ជនបទ។ ការចូលរួមដែលធ្វើ ឱ្យគោលនយោបាយមានលក្ខណៈប្រសើរឡើងនូវគោលនយោបាយជនបទ។ វានិងជួយឧបត្ថម្ភដោយក្រុម ចំរុះប្រហែលពី២៥នៃអត្រាប្រជាជននៅ % សហរដ្ឋអាមេរិកទាំងអស់។

### ៤.១.២.វិភាគគោលនយោបាយកសិកម្ម




ក្រាភិច ៤.១

### ៤.១.៣.គ្រោះថ្នាក់នៃការផ្លាស់ប្តូរតម្លៃនៅក្នុងទីផ្សារ

ប្រសិនបើតម្លៃនៅលើទីផ្សារត្រូវបានដាក់បញ្ចូលដូចជាកំនើនប្រាក់ឈ្នួលតើនេះគឺជាលទ្ធផលដែលធ្វើឱ្យថ្លៃលក់រាយ ហើយវាជាផលិតផលរបស់កសិដ្ឋាន? ជាទូទៅចំលើយទាំងពីរគឺថាកសិដ្ឋាន ហើយនឹងការលក់រាយវាប៉ះពាល់ដល់ទំហំផលធៀបអាស្រ័យលើចំណោតមេគុណពិតប្រាកនៃតម្រូវការនឹងបំពេញមុខតម្លៃផ្គត់ផ្គង។ សម្រាប់ភាពសាមញ្ញយើងត្រូវគិតថាទី១វាខ្ចីតាំងនៅផ្លូវទាបបរិយាយក្នុងរូប៣.២។ ក្នុងនេះគឺកញ្ចប់ទំនិញកំណត់បរិមាណផ្គត់ផ្គង់(Q)គឺថេរជាមុខងារនៃការលក់ រាយ។ កំនើននៅក្នុងទីផ្សារកញ្ចប់ទំនិញនិងមូលហេតុនៅក្នុងកសិដ្ឋានទទួលបានមកពីតម្រូវការពីការ ផ្លាស់ប្តូរមិនទានគេ។ ដូចនេះគឺផ្តលសិទ្ធិនៅក្នុងផ្លូវទាបបំផុតនៃកម្រិតខុសគ្នា គឺបង្ហាញនូវការបញ្ចុះ ថ្លៃកសិដ្ឋានវាមិនប៉ះពាល់ ទៅនឹងការលក់រាយទេ។

ជាមួយនៃការអនុម័តនៃពេលវាលាទោះជាយ៉ាងដូចនេះក្តីតម្លៃកសិដ្ឋាននឹងបន្ថយការវាយតម្លៃជាបរិមាណផ្គត់ផ្គង់ការផ្គត់ផ្គង់ទាបបន្ទាត់កោងបានទ្រេតវិជ្ជមាន។ ការផ្គត់ផ្គង់ទិចតួចនិងមាន កំនើនកសិដ្ឋាននិងការលក់រាយ។ ដូចនេះជាចុងក្រោយការលក់រាយនិង កែសម្រួលឡើងវិញ។ ដំបូងកំនើននៅក្នុងតម្លៃនៃទីផ្សារផលិតផលនិងធ្វើឱ្យកើតមានឡើងជាប់នៅការប្រគួតប្រជែងថា លទ្ធផលនៅក្នុងការបញ្ចុះតម្លៃកសិដ្ឋាននិងតម្លៃលក់រាយខ្ពស់។ នេះគឺជាការបរិយាយដែលគេមិន ទានបានផ្លាស់ប្តូរក្នុងការទទួលបានមកពីការផ្គត់ផ្គង់ហើយមុខងារតម្រូវការខណៈពេលដែលទទួលយក សំខាន់ការផ្គត់ផ្គត់និងមុខងារតម្រូវការគឺមិនផ្លាស់ប្តូល។




**ក្រាភិច ៤. ២**

Figure ៣.២ ជួយដល់ការនឹកគិតក្នុងចិត្តថាទ្រទ្រខុសពីគេបើការផ្គត់ផ្គង់និងតម្រូវការតែងតែទទួលផលខុសគ្នាក្នុងការកើតមានឡើងនៃកសិដ្ឋាននឹងតម្លៃលក់រាយ។ គុណសម្បត្តិនៃការវែក ញែកខាងមុខ។ ទីមួយគឺផ្លាស់ប្តូរតម្លៃនៃការផ្តល់ឱ្យមានប្រយោជន៏សម្រាប់អ្នកប្រើប្រាស់។ យើងអាចជជែកគ្នាពីការផ្លាស់ប្តូរតម្លៃក្នុងសហការីជាមួយនិងអត្តប្រយោជន៏ថ្មី។ បើការផ្លាស់ប្តូរ ពេលនេះគួរតែបរិយាពីមុខងារតម្រូវការចំៗពីផលិតផល។

ការវែកញែកទីពីរបង្ហាញនៅក្នុងFigure6-3គឺឧទាហរណ៏នៃលំនឹងទ្រឹស្តីហើយលំនឹងស្ថាន ការណ៏តែមួយសំរាបផលិតផលគឺបង្ហាញពីការផ្លាស់ប្តូរកត្តាទាំងអស់ចំណាប់ឥតឈប់ឈរ។ ទោះបីមានប្រយោជន៏សម្រាប់ការពន្យល់ជាទូទៅធម្មជាតិនៃការផ្លាស់ប្តូរក្នុងកម្រិតខុសគ្នាទៅលើកសិដ្ឋានហើយនិងតម្លៃលក់រាយវាអាចនាំឱ្យយល់ខុសពោលអនុវត្តតែងតែពិតគ្រប់ស្ថានភាពកត្តាទាំងនោះគឺឥតឈប់ឈរ។ សម្រាប់ឧទាហរណ៏តូចតម្លៃសម្រាប់ផ្លែប៉ោមមួយផ្លែនៅក្នុងWashington Stateតែងតែទទួលលទ្ធលខ្ពស់សម្រាប់Washingtonហើយធ្វើឱ្យថោកនៅតម្លៃលក់រាយសម្រាប់អតិថិជន។ យ៉ាងណាក៏ដោយការវែកញែកនេះតែងតែមិនពេញលេញវាយកបញ្ចីប្រាក់ចេញពីន្លោះ ការដាំដុះហើយការលួតលាស់របស់ផ្លែប៉ោម។

ធើឱ្យតម្លៃលក់រាយសម្រាប់ផ្លែប៉ោមនឹងលទ្ធផលថយចុះតម្លៃសម្រាប់ជំនួស។ អញ្ចឹងប្រព័ន្ធដែលជះឥទ្ធិពលទៅលើតម្លៃប៉ុន្តែវាមិនធំទេនៅពេលដែលឥទ្ធិពលទីពីរដែលយកមកពិនិត្យ។

នៅខាងមុខគេតែងតែមានគំនិតវិភាគដែរសន្មតថាការផ្លាស់ប្តូរតម្លៃប្រព្ធ័នភ្លាមៗទាំងអស់ប៉ុន្តែនេះគឺមិនមែនជាហេតុផលទេ។

**ការផ្ទេរតម្លៃ**

ពត៌មានថ្មីថាឥទ្ធិពលតម្លៃអាចបង្កើតបានសម្រាប់អ្នកប្រើប្រាស់(ផ្លាស់ប្តូរក្នុងតម្រូវការខាងដើម) សម្រាប់ថ្នាក់កសិដ្ឋាន(ផ្លាស់ប្តូរក្នុងការផ្គត់ផ្គង់)ឬសម្រាប់ផ្នែកទីផ្សារ(ផ្លាស់ប្តូរទំនាក់ទំនងទីផ្សារនាំចូល។ ដែលចូលចិត្តប្រគួតក្នុងទីផ្សារយ៉ាងសុក្រិតតម្លៃតែងតែផ្លាស់ប្តូរភ្លាមៗ ហើយពិនិត្យពីពត៌មានថ្មី ប៉ុន្តែបើតាមការពិតទីផ្សារគឺមិនសុក្រិត។

ប្រធាននៃថ្លៃត្រូវបានប្រគល់ឱ្យធ្វើជាមួយប្រភេទនៃថ្លៃកែប្រែឱ្យសមរម្យក្នុងប្រព័ន្ធនៃ ទីផ្សារ។ ទីផ្សារវិគាគថាគួរឱ្យចាប់អារម្មណ៍ដូចគ្នានិងសំនួរដែលសួរបន្តបន្ទាប់ តើធ្វើដូចម្តេច ឱ្យតម្លៃសមរម្យ?

គេច្រើនវិភាគសំអាងទៅលើការពិសោធន៍ហើយបានប្រមូលផ្តុំលើ ទំនាកទំនងចន្លោះកសិដ្ឋាន និង តម្លៃលក់រាយ។ ការវិភាគទាំងឡាយនេះគឺលំអៀងតំបូងគឺសមហេតុផលធម្មតាការរត់មកផ្លាស់ប្តូរនៅក្នុងតម្លៃកសិដ្ឋានទៅផ្លាស់ប្តូរក្នុងតម្លៃលក់រាយ។ វាគឺចម្លែកស្វែរកតម្លៃការលក់នៅសល់មួយ ដែលកើតឡើងណាលគ្នា។ ក្រោយពេលពីរខែក្នុងរយៈពេលស្មើគ្នាដែលអាចខូចរលួយដូច ដឹកដោះគោសាច់និងផ្លែឈើស្រស់ហើយនិងបន្លែ។ តម្លៃលក់រាយមួយភាគបីហាក់ដូចជាឆ្លើតបជាមួយការថ្លឹងថ្លែងខុសប្លែពី គ្នាពីការបង្កើតតម្លៃក្នុង កសិដ្ឋានភ្ជាប់ពីចំនួនចុះអន់ថយក្នុងតម្លៃកសិដ្ឋាន។

សិក្សាពីតម្រូវការខាងដើមក្នុងលេខ6-1គឺយើងប្រើចំនុចនៃការចាកចេញ។ នៅក្នុងគម្រូដើមនេះ គឺគេទុកចិត្តលើតម្លៃទីផ្សារការនាំចូលនិងបរិមាណនៅលើទីផ្សារ(ជាទូទៅប្រសិនបើតម្លៃខុសគ្នានៅលើទីផ្សារត្រូវផ្លាស់ប្តូរជាមួយបរិមាណនៅលើទីផ្សារ)។ ចាប់តាំងពីមានសម្ភាពចែកចាយតម្លៃលក់ រាយលើសពីថ្លៃកសិដ្ឋានចំនុចដែលអាចលក់រាយគឺមុខងារនៃតម្លៃកសិដ្ឋានបរិមាណដែលនាំចូលមក ក្នុងទីផ្សារ។

## ៤.២ អត្ថន័យនៃការអភិវឌ្ឍន៍

ការអភិវឌ្ឍសេដ្ឋកិច្ច : គឺមិនត្រឹមតែជាកំណើននៃទិន្នផលពិតប៉ុណ្ណោះទេប៉ុន្តែ ជាការបង្ហាញពីប្រភេទខុសគ្នារវាងទិន្នផលដែលត្រូវបានផលិតកន្លងមកវាក៏រួមបញ្ចូលផងដែរនូវការកើនឡើងបច្ចេកវិទ្យាសម្រាប់ផលិតនិងបែងចែកមុខចេញ(ទំនិញនិងសេវាកម្ម)។

## ៤.៣ អត្ថន័យនៃកំណើនសេដ្ឋកិច្ច

កំណើនសេដ្ឋកិច្ចគឺជាការកើនឡើងនៃសមត្ថភាពផលិតមុខចេញឲ្យបានច្រើនជាងមុននិងមានគុណភាពល្អដើម្បីបំពេញតម្រូវការនិងចំណង់ចំណូលចិត្តរបស់មនុស្សក្នុងសង្គមនិងបង្កើនចំណូលផលិតកម្ម។ កំណើនសេដ្ឋកិច្ចត្រូវវែកញែកភាពខុសប្លែកពីការអភិវឌ្ឍន៍សេដ្ឋកិច្ច។ កំណើនសេដ្ឋកិច្ចអាចកើតមានឡើងបើទោះជាគ្មានការអភិវឌ្ឍន៍សេដ្ឋកិច្ចក៏ដោយ។

ពេលខ្លះមានការយល់ច្រលំអត្ថន័យរវាងពាក្យកំណើនសេដ្ឋកិច្ចនិងអភិវឌ្ឍន៍សេដ្ឋកិច្ច។

ឧទាហរណ៍ :ប្រទេសដែលពឹងផ្អែកលើផលិតកម្មប្រេងសម្រាប់នាំចេញមានអត្រា កំណើនសេដ្ឋកិច្ចតាមរយៈការប្រើប្រាស់មុខចូលយ៉ាងច្រើនសម្រាប់ផលិតមុខចេញ(ប្រេង)ក្នុងកំឡុងពេលដែលការអភិវឌ្ឍន៍សេដ្ឋកិច្ចមានតិចតួច។

មានកត្តាជាច្រើន កើតឡើងដែលជាឧបសគ្គសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច។ កត្តាទាំង នោះមានដូចជា៖

ក.បរិមាណនិងគុណភាពនៃកម្លាំងពលកម្ម : តែងជះឥទ្ធិពលទៅលើការអភិវឌ្ឍ សេដ្ឋកិច្ច។ តែការកើតមានឡើងនូវកម្លាំងពលកម្មដ៏ច្រើនមិនមានន័យថាជានាដល់ការ អភិវឌ្ឍសេដ្ឋកិច្ចនោះទេដូចជាកម្លាំងពលកម្មក្នុងប្រទេសឥណ្ឌាមានការខ្វះខាតការអប់រំនិងមិនមានជំនាញ ដូចនេះធ្វើឲ្យប្រទេសនេះនៅតែឋិតក្នុងស្ថានភាពក្រីក្រ។

ខ.បរិមាណនិងគុណភាពនៃមូលធនពិត :គឺមានសារសំខាន់សម្រាប់ការអភិវឌ្ឍ សេដ្ឋកិច្ច។ មូលធនពិតជាទំនិញវិនិយោគឬជាសន្និធិក្នុងទម្រង់ជាវត្ថុធាតុដើមគ្រឿងម៉ាស៊ីននិងសម្ភារបរិក្ខាររូបវន្តផ្សេងៗទៀតដែលបម្រើឱ្យការផលិតទំនិញសម្រាប់អ្នកប្រើប្រាស់។ការផ្គត់ផ្គង់នៃមូលធនពិតអាស្រ័យទៅលើកម្រិតនៃការសន្សំនៅក្នុងប្រទេសនោះដែលបង្ហាញពីខុសគ្នារវាងចំណូលនិងការប្រើប្រាស់។

គ-កម្រិតនៃការប្រើប្រាស់បច្ចេកវិទ្យា :ត្រូវបានចាត់ទុកថាជាដំណើរការដ៏ល្អ សម្រាប់កត្តាផលិតកម្មដែលទាក់ទងទៅនឹងមុខចូលនៃធនធានសេដ្ឋកិច្ចរួមមានដីកម្លាំងពលកម្មនិងមូលធន។

ឃ- បរិមាណនិងគុណភាពនៃប្រភពធនធានធម្មជាតិក៏ជាកត្តាសំខាន់ផង ដែរព្រោះថាធនធានទាំងនោះត្រូវចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។

ង .ម្យ៉ាងទៀតកត្តាវប្បធម៌សង្គមក៏ជះឥទ្ធិពលដល់ការ អភិវឌ្ឍន៏សេដ្ឋកិច្ចរបស់ ប្រទេសមួយផងដែរដូចជាសាសនា( Religion ) ការចូលចិត្តរបស់ប្រជាជន ( consumer tastes )ជាដើម។

## ៤.៤ បម្រែបម្រួលតម្រូវការអតិថិជន និងកំណើនប្រាក់ចំណូល

### ៤.៤.១.ប្រាក់ចំណូលប្រជាជនក្នុងម្នាក់

ប្រទេសនីមួយៗត្រូវបានចាត់ទុកថាជាប្រទេសមានការអភិវឌ្ឍតិចឬច្រើនមានឬក្រគឺអាស្រ័យទៅលើការកំណត់ពីទំហំនៃផលិតផលជាតិសរុបរបស់ប្រជាជនម្នាក់ៗដែលជារង្វាស់ជាក់ស្តែងនៃតម្លៃទំនិញនិងសេវាកម្មត្រូវបានផលិតនិងមាននៅលើទីផ្សារដោយគិតជាមធ្យមរបស់ប្រទេសនីមួយៗ។ក្នុងឆ្នាំ១៩៩៧មាន៦៣ប្រទេសដែលមានប្រាក់ចំណូលរបស់ប្រជាពលរដ្ឋក្នុងម្នាក់ចំនួន៧៨៥ដុល្លារឬតិចជាងនេះ។ប្រទេសទាំងនោះមានចំនួន៣៥ភាគរយនៃចំនួនប្រជាជនសរុបនៅលើពិភពលោកប៉ុន្តែមានតែប្រាំភាគរយប៉ុណ្ណោះនៃផលិតផលជាតិសរុបរបស់ពិភពលោក។

តារាងខាងទី4.1 ក្រោមបង្ហាញអំពីការរបស់ប្រជាជនរបស់ប្រទេសមួយចំនួន។

**តារាង៤.១.ការរបស់ប្រជាជនរបស់ប្រទេសមួយចំនួន**

| Income Groups | Money per Capita GNP | Country Rank |
|---|---|---|
| Low Income | | |
| Bangladesh | 270$ | 106 |
| Ethiopia | 110 | 122 |
| India | 390 | 92 |

| | | |
|---|---|---|
| Nigeria | 260 | 114 |
| Pakistan | 490 | 94 |
| **Lower middle** | | |
| China | 860 | 65 |
| Philippines | 1220 | 63 |
| Russian federation | 2740 | 59 |
| Ukraine | 1040 | 82 |
| **Upper middle** | | |
| Brazil | 4720 | 47 |
| Hungary | 4430 | 39 |
| Mexico | 3680 | 35 |
| Poland | 3590 | 46 |
| **High** | | |
| Canada | 19 290 | 10 |
| France | 26050 | 11 |
| Japan | 37850 | 6 |
| United States | 28740 | 2 |

Source: The World Bank, World Development Report, 1998/99( Washing, D.C: The World Bank, 1998. ),190-96

## ៤.៤.២. ការកើនឡើងយ៉ាងលឿននៃចំនួនប្រជាជនសរុប

ទោះបីជាអត្រាជាទូទៅនៃកំណើនប្រជាជនសរុបនៅលើពិភពលោកត្រូវបានថយចុះចាប់តាំងពីចុងទស្សវត្សឆ្នាំ១៩៧០ក៏ដោយក៏អត្រាតួលេខប្រជាជនសរុបទូទាំងពិភពលោកប្រចាំឆ្នាំមានការកើនឡើងគិតជាមធ្យមប្រហែល១០០លាននាក់ក្នុងមួយឆ្នាំ។ស្ទើរតែទាំងអស់នៃកំណើននេះគឺកើតឡើងនៅក្នុងប្រទេសក្រីក្រដែលក្នុងនោះអត្រាផ្តល់កំណើតកើនឡើងខ្ពស់ចំណែកអត្រាមរណភាពថយចុះ។ តារាងទី4.2 ខាងក្រោមបង្ហាញអំពីកំណើននៃចំនួន ប្រជាជនសរុបរបស់ប្រទេសមួយចំនួនពីឆ្នាំ 1980 ដល់ឆ្នាំ1997។

តារាង ៤.២.កំណើននៃចំនួន ប្រជាជនសរុបរបស់ប្រទេសមួយចំនួនពីឆ្នាំ 1980ដល់ឆ្នាំ1997

| Population ( Millions ) | 1980 | 1997 |
|---|---|---|
| **Rich Nations** | | |
| Canada | 25 | 30 |
| France | 54 | 59 |
| Japan | 117 | 126 |
| United Stated | 227 | 268 |
| **Poor country** | | |
| China | 981 | 1127 |
| India | 687 | 961 |
| Pakistan | 83 | 127 |

Source: The World Bank, World Development Report, 1998/99( Washington,D.C: The World Bank. 1998 ),194-95

ក-ភាពក្រីក្រ៖ប្រជាជនជាងមួយពាន់លាននាក់នៃចំនួនប្រជាជនសរុបនៅលើពិភព លោកមាន៥,៨ពាន់លាននាក់រកចំណូលបានតិចជាងមួយដុល្លារនិងប្រហែលពីរពាន់ លាននាក់រកចំណូលបានតិចជាង២ដុល្លារក្នុងមួយថ្ងៃ។

ខ-អនក្ខរភាព៖ក្មេងៗប្រហែល២៧៥លាននាក់នៅលើពិភពលោកស្ថិតនៅក្នុង អនក្ខរភាព ដោយសារពួគគេរស់នៅក្នុងប្រទេសក្រីក្រដែលមិនមានសាលារៀន។ពួកគេនឹងក្លាយទៅជា យុវវ័យដែលមិនមានចំណេះដឹងនិងជំនាញដែលអាចប្រកួតប្រជែងជាមួយ យុវជនផ្សេងៗ ទៀតក្នុងពិភពលោកជិតមួយភាគបីនៃចំនួនប្រជាជនសរុបនៅលើពិភព លោកគឺស្ថិតនៅក្នុង អនក្ខរភាពនិងចំនួនពីរភាគបីទៀតជាស្ត្រីភេទដែលទទួលបានការអប់រំ តិចជាងបុរស។

# មេរៀនទី៥
# យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍កសិកម្ម៖ ដំណើរការ និងរចនាសម្ព័ន្ធ

ក្រោយពីបានបញ្ចប់ជំពូកនេះ លោកអ្នកនឹងយល់ដឹងពី៖

– តួនាទីនៃយុទ្ធសាស្ត្រកសិកម្ម
– ដំណើការការចូលរួមសម្រាប់យុទ្ធសាស្ត្រនៃការអនុវត្តន៍
– យុទ្ធសាស្ត្រ និងភាពមិនប្រាកដនៃគោលនយោបាយ
– ការតម្រង់ទិសនៃយុទ្ធសាស្ត្រនៃកសិកម្មឲ្យមាននិរន្តរភាព
– ការអភិវឌ្ឍន៍ជនបទ និងការកាត់បន្ថយភាពក្រីក្រ
– ការអនុវត្តន៍យុទ្ធសាស្ត្រ

## ៥.១. តួនាទីនៃយុទ្ធសាស្ត្រកសិកម្ម

### ៥.១.១ យុទ្ធសាស្ត្រជាចក្ខុវិស័យនិងឯកសារឯកភាពគ្នា

យុទ្ធសាស្ត្រគឺជាក្របខណ្ឌស្ថិរភាពសម្រាប់ការប្រមូលផ្តុំគំនិតផ្តួចផ្តើមគោលនយោបាយផ្សេងៗគ្នានៅក្នុងរចនាសម្ព័ន្ធឡជីខលដែលប្រកាន់យកទស្សនៈរយៈពេលមធ្យមឬវែងនៃវិស័យនេះ។ ទស្សនវិស័យ។ អត្ថប្រយោជន៍នៃយុទ្ធសាស្ត្រដើម្បីធានាបាននូវភាពស៊ីសង្វាក់មួយ ក្នុងចំណោមគោលនយោបាយដែលបានស្នើសម្រាប់ភ្ជាប់ទំនាក់ទំនង ទាំងនោះទៅនឹងគោលដៅអភិវឌ្ឍន៍ជាតិនិងដើម្បីធានាថាការគ្របដណ្តប់លើតំបន់ដែលត្រូវការកំណែទម្រង់មានលក្ខណៈទូលំទូលាយគ្រប់គ្រាន់។ លក្ខណៈកំណត់នៃយុទ្ធសាស្ត្រ គឺថាវាបង្ហាញពីវិធីសាស្ត្រសំខាន់ចំពោះបញ្ហាអភិវឌ្ឍន៍។ យុទ្ធសាស្ត្រដែលអាចសម្រេចបាននិងរឹងមាំដែលមានសមត្ថភាពអាចអនុវត្តបាននិងអាចជំរុញវិស័យនេះទៅមុខបានត្រូវតែមានក្របខ័ណ្ឌគំនិតរឹងមាំហើយសំណើគោលនយោបាយរបស់ខ្លួនត្រូវបង្កើតឡើងតាមលក្ខណៈបច្ចេកទេសច្បាស់លាស់។ ប្រសិនបើនេះមិនមែនជាករណីទេ នោះយុទ្ធសាស្ត្រនេះអាចនឹងក្លាយជាបញ្ជីទិញទំនិញហើយបាត់បង់អំណាចបញ្ចុះបញ្ចូលរបស់វា។ ទោះយ៉ាងណាក៏ដោយ វាមិនគួរមើលរំលងថាយុទ្ធសាស្ត្រជោគជ័យក៏មានលើសពីឯកសារបច្ចេកទេសដែរ៖ វាជាចក្ខុវិស័យនិងសម្រែកយំ។ វាគឺជាចក្ខុវិស័យមួយដែលបង្ហាញពីភាពស្រស់ថ្លា លទ្ធភាពសម្រាប់វិស័យនេះនិងផ្លូវមួយដើម្បីសម្រេចបានពួកគេ។ តួនាទីសំខាន់មួយរបស់ខ្លួន គឺបង្ហាញពីវិធីរួមគ្នាដើម្បីបំពេញនូវសេចក្តីប្រាថ្នាស្របច្បាប់របស់ប្រជាជននៅជនបទ។ វាគឺជាការប្រមូលផ្តុំគ្នា ព្រោះប្រសិនបើជោគជ័យវាអាចក្លាយជាមធ្យោបាយនៃការកៀរគរការគាំទ្រសម្រាប់ចក្ខុវិស័យនិងការអនុវត្តរបស់វា។ វិស័យកសិកម្ម មានប្រជាជនច្រើននិងសម្បូរបែបហើយដូច្នេះចក្ខុវិស័យគួរឱ្យទាក់ទាញមួយនៃសក្តានុពលរបស់វិស័យនេះគឺចាំបាច់ដើម្បីជំរុញការគាំទ្រ។ ដោយនិមិត្តសញ្ញាដូចគ្នា ដោយគ្មានការគាំទ្រជំទូលាយវាមិនអាចរីកចម្រើនលើសពីស្ថានភាពនៃការសិក្សាបច្ចេកទេសផ្សេងទៀតទេ។ ការគាំទ្រនូវយុទ្ធសាស្ត្រមួយគួរតែត្រូវបានបង្កើតឡើងនៅលើផ្នែកសំខាន់បីយ៉ាងគឺ៖

- អ្នកផលិត - គ្រួសារជនបទឱ្យកាន់តែទូលំទូលាយ - ក្នុងនាមជាអ្នកបង្កើតនិងដោយគ្មានការយល់ព្រមនិងការចូលរួមយ៉ាងសកម្មនោះមិនអាចអនុវត្តបានពេញលេញឡើយ។
- រដ្ឋាភិបាល នៅក្នុងការបង្ហាញផ្សេងៗគ្នារបស់ខ្លួនដែលត្រូវតែដឹកនាំកិច្ចខិតខំប្រឹងប្រែងនៃការអនុវត្ត។ រដ្ឋាភិបាលគឺជាការប្រមូលផ្តុំនៃបុគ្គលម្នាក់ៗដែលមានទស្សនៈខុសគ្នានិងពេលខ្លះផ្ទុយគ្នាហើយដូច្នេះដើម្បីសម្រេចបាននូវកម្រិតឯកភាពគ្រប់គ្រាន់នៅក្នុងរដ្ឋាភិបាលទាមទារឱ្យមានការសន្ទនាស្ថាប័នពហុវិស័យនិងប្រកបដោយនិរន្តរភាព។
- ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ ដែលកិច្ចព្រមព្រៀងនិងហិរញ្ញប្បទានត្រូវបានទាមទារសម្រាប់ការអនុវត្តយុទ្ធសាស្ត្រប្រកបដោយជោគជ័យ។

តាមលទ្ធភាពដែលអាចធ្វើទៅបានយុទ្ធសាស្ត្រមួយក៏គួរធ្វើឱ្យមានភាពច្របូកច្របល់ដែលអាចទទួលយកបានជាមួយផ្នែកផ្សេងៗនៃប្រជាជននិងជាមួយអ្នកដឹកនាំមតិទូទៅទោះបីជាក្រុមជាច្រើននឹងមិនសូវចូលរួមក្នុងការអភិវឌ្ឍរបស់ខ្លួនហើយដូច្នេះមិនសូវចាប់អារម្មណ៍នឹងវា។ ប្រសិនបើវាបង្កើតការប្រឆាំងយ៉ាងសកម្មនៅក្នុងវិស័យដែលមានឥទ្ធិពលការទទួលបានការយល់ព្រមពីវានិងការអនុវត្តវាទំនងជាពិបាកជាង។

ជំពូកនេះពិនិត្យឡើងវិញនូវបញ្ហាសំខាន់ៗមួយចំនួនដែលពាក់ព័ន្ធនឹងដំណើរការនៃការអភិវឌ្ឍយុទ្ធសាស្ត្រកសិកម្មឬជនបទ ដោយប្រើរូបភាពពីការងារប្រឹក្សារបស់អ្នកនិពន្ធ ស្តីពីកិច្ចខិតខំប្រឹងប្រែងកសាងយុទ្ធសាស្ត្រនៅហុងឌូរ៉ាស ហ្គីយ៉ាណា អេស្តូនី នីការ៉ាហ្គាអែល សាល់វ៉ាឌ័រ សាធារណរដ្ឋដូមីនិក និង ម៉ូសំប៊ិក រួមទាំងព័ត៌មានអំពីបទពិសោធន៍នៅប្រទេសផ្សេងទៀត។ បន្ទាប់មកជំពូកនេះពិភាក្សាអំពីខ្លឹមសារនៃការតំរង់ទិសយុទ្ធសាស្ត្ររបស់គោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មបង្ហាញពីការចំណាយលើកម្មវិធីអភិវឌ្ឍន៍ជនបទនិងពិនិត្យលក្ខណៈវិនិច្ឆ័យសម្រាប់ការបែងចែកធនធាននៅក្នុងកម្មវិធីទាំងនោះ។

## ៥.១.២ កញ្ចប់ដែលមានតុល្យភាពនៃកំណែទម្រង់

ដែលជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងក្នុងការកៀងគរការគាំទ្រសម្រាប់កំណែទម្រង់ យុទ្ធសាស្ត្រ អាចកំណត់ការដោះដូរនិងអាចព្យាយាមធ្វើឱ្យមានតុល្យភាពនៃការខាតបង់សម្រាប់អនុវិស័យផ្សេងៗគ្នា។ ពេលខ្លះវាអាចពិបាកក្នុងការទទួលបានការយល់ព្រមលើសំណើកែទម្រង់តែមួយ ចាប់តាំងពីភាគីពាក់ព័ន្ធដែលចង់បាត់បង់ពីវា ទោះបីជាផលប្រយោជន៍សក្តានុពលពីកសិកម្មដែលមានប្រសិទ្ធភាពជាងដែលពួកគេជាជនជាតិភាគតិចអាចអាចអនុវត្តវិស័យកំណែទម្រង់ការលុបបំបាត់ការហាមឃាត់ ប្រសិនបើវាត្រូវបានខ្ចប់ជាមួយកំណែទម្រង់ផ្សេងទៀតអ្នកដែលមានសម្ពាធនយោបាយគ្រប់គ្រាន់គាំទ្រវា។ ទោះយ៉ាងណាក៏ដោយ ពួកគេបានទទួលផលប្រយោជន៍ខ្លះ។ អ្នកក្រនៅតាមជនបទបានឃើញផលចំណេញគ្រប់គ្រាន់នៅក្នុងកញ្ចប់ទាំងមូល ដែលពាណិជ្ជកម្មសេរីទទួលបានមួយផ្នែកតាមរយៈការស្នើនិងឈរលើការខាតបង់ពីកំណែទម្រង់មួយដែលអាចជាកំណែទម្រង់នៅដើមទស្សវត្សរ៍ឆ្នាំ ១៩៩០ ការគាំទ្ររបស់កសិករចំពោះការតម្លើងពន្ធត្រឹមត្រូវនៅពេលតម្លៃទីផ្សារពិភពលោក គាំទ្រវា។

គាត់បានបង្កើតគោលនយោបាយកសិកម្ម របស់ប្រទេសហុងឌ្រ៉ានជាប្រព័ន្ធតម្លើងតម្លៃដែលការអនុវត្តស្វ័យប្រវត្តិមានកម្រិតទាបពិសេស (ហើយបន្ថយវានៅពេលដែលតម្លៃឡើងខ្ពស់ដើម្បីផលប្រយោជន៍អ្នកប្រើប្រាស់)។ ដូចគ្នានេះដែរ ពួកគេបានយល់ព្រមរុះរើប្រព័ន្ធធានាដំណាំតម្លៃមួយផ្នែកពីព្រោះវិធានការនេះត្រូវបានវេចខ្ចប់រួមជាមួយសំណើរធ្វើឯកជនភាវូបនីយកម្មស៊ីឡូគ្រាប់ធញ្ញជាតិដែលជារបស់រដ្ឋក្នុងវិធីមួយដែលអាចឱ្យកសិករក្លាយជាម្ចាស់កម្មសិទ្ធិនៃគ្រឿងបរិក្ខារនេះ។ ប្រសិនបើពាណិជ្ជកម្មសេរីឬការតម្លើងថ្លៃ ត្រូវបានបង្ហាញតែម្នាក់ឯងនោះ វាមិនទំនងថាវានឹងទទួលបានការគាំទ្រគ្រប់គ្រាន់ដើម្បីអនុម័តក្នុងកាលៈទេសៈនៃពេលវេលានោះទេ។

ជាតុផ្សេងទៀតនៃកញ្ចប់កំណែទម្រង់នោះ បានសម្តែងនូវការយល់ព្រមរបស់ខ្លួនទាំងមូល។ កសិករពាណិជ្ជកម្មខ្នាតធំបានយល់ឃើញពីលទ្ធភាពដែលថាការរៀបចំរចនាសម្ព័ន្ធឡើងវិញនៃដំណើរការកែទម្រង់កសិកម្មអាចនាំមកនូវការបញ្ចប់នូវភាពមិនស៊ីចង្វាក់គ្នានៃគោលនយោបាយលើប្រជានបទនោះនិងការលុកលុយដីរយៈពេល ២០ ឆ្នាំនិងការប្រឈមមុខដាក់គ្នាដោយហិង្សាលើដីហើយដូច្នេះឌ។ ប្រព័ន្ធធានាតម្លៃដែលពួកគេធ្លាប់ជាអ្នកទទួលផលធំនិងការដកចេញនូវការត្រួតពិនិត្យបរិមាណលើការនាំចូលដែលបានផ្តល់ផលប្រយោជន៍ខ្លះដល់ពួកគេ។ ជនក្រីក្រនៅតាមជនបទបានឃើញសក្តានុពលពីការធ្វើកសិកម្មប្រកបដោយប្រសិទ្ធភាពជាងមុននៃការជួលដីនិងពីជាតុផ្សេងទៀតនៃកញ្ចប់ដែលត្រូវបានកំណត់គោលដៅលើក្រុមចំណូលរបស់ពួកគេ ហើយតាមនោះពួកគេមានធន្ទះក្នុងការជួលដីនិងពីជាតុផ្សំផ្សេងទៀតនៃការបោះបង់យុទ្ធសាស្ត្រឈ្លានពានដី។ ដែលក្នុងករណីណាក៏ដោយពេលខ្លះបានស្ទុះងើបឡើងវិញ។

វាមានតម្លៃ ប្រសិនបើការរុញច្រានជាមូលដ្ឋាននៃយុទ្ធសាស្ត្រគឺការបង្កើតនូវកម្រិតលេងនៅក្នុងឆាកនយោបាយនិងការលុបបំបាត់សិទ្ធិសេដ្ឋកិច្ចពិសេស។ នេះគឺជាការចង់បាន ពីទស្សនៈនៃប្រសិទ្ធភាពសេដ្ឋកិច្ចនិងសមធម៌។ ទោះយ៉ាងណាក៏ដោយ វាអាចជាការពិបាកក្នុងការឈានដល់កិច្ចព្រមព្រៀងក្នុងរឿងនេះ។ វាអាចមានភាពងាយស្រួលជាងមុន ដើម្បីសម្រេចបាននូវការមូលមតិគ្នាអំពីតម្រូវការសម្រាប់ការព្យាបាលឯកសណ្ឋាននៃតួអង្គសេដ្ឋកិច្ចទាំងអស់នៅពេលដែលផលប្រយោជន៍ផ្សេងៗត្រូវបានប្រមូលផ្តុំគ្នា ដើម្បីចូលរួមក្នុងការបង្កើតយុទ្ធសាស្ត្រមួយជាជាងទុកឱ្យពួកគេចរចាជាលក្ខណៈបុគ្គលជាមួយរដ្ឋាភិបាល។ នៅពេលដែលបញ្ហាធំទូលាយ ត្រូវបានពិភាក្សានៅក្នុងវេទិកាជាមួយអ្នកចូលរួមជាច្រើនអ្នកលេងម្នាក់ៗ អាចដឹងថាការលុបបំបាត់បុព្វសិទ្ធិសម្រាប់អ្នកដទៃទាមទារឱ្យមានភាពស្របគ្នា៖ តក្កវិជ្ជារបស់វាទាមទារឱ្យមានឯកសិទ្ធិទាំងអស់ត្រូវចុះចាញ់។ ការបង្កើតការយល់ដឹង ទូលំទូលាយលើកញ្ចប់កំណែទម្រង់តាមរបៀបនេះ អាចជាមធ្យោបាយមួយដែលមានប្រសិទ្ធភាពជាងក្នុងការលុបចោលសិទ្ធិដែលមានស្រាប់ឬយ៉ាងហោចណាស់កាត់បន្ថយវាយ៉ាងខ្លាំង។

### ៥.១.៣ តួនាទីអប់រំនៃយុទ្ធសាស្ត្រ

តួនាទីសំខាន់បំផុតមួយនៃយុទ្ធសាស្ត្រគឺការលើកកម្ពស់កម្រិតសន្ទនាថ្នាក់ជាតិស្តីពីគោលនយោបាយ។ ដរាបណាការសន្ទនាគោលនយោបាយត្រូវបានធ្វើឡើងរវាងផលប្រយោជន៍ពិសេសនិងមន្ត្រីរដ្ឋាភិបាលលទ្ធផលឃើតជាគំរូនៃការលើកលែងចំពោះវិធាននៃការព្យាបាលឯកសណ្ឋាន។ ការ

ពិភាក្សាបែបនេះមាននិន្នាការត្រូវបានធ្វើឡើងក្នុងលក្ខណៈតូចតាចនៃផលប្រយោជន៍និងការខាតបង់សម្រាប់ក្រុមជាក់លាក់ដែលអាចបណ្តាលមកពីកំណែទម្រង់ទោះបីជាសង្គមទាំងមូលអាចទទួលបានពីពួកគេក៏ដោយ។ ដំណើរការនៃការបង្កើតយុទ្ធសាស្ត្រផ្តល់នូវឱកាសមួយដើម្បីលើកនូវការសន្ទនាទៅកម្រិតនៃបញ្ហាអភិវឌ្ឍន៍ជាតិដែលត្រូវប្រឈមនិងឧបសគ្គដែលត្រូវយកឈ្នះនិងផលចំណេញដល់ប្រទេសជាតិដែលនឹងហូរចេញពីការធ្វើដូច្នេះ។ វាអាចមានតម្លៃអប់រំរយៈពេលវែងសម្រាប់សាធារណជនដែលហួសពីអត្ថប្រយោជន៍ជាក់ស្តែងដែលកើតឡើងតាមរយៈការអនុវត្តផ្នែកសំខាន់ៗរបស់វា។

ការបង្កើតយុទ្ធសាស្ត្រក៏ជាដំណើរការអប់រំសម្រាប់អ្នកចូលរួមផងដែរ។ វាត្រូវបានសង្កត់ធ្ងន់នៅពេលក្រោយនៅក្នុងជំពូកនេះថាតាមដែលអាចធ្វើទៅបានការបង្កើតយុទ្ធសាស្ត្រគួរតែជាដំណើរការចូលរួម។ ក៏ដូចជាការគោរពតម្លៃប្រជាធិបតេយ្យវិធីសាស្ត្របែបនេះពង្រឹងការគាំទ្រយុទ្ធសាស្ត្រ។ វាក៏ជួយកែលម្អខ្លឹមសាររបស់វាផងដែរពីព្រោះអ្នកចូលរួមអាចតំណាងឱ្យជំនាញជាតិល្អបំផុតលើផ្នែកនីមួយៗនៃបញ្ហា។ ទោះយ៉ាងណាក៏ដោយអ្នកជំនាញបច្ចេកទេសមិនតែងតែស៊ាំជាមួយការពិចារណាគោលនយោបាយទាំងអស់នៅក្នុងវិស័យរបស់ពួកគេឡើយ។ ជារឿយៗពួកគេនឹងត្រូវបានធ្វើការទាំងស្រុងនៅក្នុងក្របខ័ណ្ឌគោលនយោបាយដែលមានស្រាប់ហើយពួកគេប្រហែលជាមិនមានទម្លាប់គិតគូរអំពីក្របខ័ណ្ឌជម្រើសទេជាពិសេសការផ្លាស់ប្តូរខុសគ្នាយ៉ាងខ្លាំង។ ដូច្នេះការងារលើយុទ្ធសាស្ត្រអាចផ្តល់នូវដំណើរការសិក្សាសម្រាប់អ្នកចូលរួមទាំងអស់ក្នុងការរៀនសូត្រពីរបៀបកំណត់បញ្ហាគោលនយោបាយដោយខ្លួនឯងតាមវិធីប្រកបដោយផ្លែផ្កានិងវិធីស្វែងរកដំណោះស្រាយតាមទិសដៅដែលមិនធ្លាប់មាន។ ដំណើរការសិក្សាអាចពង្រីកដល់ការផ្តល់ឱ្យអ្នកចូលរួមនូវការយល់ដឹងកាន់តែច្បាស់អំពីរបៀបវារៈរបស់ទីភ្នាក់ងារម្ចាស់ជំនួយតាមរយៈការសន្ទនាជាមួយតំណាងទីភ្នាក់ងារទាំងនោះ។ ជារួមប្រអប់អាចបង្កើតបណ្តាញទំនាក់ទំនងដូច្នេះនាពេលអនាគតទីភ្នាក់ងារម្ចាស់ជំនួយអាចធ្វើការជាមួយថ្នាក់ដឹកនាំសង្គមក្នុងការបង្កើតកម្មវិធីរបស់ពួកគេសម្រាប់ប្រទេសមួយ។ សេចក្តីព្រាងយុទ្ធសាស្ត្រនិងកំណែចុងក្រោយនៃឯកសារអាចមានតួនាទីផ្សេងៗគ្នា។ ក្រោយមកទៀតគឺជាមូលដ្ឋានផ្លូវការសម្រាប់កម្មវិធីអនុវត្តន៍ប៉ុន្តែអតីតកាលគ្រាន់តែដោយសារតែវាមានស្ថានភាពនៃសេចក្តីព្រាងច្បាប់ពេលខ្លះអាចដោះស្រាយបញ្ហាដែលរសើបដែលអ្នកបង្កើតគោលនយោបាយបានរារាំង។ ឧទាហរណ៍នៃតួនាទីនេះត្រូវបានផ្តល់ដោយសេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍDevelopmentន៍ជាតិសម្រាប់ហ្គីយ៉ាណា។ ក្នុងចំណោមបញ្ហាដែលវាបានពិភាក្សាដោយបើកចំហគឺជម្រើសនៃការធ្វើអាជីវកម្មឧស្សាហកម្មជាតិស្ករ។ នៅពេលនោះខុទ្ទកាល័យបានជំទាស់យ៉ាងដាច់ខាតចំពោះជម្រើសនោះហើយតាមពិតទៅវាមិនអាចទៅរួចទេក្នុងការពិភាក្សាសំណួរនៅក្នុងវេទិកាសាធារណៈណាមួយ។ ទោះយ៉ាងណាក៏ដោយចាប់តាំងពីយុទ្ធសាស្ត្រគឺជាសេចក្តីព្រាងបច្ចេកទេសនិងបច្ចេកទេសច្បាស់លាស់មួយសម្រាប់ការពិគ្រោះយោបល់ជាសាធារណៈក្នុងបរិបទនៃការពិនិត្យឡើងវិញនូវជម្រើសសេដ្ឋកិច្ចថ្នាក់ជាតិក្រសួងហិរញ្ញវត្ថុបានយល់ព្រមអនុញ្ញាតឱ្យមានការវិភាគពេញលេញអំពីជម្រើសឯកជនភាវូបនីយកម្ម។ សម្រាប់ហេតុផលនេះវាអាចមានតម្លៃក្នុងការដាក់ស្លាកកំណែដំបូងជាសេចក្តីព្រាងបច្ចេកទេសនិងគូសបញ្ជាក់ការពិតនោះដើម្បីរំដោះការពិភាក្សាពីឧបសគ្គនយោបាយ។

## ៥.២ ដំណើរការការចូលរួមសម្រាប់យុទ្ធសាស្ត្រនៃការអនុវត្តន៍

រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់អាទិភាពខ្ពស់និងបានប្តេជ្ញាយ៉ាងមឺងម៉ាត់ ចំពោះនអធិបតេយ្យភាពជាតិនិងការបង្រួបបង្រួមជាតិ ស្ថេរភាពនិងសណ្តាប់ធ្នាប់សង្គមប្រជាធិបតេយ្យនិងការការពារសិទ្ធិមនុស្ស ការអភិវឌ្ឍប្រកបដោយចីរភាព ដែលនឹងបង្កើនល្បឿនវឌ្ឍនភាព វិបុលភាព ភាពសុខដុមហើយនឹងលើកកម្ពស់ ជីវភាពរស់នៅនិងមោទនភាពចំពោះខ្លួនឯង សម្រាប់ជនកម្ពុជាក្នុងគ្រប់វិជ្ជាជីវៈ។

ដោយមានចក្ខុវិស័យច្បាស់លាស់ រាជដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាចិត្តចំពោះការអនុវត្តតាមគោលការណ៍ ជាមូលដ្ឋានមួយចំនួនដូចខាងក្រោម ដើម្បីនាំប្រទេសជាតិទៅរកវិបុលភាព :

- ការប្រកាន់ខ្ជាប់នូវលទ្ធិប្រជាធិបតេយ្យក្នុងអភិបាលកិច្ច ដែលពលរដ្ឋកម្ពុជាគ្រប់រូបអាចធ្វើការបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួនដោយសេរី ដើម្បីដឹកនាំសង្គមជាតិនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- ការការពារសិទ្ធិបុគ្គល និងសិទ្ធិមនុស្ស រួមទាំងសេរីភាពពេញលេញក្នុងការបញ្ចេញមតិ។
- ការថែរក្សាសន្តិភាព ស្ថេរភាពនយោបាយ នីតិរដ្ឋ សមភាព និងសណ្តាប់ធ្នាប់សង្គម។
- រដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់ត្រូវមាន ការឆ្លើយតប ការទទួលខុសត្រូវ ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងមានសមត្ថភាពអាចដឹងជាមុនបាន យ៉ាងពេញលេញ។
- រាជរដ្ឋាភិបាលត្រូវធានាឱ្យមានស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច បង្កើតនិងថែរក្សាហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនិង

ស្ថាប័នសំខាន់ៗ ក៏ដូចជា បង្កើតបរិស្ថានលើកទឹកចិត្តនិងក្របខ័ណ្ឌច្បាប់មួយសម្រាប់កិច្ចដំណើរការ និង ការរីកចម្រើនរបស់វិស័យឯកជន។

រាជរដ្ឋាភិបាល ត្រូវផ្តល់សេវាសង្គមសំខាន់ៗសម្រាប់ការបង្កើតនិងការលើកកម្ពស់មូលធនមនុស្ស (វិស័យសុខាភិបាល អប់រំ ការអភិវឌ្ឍវប្បធម៌ជាតិ ហើយក្នុងន័យនេះ ត្រូវបង្កើតបរិស្ថានមួយដែល អាចឱ្យបុគ្គលគ្រប់រូប ធ្វើការស្វែងរកនិងធ្វើឱ្យសម្រេចនូវសក្តានុពលពេញលេញរបស់ពួកគេ និងធ្វើការ មចំណែកលើកកម្ពស់សុខុមាលភាពផ្ទាល់ខ្លួនរបស់ពួកគេ និងការរីកចម្រើនរបស់ប្រទេសជាតិ។

រាជរដ្ឋាភិបាលត្រូវធានាការគ្រប់គ្រងប្រកបដោយចីរភាព លើបរិស្ថាននិងធនធានធម្មជាតិរបស់ជាតិ (ព្រៃឈើ ជលផល ដី ទឹក និងជីវចម្រុះ) ដែលស្ថានភាពជីវភាពរស់នៅនិងសុខុមាលភាពរបស់មនុស្ស ត្រូវផ្អែកលើមូលដ្ឋានទាំងនេះ។

ចំណុចនេះ សង្កត់ធ្ងន់លើយុទ្ធសាស្ត្រគន្លឹះនិងចម្បងៗ ដែលត្រូវបាន ការពិគ្រោះយោបល់យ៉ាងទូលំទូលាយ និងបង្ហាញពីទស្សនៈវិស័យរួមមួយនៃយុទ្ធសាស្ត្រនិងស តែបំណោះ។ គោលបំណងសំខាន់នៃ ជំពូកនេះ៖ គឺចង់បង្ហាញតែការណែនាំដ៏ទូលំទូលាយមួយ . ជាការពិពណ៌នាលម្អិតនៃការងារ ដែលកំពុងធ្វើ ឬដែលនឹងត្រូវធ្វើដោយក្រសួងនិងស្ថាប័នទាំងឡាយ , ការងារលម្អិតនិងច្បាស់លាស់ជាងនេះ៖ អាចនឹងត្រូវកំណត់ឡើងនៅក្នុងផែនការតាមវិស័យ ដែល រួចហើយឬនឹងត្រូវរៀបចំក្នុងពេលឆាប់ៗ។ ចំណុចដែលគួរកត់សម្គាល់នោះគឺថា គោលដៅជា សម្រេចឱ្យបានជាទូទៅ គឺជាគោលដៅផ្អែកបរិមាណ។ ទិដ្ឋភាពផ្អែកគុណភាពនៃគោលដៅទាំងឡាយ ជាមានសារៈសំខាន់ មិន

អាចនឹងធ្វើការវាស់វែងបានដោយងាយស្រួលទេ ប៉ុន្តែក្នុងរយៈពេលវែង ទីតា អាចនឹងត្រូវទទួលបានការកត់សម្គាល់ និងសម្តែងឱ្យឃើញ តាមរយៈការកែលម្អ តាមមធ្យោបាយផ្សេងៗ ,

## ៥.៣ ការអភិវឌ្ឍន៍ជនបទ និងការកាត់បន្ថយភាពក្រីក្រ

ដោយហេតុថា ៩០ភាគរយនៃអ្នកក្រស់នៅតំបន់ជនបទ ការយកចិត្តទុកដាក់ពិសេស និងធនធាននិងការវិនិយោគទាំងឡាយដែលបានកំណត់ទុក គឺមានសារៈសំខាន់នៅតំបន់ជនបទ ជាពិសេស តំបន់ដែល មិនបានគ្របដណ្តប់ក្នុងអង្កេតឆ្នាំ១៩៩៣ (និងកន្លែងនានាដែលក្រជាងនៅតាមតំបន់ផ្សេងៗទៀត) ដើម្បីកាត់ បន្ថយកម្រិតភាពក្រីក្រឱ្យបានឆាប់រហ័ស និងដើម្បីធ្វើឱ្យសម្រេចបានចំណុចដៅទាំងឡាយនៃគោលដៅអភិវឌ្ឍន៍ សហស្សវត្សរ៍កម្ពុជា សម្រាប់ឆ្នាំ២០១០និង២០១៥។ ដោយហេតុថា មួយចំណែកធំជាងមុននៃអ្នកក្រ បច្ចុប្បន្ន នេះ៖ កំពុងរស់នៅក្បែរបន្ទាត់ភាពក្រីក្រ” ចំណុចដៅទាំងនេះអាចនឹងសម្រេចបាន។ ការផ្តោតការយកចិត្តទុក ដាក់ជាពិសេសបែបនេះ រួមបញ្ចូលនូវសេវាថែរក្សាសុខភាពនិងសេវាអប់រំ ដែលមានបរិមាណច្រើនជាងមុន និងគុណភាពប្រសើរជាងមុន ការធ្វើឱ្យប្រសើរឡើងនូវប្រាក់ចំណូលតាមរយៈសកម្មភាពនានានៅតំបន់ ជាងបង (ការងារស្រែចំការនិងការងារក្រៅពីស្រែចំការ) ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធជនបទ។ មូលនិធិជាច្រើនបន្ថែមទៀត ត្រូវផ្តល់ទៅដល់វិស័យទាំងនេះ៖ តាមរយៈមូលនិធិឃុំ-សង្កាត់ និងតាមរយៈវិធានផ្សេងៗទៀត។

ការសម្រេចបាននូវវឌ្ឍនភាពដើម្បីកាត់បន្ថយភាពក្រីក្រ ដែលជាបញ្ហាអន្តរវិស័យមួយ ពឹងផ្អែកទាំងស្រុងលើគោលនយោបាយគាំទ្រអ្នកក្រ និងកិច្ចខិតខំប្រឹងប្រែងនៅក្នុងវិស័យផ្សេងៗទៀត។ រាជរដ្ឋាភិបាលកម្ពុជា ធានាថា

- យុទ្ធសាស្ត្រតាមវិស័យទាំងអស់របស់រាជរដ្ឋាភិបាលកម្ពុជា ផ្តោតការយកចិត្តទុកវិជ្ជមានទៅលើភាពក្រីក្រ ដើម្បីសម្រេចបានគោលដៅក្នុងការកាត់បន្ថយសន្ទស្សន នៅត្រឹម ២៥ភាគរយ នៅក្នុងឆ្នាំ២០១០។
- ការវិនិយោគដែលបានកំណត់ទុក និងការយកចិត្តទុកដាក់ ត្រូវបានតម្រង់ទិស ជាពិសេស ឆ្ពោះទៅរក ប្រជាជននិងតំបន់ដែលពុំបានទទួលសេវាកម្មគ្រប់គ្រាន់ ជាពិសេស ប្រជាជននិងតំបន់ដែលមានភាព ក្រីក្រខ្ពស់។
- បន្ថែមពីលើវិធីសាស្ត្រសតាមវិស័យនិងក្នុងកម្រិតជាតិ ហើយរួមទាំងការគាំទ្រពីដៃគូអភិវឌ្ឍន៍ក្រៅ បទេស កម្មវិធីពិសេសនិងថ្មីៗសម្រាប់គាំទ្រដល់កម្រិតមូលដ្ឋាន ដែលមានផលប្រយោជន៍ដោយផ្ទាល់ចំពោះអ្នកក្រ ត្រូវបានរៀបចំបង្កើតឡើងនិងយកទៅអនុវត្ត។

ដោយបានធ្វើឱ្យមានសន្តិភាព សណ្តាប់ធ្នាប់សង្គម និងកំណើនសេដ្ឋកិច្ចរឹងមាំ កម្ពុជាស្ថិតក្នុងចំណុច ចាប់ផ្តើមដ៏សំខាន់សម្រាប់កំណើនលឿននិងប្រកបដោយសមធម៌ជាងមុន។ រយៈពេល១០ឆ្នាំខាងមុខ គឺជាទសវត្សរ៍មួយនៃកាលានុវត្តភាពសម្រាប់ការដឹកនាំប្រទេសឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ កម្ពុជាដែលមានទំហំធំធេង និងការលើកស្ទួយអ្នកក្រនិងជនងាយរងគ្រោះ។ រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញាចាប់ យកកាលានុវត្តភាពនេះ៖ ដើម្បីពង្រឹងនិងកសាងបន្ថែមពីលើសមិទ្ធ

កម្មវិធីផ្តល់ដល់អ្នកក្រីក្រនៅតាមលំដាប់ថ្នាក់ដោយមិនគិតដល់ការអប់រំក្នុងនោះមានរដ្ឋហើយរដ្ឋា ភិបាលបានផ្តល់ថវិកាដល់តំបន់ដាច់ស្រយាលដោយគិតដល់ការគាំពារក្នុងសហព័ន្ធដលបានផ្តល់ថវិកា ការកើតមាននូវភាពក្រីក្រក្នុងតំបន់ដាច់ស្រយាលផ្សេងៗវាមានលក្ខណៈទូលំទូលាយទៅតាមតំបន់ដែលជាការ រីករាលដាលនូវតំបន់ភាគខាងត្បូង ប៉ុន្តែវាបានរួចផុតនៅតំបន់ខ្លះ។ កម្មវិធីភាពក្រីក្រវាហាក់ដូចជានៅក្រោម អំណាចនៃសហព័ន្ធរដ្ឋាភិបាលប៉ុន្តែវាស្ថិតនៅក្រោមឥទ្ធិពលរបស់រដ្ឋទេ។ វាគ្មានការភ្ញាក់ផ្អើលដោយសារការ បន្ថែម៧៥ក្នុងការកើនឡើងទៅលើភាពក្រីក្រក្នុងតំបន់ដាច់% ស្រយាល កម្មវិធីនៃតំបន់បូព៌ាប្រទេសទៅលើការ ត្រូវការបន្ថែមទៀត តំបន់ជនបទដាច់ស្រយាលមានភាពយឺតយ៉ាវនៅពេលជួបបញ្ហាដែលចោទសំខាន់ទៅលើ ការដឹកជញ្ជូនឬផ្ញើរ។ តំបន់ដែលមានលំនៅស្ថានច្រើនមើលហាក់ដូចជាមានអ្នកចូលរួមតិចក្នុងកម្មវិធីភាពក្រីក្រ កម្មវិធីភាពក្រីក្រវាទៅតាមលក្ខខ័ណ្ឌនៃតំបន់ដែលអាស្រ័យទៅលើកត្តាផ្សេងៗទៅលើការផ្លាស់ប្តូរដែលចាំបាច់ ត្រូវមានការទទួលខុសត្រូវក្នុងការជួយសង្គ្រោះ។ បន្ទាប់ពីប៉ាន់ស្មានយើងអាចដឹងនូវតម្លៃធនធានមនុស្សដែល តម្រូវឱ្យឱ្យគាំទ្រក្នុងកម្មវិធីជួយសង្គ្រោះអ្នកក្រីក្រដែលវាស្រដៀងគ្នាទៅអ្នករស់នៅទីក្រុងឬជនបទដាច់ស្រ យាល ការធ្វើបែបនេះលើកម្មវិធីជួយសង្គ្រោះអ្នកក្រីក្រត្រូវមានភាពទទួលខុសត្រូវដែលមានការលំបាកជាងអ្នក រស់នៅជាយក្រុងដាច់ស្រយាល។ ជាមួយគ្នានេះដែរជំរើសខ្លះវាចាំបាច់ត្រូវមានលក្ខខ័ណ្ឌក្នុងតំបន់ដែលមាន ភាពក្រីក្រ។ ប្រាក់សម្រាប់ផ្គត់ផ្គង់កម្មវិធីដែលបង្កើតដោយជំនួយហិរញ្ញវត្ថុដែលចាំបាច់ត្រូវការនៅពេលណាមួយ។ ជំនួយការហិរញ្ញវត្ថុនៅក្នុងកម្មវីធី )AFDC) នេះជាកម្មវិធីសម្រាប់អ្នកនៅលីវ។

ប្រធានបទដ៏ចំបងសម្រាប់កម្មវិធីដែលបង្កើតឡើងនូវហិរញ្ញវត្ថុបណ្តោះអាសន្នសម្រាប់គ្រួសារហើយអ្នក ដែលរស់នៅតែឯងដែលមានភាពគ្រប់គ្រាន់សំរេចបានចាំបាច់ត្រូវមានការលើកទឹកចិត្តឬជំរុញហើយថែរក្សាទៅ លើក្មេងៗជាមួយនិងភាពជាម្ចាស់ផ្ទះ។ ស្តង់ដារគ្រប់គ្រាន់វាមានលក្ខណៈទូលំ

ទូលាយហើយជនួយការមានកំ រិតទូលាយចាប់ពីរដ្ឋដែលបានបង្កើតនូវអ្វីៗដែលប្លែកសម្រាប់គ្រួសារដែលមានចំណូលទាបការចំណាយ និងបន្ថែម លើកម្រិតនៃសេរីភាពជាលទ្ធផលបន្ទាប់ពីតម្រូវការដែលមានការចែករំលែកនូវកម្មវិធីដែលទប់ទ្រព្យសម្បត្តិវាំង សមត្ថភាពដែលឲ្យរដ្ឋធ្វើការចំណាយ សារៈសំខាន់ក្នុងចំណូលផ្គត់ផ្គង់ជាជំរើសដែលរួមបញ្ចូលនូវអ្នកដែលមាន ចំណូលទាបទៅលើសហគមន៍ជនបទនៅតម្លៃនៃប្រាក់ចំណូលនៅទីក្រុង កំរៃលើគ្រួសារត្រូវមានផែនការដើម្បីកាត់ បន្ថយនៅការចំណាយ។

## ៦.៨. ការបន្តស្ថានិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត

ការងារនេះ៖ គឺជាចតុកោណមួយសម្រាប់កំណើននៃយុទ្ធសាស្ត្រចតុកោណនេះ៖ ដែលគ្របដណ្តប់ (ក) ការ យលងបន្ថែមទៀតនូវហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន (ខ) ការគ្រប់គ្រងធនធានទឹកនិងប្រព័ន្ធជាវសាស្ត្រ (គ) ការ ឱ្យវិស័យថាមពល និងបណ្តាញអគ្គិសនី (ឃ) ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍។

ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន : បណ្តាញនិងប្រព័ន្ធដឹកជញ្ជូនដែលតភ្ជាប់គ្រប់ទីកន្លែងនៃប្រសរសៃឈាម ដែលជួយឱ្យកម្ពុជាមានសេដ្ឋកិច្ចចម្រុនមួយ ហើយមានសារៈសំខាន់បំផុតសម្រាប់កំលើដែលបែងចែកទៅគ្រប់វិស័យ។ ដោយជួយសម្រួលដល់ពាណិជ្ជកម្ម ការផ្លាស់ប្តូរទំនិញនិងសេវាកម្មដោ ជំរុញសមាហរណកម្មទីផ្សារក្នុងស្រុក ក៏ដូចជា ដោយជួយឱ្យមានសមាហរណកម្មទៅក្នុងតំបន់និស.. ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ។ ហេដ្ឋារចនាសម.. រួមមាន ផ្លូវថ្នល់ កំពង់ផែ ផ្លូវទឹកក្នុងប្រទេស ផ្លូវដែក និងអាកាសយានដ្ឋាន។ គោលដៅនៃការងារនេះ បង្កើតបណ្តាញគមនាគមន៍មួយដែលមានភាពងាយស្រួលមានភាពទូលំទូលាយ មានសុវត្ថិភាព ភាពសេដ្ឋកិច្ច ដែលជួយសម្រួលដល់ការធ្វើពាណិជ្ជកម្ម ជំរុញលើកទឹកចិត្តវិស័យទេសចរណ៍ ការអភិវឌ្ឍ និងបម្រើដល់កិច្ចការការពារជាតិ។

ខិតខំស្តារ កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងផ្នែកទាក់ទងដល់ការអភិវឌ្ឍផ្សេងៗ ដែលនឹងផ្តោតការ យកចិត្តទុកដាក់បង្កើនសមាហរណកម្មអភិវឌ្ឍន៍ក្នុងតំបន់ដូចខាងក្រោម :

- ទាក់ទាញទេសចរណ៍ (ដោយរាប់បញ្ចូលតំបន់ត្រីកោណ សៀមរាប ព្រះវិហារនិង កំពង់ធំ និងតំបន់
- សេដ្ឋកិច្ចទេសចរណ៍)។
- តបន់ឧស្សាហកម្ម ដោយរាប់បញ្ចូលអាគារពាណិជ្ជកម្ម និងតំបន់តាមបណ្តោយឆ្នេរ។
- តំបន់កសិឧស្សាហកម្ម។

ការងារយ៉ាងច្រើនត្រូវបានអនុវត្តក្នុងការស្តារផ្លូវគ្រប់ប្រភេទ និងក្នុងការផ្តល់សារៈសំខាន់ទៅឱ្យបណ្តោញ ផ្លូវថ្នល់ ដែលជាផ្នែកនៃបណ្តាញផ្លូវថ្នល់អាស៊ាន។ អាទិភាពសម្រាប់ដំណាក់កាលនៃ ផយអជ គឺ

- បញ្ចប់ការរៀបចំនិងអនុម័តច្បាប់ប្រើប្រាស់ផ្លូវថ្នល់ ដើម្បីជំនឧកង្វះខាតក្នុងដំណើរការរៀបចំផែនការ និងថវិកា ដែលមានលក្ខណៈឯកភាពនិងជាប្រព័ន្ធ និងដើម្បីកំណត់ឱ្យបានច្បាស់លាស់

នូវតួនាទីនិងការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលក្នុងការងារជួសជុលនិងថែទាំផ្លូវថ្នល់។

- កំណត់អាទិភាព ស្តារ និងជួសជុលឡើងវិញ នូវផ្លូវសំខាន់ៗទៅតាមលទ្ធភាពដែលអាចធ្វើបាន។
- ផ្តល់អាទិភាពដល់ឃុំឬភូមិដែលពុំទាន់មានផ្លូវទៅដល់_ពង្រីកបណ្តាញផ្លូវជនបទដើម្បីធានាថាឃុំទាំងមានលទ្ធភាពងាយស្រួលក្នុងការធ្វើដំណើរទៅកាន់ទីរួមស្រុក និងទៅកាន់បណ្តាញផ្លូវជាតិនិងផ្លូវខេត្ត
- ដោះស្រាយបញ្ហាជូនប្រជាជនដែលត្រូវរុះរើទីលំនៅដោយមូលហេតុនៃការសាងសង់ផ្លូវថ្នល់ ដែ"
- ដោយសទ្ធិវិធី និងតាមផ្លូវច្បាប់។
- ជានាឱ្យមានការថែទាំគ្រប់ប្រភេទផ្លូវទាំងអស់ទៅតាមអាទិភាពឱ្យបានសមស្របជាងមុន ដោយត្រូវគិត ថា នៅពេលណាដែលផ្លូវត្រូវបានកែលម្អរួចហើយ ការកើនឡើងនៃចរាចរ នឹងធ្វើឱ្យមានការខូចខាតផ្លូវ ហើយតម្រូវឱ្យមានការថែទាំផ្លូវប្រសើរនិងញឹកញាប់ជាងមុន។
- ប្រើប្រាស់ឱ្យអស់លទ្ធភាពនូវវិធានការដែលប្រើប្រាស់កម្លាំងពលកម្មច្រើន ជាពិសេសសម្រាប់ការសាង សង់និងថែទាំផ្លូវជនបទ ដើម្បីបង្កើនចំណូលជនបទ។
- ធ្វើឱ្យមានការចូលរួមពីផ្នែកឯកជន ក្នុងការសាងសង់និងថែទាំផ្លូវ ស្ពាន ដោយប្រើប្រាស់រូបភាព សាង សង់-ដំណើរការ-ផ្ទេរ និងរូបភាពផ្សេងៗទៀត ដែលការចំណាយអាចប្រមូលបានវិញតាមរយៈការទារពន្ធពីអ្នកដែលធ្វើចរាចរឆ្លងកាត់។

ក្រៅពីផ្លូវជនបទដែលបានលើកឡើងរួចមកហើយ និងបន្ថែមពីលើការងារជួសជុលនិងស្តារឡើងវិញផ្លូវឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ចំណុចដៅជាបរិមាណដែលត្រូវសម្រេចឱ្យបាននៅក្នុងដំណាក់កាល ៨យអធ (២០០៦-២០១០) គឺត្រូវលើកកម្ពស់ផ្លូវជាតិនិងផ្លូវខេត្តប្រវែង ២.០០០ គីឡូម៉ែត្របែមទៀត ដែលនឹងធ្វើឱ្យ ប្រវែងសរុបនៃផ្លូវដែលនឹងត្រូវលើកកម្ពស់មានដល់ ៤.១០០គីឡូម៉ែត្រ។

**កំពង់ផែ** ៖ ការនាំចូលនិងការនាំចេញទំនិញដែលមានបរិមាណច្រើន ស្ទើរតែទាំងអស់ គឺត្រូវលើកដាក់ នៅកំពង់ផែពីរ_កំពង់ផែក្រុងព្រះសីហនុនិងកំពង់ផែក្រុងភ្នំពេញ ហើយកំពង់ផែក្រុងភ្នំពេញអាចទទួលបានតែ កប៉ាល់តូចៗល្មមប៉ុណ្ណោះ។ ដើម្បីលើកដាក់បរិមាណទំនិញដែលមានការកើនឡើង កំពង់ផែក្រុងព្រះសីហនុកំពុង ត្រូវបានលើកកម្ពស់សមត្ថភាពលើកដាក់ ហើយឃ្លាំងស្តុកកុងទែណឺដំណាក់កាលទី២ នឹងត្រូវសាងសង់ឡើង។

**ផ្លូវដែក** ៖ បណ្តាញផ្លូវដែកពីរខ្សែដែលមួយខ្សែតភ្ជាប់ពីភ្នំពេញទៅក្រុងព្រះសីហនុ និងមួយខ្សែទៀត តភ្ជាប់ពីភ្នំពេញទៅព្រំប្រទល់ប្រទេសថៃ ចាំបាច់ត្រូវធ្វើការជួសជុល និងកែលម្អឡើងវិញជាបន្ទាន់ ហើយកំណាល់ ផ្លូវដែកទាំងអស់ក៏ត្រូវធ្វើការជួសជុលផងដែរ។ អាទិភាពមួយទៀត គឺត្រូវស្តារឡើងវិញបណ្តាញផ្លូវដែកភាគ ខាងត្បូង ដើម្បីដឹកជញ្ជូនទំនិញដែលមានបរិមាណច្រើនជាងពីកំពង់ផែក្នុងអត្រាតម្លៃដឹកជញ្ជូនដែលមានលក្ខណៈ ប្រកួតប្រជែង។

**ផ្លូវទឹកក្នុងប្រទេស** : អាទិភាពបន្ទាន់ចំពោះមុខ គឺត្រូវស្តារឡើងវិញម៉ាស៊ីនបូមដី ដើម្បីបូមដីស្តារបោត ទន្លេនៅតាមបណ្តោយផ្លូវទឹកសំខាន់ៗទាំងអស់ ជាពិសេសទន្លេមេគង្គនិងទន្លេសាប ដើម្បីសម្រួលដល់ការដឹកជញ្ជូនតាមផ្លូវទឹកតាមទន្លេ។

**សេវាកម្មអាកាសចរណ៍ស៊ីវិល** ដើរតួយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ ដែលជាវិស័យស្នូលដែលមានឥទ្ធិពលយ៉ាងធំធេងដល់សេដ្ឋកិច្ចជាតិ។ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងអាកាសយានដ្ឋានអន្តរជាតិកងកេង (ក្រុងព្រះសីហនុ) នឹងត្រូវធ្វើការកែលម្អថែមទៀតទៅតាមកិច្ចព្រមព្រៀង សាងសង់-ដំណើរការ-ផ្ទេរ ដែលមានស្រាប់។ អាកាសយានដ្ឋានអន្តរជាតិសៀមរាប ក៏ត្រូវធ្វើការពង្រីកនិងតែត តាមស្តង់ដារអន្តរជាតិ។ អាកាសយានដ្ឋានក្នុងស្រុកមួយ ចំនួនចាំបាច់ត្រូវធ្វើការកែលម្អឱ្យមាន មុន ដើម្បីបង្កលក្ខណៈឱ្យមានចរាចរញឹកញាប់ជាងមុនទៅកាន់តំបន់ដាច់ស្រយាលដែលមាន ចរណ៍ខ្ពស់។ រាជរដ្ឋាភិបាលកម្ពុជានឹងខិតខំស្វែងរករូបភាព ផ្សេងៗទៀតក្នុងការផ្តល់ហិរញ្ញបនា តាមរយៈរូបភាព សាងសង់-ដំណើរការ-ផ្ទេរ ដែលពាក់ព័ន្ធជាមួយផ្នែកឯកជន។

**ការគ្រប់គ្រងធនធានទឹក និងការស្រោចស្រព** : ធនធានទឹកបានចូលរួមគាំទ្រដល់តមe.. ជាច្រើននៃសេដ្ឋកិច្ចជាតិ។ នាពេលបច្ចុប្បន្ន សម្ពាធដ៏ធ្ងន់ធ្ងរមកលើធនធានទឹក ដែលធ្វើឱ្យហានិង បំពុលមានកម្រិតខ្ពស់ បង្កឡើងដោយសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ច តែងតែកើតមានឡើងនារដូវប្រាំង បកា.. បន្ទាយរយៈពេលនៃគ្រោះរាំងស្ងួត។ ម្យ៉ាងទៀត បរិមាណទឹកដ៏លើសលប់នៅរដូវវស្សា បង្កឱ្យមានទឹកដែលធ្វើឱ្យបាត់បង់អាយុជីវិតមនុស្ស-សត្វ និងបង្កការលំបាកដល់ការរស់នៅរបស់ប្រជាជន ព្រមទាំងផសស របស់ជាតិមានការធ្លាក់ចុះ។ គោលបំណងនៃការកាត់បន្ថយនូវគ្រោះថ្នាក់ដែលបង្កឡើងដោយបាតករ ធម្មជាតិខាងលើ គឺត្រូវអនុម័តវិធីសាស្ត្ររួមក្នុងការអភិវឌ្ឍនិងការគ្រប់គ្រងធនធានទឹក។ ការអភិវឌ្ឍនិងការ គ្រប់គ្រងធនធានទឹក ត្រូវផ្តោតការយកចិត្តទុកដាក់លើ (ក) ការធានាឱ្យបានទាំងបរិមាណទឹកគ្រប់គ្រាន់ និង គុណភាពទឹកសមស្របសម្រាប់បំពេញតម្រូវការឱ្យបានពេញមួយឆ្នាំដល់គ្រប់វិស័យ ព្រមទាំងថែរក្សាឱ្យបាននូវ ប្រព័ន្ធអេកូឡូស៊ីនៃទឹក (ខ) ការគ្រប់គ្រងឱ្យបាននូវលំហូរទឹកជំនន់ និងបង្កើនសមត្ថភាពសហគមន៍ដើម្បីទប់ទល់ នឹងទឹកជំនន់ (គ) ការគ្រប់គ្រងទឹកសម្រាប់កសិកម្ម តាមរយៈការបង្កើនសមត្ថភាពអាងស្តុកទឹក ការសាងសង់ប្រព័ន្ធធារាសាស្ត្រនិងប្រឡាយដោះទឹកសមស្រប (ឃ) ការរក្សាធនធានទឹកកុំឱ្យមានភាពក្រខ្វក់ដើម្បីទ្រទ្រង់ ដល់ប្រព័ន្ធអេកូឡូស៊ី ជាពិសេស សំរាប់មច្ឆា។ សកម្មភាពជាអាទិភាពលើការអភិវឌ្ឍនិងគ្រប់គ្រងធនធានទឹក សម្រាប់រយៈពេល ៥ឆ្នាំ ខាងមុខរួមមាន :

- ស្តារនិងជួសជុលឡើងវិញនូវប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធដោះទឹក ដែលមានស្រាប់នៅក្នុងតំបន់។
- ភាពក្រីក្រមានកំរិតខ្ពស់ និងនៅតាមតំបន់ព្រំដែន។
- ពង្រឹងនិងពង្រីកសមត្ថភាពអាងស្តុកទឹក ព្រមទាំងជំរុញការប្រើប្រាស់បច្ចេកវិទ្យារក្សាទឹកទុក។
- បង្កើនការប្រើប្រាស់ធនធានទឹកក្រោមដីនៅតំបន់ដែលខ្សត់ទឹកលើដី ឱ្យមានប្រសិទ្ធភាពនិងនិរន្តរភាព

- រៀបចំនិងអនុវត្តន៍នូវវិធានការគ្រប់គ្រងនិងកាត់បន្ថយទឹកជំនន់ និងគ្រោះរាំងស្ងួត។
- ពង្រឹងនិងបង្កើនសហគមន៍កសិករប្រើប្រាស់ទឹក ដោយលើកទឹកចិត្តឱ្យស្ត្រីចូលរួមជាសមាជិក។
- ជំរុញការវិនិយោគវិស័យឯកជនលើការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធដោះទឹក និងទៀត ដែលពាក់ព័ន្ធការគ្រប់គ្រងទឹកសម្រាប់កសិកម្ម។
- កែលម្អនិងតម្លើងប្រព័ន្ធតាមដានអង្កេតនិងត្រតពិនិត្យឧតុនិយម-ជលសាស្ត្រនៅទូទាំងប្រទេស ដើម្បី បង្កើនគុណភាព និងប្រសិទ្ធភាពការព្យាករណ៍ឧតុនិយម-ជលសាស្ត្រ ក្នុងគោលបំណងបម្រើដល់ការកសាងសេដ្ឋកិច្ច-សង្គមជាតិ ព្រមទាំងផ្តល់ព័ត៌មានស្តីពីអាកាសធាតុ-ជលសាស្ត្រឱ្យបានទាន់ពេលវេលាជូនដល់សាធារណៈជន។
- ជំរុញការគ្រប់គ្រងអាងទន្លេ និងការបែងចែងទឹកឱ្យបានសមស្របនិងមានប្រសិទ្ធភាព។

**វិស័យថាមពលនិងអគ្គិសនី** : ការបន្តអភិវឌ្ឍវិស័យថាមពលជាផ្នែកសំខាន់មួយក្នុងចំណោមគោល នាយសំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងការកើនឡើងនៃ ... គិសនី។ ចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាលកម្ពុជា គឺត្រូវធានាឱ្យមានសន្តិសុខថាមពលនៅទូទាំងប្រទេស។ ប្រព័ន្ធផលិតកម្ម ប្រព័ន្ធបញ្ជូន និងប្រព័ន្ធចែកចាយ ថាមពលក្នុងស្រុក នឹងត្រូវដាក់ឱ្យដំណើរការដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍នៅតាមទីប្រជុំជននិងជនបទ និងតម្រូវការនៅក្នុងសេដ្ឋកិច្ចមួយ ដែលកំពុងរីកចម្រើន។ យុទ្ធសាស្ត្រវិស័យថាមពលរបស់កម្ពុជារយៈពេល ១៥ឆ្នាំ ២០០៦-២០២០ កំពុងដំណើរ ការរៀបចំ។ យុទ្ធសាស្ត្រនេះ៖ ស្នើឡើងដើម្បីឱ្យមានភាពជាម្ចាស់ការក្នុងវិស័យថាមពល តាមរយៈ ពាណិជ្ជកម្ម ថាមពលអគ្គិសនី និងការផ្លាស់ប្តូរថាមពលអគ្គិសនីជាមួយប្រទេសជិតខាង និងសមាហរណកម្មទៅក្នុងតំបន់។ ការផលិតថាមពលអគ្គិសនីនិងការធ្វើឱ្យអគ្គិសនីមានថ្លៃទាប នឹងអាចកាត់បន្ថយបានភ្លាមៗនូវការចំណាយផលិតកម្ម នៅក្នុងវិស័យកម្មន្តសាល និងការចំណាយប្រតិបត្តិការនៅក្នុងវិស័យផ្សេងៗទៀត ហើយតាមរយៈនេះនឹងមានការ ទាក់ទាញការវិនិយោគនិងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច។ រាជរដ្ឋាភិបាលកម្ពុជាឱ្យតម្លៃខ្ពស់ដល់ការចូលរួមរបស់ផ្នែក ឯកជន ក្នុងការនាំមុខនៅក្នុងដំណើរការវិនិយោគនៅក្នុងវិស័យនេះ។

យុទ្ធសាស្ត្ររយៈពេលមធ្យម រួមមាន :

- បន្តធ្វើការជួសជុលនិងសាងសង់រោងចក្រថាមពលក្នុងស្រុក។
- ខិតខំបញ្ចៀសការប្រើប្រាស់ប្រភពថាមពល ដែលមានថ្លៃខ្ពស់ហើយយកចិត្តទុកដាក់ជំរុញអភិវឌ្ឍប្រភពថាមពលដែលមានថ្លៃទាប។
- ទិញថាមពលអគ្គិសនីនៅក្នុងថ្លៃសមស្របពីប្រទេសជិតខាង តាមរយៈកិច្ចព្រមព្រៀងទ្វេភាគី ដែលនឹងត្រូវពិនិត្យនិងកែសម្រួលទៅតាមពេលវេលាកំណត់ជាក់លាក់។
- បន្តតម្លើង និងពង្រីកប្រព័ន្ធបញ្ជូន និងបែងចែកថាមពលអគ្គិសនីកម្រិតជាតិ។
- បន្តពង្រីកការធ្វើអគ្គិសនីភាវូបនីយកម្មនៅតំបន់ជនបទ។

**ប្រេងនិងឧស្ម័ន** : លទ្ធភាពខ្ពស់ក្នុងការរុករកធនធានប្រេងនិងឧស្ម័នក្នុងសមុទ្រនៅក្នុងប្រទេស និងផ្តល់នូវការលើកស្ទួយដល់សេដ្ឋកិច្ចជាតិ។ បញ្ហាប្រឈមចំពោះមុខ គឺត្រូវរៀបចំផែនការពីពេលបច្ចុប្បន្ននេះទៅដើម្បីប្រើប្រាស់ប្រភពថាមពលនេះ និងប្រើប្រាស់ចំណូលដែលទទួលបានពីប្រភពធនធាននេះ៖ តាមរ ល្អបំផុត សំដៅទាញយកផលប្រយោជន៍សម្រាប់ប្រទេសជាតិនិងប្រជាពលរដ្ឋក្នុងរយៈពេលមធ្យម និង វែង។ រាជរដ្ឋាភិបាលកម្ពុជានឹងចាប់ផ្តើមធ្វើការសិក្សាស្រាវជ្រាវក្នុងពេលឆាប់ៗនេះ៖ ដើម្បីជ្រើស ពិសោធន៍ល្អ១ និងចៀសវាងគ្រោះថ្នាក់ ទាំងឡាយដែលធ្លាប់បានកើតឡើងនៅតាមបណ្តាប្រទេសជពិន.. ឧស្ម័នដែលបានពីអណ្តូងប្រេងក្នុងសមុទ្រ (បើមិនដូច្នោះទេឧស្ម័នទាំងនោះនឹងឆេះចោលនៅកន្លែង ត្រូវបានយកមកប្រើប្រាស់ក្នុងរូបភាពផ្សេងៗដែលមានប្រយោជន៍សម្រាប់ផលិតកម្ម នៅលើជីគោក » មកប្រើប្រាស់សម្រាប់ផលិតកម្មជី សម្រាប់ការផលិតថាមពលសម្រាប់ធ្វើជាប្រភពថាមពលតាម ឧស្សាហកម្មជាច្រើនប្រភេទ។ រាជរដ្ឋាភិបាលកម្ពុជានឹងធ្វើការសិក្សាស្រាវជ្រាវ និងខិតខំប្រឹងប្រែង.. ដំណើរការហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ដើម្បីឱ្យធនធានប្រេងនិងឧស្ម័នដ៏មានតម្លៃ (រាប់បញ្ចូលទាំងឧស្ម័នដែលគេ ពីអណ្តូងប្រេង) ត្រូវបានយកទៅប្រើប្រាស់ ដោយមានសារប្រយោជន៍ទៅតាមលទ្ធភាពដែលអាចធ្វើបាន។

**បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍** : ចក្ខុវិស័យរយៈពេលវែងនៃការអភិវឌ្ឍ គឺត្រូវអភិវឌ្ឍប្រព័ន្ធ ទូរគមនាគមន៍និងប្រៃសណីយ៍មួយដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចនិងមានគុណភាពកម្រិតពិភពលោក ដែលត្រូវ គ្របដណ្តប់ទូទាំងប្រទេស។ ការសម្រេចបានចក្ខុវិស័យនេះ ទាមទារឱ្យមានការវិនិយោគខ្ពស់ ដើម្បីកសាង មូលដ្ឋាននៃហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធទូរគមនាគមន៍ទាំងឡាយ ជាពិសេស ខ្សែកាបអុបទិចដែលអាចប្រើប្រាស់ល្បឿនខ្ពស់ ដើម្បីរៀបចំប្រព័ន្ធទូរគមនាគមន៍ទាំងឡាយនៅជនបទ។ បញ្ហាប្រឈមបន្ទាន់ចំពោះ មុខ គឺការ បញ្ចុះតម្លៃសេវាទូរគមនាគមន៍ ដែលជាជំនួយដល់អាជីវកម្មនិងប្រជាជនជាទូទៅ។ វិស័យទូរគមនាគមន៍និង ព័ត៌មានវិទ្យា ត្រូវដាក់ឱ្យដំណើរការសម្រាប់ធ្វើឱ្យប្រសើរឡើងនៃស្ថានភាពរស់នៅរបស់អ្នកក្រ។ អាទិភាពទាំង ឡាយសម្រាប់ដំណាក់កាល ផយអជ (២០០៦-២០១០) គឺ :

- បន្ទាបតម្លៃខ្ពស់របស់សេវាកម្មទូរគមនាគមន៍ ឱ្យបានឆាប់រហ័ស។
- ពង្រីកបណ្តាញទូរគមនាគមន៍ទាំងឡាយនៅក្នុងតំបន់ទីប្រជុំជន និងពង្រីកបណ្តាញទាំងនោះទៅដល់ទីប្រជុំតូចៗ និងតំបន់ជនបទ។
- ពង្រីកសេវាប្រៃសណីយ៍ពីតំបន់ទីក្រុង-ទីប្រជុំជន ដល់តំបន់ជនបទប្រកបដោយគុណភាព មានតម្លៃថោកសមរម្យ និងពង្រឹងសមត្ថភាពស្ថាប័នគ្រប់គ្រង។
- ពង្រីកនិងធ្វើឱ្យប្រសើរឡើងនូវវិសាលភាព ប្រសិទ្ធភាព និងគុណភាពនៃបណ្តាញផ្សព្វផ្សាយរបស់
- វិទ្យុ ទូរទស្សន៍ និងទីភ្នាក់ងារសារព័ត៌មាន។
- បន្តអនុវត្តគោលនយោបាយបើកទូលាយក្នុងការជំរុញការចូលរួមរបស់ផ្នែកឯកជន។

ការផ្តោតការយកចិត្តទុកដាក់នឹងនៅតែបន្ត ទៅលើការជំរុញការប្រើប្រាស់យ៉ាងទូលំទូលាយនូវបច្ចេកវិទ្យា មាន នៅក្នុងគ្រប់រាល់រូបភាពនៃការគ្រប់គ្រងក្នុងរដ្ឋាភិបាល ដើម្បីធ្វើឱ្យប្រសើរឡើងនូវការ

រក្សាប្រកបដោយ សិទ្ធភាពនូវឯកសារនានា ទិន្នន័យមូលដ្ឋាន និងគេហទំព័រ ដែលនឹងផ្តល់ភាពងាយស្រួលប្រើប្រាស់ដល់ជនទាំងឡាយ លើគ្រប់រូបភាពនៃសេចក្តីត្រូវការ។ ក្រសួង-ស្ថាប័ននីមួយ១ នឹងបង្កើតគេហទំព័រផ្ទាល់ ng ហើយកែលម្អវាឱ្យទាន់ពេលវេលាក្នុងរាល់៦ខែម្តង ឬញឹកញាប់ជាងនេះទៅតាមតម្រូវការចាំបាច់។ គេហទំព័រទាំងនេះ នឹងមានផ្ទុកនូវទិន្នន័យនិងព័ត៌មានទាំងអស់ ដែលមានការទាក់ទងទៅនឹងក្រសួង-ស្ថាប័ន។

## ៦.៩.ការអភិវឌ្ឍផ្នែកឯកជននិងការបង្កើតការងារ

មុំទាំងបួននៃចតុកោណនេះគឺ : (ក) ការពង្រឹងផ្នែកឯកជន និងការទាក់ទាញការវិនិយោគ (ខ) ការ លើកសយសហគ្រាសធុនតូចនិងមធ្យម (គ) ការបង្កើតការងារ និងធានាលក្ខខណ្ឌការងារល្អប្រសើរជូនកម្មករ និងនិយោជិត និង (ឃ) ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម។

ការពង្រឹងផ្នែកឯកជន : ផ្នែកឯកជន ត្រូវបានចាត់ទុកជាកម្លាំងជំរុញចម្បងនៃកំណើនសេដ្ឋកិច្ច ទន្ទឹមគ្នានឹងពេលដែលរដ្ឋាភិបាលដើរតួយ៉ាងសំខាន់ជាអ្នករៀបចំយុទ្ធសាស្ត្រ មគ្គទេសក៍ និងអ្នកគ្រប់គ្រងដំណើរ ការអភិវឌ្ឍ ហើយជាអ្នកសម្រាលក្នុងការបង្កើតឱ្យមាននូវបរិយាកាសល្អប្រសើរសម្រាប់ការវិនិយោគឯកជននិង សហគ្រាស។ ដើម្បីដោះស្រាយបញ្ហាសំខាន់ទាំងឡាយដែលបង្អាក់ដល់ការអភិវឌ្ឍផ្នែកឯកជននៅកម្ពុជា" ផែនការ ១២ ចំណុច ដែលលើកឡើងពីការប្តេជ្ញាចិត្តទាំងឡាយរបស់រាជរដ្ឋាភិបាល ដើម្បីធ្វើឱ្យប្រសើរឡើងបរិយាកាសវិនិ យោគ និងសម្រួលដល់ពាណិជ្ជកម្ម ត្រូវបានអនុម័ត។

រាជរដ្ឋាភិបាលនឹងបន្តជំរុញ រក្សា និងលើកកម្ពស់បរិយាកាសអំណោយផលនេះ តាមរយៈ :

- ការបង្កើនសមាហរណកម្មសេដ្ឋកិច្ចកម្ពុជានៅក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក។
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលចាំបាច់ និងការធ្វើឱ្យមានកម្លាំងពលករជំនាញ (តាមរយៈការអប់រំ បណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈនិងការបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗទៀត)។
- បង្កើត និងអនុវត្តតំបន់សេដ្ឋកិច្ចពិសេស ដើម្បីទាក់ទាញវិនិយោគផ្ទាល់ពីបរទេស និងបង្កើតការងារ ជូនប្រជាជន។
- ការពង្រឹងជាបន្តទៀតនូវក្របខណ្ឌច្បាប់សម្រាប់សហគ្រាស រួមមានច្បាប់ លិខិតបទដ្ឋាន និងសមត្ថភាព ស្ថាប័នដែលសម្រួលដល់ការធ្វើអាជីវកម្មជំនួញ និងការវិនិយោគឯកជន ក្នុងបរិយាកាសមួយដែល មានការប្រកួតប្រជែងដោយស្មើភាពគ្នា តម្លាភាព គណនេយ្យភាព និងភាពអាចព្យាករណ៍បាន។
- ការផ្លាស់ប្តូរប្រកបដោយប្រសិទ្ធភាពនិងយ៉ាងឆាប់រហ័ស នូវកត្តាចម្បងៗទាំងឡាយដែល កំណើនផ្នែកឯកជន ដែលបានកំណត់ក្នុងការអង្កេតបរិយាកាសវិនិយោគ១ ដូចជា អភិបាលកិច្ចបន្ទុកផ្នែកទិដ្ឋភាពច្បាប់ ភាពខ្សោយនៅក្នុងបរិយាកាសតុលាការនិងច្បាប់។
- ការលុបបំបាត់នូវភាពមិនប្រាកដប្រជានិងភាពមិនអាចព្យាករណ៍បានដែលមាននាពេលបច្ចុប្បន្ន »...ឡើងដោយកត្តាដូចបានពោលខាងលើ ដែលធ្វើឱ្យអ្នកវិនិយោគពិតប្រាកដនិងសម្រាប់រយៈពេល ចៀសចេញពីកម្ពុជា ដោយធ្វើឱ្យគេអាចយល់បានថា អ្នកវិនិយោគទាំងឡាយណា

ដែលនៅកម . អ្នកចង់ទាញយកផលចំណេញភ្លាមៗ និងឆ្លៀតឱកាសរកចំណេញ ឬក៏ធ្វើអាជីវកម្មនៅក្នុងផ្នែកមិនជកា ដើម្បីគេចពន្ធ ហើយជាមួយនេះ៖ ដើម្បីរកផលចំណេញឱ្យបានច្រើនបំផុត។

- ការដាក់ឱ្យដំណើរការ ច្រកចេញចូលតែមួយ " ជាយន្តការសម្របសម្រួលមួយដ៏ឆាប់រហ័សរបស់ ភិបាល សម្រាប់ពាណិជ្ជកម្ម និងអ្នកវិនិយោគទាំងអស់។
- ការបន្តការពិភាក្សាដោយចំហជាមួយផ្នែកឯកជន តាមរយៈវេទិកាផ្នែកឯកជន និងគណៈកម្មាធិការសម្រាប់អភិវឌ្ឍន៍ផ្នែកឯកជន ដើម្បីដោះស្រាយការព្រួយបារម្ភទាំងឡាយរបស់ផ្នែកឯកជន។

ដើម្បីលើកកម្ពស់កំណើនដែលនាំមុខដោយការនាំចេញ និងកំណើនដើម្បីគាំទ្រអ្នកក្រ តាមរយៈការ ធ្វើពិពិធកម្ម រាជរដ្ឋាភិបាលនឹងបន្តលើកទឹកចិត្ត សម្រួល និងផ្តល់ការគាំទ្រដល់ការវិនិយោគផ្នែកឯកជន ក្នុងវិស័យមួយចំនួន និងក្នុងវិស័យអាទិភាព ដូចខាងក្រោម :

- កសិកម្ម និងកសិ-ឧស្សាហកម្ម រួមទាំង ជាវាសាស្ត្រ ដោយសារវិស័យទាំងនេះមានសក្តានុពលខ្ពស់សម្រាប់កំណើនខ្លាំង និងមានផលប៉ះពាល់ខ្លាំងលើសេដ្ឋកិច្ច តាមរយៈការបង្កើនចំណូលក្នុងតំបន់ជនបទ និងបង្កើនតម្រូវការ។
- ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងទូរគមនាគមន៍។ • ការផលិតនិងការចែកចាយថាមពលអគ្គិសនី។
- ឧស្សាហកម្មដែលត្រូវការកម្លាំងពលកម្មច្រើន និងកម្មន្តសាលកែច្នៃសម្រាប់ការនាំចេញ។
- ទេសចរណ៍ និងវិស័យពាក់ព័ន្ធ។
- ការអភិវឌ្ឍធនធានមនុស្ស។

**ពាណិជ្ជកម្ម** : ដោយផ្សារភ្ជាប់ផលិតកម្មទៅនឹងការប្រើប្រាស់ឬអ្នកផលិតទៅនឹងអ្នក ពាណិជ្ជកម្ម គឺជាមធ្យោបាយដ៏សំខាន់ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច។ ការជំរុញលើកទឹង ពាណិជ្ជកម្មសម្រាប់ផលិតផលកម្ពុជា គឺជាអាទិភាពខ្ពស់ក្នុងចំណោមអាទិភាពទាំងឡាយរបស់រាជរដ្ឋាភិបាល។ ប្រសិនបើមានការលក់ដូរនៅទីផ្សារ ការវិនិយោគអាចនឹងហូរចូល ដើម្បីលើកទឹកចិត្តនិងលើកកម្ពស់ផលិតកម្មទំនិញ និងសេវាកម្ម ដោយប្រើប្រាស់ភាពខ្លាំងពិតប្រាកដរបស់កម្ពុជា ដូចដែលធ្លាប់បានកើតមានឡើងក្នុងឧស្សាហកម្មកាត់ដេរ ហើយអាចនឹងសម្រេចបានក្នុងវិស័យកសិកម្ម ការកែច្នៃកសិកម្ម សិប្បកម្ម និងផ្នែកផ្សេងទៀត។

តាំងពីឆ្នាំ២០០១ ក្របខណ្ឌគោលនយោបាយពាណិជ្ជកម្មមួយសម្រាប់ជំរុញការអភិវឌ្ឍវិស័យពាណិជ្ជកម្ម «សនិងក្រៅប្រទេស ត្រូវបានដាក់ឲ្យដំណើរការ ដែលជាមធ្យោបាយមួយដើម្បីជំរុញកំណើននិងចូលរួមក្នុងការបន្ថយភាពក្រីក្រ។ គំនិតផ្តួចផ្តើមនានានិងវិធានការកែទម្រង់ ទាំងឡាយដែលត្រូវបានយកមកប្រើប្រាស់ ដើម្បីអនុវត្តក្របខ័ណ្ឌគោលនយោបាយពាណិជ្ជកម្មឱ្យបានពេញលេញ ក្នុងការនាំចេញយ៉ាងសកម្មនិងការធ្វើ សមាហរណកម្មប្រទេសទៅក្នុងតំបន់ និងការចូលរួមទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោកក្នុងឆ្នាំ២០០៤។ រាជរដ្ឋាភិបាលក៏បានចរចាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនិង/ឬពាណិជ្ជកម្ម អនុគ្រោះជាមួយប្រទេសជាច្រើន ប្រកបដោយជោគជ័យ។ ទោះជា

ដូចនេះក្តី នៅមានការរាំងស្ទះជាច្រើនទៀត ដែលមានលក្ខណៈប្រហាក់ ប្រហែលទៅនឹងការរាំងស្ទះនៅក្នុងការវិនិយោគឯកជនក្នុងវិស័យឧស្សាហកម្ម ដែលជាឧបសគ្គនៃកំណើនក្នុង វិស័យពាណិជ្ជកម្ម។ អភិក្រមគ្រប់គ្រងទូទាំងវិស័យ មួយសម្រាប់ផ្នែកពាណិជ្ជកម្មកំពុងត្រូវបានរៀបចំ។ បញ្ហា ប្រឈមបន្ទាន់ចំពោះមុខទាំងឡាយ គឺត្រូវជានាថាកិច្ចព្រមព្រៀងពាណិជ្ជកម្មអនុគ្រោះ ទាំងឡាយដែលបានចុះ ហត្ថលេខារួចហើយ ត្រូវបានទទួលឧត្តមភាពតាមរយៈពាណិជ្ជកម្មឯកជន ក្នុងការនាំផលិតផលកម្ពុជាទៅកាន់ ទីផ្សារបរទេស ដើម្បីការនាំចេញទាំងឡាយអាចមានលក្ខណៈចម្រុះនិងទូលំទូលាយដោយជួយឱ្យការនាំចេញ លែងមានការពឹងផ្អែកទៅលើឧស្សាហកម្មកាត់ដេរតែមួយមុខ។

កំណែទម្រង់នានាដែលរាជរដ្ឋាភិបាលកម្ពុជានឹងបន្តក្នុងអភិបាលកិច្ច វិស័យតុលាការនិងច្បាប់ និងរដ្ឋបាល សាធារណៈ ក៏ដូចជា ក្នុងការស្តារហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន នឹងពិតជារួមចំណែកក្នុងការធ្វើឱ្យមានបរិយាកាសល្អ ប្រសើរជាងមុខ សម្រាប់ពាណិជ្ជកម្មនិងការវិនិយោគដោយផ្នែកឯកជន។ បន្ថែមពីលើការដោះស្រាយឧបសគ្គ ទាំងឡាយក្នុងផ្នែកឧស្សាហកម្ម កម្មន្តសាលនិងឧស្សាហកម្មកែច្នៃ ក៏ដូចជា ក្នុងផ្នែកពាណិជ្ជកម្ម រាជរដ្ឋាភិបាល កម្ពុជានឹង :

- ជំរុញលើកទឹកចិត្តយ៉ាងសកម្មឱ្យមានលទ្ធភាពចូលទៅក្នុងទីផ្សារក្រៅប្រទេសនានារបស់ផលិតផល ពិសេសនិងមានគុណភាពខ្ពស់របស់កម្ពុជា ដែលរាប់បញ្ចូលទាំងផលិតផលកសិកម្ម (ជាពិសេស ផលិតផលដែលបានកែច្នៃរួចហើយ) ផលិតផលកែច្នៃពីត្រី និងសេវាកម្មកម្លាំងពលកម្ម។
- ជំរុញផលិតផលកម្ពុជានៅទីផ្សារបរទេស។
- ជំរុញលើកទឹកចិត្តឱ្យមានការបង្កើតសមាគមសម្រាប់សមាជិកភាពនៃធុរៈកិច្ច និងពង្រឹងសមត្ថភាពផ្សាយរបស់សមាគមទាំងនោះ។
- កាត់បន្ថយឧបសគ្គដែលបណ្តាលមកពីគោលនយោបាយ ចំពោះអន្តរកម្មធុរៈកិច្ចប្រកបដោយប្រសិទ្ធភាព។
- រៀបចំឱ្យមានប្រសិទ្ធភាពនូវអធិការកិច្ចគយ ដើម្បីធ្វើឱ្យការងារនេះ៖_មានភាពងាយស្រួលជា. សម្រាប់អតិថិជន និងមិនមានការពន្យារនិងការចំណាយដែលផ្សារភ្ជាប់នឹងស្ថានភាពនេះ រួមទាំងការរៀបចំ និងការអនុវត្តច្បាប់គយនិងរដ្ឋករ ដែលបានកែសម្រួលរួចហើយ។
- កាត់បន្ថយឧបសគ្គនៃការនាំចូល ដូចជាតម្លៃខ្ពស់នៃការចុះបញ្ជីនិងតម្លៃនៃការចេញអាជ្ញាប័ណ្ណ។
- ជួយសម្រួលដល់ការបង្កើតតំបន់កែច្នៃសម្រាប់ការនាំចេញ ដើម្បីជំរុញឧស្សាហកម្មកែច្នៃនិងសម្រាប់បម្រើឱ្យការនាំចេញ។

**ទេសចរណ៍** : ការកើនឡើងយ៉ាងឆាប់រហ័ស បានជំរុញឱ្យទេសចរណ៍ដែលមានលក្ខណៈជាប្រព័ន្ធ កាយ ជាវិស័យទីពីរបន្ទាប់ពីឧស្សាហកម្មកាត់ដេរ និងមានតួនាទីក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងការផ្តល់ឱកាសការងារ ជូនប្រជាពលរដ្ឋកម្ពុជាមួយចំនួនធំ ទាក់ទងនឹងផ្នែកមួយចំនួនដូចជាសណ្ឋាគារ ភោជនីយដ្ឋាន ការដឹកជញ្ជូន និង សេវាកម្មផ្សេងៗទៀត។ គោលនយោបាយសម្រាប់អភិវឌ្ឍវិស័យទេសចរណ៍ត្រូវបានផ្អែកលើគោលការណ៍ជា មូលដ្ឋានបី (ក) ការអភិវឌ្ឍត្រូវមានលក្ខណៈចីរភាព ពឹងផ្អែកលើកេរដំណែលវប្បធម៌ដ៏ស្តុកស្តម្ភ ប្រវត្តិសាស្ត្រ និងធម្មជាតិដ៏ល្អត្រកាលនៃទឹក

ដីកម្ពុជា។ សំខាន់ជាងនេះទៀត គឺការអភិវឌ្ឍដែលរួមចំណែកក្នុងការកាត់បន្ថយ ភាពក្រីក្រ (ខ) ការផ្សព្វផ្សាយយ៉ាងសកម្មនិងមានលក្ខណៈច្នៃប្រឌិតអំពីវិស័យទេសចរណ៍ ដើម្បីធ្វើឱ្យកម្ពុជា ក្លាយទៅជាគោលដៅទេសចរណ៍ វប្បធម៌និងធម្មជាតិ" មួយក៏គួរជាទីទាក់ទាញដែលមានលក្ខណៈប្រកួតប្រជែងនៅក្នុងតំបន់ និងអន្តរជាតិ (គ) ក្រៅពីការកើនឡើងនៃចំនួនភ្ញៀវទេសចរដែលបានមកដល់ ត្រូវបង្កើនចំនួនថ្ងៃ ដែលអ្នកទេសចរស្នាក់នៅក្នុងប្រទេស និងការចំណាយរបស់ភ្ញៀវទេសចរ ព្រមទាំងធ្វើឱ្យមានគោលដៅទេសចរណ៍ ច្រើនប្រភេទ និងច្រើនកន្លែង។ លើសពីនេះទៀត ការខិតខំប្រឹងប្រែងនឹងត្រូវធ្វើឡើង ដើម្បីធានាថាផលប្រយោជន៍សមស្របនៃវិស័យទេសចរណ៍ នឹងជួយដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅ ជុំវិញតំបន់ទេសចរណ៍ ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ។ ការផ្តួចផ្តើមគំនិតសំខាន់ៗដែលនឹងត្រូវបន្តធ្វើឱ្យមានប្រសិទ្ធភាព។ ទៀត ជាអាទិ៍ :

- គោលនយោបាយបើកចំហជើងមេឃ។
- ធ្វើឱ្យមានភាពងាយស្រួលក្នុងការទទួលទិដ្ឋាការ និងការទស្សនា។
- កិច្ចព្រមព្រៀងទេសចរណ៍អាស៊ាន និងកិច្ចព្រមព្រៀងផ្សេងៗទៀត ដូចជាការពង្រឹងទេសចរណ៍ក្នុង តំបន់ជាដើម។
- ពង្រឹងសមត្ថភាព និងយន្តការប្រឆាំងបទល្មើសពាក់ព័ន្ធនឹងទេសចរណ៍ផ្លូវភេទរាល់រូបភាពនៃអាជីវកម្មលើកុមារ។

រាជរដ្ឋាភិបាលបានបន្តការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (ផ្លូវគោក អាកាសយានដ្ឋាន កំពង់ផែ ប្រព័ន្ធទឹកស្អាត អគ្គិសនី) ក៏ដូចជាការផ្តល់នូវបរិយាកាសសន្តិភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គមនិងបង្កលក្ខណៈងាយស្រួលឱ្យមានការកើនឡើងនៃភ្ញៀវទេសចរ ការស្នាក់នៅ និងការទស្សនា។ ដោយមានការ កើនឡើងជាបន្តបន្ទាប់ក្នុងល្បឿនលឿន ចំនួនភ្ញៀវទេសចរមកដល់ប្រចាំឆ្នាំ ត្រូវបានរំពឹងថា នឹងកើនដល់ប្រមាណ៣លាននាក់នៅឆ្នាំ២០១០ ចំណូលទេសចរណ៍នឹងកើនឡើងដល់ប្រមាណ ១.៥០០លានដុល្លារ និងផ្តល់ការងារដល់ប្រជាពលរដ្ឋប្រមាណ ៤០០.០០០នាក់។ សម្រាប់គោលបំណងនេះៈ រាជរដ្ឋាភិបាលត្រូវអនុវត្ត វិធានការគាំទ្រជាច្រើនដូចខាងក្រោម :

- ការបង្កើតឡើងនូវក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយវិស័យទេសចរណ៍ ដើម្បីបង្កលក្ខណៈអោយផ្នែកសាធារណៈ និងឯកជនចូលរួមសហការគ្នាក្នុងការអភិវឌ្ឍវិស័យទេសចរណ៍។
- ការបង្កើតការិយាល័យ ឬបញ្ជរពត៌មានទេសចរណ៍នៅតាមច្រកទ្វារព្រំដែនអន្តរជាតិ។
- លើកទឹកចិត្តឱ្យមានការផ្តល់សេវាព័ត៌មាន ដូចជា សណ្ឋាគារឬផ្ទះសំណាក់ មគ្គុទេសក៏ទេសចរ អាក (សចរណ៍និងសេវាដែលមានការពាក់ព័ន្ធ ភោជនីយដ្ឋាន គមនាគមន៍។ ល។
- កែលម្អ និងអភិវឌ្ឍបន្ថែមទៀតនូវផលិតផលទេសចរណ៍ ដោយផ្តោតទៅលើតំបន់អាទិភាពទាំងបួន (តំបន់សៀមរាប-អង្គរ ភ្នំពេញ និងតំបន់ជុំវិញតំបន់ឆ្នេរ និងតំបន់ភូមិភាគឥសាន្ត) និងពង្រីកទៅកាន់ តំបន់ផ្សេងៗ ទៀតនៅទូទាំងប្រទេស។

**សហគ្រាសតូចនិងមធ្យម** : សហគ្រាសតូចនិងមធ្យមជាធម្មតាស្ថិតនៅជាប់ប្រជាជនសាមញ្ញ និងផ្តល់ ផលប្រយោជន៍ដល់សហគមន៍ជនបទក្នុងការកែច្នៃ និងតម្លៃបន្ថែមទៅលើផលិតផល ក៏ដូចជា

ការបង្កើតការងារ។ សហគ្រាសតូចនិងមធ្យមផ្តល់ផងដែរនូវការតភ្ជាប់យ៉ាងសំខាន់ទៅនឹងវិស័យពាណិជ្ជកម្ម ក៏ដូចជា ទៅនឹងសហគ្រាស។ ដើម្បីជំរុញល្បឿននិងសម្រួលដល់សហគ្រាសតូចនិងមធ្យម រាជរដ្ឋាភិបាលនឹងអនុវត្តវិធានការដូចខាង ក្រោម :

- ដាក់ឱ្យមាននូវវិធានការទាំងឡាយ ដើម្បីឱ្យសហគ្រាសធុនតូចនិងមធ្យម និងមីក្រូសហគ្រាសដំណើរ ការក្នុងបរិស្ថានធុរៈកិច្ចមួយមានផលចំណេញ និងបង្កើនលទ្ធភាពទទួលបានហិរញ្ញប្បទានរយៈពេលមធ្យម និងវែង។
- បង្កើតប្រព័ន្ធពិសេស១ដើម្បីគាំទ្រស្ត្រីក្នុងធុរៈកិច្ច និងបង្កលក្ខណៈងាយស្រួលដល់ស្ត្រីឱ្យអាចប្រើប្រាស់ សេវាកម្មនិងកម្មវិធីនានានៃការអភិវឌ្ឍសហគ្រាសតូចនិងមធ្យម។
- កាត់បន្ថយនីតិវិធីការចុះបញ្ជីក្រុមហ៊ុន និងជួយក្នុងដំណើរការនៃការចាប់ផ្តើមរបស់សហមធ្យម។
- បង្កើតស្ថាប័នស្តង់ដារជាតិនិងស្ថាប័នផលិតភាព ដើម្បីជួយធានាគុណភាពនៃផលិតផលក្នុងស្រុក ផលិតភាព។
- ជំរុញគាំទ្រសេវាប្រឹក្សាដល់សហគ្រាសតូចនិងមធ្យម ដើម្បីជួយអភិវឌ្ឍបច្ចេកវិទ្យាទំនើបនៅកម្ម ការកែលម្អគុណភាពផលិតផល ការគ្រប់គ្រងនិងការស្វែងរកទីផ្សារ។
- ជំរុញការបណ្តុះបណ្តាលវិជ្ជាជីវៈ ទាំងក្នុងស្រុកនិងក្រៅស្រុក។
- ពង្រឹងក្របខ័ណ្ឌច្បាប់ ដោយបង្កើតច្បាប់នានាដែលពាក់ព័ន្ធនឹងរោងចក្រ តំបន់ឧស្សាហកម្ម ប៉ាន.ការបង្កើតមុខទំនិញថ្មីៗ ខ្នាតនិងរង្វាស់រង្វាល់ និងសុវត្ថិភាពឧស្សាហកម្ម។
- លើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធនឹងការជំរុញសហគ្រាសតូចនិងមធ្យម។

ឥណទានជនបទ គឺជាកត្តាមួយសំខាន់សម្រាប់ការពង្រីកសេដ្ឋកិច្ចដែលមានមូលដ្ឋានទូលំទូលាយសម្រាប់ ការអភិវឌ្ឍជនបទ និងសម្រាប់ការកាត់បន្ថយភាពក្រីក្រ តាមរយៈការគាំទ្រផលិតកម្មកសិកម្ម និងការបង្កើត និងការពង្រីកធុរៈកិច្ច (ជាពិសេសសហគ្រាសតូចនិងមធ្យម) តាមរយៈការបង្កើនផលិតភាព ការបង្កើតចំណូល ព្រមទាំងសម្រាប់ការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន។ មូលនិធិជាច្រើន ថែមទៀត គឺជាតម្រូវ ការចាំបាច់សម្រាប់ជួយបំពេញមួយផ្នែកលើតម្រូវការដ៏ធំក្នុងឥណទានជនបទ។ បញ្ហាប្រឈមដ៏ចម្បងបំផុត គឺត្រូវស្វែងរកដំណោះស្រាយនិងមធ្យោបាយនានាដែលតាមរយៈនេះ ឥណទានជនបទ អាចមានសម្រាប់ការ ប្រើប្រាស់ក្នុងអត្រាការប្រាក់មួយទាបច្រើនជាងអត្រាដែលមានបច្ចុប្បន្ន (៤៨ភាគរយក្នុងមួយឆ្នាំ)។ ដើម្បីធានា ឱ្យមានលទ្ធភាពច្រើនជាងមុននិងមានលក្ខណៈងាយស្រួលដល់អ្នកក្រ ក្នុងការទទួលបានឥណទាន ជាពិសេស សម្រាប់គោលបំណងធ្វើផលិតកម្ម រាជរដ្ឋាភិបាលនឹងចាត់វិធានការដើម្បីពង្រីកនិងបន្ថយចំណាយខ្ពស់សម្រាប់ឥណទានជនបទ តាមរយៈ :

- ការពិនិត្យពិចារណានិងការជំរុញលើកទឹកចិត្តឱ្យមានការបង្កើតស្ថាបន័ ដូចជាសហករណ៍អ្នកប្រើប្រាស់ដែលមាននៅក្នុងតំបន់មួយចំនួននៃទ្វីបអាស៊ី។

- ការបង្វែរអង្គការក្រៅរដ្ឋាភិបាលដែលកំពុងដំណើរការការងារនេះ ឱ្យក្លាយជាប្រតិបត្តិការហិរញ្ញវត្ថុ។
- មានការចុះបញ្ជីឈ្មោះត្រឹមត្រូវ (ដំណើរការនេះ បានចាប់ផ្តើមរួចមកហើយ ហើយអង្គការ ភិបាលជាច្រើនត្រូវបានផ្តល់អាជ្ញាប័ណ្ណរួចហើយ)។
- ការធ្វើឱ្យប្រសើរឡើងការត្រួតពិនិត្យស្ថាប័នទាំងនេះ ដើម្បីធានាថា ស្ថាប័នទាំងនេះពិតជាដំណើរសមស្របទៅតាមគោលការណ៍។
- ការកាត់បន្ថយអត្រាការប្រាក់ដែលមានជាទូទៅ តាមរយៈបទពិសោធន៍ដ៏ល្អប្រសើរដែលធ្លាប់មានមកហើយ។

ការបង្កើតការងារនិងលក្ខខណ្ឌការងារល្អប្រសើរជាងមុន : ទិសដៅសំខាន់ៗក្នុងការងារនេះ៖ គឺការបង្កើតកាលានុវត្តភាពការងារដែលមានសារៈប្រយោជន៍ ទាំងក្នុងផ្នែករៀបរយនិងទាំងក្នុងផ្នែកមិនរៀបរយ ការធ្វើឱ្យប្រសើរឡើងនូវការផ្គត់ផ្គង់ពលករមានគុណភាព និងការលុបបំបាត់រូបភាពអាក្រក់បំផុតនៃពលកម្មកុមារ។ ឧស្សាហកម្មកាត់ដេរដែលកើនឡើងយ៉ាងឆាប់រហ័ស បានធ្វើឱ្យមានការប្រែប្រួលនៃស្ថានភាពការងារនៅទីប្រជុំជនតាមរយៈការបង្កើតនិងការធ្វើឱ្យមានស្ថេរភាពការងារដែលប្រើកម្លាំងពលកម្មច្រើន ជាពិសេស សម្រាប់ស្ត្រី . ក៏ដូចនៅក្នុងវិស័យផ្សេងៗទៀតដែរ គោលនយោបាយមួយដែលមានលក្ខណៈជាប្រព័ន្ធកំពុងត្រូវបាន កមកអនុវត្ត ដើម្បីបង្កើតការងារឱ្យបានច្រើនជាងមុន ជាពិសេស សម្រាប់ប្រជាជនក្មេងៗដែលកំពុងចូលខ្លួន .៥២ពលកម្ម និងសម្រាប់ពលរដ្ឋកម្ពុជាទាំងអស់តាមរយៈវិធានការទាំងឡាយ ដូចខាងក្រោម :

- បង្កើនផលិតភាពកសិកម្ម ដើម្បីបង្កើតកាលានុវត្តភាពការងារនៅជនបទឱ្យបានច្រើនជាងមុន ដែលនឹង មានឥទ្ធិពលខ្លាំងទៅលើវិស័យជាច្រើន រួមបញ្ចូលទាំង តាមរយៈការបង្កើនតម្រូវការទំនិញ និងសេវា កម្មផ្សេងៗ។
- លើកទឹកចិត្តការវិនិយោគផ្ទាល់ពីបរទេសនិងការវិនិយោគក្នុងស្រុកនៅក្នុងវិស័យអាទិភាព ជាពិសេស វិស័យកសិកម្ម កសិ-ឧស្សាហកម្ម ឧស្សាហកម្មនិងគម្រោងដែលប្រើប្រាស់ពលកម្មច្រើន ព្រមទាំងវិស័យទេសចរណ៍។
- បង្កើតបណ្តាញអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងជំនាញផ្សេងៗ ដើម្បីបម្រើដោយស្មើភាពគ្នា ទាំងបុរសនិងទាំងស្ត្រី ជាពិសេសជនក្រីក្រ ជនពិការ និងក្រុមជនដែលងាយរងគ្រោះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ សម្រាប់រយៈពេលខ្លីនិងវែង។
- រៀបចំបង្កើតមូលដ្ឋានទិន្នន័យកម្លាំងពលកម្មមួយ និងប្រព័ន្ធស្ថិតិមួយ ដោយមានទិន្នន័យដែលបំបែកលម្អិតជាច្រើនប្រភេទ ដូចជា តាមយេនឌ័រ ពិការភាព និងកត្តាផ្សេងៗទៀតដែលទាក់ទងនឹងសង្គមកិច្ច។
- ជួយពលករកម្ពុជាក្នុងការស្វែងរកការងារនៅបណ្តាប្រទេសផ្សេងៗទៀត។

ការធានាឱ្យមានលក្ខខណ្ឌនៃកន្លែងធ្វើការដែលមានសុវត្ថិភាព ត្រឹមត្រូវ និងមានអនាម័យល្អ និងលក្ខខណ្ឌ កិច្ចសន្យាដែលត្រឹមត្រូវនិងយុត្តិធម៌សម្រាប់កម្លាំងពលកម្មគឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងការងារហើយក៏ជាផ្នែកមួយដ៏សំខាន់នៃការងារផងដែរ។ រាជរដ្ឋាភិបាលកម្ពុជាកំពុង

ដោះស្រាយជាប្រចាំ នូវបញ្ហាទាំង មនេះ រួមមាន ការកម្រិតអប្បបរមានៃប្រាក់ឈ្នួលប្រចាំខែនិងថ្ងៃឈប់សម្រាក ការកាត់បន្ថយវិសមភាពក្នុងប្រាក់ឈ្នួលរវាងបុរសនិងស្ត្រីដំណោះស្រាយជម្លោះនិងការមិនឯកភាពគ្នាតាមសន្តិវិធី ដោយមិនបង្កឡើងនូវការអាក់ខានដល់សង្វាក់ផលិតកម្ម និងការបាត់បង់ប្រាក់ឈ្នួលរបស់និយោជិក។ អាទិភាពទាំងទាញ នេះគឺៈ

- ពង្រឹងយ៉ាងខ្លាំងក្លានូវការអនុវត្តច្បាប់ស្តីពីការងារនិងអនុសញ្ញាអន្តរជាតិ ដែលទាក់ទងទៅសហជីពកម្មករ ដើម្បីការពារសិទ្ធិនិងកាតព្វកិច្ចរបស់កម្មករ និយោជិត និងនិយោជក។
- ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងាររបស់កម្មករនិងនិយោជិត រួមបញ្ចូលទាំងកម្មករនៅ ទាំងក្នុងនិងក្រៅប្រទេស និងកម្មករមានផ្ទៃពោះ។
- បន្តនិងពង្រឹងការខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយសមាមាត្រនៃកុមារធ្វើការងារ (ពលកម្មកុមារ ,
- ពង្រឹងការអនុវត្តច្បាប់ស្តីពីសន្តិសុខសង្គម។
- បង្កើត " បេឡាជាតិសន្តិសុខសង្គមមួយ"។
- ពិនិត្យជម្រើសដែលអាចធ្វើបាន សម្រាប់ការបង្កើតបេឡាសោធន ជាពិសេស សម្រាប់ជនពិការ ,អ្នកនៅក្នុងបន្ទុក និងការធានារ៉ាប់រងសម្រាប់គ្រោះថ្នាក់ការងារ ដូចមានចែងក្នុងច្បាប់ការងារ។

បណ្តាញសុវត្ថិភាពសង្គម : រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តផ្តល់នូវអន្តរាគមន៍សម្រាប់វិស័យសង្គមកិច្ច ដែលក្នុងនោះរួមមាន (ក) ការកាត់បន្ថយភាពងាយរងគ្រោះនរបស់អ្នកក្រ (ខ) វិធានការដើម្បីសម្រាលផល ប៉ះពាល់នៃគ្រោះធម្មជាតិ (គ) ការជួយជនរងគ្រោះដោយសារបាតុភូតទាំងនោះ (ឃ) ការពង្រីកកម្មវិធីនីតិ សម្បទានិងកម្មវិធីសមាហរណកម្មឡើងវិញសម្រាប់ជនពិការ សម្រាប់ជនដែលរងគ្រោះដោយគ្រឿងញៀន សម្រាប់ ជនរងគ្រោះដោយសារការជួញដូរនិងកុមារដែលប្រព្រឹត្តខុសច្បាប់ ក៏ដូចជា ការពង្រីកកម្មវិធីសុខុមាលភាពសម្រាប់ ជនចាស់ជរា កុមារកំព្រា មេម៉ាយនិងពោះម៉ាយក្រីក្រ គ្រួសារក្រីក្រដែលមានស្ត្រីជាមេគ្រួសារ ស្ត្រីរងគ្រោះ ជនគ្មានទីលំនៅដ្ឋាន និងអតីតយុទ្ធជននិងគ្រួសាររបស់ពួកគេ (ង) ការទប់ស្កាត់បទល្មើសនិងការការពាសុវត្ថិភាព សហគមន៍នៅថ្នាក់ឃុំ-សង្កាត់ ស្រុក-ខ័ណ្ឌ ខេត្ត-ក្រុង និងថ្នាក់ជាតិ ដោយសហការក្នុងភាពជាដៃគូអភិវឌ្ឍន៍ និងអ្នកមានចំណែកពាក់ព័ន្ធផ្សេងៗទៀត។ យុទ្ធសាស្ត្រនិងសកម្មភាពជាអាទិភាពទាំងឡាយដែលត្រូវអនុវត្ត រួមមាន ការអនុម័តយកនិងការពង្រឹងការអនុវត្តច្បាប់សំខាន់ៗ និងការបង្កើតមជ្ឈមណ្ឌលនីតិសម្បទាំសប្រម កុមារកំព្រាជនអនាថាតាមផ្លូវ ជនពិការ ជនចាស់ជរា ព្រមទាំងស្ត្រីនិងកុមាររងគ្រោះដោយការជួញដូរ ដោយសារបច្ចុប្បន្ននេះៈ បញ្ហាគ្រឿងញៀនបានក្លាយជាកង្វល់ដ៏ធំមួយសម្រាប់សន្តិសុខ និងសុខុមាលា សង្គមជាតិទាំងមូល វិធានការដើម្បីទប់ស្កាត់ ការផលិត ការហូរចូល ការលក់ដូរ និងការប្រើប្រាស់។ នឹងត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់ដោយអាជ្ញាធរពាក់ព័ន្ធ។

## ៦.១០.ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស

ផ្នែកនេះបង្ហាញពីចតុកោណទី៤ នៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដែលភាគច្រើនគ្រប់ លើផ្នែកសង្គមកិច្ច ក្នុងនោះរួមមាន អប់រំ សុខាភិបាល សមភាពយេនឌ័រ និងបញ្ហាប្រជាជន។

ការអប់រំ ការអប់រំត្រូវបានទទួលយកជាសកល ថាជាមូលដ្ឋានសិទ្ធិមនុស្សមួយដ៏សំខាន់។ ការអប់រំបើជាកត្តាមួយចម្បងផងដែរ ដែលផ្តល់វិភាគទានដល់ការកាត់បន្ថយភាពក្រីក្រ។ ទិសដៅរយៈពេលវែង គឺដើម្បីធានាថាកុមារនិងយុវជនកម្ពុជាទាំងអស់មានឱកាសស្មើៗគ្នា ក្នុងការទទួលបានការអប់រំប្រកបដោយគុណភាព បព់គិតពីឋានៈក្នុងសង្គម តំបន់ភូមិសាស្ត្រ ជនជាតិ សាសនា ភាសា ភេទ ឬភាពពិការឡើយ។ ការអប់រំ បង្កើតឱ្យមានមោទនភាពចំពោះជាតិនិងចំពោះខ្លួនឯងក្នុងឋានៈជាពលរដ្ឋម្នាក់ មានកម្រិតសីលធម៌និងសុទិដ្ឋិនិយមខ្ពស់ដូចជា មានការទទួលខុសត្រូវចំពោះប្រទេសជាតិនិងប្រជាជន។ តួនាទីនៃការអប់រំ គឺដើម្បីលើក ឧស់គណភាពសិស្ស-និស្សិត ដើម្បីក្លាយខ្លួនជាអ្នកមានផលប្រយោជន៍ និងការរស់នៅប្រកបដោយភាពសុខដុមរមនានៅក្នុងសង្គមមួយដែលស្ថិតនៅក្នុងបរិបទនៃសកលភាវូបនីយកម្ម។

វិស័យអប់រំគឺជាវិស័យមួយដែលត្រូវបានទទួលស្គាល់ថាសម្រេចបានជោគជ័យនៅក្នុងទិដ្ឋភាពសេដ្ឋកិច្ចសង្គមកិច្ចរបស់កម្ពុជា ទាំងនៅក្នុងការងារកំណែទម្រង់ ទាំងនៅក្នុងការសម្រេចបាននូវសមិទ្ធផលទាំងឡាយ។ ទោះជាយ៉ាងណាក៏ដោយ ក៏បញ្ហាប្រឈមជាច្រើននៅតែកើតមានឡើងនៅឡើយ ហើយនៅក្នុងចំណោមបញ្ហា ប្រឈមទាំងនោះ មានជាអាទិ ភាពចាំបាច់និងបន្ទាន់ក្នុងការលើកកម្ពស់គុណភាពនៃការអប់រំ។ កិច្ចសហប្រតិ បត្តិការក្នុងចំណោមភាគីដែលមានចំណែកពាក់ពន្ធ័នានា មានការរីកចម្រើនច្រើនក្នុងរយៈពេលថ្មីៗកន្លងទៅនេះ។ តាមរយៈបទពិសោធន៍ដែលទទួលបានក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០១-២០០៥ ផែនការ យុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៦-២០១០ មួយទៀត ត្រូវបានរៀបចំឡើង ដោយមានការពិគ្រោះយោបល់យ៉ាង ទូលំទូលាយជាមួយអ្នកមានចំណែកពាក់ពន្ធ័ទាំងអស់ ហើយផែនការនេះបានបញ្ចូលនូវគោលដៅទាំងឡាយនៃ ផនការអប់រំសម្រាប់ទាំងអស់គ្នាឆ្នាំ២០០៣-២០១៥។ ផែនការនេះ គឺជាក្របខ័ណ្ឌគោលនយោបាយនិងការ ** ដលខានមួយ សម្រាប់ការកែលមសានភាពរស់នៅរបស់អ្នកក្រ ដោយប្រើប្រាស់ការអប់រំជាកត្តាសំខាន់ការលើកកម្ពស់ការអភិវឌ្ឍសង្គមនិងកំណើនសេដ្ឋកិច្ច។ ការផ្តោតការយកចិត្តទុកដាក់ ត្រូវធ្វើឡើងនៅក្នុង លម្អគុណភាពអប់រំនៅគ្រប់កម្រិតទាំងនៅកម្រិតមតេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាបឋមភូមិសិក្សាទុតិយភូមិ និងឧត្តមសិក្សា។ ផ្នែកនេះ៖ គូសបញ្ជាក់ពីចំណុចសំខាន់ៗនៃ ផែនការយុទ្ធសាស្ត្រវិស័យ អប់រំឆ្នាំ២០០៦-២០១០ ដែលផ្តល់ព័ត៌មានលម្អិតជាងនេះ។

បង្អែករឹងមាំរបស់ប្រទេសជាតិមួយ គឺជា " សំណុំដ៏សំខាន់ៗ នៃធនធានមនុស្សដែលមានការអប់ .. ជំនាញ មានទេពកោសល្យ និងមានសមត្ថភាព នៅក្នុងវិស័យនានានៃផ្នែកសេដ្ឋកិច្ចនិងសង្គមកិច្ច។ បច្ចុប្បន្ននេះ ការផ្តល់សេវាអប់រំនៅកម្រិតឧត្តមសិក្សា ជាពិសេស ការផ្តល់ដោយផ្នែកឯកជនហាក់ដូចជាមិន មានតុល្យភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការរយៈពេលខ្លីនៃទីផ្សារ ដូចជាតម្រូវការបន្ទាន់នូវបុគ្គលិក ថ្នាក់ទាបនិងថ្នាក់មធ្យម។ ការបន្សាគ្នាមិនត្រឹមត្រូវរវាងទិដ្ឋភាពការងាររយៈពេលវែងនិងការសិក្សា កំពង នៅកើតមានឡើង។ ដើម្បីឱ្យមានការរីកចម្រើននិងរក្សាបាននូវកំណើនសេដ្ឋកិច្ច

ប្រកបដោយចីរភាព រូបនេះ ជាតិត្រូវការមុខជំនាញជាច្រើន ដូចជា អ្នកវិទ្យាសាស្ត្រ វិស្វករ អ្នកស្រាវជ្រាវ និងអ្នកឯកទេស នៅតាម ផ្នែកនានានៃសេដ្ឋកិច្ច-សង្គមកិច្ច។ បញ្ហាប្រឈមនៅក្នុងវិស័យអប់រំ គឺត្រូវផ្តល់សេវាកម្មនានាសម្រាប់ការអប់ ចាំបាច់ប្រកបដោយគុណភាពខ្ពស់នៅក្នុងគ្រប់វិស័យតាមរយៈ ការបណ្តុះបណ្តាលវិជ្ជាជីវៈនិងបច្ចេទេស និងការ អប់រំកម្រិតឧត្តមសិក្សា ហើយត្រូវមានសមត្ថភាពទាក់ទាញនិស្សិតឱ្យមកចូលរួមក្នុងវគ្គសិក្សាទាំងនេះ៖។ ចំពោះ បញ្ហានេះ តួនាទីរបស់ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំកម្ពុជា គឺមានសារៈសំខាន់ក្នុងការវាយតម្លៃនិង ទទួលស្គាល់គុណភាពតែចំពោះមហាវិទ្យាល័យទាំងឡាយណា ដែលមានលក្ខណៈវិនិច្ឆ័យផ្នែកគុណភាពជាអប្បបរមា និងមានសារៈសំខាន់សម្រាប់ការរៀបចំបង្កើតឡើងនូវ យុទ្ធសាស្ត្រអប់រំឧត្តមសិក្សាដ៏ទូលំទូលាយមួយ។

នៅក្នុងចំណោមអាទិភាពទាំងឡាយនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៦-២០១០ និងគោល នយោបាយសំខាន់ៗ ការងារដែលត្រូវធ្វើ ជាអាទិ៍មាន

- ការធានាឱ្យមានលទ្ធភាពចូលរៀនប្រកបដោយភាពងាយស្រួលនិងសមធម៌ ជាពិសេស សម្រាប់អ្នកក្រ ក្មេងស្រី ជនជាតិភាគតិច និងកុមារក្រីក្រ ក៏ដូចជា ប្រជាជនរស់នៅក្នុងតំបន់ដែលអត្រាភាពក្រីក្រខ្ពស់។
- សកលកម្មនៃការអប់រំមូលដ្ឋាន ៩ឆ្នាំ និងលើកកម្ពស់កាលានុវត្តភាពជីវិតរស់នៅ។
- ការបង្កើនគុណភាពនិងប្រសិទ្ធភាពនៃសេវាអប់រំ ដោយរាប់បញ្ចូលទាំង តាមរយៈការធ្វើទំនើបកម្ម និងកំណែទម្រង់ប្រកបដោយប្រសិទ្ធភាព។
- ការផ្សារភ្ជាប់ការអប់រំនិងការបណ្តុះបណ្តាលទៅនឹងទីផ្សារពលកម្មរយៈពេលវែងនិងមធ្យម និងទៅ នឹងសង្គម រួមបញ្ចូលទាំង ការអប់រំឱ្យមានជំនាញសម្រាប់ការរស់នៅនិងសុខភាពល្អនិងការអបរមតា
- ការពារមេរោគហ៊ីវ /ជម្ងឺអេដស៍។
- ការអភិវឌ្ឍបន្ថែមទៀតក្នុងវិស័យយុវជននិងកីឡា ដោយបង្កើនការយកចិត្តទុកដាក់ចំពោះយុវជនក្នុងគ្រប់មុខជំនាញ។
- ការអភិវឌ្ឍនិងការកសាងសមត្ថភាពស្ថាប័ន សម្រាប់ការងារវិមជ្ឈការ។

ក្នុងពេលថ្មីៗនេះ៖ វឌ្ឍនភាពសំខាន់ៗមួយចំនួនត្រូវបានធ្វើឱ្យសម្រេចឡើង ក្នុងការបង្កើនកម្រិតចុះឈ្មោះ៖ចូលរៀននៅសាលាបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ (បញ្ចប់ការសិក្សាជាមូលដ្ឋាន ៩ឆ្នាំ) ប៉ុន្តែទោះជា ដូចនេះក្តី គម្លាតធំចំពោះអ្នកក្រខ្លាំង និងនៅតំបន់ដាច់ស្រយាល នៅតែមាននៅឡើយ។ នៅពេលដែលកម្រិតនៃ បេននិងផលធៀបយេនឌ័រនៅកម្រិតបឋមសិក្សា អាចសម្រេចបាន ១០០ភាគរយ នៃគោលដៅនៅមុនឆ្នាំ២០១៥កម្រិតនៃការចុះឈ្មោះចូលរៀន និងផលធៀបយេនឌ័រនៅកម្រិតបធ្យមសិក្សានិងមិនអាចសម្រេចបាន ១០០ភាគរយតាមចំណុចដៅ បើមិនមានការខិតខំប្រឹងប្រែងរួមគ្នានោះទេ។ គោលដៅសំខាន់ៗ ចំពោះ មុខរបស់វិស័យអប់រំរួមមាន :

- ការកាត់បន្ថយចំងាយផ្លូវ ដែលកុមារធ្វើដំណើរពីផ្ទះមកកាន់សាលាបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ តាមរយៈការសាងសង់និងបើកសាលារៀននៅជិតភូមិដែលកុមាររស់នៅ ជាពិសេសនៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក។
- បង្កលក្ខណៈងាយស្រួល ដើម្បីឱ្យកុមារីបានចូលរៀននៅសាលាមធ្យមសិក្សាបឋមភូមិ និងកម្រិតសិក្សាខ្ពស់ជាង។
- កាត់បន្ថយការចំណាយរបស់ឪពុកម្តាយសិស្សក្នុងការចុះឈ្មោះចូលរៀន និងធានាឱ្យមានការចូលរៀននិងការសិក្សារបស់កុមារក្រីក្រ ហើយតាមរយៈនេះ៖ នឹងធានាឱ្យមានការកាត់បន្ថយកម្លាំងពលកម្មកុមារផងដែរ។
- បង្កើនគុណភាពអប់រំឱ្យដល់និងក្រោយកម្រិតអប់រំមូលដ្ឋាន _ រាប់បញ្ចូលទាំងការកែសម្រួលកម្មវិធីសិក្សានិងការដាក់បញ្ចូលស្តង់ដារអប្បបរមានៃលទ្ធផលនៃការសិក្សារបស់សិស្ស និងប្រព័ន្ធវាយតម្លៃការសិក្សា របស់សិស្ស សម្រាប់ថ្នាក់ទី៣ ថ្នាក់ទី៦ និងថ្នាក់ទី៩។ ការអភិវឌ្ឍគ្រូបង្រៀន និងការកំណត់ប៉ុស្តិ៍បំពេញការងារគ្រូ ការធានាគុណភាព និងប្រព័ន្ធវាយតម្លៃនិងទទួលស្គាល់គុណភាព។

ទន្ទឹមនឹងពេលដែលយុទ្ធសាស្ត្ររយៈពេលវែងមួយត្រូវបានរៀបចំឡើង ហើយការវិនិយោគត្រូវបន្តធ្វើ សម្រាប់វឌ្ឍនភាពនៅកម្រិតមធ្យមសិក្សា ឧត្តមសិក្សា និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងដំណាក់កាល ជ័យអន គោលដៅនិងចំណុចដៅសំខាន់ៗ ជាអាទិ៍មាន :table4

យុទ្ធសាស្ត្រចំបង១និងសកម្មភាពសំខាន់ៗរបស់វិស័យអប់រំ ដើម្បីសម្រេចគោលដៅទាំងនេះ និងនៅ ផ្សេងៗទៀត រួមមាន :

- បង្កើនចំនួនកុមារថ្នាក់មត្តេយ្យសិក្សា ដែលចូលរៀនក្នុងកម្មវិធីអប់រំសម្រាប់កុមារតូច១ ដែលបានរៀបចំឡើងនៅក្នុងសាលា សហគមន៍ និងតាមផ្ទះ។
- បង្កើនចំនួនសាលាបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ ជាពិសេស នៅតំបន់ដាច់ស្រយាល និងតំបន់ដែលទទួលសេវាកម្មមិនគ្រប់គ្រាន់។
- បង្កើនចំនួនគ្រូបង្រៀន ទាំងគ្រូប្រុសនិងគ្រូស្រីនៅគ្រប់កម្រិតសិក្សាទាំងនោះ៖ ដើម្បីលើកកម្ពស់ផលធៀបសិស្ស-គ្រូ និងសមាមាត្របុគ្គលិកសិក្សាស្រី ជាពិសេស ការផ្តល់ប្រាក់លើកទឹកចិត្ត សម្រាប់ការបំពេញ ការងារនៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក។
- លើកកម្ពស់គុណភាពគ្រូបង្រៀន តាមរយៈការអភិវឌ្ឍមុខរបរវិជ្ជាជីវៈ ដែលផ្សារភ្ជាប់ទៅនឹងការផ្តល់
- ប្រាក់លើកទឹកចិត្ត សម្រាប់ការបំពេញការងារ។
- យកចិត្តទុកដាក់ជាពិសេសក្នុងការបង្កើនប្រាក់បៀវត្សរ៍របស់គ្រូបង្រៀន (បាននឹងកំពុងដំណើរការ) និងបើកប្រាក់បៀវត្សរ៍ឱ្យទាន់ពេលវេលា។
- ធានាគុណភាពអប់រំ តាមរយៈការកែលម្អការផ្តល់នូវសៀវភៅសិក្សា សម្ភារៈសិក្សា បរក្សា។ បណ្ណាល័យ និងបន្ទប់ពិសោធន៍។

- រៀបចំឱ្យមានស្តង់ដារគុណភាពសម្រាប់គ្រប់កម្រិត និងប្រព័ន្ធវាយតម្លៃថ្នាក់ជាតិមួយសម្រាប។
- មូលដ្ឋាន។
- បង្កើនចំនួនអន្តេវាសិកដ្ឋានដែលមានសវត្ថិភាពសម្រាប់សិស្សស្រីដែលមកពីតំបន់ឆ្ងាយៗ ដើម្បីមករៀន នៅសាលាមធ្យមសិក្សាបឋមភូមិដែលជិតបំផុត នៅលើមូលដ្ឋាននៃគម្រោងសាកល្បងជាគំរូដែលបាននិងកំពុងដំណើរការរួចហើយ។
- កាត់បន្ថយបន្ទុកចំណាយរបស់សិស្សក្រីក្រ ជាពិសេសសិស្សស្រី តាមរយៈការផ្តល់អាហារូបករណ៍ (នៅ បឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា) និងការលុបបំបាត់ការបង់ប្រាក់ក្រៅ
- ផ្លូវការគ្រប់ប្រភេទទៅឱ្យគ្រូ។
- ពង្រីកនិងកំណត់មុខសញ្ញាឱ្យបានល្អជាងមុនសម្រាប់កម្មវិធីផ្តល់អាហារសម្រន់នៅបឋមសិក្សា និងកម្មវិធី លើកទឹកចិត្តសម្រាប់សិស្សថ្នាក់ទី៧ ដល់ទី៩។
- បន្តជានាឱ្យមានការវិភាជន៍ឱ្យបានគ្រប់គ្រាន់និងការផ្តល់ឱ្យបានទាន់ពេលវេលានូវថវិកាចរន្តសម្រាប់ វិស័យអប់រំ ជាពិសេស សម្រាប់ការអប់រំមូលដ្ឋាន។
- បង្កើននិងកែលម្អកម្មវិធីអក្ខរកម្មសម្រាប់ប្រជាជនពេញវ័យ ជាពិសេស សម្រាប់ស្ត្រី។

**សុខាភិបាល** : ការលើកកម្ពស់ស្ថានភាពសុខភាពរបស់ប្រជាជនគឺជាអាទិភាពមួយខ្ពស់បំផុត។ ការលើក កម្ពស់ស្ថានភាពអាហារូបត្ថម្ភ ក៏ដូចជា សុខភាពបន្តពូជ សុខភាពមាតានិងកុមារ ការលុបបំបាត់មូលហេតុបណ្តាល នៃជម្ងឺ ការចាត់វិធានការបង្ការ និងការផ្តល់ការព្យាបាលដែលចាំបាច់ គឺមានសារៈសំខាន់ ក្នុងការលើកកម្ពស់ស្ថាន ភាពសុខភាពនៃប្រជាជនជាទូទៅ ជាពិសេស ជនងាយរងគ្រោះដែលគ្មានមធ្យោបាយ ដើម្បីទទួលបានសេវាទាំងនោះ។ កត្តាអន្តរវិស័យនិងកត្តាផ្សេងទៀតជាច្រើនដែលប៉ះពាល់ដល់ស្ថានភាពសុខភាពរបស់ប្រជាជន មានជាអាទិ៍ (ក) ភាពក្រីក្រជាមូលហេតុនិងបច្ច័យអាក្រក់នៃសុខភាពមិនល្អ (ខ) ការលំបាកផ្នែកហិរញ្ញវត្ថុរបស់អ្នកក្រ ដែលរារាំង មិនឱ្យពួកគាត់មានលទ្ធភាពទទួលសេវាសុខាភិបាលសាធារណៈ (គ) ការកែលម្អគុណភាពទឹកនិងសេវាអនាម័យ (ឃ) ការអប់រំប្រសើរជាងមុននិងកម្រិតអក្ខរកម្មខ្ពស់ជាងមុន ក៏ដូចជាលទ្ធភាពទទួលបានព័ត៌មាននិងការយល់ដឹងច្រើនជាងមុន (ង) សមធម៌យេនឌ័រ (ច) បណ្តាញសុវត្ថិភាពសង្គមសម្រាប់អ្នកក្រនិងអ្នកងាយរងគ្រោះ៖ (ឆ) ការផ្តល់អាហារូបត្ថម្ភល្អជាងមុន តាមរយៈ ការធ្វើអន្តរាគមន៍សមស្រប។ល។

ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាលឆ្នាំ២០០៣-២០០៧ ដែលនឹងត្រូវបន្តរហូតដល់ឆ្នាំ២០១០ បន្ទាប់ពីការត្រួតពិនិត្យឡើងវិញនៅឆ្នាំ២០០៦ (នៅពេលដែលមានទិន្នន័យការកែសម្រួលរួចតាមរយៈអង្កេត ប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា) ផ្តល់នូវក្របខ័ណ្ឌសកម្មភាពដែលនឹងត្រូវអនុវត្តដើម្បីសម្រេចបាននូវ អាទិភាពនានាដែលក្នុងនោះរួមមាន (ក) ការផ្តល់សេវាសុខាភិបាល (ខ) ការផ្លាស់ប្តូរឥរិយាបទ (គ) ការកែលម្អគុណភាព (ឃ) ការអភិវឌ្ឍធនធានមនុស្ស (ង)ហិរញ្ញប្បទានសុខាភិបាល (ច) ការអភិវឌ្ឍស្ថាប័ន។ ផែនការ យុទ្ធសាស្ត្រសុខាភិបាល គឺជាក្របខ័ណនៃការណែនាំតម្រង់ទិស សម្រាប់គ្រប់សកម្មភាពទាំងអស់ក្នុងវិស័យសុខាភិបាល ការរៀបរាប់ខាងក្រោមនេះ៖ (រួម

បញ្ចូលទាំងសូចនាករនៅក្នុងតារាង ៤.៥) គឺគ្រាន់តែ បង្ហាញបញ្ហាសំខាន់ៗមួយចំនួនតែប៉ុណ្ណោះ ពុំបានធ្វើការបញ្ជាក់លម្អិតនោះទេ។

សុខាភិបាល គឺជាវិស័យអាទិភាពមួយ ក្នុងចំណោមវិស័យអាទិភាពទាំងបួនរបស់ កម្មវិធីសកម្មភាព ដែលជានាបាននូវការធ្វើវិភាជន៍និងការផ្តល់ថវិកាទាន់ពេលវេលាទាំងចំណាយចរន្តនិងមូលធន ដូចនេះក្តី នៅក្នុងការប្រើប្រាស់ថវិកាជាក់ស្តែងថ្នាក់ជាតិហាក់ដូចជាប្រើប្រាស់ចំណែកមួយធំជាងទៅ.. និងថ្នាក់ក្រោមបន្តបន្ទាប់។ ដោយសារអ្នកផ្តល់សេវាច្រើន ទាំងផ្នែករដ្ឋនិងទាំងផ្នែកឯកជនហើយការ ដែលកើតមានដោយបុគ្គលម្នាក់ៗ ដែលពួកគេភាគច្រើនជាអ្នកក្រីក្របំផុត ធ្វើឱ្យមានការពិបាកណាស់ កែតម្រូវការប៉ាន់ប្រមាណចំណាយឱ្យបានត្រឹមត្រូវលើការថែទាំសុខភាពនៅកម្ពុជា ប៉ុន្តែផ្នែកលើមូលដ្ឋាន ចំនួន ការចំណាយនៅតែមានកម្រិតទាបនៅឡើយ ប្រហែល ៣៣ដុល្លារអាមេរិកក្នុងប្រជាជនម្នាក់។ "មូលនិធិ សមធម៌ " ត្រូវបានចាប់ផ្តើមអនុវត្ត ដើម្បីបំពេញបន្ថែមពីលើប្រព័ន្ធមិនទូទាត់ថ្លៃព្យាបាលជម្ងឺដែលមានស្រាប់។ ដើម្បីកែលម្អលទ្ធភាពប្រើប្រាស់នូវប្រព័ន្ធថែទាំសុខភាព។ គម្រោងសាកល្បងចំនួន ១៧ កំពុងដំណើរការក្នុង ចំណោមខេត្ត-ក្រុងចំនួន ១៣ ហើយ មូលនិធិសមធម៌ នឹងត្រូវបង្កើនកម្រិត នៅក្នុងពេលដ៏ខ្លីខាងមុខ។ ទោះបីជា ដូចនេះក្តី វិធីសាស្រ្តជាច្រើនទៀតប្រកបដោយចីរភាពជាង សម្រាប់ជួយអ្នកក្រនៅក្នុងរយៈពេលវែង ត្រូវតែបានយក មកគិតគូរពិចារណា។ ដើម្បីឈានទៅសម្រេចបាននូវការកែលម្អគុណភាព ការការពារនិងការថែរក្សាសុខភាពគម្រោង សំណុំសកម្មភាពអប្បបរមា និង គម្រោងសំណុំសកម្មភាពបង្កប់ ត្រូវបាននិងកំពុងដាក់ឱ្យដំណើរការ។ អង្គការក្រៅរដ្ឋាភិបាលមួយចំនួន បាននឹងកំពុងអនុវត្តកិច្ចសន្យាគម្រោងសាកល្បងនៅក្នុងស្រុកប្រតិបត្តិចំនួន ១១ ដើម្បីជានាផ្តល់ឱ្យបានសមរម្យនូវការថែទាំសុខភាព ជាពិសេស នៅតំបន់អ្នកក្រីក្រនិងអ្នករស់នៅតំបន់ដាច់ស្រយាល ដើម្បីឱ្យបានដល់ដៃជនងាយរងគ្រោះនៅតំបន់នោះ។ គម្រោងទាំងអស់នេះ នឹងត្រូវពង្រីកទៅកាន់តំបន់ផ្សេងៗ ទៀត។ table5

## ៦.១១.សកម្មភាពនិងយុទ្ធសាស្រ្ត

សកម្មភាពនិងយុទ្ធសាស្រ្តជាអាទិភាព ដើម្បីអនុវត្តនៅក្នុងវិស័យសុខាភិបាល រួមមាន : .

- បង្កើនល្បឿនកំណែទម្រង់នៅគ្រប់ផ្នែកទាំងអស់។
- ព្យាយាមនិងសម្រេចការសម្របសម្រួលប្រសិទ្ធភាពចំណាយ ឱ្យបានប្រសើរនៅក្នុងកម្មវិធីត្រួតពិនិត្យ ជម្ងឺតាមរយៈខ្សែបណ្តាយនិងយន្តការបែងចែកសេវាសុខាភិបាល។
- លើសពីនេះទៀត ពង្រីកនិងពង្រឹងមូលនិធិសមធម៌សុខាភិបាល ដើម្បីជួយអ្នកក្រីក្រឱ្យអាចប្រើប្រាស់ សេវាសុខភាពសាធារណៈបានស្រាវជ្រាវដើម្បីស្វែងរកមធ្យោបាយនានាប្រកបដោយចីរភាពក្នុងការជួយ អ្នកក្រីក្រ ដើម្បីមានភាពងាយស្រួលក្នុងការទទួលបាននូវប្រព័ន្ធថែទាំសុខភាពដោយមិនបាច់បង់ថ្លៃ ព្យាបាល ឬតាមរយៈនៃជំនួយរូបិយវត្ថុដែលមានគោលដៅច្បាស់លាស់។
- ជាទូទៅ ធ្វើសនិទានកម្មប្រព័ន្ធស្តារចំណាយឡើងវិញ ដើម្បីជានាឱ្យមានការអនុវត្តល្អប្រសើរបំផុត។

- ស្វែងរកវិធីនិងមធ្យោបាយនានា ដើម្បីកែលម្អឱ្យបានប្រសើរឡើងនូវហិរញ្ញប្បទានសម្រាប់មន្ទីរពេទ្យ។
- បង្កើនការជ្រើសរើសនិងការបណ្តុះបណ្តាលធ្ម និងធានាការបែងចែកពួកគេឱ្យទៅបម្រើការងារនៅតំបន់ដែលមានតម្រូវការ។
- បង្កើនសមាមាត្រនៃការសម្រាលកូនដោយបុគ្គលិកសុខាភិបាលដែលមានជំនាញ និងលើកកម្ពស់សេវាសង្គ្រោះបន្ទាន់ផ្នែកសម្រាលកូនដោយការវះកាត់។
- កែលម្អសុខភាពកុមារ តាមរយៈការគ្របដណ្តប់ជាទូទៅ នៃអន្តរាគមន៍របស់កម្មវិធី ប័ណ្ណពិនសម្រាប់ ការគង់វង្សនៃកុមារ រួមបញ្ចូលទាំង អន្តរាគមន៍ផ្នែកអាហារូបត្ថម្ភ និងកម្មវិធី ការគ្រប់គ្រងចម្រើននៃ ជម្ងឺរយៈកុមារ។
- កែលម្អសេវានិងព័ត៌មានពីសុខភាពបន្តពូជ រួមទាំងការពន្យារកំណើត និងដោះស្រាយបញ្ហានិងសេវា
- សុខភាពផ្លូវភេទនិងសុខភាពបន្តពូជ របស់យុវជន។
- ពិនិត្យស្វែងរកលទ្ធភាពក្នុងការពង្រីកកម្មវិធីអ្នកស្ម័គ្រចិត្តតាមភូមិដែលមានបច្ចុប្បន្នសម្រាប់ការថែទាំសុខភាពទាក់ទងនឹងជម្ងឺគ្រុនចាញ់ ដើម្បីផ្តល់ការការពារនិងថែរក្សាសុខភាព តាមរយៈ បុគ្គលិកសុខាភិបាលតាមភូមិដែលមានតម្លៃពលកម្មទាប ដែលត្រូវបានជ្រើសរើសដោយសហគមន៍ និងចែករំលែក ចំណេះដឹងអប្បបរមាស្តីពីការថែទាំសុខភាព។
- សាងសង់ឬស្តារឡើងវិញ និងកែសម្រួលមណ្ឌលសុខភាពបន្ថែមទៀត ( ថ្នាក់ស្រុកនិងឃុំ ) និងមន្ទីរពេទ្យបង្អែកថ្នាក់ស្រុក ជាពិសេស នៅតំបន់ក្រីក្របំផុត។
- លើកកម្ពស់ការអប់រំ និងសេវាសង្គ្រោះបន្ទាន់។
- ពង្រឹងជាការអនុវត្តបទបញ្ញតិនិងច្បាប់សុខាភិបាល ដែលទាក់ទងនឹងវេជ្ជសាស្រ្តនិងឱសថ ព្រមទាំងសុវត្ថិភាពចំណីអាហារផងដែរ។
- ធានាផ្តល់ថវិកាឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលាសម្រាប់វិស័យសុខាភិបាល។
- បង្កលក្ខណៈងាយស្រួលនិងលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជន ក្នុងការថត ទាំងនៅទីប្រជុំជន និងទាំងនៅទីជនបទ។

**មេរោគហ៊ីវ/ជម្ងឺអេដស៍** : ការការពារ ការព្យាបាល ការថែទាំ និងការខិតខំកាត់បនេះ មេរោគហ៊ីវ/ជម្ងឺអេដស៍ គឺជាកត្តាសំខាន់រួមចំណែកដល់គោលដៅរួមនៃ ផយអដ ក្នុងការការ និងកំណើនសេដ្ឋកិច្ច។ កិច្ចប្រឹងប្រែងរួមគ្នា បានធ្វើឱ្យមានការថយចុះប្រើវាឡង់បន្ទាប់ពីមានការ ចាប់តាំងពីឆ្នាំ១៩៩៧ ការពង្រីកសេវាកម្មយ៉ាងឆាប់រហ័សសម្រាប់ប្រជាជនដែលមានផ្ទុកមេរោគ បន្តការថែទាំ បង្កើនកម្រិតយល់ដឹងអំពីមេរោគហ៊ីវដល់ប្រជាជនទាំងអស់ និងការផ្លាស់ប្តូរបរិយាកា នយោបាយ ដូចជា ការអនុម័តិច្បាប់ស្តីពីការការពារនិងការត្រួតពិនិត្យមេរោគហ៊ីវ /ជម្ងឺអេដស៍។ ការប្រែប្រួលនៃជម្ងឺរាតត្បាតប្រមូលផ្តុំលើក្រុមដែលមានហានិភ័យខ្ពស់ ដែលរាលដាលក្នុងចំណោមប្រជាជន ១ ចាំបាច់ត្រូវពង្រឹងបន្ថែមទៀតនូវការទទួលខុសត្រូវនៅថ្នាក់ជាតិចំពោះមេរោគហ៊ីវ /ជម្ងឺអេដស៍។ រាជរដ្ឋាន កម្ពុជា ប្តេជ្ញាដើម្បីធ្វើការឆ្លើយតបទៅនឹងបញ្ហាពហុវិស័យ ដែលបានណែនាំតាមរយៈ ផយអដ សម្រាប់ ឆ្លើយតប

យ៉ាងទូលំទូលាយលើមេរោគហ៊ីវ/ជម្ងឺអេដស៍ ឆ្នាំ២០០៦-២០១០ ជាមួយនឹងការឆ្លើយតបយ៉ាងខ្លាំងកាតាមលក្ខណៈវិមជ្ឈការ។ អាទិភាពសំខាន់ៗ រួមមាន :

- ជំរុញកម្មវិធីលើកទឹកចិត្តឱ្យបានទូលំទូលាយ ចំពោះបុរស ស្ត្រីក្នុងការប្រើប្រាស់ស្រោមអនាម័យ និងជំរុញសកម្មភាពប្រើប្រាស់ស្រោមអនាម័យសម្រាប់ប្រជាជនទូទៅ ដែលធ្វើសកម្មភាពផ្លូវភេទ រួមមាន ស្ត្រី មនុស្សពេញវ័យ និងយុវវ័យ។
- ទប់ស្កាត់ការឆ្លងនៃមេរោគហ៊ីវ ជំងឺអេដស៍ទៅលើគ្រួសារ តាមរយៈកម្មវិធីព័ត៌មាន ការអប់រំ ការប្រាស្រ័យទាក់ទង និងការពិគ្រោះយោបល់ជាលក្ខណៈបុគ្គល។
- បង្កើននិងកែលម្អសេវាគាំទ្រ និងសេវាថែទាំសុខភាព ដែលមានផលប៉ះពាល់ដោយមេរោគហ៊ីវ ជម្ងឺអេដស៍។

**សមភាពយេនឌ័រ** : រាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកស្ត្រីមានតួនាទីសំខាន់នៅក្នុងសេដ្ឋកិច្ច និងសង្គមក។ ផែនការយុទ្ធសាស្ត្រសម្រាប់ស្ត្រី "នារីរតនៈ ឬ ស្ត្រីគឺជាត្បូងមានតម្លៃ" នឹងបន្តនូវភាពខ្លាំងក្លាក្នុងគោលប ផ្តល់ជូនស្ត្រីកម្ពុជានូវតម្លៃនិងក្តីសង្ឃឹមក្នុងជីវិត តាមរយៈ ការបញ្ជ្រាបយេនឌ័រនៅគ្រប់សកម្មភាពទាំង រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់អាទិភាពខ្ពស់លើការលើកទឹកចិត្ត និងការលើកកម្ពស់ស្ថានភាពសង្គមរបប ដោយផ្តោតការយកចិត្តទុកដាក់លើការអនុវត្តយុទ្ធសាស្ត្រយេនឌ័រ ការកសាងសមត្ថភាពស្ត្រីលើគ្រប់វិស័យការផ្លាស់ប្តូរឥរិយាបទសង្គមដែលមានការរើសអើងប្រឆាំងនឹងស្ត្រី និងការធានានូវសិទ្ធិរបស់ស្រីឱ្យម លរួមយ៉ាងសកម្ម និងដោយស្មើភាពក្នុងការកសាងប្រទេសជាតិ។

បញ្ហាសំខាន់បំផុតដើម្បីកាត់បន្ថយភាពក្រីក្រគឺការលុបបំបាត់យ៉ាងឆាប់នូវរាល់ឧបសគ្គចំពោះមុខ និងដែលជាប់ពាក់ព័ន្ធវិសមភាពយេនឌ័រ ដូចជា វិសមភាពក្នុងការទទួលបានការអប់រំ ថ្លៃឈ្នួលការងារ ភាពជា «សិទឹកងការកាន់កាប់ដីធ្លី ការថែរក្សាសុខភាពបន្តពូជរបស់ពួកគេ ភាពងាយទទួលរងគ្រោះដោយសារ រោគហ៊ីវ ជម្ងឺអេដស៍ និងការជួញដូរស្ត្រី និងការធ្វើការងារដែលមិនទទួលបានផលប្រយោជន៍ជាទូទៅ ទាំងក្នុង គេសារនិងសង្គម នៅពេលជាមួយគ្នានេះដែរ ការទទួលបន្ទុកដ៏ធ្ងន់ធ្ងរក្នុងការចិញ្ចឹមបីបាច់គ្រួសារ។ ខណៈពេល ដែលស្ត្រីជាច្រើនជាកម្លាំងពលកម្មនៅក្នុងវិស័យឧស្សាហកម្មដោយសារបច្ចុប្បន្នវិស័យកាត់ដេររីកចម្រើនយ៉ាង ឆាប់រហ័ស ទោះបីជាស្ត្រីដ៏ច្រើនលើសលប់ជាកម្លាំងពលកម្មដែលមានកម្រិតទាប ក៏តំណាងរបស់ស្ត្រីនៅក្នុងកម្រិត អ្នកតាក់តែងគោលនយោបាយនិងការធ្វើសេចក្តីសម្រេចចិត្ត រួមមានរដ្ឋសភាជាតិ និងស្ថាប័នប្រជាធិបតេយ្យ ផ្សេងៗ មន្ត្រីរាជការ និងផ្នែកផ្សេងៗទៀតនៅមានកម្រិតទាបនៅឡើយ ហើយត្រូវទាមទារធ្វើការកែលម្អដោយ យកចិត្តទុកដាក់។ ៤.៩៩ ដោយសារយេនឌ័រជាបញ្ហាអន្តរវិស័យ និងជាការទទួលខុសត្រូវរបស់គ្រប់ស្ថាបន៍ទាំងអស់បញ្ហានិង យុទ្ធសាស្ត្រដើម្បីដោះស្រាយវិសមភាពយេនឌ័រត្រូវបានបង្ហាញ រួចមកហើយនៅក្នុងវិស័យផ្សេងៗដូចជា កសិកម្ម ការងារ អប់រំ សុខាភិបាល និងផ្នែកផ្សេងៗទៀតនៅផ្នែកខាងដើមនៃជំពូកនេះ។ ចំនួនដ៏ច្រើននិងទិដ្ឋភាពផ្សេងៗការបញ្ជ្រាបយេនឌ័រនៅក្នុងប្រទេស ត្រូវមានការចូលរួមយ៉ាងខ្លាំងក្លា។ នៅថ្នាក់ជាតិ ក៏ដូចជាថ្នាក់ក្រោម ជាតិ និងការចូលរួមនៅថ្នាក់មូលដ្ឋាន គឺផ្តោតទៅលើ :

- ការប្តេជ្ញាចិត្តកសាងសមត្ថភាពនៅគ្រប់កម្រិតទាំងអស់ រួមមាន ទាំងអ្នកធ្វើគោលនយោបាយ និងកម្មវិធី នានា ដែលទាក់ទងនឹងយេនឌ័រ និងការបញ្ជ្រាបយេនឌ័រ។

- ជំរុញការផ្តល់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី។
- លើកកម្ពស់ការការពារខាងផ្លូវច្បាប់ចំពោះស្ត្រី។

ផយអជ នឹងផ្តោតលើផ្នែកសំខាន់ៗមួយចំនួន តាមរយៈការផ្សព្វផ្សាយតាមរយៈការផ្សព្វផ្សាយ ចំណេះដឹង និងសកម្មភាពសំខាន់នានា រួមមាន :

- បញ្ជ្រាបយេនឌ័រទៅក្នុងផ្នត់គំនិតរបស់ប្រជាជនកម្ពុជាទាំងមូល រួមមាន នៅក្នុង ថ្នាក់រដ្ឋាភិបាលទាំងអស់និងនៅក្នុងដំណើរការផ្តល់ថវិកា។
- ណែនាំ ដោះស្រាយបញ្ហាអំពើហិង្សាក្នុងគ្រួសារ ការជួញដូរស្ត្រី (តាមរយៈការលុបបំបាត់អំពើពុករលួយនិងការពង្រឹងច្បាប់ឱ្យបានម៉ឺងម៉ាត់) និងទំនៀមទំលាប់វប្បធម៌ ដែលទ្រទ្រង់វិសមភាពយេនឌ័រនៅក្នុងគ្រួសារ និងសង្គម។
- បង្កើនលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានផលិតភាពទ្រព្យសកម្មដូចជា មូលធនហិរញ្ញវត្ថុ ការកាត់ បន្ថយការរើសអើងដែលទាក់ទងនឹងយេនឌ័រនៅលើទីផ្សារពលកម្ម និងផ្តល់បរិយាកាសដ៏ល្អប្រសើរដើរ ឱ្យស្ត្រីអាចចូលរួមបានច្រើនជាងមុននៅក្នុងការងារដែលមានគុណភាពខ្ពស់។
- ដោះស្រាយបញ្ហាផ្សេងៗដូចជាការបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងរចនាសម្ពន្ធ័នៃសេចក្តីសម្រេច នានា ទាំងក្នុងនិងក្រៅផ្លូវការ ជំរុញឱ្យស្ត្រីទទួលបាននូវកម្រិតឋានៈនិងតួនាទីខ្ពស់នៅក្នុងរដ្ឋបាលសាធារណៈ តាមរយៈគោលនយោបាយនិងច្បាប់។ បង្កើនល្បឿននិងជំរុញឱ្យមានការអនុវត្តច្បាប់រដ្ឋប្បវេណីឱ្យបាន ម៉ឺងម៉ាត់ក្នុងការដោះស្រាយអំពើហិង្សាក្នុងគ្រួសារ ជំរុញឱ្យមានការអនុម័តច្បាប់ជួញដូរមនុស្ស និងការ អនុវត្តផែនការសកម្មភាពជាតិ ដើម្បីការពារជនរងគ្រោះដោយអំពើហិង្សា។

គោលនយោបាយប្រជាជន : គោលនយោបាយនេះក៏ជាបញ្ហាអន្តរវិស័យមួយយ៉ាងទូលំទូលាយ ដែលមាន ការពាក់ព័ន្ធនឹងវិស័យផ្សេងៗទៀតជាច្រើន ដូចជា សុខាភិបាល អប់រំ បរិស្ថាន ម៉ាក្រូសេដ្ឋកិច្ច សមភាពយេនឌ័រ បញ្ហាគ្រឿងញៀន និងវិស័យផ្សេងៗទៀត។ បច្ចុប្បន្នអត្រាកំណើនប្រជាជនប្រចាំឆ្នាំគឺ ១,៨ភាគរយ ជាបន្ទុកដ៏ ធ្ងន់ធ្ងរមួយទៅលើសេវាសាធារណៈនិងធនធាន និងជាកត្តាមួយរួមចំណែកឱ្យកើតមានភាពក្រីក្រ។ ដំណោះ៖ ស្រាយជាអាទិភាពរួមមាន :

- គាំទ្រដល់គូស្វាមីភរិយានិងបុគ្គលម្នាក់ៗឱ្យធ្វើការសម្រេចចិត្តដោយសេរី និងដោយទទួលខុសត្រូវលើ ចំនួនកូន និងការពន្យារកំណើត ហើយឱ្យទទួលបាននូវ ព័ត៌មាន ការអប់រំ សេវាកម្មនានា និងមធ្យោបាយដើម្បីអនុវត្តការសម្រេចចិត្តខាងលើ។
- កាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាននៃការផ្លាស់ប្តូរទីលំនៅ ទៅលើទីប្រជុំជននិងជនបទ។
- បញ្ចូលអថេរប្រជាជន រួមទាំង បញ្ហាមនុស្សចាស់និងការផ្លាស់ទីលំនៅ ទៅក្នុងគោលនយោបាយ សេដ្ឋកិច្ចនិងសង្គមកិច្ច នៅគ្រប់កម្រិតទាំងអស់នៃផែនការ និងកម្មវិធីនានា។

ចំណាយ ធនធាន និងការរៀបចំកម្មវិធី : ការសម្រេចបាននូវគោលដៅនិងចំណុចដៅទាំងអស់នៅ ក្នុងកំឡុងពេលអនុវត្ត ផយអជ ២០០៦-២០១០ នឹងពាក់ព័ន្ធទៅនឹងចំនួនដ៏ច្រើននៃធនធាន

ហិរញ្ញវត្ថុ" បច្ចេកទេស ទាំងផ្នែកសាធារណៈនិងទាំងផ្នែកឯកជន។ ការលើកឡើងនៅក្នុងជំពូកបន្ទាប់ (ជទូក។ មួយចំនួនធនធានដែលអាចរកបាននិងការរៀបចំកម្មវិធីកៀរគរជំនួយ តាមរយៈកម្មវិធីវិនិយោគសាធារណៈ និងថវិកាប្រចាំឆ្នាំ។

# មេរៀនទី៧
# ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យកសិកម្ម

ក្រោយពីបានបញ្ចប់ជំពូកនេះ លោកអ្នកនឹងយល់ដឹងពី៖

– ការយល់ដឹងពីការលើកទឹកចិត្ត
– តើផែនការអាជីវកម្មអាចបំពេញតម្រូវការមនុស្សបានឬទេ ?
– ការគ្រប់គ្រងតាមគោលបំណង

## ៧.១.ការយល់ដឹងពីការលើកទឹកចិត្ត

### ៧.១.១.សញ្ញាណទូទៅ

ដើម្បីឲ្យដឹងថា អ្វីទៅជាការលើកទឹកចិត្តនោះ ចូរយើងចាប់ផ្តើមពិនិត្យមើលចំណុចដែលមិនមែនជាការជំរុញទឹកចិត្តសិន។ ពីព្រោះថាមនុស្សជាច្រើនយល់ខុស ទៅលើការជំរុញទឹកចិត្ត ជាលក្ខណៈបុគ្គលមួយដែលមានអ្នកខ្លះមានវាហើយអ្នកខ្លះទៀតគ្មានវាទេ។ ក្នុងការអនុវត្តជាក់ស្តែង បញ្ហានេះនិងបានបញ្ជាក់លក្ខណៈគ្រប់គ្រងដែលចាត់ទុកនិយោជិតម្នាក់ថាមនុស្សខ្ជិល។ តើការចាត់ទុក្ខមនុស្សនេះ មនុស្សម្នាក់នោះតែងតែខ្ជិលឬជាការខ្វះការជំរុញទឹកចិត្ត។

ដូច្នេះនិយមន័យនៃការជំរុញទឹកចិត្ត (Motivation )គឺជាការស្ម័គ្រចិត្ត (The willingness) ដាក់កម្រិតខ្ពស់នៃការខឹតខំប្រឹងប្រែងលើគោលដៅរបស់អង្គការចាត់តាំងនីមួយ និងដាក់លក្ខណៈឲ្យសមត្ថភាព នៃការខឹតខំប្រឹងប្រែង(The Efforts ability)ដើម្បីសម្រេចបំណងផ្ទាល់ខ្លួន។

នៅពេលដែលមានការជំរុញទឹកចិត្តទូទៅ សំដៅដល់ការខឹតខំសម្រេចដៅណាមួយទៅលើគោលដៅរបស់អង្គការចាត់តាំងពីព្រៅការពាក់ពន្ធ័របស់យើង គឺទៅលើលក្ខណៈសម្បត្តិដែលទាក់ទងទៅនិងការងារ។

ដូចនេះ មានសមត្ថភាពបីសំខាន់ៗនៅក្នុងនិយនន័យនៃការជំរុញទឹកចិត្តគឺ៖

- ការខិតខំ (The Effort )គឺជារង្វាស់មួយនៃប្រពលភាព (Intensity of Emotion )។ នៅពេលអ្នកណាម្នាក់ត្រូវបានគេជំរុញ
- ទឹកចិត្តគាត់តែងតែខឹតខំធ្វើការខ្លាំងឡើង។
- គោលដៅរបស់អង្គការចាត់តាំង (Organizaional Goals)ប៉ុន្តែកម្រិតខ្ពសនៃការខឹតខំប្រឹងប្រែង គឺប្រហែលជាមិនបាន
- សម្លេងល្អប្រសើរទេលុះត្រាតែខឹតខំប្រឹងប្រែងទាំងនោះត្រូវបានគេបង្ហាញផ្លូវក្នុងទិសដៅមួយ ដែលផ្តល់ផលប្រយោជន៍
- ឬចំណេញដល់អង្គភាពចាត់តាំង ដូចច្នេះយើងត្រូវគិតថា គុណភាពនៃការខឹតខំគឺជាប្រពលភាពរបស់វា។ ម្លោះហើយការខឹតខំ

- ដែលត្រូវបានណែនាំនិងស្របទិសដៅជាមួយនិងគោលដៅអង្គភាព គឺជាប្រភេទនៃការខឹតខំ ដែលគួរត្រូវបានគេស្វែងយល់ចាំបាច់។
- តម្រូវការ (Need) គឺជាការបង្ហាញនូវផ្ទៃក្នុងមួយ ដែលធ្វើឲ្យមានលទ្ធផលជាក់ស្តែង បញ្ចក់ពីការទាក់ទាញទឹកចិត្ត។

## ៧.១.២.ទ្រឹស្តីទូទៅមួននៃការជំរុញទឹកចិត្ត (Fell-Know Theoriesof motivation)

### ក. ការបំពេញសេចក្តីត្រូវការជាមូលដ្ឋាន (Basic Need Satisfaction)

រាល់ការខឹតខំរបស់មនុស្សទាំងអស់ ត្រូវបានគេជំរុញទឹកចិត្តដោយធ្វើយ៉ាងណាដើម្បីបំពេញសេចក្តីត្រូវការជាមូលដ្ឋានរបស់គេ ការខឹតខំធ្វើការនោះ គឺទៅតាមគំរូមួយ ដែលតម្រូវការបានបំពេញតាមលំដាប់ នៃសារៈសំខាន់របស់គេម្នាក់ៗ។ Abraham Maslow បានសិក្សានិងបង្កើតនូងទ្រឹស្តីមួយនៃតម្រូវការរបស់មនុស្សជាតិ ដែលមានឈ្មោះថា ឋានានុក្រមនៃទ្រឹស្តីតម្រូវការ (Hierachy of need Theory) ដែលរួមមានឋានានុក្រម៖

- តម្រូវការរូបរាងកាយៈ ម្ហូបអាហារ ទឹក សម្លៀកបំពាក់ ជម្រក ភេទ និងតម្រូវការរាងកាយផ្សេងៗទៀត
- -តម្រូវការសុវត្ថភាពៈ សន្តិសុខ និងការពារផល់អាក្រកមកលើរាងកាយ និងសតិអារម្មណ៏។
- -តម្រូវការសង្គមៈ សេចក្តីស្រលាញ់ ភាពមិនឯកោ ការទទូលស្គាល់ក្នុងសង្គម និងភាពរាប់អានពីមិត្តភ័ក្រ។
- -តម្រូវការនូវសេចក្តីគោរពៈ ការចងឲ្យគេគោរពខ្លួន ចងបានកិត្តិយស កេរ្ត៍ឈ្មោះ និងឋានៈ ក្នុងសង្គម។
- -តម្រូវការពេញលេញៈ ជាតម្រូវការដែលដល់កំពូល ចង់បានធ្វើឲ្យទៅជារឿងជាក់ស្តែងពិតប្រាកដ តម្រូវការបង្កើនសមត្ថភាព និងឈានដល់លទ្ធភាពពេញលេញផ្ទាល់ខ្លួន។

### ខ. ទ្រឹស្តីអនាម័យ និងជំរុញទឹកចិត្ត ( Motivation – Hygiene Theory)

កម្មករទាំងអស់ត្រូវបានគេជំរុញទឹកចិត្ត ដោយផ្តល់នូវកត្តាទាំងឡាយនៃលក្ខខណ្ឌដែលគេចង់បានពីការងាររបស់គេ។

ដើម្បីជំរុញទឹកចិត្តមនិស្សឲ្យធ្វើការដោយយកចិត្តទុក្ខដាក់លើការងារអ្នកចិត្តវិទ្យា Frederck Herzberg បានបង្កើតទ្រឹស្តីអ

អនាម័យ-ជំរុញទឹកចិត្ត (Motivation-Hygiene Theory) ដែលបញ្ជាក់ពីកត្តាទាំងឡាយដែលរួមចំណែកទៅការងារ(job Dissatisfication)ហៅថា(Motivators)ដូចជាការសម្រេចសមិទ្ធិផល ការទទួលស្គាល់ការទទួលខុសត្រូវការជឿនលឿន និងការរីកចម្រើន។

ដូចនេះអ្នកគ្រប់គ្រងដែលខំប្រឹងប្រែងលុបបំបាត់ ឬជម្រុះចោលនូវកត្តាទាំងឡាយដែលបង្កើតការមិនពេញចិត្តនិងការងារ អាចធ្វើឲ្យមាននូវភាពស្ងៀមស្ងាត់ប៉ុន្តែមិនចាំបាច់ប្រើប្រាស់ការជំរុញទឹកចិត្តទេ។ មានន័យថាគេកំពុងតែធ្វើឲ្យស្ងប់នូវកម្លាំង។

**គ.ទ្រឹស្តីXនិងY(Theory X and Y)**

**ទ្រឹស្តីX:** មនុស្សជាច្រើនមានការមិនចូលចិត្តការងារ ហើយនិងបោះបង់វាចោលប្រសិនជាអាច។ ពីព្រោះតែហេតុនេះមនុស្ស

ភាគច្រើនត្រូវបានបង្ខិតបង្ខំបង្គប់បញ្ជាឬគម្រាមកំហែងដើម្បីឲ្យគេធ្វើការងារប្រចាំថ្ងៃ។ មនុស្សប្រភេទនេះត្រូវបានជំរុញដោយប្រើទឹកប្រាក់៕

**ទ្រឹស្តីY:** មនុស្សសប្បាយនិងការងារមានសមត្ថភាពត្រួតពិនិត្យខ្លួនឯងប្រសិនបើគេត្រូវបានជំរុញឲ្យសម្រេចគោលដៅអ្វីមួយ កម្មករម្នាក់ជាធម្មតានិងមិនត្រឹមតែទទួលយកងារប៉ុណ្ណោះទេ តែថែមទាំងខិតខំយ៉ាងសកម្មដើម្បីទទួលខុសត្រូវលើការងារនោះទៀតផង៕មនុស្សប្រភេទនេះត្រូវបានគេជំរុញទឹកចិត្តដោយលក្ខខណ្ឌនិងបរិយាកាស៕

**ឃ.ទ្រឹស្តីដែលមានអនាមយ៍ពេញលេញ(Theory of Meaningful Work)**

យើងមានការងារធម្មតា និងការងារសំខាន់ៗច្រើនណាស់ ដែលយើងបានដកយកនូវផលប្រយោជន៍ជាច្រើនពីវា។ ការងារខ្លួនវាផ្ទាល់ត្រូវបានគេធ្វើឲ្យកាន់តែមានអត្ថន័យថែមទៀតនិងកាន់តែធ្វើឲ្យយើងខិតខំអស់ពីសមត្ថភាព ដើម្បីបំពេញបំណងឬតម្រូវរបស់កម្មករ៕ការងារទាំងនេះត្រូវតែរួមមានៈផែនការការប្រតិបត្តិនិងការត្រួតពិនិត្យ ប្រសិនបើវាជាការផ្តល់នូវឱកាសសម្រាប់ការរីកចម្រើននិងការទទួលស្គាល់។ ទាំងនេះគឺជាទ្រឹស្តីនៃការជំរុញទឹកចិត្តដោយការងារដែលមានន័យពេញលេញ។

## ៧.២.ការសិក្សាពីបុគ្គលិកធ្វើការក្នុងអង្គភាព

សូមចាប់ផ្តើមការសិក្សាអំពីគន្លឹះទី៣ ក្នុងរបៀបគ្រប់គ្រងដឹកនាំអង្គភាព (គន្លឹះទី៣ ការរៀបចំមន្ត្រីរាជការធ្វើការ ដោយពិចារណាលើសំណួរ អាទិភាពចំនួន ៩ គឺៈ

- លក្ខណៈ និងធម្មជាតិនៃមន្ត្រី (ការយល់ ដឹង និងស្គាល់មន្ត្រី)
- របៀបធ្វើការជាក្រុមដែលប្រសើរបំផុត
- មធ្យោបាយប្រសើរបំផុតក្នុងរបៀបធ្វើការជាក្រុម
- សារៈសំខាន់នៃរង្វាន់ និងការលើកទឹកចិត្តមន្ត្រីដែលធ្វើការជាមួយ
- វិធីបង្កើនប្រាជ្ញា និងប្រសិទ្ធភាពការងារក្រុម
- មធ្យោបាយបង្កើនសមត្ថភាពជំនាញរបស់មន្ត្រី
- វិធីទាក់ទាញជំនឿចំពោះអ្នក អង្គភាព និងទិសដៅការងារពីមន្ត្រី
- ការជំរុញឥរិយាបទល្អ និងសុភវិនិច្ឆ័យក្នុងចំណោមមន្ត្រី
- មធ្យោបាយបង្កើត និងបង្កើនប្រសិទ្ធភាពនៃការដឹកនាំមន្ត្រី។

ឆ្លើយសំណួរទាំង ៩ នេះបានល្អ និងបានត្រឹមត្រូវ លោក-អ្នក។ ណាស់នឹងមានសមត្ថភាពក្នុងរបៀបធ្វើការជាក្រុមល្អ និងជាអ្នកគ្រប់គ្រងដឹកនាំល្អម្នាក់។ មិនស្រួលប៉ុន្មានទេ ដើម្បីយល់ចេះ ដឹង និងអនុវត្តបានយ៉ាងមាន ប្រសិទ្ធភាព គន្លឹះទី៣ ដែលហៅថា ការរៀបចំមន្ត្រីរាជការធ្វើការ នេះ គឺទាមទារការសិក្សា វិភាគត្រិះរិះ។ បើធ្វើបានល្អ ធ្វើមន្ត្រីធំទៅវាមានន័យ ព្រោះហូរ ហែរ គឺលោក-អ្នកដើរត្រូវផ្លូវមិនធ្វើតាពីសតាពាសស្រេចតែចិត្ត អាងអំណាច និងអាងមានអ្នកខិលខូចចាំសាទរទាំងគ្មានរបៀបផងនោះទេ។

មន្ត្រីក្នុងអង្គភាពមានប្រភេទច្រើន និងផ្សេងៗគ្នា។ មន្ត្រីមួយចំនួនក្នុង ចំណោមនោះ មានចរិតឬកពារល្អ ឆ្លាតវៃ ស្រឡាញ់ការងារ និងចូលរួមក្នុង សកម្មភាពរបស់អង្គភាព។ មួយក្រុមខ្សឹបខ្សៀវសម្តែងនូវការមិនពេញចិត្ត មិន មានបំណងសុហាការ និងឡេបខាយ។ មួយក្រុមទៀត មិនមាត់មិនករ អ្វីក៏មិន ខ្វល់ អ្វីក៏មិនធ្វើដែរ អង្គុយរាប់ថ្ងៃរង់ចាំប្រាក់ខែ។

មួយក្រុមទៀត ធ្វើចង់ងាប់ ធ្វើរហូត ធ្វើដោយងងិតងងុល។ មួយចំនួន ផ្សេងទៀត លួចលាក់អាថ៌កំបាំង ធ្វើរឿងអាក្រក់ ធ្វើរឿងមានប្រយោជន៍ដល់ ខ្លួន និងក្រុមខ្លួន មិនចែករំលែក មិនខ្វល់អ្វីទាំងអស់។ មួយក្រុមណានោះ គិត តែចង់ឡើងខ្ពស់ទៅរកកម្រិតមួយ ដែលហួសសមត្ថភាព គឺចង់បានទទួលឋានៈ បុណ្យស័ក្តិកាន់តែធំទាំងគ្មានសមត្ថភាព។ មួយក្រុម ប្រមែរប្រមូលប៉ាក់ពួក ក្លែចឋានានុក្រមការងារ ធ្វើរឿងដើម្បីអំណាច ឥទ្ធិពល និងប្រាក់យ៉ាងងុបងុល។ ល។

ប្រឈមនឹងស្ថានភាពបែបនេះ ការគ្រប់គ្រងដឹកនាំ គឺមិនស្រួលទេ។ : ទោះជាយ៉ាងនេះក្តី មេដឹកនាំ ត្រូវតាំងចិត្តរៀបចំ និងជួយមន្ត្រីជុំវិញខ្លួន ឱ្យចេះ ធ្វើការ ឱ្យប្រកាន់ខ្ជាប់គោលជំហរសមូហភាព និងជៀសវាងការបរាជ័យ។

មន្ត្រី គឺជាធនធានដ៏មានតម្លៃបំផុតរបស់អង្គភាព និងរបស់មេដឹកនាំ។ គេគឺជាអ្នករ៉ាប់រងរៀបចំប្រព័ន្ធការងារ លើសេវា ស្វែងយល់ពីអតិថិជន និងរុញការងារអង្គភាពឱ្យទៅមុខ។ ការមើលថែមន្ត្រី គឺជាការមើលថែទាំអង្គភាព។ រឿងនេះមិនស្រួលទេ គឺពិបាកធ្វើឱ្យបានល្អណាស់។

បទពិសោធន៍ក្នុងការងារអនុវត្តបង្ហាញថា មានតែជំនាញនិងការមើល ថែតែមួយគត់ ដែលនឹងធ្វើឱ្យមន្ត្រីរបស់យើងព្រមចូលរួមក្នុងការងារជាមួយ យើង និងផ្តល់ឱ្យយើងនូវភាពភ្ញាក់ផ្អើល។ បើពួកគេ មិនស្អាតស្អំ ឪឡា ធ្វើស ប្រហែស គ្មានជំនាញគ្រប់គ្រាន់ ឬគ្មានហេតុផលក្នុងការបង្ហាញឡើងពេលធ្វើ ការងារ ពេលបម្រើសេវាកម្ម និងដោះស្រាយបញ្ហាជាមួយអតិថិជន (សាធារណៈជន) ឱកាសសម្រាប់ឈានទៅមុខ (ការលូតលាស់កម្រិតខ្ពស់ និងទៀង ទាត់) របស់អង្គភាព គឺនឹងបាត់បង់។

បើមន្ត្រីមិនឆ្លើយតបទូរស័ព្ទគួរសម និងព្រងើយកន្តើយ អតិថិជន (ឬ សាធារណៈជន) នឹងអាក់អន់ស្រពន់ចិត្ត។ បើមន្ត្រីចេះលើកទឹកចិត្ត ចេះយក ចិត្តទុកដាក់គ្រប់បែបយ៉ាងទៅលើការបម្រើរីករាយនឹងការងារ អង្គភាពនឹង បោះជំហានល្អទៅមុខ។

ការរួសរាយរាក់ទាក់ និងរក្សាមន្ត្រីល្អ គឺជារឿងពិបាក។ វាគឺជារឿង មួយដែលមានតម្លៃបំផុតដោយសារវាអាចដាក់យើងឱ្យនៅខ្ពស់។ បើមន្ត្រីរបស់យើងផ្តើម យើងក៏អាចផ្តើមជីវិតរបស់យើងនឹងកាន់តែងាយស្រួល។ បើមន្ត្រី របស់យើងអន់ យើងនឹងអន្តរាយ អង្គភាពរបស់នឹងបាត់បង់តម្លៃ។

## ៧.៣.ការទទួលស្គាល់បុគ្គលិកក្នុងអង្គភាព

ការគ្រប់គ្រងដឹកនាំអង្គភាព មានទំនាក់ទំនងជាអាទិភាពនឹងភាពស្ទាត់ ជំនាញមួយទៀត គឺ សមត្ថភាពខាងការយល់ដឹង ស្គាល់មន្ត្រី (មន្ត្រី និងបុគ្គលិក) ដែលធ្វើការងារជាមួយ ឬធ្វើការនៅក្រោមបង្គាប់ឱ្យបានជាក់ច្បាស់ ចេះ ចាត់ចែង និងចេះធ្វើការជាក្រុមជាមួយមន្ត្រីទាំងនោះ បានយ៉ាងល្អផង (ចេះ ចាត់ចែងប្រើពួកគេ និងមានទំនាក់ទំនងល្អជាមួយពួកគេផង)។

តាមន័យដូចខាងលើ គឺអ្នកគ្រប់គ្រងដឹកនាំ ត្រូវតែស្គាល់ឱ្យបានច្បាស់ មន្ត្រីដែលខ្លួនធ្វើការជាមួយ ស្គាល់ពីធម្មជាតិរបស់ពួកគេ យល់ដឹងពីការសម្រប សម្រួលជាមួយពួកគេ និងចេះអន្ទងទាក់ទាញបង្កើតកម្លាំងចិត្ត ជំនឿ និងការ ទុកចិត្តពីពួកគេ ធ្វើឱ្យពួកគេមានចំណង់នឹងបំពេញការងារដែលត្រូវធ្វើ។

អ្នកគ្រប់គ្រងដឹកនាំទោះពូកែខាងយុទ្ធសាស្ត្រយ៉ាងណាក៏ដោយ តែបើ មិនប៉ិនប្រសប់ខាងចិត្តសាស្ត្រ ខាងការយល់ដឹង ស្គាល់ពីមន្ត្រីធ្វើការជាមួយបើមិនចេះចាត់ចែង មិនចេះធ្វើការប្រកបដោយភាពចុះសម្រុង មិនចេះយោគ យល់ មិនចេះអធ្យាស្រ័យ និងមិនចេះអត់ធ្មត់នឹងចរិតមានពីធម្មជាតិរបស់បណ្តា មន្ត្រីដែលធ្វើការជាមួយយនោះ អ្វីទាំងឡាយពិតណាស់នឹងបរាជ័យ។ អ្នកគ្រប់គ្រងដឹកនាំនឹងកាន់តែមានសមត្ថភាពធ្វើរឿងនេះ ក្រោយពីបានអានយ៉ាងយក ចិត្តទុកដាក់ស្នាដៃរបស់អ្នកនិពន្ធ

មន្ត្រីខុសគ្នា និងផ្សេងៗគ្នា ព្រោះពួកគាត់មានប្រភព និងកំណើត ការ អប់រំ ការពេញចិត្ត របៀបរស់នៅចំណូលចិត្ត ការអនុវត្ត ទង្វើ និងរបៀបធ្វើការ ផ្សេងៗគ្នា។ តាមហេតុផលបានលើកឡើងនេះ មន្ត្រី ត្រូវបានបែងចែកទៅ លក្ខណៈសង្គម ចរិយាសម្បត្តិ និងបញ្ញាសម្បត្តិ។ នៅឆ្នាំ១៩៦៤ ក្រោសិក្សាស្រាវជ្រាវ «ពីធម្មជាតិរបស់មន្ត្រី» លោក ឌូក្លាស់ ម៉ាក់ ក្រេក្លរ ក្នុង ឡើងនូវទ្រឹស្តីពីរ គួរឱ្យកត់សម្គាល់ គឺ ទ្រឹស្តី X និងទ្រឹស្តី Y។

តាមសម្មតិកម្មនៃទ្រឹស្តី -X មន្ត្រី គឺមិនសូវចូលចិត្តធ្វើការងារទេ ភាគច្រើនគេចពីការងារដែលប្រគល់ឱ្យ មានមហិច្ឆិតាតិចតួចក្នុងការងារ ក្នុង ជីវិត និងចូលចិត្តសម្ងំសុខ។ ក្រុមនេះ ត្រូវការឱ្យគេត្រួតពិនិត្យ សួរនាំ បង្ខំ គំរាមកំហែង និងដាក់ទណ្ឌកម្ម និងការជំរុញដើម្បីធ្វើការ។

ផ្ទុយពីនេះ មន្ត្រីតាមសម្មតិកម្មនៃទ្រឹស្តី .Y ជាអ្នកប្រឹងប្រែងខាង កម្លាំងកាយ និងស្មារតី រួមបញ្ចូលទាំងធម្មជាតិលេងសើច និងការសម្រាកផង។ មន្ត្រីក្រុមនេះ ជាទូទៅ ចេះដឹកនាំ និងត្រួតពិនិត្យខ្លួនគេផ្ទាល់ ដើម្បីឈានទៅ សម្រេចគោលដៅដែលគេបានប្តេជ្ញាធ្វើ។

នៅក្នុងគ្រប់អង្គភាព តែងតែមានជួបប្រឈមនឹងក្រុមមន្ត្រីទាំងប្រភេទ X និង Y នេះ នៅលាយឡំគ្នា។ នេះ គឺជាឧបសគ្គនៃការងារគ្រប់គ្រង ដឹកនាំ ព្រោះបើមិនអាចរៀបចំមន្ត្រី ឱ្យធ្វើការប្រកបដោយគុណភាពទេនោះ បញ្ហាប្រាកដហើយ គឺកើតមានរាល់ថ្ងៃ។ ពេលជំរុញមន្ត្រីទាំងឡាយឱ្យធ្វើការ សូមអ្នកគ្រប់គ្រងដឹកនាំចាំថា ការត្រួតពិនិត្យ .ការគំរាមគំហែង និងទណ្ឌកម្ម ពុំមែនជាមធ្យោបាយល្អជំរុញមន្ត្រីឱ្យធ្វើការទេ។

មន្ត្រី គឺបែបនេះឯង និងគឺមិនដូចយើងទេ។ យើង ក៏មិនមែនគេដែរ គឺ មិនដូចគ្នាទេ។ បើមិនយល់ពីគេ គេក៏មិនអាចយល់ពីយើងដែរ។ ដាល ការណ៊ីហ្ស៊ី បានអះអាងថាចង់ទទួលបានការស្រឡាញ់ចូលចិត្ត ឬការគោរពពីអ្នកដទៃ លោក-អ្នកចាំបាច់ ត្រូវបង្ហាញនូវសមានចិត្តល្អទៅកាន់គេជា

មុនសិន។ មែន បើ លោក-អ្នកមិនបង្ហាញនូវការចូលចិត្ត និងចាប់អារម្មណ៍ចំពោះអ្នកណាម្នាក់ នោះផង ធ្វើម៉េចគេមកចាប់អារម្មណ៍ និងចូលចិត្តអ្នកបាន។

ស្គាល់មន្ត្រីដែលធ្វើការជាមួយឱ្យច្បាស់ មានន័យថាដឹងច្បាស់ថាអ្នក ណាមានចរិតឬកពារអាកប្បកិរិយា និងការសម្តែងយ៉ាងម៉េច? ការសិក្សា រៀនសូត្រ អប់រំ លក្ខណៈសង្គម លក្ខណៈសម្បត្តិចរិយាសម្បត្តិ បញ្ញាសម្បត្តិ សន្តានចិត្ត ចំណូលចិត្ត ជីវភាពរស់នៅ តម្រូវការ និងរបៀបធ្វើការយ៉ាងណា ដែរ? បន្ទាប់មក គឺរកវិធីឆ្លើយតបឱ្យបានត្រឹមត្រូវ និងសមសួន មន្ត្រីទាំងឡាយ ប្រហែលជានឹងធ្វើការ ហើយសហការតាមគ្រប់ក្រាភិចជាមួយលោកអ្នក។

សូមយល់ផងដែរថា មានមធ្យោបាយតែមួយគត់ដែលនាំមន្ត្រីឱ្យសាង (ធ្វើអំពើល្អ សហការ និងធ្វើការងារជាមួយអ្នកប្រកបដោយថាមភាព និង គុណភាព។ តែមួយគត់ គឺធ្វើយ៉ាងណាឱ្យគេមានចំណង់ និងបំពេញការងារនោះ។ ដឹងទេថា, មានតែផ្តល់ដល់អ្នកនូវអ្វីដែលអ្នកចង់បានទេ ទើបធ្វើឱ្យអ្នក រំភើប និងជំរុញអ្នកឱ្យធ្វើសកម្មភាព។ ចុះអ្វីទៅដែលអ្នកចង់បាន? សូមថា" យ៉ាងម៉េច? មន្ត្រីជុំវិញអ្នកយ៉ាងម៉េច? គេចង់បានអ្វីដែរ?

គ្រូពេទ្យពិនិត្យព្យាបាលជម្ងឺវិកលចរិតជនជាតិអូទ្រីសដ៏ល្បីល្បាញទេ សតវត្សរ៍ទី២០ គឺបណ្ឌិតសេយម៉ាន់ ហ្វ្រើត បានអះអាងថា ទង្វើទាំងអស់របស់មន្ត្រី ត្រូវបានបណ្តាលឡើងដោយចំណង់ជាមូលដ្ឋានពីរ គឺ (១) ចំណង់ខាង កាមគុណ និង (២) ចំណង់ចង់«ធ្វើធំ»។ ទស្សនវិទូ John Dewey អះអាងថា មូលហេតុដ៏ធំជាងគេនៃចរិតមន្ត្រី គឺ «ចំណង់ចង់ក្លាយជាមន្ត្រីសំខាន់»។

ឃ្លា ចំណង់ចង់ក្លាយជាមន្ត្រីសំខាន់ មានន័យណាស់។ តើរបស់អ្វីខ្លះ ដែលមន្ត្រីសួររក? ចម្លើយ គឺថារបស់អស់នោះមានចំនួនតិចតួចទេ តែមន្ត្រី នៅ ជុំវិញអ្នក និងអ្នកខ្លួនឯង តែងតែសួររកវាជានិច្ចកាលហាក់មិនចេះនឿយហត់។

ដាល ការណឺហ្ស៊ី ផ្តល់ចម្លើយនិងបញ្ជាក់ថារបស់អស់នោះ គឺ៖

- សុខភាព និងការរក្សាអាយុជីវិតឱ្យយឺនយូរ
- ការចិញ្ចឹមជីវិត
- លុយកាក់និងទ្រព្យសម្បត្តិ
- ការរស់នៅនាពេលអនាគត
- ការបំពេញចិត្តខាងកាមគុណ
- សុភមង្គលបុត្រធីតា និង
- មនោសញ្ចេតនាអំពីសារៈសំខាន់ក្នុងនាមជាមន្ត្រី។

សេចក្តីត្រូវការទាំងប៉ុន្មាននេះ គឺសំខាន់ និងនាំដល់ការពេញចិត្ត តែ មានរបស់មួយដែលមន្ត្រីកម្របានភ្លក្ស ហើយវាមានជម្រៅ និងកម្លាំងស្រូប ទាញទ្រាំមិនបានប្រហែលនឹងការស្រេកឃ្លានផងដែរនោះ គឺអ្វីដែល ហ្វ្រេតហៅថ «ចំណង់ចង់ធ្វើធំ និង ចន ឌីវេយ ហៅថា «ចំណង់ចង់ក្លាយជាមន្ត្រីសំខាន់ ឬមន្ត្រីគន្លឹះក្នុងអង្គភាព»។

ពិតណាស់ថា មន្ត្រីគ្រប់រូប រួមទាំងយើងខ្ញុំផង គឺចូលចិត្តការសរសើរ។ មន្ត្រីចង់ឱ្យគេផ្តល់នូវយុត្តិធម៌ ចង់ឱ្យគេលើកតម្លៃ។ មន្ត្រីស្រេកឃ្លានការសរសើរ ដោយសុទ្ធចិត្ត។ ជាអកុសល, គេកម្រផ្តល់

ឱ្យមន្ត្រីនូវអ្វីៗទាំងអស់នេះណាស់។ សូមចាំថា ជនណាដែលមានអំណាចដ៏កម្រក្នុងការសម្រន់ សេចក្ដីស្រេកឃ្លានដ៏ អាចកំបាំង និងពុំចេះស្កប់ស្កល់នេះ ហើយបំពេញបានបំណងប្រាថ្នាដ៏ជ្រាលជ្រៅក្នុងចិត្តមន្ត្រី ជននោះហើយដែលក្ដាប់មន្ត្រី និងមនុស្សម្នាទាំងពួងផងគ្នានៅ ក្នុងកណ្ដាប់ដៃរបស់ខ្លួន (ពិតណាស់ មន្ត្រីនឹងគោរពស្រលាញ់ ឱ្យតម្លៃខ្ពស់ រាប់ អាន និងស្ដាប់បង្គាប់ជននោះ) ។

ចំណង់ចង់ក្លាយ និងធ្វើខ្លួនជាមនុស្សដ៏មានសារសំខាន់នេះ គឺពុំមាន ឡើយចំពោះសត្វជាតុ។ ចំណុចនេះរហូតអាចចាត់ទុកថាជាការខុសគ្នាមួយ យ៉ាងច្បាស់រវាងមន្ត្រី និងសត្វ។ ដឹងទេថា នេះជារឿងពិត និងដែលបានកើត មានក្នុងសង្គមខ្មែរនាសម័យបុរាណ។ បុព្វបុរសខ្មែរពិតណាស់ គឺមានចំណង និងបានធ្វើរឿងបែបនេះ ហើយក៏សម្រេចបានជោគជ័យរួចហើយដែរ។ សូមដឹងថា ប្រសិនបើបុព្វបុរសខ្មែរ ពុំមានចំណង់ចង់ធ្វើធំដ៏រស់រវើក ពុំចេះលោតទេ អរិយធម៌ខ្មែរ គឺពុំកើតមានឡើយ។ គ្មានចំណងបែបនេះ មន្ត្រីរស់នៅប្រហាក់ប្រហែលនឹងសត្វ។

សេចក្ដីត្រូវការ «សារៈសំខាន់» នេះហើយ ដែលនាំឱ្យខ្ញុំ និងមន្ត្រីទាំង អស់ខំរៀន ខំអាន និងតាមដានសៀវភៅ។ ចំណង់ចង់ធ្វើធំ នេះហើយដែលនាំ ឱ្យមន្ត្រីជាច្រើន ខំធ្វើការ និងប្រមូលប្រាក់ដើម្បីសម្រេចគោលបំណងរបស់ខ្លួន ហើយមនោសញ្ចេតនាដដែលនេះ ដែលនាំអ្នកមានបំផុតនៅទីក្រុងភ្នំពេញឱ្យ ខិតខំសាងសង់វិមានដ៏ស្កឹមស្កៃដើម្បីបំពេញសេចក្ដីត្រូវការ «សារៈសំខាន់» ផ្ទាល់ខ្លួន។ ដើម្បីអះអាងដោយអចេតនាឱ្យលេចចេញ ឬឃើញ សារៈសំខាន់ នេះហើយដែលមន្ត្រីនៅទីក្រុងភ្នំពេញ ឬអ្នកជំនួញ ខំប្រឹងរកប្រាក់តាមគ្រប់រូប ភាព ហើយទិញរថយន្តឡង់គ្រួស័រ ឬឡិចស៊ិសធុនសេរីថ្មីចុងក្រោយ។ ) ។

នៅក្នុងទូទាំងពិភពលោក គេឃើញមន្ត្រីល្បីៗ ខំប្រឹងប្រែងបង្ហាញឱ្យ ឃើញនូវសារៈសំខាន់របស់ខ្លួន។ ហ្សក វ៉ាស៊ីនតុន ក៏បានតម្រូវឱ្យគេហៅថា លោកម្ចាស់ប្រធានាធិបតី។ មហាក្សត្រីយ៍ កាតេរីន នៃប្រទេសរុស្ស៊ី ប្រកាន់ មិនបើកឡើយនូវលិខិតទាំងឡាយណាដែលមិនមានការណ៍ខ្នងថា ផ្ញើថ្វាយ «ព្រះមហារាជនី»។ ខ្ញុំ ប្រកាន់មិនមើលសំបុត្រ ឬចូលរួមក្នុងកម្មវិធីអញ្ជើញណា ដែលមិនមានចំណារថា គោរពអញ្ជើញ បណ្ឌិត ឆាយ គង្គា។

សម្ដេច ឯកឧត្តម លោកជំទាវ ច្រើនណាស់នៅស្រុកខ្មែរ ស្រែកឡូឡា ខឹងសម្បារករឿងពិធីការ «ម៉េចក៏អ្នកឯងមិនធ្វើការ និងមិនអប់រំ មិនបង្រៀន ឬ ប្រាប់ភ្ញៀវអំពីរបៀបធ្វើគារវកិច្ច កិច្ចស្វាគមន៍ក្នុងខណៈដែលគេជួប និង ធ្វើទំនាក់ទំនងជាមួយខ្ញុំ។

លោក ស្នេកស្មៀរ មានកេរ្តិ៍ឈ្មោះឧត្តុង្គឧត្តមរួចហើយក្នុងចំណោម អ្នកធំៗនៅសហរដ្ឋអាមេរិកនៅតែចង់បង្កើតថែមទៀតនូវស្នើចិញ្ចាចចិញ្ចែង កិត្តិគុណរបស់លោក ដោយផ្ដល់ឱ្យគ្រួសាររបស់លោកនូវឋានៈជាអភិជន។

ពិធីករក្នុងទូរទស្សន៍ខ្មែរស្ទើរតែគ្រប់រូប ត្រូវបង្ខំចិត្តរៀនអាន និងអាន នាមរបស់មន្ត្រីជាន់ខ្ពស់ខ្មែរក្នុងមួយកម្មវិធី គឺមិនតិចជា ១០ដងដដែលៗនោះ ឡើយ។ ព្រោះខ្លាចត្រូវម៉ាត់ ឬក៏ខ្លាចដំបង និងការពិន័យ។ ដូចគ្នានេះដែរ សិល្បករជាច្រើន ត្រូវការជាអាទិភាពនូវស្នូរទះដៃ ដែលស្ដែងឱ្យឃើញនូវការ ផ្ដល់តម្លៃ និងសេចក្ដីរាប់អាន។

លោក ឆាល ឆ្វាប ជាអ្នកទទួលបានចាប់អារម្មណ៍ និងការលើកទឹកចិត្ត ពិសេស (ទទួលបានបៀវត្សរ៍ ១លានដុល្លាក្នុង ១ឆ្នាំ នាចុងទសវត្សរ៍ទី១៩) ពី ស្តេចដែកថែបអាមេរិកលោក អាន់ឌ្រូ ការណេហ្ស៊ីបានអះអាងថា នេះមិន មែនមកពីលោកមានកោសល្យដ៏ពិសេស ឬមានសមត្ថភាពយ៉ាងកម្រ ឬជាអ្នក បច្ចេកទេសដ៏ប៉ិនប្រសប់ ឬពូកែជាងអ្នកបច្ចេកទេសដទៃនោះទេ។ ការទទួល បែបនេះ គឺលោក ឆ្វប ចេះប្រើមន្ត្រី ចេះផ្តល់នូវអ្វីដែលមន្ត្រីចង់បាន ចេះលើក សរសើរ និងចេះលើកទឹកចិត្ត។

លោក ដាល ការណឺហ្ស៊ីជាអ្នកនិពន្ធសៀវភៅ សិល្បៈមូលមិត្ត។ ជោគជ័យក្នុងជីវិតបានដកស្រង់ពាក្យសម្តីផ្ទាល់របស់លោក ឆ្វាប ជាជនជាតិអាមេរិកទទួលស្គាល់ និងតែងតែយករូបគាត់មកតាំងតម្កល់ក្នុងគេហដ្ឋាន សាលារៀន ឬក្នុងហាងលក់ទំនិញ។ ល។ និងជឿថាពាក្យសម្តីទាំងនេះ អាចកែប្រធាកជីវិតរបស់ពួកគេះ

*"អំណាចក្នុងការដាស់មន្ត្រីឱ្យរំភើបរីករាយ គឺជាទុនដ៏មានតម្លៃបំផុត។ ការលើកទឹកចិត្តនេះហើយដែលបំផុសឱ្យលេច និងពង្រីកឱ្យចម្រើនឡើងនូវ និស្ស័យដ៏ឆ្នើមៗរបស់បុគ្គល"* ។

*«គ្មានអ្វីទៀតក្រៅពីការទិតៀនរបស់មេកើយឡើយ ដែលអាចសម្លាប់ មហិច្ឆតាកូនចៅ។ កុំស្តីបន្ទោសនរណាម្នាក់ និងគប្បីលើកទឹកចិត្ត ផ្តល់ដល់មន្ត្រី នូវឧត្តមគតិ ដើម្បីឈោងចាប់។ សូមតាំងចិត្តជានិច្ច ធ្វើការសរសើរ និងកុំស្រែក គំហក។ បើមើលឃើញកិច្ចការមួយត្រូវបានបំពេញល្អ សូមអបអរដោយស្មោះ ស្ម័គ្រ ហើយកុំសំចៃមាត់ក្នុងការពោលពាក្យសរសើរលើកទឹកចិត្ត»*។

នេះហើយអាថ៌កំបាំងរបស់លោក ឆ្វាប ចុះលោក-អ្នកវិញតើធ្វើដូច ម្តេច? គឺធ្វើផ្ទុយពីលោក ឆ្វាប មែនទេ? ពិតណាស់ គឺយើងអាចធ្វើផ្ទុយពីលោក ឆ្វាប។ ពេលឃើញកិច្ចការណាមួយមន្ត្រីធ្វើឱ្យទាស់ចិត្ត ខ្ញុំ និងលោក-អ្នកនឹងស្រែកសម្តែងការក្រេវក្រោធតែនៅពេលឃើញមន្ត្រីបានបំពេញកិច្ចការល្អ ត្រឹមត្រូវ យើងនឹងនៅស្ងៀមមិនចេញស្តីមួយម៉ាត់។ មិនល្អទេ ខ្ញុំ និងលោក-អ្នក គឺត្រូវតែនាំគ្នាខំកែលម្អ ..ខំរកវិធីនិយាយលើកសរសើរ....

លោក ឆ្វាប បានអះអាងថែមទៀតថា សូមជឿថា មន្ត្រីតិចណាស់.ដែលមិនខិតខំផ្ចិតផ្ចង់ថែមទៀត និងប្រឹងប្រែងអស់កម្លាំងកាយចិត្តបន្ទាប់ពី បានទទួលនូវការលើកទឹកចិត្ត។ លោកបញ្ជាក់ថា ប្រការនេះ គឺជាចំណុចមួយ ក្នុងចំណោមមូលហេតុសំខាន់ៗនៃជោគជ័យដ៏អស្ចារ្យរបស់លោក អាន់ឌ្រូ កាណេហ្ស៊ី ស្តេចដែកថែប។ ឧស្សាហកម្មដ៏ស្មុកស្មាញនេះ មិនដែលខកខានសោះ ឡើយក្នុងការសម្តែងសេចក្តីសរសើរ ដល់សហការីរបស់លោក ទាំងធ្វើជាចំហរ សាធារណៈ ទាំងធ្វើស្ងាត់ៗតែពីរនាក់។

រហូតក្រោយពេលស្លាប់បាត់ទៀត លោក អាន់ឌី ការណេហ្ស៊ី ក៏នៅរក ឃើញមធ្យោបាយសរសើរកូនចៅក្រោមបង្គាប់។ លោក អាន់ឌី ការណេហ្ស៊ី បានប្រាប់ជាមុនឱ្យចារឹកមុខផ្នូររបស់លោកថា «ទីនេះជាកន្លែងសម្រាករបស់ មន្ត្រីម្នាក់ដែលជុំវិញមូលមីរដោយមន្ត្រីប្រកបដោយប្រាជ្ញាឈ្លាសវៃជាងខ្លួន»។

ការយកចិត្តទុកដាក់លើកសរសើរ លើកទឹកចិត្ត ក៏ជាអាថ៌កំបាំងរបស់ លោក រ៉ុកហ្វែល័រ។ សាច់រឿងវានេះ គឺលោកបានចាត់បញ្ជូនអ្នកភាគហ៊ុនម្នាក់ ឱ្យដឹកនាំការងារក្រុមហ៊ុននៅអាមេរិចខាងត្បូង និងមួយរយៈក្រោយមកក្រុម ហ៊ុននោះបានទទួលរងការខាតបង់អស់ប្រាក់ ១លានដុល្លា។ រ៉ុកហ្វែល័រដឹងថា អ្នកភាគហ៊ុនបានខិតខំប្រឹងប្រែងច្រើនណាស់ តែមិនមានសល់ មិនត្រឹមតែមិនសម្តែងនូវការ

អាក់អន់ចិត្តនោះទេ លោកបែរជាល។ ចំពោះអ្នកនោះដែលអាចជ្រោង ៦០% នៃមូលនីធិវិនិយោគបានរួចពីការខូចខាត។ លោករ៉ុកហ្វែល័រ ពោលថា «ជាជោគជ័យមួយដ៏ត្រចះត្រចង់។ បើយើងនៅទីនេះវិញក៏មិនធ្វើបានល្អជានិច្ចដែរ»។

មធ្យោបាយល្អបំផុតក្នុងការរុញ (ទាក់ទាញ) មន្ត្រីឱ្យសហការ ចាប់អារម្មណ៍ និងចូលរួមយ៉ាងសកម្មក្នុងការងារ គឺការដែលអ្នកគ្រប់គ្រងដឹកនាំ ចេះ ប្រមូលផ្តុំគំនិត និងយកចិត្តទុកដាក់សង្កេត (ពិនិត្យ) រកមើលលក្ខណៈសម្បត្តិ និងគុណសម្បត្តិមន្ត្រីរបស់ខ្លួន។ បញ្ចេញនូវការចាប់អារម្មណ៍ដ៏ស្មោះស្ម័គ្រ ចំពោះពួកគេ និងរៀនសូត្រពីពួកគេ ព្រោះមន្ត្រីធ្វើការជាមួយយើង អាចមាន កម្រិតលើសយើង (អាចធ្វើបានល្អជាងយើង)។

មួយវិញទៀត គឺកាត់បន្ថយឱ្យបានច្រើនបំផុត តាមដែលអាចធ្វើបាន ការគិតគូរពីខ្លួនឯងផ្ទាល់ ពីគុណូបការៈ ពីបំណងប្រាថ្នាផ្ទាល់ខ្លួន ដោយបង្វែរ រឿងទាំងនេះ (ឬដកចេញ) ហើយបង្វែរទៅយកចិត្តទុកដាក់ចំពោះមន្ត្រី ឬ បុគ្គលិកក្រោមបង្គាប់ជំនួសវិញ និងត្រូវលើកសរសើរ លើកទឹកចិត្តពួកគេ។

សូមប្រុងប្រយ័ត្នផង ចៀសឱ្យឆ្ងាយពីការបញ្ចោរ មានន័យថា បើចង់លើកសរសើរ គឺសរសើរដោយសប្បុរសធម៌ និងសុខចិត្ត ហើយផុសចេញពី បេះដូងពិតប្រាកដ និងកុំសន្សំសំចៃ ក្នុងការសម្តែងនូវសញ្ញានៃកតវេទិតា និង ការលើកទឹកចិត្តចំពោះមន្ត្រីក្រោមបង្គាប់។ បែបនេះ សម្តីរបស់អ្នកគ្រប់គ្រងដឹកនាំ នឹងចារជាប់ក្នុងបេះដូងរបស់ពពួកមន្ត្រី ឬបុគ្គលិក។

ត្រង់នេះ គឺចង់បញ្ជាក់ថា ការគិតតែខ្លួនឯងជ្រុលពេក គឺជាទង្វើមិនល្អ និងមានឥទ្ធិពលអាក្រក់ដល់ការគ្រប់គ្រងដឹកនាំ។ តែការគិតគូរបានហត់ នូវអ្វីដែលអ្នកនឹងធ្វើ គឺជារឿងល្អ និងជារឿងដែលត្រូវការបំផុត។ ការធ្វើទស កិច្ចសិក្សាជាច្រើនទៅកាន់បណ្តាប្រទេសនៅជុំវិញកម្ពុជា បានបង្ហាត់បង់ យើងជាច្រើនថែមទៀតអំពីការបង្កើតបរិយាកាសល្អ រីករាយ និងស្នាមញញឹម នៅក្នុងអង្គភាព។ យើងបានដឹងថា មេដឹកនាំ និងអ្នកគ្រប់គ្រង ត្រូវបានផ្តល់វគ្គ សិក្សាស្តីពីការបង្កើតបរិយាកាសសប្បាយ។ ការសិក្សាទាំងនោះ មិនបង្រៀន សិល្បៈនៃការនិយាយកំប្លែងយ៉ាងប៉ិនប្រសប់ទេ ប៉ុន្តែវាមានបំណងជួយមន្ត្រី ទាក់ទងនឹងអ្វីដែលពួកគេមាននៅក្នុងខ្លួន។ នោះគឺអារម្មណ៍កំប្លែង។

សមត្ថភាពធម្មជាតិក្នុងការធ្វើឱ្យមានទិដ្ឋភាពមួយ ដែលគួរឱ្យចង់សើច សប្បាយ ឬគួរឱ្យអស់សំណើច មិនត្រឹមតែជួយបង្កើនកម្លាំងជំរុញសម្រាប់ការ ងារប៉ុណ្ណោះទេ តែថែមទាំងនឹងមានឥទ្ធិពលទៅលើមន្ត្រីនៅជុំវិញផង។ អ្នក គ្រប់គ្រងដឹកនាំ ត្រូវយកចិត្តទុកដាក់រៀនសូត្រអំពីតម្លៃនៃភាពញញឹម បើពុំ នោះទេពួកគេមិនអាចខ្មោចសមត្ថភាពមន្ត្រីជុំវិញខ្លួន ដើម្បីរកឱ្យឃើញការក រាយសប្បាយពិតប្រាកដនៅក្នុងការងារនោះទេ។

ចូរចាប់ផ្តើមគិតពីការញញឹមរហូតដល់ក្លាយជាមហាសេដ្ឋីញញឹម។ មន្ត្រីរបស់អ្នកនឹងសប្បាយចិត្តពេលឃើញលោក-អ្នកចូលមក និងលុបចោល (លុបចេញ) ជាបន្ទាន់នូវការប្រកាន់អាកប្បកិរិយាបែបមែន ការធ្វើទឹកមុខមាំ មិនលេងសើច។ ការសម្តែងបែបនេះ គឺជួយកាត់បន្ថយភាពធុញថប់ បរិស្ថានការងារ កាត់បន្ថយភាពតានតឹង និងបង្កើតឡើងនូវភាពច្នៃប្រឌិត ការងារផង។ ការនាំឬបង្កឱ្យមានការលេងសើចសប្បាយ ធ្វើឱ្យមន្ត្រីចង់ កាពីមសប្បាយ និងរីករាយជាមួយការងារ គឺពិតជាសំខាន់។

ការសហការ ចាប់អារម្មណ៍ និងចូលរួមពិតប្រាកដ គឺជាផលនៃការទុក ចិត្ត និងកើតមានពេលមន្ត្រីមានអារម្មណ៍ថាមានសុវត្ថិភាព។ កុំតាមដាន និង វាយតម្លៃមន្ត្រីរបស់ខ្លួនច្រើនពេក។ ទង្វើបែបនេះបង្កើតនូវការមិនជឿទុកចិត្ត។ ចូររកមធ្យោបាយទាក់ទាញ និងប្រាប់មន្ត្រីរបស់អ្នកឱ្យជឿថា អ្នកចាត់ទុកពួក គេជាអ្នកឈ្នះ អ្នកនឹងឈ្នះហើយអ្នកមិនចង់ឱ្យពួកគេមានគ្រោះថ្នាក់អ្វីមួយ ទេ។ បែបនេះការទំនាក់ទំនងនៅក្នុងអង្គភាព ពិតជារីកចម្រើនឡើង និងមាន ភាពប្រសើរជាហូរហែរ។

រឿងមួយទៀតដែលអ្នកគ្រប់គ្រងដឹកនាំត្រូវដឹង និងយល់គឺថា មន្ត្រីក្នុង អង្គភាពមួយចំនួន (ឬច្រើននាក់) អាចមានសមត្ថភាពខាងការបង្កើត ច្នៃប្រឌិត មានគំនិតផ្តួចផ្តើម និងអាចបង្កើតថ្មី។ តើសក្តានុពលខាងប្រាជ្ញារបស់បុគ្គល ទាំងនោះ ត្រូវបានបុគ្គលទាំងនោះខ្លួនឯង (ឬអង្គភាព) ប្រើហើយ ឬនៅ និងប្រើ បានប៉ុណ្ណា? និងសួរថាតើប្រធានអង្គភាពនីមួយៗ បានចាប់អារម្មណ៍លើបញ្ហា នេះទេ? ប្រធានអង្គភាពនីមួយៗបានធ្វើរឿងនេះទេ? ស្តាយណាស់ បើមិនបាន ប្រើសក្តានុពលខាងប្រាជ្ញាជាប្រយោជន៍សម្រាប់អង្គភាព?

ហេតុអ្វីបានជាមន្ត្រីមិនបញ្ចេញសមត្ថភាពដែលខ្លួនមាន មកជំរុញ និងជួយការងារអង្គភាព? រឿងបែបនេះទាក់ទងនឹងបញ្ហា ៤យ៉ាង គឺ៖

- គ្មានឱកាសនឹងបញ្ចេញសមត្ថភាព។
- ខ្ជិលច្រអូស មិនមានចេតនាជួយការងារ (បើធ្វើចេះខ្លាចគេប្រើ)
- មិនដឹងបញ្ចេញសមត្ថភាពបែបណាបើវាគ្មានផង និង
- មានឱកាសតែមិនដឹងបញ្ចេញយ៉ាងម៉េច ព្រោះបានរៀនចេះដឹង តែមិនដែលគិតនិងមិនដែលបានធ្វើ។

រឿងធំបែបនេះតើត្រូវដោះស្រាយបែបណា?មិនស្រួលទេ។

ក្នុងចំណោមបញ្ហាទាំង ៤ នេះ បញ្ហាទី៤ អាចដោះស្រាយបានតាម រយៈការប្រើហ្គោលចាប់យកការងារ និងការគ្រប់គ្រង ព្រមទាំងពង្រីកភាពឆ្លាត និងរហ័សក្នុងគំនិតផង។ បញ្ហា ទី៣ អាចដោះស្រាយបានតាមរយៈការជ្រើសរើសមន្ត្រីដែលមានសមត្ថភាព ផ្តត់គំនិត និងឥរិយាបថល្អមកធ្វើការ (ធ្វើឱ្យបានត្រឹមត្រូវ) រីឯ បញ្ហាទី២ និង បញ្ហាទី១ គឺទាមទារការសិក្សាស្វែងកំណត់នូវមូលហេតុ។

លោក ខូភ្លាស់ ម៉ាក់ ក្រេគ្ល័រ បានលើកឡើងយ៉ាងច្រើនពី អត្តចរិតជា ធម្មជាតិរបស់មន្ត្រី។ លោកបាននិយាយផ្តោតជាអាទិភាពលើតម្រូវ មន្ត្រីថា ពេលដែលតម្រូវការមិនត្រូវបានឆ្លើយតប មន្ត្រីនឹងមិនមានថាមពល ឬនិងមិនចំណាយថាមពលផ្ទាល់ខ្លួន ដើម្បីធ្វើការងារនោះទេ។ លោកបញ្ជាក់ថា វង្វាន់ ការមានអារម្មណ៍ល្អ និងចិត្តរីករាយ ការលើកទឹកចិត្ត ការបំពេញបំណង និងសេចក្តីត្រូវការ រួមទាំង លក្ខខណ្ឌ និងអំណោយផលការងារល្អ នឹងនាំមន្ត្រីមិនត្រឹមតែខំធ្វើការងារប៉ុណ្ណោះទេ តែថែមទាំងរៀនសូត្រ និងស្វែង រកការទទួលខុសត្រូវថែមទៀតផង។

ការគ្រប់គ្រងដឹកនាំនឹងទទួលបានផលល្អ ប្រសិនបើមេដឹកនាំបាន យល់ពីតម្រូវការរបស់មន្ត្រី និងព្យាយាមឆ្លើយតប ធ្វើឱ្យមន្ត្រីជុំវិញបានឃើញ ជឿជាក់ និងទទួលស្គាល់ថា មេដឹកនាំបានខិត ខំដោះស្រាយ ឬបានឆ្លើយតប ចំពោះបញ្ហានោះប្រាកដមែន (បញ្ជាក់៖ ការបំពេញតម្រូវការត្រូវស្រប

ច្បាប់ មិនប៉ះពាល់អវិជ្ជមានដល់មន្ត្រីដទៃ និងមិនប៉ះពាល់អវិជ្ជមានដល់សេដ្ឋកិច្ច និងសង្គម) ។ វិធានការបង្ខំ គំរាមគំហែង ទណ្ឌកម្ម គឺមិនល្អទេ។

ការព្យាយាមឆ្លើយតបតម្រូវការរបស់មន្ត្រី គឺជាវិធានដ៏ល្អ តែក៏សូមឱ្យ អ្នកគ្រប់គ្រងដឹកនាំយល់ផងថា នឹងមិនធ្វើអ្វីខុស ឬផ្ទុយនឹងច្បាប់ដើម្បីឆ្លើយ តបចំពោះតម្រូវការមន្ត្រីនោះឡើយ។

លោក អាប្រាហាំ ម៉ាស្លូវ បានអះអាងដ៏មានសារៈសំខាន់ថា អ្នកគ្រប់ គ្រងដឹកនាំ ឬអ្នកដែលរៀបចំខ្លួនដើម្បីធ្វើជាអ្នកគ្រប់គ្រងដឹកនាំ ក្នុងសហគ្រាស ឬអង្គភាពមួយ ត្រូវចាំថាដើម្បីឱ្យមន្ត្រីរបស់គាត់ធ្វើការងារបានល្អ និងប្រព្រឹត្តល្អចំពោះគាត់ ចំពោះក្រុម ឬអង្គភាព.គាត់ត្រូវតែយល់ពីតម្រូវការរបស់ពួកគេ និងអះអាងពីអ្វីដែលអាចធ្វើដើម្បីពួកគេ។ សូមតាំងចិត្តធ្វើរឿងមួយចំនួនដើម មន្ត្រីរបស់អ្នក (តែសូមកុំភ្លេចថាត្រូវស្របច្បាប់) ។

ឋានានុក្រម ៥ នៃទ្រឹស្តីតម្រូវការរបស់លោក អាប្រាហាំ ម៉ាស្លូវ៖

- តម្រូវការរូបរាងកាយ៖ ម្ហូបអាហារ ទឹក សម្លៀកបំពាក់ ជម្រក ផ្លូវភេទ (កាមគុណ) តម្រូវការសម្រាប់រូបរាងកាយផ្សេងទៀត។
- តម្រូវការសុវត្ថិភាព៖ សន្តិសុខ ការការពារផលអាក្រក់ដែលអាចធ្លាក់មកលើរូបរាងកាយ ឬអារម្មណ៍របស់មនុស្ស និងភាពងាយ ...ស្រួល និងរីករាយក្នុងការរស់នៅ។
- តម្រូវការសង្គម៖ សេចក្តីស្រឡាញ់ ភាពមិននៅឯកោ ការទទួលខុសត្រូវក្នុងសង្គម ការរាប់អានពីមេកើយ មិត្តភក្តិ មិត្តរួមការងារ និងញាតិសន្តាន និងមនុស្សជុំវិញ។
- តម្រូវការសេចក្តីគោរព៖ តម្រូវការចង់បានឱ្យអ្វីៗប្រែទៅជារឿង ជាក់ស្តែង និងប្រាកដប្រជា។
- តម្រូវការពេញលេញ៖ ការបង្កើនសមត្ថភាព ការឈានដល់ ឬ ទទួលបានលទ្ធផលពេញលេញផ្ទាល់ខ្លួន និងបានជាទីគាប់ចិត្ត

វាប្រសើរបំផុតនៅពេលដែលអ្នកគ្រប់គ្រងដឹកនាំ បានតាំងចិត្តធ្វើ និង ដើម្បីរឿងពិសេសសម្រាប់មន្ត្រី ដូចជា ជួយបង្កើត សន្សំ និងផ្តល់ឱ្យពួកគេ។

- ប្រាក់
- ពេលវេលា
- ម្ហូបអាហារ
- ទីជម្រក
- សម្លៀកបំពាក់
- សន្តិសុខ សុវត្ថិភាព និងភាពងាយស្រួល
- ការសម្រាកលំហែ និងក្តីស្រឡាញ់
- មិត្តភាព និងកម្មសិទ្ធិ
- ភាពខ្ពង់ខ្ពស់ និងកិត្យានុភាព
- ការគោរព និងការកោតសរសើរ
- បន្ថែមនូវតម្លៃចំពោះការរស់នៅ។

ប្រយោគខាងលើនេះបញ្ជាក់ថា ការលើកទឹកចិត្ត និងការបំពេញតម្រូវ ការរបស់មន្ត្រី គឺជាមធ្យោបាយតែមួយ និងប្រសើរបំផុតដើម្បីប្រសិទ្ធភាព និង ភាពសក្តិសិទ្ធិការងាររបស់អង្គភាព។ បែបនេះមន្ត្រីគ្រប់រូប នឹងពុំមានកង្វល់ ពុំ ខ្វះចសតិអារម្មណ៍ គេរាល់គ្នានឹងមានមោទនភាពក្នុងការងារ ហើយស្វែងរកជាស្វ័យប្រវត្តិនូវការទទួលខុសត្រូវ។

ការងារគ្រប់គ្រងដឹកនាំអង្គភាព មាន ទំនាក់ទំនងជាពិសេសទៅនឹង សិក្សាស្វែងយល់ពីរបៀបអាចធ្វើការបានរលូន និងល្អជាមួយមន្ត្រី។ គ្រប់ កន្លែង និងគ្រប់ពេលយើងប្រឈមនឹងធ្វើការជាមួយមន្ត្រី។ លទ្ធផលនៃការ សិក្សាបង្ហាញថា ពិតជាពិបាកណាស់។ តែការងាររបៀបនេះមានគុណសម្បត្តិច្រើន និងជាពិសេស នៅក្នុងការសម្រេចបានលឿននូវគោលបំណង ការទទួល ខុសត្រូវ និងការរួមចំណែកដោះស្រាយបញ្ហា ការជួយ និងលើកទឹកចិត្តដល់ មន្ត្រីក្នុងកាលៈទេសៈលំបាក ហើយការងារក៏អាចដំណើរការបាន ទោះជាមាន ប្រឈមនឹងអវត្តមានមន្ត្រីសមាជិកក្រុម ឬអង្គភាពម្នាក់ ឬពីរនាក់ក៏ដោយ។

ការពង្រឹងឥរិយាបថធ្វើការងារជាក្រុម ដោយតម្រូវឱ្យមានការចូលរួម និងគាំទ្រពីគ្រប់ (ឬទាំងអស់) គ្នាជាមធ្យោបាយសំខាន់។ អ្នកគ្រប់គ្រងដឹកនាំ ត្រូវតែជំរុញការប្រកាន់យកនូវឥរិយាបថវិជ្ជមានក្នុងចំណោមមន្ត្រីរបស់ខ្លួន តាមរយៈ (ឬដោយ) ការតម្រូវឱ្យពួកគេះ

- យល់ពីគោលបំណងរួម
- ដឹងពីគោលបំណងរបស់ម្នាក់ៗ
- គោរពវិន័យ និងទទួលខុសត្រូវលើការងាររបស់ខ្លួន
- ប្តេជ្ញាធ្វើឱ្យសម្រេចគោលដៅរួម
- ស្វែងយល់ពីគ្នា និងចេះជួយគ្នា
- ជឿជាក់លើគ្នា
- មានចិត្តទូលាយ និងអធ្យាស្រ័យឱ្យគ្នា
- មានទំនាក់ទំនងល្អនឹងគ្នា
- ផ្លាស់ប្តូរព័ត៌មាន ចែករំលែក និងរៀនសូត្រពីគ្នា
- លើកទឹកចិត្តការបញ្ចេញយោបល់ និងធ្វើការសម្រេចចិត្ត
- ស្គាល់ពីតម្លាភាព និងគណនេយ្យភាព

ការរៀបចំ និងកែសម្រួលឥរិយាបថមន្ត្រីនៅជុំវិញខ្លួន មិនមែនជាការងារសាមញ្ញ និងងាយស្រួលទេ តែវាគឺចាំបាច់។ នៅសាលាភូមិន្ទរដ្ឋបាល ចាប់ ពីដើមឆ្នាំ២០១៥ មក គឺជាងពីរឆ្នាំហើយដែលយើងបានយកចិត្តទុកដាក់ធ្វើ រឿងនេះ។ ពិបាកណាស់ ការកែប្រែផ្នត់គំនិត និងឥរិយាបថរបស់មន្ត្រី។ ពិត ណាស់មន្ត្រី គឺមិនអីទេ គឺឥរិយាបថរបស់ពួកគេទេដែលមានបញ្ហា។ អ្នកដឹង ទេថាតើយើងខ្ញុំធ្វើដូចម្តេច និងធ្វើបែបណា?

យើងតាំងចិត្តជាប់ជានិច្ចថា នឹងមិនព្យាយាមចាប់កំហុសចំពោះមន្ត្រី ដែលប្រព្រឹត្តកំហុសណាមួយនោះទេ។ យើងជាដំបូងពិនិត្យមើលការពិត អត់ ធ្មត់មិននិយាយស្តី និងទុកឱកាសឱ្យអ្នកនោះ

មើលឃើញពីកំហុសដែលគាត់ បានប្រព្រឹត្ត និងធ្វើការកែប្រែវា។ តែមិនបានលទ្ធផលទេ។ ដើម្បីកែប្រែស្ថាន ភាព របៀបដោះស្រាយថ្មីត្រូវបានយកមកអនុវត្ត ឧទាហរណ៍ថាយើងស្នើឱ្យ បុគ្គលនិយាយត្រង់អំពីផលប៉ះពាល់នៃទង្វើខុសឆ្គង (កំហុស) .របស់គាត់ និង រួមចំណែកជាមួយគាត់ពិនិត្យមើលបញ្ហាផលប៉ះពាល់ និងវិធីដោះស្រាយ។ ពិតជាបានផលមែន។ ខ្ញុំតែងតែនិយាយជាមួយមន្ត្រីដែលប្រព្រឹត្តខុសថា សោក ស្តាយចំពោះអ្វីដែលបានកើតឡើង ឈប់មួយភ្លែតទុកពេលឱ្យពាក្យសម្តីនេះ ជ្រាបចូលក្នុងខ្លួនគាត់។ ខ្ញុំជឿ និងទុកចិត្តអ្នក ខ្ញុំយល់ថាអ្នកនឹងធ្វើរឿងនេះ បាន ហើយល្អប្រសើរផង។

លោក-អ្នកពិតជាឆ្ងល់ និងសួរខ្ញុំថា "ហេតុអ្វីចាំបាច់និយាយបែបនេះ | ជាមួយមន្ត្រីដែលធ្វើខុស (ប្រព្រឹត្តកំហុស) ?" ចម្លើយគឺ៖ រឿងនេះសំខាន់ ព្រោះ ថាយើងត្រូវតែឱ្យបុគ្គលនោះដើរចេញ ហើយគិតអំពីការកែតម្រូវឥរិយាបថ ជា ជាងគិតថា គាត់ត្រូវបានយកចិត្តទុកដាក់។ យើងត្រូវកម្ចាត់ចោលឥរិយាបថ ឬកែសម្រួលឥរិយាបថរបស់មន្ត្រី គឺមិនមែនកម្ចាត់មន្ត្រីទេ។ មន្ត្រី គឺមិនអីទេ គឺ ឥរិយាបថរបស់ពួកគេទេដែលមានបញ្ហា។

៧ ចំណុចមានប្រសិទ្ធភាពក្នុងការងារគ្រប់គ្រងដឹកនាំអង្គភាព គឺ៖

- បង្កើតជំនឿ និងការគោរពដើរតាម
- លះបង់ និងធ្វើដើម្បីសមូហភាព
- គ្មានអត្តចរិតមានៈ មិនទទួលគំនិត
- ប្រើប្រាស់មតិយោបល់ល្អដើម្បីអភិវឌ្ឍអង្គភាព
- ចេះស្តាប់ និងទទួលយកការរិះគន់យ )
- ឱ្យតម្លៃ និងលើកសរសើរមន្ត្រីជុំវិញខ្លួន
- បន្ថយការព្រោកប្រាជ្ញឥតប្រយោជន៍។

## ៧.៤.ការបង្កើនសមត្ថភាពជំនាញ

### ៧.៤.១.ការបង្កើនសមត្ថភាពជំនាញ

ការរៀបចំមន្ត្រីឱ្យមានជំនាញកាន់តែប្រសើរ មានទស្សនៈកាន់តែទូលំទូលាយ គឺជាមធ្យោបាយគន្លឹះសម្រាប់ការអភិវឌ្ឍ និងធ្វើឱ្យអង្គភាពរបស់អ្នក រីកចម្រើនពិតប្រាកដ។ មន្ត្រីដែលមានជំនាញ ប្រាជ្ញា និងមានភាពឆ្លាតវៃ នឹង បង្កើតប្រពៃណី សេវាល្អ គុណភាពខ្ពស់ និងកិត្តិស័ព្ទ។

គោលការណ៍ចម្បងក្នុងការជួយមន្ត្រីឱ្យមានជំនាញ និងសមត្ថភាព៖

- ជួយគេបង្កើនប្រាជ្ញា និងភាពវាងវៃ
- ធ្វើឱ្យគេបានដឹងពីរបៀបធ្វើការមានប្រសិទ្ធភាព។
- បង្វឹកពួកគេឱ្យចាប់អារម្មណ៍ចំពោះបញ្ហា
- ធ្វើឱ្យគេបានដឹងពីតម្រូវការបច្ចេកទេស។ ល។

### ក.ជួយមន្ត្រីបង្កើនប្រាជ្ញា ភាពម៉ឺងម៉ាត់ និងភាពវាងវៃ

ការបង្វឹករៀបចំមន្ត្រីឱ្យតាំងចិត្ត និងធ្វើការប្តេជ្ញាអភិវឌ្ឍខ្លួនឱ្យប្រសើរ ឡើងឥតឈប់ឈរ គឺជារឿងល្អពិសេស។ ទង្វើនេះ ជួយមន្ត្រីឱ្យរឹងមាំ និងមាន សន្តិសុខការងារ។ មន្ត្រី គួរទទួលបានការបង្វឹក និងជំរុញឱ្យត្រៀមខ្លួនជានិច្ច។

ទស្សនៈប្រសើរឡើងគ្រប់ពេល ត្រូវស្ថិតក្នុងទឹកចិត្តមន្ត្រីជាប់ជានិច្ច។ បែបនេះ វានឹងជួយមន្ត្រីទាំងនោះឱ្យបង្កើនបានថែមទៀតប្រាជ្ញា និងភាពវាងវៃ ផ្ទាល់ខ្លួនដែលចាំបាច់បំផុតដើម្បីប្រសិទ្ធភាព និងប្រសិទ្ធផលការងារ។

មន្ត្រីនឹងបង្កើតជំនាញធ្វើ ព្រមទាំងកាពវ័យឆ្លាតរបស់ខ្លួន ប្រសិនបើ ទទួលបានការលើកទឹកចិត្ត និងអនុញ្ញាតឱ្យចូលរួមពិគ្រោះយោបល់ ឬក៏ដៅ ស្រាយបញ្ហានានា។ ទង្វើនេះ គឺរុញមន្ត្រីឱ្យមានកម្លាំង ថាមពល និងឆន្ទៈរត់ ប្រណាំងប្រជែងដោយសន្សឹមៗ និងគ្មាននឿយណាយដើម្បីការទទួលស្គាល់។

មន្ត្រី ត្រូវទទួលបានការបង្វឹកបង្ហាត់ឱ្យនឹងនរ និងមានសេចក្តីអំណត់ អត់ធ្មត់។ ពិតណាស់ មន្ត្រីចង់បានអ្វីដែលពួកគេត្រូវការ ហើយពួកគេចង់បាន ភ្លាមៗតែម្តង។ ឥទ្ធិពលអវិជ្ជមាននៃភាពមិនអត់ធ្មត់បែបនេះ គឺជាការសម្រេច ចិត្តមិនល្អ។ ភាពអត់ធ្មត់ជួយមន្ត្រីឱ្យយល់ដឹងថាបើ ពួកគេធ្វើអ្វីដែលត្រឹមត្រូវ ទោះបីជាខាតបង់ពេលវេលា ឬខាតបង់នៅពេលខ្លីក៏ដោយ តែវានឹងផ្តល់ផល ល្អនៅក្នុងរយៈពេលវែងខាងមុខ។

សូមធ្វើឱ្យមន្ត្រីយល់ថា ការជឿនលឿន និងការចម្រើនឡើងនានានៅ ក្នុងប្រវត្តិសាស្ត្រមន្ត្រីលោក ដូចជាកំណែទម្រង់នយោបាយ និងសង្គមដ៏អស្ចារ្យ ផលិតកម្មសិល្បៈ ការច្នៃប្រឌិតគ្មានពីរ។ល។ មិនមែនបានមកពីការប្រញាប់ ប្រញាល់ឆ្លេឆ្លានោះទេ តែគឺបានមកពីភាពនឹងនរ។ វាតម្រូវឱ្យមានការគិតគូរ យ៉ាងហ្មត់ចត់ យ៉ាងជ្រាលជ្រៅ និងយ៉ាងត្រឹមត្រូវ។ ទាំងនេះ គឺជាមធ្យោបាយ តែមួយគត់ដែលមានប្រយោជន៍ក្នុងការសម្រេចរឿង។ មន្ត្រី ត្រូវតែបង្ខកង។ អារម្មណ៍ និងធ្វើរឿងនេះ។ មានន័យថា ចេះលៃលករកពេលវេលាស្ងប់ស្ងាត់ បំផុតសម្រាប់ការគិតគូរ ធ្វើការសិក្សា ស្រាវជ្រាវ ពិចារណា អានសរសេរ ឬក៏ធ្វើឱ្យចិត្តស្ងប់។ មន្ត្រី ត្រូវតែធ្វើរឿងនេះសម្រាប់ខ្លួនគាត់ សម្រាប់ការងារ និងសម្រាប់ក្រុម ឬអង្គភាព។

អ្នកគ្រប់គ្រងដឹកនាំ ត្រូវជំរុញធ្វើរឿងនេះ និងបើអាចគួរជ្រើសរើស ពេលវេលានាំមន្ត្រីរបស់ខ្លួនឱ្យធ្វើ ឧទាហរណ៍ថា ក្នុងចន្លោះម៉ោង ៨កន្លះ និង ម៉ោង ៩កន្លះព្រឹក ដាច់ខាតគឺមិនអនុញ្ញាតឱ្យមន្ត្រីណាម្នាក់និយាយទូរស័ព្ទ ឬ ជជែកគ្នាឡើយ ពួកគេត្រូវធ្វើឱ្យចិត្តស្ងប់ ធ្វើការគិតគូរ ពិចារណា អាន សរសេរ ពីអ្វីដែលបានរកឃើញក្នុងរបៀបធ្វើរឿងណាមួយ។

ការតម្រង់ទិស និងការបង្វឹកបង្ហាត់មន្ត្រីដើម្បីឱ្យគេបំពេញការងារមួយ បានល្អ គឺទាមទារការត្រួតពិនិត្យគ្រប់គ្រងពួកគេឱ្យបានច្រើននៅគ្រាដំបូង។ សូមកុំយល់ ឬក៏កុំប៉ាន់ស្មានថាមន្ត្រីជុំវិញអ្នកល្អប្រសើរ ឬក៏ពូកែឱ្យសោះ សូមកុំ អាលបន្ទូរដៃ និងមិនត្រូវបង្ហាញនូវការគោរពចំពោះសមត្ថភាពការងាររបស់ពួក គេឱ្យសោះ ពេលដែលលោក-អ្នកមិនទាន់បានឃើញពិតនឹងភ្នែក។

អ្នកគ្រប់គ្រងដឹកនាំត្រូវយល់ថា ការត្រួតពិនិត្យតិចតួចទៅលើមន្ត្រី និង បន្ទាប់មកទើបមើលឃើញថា ជំនាញរបស់ពួកគេមិនល្អដូចដែលសង្ឃឹមចង់ បាន គឺជាគ្រោះថ្នាក់ដែលនាំដល់ការដកខ្លួនមិនរួច។ នេះព្រោះថា ពេលធ្វើការ កែតម្រូវ ឬការតម្រង់ទិសដៅការងារ មន្ត្រីនឹងមានអារម្មណ៍ថាទទួលបានការ រិះគន់មិនសមស្រប រឿងកំប៉ិចកំប៉ុកសោះ ហេតុអ្វីចាំធ្វើទុក្ខបុកម្នេញ។ មន្ត្រីនិងមិនបានធ្វើអ្វីប្លែក ឬល្អប្រសើរទេ និងបង្កើតនូវការខឹងសម្បារផង។ សូមអក គ្រប់គ្រងដឹកនាំប្រកាន់ខ្ជាប់នូវឥរិយាបថ ការចាប់ផ្ដើមតឹងតែង និងក្រោយមក ល្អ ហើយលុបចោលការចាប់ផ្ដើមល្អ និងក្រោយមកតឹងតែង។

**ខ.ណែនាំមន្ត្រីពីរបៀបធ្វើការមានប្រសិទ្ធភាព,**

ការណែនាំ បង្វឹកបង្ហាត់មន្ត្រីឱ្យធ្វើការប្រកបដោយភាពវៃឆ្លាត គឺជា ទង្វើល្អរបស់អ្នកគ្រប់គ្រងដឹកនាំ។ មន្ត្រីអាចគិតថា ធ្វើការកាន់តែច្រើន គឺកាន់ តែជោគជ័យ។ ការកែប្រែគំនិត និងទម្លាប់នេះ គឺជាការងារបាច់។

អ្នកគ្រប់គ្រងដឹកនាំ ត្រូវរៀបចំមន្ត្រីជុំវិញខ្លួនឱ្យយល់ច្បាស់ និងដឹងថា មន្ត្រីជោគជ័យប្រឹងធ្វើការងារមែន តែពួកគេត្រូវគិតមុនពេលមានសកម្មភាព។ ពួកគេមិនគ្រាន់តែមានប្រតិកម្មទេ តែចេះច្នៃប្រឌិត។ ការមិនចំណាយពេលគិត បង្កើតយុទ្ធសាស្ត្រ និងអាទិភាព មន្ត្រីនឹងធ្វើការខ្លាំង និងពុំបានផលប្រយោជន៍ ពីការងារមួយនោះឡើយ។ មន្ត្រីជោគជ័យ ហ្នឹងធ្វើការនោះយ៉ាងឆ្លាតវៃ ហើយ ទទួលបានផលសមនឹងកម្លាំង ឬចង់បានរបស់គេ។

ក្នុងអំឡុងពេលច្រើនឆ្នាំនៃការបង្រៀន ខ្ញុំតែងតែលើកផែនការបង្រៀន សិស្ស និស្សិត នូវអ្វីដែលខ្ញុំយល់ថាមានសារសំខាន់បំផុតក្នុងជីវភាព និងការ កសាងអនាគតជាអ្នកគ្រប់គ្រងដឹកនាំ។ ខ្ញុំព្យាយាមដាស់ឱ្យពួកគេខិតខំបង។ ការហ្វឹកហាត់ធ្វើ (អនុវត្តរឿង) និងឱ្យពួកគេយល់អំពីសារៈសំខាន់នៃខ្លឹមសារមេរៀននីមួយៗ និងពេលប្រឡង គឺទទួលបានពិន្ទុល្អ។ ការផ្ដល់ពិន្ទុខ្ពស់ ខ្ញុំមិនចង្អៀតទេតែការយល់ដឹងពីសារៈសំខាន់នៃខ្លឹមសារមេរៀន និងការខំហាត់រៀន របស់សិស្ស និស្សិតទៅវិញទេដែលវាសំខាន់។

ការបំផុសស្មារតី និងបង្កើតចំណង់ចង់បានពិន្ទុខ្ពស់ក្នុងចំណោមពួក គេតាមរយៈការយល់ ការពិចារណា ការតាំងចិត្តខំហាត់រៀន និងស្គាល់ពីសារសំខាន់នៃមេរៀននីមួយ សម្រាប់ខ្ញុំគឺសំខាន់ណាស់។ ការធ្វើឱ្យពួកគេយល់ ដឹង និងច្បាស់សោយខ្លួនឯងថា ប្រសិទ្ធភាពការងារ មានទំនាក់ទំនងនឹង (១) ផែនការការងារ" ពេលគោលដៅ និងទិសដៅត្រូវបានកំណត់ (២) រុញវាទៅក្នុងការ អនុវត្តប្រចាំថ្ងៃ និង (៣) ការវាយតម្លៃការងារពេលវាត្រូវកំណត់ គឺសំខាន់។

ទង្វើទាំងអស់នេះ សរុបទៅ គឺដើម្បីរៀបចំមន្ត្រីឱ្យបោះជំហានត្រូវក្នុង ជីវិត និងការងារ ហើយសម្រេចបានផងបំណង ទទួលពិន្ទុខ្ពស់ផង។ ខ្ញុំធ្វើដូច្នេះ ចុះអ្នកវិញយល់បែបណា? អាចធ្វើរឿងនេះជាមួយមន្ត្រីរបស់ខ្លួនទេ?

ការជួយមន្ត្រីឱ្យរស់នៅ រៀន និងធ្វើការងារជាមួយចក្ខុវិស័យ គឺពិតជា រឿងពិសេសណាស់ ក្នុងវិធីរៀបចំមន្ត្រីឱ្យធ្វើការងារល្អ និងមានប្រសិទ្ធផល។ មន្ត្រីបច្ចុប្បន្នត្រូវតែមានចក្ខុវិស័យរឹងមាំ និងមាន

ជំនឿរីជ្ជមានសម្រាប់គាំទ្រ ចក្ខុវិស័យនោះ។ បើពុំដូចនេះទេ ពេលការលំបាកបង្ហាញឡើង គំនិតមន្ត្រី តាម មិនទាន់ទេ និងមិនអាចប្រឈមដោះស្រាយការលំបាកបានឡើយ។

ការជំរុញឱ្យមន្ត្រីទស្សនៈហ៊ានប្រឈមនឹងបញ្ហា ពិតជាមធ្យោបាយល្អ ដើម្បីប្រសិទ្ធភាពការងារ។ ពេលណាគេនិយាយ ពីពាក្យ "បញ្ហា" មានន័យថា គេកំពុងនិយាយតាមផ្លូវអវិជ្ជមាន។ មន្ត្រីមិនប្រាកដថា មើលឃើញបញ្ហាទេ។ មន្ត្រីជាញឹកញាប់គិតថា ជីវិតនឹងល្អប្រសើរបើគេជួបបញ្ហាកាន់តែតិច។ មិនដូ ច្នោះទេ មន្ត្រីកាលណាមានបញ្ហាកាន់តែច្រើន គឺអាចកាន់តែមានជីវិតរស់រវើក ឡើង។ មន្ត្រីមិនត្រឹមតែត្រូវហ៊ានប្រឈមនឹងបញ្ហាប៉ុណ្ណោះទេ តែត្រូវចាប់អារម្មណ៍ផងអំពីបញ្ហានៅជុំវិញខ្លួន។

## គ.បង្វឹកមន្ត្រីឱ្យចាប់អារម្មណ៍ចំពោះបញ្ហា

ការបង្វឹក និងការជំរុញមន្ត្រីនៅក្នុងអង្គភាពឱ្យចេះយល់ ដឹង និងចាប់ អារម្មណ៍ចំពោះអ្វីដែលមិនដំណើរការ និងចេះចាប់អារម្មណ៍ចំពោះបញ្ហានៅ ជុំវិញខ្លួន គឺជារឿងអាទិភាព។ នៅពេលកំហុសមួយកើតមាននៅក្នុងអង្គភាព តើនឹងមានសំណួរអ្វីលេចឡើង? តើមន្ត្រីទាំងឡាយ អាចនឹងរៀនសូត្រអ្វីខ្លះពី កំហុសនោះ? នរណាជាអ្នកខុស?

អ្នកគ្រប់គ្រងដឹកនាំ មិនត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍ចាស់គម្រូល ដោយលើកទឹកចិត្តមន្ត្រីឱ្យលាក់បាំងកំហុស និងបិទបាំងការខុសឆ្គងដាច់ខាត។ ការបណ្តែតបណ្តោយចំពោះរឿងនេះ នឹងនាំដល់ការបដិសេធ និងបណ្តាលឲ្យ មន្ត្រីមើលចេញឆ្ងាយពីកំហុសជាជាងសម្លឹងមើលវា។ មធ្យោបាយធ្វើរឿងដើរ គឺតម្រែតម្រង់មន្ត្រីធ្វើឱ្យ និងឱ្យយល់ ឱ្យចាត់ទុកកំហុសជាឱកាសសម្រាប់រៀនសូត្រ។ ការមិនដាក់ទណ្ឌកម្មអ្នករៀនសូត្រ នឹងធ្វើឱ្យមធ្យោបាយដ៏ល្អនេះ ចាក់ ចូលទៅក្នុងជម្រៅចិត្តរបស់មន្ត្រី។

ពិតណាស់ថាយើងខឹងខ្លាំងណាស់ ពេលឃើញមន្ត្រីធ្វើខុសចិត្ត ទោះ ក្នុងកាលៈទេសៈណាក៏ដោយ។ តាមដែលខឹង គឺនឹងពិន័យ ស្តីបន្ទោសឱ្យ ឬក៏ បណ្តេញចេញពីបន្ទប់ ឬបណ្តេញចេញពីអង្គភាពតែម្តងបើអាច។

សូមគិតថាធ្វើដូច្នេះនឹងបានការឬ?.ការដាក់ទណ្ឌកម្មទៅលើមន្ត្រីដែល ខ្វះជំនឿចិត្ត ឬក៏មិនទាន់ច្បាស់នៅឡើយចំពោះអ្វីដែលយើងដាក់ឱ្យគាត់ធ្វើ នឹងនាំដល់ការច្របូកច្របល់។

ខ្ញុំស្នើមធ្យោបាយមួយ គឺការតម្រង់ទិសឡើងវិញ។ នៅពេលមន្ត្រីណា ម្នាក់ធ្វើខុស ឬមានកំហុសចូរធ្វើឱ្យប្រាកដថា គាត់នោះដឹងភ្លាមៗថាឥរិយាបថ នេះមិនត្រឹមត្រូវទេ។ សូមលើកកំហុសមកដាក់លើខ្លួនអ្នក "សុំទោសខ្ញុំមិនបាន ប្រាប់ឱ្យច្បាស់ និងបន្ទាប់មកធ្វើការតម្រង់ទិស ណែនាំឡើងវិញយ៉ាងអត់ធ្មត់ ដោយពិនិត្យមើលជាថ្មីនូវការងារ។

បើសិនជាអាច ចូរបង្ហាញគំរូការងារដ៏ល្អមួយ។ បន្ទាប់មកសូមិសង្កេត វាយោបថថ្មីរបស់មន្ត្រីជាមួយក្តីសង្ឃឹម ឃើញគាត់ធ្វើការងារសឹងតែត្រឹមត្រូវ មែនទែន ហើយកុំភ្លេចការលើក (ឬស្ញើច) សរសើរឱ្យសោះ។

ការព្យាយាមបង្វឹកមន្ត្រីជុំវិញខ្លួនឱ្យក្លាហាន និងចេះមើលឃើញបញ្ហា ខាងមុខ ហើយត្រៀមរកវិធីដោះស្រាយ គឺជាការងារល្អបំផុត។ ការមើលឃើញ បញ្ហានៅខាងមុខ មានន័យថា បានឃើញថាដៃគូមានកម្លាំងខ្លាំងក្លាប់ណា ខ្លាំងត្រង់ណា? ហេតុអ្វី? បន្ទាប់មករៀបចំយុទ្ធសាស្ត្រដណ្តើមយកប្រៀប

ឈ្នះ។ បណ្តុះមន្ត្រីឱ្យមានស្មារតីបែបនេះ មានន័យថា បណ្តុះកម្លាំងដ៏ខ្លាំងក្លាសម្រាប់ បង្កើនគុណភាព និងគុណផលការងារ។

ការបណ្តុះស្មារតីមន្ត្រីឱ្យយល់ដឹង និងចាត់ទុកបញ្ហា ឬកំហុសថាជា ល្បែងបង្កើតប្រាជ្ញា មិនបាក់ស្បាត មិនខ្លាចបញ្ហា ឬកំហុស ព្រមទាំង ចាត់ទុក បញ្ហាជាទាសករ គឺជារឿងសំខាន់ និងមានប្រយោជន៍ដល់ភាពរឹងមាំរបស់ពួក គេ។ បញ្ហា ឬក៏កំហុស មិនសុទ្ធតែអាក្រក់នោះទេ ពេលខ្លះក៏ធ្វើឱ្យយើងទទួល បាននូវប្រាជ្ញា និងភាពឆ្លាតវាងវៃផងដែរ។ នៅក្នុងការងារដឹកនាំ បញ្ហាគួរចាត់ ជាមេរៀនក្នុងការទទួលបានប្រាជ្ញា និងចំណេះដឹងថ្មីដើម្បីដឹកនាំ។ បញ្ហា គឺជា មេរៀនដ៏ល្អដែលគួររៀនសូត្រ បើគ្មានបញ្ហា មន្ត្រីពិតណាស់ពិបាកនឹងស្គាល់ អត្ថន័យនៃពាក្យជោគជ័យណាស់។

ការខិតខំដោះស្រាយបញ្ហា មិនប្រាកដថាជោគជ័យរហូតដែរ តែក៏មិន ត្រូវបាក់ទឹកចិត្ត និងអង្គុយអោនក្បាលចុះនោះដែរ។ អ្វីដែលមន្ត្រីត្រូវធ្វើ គម។ មុខឡើង ពើងដើមទ្រូងដើរទៅមុខទៀតកុំបញ្ឈប់។ អ្នកដឹកនាំពិតប្រាកដ គឺជា មនុស្សដែល «ដួលកន្លែងណា ងើបឈរនៅកន្លែងហ្នឹង»។

**ឃ.ជួយមន្ត្រីឱ្យយល់ដឹងពីតម្រូវការបច្ចេកទេស,**

ទាក់ទងទៅនឹងការងារអង្គភាព មានចម្លើយតប ៣ គឺការឆ្លើយវិជ្ជមាន អវិជ្ជមាន និងគ្មានសោះ។ មានតែចម្លើយតបមួយទេក្នុងចំណោមនិន្នាការទាំង ៣នេះ ដែលបង្កើនការប្រតិបត្តិការងារល្អ នោះគឺការឆ្លើយតបវិជ្ជមាន។ មេដឹក នាំត្រូវតែប្រកាន់ចរិតមួយ គឺលើកឡើងពីអំពើដែលល្អ។

មន្ត្រីម្នាក់ដែលធ្វើអ្វីមួយត្រឹមត្រូវ និងទទួលការឆ្លើយតបវិជ្ជមានមុខជា នឹងបន្តចរិយាដ៏ល្អនោះទៀត។ ដូចគ្នាអីចឹងដែរ មន្ត្រីម្នាក់ដែលទទួលការឆ្លើយ តបអវិជ្ជមាន ចំពោះការធ្វើអ្វីមួយខុសមុខជាមិនប្រព្រឹត្តបែបនោះទៀតទេ។ តែ តើមានអ្វីកើតឡើង បើនរណាម្នាក់ធ្វើអ្វីមួយត្រឹមត្រូវ និងពុំមានការឆ្លើយតប ទាល់តែសោះ? ចម្លើយ គឺចរិយារបស់គាត់អាចបន្តមួយរយៈ ទីបំផុតវានឹងធ្លាក់ ចុះដោយសារគ្មាននរណាចាប់អារម្មណ៍ចំពោះការធ្វើល្អរបស់ខ្លួន។

អ្នកដឹកនាំភាគច្រើន កត់សម្គាល់ឃើញមន្ត្រីរបស់ខ្លួនធ្វើការត្រឹមត្រូវ ហើយគិតល្អអំពីពួកគេ។ ប៉ុណ្ណឹងមិនគ្រប់ទេ គឺគាត់ត្រូវនិយាយចេញនូវគំនិត វិជ្ជមាននោះ។ ធ្វើបែបនេះបានលទ្ធផលការងាររបស់មន្ត្រីនឹងរឹតតែល្អ។ សូម ដឹងថា មន្ត្រីរបស់យើង គឺពិតណាស់ចង់ឱ្យយើងកត់សម្គាល់ និងយកចិត្តទុក ដាក់អំពីអ្វីដែលគេធ្វើត្រូវធ្វើបានល្អ។ អ្នកស្រាវជ្រាវលោកខាងលិចជាប្រេង បានអះអាងថាគន្លឹះសម្រាប់ការអភិវឌ្ឍមន្ត្រី គឺត្រូវមើលឃើញពួកគេធ្វើត្រូវ។ ពិតមែន មេដឹកនាំដ៏ច្រើនមានទេពកោសល្យមើលឃើញមន្ត្រីធ្វើខុស (ចាប់កំហុស) ។ មិនបានទេ, មេដឹកនាំ មិនត្រូវធ្វើបែបនេះទេ គាត់គួរចំណាយពេ.វេលាខ្លះដើម្បីរកមើលមន្ត្រីធ្វើត្រូវ។

សំខាន់, រឿងនេះសំខាន់ ព្រោះថាការសរសើរមន្ត្រីនឹងមានប្រសិទ្ធភាព កាលណាវាមានលក្ខណៈច្បាស់លាស់ពោល គឺត្រូវសរសើរឱ្យចំគោលដៅ និងលើក ទឹកចិត្តមន្ត្រីធ្វើត្រូវ ឱ្យខំបន្តការងារល្អតទៀត។

ជារឿងពិតណាស់ដែលថា មន្ត្រីផ្តល់លទ្ធផលការងារល្អ មានអារម្មណ៍ ល្អចំពោះខ្លួនឯង។ យើងខ្ញុំ គឺបែបហ្នឹង រីករាយណាស់នៅពេលបានធ្វើការដ៏ល្អ ឬបានធ្វើរឿងល្អសម្រាប់អង្គភាព និង

សម្រាប់មេរបស់ខ្លួន។ មិនត្រឹមតែប៉ុណ្ណឹង ទេជារៀងរាល់ថ្ងៃយើង តែងបានផ្តោតអាទិភាពលើការជួយមន្ត្រីឱ្យផ្តល់លទ្ធផលការងារល្អ។

វាអស្ចារ្យណាស់ វាពិសេសណាស់ ប្រសិនបើ មន្ត្រីរបស់យើង អាចធ្វើ ការងារជំនួសយើង និងធ្វើបានលទ្ធផលល្អគ្រប់ពេល។

យើងនឹងមានអារម្មណ៍ល្អ ពេលមន្ត្រីរបស់យើងផ្តល់លទ្ធផលការងារ ល្អ។ មន្ត្រីក្រោយបានដឹងថាខ្លួនបានធ្វើការងារល្អមួយហើយ (ឬថាកិច្ចខំប្រឹង ប្រែងរបស់ពួកគេបានផលខ្ពង់ខ្ពស់ហើយ) គឺពិតជាមានអារម្មណ៍ល្អបំផុត។ ការ ជួយមន្ត្រី ១) ឱ្យដឹងអំពីអ្វីជាគោលបំណងរបស់ពួកគេ និង (២) ធ្វើគ្រប់យ៉ាង ដើម្បីគាំទ្រ លើកទឹកចិត្ត និងបង្ហាត់បង្រៀនពួកគេសម្រេចបំណងទាំងនោះ គឺ ជាមធ្យោបាយអស្ចារ្យបំផុត។ អាចជួយឱ្យមន្ត្រីទទួលជោគជ័យបានក្នុងការងារ អាជីព, មានន័យថា អ្នកគ្រប់គ្រងដឹកនាំបានជួយផ្តល់ពន្លឺជីវិតសម្រាប់មន្ត្រី។ វានេះ គឺជាការងារដែលមានន័យបំផុត។

បែបនេះហើយបានជាស្នាដៃនេះ ត្រូវបានតស៊ូ ប្រឹងប្រែងផលិតចេញ ដែលធ្វើឱ្យយើងខ្ញុំបាត់បង់ពេលទំនេរសម្រាប់ការកម្សាន្ត , សម្រាប់ជីវិតខ្លួនឯង និងសម្រាប់គ្រួសារ។ យើងពិតជាចង់ឱ្យកូនខ្មែរចេះក្បួនទាំង ៥ សម្រាប់ការ គ្រប់គ្រងដឹកនាំអង្គភាពនេះ។ យើងមោទនភាពជាទីបំផុតប្រសិនបើស្នាដៃនេះ ត្រូវបានគាំទ្រ និងកូនខ្មែរយល់ថារឿងទាំងនេះ គឺសំខាន់សម្រាប់ពួកគេ ពួកគេ ខំរៀន និងបានប្រើប្រាស់គន្លឹះទាំង ៥ នេះ ក្នុងការងារអាជីពរបស់ខ្លួន និងក្នុង ការកសាងជីវភាពប្រចាំថ្ងៃ។

រឿងសំខាន់មួយទៀត និងជារឿងដែលថាចាំបាច់ គឺត្រូវឱ្យមន្ត្រីយល់ ច្បាស់ និងដឹងថាត្រូវធ្វើដំណើរទៅទីណា? សូមជ្រោមជ្រែងឱ្យពួកគេសម្គាល់ សកកម្មរបស់ខ្លួន និងជំរុញឱ្យមន្ត្រី បង្កើតសេចក្តីថ្លែងការណ៍អំពីបេសកកម្មផ្ទាល់ខ្លួនរបស់គេផង។ ទង្វើនេះ ជួយពួកគាត់កំណត់ថាតើខ្លួនគាត់ជានអាទិភាពរបស់គាត់គឺអ្វី?

ការផ្តល់ប្រតិកម្មវាយតម្លៃលទ្ធផលការងារដ៏ត្រឹមត្រូវ គឺជាយុទ្ធសាស្ត្រ មានប្រសិទ្ធភាពបំផុតដើម្បីលើកកម្ពស់ការងារ និងបណ្តុះការពេញចិត្តនៃមន្ត្រី ក្រោមឱវាទ។ អ្នកគ្រប់គ្រងដឹកនាំអាចធ្វើបានភ្លាមៗ និងមិនចំណាយអ្វីទេ ហើយអាចធ្វើឱ្យមន្ត្រីក្រោមបង្គាប់ សម្រេចការងារបានយ៉ាងឆាប់រហ័សផង។ ក្នុងនាមជាអ្នកគ្រប់គ្រងដឹកនាំ ការមានប្រតិកម្មត្រឹមត្រូវចំពោះការងាររបស់ មន្ត្រីមុនកាត់សេចក្តីថា គួរសរសើរ ឬក៏រិះគន់ គឺមានសារៈសំខាន់ណាស់។

ប្រតិកម្មជាមតិថាល្អឬអាក្រក់មានសារៈសំខាន់ជាខ្លាំងចំពោះមន្ត្រី។ មន្ត្រីទាំងអស់ចង់ដឹងថាគេធ្វើល្អដល់កម្រិតណា។ បែបនេះ ការរៀបចំឱ្យមាន ប្រព័ន្ធត្រួតពិនិត្យការប្រតិបត្តិដ៏មានប្រសិទ្ធភាពមួយ ដើម្បីផ្តល់នូវប្រតិកម្មវាយ តម្លៃអំពីការងារ ពិតជាសំខាន់ និងចាំបាច់។

ការសន្សំព័ត៌មានអវិជ្ជមាន និងបញ្ចេញវាដោយសារឧប្បត្តិហេតុក៏ប៉ុចកំប៉ុក គឺជារឿងមិនល្អ។ អ្នកខ្លះត្រូវបានចាប់កំហុស អ្នកខ្លះមិន អ្នកខ្លះធ្វើអន្ទ ទៅ គឺអ្នកគ្រប់គ្រងដឹកនាំ បិទភ្នែកធ្វើមិនឃើញ គឺជាគ្រោះថ្នាក់ក្នុងរបៀប គ្រងដឹកនាំអង្គភាព។ សូមដឹងថា មន្ត្រីដែលត្រូវបានរិះគន់ វាយប្រហារ ឬ ត្រូវបានអ្នកគ្រប់គ្រងដឹកនាំ (មេដឹកនាំ) ដោះស្រាយឱ្យដោយយុត្តិធម៌នឹងបាត់បង់ការគោរពចំពោះមេកើយ ចំពោះក្រុម ឬអង្គភាព និងទីបំផុតនឹងបាត់បង់មោទនភាពភាពការងាររបស់ពួកគេ។

## ៧.៥.ការបង្កើតជំនឿចំពោះអង្គភាព

មន្ត្រីអាចនឹងធ្វើការបានល្អប្រសិនបើពួកគេមិនមានអារម្មណ៍ភ័យ ខ្លាច ឬខូចចិត្ត។ ការធ្វើ និង រៀបចំបរិយាកាសនៅកន្លែងធ្វើការបានល្អ ជួយធ្វើ ឱ្យមន្ត្រីទាំងអស់ មានអារម្មណ៍កាន់តែមានទំនុកចិត្ត និងមានសុវត្ថិភាព។ បែប នេះ ពួកគេកាន់តែមានការពិចារណា និងមានការច្នៃប្រឌិតខ្ពស់ក្នុងការធ្វើឱ្យ សម្រេចគោលដៅរបស់អង្គភាព ហើយបំពេញការងារអស់ពីសមត្ថភាព។

ការមិនស្តីបន្ទោស ការមិនរិះគន់ និងការផ្តោតទៅលើអ្វីដែលអាចធ្វើ ទៅបានដើម្បីជួយឱ្យមន្ត្រី រៀននូវមេរៀនមានតម្លៃ ឬរៀននូវអ្វីដែលមានក្នុងបទ ពិសោធន៍របស់មេដឹកនាំ គឺជាមធ្យោបាយជួយឱ្យ ពួកគេដុះដាលនូវជំនាញ និង ឧត្តមគតិមិនគេសកំហុស។ មធ្យោបាយដ៏ល្អដើម្បីជួយមន្ត្រី ឱ្យធ្វើការ បានល្អ និងមិនមានកំហុសច្រើន គឺ៖

- ពន្យល់យ៉ាងច្បាស់ពីអ្វីដែលមន្ត្រីត្រូវធ្វើ
- មានបទដ្ឋានអនុវត្តការងារនោះ និងដែលអាចវាស់វែងបាន
- ឱ្យមន្ត្រីបញ្ជាក់មកវិញថាយល់ និងដឹងថាត្រូវធ្វើអ្វី
- ផ្តល់ការពិនិត្យកែតម្រូវអំពីការងារយ៉ាងទៀងទាត់។

មនុស្សពិតណាស់ ចូលចិត្តមានអារម្មណ៍អំពីការបំពេញមុខងារ ច ចិត្តនូវអារម្មណ៍ជោគជ័យ ចូលចិត្តជាពិសេសនូវការកែតម្រូវជាវិជ្ជមាន និងការ ទទួលស្គាល់នូវអ្វីដែលគេធ្វើបានល្អ។ ការយល់ ច្រឡំ ការប្រព្រឹត្តខ្វះចនោះ បញ្ហាបុគ្គលិកលក្ខណៈអាចនឹងកើតឡើងគ្រប់ពេល និងមិនមែនជាកំហ របស់មន្ត្រីនោះទេ។ កង្វះការដឹងប្រាកដអំពីអ្វីដែលមេដឹកនាំចង់បាន និងកង្វះ ការពិនិត្យកែតម្រូវ គឺជា ប្រភពនៃការមិនពេញចិត្ត។

រឿងដែលល្អបំផុត គឺមេដឹកនាំអាចធ្វើឱ្យមន្ត្រីយល់ថាគាត់គឺជាមនុស្ស ដែលយកចិត្តទុកដាក់ អំពីពួកគេ និងតែងតែបន្ទរដៃឱ្យពួកគេក្នុងការស្វែងរក ភាពល្អប្រសើរ។ វារឹតតែប្រសើរទៅទៀត ប្រសិនបើ មន្ត្រីបានប្រៀបប្រដូចមេដឹកនាំថាដូចឪពុកម្តាយ គ្រូបង្រៀន គ្រូបង្ហាត់ដែលមានភាពតឹង តែង តែចិត្តល្អ ហើយមិនធ្វើបាប និងមិនបំផ្លាញកូនចៅ។

បែបនេះការទាមទារ និងសុំការយល់ព្រមពីមន្ត្រីសំដៅឱ្យពួកគេបន្ថែម តម្លៃឱ្យអង្គភាពតាមរ យៈការងារ និងការថែរក្សាស្តង់ដាកោរងារឱ្យនៅខ្ពស់ គឺ មានប្រយោជន៍។ ការលះបង់ប្រជាប្រិយភាព ក្នុងកិច្ចប្រឹងប្រែង និងព្យាយាម ធ្វើអ្វីដែលល្អ ដែលត្រឹមត្រូវ នឹងរឹតតែវិសេសវិសាលទៅទៀត។

ការបង្កើតជំនឿ និងការទុកចិត្តរបស់មន្ត្រីចំពោះអង្គភាព អាចត្រូវបាង ជំរុញបន្ថែមតាមរយៈ៖

- ក្របខណ្ឌល្អនៃការទំនាក់ទំនង
- ការអនុវត្តបានល្អការលើកទឹកចិត្ត
- ការប្រកាន់ឥរិយាបទអនុគ្រោះ
- ការស្គាល់ និងយល់ពីតម្លៃរបស់មន្ត្រី។

ការបង្កលក្ខណៈឱ្យមន្ត្រីអាចធ្វើទំនាក់ទំនងបានស្រួល និងមិនស្មុគ្រ ស្មាញ គឺជារឿងសំខាន់។ វាល្អប្រសើរណាស់ ប្រសិនបើ មនុស្សដែលធ្វើការ ជាមួយគ្នាក្នុងអង្គភាពមួយ ចេះលើកទឹកចិត្តគ្នាទៅ វិញទៅមក និងហាក់ដូចជា កំពុងតែថែចង់គ្នាទៅវិញទៅមក ពេលជួបគ្នាពួកគេមានក្តីរីករាយ។ ពួកគេ

ប្ដេជ្ញាចិត្តធ្វើអ្វីគ្រប់យ៉ាង ដើម្បីបង្ហាញការគោរព និងការវាយតម្លៃលើកសរសើរ គ្នាដោយឥតលក្ខខណ្ឌ និងដាក់ចិត្តថាជាមិត្តរួមការងារដ៏ល្អ។

ការជំរុញការងារជាទស្សនាទានលំបាកមួយសម្រាប់ពេលបច្ចុប្បន្ន។ លុយ រង្វាន់ ឬក៏វិស្សមកាលពិសេស មិនមែនជាកម្លាំងជំរុញការងារយ៉ាងមាន ប្រសិទ្ធភាពនោះទេ។ ពិតណាស់ថា អ្វីដែលលើកទឹកចិត្តមន្ត្រីម្នាក់ឱ្យធ្វើការងារ ប្រហែលជាមិនលើកទឹកចិត្តមន្ត្រីផ្សេងទៀតឱ្យប្រឹងធ្វើការងារទេ។

ឧបមាថាអ្នកចង់ផ្ដល់រង្វាន់ដល់មនុស្ស២នាក់ ម្នាក់ដោយការតម្លើង ប្រាក់បៀវត្សរ៍ ម្នាក់ទៀត គឺបន្ថែមការទទួលខុសត្រូវ តែអ្វីៗប្រហែលជាត្រូវផ្ទុយ ពីសេចក្ដីសម្រេចនេះទៅវិញ។ បែបនេះ គឺត្រូវពិចារណាមុននឹងធ្វើ។

ធ្វើដូចម្ដេចទើបដឹងបានថា តើការជំរុញប្រភេទណាមានប្រសិទ្ធភាព ជាមួយមន្ត្រី? ត្រូវតែសួរពួកគេ, គិត និងប្រើសិល្បៈ លើកសំណួរ ឧទាក ថារង្វាន់ប្រភេទណា? ដែលចង់បានដើម្បីបន្តប្រសិទ្ធភាពការងារ៉។

សេចក្ដីត្រូវការរបស់មនុស្សម្នាក់ៗមិនដូចគ្នាទេ។ ភាពខុសគ្នានៃសេចក្ដី ត្រូវការរបស់មនុស្សម្នាក់ៗ គឺអាស្រ័យលើឋានានុក្រមនៃតម្រូវការរបស់ពួកគេ។ ការយល់ដឹងពីសេចក្ដីត្រូវការរបស់មនុស្សបានច្បាស់អាចជួយមេដឹកនាំឱ្យធ្វើ ការលើកទឹកចិត្តដល់មន្ត្រីបានសមស្រប និងមានប្រសិទ្ធភាព។

មធ្យោបាយល្អក្នុងការធ្វើរឿងនេះ មាន

- ការចាត់ចែងគ្រប់គ្រងអង្គភាពល្អ និងដឹកនាំប្រព្រឹត្តទៅប្រកបដោយ ឥរិយាបថ និងអាកប្បកិរិយាល្អ
- បរិយាកាសការងារក្នុងអង្គភាពល្អ និងគាំទ្រដល់ការងារអនុវត្តរបស់ មន្ត្រី ដូចជា គោលនយោបាយអភិវឌ្ឍបុគ្គលិកល្អ តម្លាភាពនៃច្បាប់ ការងារ និងប្រព័ន្ធគ្រប់គ្រងគួរជឿទុកចិត្ត។

ការធ្វើឱ្យមន្ត្រីយល់ថាខ្លួនមានតម្លៃនៅក្នុងអង្គភាព និងនៅក្នុងក្រសែរ ភ្នែករបស់មេដឹកនាំ ពិតជាសំខាន់។ តាមទស្សនៈជាច្រើនមធ្យោបាយ។ ជួយក្នុងការធ្វើរឿងនេះ គឺមាន

- គិតពីផលប្រយោជន៍មន្ត្រី
- បង្កើតបរិយាកាសការងារជឿជាក់ និងការសហការល្អ
- ធ្វើឱ្យមន្ត្រីយល់ពីភាពសំខាន់របស់ពួកគេក្នុងការងារអង្គភាព
- ធ្វើឱ្យមន្ត្រីយល់ពីមុខងារ និងតួនាទីរបស់ពួកគេ
- ផ្ដល់ឱកាសឱ្យមន្ត្រីធ្វើការអភិវឌ្ឍសមត្ថភាព
- ផ្ដល់ឱកាសទំនាក់ទំនងក្នុង-ក្រៅអង្គភាព
- ជំរុញចែករំលែកចំណេះ និងបទពិសោធន៍ឱ្យគ្នា។
- រាយការណ៍ពីភាពរីកចម្រើនដល់ក្រុម
- លើកសរសើរ ផ្ដល់រង្វាន់ និងលើកទឹកចិត្ត។

វិធី ៥យ៉ាងជួយធ្វើឱ្យមន្ត្រីមានអារម្មណ៍ថាគេជាមនុស្សសំខាន់៖

- ទទួលស្គាល់
- ដឹងគុណ

- យល់ព្រម
- កោតសរសើរ
- យកចិត្តទុកដាក់។

### ៧.៥.១.ការទទួលស្គាល់,

រង្វាន់ដ៏វិសេសវិសាលដែលគួរប្រគល់ឱ្យមន្ត្រីគឺ *ទស្សនៈក្នុងផ្លូវល្អ ដោយគ្មានលក្ខខណ្ឌ មានន័យថា មេដឹកនាំ មិនធ្វើការវិភាគ មិនទិតៀនរិះគន់ ឬមិនព្យាយាមចាប់កំហុស *ទទួលស្គាល់" ពីអ្វីៗដែលទាក់ទងនឹងពួកគេ។ ទទួលស្គាល់សម្ដែងដោយការញញឹម"។ ពេលមេដឹកនាំញញឹមប្រកបដោយក្ដីសុខពេលជួបមន្ត្រី ការរីករាយរបស់មន្ត្រីកើតឡើងដោយស្វ័យប្រវត្តិ គាត់ នឹងមានអារម្មណ៍ល្អចំពោះខ្លួនឯង និងយល់ថាខ្លួនសំខាន់។

### ៧.៥.២.ការដឹងគុណ

ពេលដែលមេដឹកនាំសម្ដែងការដឹងគុណចំពោះអ្វីដែលមន្ត្រីធ្វើ ទោះ តិចក្ដី ឬច្រើនក្ដី មន្ត្រីនឹងកើតមានមោទនភាពចំពោះខ្លួនឯង មានអារម្មណ៍ថា ខ្លួនគឺជាមនុស្សគ្រាន់បើម្នាក់ ជាមនុស្សសំខាន់ម្នាក់ ជាមនុស្សមានសមត្ថភាព ធ្វើអ្វីៗបានកាន់តែច្រើន។ គេមើលឃើញក្រាភិចរបស់ខ្លួន កាន់តែល្អប្រសើរជាង មុន ការគោរពចំពោះខ្លួនឯង ក៏កាន់តែខ្ពស់ទៅៗផងដែរ។

ការបណ្ដុះនិស្ស័យបង្ហើបមាត់ និងនិយាយថា "អរគុណ .នៅគ្រប់ ឱកាសមិនថាជារឿងតូច ឬរឿងធំ ពិតជាវិសេសវិសាលណាស់។ ស្នាមញញឹម ជាមួយនឹងពាក្យថា អរគុណ ធ្វើឱ្យមនុស្សពេញចិត្តនឹងខ្លួនឯង ព្រោះគាត់បាន ធ្វើឱ្យអ្នកដទៃសប្បាយចិត្ត។ បើមនុស្សកាន់តែពេញចិត្តនឹងខ្លួនឯង គាត់ក៏កាន តែចូលចិត្តអ្នកដទៃដោយសុទ្ធចិត្តផងដែរ។ បានធ្វើរឿងនេះហើយ បានបង្ហាញ ស្នាមញញឹម និងបានប្រើពាក្យថា អរគុណទៅកាន់មនុស្សជុំវិញដោយសុខ ចិត្ត) មានន័យថា លោក-អ្នកបានធ្វើរឿងល្អរួចហើយ សូមកុំខលទៅ ថាខ្លួនមិនបានធ្វើអ្វីល្អៗចំពោះ (ឬជាមួយ) អ្នកដទៃ។

### ៧.៥.៣. ការយល់ព្រម

ក្នុងជម្រៅចិត្តរបស់មន្ត្រីគ្រប់ៗរូប គឺត្រូវការ "ការយល់ព្រម។ ចំពោះទង្វើផ្សេងៗ ព្រមទាំងការសម្រេចជោគជ័យផង។ សេចក្ដីត្រូវការអំពី "ការយល់ ព្រម" នេះមិនចេះគ្រប់គ្រាន់ឡើយ។ គេត្រូវការជារៀងរហូតតទៅប្រៀបដូចជា មនុស្សដែលត្រូវការបរិភោគ និងត្រូវការសម្រាកដូច្នោះដែរ។ អ្នកដែលស្វែងរក ឱកាសបង្ហាញ "ការយល់ព្រម" ចំពោះអ្នកដទៃ គឺជាអ្នកដែលត្រូវបានទទួល ការស្វាគមន៍នៅគ្រប់ទិសទីដែលគាត់ទៅដល់។

ទង្វើដ៏សមរម្យក្នុងការបង្ហាញពីការយល់ព្រមគឺ "ការសរសើរ។ ពេល លោក-អ្នកសរសើរមន្ត្រីម្នាក់អំពីអ្វីដែលគេបានធ្វើ , មន្ត្រីនោះនឹងមានអារម្មណ៍ ល្អចំពោះខ្លួនគេ ហើយគេក៏ចាប់អារម្មណ៍លើលោក-អ្នកវិញដែរថាជាមនុស្ស ចេះផ្ដល់កិត្តិយសដល់គេ គឺជា "មនុស្សមានស្នេហ៍" ដ៏ពិតប្រាកដ។

### ៧.៥.៣.ការកោតសរសើរ,

មនុស្សគ្រប់រូបចូលចិត្តការកោតសរសើរ"។ ពេលពោលពាក្យសរសើរ មន្ត្រីម្នាក់ដោយសុទ្ធចិត្ត ទាក់ទងនឹងទង្វើផ្សេងៗ របស់បេរប្រើប្រាស់ ឬពីជោគ ជ័យរបស់ពួកគេ ពួកគេនឹងមានអារម្មណ៍ល្អ ព្រោះនេះជាការទទួលស្គាល់ ជាការទទួលដឹងឮអំពីសារៈសំខាន់ដែលគេធ្វើបាន។ ចូរលើកសរសើរពីស ម្លៀក បំពាក់ពីការគោរពពេលវេលា ពីការតស៊ូព្យាយាម ពីការទទួលជោគជ័យក្នុង រឿងកំប៉ិចកំប៉ុក រឿងធំដុំ...ចូររកពាក្យសរសើរគ្រប់ពេលដែលលោក-អ្នកបានជួបពួកគេ។ អ្នកទាំងនោះ មុខជាចូលចិត្ត លោក-អ្នក ហើយចាត់ទុកថា "អ្នកជា មនុស្សមានស្នេហ៍"។

### ៧.៥.៤.ការយកចិត្តទុកដាក់

វិធីនេះអាចជាវិធីដ៏សំខាន់ជាងគេ ជាវិធីដែលផ្តល់ថាមពលខ្លាំងបំផុត ដើម្បីឱ្យមន្ត្រីគោរពខ្លួន ឯង និងជាតិចនិចដ៏ល្អ ក្នុងការបង្កើនស្នេហ៍មុខរបស់ អ្នកគ្រប់គ្រងដឹកនាំ។ ពេលយកចិត្តទុកដាក់ ចំពោះមន្ត្រីម្នាក់ បុគ្គលនោះនឹង មានអារម្មណ៍ថាខ្លួនជាមនុស្សសំខាន់ និងគេក៏ចូលចិត្តមកលើរូបអ្នក គ្រប់គ្រង ដឹកនាំវិញកាន់តែខ្លាំងផងដែរ។ ការយកចិត្តទុកដាក់ទៅលើមន្ត្រី ជាឧបករណ៍ មានអានុភាព បំផុតក្នុងការផ្តល់កម្លាំងចិត្ត។ ការហ្វឹកហាត់ធ្វើរឿងនេះឱ្យស្ទាត់ ជំនាញ គឺជួយមេដឹកនាំឱ្យក្លាយជា បុគ្គលមានស្នេហ៍ មានឥទ្ធិពលក្នុងសង្គម និងក្នុងជីវភាពការងាររបស់ខ្លួន។

ការប្រកាន់ឥរិយាបទអនុគ្រោះ គឺជាទង្វើមួយដែលមេដឹកនាំត្រូវអនុវត្ត រាល់ថ្ងៃ រាល់ម៉ោង និង គ្រប់ពេល។ គ្មាននរណាម្នាក់ ក្នុងចំណោមមន្ត្រីចង់ ទទួលយកការរិះគន់ ឬស្តីបន្ទោសទេ។ ការរិះគន់ ឬស្តីបន្ទោសទោះជាក្នុងចេតនាស្ថាបនាក៏ដោយ អាចធ្វើឱ្យមន្ត្រីឈឺចាប់ និងខូចអារម្មណ៍។ ពួកគេមិន យល ថាការរិះគន់ គឺមិនមែនធ្វើដើម្បីសម្លាប់ បំផ្លាញ ឬដោយការស្អប់ទេ។ ការ រិះគន់ អាចត្រូវបានធ្វើ សំដៅកែប្រែកំហុសឆ្គងទាំងឡាយ និងការមិនមានបំណង ឱ្យរឿងរ៉ាវដែលកើតមានដោយការធ្វេស ប្រហែស ឬដោយការមិនមានស្មារតីទទួលខុសត្រូវ។ ចិត្តសាស្ត្រមនុស្ស គឺយ៉ាងនេះ គឺមិនទទួលយក ការរិះគន់ និង ការស្តីបន្ទោសទេ តែពេញចិត្តនឹងការបញ្ជោរ ឬការលើកសរសើរ។

មេដឹកនាំ ត្រូវតែប្រុងប្រយ័ត្នចំពោះការរិះគន់។ ក្នុងករណីថាមានតម្រូវ ការចាំបាច់ គឺគួរធ្វើ។ តែត្រូវរិះគន់ក្នុងន័យស្ថាបនា មានន័យថា រិះគន់ ឬស្តី បន្ទោសដែលធ្វើទៅជាមួយនឹងការព្យាយាម ប្រាប់ពីការកែតម្រូវកំហុសនានា (ហៅថា ការរិះគន់ដោយស្ថាបនា និងមានប្រយោជន៍) ។ ការរិះគន់ ជាមួយនឹង ការប្រាប់ថា រឿងនេះធ្វើដូច្នេះវិញទើបបានផល ប៉ះដល់អារម្មណ៍ខ្លះមែន តែ មានប្រយោជ ន៍។ ពិតណាស់ ការរិះគន់គួរជំនួសដោយការផ្តល់មតិឱ្យមានការ ផ្លាស់ប្តូរ ឬការអភិវឌ្ឍដែលអាចនឹង សន្សំវេលា កម្លាំងពលកម្ម សម្ភារ ឬការ ចំណាយផ្សេងៗ។

ទង្វើនេះក៏ជួយបង្កាត់មន្ត្រីឱ្យទទួលយកគំនិតរិះគន់ស្ថាបនា ឱ្យស្មោះ ត្រង់ និងឱ្យក្លាហានក្នុង ការបង្ហាញនូវកំហុស (មិនបិទបាំងកំហុសឆ្គង) ដែល គេបានប្រព្រឹត្តផងដែរ។

ការជំរុញរៀបចំមន្ត្រីឱ្យប្រព្រឹត្តស្មោះត្រង់ជាបញ្ហាអាទិភាព និងចំពោះមុខ។ ក្នុងសង្គមខ្មែរ បច្ចុប្បន្ន បរិយាកាសសម្ភារនិយមកំពុងត្រូវបានចាប់អារម្មណ៍ និងលើកតម្លៃឱ្យខ្ពស់។ មន្ត្រីជាច្រើន អាចបោះបង់ចោលការពិចារណា ខាងសីលធម៌ និងមិនខ្វល់ពីអ្វីទាំងអស់។ គេធ្វើសព្វបែបយ៉ាងឱ្យតែ

មានតម្រូវការសង្គម។ ទង្វើនេះ អាចបង្កគ្រោះថ្នាក់ខ្លាំង ព្រោះជាបឋមម ចំពោះការបាត់បង់ការគោរពតម្លៃខ្លួនឯង និងបាត់បង់ដៃគូ។

សេចក្តីសុចរិត គឺជាមធ្យោបាយទាញយកជំនឿ និងទំនុកចិត្ត។ តនៃ ផ្ទាល់ខ្លួន (ការដឹងនូវអ្វីដែលខុស និងអ្វីដែលត្រូវ) ជាគោលការណ៍មួយសំខាន់ របស់មន្ត្រី។ ប្រសិនបើ តម្លៃផ្ទាល់ខ្លួនមិនរឹងមាំ មិនខ្ពស់ មិនគួរឱ្យគោរព មនុស្ស នឹងមានអារម្មណ៍ថាខ្លួនគ្មានតម្លៃ ហើយវានឹងបំផ្លាញនូវភាពជឿជាក់ និងការ ឱ្យតម្លៃលើខ្លួនគាត់។

មន្ត្រីគួរជំរុញឱ្យអំណាត់អត់ធ្មត់ និងចេះជ្រើសរើសនូវតម្លៃណាដែល ត្រឹមត្រូវ និងពិតប្រាកដ ហើយទាញវាឱ្យជាប់នៅនឹងខ្លួនគាត់។ នៅរយៈពេលដ៏ វែងមួយ តម្លៃដ៏ត្រឹមត្រូវទាំងនេះនឹងផ្តល់ឱ្យគាត់នូវភាពខ្លាំងទាំងផ្នែកផ្ទាល់ខ្លួន និងផ្នែកការងារ។ បទពិសោធន៍ក្នុងការងារប្រាប់ថាភាពស្មោះត្រង់ និងសេចក្តី សុចរិត គឺជាគន្លឹះនាំមនុស្សទៅទទួលបានជោគជ័យធំ។

ភាពស្មោះត្រង់ និងសេចក្តីសុចរិត ជារបស់មានតម្លៃដ៏សំខាន់បំផុត សម្រាប់មនុស្សរាល់គ្នា។ វាផ្តល់នូវផ្លូវមួយដែលជួយមនុស្សឱ្យធ្វើដំណើរឆ្ពោះ ទៅទទួលបានភាពជោគជ័យ។ ជីវិតមួយដែលរស់នៅដោយភាពស្មោះត្រង គឺជាជីវិតមួយដែលរស់នៅដោយពុំមានការភ័យខ្លាច ព្រោះអ្វីដែលមនុស្ស គឺជាការត្រឹមត្រូវ។ របស់មានតម្លៃគ្រប់យ៉ាងពេលបាត់បង់ មនុស្សអាចរកជំនួសវិញបាន តែកេរ្តិ៍ឈ្មោះរបស់មនុស្សប្រសិនបើត្រូវបានបំផ្លាញនឹងមិនអាច ជួសជុលបានទេ។ គាត់ត្រូវរស់ជាមួយកេរ្តិ៍ឈ្មោះអាក្រក់រហូត។

ភាពស្មោះត្រង់ និងសេចក្តីសុចរិត ធ្វើឱ្យមន្ត្រីទទួលបានប្រាក់ចំណេញ តិចនៅរយៈពេលខ្លី តែវាពិតជាមានតម្លៃសម្រាប់រយៈពេលវែង។ ពេលដែល មន្ត្រីមានភាពស្មោះត្រង់ជាមួយនឹងអ្នកដទៃ និងខ្លួនឯង រាល់ការសម្រេចចិត្ត របស់គាត់ជានិច្ចកាលពិតជាត្រឹមត្រូវ។ ការសម្រេចចិត្តជ្រើសរើសផ្លូវនេះគឺជា ការសម្រេចចិត្តមួយធ្វើឱ្យគាត់មានទំនាក់ទំនងល្អជាមួយមនុស្ស។

ភាពស្មោះត្រង់ គឺចាប់ផ្តើមស្របគ្នារវាងអ្វីដែលអ្នកបាននិយាយ និងអ្វី ដែលអ្នកបានធ្វើ មានន័យថា គ្រប់ម៉ាត់នៃពាក្យសម្តីរបស់អ្នកត្រូវតែមានពាក្យ សច្ចៈ។ បែបនេះ អ្នកដទៃនឹងមានជំនឿចិត្តលើអ្នកក្នុងរយៈពេលដ៏យូរមួយ។ ភាពជឿជាក់ និងកេរ្តិ៍ឈ្មោះល្អ មានតម្លៃថ្លៃជាងអ្វីៗទាំងអស់ និងជួយឱ្យការ ងាររបស់អ្នកមានការរីកចម្រើន ធ្វើឱ្យអ្នកមានអតិថិជនកាន់តែច្រើន និងធ្វើឱ្យ កេរ្តិ៍ឈ្មោះរបស់អ្នកកាន់តែមានតម្លៃ។

ជីវិត និងការងាររបស់អ្នកនឹងកាន់តែមានភាពងាយស្រួលទៅៗ ព្រោះ ថាមនុស្សទាំងឡាយបានធ្វើការកោតសសើរ និងផ្តល់ឱ្យអ្នកនូវឱកាសថ្មីៗជា ច្រើន។ ពិតណាស់មនុស្សទាំងឡាយ ចង់ទំនាក់ទំនងជាមួយមនុស្សដែលពួក គេអាចជឿជាក់ និងទុកចិត្តបាន។

មន្ត្រីត្រូវតែបានអប់រំ និងតម្រង់ឱ្យៈ

- និយាយការពិត និងមិនកុហកបោកប្រាស់
- ធ្វើតាមការសន្យា
- មិនចង់បាន ឬបំពានរបស់ ឬកម្មសិទ្ធអ្នកដទៃ
- ស្មោះត្រង់ចំពោះអង្គភាព និងមនុស្សធ្វើការជាមួយ។

## ៧.៦.វិធីសាស្ត្រ និងនីតិក្នុងការរៀបចំបុគ្គលិកតាមលក្ខណៈវិទ្យាសាស្ត្រ

### ៧.៦.១.និងន និងមិនភ័យខ្លាច

នឹងន មិនស្លុត និងមិនភ័យខ្លាច កើតមានក្នុងការអនុវត្តប្រចាំថ្ងៃ លុះត្រាណាមេដឹកនាំមានភាពម៉ឺងម៉ាត់ មានវិន័យ និងមានគុណធម៌។ ពិតណាស់! ក្នុងស្ថានភាពបច្ចុប្បន្នមេដឹកនាំច្រើនណាស់ ខ្វះភាពក្លាហានក្នុងការពង្រឹងការ ងារ ខ្វះភាពម៉ឺងម៉ាត់ មានវិន័យតឹងតែងតែប្រកបដោយគុណធម៌។

ក្នុងស្ថានភាពបច្ចុប្បន្ន ការអារកាត់កែសម្រួលរបៀបរបបធ្វើការ និងវិញ្ញផ្ទត់គំនិតរបស់មន្ត្រី គឺពិតជាចាំបាច់បំផុត។ មន្ត្រីដូចលើកខាង។ គឺមិនដូចគ្នាទេ។ មេដឹកនាំត្រូវមានសេចក្តីក្លាហាន ក្នុងការដាក់ទោសមន្ត្រី ដែលធ្វើការមិនយកចិត្តទុកដាក់ និងមិនប្រុងប្រយ័ត្នធ្វើឱ្យតែរួចពីដៃ ព្រមទាំង ៩ដែលប្រព្រឹត្តគ្មានសីលធម៌ផង។ ការចេះតែបណ្តោយឱ្យមន្ត្រីប្រព្រឹត្តដូច លើកឡើងនេះ គឺជារឿងគ្រោះថ្នាក់។ ដូចគ្នានេះដែរ បើសិនជាមិនផ្តល់រង្វាន់ ទេមន្ត្រីនឹងធ្វើការចុងដៃចុងជើង គេចវេះយករួចខ្លួន។ កាលបើមន្ត្រីគិត និង មានគំនិតអឺចឹង មេដឹកនាំនឹងបះជើងមិនខាន។ នាយថ្កើងដោយសារពល បើពលមិនជួយធ្វើ និងជួយទ្រទ្រង់ទេ តើនាយខ្ពស់ដូចម្តេចបាន?

គោលការណ៍ប្រើមនុស្សដ៏សំខាន់បំផុតមួយនិងដែលសង្គមមនុស្ស ពេញនិយម គឺការផ្តល់រង្វាន់ជាមួយនឹងការដាក់ទោស _មានន័យថា ការឱ្យ រង្វាន់ និងការដាក់ទោស គឺត្រូវតែធ្វើឱ្យទាន់ពេលវេលាបំផុត។ ដូចពាក្យស្លោក ខ្មែរថា ធ្វើស្រែឱ្យទាន់ក្តៅដី ធ្វើអ្វីៗឱ្យទាន់ក្តៅចិត្ត។ ការទុកស្ថានការណ៍ឱ្យ បន្ថយយឺយូរទៅ អាចនាំឱ្យគ្រោះថ្នាក់ដល់មេដឹកនាំបាន មានន័យថា ត្រូវ ពន្លត់ភ្លើងឱ្យទាន់ពេលវេលាមុននឹងឱ្យខ្យល់បក់បោកមកដល់។

ការផ្តល់រង្វាន់ឱ្យទាន់ពេល និងដាក់ទោសភ្លាមដោយមិនបណ្តោយឱ្យ រឿងរ៉ាវកន្លងផុតទៅយូរ គឺជាមធ្យោបាយដ៏ល្អមួយក្នុងការកែតម្រូវ ធ្វើការ ការប្រព្រឹត្តមិនល្អ និងកែលម្អផ្នត់គំនិតរបស់មន្ត្រីផង។ "ការមិនបានផ្តល់រង្វាន់ទាន់ពេល និងរឿងរ៉ាវកន្លងទៅយូរហើយ ទើបដាក់ទោសគឺជាគ្រោះដែល នាំឱ្យមន្ត្រីពិបាករួមចិត្តគំនិតដើម្បីសាងជ័យជំនះជូនអង្គភាព។

### ៧.៦.២.ធ្វើខ្លួនជាមេដឹកនាំដែលមន្ត្រីគោរព និងជឿទុកចិត្ត,

ទង្វើនេះ គឺជាអាទិភាពមួយទៀត។ ពិតណាស់ថា សេចក្តីគោរពដ៏ពិត ប្រាកដគឺកើតចេញមកពីការបំពេញមុខងារបានល្អ និងមានទិន្នផលខ្ពស់។ មេ ដឹកនាំដែលល្អ ខ្លាំង ត្រូវតែជាមនុស្សដែលមានការអធ្យាស្រ័យផង និងទទួល យកគំនិតដ៏ល្អៗដែលអ្នកដទៃអាចមានផង។

ជាការល្អបំផុតប្រសិនបើមេដឹកនាំចេះរៀបចំខ្លួន និងប្រព្រឹត្តក្នុងទម្លាប់ រាល់ថ្ងៃ ជាមនុស្ស មានករុណាធម៌ ភក្តីភាព មនុស្សធម៌ និងមានក្តីសុច្ចរិតទៀង ត្រង់។ ប្រសើរណាស់ បើមានគុណសម្បត្តិទាំងនេះពេញលេញ។

ជៀសវាងកុំឱ្យគេស្អប់ និងមើលងាយក៏ជាមធ្យោបាយមួយជួយបង្កើត បង្កើនការគោរព និងជឿទុកចិត្តផងដែរ។ សូមដឹងថាការស្អប់ គឺកើតមានដោយ សារសេចក្តីលោភលន់អត់ព្រំដែន និងការរំលោភទ្រព្យសម្បត្តិ និងប្រពន្ធកូន អ្នកដទៃ។ ត្រូវជៀសវាងកុំឱ្យធ្វើដូច្នេះ។ ការមិនយាយីទ្រព្យសម្បត្តិ

ឬកិត្តយសា អ្នកដទៃ នាំឱ្យអ្នកទាំងនោះនឹងរស់នៅយ៉ាងពេញចិត្ត។ ដូចគ្នានេះផងដែរ។ អាចមើលងាយមេដឹកនាំណា ដែលផ្លាស់ប្តូរមិនឈប់ឈរ យកជាការ ឬកពារដូចស្រី ខ្មាស់អៀនច្រើន ជាមនុស្សមិនដាច់ស្រេច។

សូមជៀសវាងគុណវិបត្តិទាំងនេះ និងបង្ហាញថាអំពើរបស់អ្នកទាំង ប៉ុន្មាន គឺប្រកបដោយកិត្យានុភាព ចិត្តមុតមាំ និងភាពក្លាហាន។ សូមពង្រឹង កិច្ចការអភិបាល សូមកុំផ្លាស់ប្តូរពាក្យសម្តី និងត្រូវអនុវត្តតាមការសម្រេចនានា ហើយកុំឱ្យនរណាម្នាក់បង្វែងដាន ឬបោកបញ្ឆោតបានឱ្យសោះ។

### ៧.៦.៣.ការបង្កើត និងបង្កើនអំណាច,

ប្រសិទ្ធភាពមួយក្នុងចំណោមរឿងជាច្រើនសម្រាប់ការងារគ្រប់គ្រង ដឹកនាំមន្ត្រី គឺបង្កើត និងបង្កើនអំណាច។ ការងារនេះអាចរៀបចំឡើងតាមរយៈ ការស្លៀកពាក់ ការរៀបចំចរិត និងការសម្តែងល្អព្រមទាំង ការបង្ហាញនូវទិន្នផល ឬក៏លទ្ធផលការងារខ្ពស់។

ការចាប់អារម្មណ៍ដំបូងអាចបង្កើតនូវការពេញចិត្ត ឬមិនពេញចិត្ត។ ការមើលមក ឬទៅលើមនុស្សម្នាក់បែបណានោះ គឺជាការសំខាន់ជាទីបំផុត។ ការស្រាវជ្រាវបានបង្ហាញថា ឫកពារខាងក្រៅរបស់មនុស្សបង្ហាញនូវការចាប់ អារម្មណ៍ ៥៥% សម្លេង ៣៨% និងសម្តីនិយាយធម្មតា ៧%។

ការរៀបចំខ្លួន ការតុបតែង និងការស្លៀកពាក់ក្នុងឱកាសធម្មតា ឬក្នុង ឱកាសពិសេសណាមួយ គឺមានសារៈសំខាន់។ បែបនេះ អ្នកគ្រប់គ្រងដឹកនាំ ត្រូវ រៀបចំ តុបតែង និងសៀកពាក់ឱ្យសមនឹងពេលវេលា ត្រូវតែល្អ ស្អាត និង សង្ហារ (សូមឱ្យប្រាកដថាអ្នកស្លៀកពាក់អ្វីសម ខោខូវប៊យ ឬអាវឈុត) ។

### ៧.៦.៤.ប្រសិទ្ធភាពបែងចែកទិសដៅការងារ

មធ្យោបាយសំខាន់ដើម្បីជំរុញការងារមន្ត្រី គឺធ្វើឱ្យប្រាកដថាពួកគេ ដឹងថាពួកគេកំពុងតែធ្វើដំណើរទៅទីណា? ការងារល្អមានលក្ខណៈយ៉ាងដូច ម្តេច? រឿងនេះមិនត្រឹមតែផ្តល់ឱ្យពួកគេនូវការផ្តោតការយកចិត្តទុកដាក់ច្បាស់ លាស់ និងប្រកបដោយថាមភាព ឬក៏តម្រង់ផ្លូវពួកគេឱ្យក្លាយទៅជាអ្នកធ្វើការ ងារល្អប៉ុណ្ណោះទេ តែក៏បង្កើតការពេញចិត្ត និងជំនឿចំពោះការងារផង។

ក្បួនដឹកនាំដែលល្អបំផុត គឺការចូលរួមស្តាប់មតិយោបល់គំនិតមន្ត្រី របស់ខ្លួន និងអនុញ្ញាតឱ្យពួកគេចូលរួមសម្រេចចិត្ត។ ការប្រាប់មន្ត្រីពីអ្វីត្រូវធ្វើ គឺមិនសមរម្យទេ។ សូមយល់ផងដែរថា មន្ត្រីជាច្រើនត្រូវការក្បួនដឹកនាំតម្រង់ ទិស ហេតុដល់ពួកគេមានចំណេះដឹងជំនាញគ្រប់គ្រាន់។ បែបនេះ ទស្សនទាន ភាពជាអ្នកដឹកនាំតាមស្ថានភាព គឺជាអាទិភាព។

តើអ្វីទៅជាក្បួនដឹកនាំល្អបំផុត? ក្បួនដឹកនាំដែលល្អបំផុតជាក្បួនមួយ ដែលត្រូវគ្នានឹងសេចក្តីត្រូវការនៃបុគ្គលក្នុងអង្គភាព និងសមត្ថភាពខាងស្តាប់ ខ្ពស់។ ពិតណាស់មេដឹកនាំដែលពូកែស្តាប់ ជាមនុស្សពូកែរៀនសូត្រដោះស្រាយ ការងារពីអ្នកដទៃ និងតែងធ្វើការសន្ទនាដោយផ្តោតទៅលើដៃគូ។

សំខាន់ណាស់ ការស្តាប់ និងការផ្តោតអារម្មណ៍ទៅលើអ្នកដទៃ។ លោក ដាល់ កាលីហ្គី ក្នុងស្នាដៃមានចំណងជើងថា សិល្បៈមូលមិត្ត បានលើករឿងនេះឡើងនិងបានផ្តល់ដំបូន្មានយ៉ាងច្រើនអំពីគុណសម្បត្តិនៃការស្តាប់ និង និយាយជាមួយដៃគូដោយផ្តោតអារម្មណ៍លើដៃគូ និយាយពីរឿងដៃគូ។

ចាំថាមេដឹកនាំត្រូវឱ្យមន្ត្រីយល់ពីអ្វីដែលពួកគេត្រូវធ្វើ កំពុងធ្វើ ហើយ ធ្វើអ្វីដែលគាត់ព្យាយាមទាក់ទាញឱ្យអ្នកទាំងនោះធ្វើ និងអាចជំរុញឱ្យអ្នកទាំង អស់នោះទទួលធ្វើដោយរីករាយ។

ទស្សនៈស្តីពីការផ្តល់ និងចែករំលែកដោយសមធម៌ គឺជាគំនិតដ៏ល្អ មួយអាចជួយបណ្តុះស្មារតី និងឆន្ទៈការងាររបស់មន្ត្រីឱ្យកាន់តែខ្ពស់។ មន្ត្រី គ្រប់ៗរូបតែងមានអារម្មណ៍ល្អ ចំពោះសមិទ្ធផលដែលពួកគេបានបង្កើតឡើង។ មោទនភាពនេះ ត្រូវតែតបស្នងដោយការផ្តល់នូវផលប្រយោជន៍ស្របច្បាប់ណាមួយ។ ពិតណាស់ មន្ត្រីដែលធ្វើការបានល្អសមនឹងទទួលបាននូវការផ្តល់ កិត្តិយសដើម្បីបង្ហាញពីភាពសំខាន់ជាងអ្នកដទៃ តែមេដឹកនាំ ត្រូវប្រុងប្រយ័ត្ន ចំពោះការធ្វើរឿងនេះ និងប្រុងប្រយ័ត្នចំពោះមោទនភាពក្លែងក្លាយ។ មួយ ទៀត គឺប្រុងប្រយ័ត្នកុំឱ្យមន្ត្រីទាំងនោះមានអំណួត និងមោទនភាពជ្រុល។

## ៧.៦.៥.បន្ថយអំណួត មោទនភាព និងបក្សពួក

មោទនភាពមាន ៣ ប្រភេទ គឺមោទនភាពភូតភរ មោទនភាពក្រអឺត និងមោទនភាពពិតប្រាកដ។ សូមជៀសឱ្យផុតពីការលួចយកគុណសម្បត្តិ យោបល់ ឬគំនិតល្អៗពីមន្ត្រីក្រោមបង្គាប់ បន្លំធ្វើដូចជាគំនិតផ្ទាល់ខ្លួន។

ដើម្បីអនាគតដ៏ភ្លឺស្វាង និងរុងរឿងពិតប្រាកដ សូមជៀសវាងកុំធ្វើរឿងនេះ។ ថា ថាគ្រប់ទង្វើដែលអ្នកគ្រប់គ្រងដឹកនាំធ្វើ (អនុវត្ត) គឺមិនអាចលាក់កំបាំងពីផ្នែក របស់មន្ត្រីបាននោះទេ។

ប្រសិនបើអ្នកធ្វើបែបនេះ មានន័យថាអ្នកជាមនុស្សដែលបង្ខំអង្គភាព និងមន្ត្រីឱ្យបង្កើតនូវប្រអប់សំបុត្រសម្រាប់ផ្តល់មតិហើយ។ សូមតាំងចិត្តជៀស វាងការបន្ទាបបន្ថោក ឬរារាំងការខិតខំរបស់អ្នកដទៃ និងផ្តល់ឱ្យពួកគេនូវការ លើកទឹកចិត្ត ឬការសរសើរ ទោះអ្នកនោះជាគូប្រជែងដ៏ស្វិតស្វាញរបស់អ្នកក៏ ដោយ។ ទង្វើនេះជួយជំរុញអ្នកឱ្យឈានទៅកម្រិតខ្ពស់ជាងនេះ ព្រោះថាអ្នក បានធ្វើរឿងល្អសម្រាប់មនុស្សដែលពាក់ព័ន្ធ។

សូមដឹងថា គ្មានអ្វីដែលអាចធ្វើមេដឹកនាំដើរខុសផ្លូវហួស ជាងការមាន អំណួតជ្រុល និងមោទនភាពក្លែងក្លាយទេ។

ការធ្វើចិត្តទូលាយ និងទទួលយកទស្សនៈល្អ ជាមធ្យោបាយដ៏ល្អមួយ ដើម្បីទទួលបានការគោរព និងតម្លៃ។ ការផ្តល់ឱកាសឱ្យមន្ត្រីឆ្លើយនូវសំណួរ មួយចំនួន និងបញ្ចេញមតិគឺមានសារៈសំខាន់ណាស់ក្នុងការបង្កើតប្រសិទ្ធភាព ដឹកនាំមន្ត្រី។ តាមពិសោធន៍ គឺគួរអនុញ្ញាតិឱ្យមន្ត្រីជុំវិញទទួលបានឱកាសក្នុង ការឆ្លើយសំណួរថា៖

តើពួកគេអាចធ្វើអ្វីដើម្បីឱ្យអង្គភាពបានរីកចម្រើន? • តើខ្ញុំអាចធ្វើយ៉ាងណាដើម្បីឱ្យការងាររបស់អ្នកងាយស្រួល? តើមានកិច្ចការខ្លះៗដែលខ្ញុំអាចប្រគល់សិទ្ធិឱ្យអ្នកដទៃដែរឬទេ?

ក្នុងការធ្វើរឿងនេះ អ្នកដឹកនាំ ត្រូវម៉ឺងមាត់ និងមិនត្រូវដាក់ខ្លួនឱ្យទាបហួសហេតុនោះទេ តែត្រូវសុភាពរាបសារ។

អ្នកគ្រប់គ្រងដឹកនាំដ៏អស្ចារ្យ ត្រូវមានរាងកាយមាំមួន អំណត់អត់ធន់ មានសេចក្តីក្លាហាន ចេះដឹកនាំខ្លួនឯងដោយថាមពល និងភាពស្វាហាប់ ហើយ រឹងមាំ។ គាត់ថែមទាំងត្រូវមានសមត្ថភាពដើម្បីត្រួតពិនិត្យភាពតានតឹង និង បង្កើតឱ្យមានតុល្យភាពរវាងការងារ និងពេលសម្រាកផង។

វិធីល្អបំផុតដើម្បីជួយអ្នកឱ្យមានសុខភាពល្អ រាងកាយមាំមួន អាចដឹក នាំខ្លួនឯងដោយថាមពលនិងភាពស្វាហាប់ រឹងមាំ ហើយមិនឆាប់ចាស់មុន អាយុ គឺការចេះប្រើប្រាស់ពេលវេលាឱ្យបានត្រឹមត្រូវ។

សូមជៀសវាងការធ្វើការច្រើនហួសហេតុ និងពន្យាពេលវេលាដែល ត្រូវសម្រាក។ បែបនេះ អ្នកអាចបាត់បង់ឱកាសជោគជ័យ។ សូមឱ្យច្បាស់ថា ត្រូវឈប់សម្រាកម្តង ឬពីរដងក្នុងមួយឆ្នាំ និងមួយដងយ៉ាងតិចក៏ ១០ថ្ងៃដែរ។ ពេលដែលរាងកាយ និងផ្លូវចិត្តរបស់មនុស្សហត់ ឬអស់កម្លាំង ឬក៏ឆាប់ខឹងដោយមានការឈ្លោះទាស់ទែងជាមួយថ្នាក់លើ ឬការស្រែកដាក់មន្ត្រី សូមដឹង ថាដល់ពេលសម្រាកហើយ ទោះសម្រាប់ចុងសប្តាហ៍ក៏ដោយ។

ចំពោះការបើកបរវិញ គួរប្រើប្រាស់ផ្លូវដែលរីករាយបំផុតទោះបីប្រើ ពេលយូរក៏ដោយ។ ការព្យាយាមធ្វើការទំនាក់ទំនងថ្មី ទទួលយកភាពរីករាយ ក្នុងចិត្ត ការប្រើប្រាស់ពេលវេលាឱ្យបានរីករាយដោយអាកប្បកិរិយាស្លូតបូត និងដោយស្និទ្ធស្នាល គឺពិតជាចាំបាច់ណាស់។ បែបនេះជួយអ្នកឱ្យមានភាពរីក រាយដោយវិជ្ជមាន។ ចាំថា ថ្ងៃសម្រាកត្រូវតែឱ្យខ្លួនបានសម្រាក។

## ៧.៦.៥.តាំងចិត្តបង្កើនការទទួលខុសត្រូវ

មេដឹកនាំ មានភាពចាំបាច់ខ្ពស់បំផុតក្នុងការទទួលខុសត្រូវចំពោះការ ងារ ចំពោះអង្គភាព និងចំពោះមន្ត្រី ហើយឆ្លើយតបឱ្យបានល្អតាមដែលធ្វើបាន ផងសេចក្តីត្រូវការរបស់មន្ត្រី។

រឿងនេះអាចធ្វើបាន តាមរយៈការពិនិត្យតាមដានមើលមន្ត្រីគ្រប់រូប យ៉ាងយកចិត្តទុកដាក់។ មើលឱ្យឃើញថាមន្ត្រីខ្លះចេះសម្រេចដោយខ្លួនឯង មន្ត្រីខ្លះ ត្រូវការឱ្យប្រាប់ថាត្រូវធ្វើអ្វី? យ៉ាងដូចម្តេច? ឬហេតុអ្វី? អ្នកគ្រប់គ្រ ដឹកនាំ មិនអាចសន្មត (ដោយទាំងមិនបានច្បាស់ផង) ថា ពួកគេអាចធ្វើការ ពុំចាំបាច់ណែនាំតម្រែតម្រង់ បង្វឹកបង្ហាត់ ពុំបាច់មានការត្រួតពិនិត្យ និងមិនត្រូវ គ្រប់គ្រងពួកគេបែបបន្ធូរដៃឱ្យសោះ។

ការចែករំលែកនូវយុទ្ធសាស្ត្រដឹកនាំជាមួយមន្ត្រី ពិតណាស់នឹងផ្តល់ ឱកាសឱ្យពួកគេបញ្ចេញមតិយោបល់ចំពោះការងារ ចេះជួយការងារ និងឱ្យ កគេយល់ពីទឹកចិត្តល្អរបស់អ្នក។ ការអនុវត្តយុទ្ធសាស្ត្រភាពជាអ្នកដឹកនាំជា មួយមន្ត្រី នឹងជួយមេដឹកនាំឱ្យសម្រេចបានលទ្ធផលខ្ពស់ក្នុងការទទួលខុសត្រូវ ចំពោះការងារ ចំពោះអង្គភាព និងចំពោះមន្ត្រីរបស់ខ្លួន។

## ៧.៦.៦.ឆ្លើយតបសេចក្តីត្រូវការរបស់មន្ត្រី,

រឿងនេះគឺជាមធ្យោបាយដ៏ល្អមួយ ក្នុងការជួយជំរុញបង្កើនគុណភាព ការងាររបស់មន្ត្រី។ ផ្នែកនេះនឹងមានអត្ថាធិប្បាយលម្អិតនៅក្នុង គន្លឹះទី៤, ការ រៀបចំខ្លួន និងចិត្តគំនិត, អំពី ការឆ្លើយតបតម្រូវការរបស់មន្ត្រី ផ្នែក លើកទឹកចិត្ត ត្រឹមត្រូវ និងការផ្តល់រង្វាន់។

លោកជំទាវបណ្ឌិតសភាចារ្យ ខ្លូត ធីតា តែងពោលជារឿយៗថា មេដឹកនាំត្រូវតែធ្វើការដោយគិតពីរបៀបរបបនៃចិត្តរបស់មនុស្ស។ គាត់អះអាង ថាដរាបណាមានសម្លៀកបំពាក់ មានម្ហូបអាហារបរិភោគគ្រប់គ្រាន់ និងមាន ជម្រកសម្រាប់ស្នាក់នៅសមរម្យ ទើបមនុស្សយល់ពីសុជីវធម៌។ នេះចង់បញ្ជាក់ ថាមេដឹកនាំ ត្រូវតែយល់ និងច្បាស់ថា ភាពគ្មានសុជីវធម៌របស់មន្ត្រី គឺកើតមាន ឡើងដោយសារការស្លៀកពាក់ និងការហូបចុករបស់ពួកគេមិនគ្រប់គ្រាន់ ពួក គេកាពគ្មានជម្រកប្រាកដប្រជា ជីវភាពរបស់ពួកគេជួបនឹងបញ្ហា។ បញ្ហាទាំង អស់នេះ នឹងនាំគ្រោះដល់ការងារគ្រប់គ្រងដឹកនាំ។

## ៧.៦.៧.ផ្តល់ឱកាសមន្ត្រីទទួលបានព័ត៌មាន

មន្ត្រីដែលគ្មានព័ត៌មានពុំអាចធ្វើអ្វីប្រកបដោយការទទួលខុសត្រូវបាន ទេ។ ទស្សនៈនេះ ត្រូវស្ថិតនៅជាប់ជានិច្ចជាមួយនឹងចិត្តរបស់មេដឹកនាំ។ មាន ន័យថា គាត់ត្រូវផ្តល់ឱកាសមន្ត្រីទទួលបានព័ត៌មាន។

មេដឹកនាំជាច្រើន ហាក់ដូចជាមិនទុកចិត្តមន្ត្រីរបស់ខ្លួន។ ស្ទើរតែគ្រប់ រឿងតាំងពីតូចតាចដល់ធំ គឺត្រូវឆ្លងកាត់ការពិនិត្យផ្ទៀងផ្ទាត់ទម្រាំនឹងបានធ្វើ សេចក្តីសម្រេច។ សូមកុំតាំងចិត្តធ្វើបែបនេះឱ្យសោះ សូមកុំយល់ថាមានតែអ្នក គ្រប់គ្រងដឹកនាំទេដែលមានខួរក្បាលគិត។

ការផ្តល់ព័ត៌មានទាំងអស់ដល់មន្ត្រីអំពីឥទ្ធិពលនៃបញ្ហា ហើយទុកចិត្ត ពួកគេ ដោយផ្តល់អំណាចធ្វើការសម្រេចចិត្តឱ្យពួកគេ គឺជារឿងល្អ។ បែបនេះ ការឱ្យតម្លៃខ្លួនឯងក្នុងចំណោមមន្ត្រីក៏កើតឡើង ហើយការផ្តល់សេវាក៏កាន់តែ ប្រសើរ។ ចាំថាការផ្តល់ឱ្យមន្ត្រីនូវព័ត៌មាន និងឱកាសដើម្បីធ្វើការងារ ធ្វើយ៉ាង ទទួលខុសត្រូវ នឹងនាំឱ្យពួកគេធ្វើការល្អជាងមុន។

## ៧.៦.៨.ការប្រគល់សិទ្ធិ និងអំណាច,

រឿងនេះ ត្រូវបានគេប្រើយ៉ាងច្រើនក្នុងការគ្រប់គ្រងនៃដំណាក់កាល វិវឌ្ឍន៍បច្ចុប្បន្ន។ រឿងនេះជាប់ទាក់ទងនឹងការផ្តល់អំណាចដល់មន្ត្រី និងការ ពិនិត្យមើលការសម្រេចចិត្តនានារបស់ពួកគេ។ អ្នកគ្រប់គ្រងដឹកនាំ ត្រូវយល់ថារឿងនេះសំខាន់ (អំណាចខ្លួនឯងនឹងកើនឡើង ករណីបានផ្តល់អំណាចះមឱវាទ) និងត្រូវមានជំនឿថាមន្ត្រីរបស់គាត់ អាចគ្រប់គ្រងវាសនាផ្ទាល់ខ្លួនក្នុងការងារបាន។

មធ្យោបាយដែលជួយឱ្យធ្វើរឿងនេះបានល្អ គឺទុកឱ្យមន្ត្រីចេះរកឃើញ ដំណោះស្រាយផ្ទាល់ខ្លួន (ទុកឱ្យពួកគេរកបញ្ហាដោយខ្លួនឯង) , ជៀសវាងការ ប្រាប់ថាពួកគេមានបញ្ហា និងត្រូវធ្វើឱ្យមន្ត្រីទាំងនោះមានការជំរុញលើកទឹក ចិត្តដោយខ្លួនឯង។ ការផ្តល់សិទ្ធិអំណាចដែលអាចសម្រេចបានលទ្ធផលខ្ពស់ មានទំនាក់ទំនងនឹង៖

- អនុញ្ញាតឱ្យមន្ត្រីរកឃើញទិសដៅផ្ទាល់ខ្លួន និងគាំទ្រឱ្យពួកគេមាន ទស្សនៈសម្រាប់អនាគតនៃអង្គភាព។ មានន័យថា ធ្វើឱ្យមន្ត្រីមាន អារម្មណ៍ដូចជាវីរៈបុរស ហើយផ្តល់ទំនុកចិត្ត និងតម្លៃឱ្យពួកគេ។
- បញ្ជាក់ឱ្យបានច្បាស់នូវអ្វីដែលធ្វើ មិនមែនពីរបៀបធ្វើទេ និងផ្តល់ឱ្យពួកគេនូវសេរីភាពដើម្បីធ្វើការងារឱ្យបានសម្រេច ឧទាហរណ៍ ការសម្រេចចិត្តពីវិធីដែលពួកគេធ្វើ កន្លែងធ្វើ និងពេលត្រូវធ្វើ។

• បង្កើតឱ្យមានស្មារតីល្អក្នុងក្រុម.និងផ្តល់ឱ្យមន្ត្រីនូវភាពជាម្ចាស់នៃបញ្ហាទាំងឡាយ និងជំរុញការទទួលខុសត្រូវធ្វើអ្វីៗដោយខ្លួនឯង។

• ជឿជាក់មន្ត្រី និងឱ្យពួកគេធ្វើកិច្ចការ ដោយគ្មានការជ្រៀតជ្រែក ឧទាហរណ៍ អាចធ្វើការនៅផ្ទះ ឬនៅក្រៅការិយាល័យបានបើសិន ពួកគេមានចំណង់។

• ត្រៀមផ្តល់ឱ្យមន្ត្រីនូវធនធាន ដូចជា ប្រាក់កាក់ សម្ភារ និងផ្តល់មន្ត្រី បន្ថែមទៀតដើម្បីធ្វើកិច្ចការបាន និងមួយទៀត គឺវិនិច្ឆ័យលើលទ្ធផលការងារទទួលស្គាល់ និងផ្តល់រង្វាន់ចំពោះការធ្វើកិច្ចការបាន ល្អ (ធ្វើរឿងនេះ ប្រកបដោយភាពត្រឹមត្រូវ។

• បើកចំហរ និងផ្តល់ចំណេះដឹងដល់មន្ត្រី ហើយប្រសិនបើអាចគឺ ធ្វើឱ្យមន្ត្រីមានអារម្មណ៍ថាពួកគេជាផ្នែកមួយនៃសមាជិកគ្រួសារដ៏ ធំមួយដែលតែងតែបានជួយលើកទឹកចិត្តពួកគេ។

• យកឈ្នះលើការភ័យខ្លាចរបស់មន្ត្រី ដោយណែនាំឱ្យពួកគេយល់ពី គោលបំណង ផលប្រយោជន៍នៃការផ្តល់សិទ្ធិ និងធ្វើឱ្យពួកគេមាន អារម្មណ៍ថាគ្មានការគំរាមកំហែង និងគ្មានការប្រើប្រាស់។

• រំដោះមន្ត្រីពីការិយាល័យធិបតេយ្យ និងជួយឱ្យពួកគេមានការ ចម្រើនជាមនុស្សជាតិ ដោយលើកទឹកចិត្តចំពោះការរៀនសូត្រ និង អភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈ។

ការប្រគល់សិទ្ធិ គឺជារឿងអាទិភាពតែកុំភ្លេចថាពួកគេត្រូវការព្រំដែន។ នរដៃដោយគ្មានការតម្រង់ទិស អាចនាំឱ្យវង្វេងផ្លូវ និងងាកមករកទម្លាប់ គ៌ានសិទ្ធិអំណាចវិញ ពិតជាមិនល្អទេ។ សូមប្រុងប្រយ័ត្ន និងកុំបញ្ជូនមន្ត្រី មានបទពិសោធន៍ចេញតែឯង និងក្រោយមកដាក់ទណ្ឌកម្មនៅពេលពួក ជីខស។ សូម កុំព្រលែងមន្ត្រីឱ្យមានសេរីភាពក្នុងការសម្រេចចិត្ត មានគំនិត ផ្តួចផ្តើម និងប្រតិបត្តិការងារប្រៀបដូចជាម្ចាស់ ដោយមិនបានកំហិតព្រំដែន ឱ្យសោះ។ ធ្វើត្រូវ ការងារអង្គភាពអាចស្ថិតនៅលើផ្លូវត្រឹមត្រូវ។

### ៧.៦.៧.បង្កើត និងការពារកេរ្តិ៍ឈ្មោះផ្ទាល់ខ្លួន

វិធីដ៏ល្អមួយដើម្បីបង្កើត និងការពារកេរ្តិ៍ឈ្មោះផ្ទាល់ខ្លួន គឺគុណភាព ការងារ និងការគ្រប់គ្រងដឹកនាំប្រកបដោយគុណតម្លៃ។ ទាំងអស់នេះ មាន ពាក់ព័ន្ធនឹងការប៉ិនប្រសប់។ ..

មនុស្សជាច្រើន ចេះធ្វើអ្វីៗបានស្ទើរទាំងអស់តែពុំមានការប៉ិនប្រសប់ ខាងផ្នែកអ្វីមួយឱ្យជាក់លាក់នោះទេ។ ការផ្តោតអារម្មណ៍ គឺសំខាន់ណាស់ក្នុង ការជួយខ្លួនមនុស្សឱ្យខ្លាំងពូកែ និងប្រសប់ក្នុងការធ្វើរឿងណាមួយ។

លទ្ធផលដ៏ល្អ គឺបានមកពីការផ្តោតអារម្មណ៍យ៉ាងច្បាស់លាស់។ ធ្វើការផ្តោតអារម្មណ៍ ដោ ដៅតែមួយ ពិតជាជួយបង្កើតអារម្មណ៍ ដោយខិតខំប្រឹងប្រែងប្រមូលថាមពលឱ្យមកផ្តុំក្នុងទិសដៅតែមួយ ពិតជាជួយបង្កើតភាពពូកែក្នុងការធ្វើរឿងដែលអ្នកគិតចង់ធ្វើ។

មនុស្សចេះធ្វើអ្វីៗបានស្ទើរទាំងអស់ តែបើមិនចេះផ្តោតអារម្មណ៍ ពិតណាស់ ពុំមានការប៉ិនប្រសប់ខាងផ្នែកអ្វីមួយជាក់លាក់ឡើយ។ សូមដឹង វាសនារបស់មនុស្សបែបនេះ គឺបានត្រឹមតែមធ្យមប៉ុណ្ណោះ មានន័យថា ធម្មតា ហើយគ្មានអ្វីពិសេស និងលេចធ្លោឡើយ និងឆាកជីវិតក៏បានត្រឹមមធ្យមដែរ។

### ៧.៦.១០.បង្កើនកម្លាំង និងអភិវឌ្ឍន៍ថាមពលដើម្បីការងារ,

មេដឹកនាំក្នុងស្ថានភាពជាច្រើន គឺខ្វះកម្លាំង និងថាមពលដើម្បីធ្វើរឿង ដែលត្រូវធ្វើជាច្រើនឱ្យបានល្អ និងបានលទ្ធផល។ បែបនេះ ការបង្កើនកម្លាំង និងអភិវឌ្ឍន៍ថាមពលដើម្បីការងារ គឺចាំបាច់បំផុតសម្រាប់គាត់។

តាមដែលយើងធ្លាប់បានអនុវត្ត និងធ្លាប់បានលទ្ធផលល្អជាទីគាប់ចិត្ត គឺហ្វឹកហាត់ប្រើវិធីសាស្ត្រដកដង្ហើមចូល ដោយត្រូវជ្រើសរើសទីកន្លែងស្ងប់ ស្ងាត់ល្អ រួចចាក់បទភ្លេងមានចង្វាក់យឺត សម្រួលដល់ការសម្រាក អង្គុយពែន ភ្នែនហើយដាក់បាតដៃផ្ងារឡើងលើ កែងដៃទាំងពីរដាក់លើភ្លៅទាំងសងខាង។ អង្គុយឱ្យមានលក្ខណៈសុខស្រួល ឱ្យខ្យល់ដង្ហើមចេញចូលបានល្អ និងបើការ អង្គុយបែបនេះលំបាក សូមអង្គុយលើកៅអី ឬគេងផ្ងារ។

កាលណាមានអារម្មណ៍សុខស្រួលជាមួយស្ថានភាពណាមួយហេ ចូរចាប់ផ្ដើមការដកដង្ហើមឱ្យបានវែងៗមួយៗតាមច្រមុះ ដើម្បីស ពេញលេញ។ បន្ទាប់មក ដកដង្ហើមចូល ប្រមូលថាមពលតាមខ្យល់ដង្ហើម និងនិងធ្វើបាន ៣ដង អាចទប់ខ្យល់ដង្ហើមចូលឱ្យបាន ៣០ វិនាទី ដើម ខ្យល់ដង្ហើមវាជ្រាបពេញសួតរបស់អ្នករួចបញ្ចេញដង្ហើមមកវិញតាមមាត់។ សូមចាំថា រាល់ដង្ហើមចូលនីមួយៗត្រូវស្រូបខ្យល់ឱ្យបានវែងៗពេញសួត។

សូមបន្តធ្វើៗ រហូតដល់ពេលដកដង្ហើមចូល ដែលផ្ដល់នូវអារម្មណ៍ថា ខ្យល់ដង្ហើមបានជ្រាបដល់គ្រប់អាតូមទាំងអស់នៃគ្រប់រាងកាយរបស់អ្នក និង បន្តទប់ខ្យល់ដង្ហើមចូលជាថ្មីទៀត។

ការបន្តអនុវត្តលំហាត់បែបនេះជារៀងរាល់ថ្ងៃ នឹងជួយឱ្យរាង្គកាយ ចិត្ត និងស្មារតីរបស់អ្នកចាប់ផ្ដើមមានជីវិតតាមរបៀបមួយថ្មី។ សូមដឹងថា ទង្វើ នេះ ជួយឱ្យ កម្លាំង និងថាមពល បានបាត់បង់ត្រូវបានស្តារត្រឡប់មកវិញ។ កុំ ភ្លេចសាកល្បងហាត់រៀនធ្វើឱ្យសោះ។

# មេរៀនទី៨
# ផែនការធនធានមនុស្សក្នុងវិស័យកសិកម្ម

ក្រោយពីបានបញ្ចប់ជំពូកនេះ លោកអ្នកនឹងយល់ដឹងពី៖
- សារៈសំខាន់នៃផែនការធនធានមនុស្ស
- ជំហាននៃដំណើរការផែនការធនធានមនុស្ស
- ការពន្យល់ពីប្រព័ន្ធព័ត៌មាននៃផែនការធនធានមនុស្ស

## ៨.១ សារៈសំខាន់នៃផែនការធនធានមនុស្ស

ការធ្វើផែនការធនធានមនុស្ស ជាគោលការណ៍មានប្រយោជន៍ដូចខាងក្រោម៖
- -ដើម្បីគ្រប់គ្រងធនធានមនុស្ស ឲ្យកាន់តែមានប្រសិទ្ធភាព
- -ការអភិវឌ្ឍបណ្តុះបណ្តាលបុគ្គលិក ឲ្យកាន់តែមានសមត្ថភាពជំនាញតាមតម្រូវការ
- -ការធ្វើឲ្យកាន់តែមានភាពស្មើគ្នានៃឱកាសការងារ
- -រៀបចំផែនការឲ្យស៊ីចង្វាក់ នៃតម្រូវការ និងបែងចែកបុគ្គលិក
- -ដើម្បីគ្រប់គ្រងបុគ្គលិកឲ្យមានចរន្តស្រប និងដំណើរការរបស់ស្ថាប័នឬអង្គភាព។

**ហេតុអ្វីបានជាការគ្រប់គ្រងធនធានមនុស្សមានសារៈសំខាន់ ?**

តាមពិត ធនធានមនុស្សមានសារៈសំខាន់ទាំងនៅកម្រិតជាតិ និង ទាំងនៅកម្រិតអង្គភាព ( និងទាំងនៅកម្រិតគ្រួសារ )។ ប្រជាជាតិមួយនិងរីកចម្រើនលុះត្រាតែមានពលរដ្ឋសកម្មច្រើន មានចំណេះដឹងនិងជំនាញខ្ពង់ខ្ពស់ និងហ៊ានលះបង់សម្រាប់មាតុប្រទេស ឬសង្គមខ្លួន។ យ៉ាងណាមិញ ធនធានមនុស្សសំខាន់ដូចគ្នាសម្រាប់អង្គភាព ឬសហគ្រាសដែរ។ នៅកម្រិតក្រោយនេះ ការគ្រប់គ្រងធនធានមនុស្សមានសារៈសំខាន់ ដោយសារបណ្តាញកត្តាខាងក្រោម ៖

- សហគ្រាសគឺជាមនុស្ស ( Enterprise is Human )

អង្គភាពគ្រប់ប្រភេទទាំងអស់គ្រប់គ្រងដោយមនុស្សនិងប្រតិបត្តិដោយមនុស្ស។ បើគ្មានធនធានមនុស្ស អង្គភាពមិនអាចកើតមានទេ។ ជាបន្ថែម កាលានុវត្តន៍ បញ្ហា និងការធ្លាក់ទឹកចិត្តភាគច្រើនកើតចេញពីកត្តាមនុស្ស។ ការគ្រប់គ្រងមនុស្សមិនបានល្អនាំទៅជាបញ្ហា ផ្ទុយទៅវិញ ការគ្រប់គ្រងល្អនាំទៅដល់ការសម្រេចនូវជោគជ័យរបស់អង្គភាព ពោលគឺជោគជ័យ ឬបរាជ័យរបស់អង្គភាព អាស្រ័យជាសំខាន់ទៅលើមនុស្ស។

ម្យ៉ាងទៀតដូចដែលបញ្ជាក់ពីខាងដើម បើទោះបីជា សហគ្រាសច្រើនផ្តល់សារៈសំខាន់និងយកចិត្តទុកដាក់លើបច្ចេកវិជ្ជាក៏ដោយ ក៏ប៉ុន្តែសមត្ថភាព និងមុខនាទីនៃធនធានមនុស្សក្រោយនេះមានកម្រិត ហើយមិនអាចជំនួសធនធានមនុស្សទាំងស្រុងនិងគ្រប់ពេលវេលាឡើយជាពិសេសនៅពេលដែលសេដកិច្ចវិវឌ្ឍន៍ដោយផ្អែកលើចំណេះដឹង ( Knowledge-based economy )។

- កំហុសនៃការជ្រើសរើសនិងគ្រប់គ្រងធនធានមនុស្សមិនបានត្រឹមត្រូវ

ចំពោះធនធានដទៃទៀតដែលអង្គភាពប្រើ គេមិនពិបាកក្នុងការវាយតម្លៃពីគុណប្រយោជន៍របស់វា ឡើយ។ ប៉ុន្តែសម្រាប់ធនធានមនុស្សវិញ ការជ្រើសរើសខុសនិងការគ្រប់គ្រងនិយោជិតមិនបានត្រឹមត្រូវនាំមកនូវផលវិបាក ឬ បញ្ហាជាច្រើនដូចជា៖

- មិនបំពេញការងារប្រកបដោយប្រសិទ្ធិភាព ( Not productive work )
- បង្ខូននូវធនធាន ( Waste resources )
- បាត់បង់សមត្ថភាពប្រកួតប្រជែង
- អវត្តមានច្រើន ការចាកចេញញឹកញាប់( Have high turn over ) និងបង្ខាត់បង់ពេលនិងធនធានពាក់ព័ន្ធទៅនឹងការជ្រើសរើស ហ្វឹកហ្វឺន និង បៀវត្សរ៍ជាដើម។
- អាចរងការប្តឹងប្តល់ពីអតិថិជន ឬភាគីផ្សេងទៀត។
- លទ្ធផលការងាររបស់សហគ្រាស

គ្រប់គ្រងធនធានមនុស្សជះឥទ្ធិពលទៅលើការលើកទឹកចិត្តនិងជំរុញការប្តេជ្ញាចិត្តរបស់បុគ្គលិក និយោជិត។ ការគ្រប់គ្រងធនធានមនុស្សដែលមានប្រសិទ្ធភាពក៏ផ្សារភ្ជាប់ទៅនឹងលទ្ធផលហិរញ្ញវត្ថុដែរ។ ការគ្រប់គ្រងល្អនាំឲ្យបុគ្គលិក និយោជិតពេញចិត្តដែលនាំមកនូវកិច្ចខិតខំអស់ពីសមត្ថភាពក្នុងការកែលម្អនិងផ្តល់ផលិតផលឬសេវាប្រកបគុណភាពដែលនាំឲ្យទៅការពេញចិត្តរបស់អតិថិជនហើយដែលនាំឲ្យទៅដល់ការឧត្តមភាពប្រកួតប្រជែង និង ទទួលបានប្រាក់ចំណេញរយៈពេលយូរ។

គេច្រើនយល់ច្រឡំថា ការគ្រប់គ្រងធនធានមនុស្សអនុវត្តតែសម្រាប់អ្នកដែលធ្វើការក្នុងផ្នែកគ្រប់គ្រងធនធានមនុស្ស។ ការពិតអ្នកគ្រប់គ្រងគ្រប់កម្រិតទាំងអស់ត្រូវយល់ថាសកម្មភាពគ្រប់គ្រងធនធានមនុស្សអនិវត្តមិនមែនចំពោះតែផ្នែកគ្រប់គ្រងធនធានមនុស្សប៉ុណ្ណោះទេ។ ជាក់ស្តែងអ្នកគ្រប់គ្រងជួរមុខ និងអ្នកគ្រប់គ្រងថ្នាក់លើក៏អនុវត្តនូវផ្នែកខ្លះនៃកិច្ចការនេះដែរ។ ប៉ុន្តែ ជំហ៊ានដំបូងត្រូវយល់ថា សកម្មភាពធនធានមនុស្សក្នុងបំណងអ្វី? បទពិសោធន៍បង្ហាញសកម្មភាពធនធានមានគោលបមណសំខាន់ៗរួមមាន ៖

- បង្កើនផលិតភាពការងារ
- ទទួលបាននិងរក្សាឧត្តមភាពក្នុងការប្រកួតប្រជែងយូរអង្វែង
- ធ្វើឲ្យសម្រេចលទ្ធផល / គោលដៅអង្គភាពមានកម្រិតខ្ពស់
- លើកកម្ពស់ភាពរីករាយនិងការពេញចិត្តការងាររបស់និយោជិត
- ឆ្លើយតបទៅនឹងសំណូមពរ (ក៏ដូចជាចៀសវាងបញ្ហា) ផ្លូវច្បាប់។

ដូចនេះដើម្បីបមពេញគោលបំណងខាងលើ ការគ្រប់គ្រងធនធានមនុស្សកំណត់នូវសកម្មភាពជាសារវ័ន្តដូចខាងក្រោម ៖

- ធ្វើការវិភាគការងារ និង ធ្វើផែនការធនធានមនុស្ស
- ធ្វើការជ្រើស សម្រាំងបុគ្គលិកនិយោជិត និងបង្កលក្ខណៈដល់ការបម្រើការងារ
- ធ្វើការវាយតម្លៃការងារ និងផ្តល់ប្រាក់កម្រៃ
- លើកទឹកចិត្ត និងថែរក្សាធនធានមនុស្ស។

ជាបន្ថែម ឥឡូវនេះនិយោជកច្រើនជាងមុនយល់ថា ការថែរក្សាបុគ្គលិកក៏មានសារៈសំខាន់មួយទៀត។ ប្រសិនបើមានបុគ្គលិកដែលល្អ ហើយបែជាមិនអាចរក្សានៅជាមួយអង្គភាពបាន នោះគឺជាការបាត់បង់។ ដូចនេះ មានបន្ថែមសកម្មភាព ឬមុខងារពីរផ្សេងទៀតចំពោះកិច្ចការគ្រប់គ្រងធនធានមនុស្ស ដែលមានសារៈសំខាន់ហើយត្រូវយកចិត្តទុកដាក់ដូចគ្នា គឺ ៖

- ថែរក្សាទំនាក់ទំនងការងារល្អជាមួយនិយោជិតនិងសហជីព
- ជានាការគ្រប់គ្រងនិងប្រើប្រាស់ធនធានមនុស្សសមស្របទៅនឹងច្បាប់រួមទាំងនិយ័តកម្មទាំងឡាយស្តីពីការងារ។

## ៨.២.ជំហាននៃដំណើរការផែនការធនធានមនុស្ស

ក្នុងការធ្វើផែនការធនធានមនុស្ស អ្នកធ្វើផែនការពិនិត្យនិងរកដំណោះស្រាយលើសំណួរខាងក្រោម :

– ប្រភេទការងារ(Type of jobs) ដោយពិនិត្យលើសេចក្តីពណ៌នាពីការងារ និងសំណូមពរការងារ

– ចំនួនបុគ្គលិកត្រូវការ / ឬលើសពីតម្រូវការប្រសិនជាមាន

– ពេលណាត្រូវការ

– កម្រិតចំណេះដឹង ជំនាញ និងសមត្ថភាពដែលត្រូវការ

– សំណូមពរពិសេសដទៃទៀត។

ដំណើរការនៃការធ្វើផែនការឆ្លងកាត់បួនដំណាក់កាល :

### ៨.២.១ វិភាគបរិដ្ឋានខាងក្រៅ និងស្ថានភាពក្នុងអង្គភាព

ការធ្វើផែនការធនធានមនុស្សចាប់ផ្តើមនៅពេលដែលផែនការយុទ្ធសាស្ត្រនិងផែនការធនធានមនុស្សមានការពាក់ពន្ធ័គ្នា។ ការធ្វើផែនការយុទ្ធសាស្ត្រត្រូវសម្របទៅនឹងស្ថានភាពខាងក្នុងនិងខាងក្រៅហើយការគ្រប់គ្រងធនធានមនុស្សជាយន្តការសំខាន់មួយដែលចាំបាច់ដើម្បីសម្របសម្រួលទៅនឹងការផ្លាស់ប្តូរនៃកត្តាទាំងនេះ។ ឧទាហរណ៍ ការប្រែប្រួលយ៉ាងលឿននៃបច្ចេកវិជ្ជាជំរុញអង្គភាពឲ្យធ្វើការកំណត់និងជួលកម្លាំងពលកម្មមានជំនាញថ្មី ដែលកន្លងមកពុំមានតម្រូវការលើជំនាញបែបនោះទេ។

ជាមួយគ្នានេះ ពិនិត្យមើលកត្តាខាងក្រៅខ្លះទៀតដូចជា ៖

ទីផ្សារកម្លាំងពលកម្ម : នៅកម្ពុជាបច្ចុប្បន្ន សូម្បីតែពលកម្មមិនសូវមានជំនាញយើងមានការខ្វះខាតពលកម្មដែលសារចំណាកស្រុកច្រើន។ ក្រៅពីនេះ សមាសភាពនៃពលកម្ម ប្រភេទជំនាញ និងថ្លៃពលកម្ម ភាពចល័តនៃពលកម្ម ទាំងនេះមានប្រយោជន៍ដលការពិចារណាក្នុងការធ្វើផែនការ។

កត្តាសេដ្ឋកិច្ចជាប្រការសំខាន់មួយត្រូវតាមដានមើលដែរ។ បើសេដ្ឋកិច្ចមានកំណើននឹងនាំឲ្យត្រូវការពលកម្មបន្ថែម ប៉ុន្តែស្ថានភាពនេះវាអាចលំបាកក្នុងការជ្រើសរើសដែរ ព្រោះអត្រានៃភាពអត់ការងារធ្លាក់ចុះទាប។

ក្នុងបរិបទនៃសកលភាវូបនីយកម្មសេដ្ឋកិច្ច គេត្រូវប្រមើលឲ្យបានវែងឆ្ងាយនិងទូលំទូលាយទាំងទៅលើទិដ្ឋភាពនយោបាយ សេដ្ឋកិច្ច_ច្បាប់ និងការប្រកួតប្រជែងជាដើម ដោយមិនផ្តោតតែទៅលើបរិបទក្នុងស្រុកប៉ុណ្ណោះទេ។ ឧទាហរណ៍ ការផ្លាស់ប្តូរនិងប្រែប្រួលរដ្ឋាភិបាល អ្នកដឹកនាំ ច្បាប់សំខាន់ៗ និង សេដ្ឋកិច្ចនៅអាមេរិកនៅសហគមន៍អឺរ៉ុបនៅជប៉ុន នៅចិននៅថៃ និងនៅវៀតណាម នឹងប្រាកដជាមានការប៉ះពាល់មកលើនយោបាយ សេដ្ឋកិច្ច និងធុរ-កិច្ចនៅកម្ពុជាដែរ។ ជាអាទិ៍ បើសេដ្ឋកិច្ចប្រទេសអាមេរិក ជប៉ុននិងសហគមន៍អឺរ៉ុបប្រឈមនឹងវិបត្តិធ្ងន់ធ្ងរ នោះវានឹងប៉ះពាល់លើសេដ្ឋកិច្ចកម្ពុជាដែរ ដោយសារការនាំចេញជាសម្លៀកបំពាក់ស្បែកជើង។ ល។ របស់សហគ្រាសនៅកម្ពុជាច្រើនផ្តោតទៅទីនោះ ហើយប្រទេសខាងលើនេះជាប្រភពជំនួយហិរញ្ញវត្ថុមកកាន់កម្ពុជាថែមទៀត។ ដំណើរទស្សនកិច្ចរបស់អ្នកដឹកនាំចិន និង វៀតណាមថ្មីៗ នៅកម្ពុជាច្រើនតែជំរុញឲ្យមានកិច្ចសហប្រតិបត្តិការស្អិតរមូតទ្វេភាគីឲ្យកាន់តែខ្លាំងក្លាឡើង ដូចនេះចរន្តនៃលំហូរទំនិញនាំចូលពីប្រទេសខាងលើនឹងមានច្រើនជាងមុន (ដោយសក្តានុពលនៃផលិតកម្មនាំចេញរបស់កម្ពុជាទន់ខ្សោយ)។ គួរតាមដានថែមទៀតថា ការវិនិយោគទុនធំៗខ្លះនៅប្រទេសថៃ ឬវៀតណាម ជួនកាលមិនមែនផ្តោតតែលើទីផ្សារក្នុងស្រុកថៃ ឬវៀតណាមប៉ុណ្ណោះទេ ក្នុងករណីជាញឹកញាប់គឺក៏អាចសម្លឹងមកទីផ្សារកម្ពុជាថែមទៀត។ និន្នាការបែបនេះកើនឡើងជាពិសេសក្នុងក្របខណ្ឌសមាហរណកម្មសេដ្ឋកិច្ច និងទីផ្សារនៃបណ្តាប្រទេសសមាជិកអាស៊ានក្រោយឆ្នាំ ២០១៥។ ដូចនេះ កត្តាខាងលើនឹងប៉ះពាល់វិជ្ជមាន ឬអវិជ្ជមានមកលើការលក់ និងធុរកិច្ចរបស់សហគ្រាសនានាដែលតាំងនៅលើទឹកដីព្រះរាជាណាចក្រកម្ពុជា ហើយដែលនឹងពាក់ពន្ធ័ទៅដល់តម្រូវការពលកម្មរបស់ខ្លួននៅកម្រិតសហគ្រាសជាខាងក្រោយ។

គួរកត់ចំណាំថា ការធ្វើផែនការយុទ្ធសាស្ត្ររបស់សហគ្រាសគួរពិនិត្យឲ្យជាក់លាក់ទៅតាមបរិបទនៃធុរកិច្ចរបស់ខ្លួន។

ដើម្បីឲ្យការធ្វើផែនការធនធានមនុស្សមានភាពច្បាស់លាស់និងប្រសិទ្ធភាព គេត្រូវចាំបាច់ពិនិត្យមើលកត្តាខាងក្នុងសហគ្រាសដូចជាបេសកកម្ម គោលដៅនិងយុទ្ធសាស្ត្ររបស់សហគ្រាស។ បើសហគ្រាសមានយុទ្ធសាស្ត្រពង្រីកអាជីវកម្មទៅក្នុងទីផ្សារថ្មី គេនឹងត្រូវការពលកម្មបន្ថែម ហើយប្រសិនបើសហគ្រាសមានបំណងបង្រួមទំហំអាជីវកម្មនោះ ការបន្ថយចំនួនពលកម្មជាការចាំបាច់។ ក្រៅពីនេះ ត្រូវពិចារណាពីគោលនយោបាយលើធនធានមនុស្សដូចជាលើការប្តូរតំណែង ការផ្ទេរចេញ និង ការផ្លាស់ប្តូរនានាក្នុងអង្គភាពរួមទាំងការដឹកនាំនៅក្នុងសហគ្រាសដែរ។ ប្រការមួយទៀត ព័ត៌មានដែលទទួលស្រង់ពីសេចក្តីពណ៌នាពីការងារ និងសំណូមពរការងារក៏ជាមូលដ្ឋានត្រូវពិចារណាក្នុងការធ្វើផែនការពីកម្លាំងពលកម្មដែលត្រូវការ។

### ៨.២.២ ព្យាករណ៍តម្រូវការបុគ្គលិក

តម្រូវការបុគ្គលិកផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រដែលសហគ្រាសបានជ្រើសយក។

- តើសហគ្រាសប្រកាន់យកយុទ្ធសាស្ត្រកំណើន ?
- តើសហគ្រាសប្រកាន់យកយុទ្ធសាស្ត្រស្ថេរភាព? ឬបង្រួម ?

- តើសហគ្រាសប្រកាន់យក Outsourcing ? (ករណីក្រោយនេះគឺជាការងាកទៅជួលសហគ្រាសដទៃឲ្យផលិតជំនួសខ្លួន)។

ការព្យាករណ៍ថា តើកម្លាំងពលកម្មប៉ុន្មាន និងប្រភេទណាខ្លះដែលត្រូវការជាកិច្ចការស្មុកស្មាញមួយ។ ការពិនិត្យមើលយុទ្ធសាស្ត្រនិងផែនការសកម្មភាពតូចៗទើបអាចប៉ាន់ប្រមាណពីតម្រូវការពលកម្មតាមបណ្តោះផ្នែកនិងជំនាញផ្សេងៗ។ ជួនកាល ការព្យាករណ៍ពីបរិមាណតម្រូវការមកលើផលិតផលរបស់សហគ្រាស ជាទិន្នន័យសំខាន់ក្នុងការព្យាករណ៍ពីតម្រូវការធនធានមនុស្ស។

*របៀបក្នុងការព្យាករណ៍* (Planning Approaches)

ការព្យាករណ៍ពីតម្រូវការនិយោជិកអាចធ្វើឡើងតាមវិធីមួយចំនួនដូចខាងក្រោម :

- **ការព្យាករណ៍ដោយអ្នកគ្រប់គ្រង** (Managerial Judgment)

តាមវិធីនេះ អ្នកគ្រប់គ្រងផ្ទាល់អាចព្យាករណ៍ពីចំនួនបុគ្គលិកដែលត្រូវការនៅពេលខាងមុខ។ ផ្អែកលើបទពិសោធន៍ ការយល់ពីការងារ និងការសង្កេតផង អ្នកគ្រប់គ្រងអាចធ្វើការវិនិច្ឆ័យពីកម្លាំងពលកម្មត្រូវការ។ ផ្អែកលើការយល់ដឹងនិងអារម្មណ៍អ្នកគ្រប់គ្រងអាចប៉ាន់ស្មានបានល្អដែរ។

ជាវិធីដែលងាយរហ័ស និងអស់សោហ៊ុយតិច។ ប៉ុន្តែ វានឹងគ្មានប្រសិទ្ធភាពឡើយនៅពេលដែលលក្ខខណ្ឌខាងក្រៅដូចជាទីផ្សារប្រែប្រួលលឿន។

- **ការព្យាករណ៍តាមវិធី** Delphi Method

វិធីនេះមានបំណងកាត់បន្ថយប្រការខ្វះខាតនៃវិធីទី១ ក្នុងនោះគេត្រូវការអ្នកឯកទេស៤-៥នាក់ចូលរួម។ អ្នកសម្របសម្រួលសំណូមពរឲ្យអ្នកឯងទេសវាយតម្លៃ ឧទាហរណ៍ពីតម្រូវការធនធានមនុស្ស និងពិនិត្យឡើងវិញជាច្រើនដង រហូតដល់ឈានទៅចំណុចព្រមព្រៀងគ្នា។ វាប្រើពេលច្រើនបន្តិច។

- **ការព្យាករណ៍តាម** Work-study Technique

តាមវិធីនេះ គេគណនាចំនួនផលិតផលដែលត្រូវផលិតនៅខែខាងមុខ ឧ. ផលិតស្បែកជើងឲ្យបាន៣៦០០០គូរ។ ជាមួយគ្នានេះគេដឹងថាម្នាក់ផលិតបាន៣០០គូរក្នុងមួយខែ។ ដូចនេះគេត្រូវការកម្មករចំនួន (៣៦០០០ / ៣០០) ១២០នាក់ក្នុងមួយខែ។

- The Scatter Plot

ជារបៀបដោះស្រាយតាមក្រាហ្វិកដែលជួយកំណត់ទំនាក់ទំនងរវាងអថេរពីរ ឧទាហរណ៍សកម្មភាពធុរកិច្ច និងចំនួនបុគ្គលិកដែលពាក់ព័ន្ធគ្នា។ ប្រសិនបើយើងអាចព្យាករណ៍ពីកម្រិតនៃសកម្មភាពធុរកិច្ច នោះយើងអាចរកឃើញនូវចំនួនបុគ្គលិកដែលត្រូវការ។

ឧទាហរណ៍ មន្ទីរពេទ្យមួយមានទិន្នន័យដូចខាងក្រោម :

| ទំហំមន្ទីរពេទ្យ ( ចំនួនគ្រែ) | ចំនួនគ្រូពេទ្យ Nurse បម្រើ |
|---|---|
| ២០០ | ២៤០ |

| | |
|---|---|
| ៣០០ | ២៦០ |
| ៤០០ | ៤៧០ |
| ៥០០ | ៥០០ |
| ៦០០ | ៦២០ |

ក្រាភិច១០.២




បន្ទាប់មកគូសក្រាហ្វិកដៅទំហំមន្ទីរពេទ្យ(តាងដោយចំនួនគ្រែ) លើអ័ក្សផ្តេក និងចំនួន Nurse លើអ័ក្សបញ្ឈរ។

ក្រោយពីដៅចំណុចដែលត្រូវគ្នារវាងចំនួនគ្រែនិងចំនួនគិលានុប្បដ្ឋាយិកានីមួយៗហើយគេឃើញបញ្ហាចំណុចទាំងឡាយដែលបង្កើតជានិន្នាការមួយហើយដែលយើងអាចគូសតាងដោយបន្ទាត់មួយ។ នៅពេលដែលយើងជ្រើសចំនួនគ្រែសម្រាប់រយៈពេលទៅខាងមុខយើងអាចធ្វើចំណោលកែងទៅលើអក្សអរដោណេ ហើយចំណុចប្រសព្វរបស់វាប្រាប់ពីចំនួនគ្រូពេទ្យដែលត្រូវគ្នានោះ។

### ៨.២.៣.វិភាគពីការផ្គត់ផ្គង់កម្លាំងពលកម្មក្នុងអង្គភាព

ក្នុងការវិភាគពីការផ្គត់ផ្គង់ពលកម្ម គេត្រូវញែកពលកម្មក្នុងអង្គភាពតាមប្រភេទរបស់ និង ពិនិត្យពីការប្រែប្រួលរបស់វា។ ផ្តើមចេញពីការពិនិត្យលើបញ្ជីសន្និធិជំនាញ (Skill inventory) និងលំហូរពលកម្មក្នុងអង្គភាពដូចជាការចាកចេញ (Turnover) និងផែនទីជំនួស (Replacement chart) ជាដើម។

បញ្ជី សន្និធិ ជំនាញជាទិន្នន័យជ រឿន លើ បុគ្គលិកដែលផ្តល់ព័ត៌មានជាមូលដ្ឋានពីបុគ្គលិកនិយោជិតទាំងអស់ដោយមានកត់ត្រាពី លក្ខណៈសម្បត្តិ សមត្ថភាពនិងជំនាញ ប្រវត្តិការងារ និងអត្ថប្រយោជន៍ដែលទទួលបានរបស់បុគ្គល។

ទោះជាយ៉ាងនេះក្តី ចំនួនបុគ្គលិកនិយោជិតខាងដើមមានការប្រែប្រួលដោយសារកត្តាសត្យានុម័ត និង អត្តនោម័តដូចជាការចូល និងចាកចេញរបស់បុគ្គលិក។ ការចាកចេញ(Turnover) ដំបូងបង្អស់សំដៅការលាឈប់របស់និយោជិត រួមនិងការថយចុះនៃចំនួនបុគ្គលិកផ្សេងទៀតមានការធ្វើមរណកាល ការចូលនិវត្តន៍ ការបាត់បង់សមត្ថភាពពលកម្មដោយពិការភាពឬការបញ្ឈប់ដោយសហគ្រាស។ ជាធម្មតា វាលំបាកបន្តិចក្នុងការព្យាករណ៍លើការចាកចេញនេះ។ ចំពោះកត្តានេះគេធ្វើការវិភាគការចាកចេញ" (Turnover analysis) ដោយផ្អែកលើ "រ៉ាស្យូនៃការចាកចេញ" ដែលជាផលធៀបរវាងចំនួនអ្នកចាកចេញទៅនឹងចំនួនបុគ្គលិកទាំងអស់។ ឧទាហរណ៍ មានបុគ្គលិកចាកចេញក្នុងគ្រា ២៤នាក់ក្នុងបញ្ជានិយោជិតទាំងអស់ ១៦០០នាក់។ ដូច្នេះ រ៉ាស្យូនៃការចាកចេញមាន ១.៥ ភាគរយ។

គួរបញ្ជាក់ថា ការចាកចេញខ្លះមិនមែនអាក្រក់ទេ ព្រោះវាផ្តល់ឱកាសដល់និយោជិតថ្មី ដែលមានជំនាញថ្មីមកបំពេញការងារក្នុងអង្គភាពដែរ។

លំហូរធនធានមនុស្សក្នុងអង្គភាពអាចកើតមានមួយផ្នែកទៀតដោតសារ" ផែនទីជំនួស"។ វាគឺជាបច្ចេកទេសព្យាករណ៍ធនធានមនុស្ស ដោយសំដៅទៅលើកម្រោងក្នុងការជំនួសនិយោជិតដែលមានតំណែងគ្រប់គ្រង ឫលក្ខណៈបែបអាជីព (Professional position)។ តំណែងនិមួយៗ អាចមានបេក្ខជនដែលមានសក្តានុពលមកជំនួសដោយពិនិត្យមើលទៅលើព័ត៌មានជាអាទិ៍ ចំណេះដឹង បទពិសោធន៍ និងជំនាញដែលមានភេទនិងអាយុ។ ការផ្តល់តំណែងគ្រប់គ្រង ឫអាជីពដល់និយោជិតដែលមានស្នាដៃ និងសមត្ថភាព វាជាការលើកទឹកចិត្តមួយដែរ។

### ៨.២.៤.ផែនការបំណោះស្រាយ

ក្រោយពីគណនាតម្រូវការនិងការផ្គត់ផ្គង់ពលកម្មហើយអ្នកធ្វើផែនការត្រូវការផ្ទៀងផ្ទាត់នូវតម្រូវការ និង ការផ្គត់ផ្គង់កម្លាំងពលកម្មដែលជាលទ្ធផល សហគ្រាសអាចជួបនឹងស្ថានភាពពីរឬមួយមានកម្លាំងពលកម្មលើស ឬ មួយខ្វះ។ ដំណោះស្រាយបែបណានោះ វាអាស្រ័យទៅនឹងស្ថានភាពជាក់ស្តែ-ង :

- **វិធានការដោះស្រាយករណីពលកម្មលើស**

ក្នុងករណីដែលកម្លាំងពលកម្មលើពីតម្រូវការ សហគ្រាសធ្វើការដោះស្រាយតាមសកម្មភាពខាងក្រោម

- **រឹតត្បិតការជួល** (Restricted Hiring policy)

រឹតត្បិតការជួល គឺជាការបន្ថយកម្លាំងពលកម្មដោយមិនធ្វើការជំនួសនិយោជិតដែលឈប់ ឬចាកចេញឡើយ។

- **បន្ថយម៉ោងធ្វើការ** (Reduced Hours)

ជាការកាត់បន្ថយម៉ោងធ្វើការសរុប។ ជាជំនួសការបន្តអនុវត្តន៍របបការងារ៤៨ម៉ោងក្នុង១សប្តាហ៍ អ្នកគ្រប់គ្រង អាចសម្រេចកាត់បន្ថយការងារមកត្រឹម៣០ម៉ោងវិញ។ ការកាត់បន្ថយនេះអនុវត្តតែចំពោះបុគ្គលិកដែលប្រាក់ចំណូលគិតតាមម៉ោងប៉ុណ្ណោះ។ បទពិសោធនេះធ្លាប់ត្រូវបានប្រើដោយសណ្ឋាគារនៅខេត្តសៀមរាបខ្លះ កាលជួបវិបត្តិសេដ្ឋកិច្ច និងកង្វះភ្ញៀវក្នុងរយៈកាលឆ្នាំ ២០០៩ ២០១០។

- **ដាក់ឱ្យចូលនិវត្តន៍បានលឿន** (Early Retirement)

ជាការដាក់ឲ្យចូលនិវត្តន៍មុនអាយុកាល ដែលតម្រូវដោយច្បាប់មកដល់។ ចំពោះវិធានការនេះត្រូវការសម្របសម្រួលដែរព្រោះនិយោជិតខ្លះពេញចិត្តនឹងការចូលនិវត្តន៍ ប៉ុន្តែខ្លះ ក៏អាចនឹងមានការរួញរាដែរ។ ប៉ុន្តែ ពួកក្រោយនេះអាចនឹងចង់ទទួលយកការចូលនិវត្តន៍មុនកាលកំណត់ដែរ ប្រសិនបើកញ្ចប់ប្រាក់ចូលនិវត្តន៍មានលក្ខណៈទាក់ទាញ។

- **បញ្ឈប់ពីការងារ** (Layoffs)

ការបញ្ឈប់ពីការងារ ជាលទ្ធភាពនៃដំណោះស្រាយ មួយទៀតនៅពេលដែលពលកម្មមានចំនួនលើសពីតម្រូវការដាក់ស្តែងរយៈពេលយូរ។ បញ្ហានេះក៏ត្រូវដោះស្រាយដោយសម្របសម្រួលឲ្យបានល្អព្រោះអាចមានការតវ៉ានិងប្តឹងផ្តល់ច្រើន។ នៅពេលដែលសហគ្រាសមានសហជីពនោះនីតិវិធីអាចបញ្ជាក់ច្បាស់នៅក្នុងសេចក្តីព្រមព្រៀងរវាងសហជីពនិងនិយោជក។ ដាក់ស្តែង តាមទំនោររបស់សហជីព បុគ្គលិកនិយោជិតដែលមានអតីតភាពការងារតិចត្រូវបានគេបញ្ឈប់មុនគេ។

- **វិធានការដោះស្រាយករណីកង្វះពលកម្ម**

ការដោះស្រាយក្នុងករណីនេះមាន :

- **ប្រើប្រាស់ពលកម្មមានស្រាប់អស់លទ្ធភាព**

ការប្រើពលកម្មដែលមានមកហើយឲ្យអស់លទ្ធភាព ( Extensive use of existing employees) ដោយធ្វើការបន្ថែមម៉ោងបន្ទឹកហាត់ឲ្យមានជំនាញបន្ថែម និងផ្ទេរនិយោជិតទៅផ្នែកផ្សេងដែលត្រូវការ។

- **ផ្លាស់ប្តូរប្រាក់លើកទឹកចិត្ត** (Compensation incentives)

ជាឧទាហរណ៍ ក្នុងករណីខ្វះកម្លាំងពលកម្ម សហគ្រាសអាចបន្ថែមប្រាក់កម្រៃ។ ការបន្ថែមប្រាក់កម្រៃអាចជំរុញបុគ្គលិកឲ្យមានការទទួលខុសត្រូវ និងខិតខំបង្កើនផលិតភាពការងារច្រើនជាងមុន និងកាត់បន្ថយការចាកចេញដែរ។

- **ជួលបុគ្គលិកខាងក្រៅ** (Recruit part-time Workers)

ប្រសិនបើប្រើប្រាស់ពលកម្មក្នុងសហគ្រាសអស់លទ្ធភាពហើយសហគ្រាសអាចមានដំណោះស្រាយមួយទៀតគឺជ្រើសរើសបុគ្គលិកពីខាងក្រៅ។ ក្នុងករណីដែលការងារមានលក្ខណៈបណ្តោះអាសន្នតែមួយរយៈកាលទេនោះ សហគ្រាសអាចជួលបុគ្គលិកមិនមានលក្ខណៈពេញម៉ោងមកបំពេញការងារនេះ។

**ក្រាភិច៨.១ធាតុជាមូលដ្ឋាននៃការធ្វើផែនការគ្រប់គ្រងធនធានមនុស្ស**


(១) ព្យាករណ៍តម្រូវការការងារ
(៣) ការវិភាគអំពីបរិយាកាស
ការប្រៀបធៀប
(៤) កំណត់អំពីគម្លាត
(៥) អភិវឌ្ឍន៍ផែនការសកម្មភាព
(២) ព្យាករណ៍លទ្ធភាពការងារ

ក្រាភិច ៨.២.ដំណើរការនៃការគ្រប់គ្រងធនធានមនុស្ស



# មេរៀនទី៩
# ការវិភាគការងារលើវិស័យកសិកម្ម

ក្រោយពីបានបញ្ចប់ជំពូកនេះ លោកអ្នកនឹងយល់ដឹងពីៈ

- គម្រោងអង្គការចាត់តាំង
- ទំនាក់ទំនងយុទ្ធសាស្រ្តអង្គការចាត់តាំងទៅនឹងផែនការធនធានមនុស្ស
- ការកំណត់តម្រូវការពលកម្ម
- ការព្យាករណ៍ពលកម្មនាពេលអនាគត
- ការវិភាគការងារ

## ៩.១.គម្រោងអង្គការចាត់តាំង

ការរៀបចំចាត់តាំងផ្នែកគ្រប់គ្រងធនធានមនុស្សវាអាស្រ័យទៅនឹងកត្តាមួយចំនួនដូចជា ទស្សនៈរបស់អ្នកគ្រប់គ្រងថ្នាក់ខ្ពស់ផ្តល់សារៈសំខាន់ដល់ការប្រើប្រាស់ធនធានមនុស្សចំនួនកម្មករនិយោជិតច្រើនកម្រិតណា ការមានបំណងបំពេញមុខងារឫសកម្មភាពអ្វីខ្លះ ធនធានរបស់អង្គភាព និងកម្រិតនៃការធ្វើវិមជ្ឈការអំណាចក្នុងសហគ្រាសកម្រិតណា។ ជាទូទៅ នៅក្នុងអង្គភាពធំមួយអាចមានផ្នែកផ្សេងៗដែលបំពេញកិច្ចការពាក់ពន្ធ័ទៅនឹងការគ្រប់គ្រងធនធាន មនុស្ស ដូចជា :

- ផ្នែកផែនការបុគ្គលិក (Personel Plans)
- ផ្នែកហ្វឹកហ្វឺននិងអភិវឌ្ឍន៍ (Training and Development)
- ផ្នែករៀបចំប្រាក់កម្រៃ (Compensation)
- ផ្នែកទំនាក់ទំនងការងារ (Labor Relation)
- ផ្នែកសុវត្ថិភាពការងារ ( Security and Safety )។

### ក្រាភិច ៩ .១.គ្រប់គ្រងអង្គភាព




រចនាសម្ព័ន្ធគ្រប់គ្រងក្នុងអង្គភាព និងផ្នែកគ្រប់គ្រងធនធានមនុស្សការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងក្នុងការគ្រប់គ្រងធនធានមនុស្សការគ្រប់គ្រងធនធានមនុស្សមិនមែនតែជាភារកិច្ចរបស់មន្ត្រីនិងអ្នកគ្រប់គ្រងផ្នែកធនធានមនុស្សតែម្នាក់ឯងទេ។ ប្រាកដណាស់ថា អ្នកគ្រប់គ្រងតាមបណ្តាផ្នែកក្នុងអង្គភាពក៏ត្រូវរួមចំណែកក្នុងកិច្ចការនេះដែរ។ ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងបញ្ញាផ្នែកទាំងនោះ គឺ:

→ ដាក់មនុស្ស /និយោជិតឲ្យត្រូវទៅតាមការងារ
→ ធ្វើការផ្តល់ការតម្រង់ទិសដល់និយោជិតថ្មី
→ ផ្តល់ការហ្វឹកហ្វឺនសម្រាប់ការងារថ្មីចំពោះនិយោជិត
→ លើកកម្ពស់លទ្ធផលការងាររបស់និយោជិតម្នាក់ៗ
→ ធ្វើទំនាក់ទំនងការងារនិងកិច្ចសហការប្រកបដោយភាពច្នៃប្រឌិត
→ បកស្រាយគោលនយោបាយការងារ និង នីតិវិធីរបស់អង្គភាព
→ ការអភិវឌ្ឍសមត្ថភាពបុគ្គលិក និយោជិត
→ បង្កើតនិងរក្សាគុណធម៌តាមផ្នែករបស់ខ្លួន
→ ការពារសុខភាព និង សុវត្ថិភាពរបស់និយោជិត
→ ត្រួតពិនិត្យចំណាយលើកម្លាំងពលកម្ម។

## ៩.២.ទំនាក់ទំនងយុទ្ធសាស្ត្រអង្គភាពចាត់តាំងទៅនឹងផែនការធនធានមនុស្ស

ពាក្យ" ធ្វើផែនការធនធានមនុស្ស " អាចមានន័យទូលាយនិងចង្អៀត។ ក្នុងន័យទូលាយ " ធ្វើផែនការធនធានមនុស្ស " រាប់បញ្ចូល ទាំងការធ្វើផែនការជ្រើសរើស ហ្វឹកហ្វឺន ទាំងការតម្លើងតួនាទីតំណែងការត្រៀមលក្ខណៈក្នុងការផ្លាស់ប្តូរ។ ល។ ប៉ុន្តែពាក្យនេះក៏ត្រូវបានប្រើជាញឹកញាប់ក្នុងន័យចង្អៀត ដែលសំដៅតែលើការគ្រោងប្រមាណពីចំនួន និងលក្ខណៈធនធានមនុស្សដែលនឹងត្រូវការក្នុងពេលខាងមុខ។ ក្នុងសៀវភៅនេះ យើងប្រើពាក្យខាងដើមក្នុងន័យចង្អៀតតែប៉ុណ្ណោះ។

ការធ្វើផែនការធនធានមនុស្សគឺជាដំណើរពិនិតដោយមានលក្ខណៈជាប្រព័ន្ធនូវតម្រូការធនធានមនុស្ស ដើម្បីធានាថាចំនួនបុគ្គលិកដែលត្រូវការជាមួយជំនាញដែលទាមទារអាចរកបាននៅពេលដែលត្រូវការ។

ក្រុមហ៊ុនដែលរៀបចំដំណើរការអាជីវកម្មបានល្អ នោះគេតែងតែធ្វើការព្យាករណ៍នូវ តម្រូវការបុគ្គលិក ( និយោជិក ) នៅពេលអនាគតឲ្យបានម៉ត់ចត់បំផុត។

ការរៀបចំផែនការធនធានមនុស្ស គឺជាដំណើរនៃការព្យាករណ៍ពីតម្រូវការបុគ្គលិក ដែលក្នុងនោះរួមមាននូវចំណុចសំខាន់ បី ត្រូវយកចិត្តទុកដាក់ គឺៈ

- ការព្យាករណ៍ពីតម្រូវការបុគ្គលិកនៅពេលអនាគត
- ការប្រៀបធៀបតម្រូវការបុគ្គលិកជាមួយលទ្ធភាពការងាររបស់បុគ្គលិកនា ពេលបច្ចុប្បន្ន
- កំណត់ផែនការជាក់លាក់ សម្រាប់ប្រកាសជ្រើសរើសមនុស្សពីខាងក្រៅ ឬ បុគ្គលិកចាស់ណាខ្លះដែលត្រូវបណ្តុះបណ្តាល ឬ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បី បំពេញនូវកន្លែងការងារដែលបានគ្រោងទុក។

ជាតុជាមូលដ្ឋាននៃការធ្វើផែនការគ្រប់គ្រងធនធានមនុស្ស

( ១ ) ព្យាករណ៍តម្រូវការការងារ

( ២ ) ព្យាករណ៍លទ្ធភាពការងារ

( ៣ ) ការវិភាគអំពីបរិយាកាស

( ៤ ) កំណត់អំពីគម្លាត

( ៥ ) អភិវឌ្ឍន៍ផែនការសកម្មភាព

## ៩.២.១.ផ្សារភ្ជាប់ផែនការយុទ្ធសាស្ត្រទៅផែនការធនធានមនុស្ស

ដើម្បីអោយផែនការធនធានមនុស្សរួមវិភាគទានកម្រិតខ្ពស់ក្នុងការជួយអោយសម្រេចគោលដៅវែងឆ្ងាយរបស់សហគ្រាស ចាំបាច់ផែនការនេះត្រូវផ្សារភ្ជាប់ទៅនឹងផែនការយុទ្ធសាស្ត្ររបស់អង្គភាព។ ដោយហេតុថា ធ្វើផែនការយុទ្ធសាស្ត្រពាក់ព័ន្ធទៅនឹងការកំណត់គោលដៅរយៈពេលវែងដូចជាការបង្កើនការលក់ ប្រាក់ចំណេញ ចំណែកទីផ្សារ ការទន្ទ្រានចូលទៅក្នុងទីផ្សារថ្មី ឬ គោលដៅផ្សេងទៀត។ ផ្អែកលើគោលដៅទាំងនេះ សហគ្រាសចាំបាច់តាក់តែងយុទ្ធសាស្ត្រតាមបណ្តាផ្នែកតាមរយៈផែនការលំអិតរបស់បណ្តាផ្នែកផ្សេងៗ ដូចជាហិរញ្ញវត្ថុ ទិញ ផលិតកម្ម និងម៉ាឃីធីង។ ក្នុងការប្រតិបត្តិសហគ្រាសត្រូវចែកចាយធនធាន គិតបញ្ចូលទាំងផ្នែកធនធានមនុស្សផងហើយផែនការធនធាន

មនុស្សត្រូវតែគាំទ្រ ព្រមទាំងស៊ីសង្វាក់គ្នាជាមួយផែនការយុទ្ធសាស្ត្រដើម្បីជានា គោលដៅយុទ្ធសាស្ត្រ និងសម្រេចបាន។




**ក្រាភិច ៩.២ ដំណើរការធ្វើផែនការធនធាន**

## ៩.៣ ការកំណត់តម្រូវការពលកម្ម

ដោយការវិភាគលើស្ថានភាព ឬការត្រួតពិនិត្យមើលបរិយាសការងារ បានន័យថា អ្នកគ្រប់គ្រងធនធានមនុស្សត្រូវពិនិត្យមើលថា តើការរៀបចំបុគ្គលិក សមស្របទៅតាមជំនាញនិងចំនួនសេចក្តីត្រូវការរបស់ស្ថាប័ន ឬអង្គភាពឬទេ? ព្រោះតម្រូវបុគ្គលិក ត្រូវតាមសភាពការណ៍ជាក់ស្តែង និងតាមជំនាញ ដើម្បីឲ្យការងារកាន់តែប៉ិនប្រសប់។

## ៩.៤ ការព្យាករណ៍ពលកម្មនាពេលអនាគត

ការព្យាករណ៍តម្រូវការបុគ្គលិក ត្រូវពឹងផ្អែកលើព័ត៌មានឲ្យបានគ្រប់គ្រាន់ ពិសេសត្រូវយល់ដឹងនិន្នាការក្នុងការប្រើប្រាស់ធនធានមនុស្ស នាពេលអនាគត និងនិន្នាការសេដ្ឋកិច្ចទូទៅ។

ក្នុងការព្យាករណ៍តម្រូវការបុគ្គលិក គឺតែងតែធ្វើទៅតាមតារាជំនួស (Replacemcnt Charnt) ដែលធ្វើបញ្ជីរាយមុខតំណែងសំខាន់ៗ អ្នកដែលកំពុងកាន់កាប់កិច្ចការនេះ រយៈពេលដែលគាត់ និង

ប្រហែលជាស្ថិតនៅក្នុងមុខតំណែង មុនពេលដែលគាត់ផ្លាស់ចេញ និងអ្នកណាដែលមានគុណសម្បត្តិគ្រប់គ្រាន់ ដើម្បីរៀនចំចូលកាន់មុខតំណែងនេះ។

បច្ចេកទេសនេះនិងផ្តល់ពេលវេលាដ៏បរិបូរណ៍ក្នុងការធ្វើផែនការអភិវឌ្ឍន៍របស់អ្នកស្នង ដែលមានសក្តានុពលដើម្បីកាន់ការងារគ្រប់គ្រងសំខាន់ៗ។

## ៩.៥ ការវិភាគការងារ

អង្គភាពទាំងឡាយតែងមានចក្ខុវិស័យ និងគោលដៅដែលត្រូវសម្រេចឲ្យបាន ក៏ប៉ុន្តែការប៉ុនប៉ងសម្រេចនូវគោលដៅទាំងមូលរបស់អង្គភាព វាធំធេងណាស់សម្រាប់បុគ្គលិកនិយោជិតម្នាក់ៗ។ ជាផលវិបាក អង្គភាពត្រូវមានប្រព័ន្ធមួយក្នុងការញែកបំបែកគោលដៅទាំងនោះ ជាមុខងារ ឬកិច្ចការអ្វីខ្លះដែលបញ្ហាផ្នែក ក្រុម ឬបុគ្គលិក និយោជិតទាំងនោះត្រូវសម្រេចឲ្យបានជាប្រយោជន៍អង្គភាព។ ដូច្នេះមុនដំបូងបង្អស់សហគ្រាសត្រូវកំណត់នូវការងារអ្វីខ្លះដែលត្រូវបំពេញដោយបុគ្គលិក និយោជិតរបស់ខ្លួន។

ដើម្បីសម្រេចនូវលទ្ធផលការងារកម្រិតខ្ពស់ អង្គភាពត្រូវយល់ពីការងារ និងធ្វើការផ្ទូរផ្ទង់សំណូមពរការងារ និងមនុស្សដែលត្រូវអនុវត្ត។ ដើម្បីយល់បានល្អពីការងារ វាទាមទារការវិភាគការងារ (Job Analysis) ដែលជាដំណើរការក្នុងការទទួលបានព័ត៌មានយ៉ាងលំអិតអំពីការងារ។ ការវិភាគពីការងារនិងស្វែងយល់ពីអ្វីដែលត្រូវការដើម្បីអនុវត្តន៍ការងារនោះ ផ្តល់នូវការយល់ដឹងសំខាន់ក្នុងការបំពាក់នូវមនុស្សធ្វើការហ្វឹកហ្វឺន វាយតម្លៃ និងមុខការសកម្មភាពពាក់ព័ន្ធការគ្រប់គ្រងមនុស្សដទៃទៀត។

### ៩.៥.១. អ្វីទៅជាការវិភាគការងារ ?

ការវិភាគការងារ គឺជាដំណើរការជាប្រពន្ធ័ក្នុងការប្រមូល ធ្វើការចងក្រង និង ធ្វើការវិភាគព័ត៌មានអំពីខ្លឹមសារ បរិបទ និងសំណូមពរការងារ។






### ក្រាភិច៩៣. ការវិភាគការងារ

**ក. ខ្លឹមសារការងារ (Job content)**

ផ្សំឡើងដោយព័ត៌មានអំពីសកម្មភាពផ្សេងដែលត្រូវបំពេញសម្រាប់ការងារ។ ព័ត៌មានទាំងនោះមាន :

- ភារកិច្ចដែលបុគ្គលិក និយោជិតត្រូវបំពេញជាក់ស្តែង
- គ្រឿងម៉ាស៊ីន បរិក្ខារ ឧបករណ៍ត្រូវប្រើក្នុងការបំពេញការងារ
- ភារកិច្ចបន្ថែមដែលពាក់ព័ន្ធ
- លទ្ធផលការងាររំពឹងចង់បាន
- ប្រភេទនៃការហ្វឹកហ្វឺនដែលត្រូវការ។ ល។

**ខ. បរិបទការងារ (Job context)**

សំដៅលើស្ថានភាពឬលក្ខខណ្ឌដែលនិយោជិតបំពេញកិច្ចការណាមួយ ឧទាហរណ៍ :

- លក្ខខណ្ឌ
- ហានិភ័យអាចកើតមាន
- ផលប៉ះពាល់លើសុខភាព
- ត្រូវរាយការណ៍ទៅនរណា ?
- មនុស្សប៉ុន្មាននាក់នៅក្រោមបង្គាប់ ?

**គ. សំណូមពរការងារ ( Job requirements )**

ក្រៅពីនេះការវិភាគការងារបង្ហាញពី សំណូមពរការងារ(Job requirements) ដែលរាប់បញ្ចូលលក្ខណៈសម្បត្តិជាមូលដ្ឋានដែលបុគ្គលិកបំពេញការងារនោះត្រូវមាន ដើម្បីបំពេញការងារឲ្យមានប្រសិទ្ធភាពមានដូចជា

- ចំណេះដឹង ឬព័ត៌មានជាមូលដ្ឋានក្នុងការបំពេញការងារ
- ជំនាញដោយឡែក ដូចជាក្នុងការប្រាស្រ័យ ឬផ្នែកបច្ចេកវិជ្ជាព័ត៌មានជាដើម។
- លក្ខណៈបុគ្គលភាព និង
- សមត្ថភាពជាដើម។

## ៩.៥.២. អត្ថប្រយោជន៍ និងគុណវិបត្តិនៃការវិភាគការងារ

ការវិភាគការងារជាកិច្ចការដ៏ស្មុគស្មាញប្រើពេលច្រើន ប៉ុន្តែ :

- ផ្តល់ព័ត៌មានដើមពាក់ពន្ធ័ទៅការងារផ្ទាល់
- ជួយឲ្យមានលក្ខណៈសមស្របគ្នារវាងការងារ និងនិយោជិត

•ជួយដល់ការធ្វើផែនការនិងការសម្រេចចិត្តផ្នែកធនធានមនុស្សដូចជាការជួលកម្លាំងពលកម្ម ការវាយតម្លៃការងារ ការផ្តល់ប្រាក់កម្រៃជាដើម។

ដំណាលគ្នានេះ ការវិភាគការងារក៏មានគុណវិបត្តិជាច្រើនដែរដូចជា :

•ខាតពេលវេលា និងប្រើពលកម្មផ្នែកប្រាជ្ញាមនុស្សច្រើន

•អាចបង្កប់នូវការលំអៀងរបស់បុគ្គល

•អ្នកវាយតម្លៃមិនមានជំនាញ និងយល់ពីការងារច្បាស់លាស់។




ក្រាភិច៩៤. តួនាទីការវិភាគការងារ

### ៩.៥.៣. ការប្រើប្រាស់លទ្ធផលនៃការវិភាគការងារ

ការវិភាគការងារជាចំណុចចាប់ផ្តើមនៃរាល់កិច្ចការឬមុខងារក្នុងការគ្រប់គ្រងធនធានមនុស្សទាំងឡាយ។ ការវិភាគការងារបានល្អអាចទទួលបាននូវព័ត៌មានជាមូលដ្ឋាន ដែលអាចប្រើក្នុងកិច្ចការគ្រប់គ្រងធនធានមនុស្សផ្សេងៗដូចជា :

**ក. ការជ្រើសរើស**

ការជ្រើសបុគ្គលិក (Staffing) អាចគ្មានប្រសិទ្ធភាព ប្រសិនបើលទ្ធផលវិភាគការងារ និងការធ្វើផែនការការងារដទៃទៀត អ្នកជ្រើសរើសមិនបានដឹងពីគុណវុឌ្ឍចាំបាច់សម្រាប់បុគ្គលិកនិយោជិតដែលត្រូវបំពេញការងារ។ កង្វះនូវសេចក្តីពណ៌នាថ្មី ៗ និងពីសំណូមពរការងារធ្វើឲ្យសហគ្រាសជ្រើសរើសបុគ្គលិកដោយប្រថុយប្រថាន។




ក្រាភិច ៩ការជ្រើសរើសបុគ្គលិក .៥.

**ខ. ការហ្វឹកហាត់និងអភិវឌ្ឍន៍**

សំណូមពរពណ៌នាពីការងារជាញឹកញាប់ផ្តល់មូលដ្ឋានក្នុងការវាយតម្លៃ និងកំណត់ពីតម្រូវការហ្វឹកហ្វឺននិងអភិវឌ្ឍន៍ (Training &Development)។ ប្រសិនបើសំណូមពរការងារស្នើឡើងថា ការងារ

ទាមទារចំណេះដឹង ជំនាញ ឬសមត្ថភាពដោយឡែក បុគ្គលិកដែលបំពេញការងារនោះត្រូវមានគុណវុឌ្ឍិស្របតាមតម្រូវការ។

### គ. វាយតម្លៃការងារ

ការវាយតម្លៃការងារ (Performance Appraisal) បានសុក្រិតទាមទារឲ្យមានព័ត៌មានថាតើបុគ្គលិក និយោជិកម្នាក់ៗបំពេញការងារដូចម្តេចដើម្បីធ្វើការលើកទឹកចិត្តអ្នកដែលមានស្នាដៃនិងជួយកែលំអអ្នកណាដែលបំពេញមិនសូវបានល្អ។ ការវាយតម្លៃត្រូវការប្រៀបធៀបការងារជាក់ស្តែងទៅនឹងស្ថានភាពនិងតម្រូវការនៃការងារដែលជាព័ត៌មានបានពីការវិភាគការងារនេះឯង។

### ឃ. ផ្តល់ប្រាក់កម្រៃ និងអត្ថប្រយោជន៍

ក្នុងការរៀបចំប្រាក់កម្រៃ (Compensation & Benefits) តម្លៃនៃការងារនិមួយៗចំពោះអង្គភាពត្រូវតែកំណត់ជាមុន។ ជាគោលការណ៍ការងារណាដែលមានសារៈសំខាន់ និងមានការទទួលខុសត្រូវខ្ពស់ជាង នោះវានឹងមានតម្លៃជាង។

### ង. សុវត្ថិភាព និងសុខភាព

ព័ត៌មានដែលទាញយកពីការវិភាគការងារមានសារៈសំខាន់ក្នុងការពិចារណានិងកំណត់ពីសុវត្ថិភាពនិងសុខភាពនិយោជិត (Safety and Health)។ សេចក្តីពណ៌នាពីការងារ និងសំណូមពរការងារត្រូវឆ្លុះបញ្ចាំងពីលក្ខណៈនៃសុវត្ថិភាព។ ចំពោះការងារប្រកបដោយគ្រោះថ្នាក់ខ្លះ និយោជកត្រូវការដឹងជាក់លាក់ពីគ្រោះថ្នាក់ទាំងនោះក្នុងគោលបំណងការពារ និងធ្វើឲ្យការបំពេញការងារមានសុវត្ថិភាព។

### ច. ការតាក់តែងការងារសារជាថ្មី

ការងារខ្លះមិនសូវមានប្រសិទ្ធភាព ហើយត្រូវការតាក់តែងសារជាថ្មី

(Work redesign)។ ដូចនេះមុនតាក់តែងជាថ្មីនេះឲ្យបានល្អ គេត្រូវធ្វើការប្រមូលព័ត៌មានពីកិច្ចការនោះកន្លងមកដូចម្តេចខ្លះ។

## ៩.៥.៤.របៀបក្នុងការប្រមូលព័ត៌មាននិងវិភាគការងារ ( Job analysis Methods )

អ្នកគ្រប់គ្រងផ្ទាល់ ឬអ្នកឯកទេសខាងវិភាគការងារជាអ្នកមានបន្ទុកធ្វើការវិភាគនេះ។ ដើម្បីធ្វើការវិភាគការងារ គេត្រូវការទិន្នន័យមួយចំនួនដែលអាចប្រមូល

បានតាមរយៈវិធីខាងក្រោម :

### ក. ធ្វើបញ្ជីសំណួរ

ជាវិធីរហ័ស និង អស់សោហ៊ុយតិចនៅក្នុងការប្រើបញ្ជីសំណួរ(Questionnaires)។ ជាវិធីដែលមានប្រសិទ្ធភាពច្រើនក្នុងការប្រមូលព័ត៌មានពាក់ពន្ធ័ការងារ។

វាគួរមានលក្ខណៈជា :

– សំណួរមានលក្ខណៈរចនាសម្ព័ន្ធ

– ធ្វើយ៉ាងណាឲ្យខ្លី។

ក្រោយចងក្រងព័ត៌មានហើយអ្នករៀបរៀងបញ្ជីសំណួរគួរធ្វើការសាកល្បងជាមុន ហើយក្នុងការប្រមូលពត៌មានគួរពន្យល់ពីសំណួរ ប្រសិនបើមានចម្ងល់។

### ខ. ការសង្កេត

នៅពេលប្រើវិធីសង្កេត (Observation) អ្នកវិភាគតែងមើលថា តើនិយោជិតបំពេញការងារដូចម្តេច ហើយធ្វើការកត់ត្រានូវអ្វីដែលគេបានឃើញ។ វិធីនេះត្រូវបានប្រើ ជាពិសេសចំពោះការប្រមូលព័ត៌មានពីការងារទាំងឡាយណា ដែលប្រើកម្លាំងកាយដូចជាអ្នកបើកបររថយន្តជាដើម។ វាក៏អាចជួយអ្នកវិភាគក្នុងការកំណត់ទំនាក់ទំនងរវាងការងារផ្លូវកាយនិងប្រាជ្ញាដែរ។

### គ. ការធ្វើបទសម្ភាសន៍

ជាគោលការណ៍ ការធ្វើសម្ភាស(Interview)ជាវិធីមួយបំពេញបន្ថែមទៅលើការ

សង្កេត។ ប៉ុន្តែវិធីនេះត្រូវបានប្រើទូលាយក្នុងការវិភាគការងារ។ អ្នកធ្វើសម្ភាសន៍ អាចដំបូងធ្វើការសម្ភាសនិយោជិត (ម្នាក់ឬជាក្រុម ) រួចហើយទើបធ្វើការសម្ភាសអ្នកគ្រប់គ្រងផ្ទាល់ (Supervisor) ដើម្បីបានយល់ស៊ីជម្រៅពីការងារភារកិច្ចដែលបំពេញ

និងពិនិត្យពីភាពជាក់លាក់របស់វា ហើយធ្វើការបញ្ជាក់ពីបញ្ហាចំណុចខ្លះ។ វិធីនេះខាតពេល និងចុះសោហ៊ុយច្រើន។

### ឃ. កំណត់ត្រារបស់បុគ្គលិកនិយោជិត

ក្នុងករណីខ្លះព័ត៌មានសម្រាប់ការវិភាគការងារត្រូវបានប្រមូលពី

កំណត់ត្រារបស់និយោជិត(Employee recording) ពីសកម្មភាពប្រចាំថ្ងៃរបស់គេ។ ការកត់ត្រាល្អិតល្អន់ និងជាទៀងទាត់របស់បុគ្គលិកមានប្រយោជន៍ក្នុងការស្រង់យកព័ត៌មានពីការបំពេញកិច្ចការឬសកម្មភាពជាមួយនឹងបញ្ហារបស់គេ។

### ៩.៥.៥.សេចក្តីពណ៌នាពីការងារ និងសំណូមពរការងារ (Job Description and Specification)

ជាលទ្ធផលនៃការធ្វើវិភាគការងារ គេទទួលបានសេចក្តីពណ៌នាពីការងារ (Job Description)។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយសហគ្រាសត្រូវការសេចក្តីពណ៌នាពីការងារកាន់តែច្រើនឡើងដោយសារៈ

- អង្គភាពមួយចំនួនធំធ្វើការកែទម្រង់ជាច្រើន
- សេចក្តីត្រូវការក្នុងការអនុវត្តវិធីសាស្ត្រច្នៃប្រឌិតថ្មីដើម្បី លើកទឹកចិត្តនិងផ្តល់រង្វាន់ដល់បុគ្គលិក
- បច្ចេកវិជ្ជាផ្លាស់ប្តូរបរិដ្ឋានការងារយ៉ាងច្រើន
- ការពិនិត្យពិច័យផ្នែកច្បាប់ច្រើនជាងមុនដូចជាទៅលើការរើសអើង និងសុវត្ថិភាពការងារជាដើម។

ជាធម្មតា មិនមានការឯកភាពគ្នាលើខ្លឹមសារនៃសេចក្តីពណ៌នាពីការងារនេះទេ។ ប៉ុន្តែជារួមវារាប់បញ្ចូលប្រការសំខាន់ខាងក្រោម :

- ចំណងជើងការងារ (Job title)
- សេចក្តីសង្ខេបពីការងារ (Job summary) :
  ជាការងារពេញម៉ោង ឫមិនពេញម៉ោង
  គោលបំណងនៃការងារ
- បញ្ជីនៃភារកិច្ច និងការទទួលខុសត្រូវ :
  បញ្ជាក់ពីការងារអ្វីខ្លះត្រូវបំពេញ
  ការទទួលខុសត្រូវ ឥរិយាបថក្នុងការបំពេញការងារ
- សម្ភារៈ ឧបករណ៍ និងព័ត៌មានដែលត្រូវការប្រើក្នុងការងារ
- បរិដ្ឋានការងារ (Work Environment) :
  ពណ៌នាពីលក្ខខណ្ឌការងារដូចជាទីកន្លែងបំពេញការងារ
- សមត្ថភាព ចំណេះដឹង និងបទពិសោធន៍ត្រូវការ។ ល។

ផ្លែផ្កានៃការវិភាគការងារមួយទៀត គឺសំណូមពរការងារ (Job Specification)។

សំណូមពរការងារប្រែប្រួលទៅតាមសេចក្តីពណ៌នាពីការងារ។ វាផ្តោតទៅលើលក្ខណៈសម្បត្តិបុគ្គលបែបណាដែលអាចបំពេញការងារមានប្រសិទ្ធភាព។

សំណូមពរការងារសង្កត់លើ :

- ចំណេះដឹង បទពិសោធន៍
- ជំនាញ និង

- សមត្ថភាពចាំបាច់
- បុគ្គលិកលក្ខណៈដើម្បីបំពេញការងារនោះ។

សំណូមពរការងារនេះ មានប្រយោជន៍ដោយសារវាផ្តល់ការណែនាំនៅក្នុងការជ្រើសរើសបុគ្គលិកនិយោជិត។

## ៩.៦. ការតាក់តែងការងារ (Job Design)

ការចាប់ផ្តើមនៅចុងបញ្ចាឆ្នាំ ១៩៤០ និងនៅដើមបញ្ចាឆ្នាំ ១៩៥០ ជាលទ្ធផលនៃការយកចិត្តទុកដាក់ ជាងមុនរបស់អ្នកចិត្តសាស្ត្រ អ្នកសង្គមសាស្ត្រនិង អ្នកវិទ្យាសាស្ត្រសង្គមដទៃទៀត ដែលផ្តោតការយកចិត្តទុកដាក់ទៅលើសេចក្តីត្រូវការក្នុងភារៈជាមនុស្សរបស់កម្មករ និយោជិត។ ហេតុផលនៃការយកចិត្តទុកដាក់ គឺថា លទ្ធផលការងារនឹងប្រសើរច្រើនជាងមុនប្រសិនបើកែលំអលើសេចក្តីត្រូវការនេះ។ កន្លងមកការងារផ្តោតតែលើឯកទេសកម្មហួសហេតុដែលពីដំបូងបាននាំមកនូវលទ្ធផលល្អប្រសើរ ប៉ុន្តែបើប្រព្រឹត្តយូរទៅវាមានបង្កប់នូវភាពអវិជ្ជមានមួយចំនួនដូចជាភាពដដែលៗមិនផ្លាស់ប្តូរ វាមានភាពធុញទ្រាន់ (Boring) និងកំណើននៃការអស់ទឹកចិត្ត។

ការតាក់តែងការងារគឺជាដំណើរការក្នុងការកំណត់និងតម្រៀបភារកិច្ចមុខនាទី និងដំណើរការដទៃទៀត ដើម្បីសម្រេចគោលបំណងរបស់បុគ្គលិក និងរបស់អង្គភាពដោយមានប្រសិទ្ធភាព[២៧]។ កិច្ចការនេះ ក្រៅពីជួយឲ្យសម្រេចគោលដៅសហគ្រាសក៏ត្រូវតែទទួលស្គាល់ជាមួយគ្នានោះនូវសមត្ថភាពនិងសេចក្តីត្រូវការរបស់នរណាដែលបំពេញសេចក្តីត្រូវការនោះផងដែរ។

ការតាក់តែងការងារជាផ្នែកសំខាន់មួយក្នុងការជម្រុញអោយមានប្រសិទ្ធភាព។ ជានិន្នាការ គេសង្កេតឃើញការតាក់តែងនេះហាក់ត្រូវបានផ្តោត និងប្រើច្រើនជាងមិនដោយសារសហគ្រាសធ្វើការកែប្រែយុទ្ធសាស្ត្រ ធ្វើការបង្រួបបង្រួមទំហំ (Downsizing) ធ្វើវិស្វកម្មសារជាថ្មី (Re-engineering) ឬធ្វើការកែទម្រង់ផ្សេងៗ។ ប៉ុន្តែទោះជាយ៉ាងណានេះក្តី មានការត្អូញត្អែរថា វិស្វកម្មសារជាថ្មីនេះកែប្រែដំណើរការអាជីវកម្មរបស់សហគ្រាស។ ជាមួយគ្នានោះមានការបង្កើតនូវការងារដែលទទួលខុសត្រូវបានតាក់តែងមិនល្អ និងមិនសមស្របទៅនឹងបរិដ្ឋានអាជីវកម្ម។

កត្តាគួរពិចារណាក្នុងការតាក់តែងការងារ




ក្រាភិច៩.៦.ទំនាក់ទំនងនិងលទ្ធផលនៃការតាក់តែងការងារ

ការតាក់តែងការងារទទួលរងឥទ្ធិពលនៃកត្តាបីក្រុមដូចតទៅ: គឺកត្តាអង្គភាព កត្តាឥរិយាបថបុគ្គលិក និយោជិត និងកត្តាបរិស្ថានខាងក្រៅ។

យើងពិនិត្យពីកត្តាទាំងនោះជាលំអិតដូចខាងក្រោម:

### ៩.៦.១. ចក្ខុវិស័យរបស់អ្នកគ្រប់គ្រង

ការតាក់តែងការងារត្រូវតែស្របទៅនឹងទស្សនៈវិជ្ជា គោលបំណង បេសកកម្មរបស់អង្គភាព និងទស្សនៈរបស់អ្នកគ្រប់គ្រងថ្នាក់ខ្ពស់ដែរ។ ប្រសិនបើអ្នកគ្រប់គ្រងមិនមានការប្តេជ្ញាចំពោះទស្សនាទាននៃការតាក់តែងការងារទេ ឬមិនសូវជឿជាក់លើលទ្ធផល ជាផ្លែផ្កាពីលទ្ធផលរបស់វា នោះកិច្ចខិតខំទាំងឡាយនិងមិនទទួលបានលទ្ធផលដូចការចង់បានឡើយ។

### ៩.៦.២. ឥរិយាបថ និងសន្ទានុពលនិយោជិត

ការតាក់តែងការងារត្រូវឆ្លើយតបទៅនឹងការចង់បានរបស់បុគ្គលិក និយោជិតដែរ។ ការចង់ជៀសវាងគ្រោះថ្នាក់ ការឈឺចាប់ និងប្រសិទ្ធភាពការងារ។

### ៩.៦.៣. បច្ចេកវិជ្ជា

ប្រភពនៃគ្រឿងម៉ាស៊ីន និងឧបករណ៍ដែលប្រើ ក៏ដូចជាវិធីសាស្ត្រដែលប្រើក្នុងការបំពេញការងារ ជាផ្នែកសំខាន់ដែលត្រូវពិចារណា។ បច្ចេកវិជ្ជាថ្មីៗអាចនិងធ្វើអោយការងារមានការកែប្រែ។

### ៩.៦.៤. កត្តាច្បាប់ និយ័តកម្មផ្សេងៗ

តើច្បាប់ដែលពាក់ព័ន្ធទៅនឹងការងារ បរិស្ថាន និងសុវត្ថិភាពត្រូវបានរំលោភដែរឬយ៉ាងណាក្នុងការតាក់តែងការងារថ្មីនេះ ?

### ៩.៦.៥. កត្តាសហជីព

ការតាក់តែងការងារអាចនឹងរងឥទ្ធិពលពាក់ព័ន្ធទៅនឹងទស្សនវិជ្ជា នយោបាយ និងយុទ្ធសាស្ត្ររបស់សហជីព។ ជួនកាលប្រសិនបើមិនប្រុងប្រយ័ត្នទេ ការរៀបចំការងារថ្មីអាចត្រូវបានយល់ឃើញដោយសហជីពថា ជាខិតខំរបស់អ្នកគ្រប់គ្រងក្នុងការបង្រួបបង្រួមកិច្ចការរបស់និយោជិតដែលនាំអោយកាត់បន្ថយកម្លាំងពលកម្ម បន្ថយបៀវត្សន៍ និងអំណាចរបស់ខ្លួន។

### ៩.៦.៦. សេដ្ឋកិច្ច

បើទោះបីជាការតាក់តែងឡើងវិញនូវការងារជាសំណូមពរដែលយើងចង់បាន ប៉ុន្តែសោហ៊ុយថ្លៃដើមរបស់វាមិនត្រូវកើនលើសផលចំណេញពិតដែលបានមកវិញនោះទេ។

ជាទូទៅ គោលដៅនៃការតាក់តែងការងារមាន :

- ប្រសិទ្ធភាពការងារ (Work efficiency)
- លើកកម្ពស់គុណភាពផលិតផល
- ការលើកទឹកចិត្តបុគ្គលិក
- សុវត្ថិភាពការងារ
- ភាពមានទំនុកចិត្ត (Dependability)។ ល។

### ៩.៦.៧. វិធីក្នុងការតាក់តែងការងារ (Approaches to Job Design)

ក្នុងការតាក់តែងការងារ អ្នកនិពន្ធខ្លះត្រូវពិនិត្យពីម៉ូដែលលក្ខណៈការងារធ្វើអោយមានការលើកទឹកចិត្ត។ ម៉ូដែលដូចបង្ហាញខាងក្រោមនឹងបង្ហាញពីទ្រឹស្តីលក្ខណៈការងារ (Job characteristics theory) របស់ Hackman និង Oldham។ ទ្រឹស្តីនេះកំណត់លក្ខណៈការងារប្រាំងយ៉ាង មានពិពិធកម្មជំនាញ (Skill variety) អត្តសញ្ញាណភារកិច្ច (Task identity) សារៈសំខាន់នៃការងារ (Task significance) ការមានស្វ័យភាព (Autonomy) និងព័ត៌មានត្រឡប់ (Feedback)។ តាមទ្រឹស្តីនេះ ការងារដែលមានពិពិធកម្មជំនាញ ជាការបំពេញកិច្ចការដោយប្រើនូវជំនាញផ្សេងៗក៏ដូចជាសារៈសំខាន់នៃភារកិច្ចជាកម្រិតដែលការងារមានផលប៉ះពាល់ទៅលើជីវិត ឬការងារមនុស្សដទៃជាកត្តាជំរុញអោយមានការលើកទឹកចិត្ត និងកិច្ចខិតខំ។

ម៉ូដែលខាងក្រោមអះអាងថានិយោជិតដែលមានការលើកទឹកចិត្ត ពេញចិត្ត នឹងធ្វើការប្រកបដោយផលិតភាពគឺជាមនុស្សដែល :

ក/មានអារម្មណ៍ថាការងាររបស់គេមានន័យ

ខ/មានការទទួលខុសត្រូវចំពោះលទ្ធផលការងារ

គ/យល់ដឹងពីលទ្ធផលការងារដែលខ្លួនបានបំពេញ។

ម៉ូដែលលក្ខណៈការងារធ្វើ ឲ្យមានការលើកទឹកចិត្តទៅលើផ្លូវចិត្តរបស់និយោជិតដែលនាំអោយ

១/លើកទឹកចិត្តផ្ទៃក្នុងរបស់និយោជិត

២/លទ្ធផលការងារល្អ

៣/ការថយចុះនូវអវត្តមាន និងការលាឈប់។

ដូចនេះរបស់លក្ខណៈការងារ វាប៉ះពាល់ទៅលើផលិតភាពការងារ ការលើកទឹកចិត្ត និងការពេញចិត្តការងារ។

បទពិសោធន៍ខ្លះបង្ហាញថា វាមិនមានវិធីតាក់តែងណាដែលល្អជាងគេនោះទេ ។[២៩] ស្ថានភាពខុសគ្នាទាមទាររបៀបផ្សេងគ្នាក្នុងការតាក់តែងការងារដែរ។ម្យ៉ាងទៀត វិធីក្នុងការតាក់តែងការងារហាក់ផ្តោតទៅលើគោលដៅផ្សេងៗគ្នា។ ការតាក់តែងការងារខ្លះធ្វើការផ្តោតទៅលើការបង្កើនលទ្ធផលការងារ នៅពេលដែលខ្លះទៀតហាក់ធ្វើការសង្កាត់ទៅលើការពេញចិត្តទៅលើការងារ (Job satisfaction) ទៅវិញ។

## ក. តាក់តែងការងារអោយមានប្រសិទ្ធភាព

ជាការតាក់តែងការងារដែលធ្វើយ៉ាងណាអោយការងារមានប្រសិទ្ធភាព (Efficient Job) ដោយធ្វើអោយមានភាពងាយស្រួល កាត់បន្ថយភាពស្មុគស្មាញ ធ្វើអោយមានលក្ខណៈសាមញ្ញ ងាយស្រួលក្នុងការហ្វឹកហាត់ ដែលបុគ្គលិកនិយោជិតគ្រប់គ្នាទទួលបាន ដោយឆាប់រហ័ស និងបំពេញបានដោយងាយស្រួល។ នេះជាវិធីវិស្វកម្មជាថ្មី (Re-engineering) ប៉ុន្តែការងារបែបនេះអាចធ្វើអោយបុគ្គលិក និយោជិតឆាប់មានការធុញទ្រាន់។ ការធ្វើបែបនេះក៏ត្រូវតែមានការលើកទឹកចិត្តផងដែរ។

## ខ. ការតាក់តែងការងារលើកទឹកចិត្ត

ប្រការសំខាន់មួយទៀតក្នុងការតាក់តែងការងារ គឺធ្វើយ៉ាងណាអោយមានការលើកទឹកចិត្ត (Motivating Job)ក្នុងការបំពេញការងារដែលនឹងជួយជំរុញបុគ្គលិកអោយខិតខំក្នុងការអនុវត្ត។

វិធីសាស្ត្រទាំងនោះមាន:

### ខ.១. ការពង្រីកការងារ

ការពង្រីកការងារ (Job enlargement) សំដៅលើការធ្វើអោយកាន់តែទូលំទូលាយនូវកិច្ចការដែលត្រូវបំពេញ។ គោលដៅនៃការពង្រីកការងារគឺធ្វើអោយកិច្ចការមិនសូវដដែលៗ និងមានការចាប់អារម្មណ៍ (Interesting)។ វិធីក្នុងការពង្រីកមាន Job extension និង ការផ្លាស់ប្តូរពីការងារមួយទៅមួយ (Job rotation)។ Job extension ជាការពង្រីកតាមការផ្សំបន្ថែមនូវកិច្ចមួយចំនួន ដូចជាបន្សំការងាររបស់អ្នកទទួលភ្ញៀវជាមួយការងារវាយអត្ថបទ និងជាលេខាធិការ។ ល។ ឯងការប្តូរការងារមិនមែនជាការតាក់តែងការងារជាថ្មីទេ ប៉ុន្តែ គឺជាការប្តូរនិយោជិត បុគ្គលិកពីការងារមួយទៅមួយ។

### ខ.២. ការធ្វើអោយការងារសម្បូរបែប

គំនិតពីការធ្វើអោយការងារសម្បូរបែប (Job enrichment) ឬការផ្តល់អំណាចដល់និយោជិត ក្នុងការធ្វើសេចក្តីសម្រេចក្នុងការងាររបស់គេមកអំពីទស្សនៈរបស់ Frederic Herzberg។ របៀបក្នុងការធ្វើអោយសម្បូរបែបការងារនៅក្នុងផ្នែកផលិតកម្ម គឺការអាចធ្វើការសម្រេចអោយបញ្ឈប់ផលិតកម្ម នៅពេលដែលគុណភាពផលិតផល មិនឆ្លើយតបទៅនឹងស្តង់ដារបានកំណត់។

### ខ.៣.ក្រុមការងារស្វ័យគ្រប់គ្រង

ក្រុមការងារស្វ័យគ្រប់គ្រង (Self-managing work Teams) នៅមានសិទ្ធិក្នុងការចាត់ចែងដំណើរការកិច្ចការទាំងមូល ឬតែផ្នែកណាមួយ។ សមាជិកក្រុមមានអំណាចក្នុងការជ្រើសសមាជិកក្រុម ចាត់ចែងវិធីការងារ ដោះស្រាយបញ្ហាពាក់ព័ន្ធ និងបំពេញភារកិច្ចដទៃដែលកន្លងមកអនុវត្តដោយអ្នកគ្រប់គ្រង។

### ខ.៤. ពេលវេលាការងារទន់ភ្លន់

ជាការផ្តល់សិទ្ធិក្នុងការចាត់ចែងកម្មវិធីការងារទន់ភ្លន់ (Flexible Work time) ដោយអាស្រ័យទៅនឹងសំណូមពររបស់អង្គភាព ក៏ដូចជាការងាររបស់បុគ្គលិកនីមួយៗ។ ពេលដែលបត់បែននេះជានយោបាយមួយដែលក្នុងនោះ បុគ្គលិកពេញម៉ោងអាចជ្រើសរើសពេលណាចាប់ផ្តើមនិងពេលណាបញ្ចប់ក្នុងវង្វង់គោលការណ៍កំណត់ដោយអង្គភាព។

## គ. តាក់តែងការមិនសុវត្ថិភាពនិងសុខភាព

របៀបដែលមនុស្សប្រើប្រាស់ដងខ្លួនក្នុងការបំពេញការងារដែលប៉ះពាល់ដល់សុខភាពផ្លូវកាយហើយនិងប៉ះពាល់ថា តើគេបំពេញការងារបានល្អនិងបានយូរប៉ុណ្ណា។ ការសិក្សានូវទំនាក់ទំនង (Interface) រវាងសរីរៈបុគ្គលិកនិងលក្ខណៈ របស់បរិដ្ឋានរូបសាស្ត្រការងារត្រូវបានគេហៅថា Ergonomics។ គោលបំណងរបស់ Ergonomics នេះគឺកាត់បន្ថយភាពតានតឹងផ្នែកផ្លូវកាយរបស់និយោជិត ដោយរៀបចំបរិដ្ឋានរូបសាស្ត្រ ស្របតាមរបៀបដែលដងខ្លួនមនុស្សប្រព្រឹត្ត។ វិធីសាស្ត្រនេះផ្តោតការយកចិត្តទុកដាក់ទៅលើការកាត់បន្ថយនូវការហត់នឿយផ្លូវកាយ ការឈឺចាប់ ចុករោយនិងបញ្ហាផ្សេងទៀត។ ប្រិយមិត្តអ្នកអានដែលបើកបររថយន្តឃើញហើយ ប្រសិនបើរថយន្តរបស់អ្នកមិនអាចសម្រួលកម្ពស់ដៃចង្កូត និងការដាក់ពួកបង្អយ និងកែសម្រួលទាំងទាញមកមុខឬថយក្រោយតាមលក្ខណៈរូបសាស្ត្រនៃដងខ្លួនយើងទេ លោកអ្នកក៏អាចបញ្ជារថយន្តមិនស្រួលដែរហើយក៏ប្រឈមនិងការចុករោយច្រើនទៀត ជាពិសេសចំពោះការបើកបរនៅរយៈចម្ងាយឆ្ងាយ។

Ergonomics នាំអោយមានការកែសម្រួលឧបករណ៍ បរិក្ខារ កៅអី តិបន្ទះវាយអក្សរ (Keyboards) ដែលមានសារៈសំខាន់ក្នុងការជួយកិច្ចការនៅការិយាល័យ។ ការចូលរួមរបស់និយោជិតជាកត្តាសំខាន់ក្នុងការឌីសាញឧបករណ៍ បរិក្ខារទាំងនេះ។ នៅសហរដ្ឋអាមេរិកនាឆ្នាំ២០០១ ស្ថានីយ៍ទីភ្នាក់ងារសុវត្ថិភាពមុខរបរនិងសុខភាព (Occupational Safety and Health Agency) ស្នើឡើងនូវកិច្ចការដែលនិយោជិតគួរជៀសវាងព្រោះវាជាកិច្ចការមានហានិភ័យខ្ពស់ដូច ៖

១-ប្រើបន្ទះក្តារចុច (Keyboard) ដល់ទៅបួនម៉ោងដោយមិនសម្រាក
ការបង្កើតតារាងទីផ្សារផលិតផល គឺការ កត់ចូលប្រភេទទីផ្សារទៅក្នុងជួរទទឹង នៃតារាងនិងកត់ចូលប្រភេទផលិតផលទៅក្នុងកូឡោន បញ្ឈរនៃតារាងដូចមានបង្ហាញក្នុងតារាងទី៥.១១។ ទំហំទីផ្សារ (គឺការបូកបញ្ចូលគ្នាទីផ្សារ និង ផលិតផល) នៅក្នុងកូឡោននីមួយៗនៃតារាងគឺត្រូវតែធ្វើការព្យាករណ៍។ ចំពោះភោជនីយដ្ឋាន ភ្នំពេញ របស់អ្នកវិញ ការព្យាករណ៍គឺការទស្សន៍ទាយពីចំនួន ឬ ចំណូលដែលសង្ឃឹមថានឹង អាចលក់ទៅឱ្យចំណែកទីផ្សារនីមួយៗ។ ផលិតផល-ម្ហូបអាហារ

**តារាង ១១១ ការជ្រើសរើសទីផ្សារគោលដៅសម្រាប់ភោជនីយដ្ឋានភ្នំពេញ.**

| ទីផ្សារ | អាហារពេលព្រឹក | អាហារថ្ងៃត្រង់ | អាហារសំរន់ក្រោយថ្ងៃត្រង់ | អាហារពេលល្ងាច | អាហារសំរន់ក្រោយពេលល្ងាច |
|---|---|---|---|---|---|
| ទីផ្សារនិស្សិត | | | | | |
| រៀនព្រឹក | ធំ | តូច | តូច | គ្មាន | គ្មាន |
| រៀនល្ងាច | តូច | ធំ | ធំ | | គ្មាន |
| រៀនយប់ | គ្មាន | គ្មាន | តូច | ធំ | មធ្យម |
| រៀនចុងសប្តាហ៍ | ធំ | ធំ | មធ្យម | គ្មាន | គ្មាន |
| ទីផ្សារមិនមែននិស្សិត | | | | | |
| បុគ្គលិកមហាវិទ្យាល័យ | គ្មាន | ធំ | តូច | តូច | គ្មាន |
| អ្នករស់នៅក្បែរមហាវិទ្យាល័យ | គ្មាន | តូច | មធ្យម | មធ្យម | តូច |
| អ្នកធ្វើការជុំវិញមហាវិទ្យាល័យ | តូច | ធំ | គ្មាន | តូច | គ្មាន |

-តូច ៖ ទីផ្សារមានទំហំតូច

-ធំ ៖ ទីផ្សារមានទំហំធំ

-មធ្យម ៖ ទីផ្សារមានទំហំមធ្យម

-គ្មាន គ្មានទីផ្សារ។

**.ជំហានទី៤៖ ការជ្រើសរើសទីផ្សារគោលដៅ** (Select target markets)

ក្រុមហ៊ុនគួរតែ ជ្រើសរើសយកចំណែកទីផ្សារគោលដៅនីមួយៗដោយប្រុងប្រយ័ត្ន។ ការជ្រើសយកទីផ្សារ គោលដៅដែលមានចំណែកទីផ្សារតិចតួចពេកអាចនាំឲ្យក្រុមហ៊ុនមិនអាចសម្រេចបានគោលដៅ នៃទំហំការលក់ និងប្រាក់ចំណេញ។ តែបើជ្រើសយកទីផ្សារគោលដៅដែលមានចំណែកទីផ្សារច្រើនពេក នាំឲ្យក្រុមហ៊ុនត្រូវពង្រីកសកម្មភាពប្រតិបត្តិការទីផ្សារ បន្ថែមហើយចំណាយផ្សេងៗនឹងកើនឡើងលើសពីកំណើននៃការលក់ និងប្រាក់ចំណេញទៅទៀត។ មានលក្ខណៈវិនិច្ឆ័យ ប្រាំ (live criteria) ដែលអ្នកគ្រប់គ្រងត្រូវចាប់អារម្មណ៍ក្នុងការជ្រើសរើសទីផ្សារគោលដៅគឺ៖

**- ទំហំ** (Size)៖ ទំហំទីផ្សារគឺជាកត្តាមួយសំខាន់ណាស់ដែលត្រូវពិចារណាថាតើការ សម្រេចធ្វើអាជីវកម្មលើចំណែកទីផ្សារមួយអាចនឹងបានទទួលប្រយោជន៍ ឬ អត់។ ឧទាហរណ៍៖ ដូចជាក្នុងករណីភោជនីយដ្ឋានភ្នំពេញរបស់អ្នកយើងឃើញថា គ្មានទីផ្សារ

សម្រាប់អាហារពេលល្ងាចក្នុងចំណោមនិស្សិតដែលរៀនពេលព្រឹក និងនៅចុងសប្តាហ៍ ហេតុនេះយើងមិនគួរលះបង់សកម្មភាពប្រតិបត្តិការទីផ្សារ ដើម្បីផ្តោតទៅលើចំណែក ទីផ្សារដ៏តូច ឬក៏សឹងតែគ្មាននោះទេ។

**-កំណើនដែលបានគិតទុក** (expected growth) ទោះបីជាចំណែកទីផ្សារមានទំហំតូច ប៉ុន្តែកម្រិតលូតលាស់ ឬ ប្រាក់ចំណេញពីចំណែកទីផ្សារនោះបានកើនឡើងបន្តិច ឬនឹងកើនឡើងនៅពេលខាងមុខ ហើយនេះក៏ជាការលើកទឹកចិត្តមួយដល់អ ប្រតិបត្តិការទីផ្សារក្នុងការពិចារណាទៅលើចំណែកទីផ្សារបែបនេះ។

**-ស្ថានភាពប្រកួតប្រជែង** (competitive position) ប្រសិនបើកម្រិតប្រកួតប្រជែងកំពស់ កើនឡើងខ្លាំង ឬ នឹងកើនខ្លាំងនៅពេលខាងមុខសម្រាប់ចំណែកទីផ្សារណាមួយទេ អ្នកប្រតិបត្តិការទីផ្សារក៏ត្រូវចាប់អារម្មណ៍ផងដែរ។ ចំណែកទីផ្សារដែលមានកះ ប្រកួតប្រជែងតិចតួចទើបជាចំណែកទីផ្សារដែលគួរឲ្យទាក់ទាញ និងគួរជ្រើសយក។

**-ចំណាយក្នុងការប្រតិបត្តិចំណែកទីផ្សារ** (cost of reaching the segment) ចំណែក ទីផ្សារណាដែលពិបាក ឬ មិនអាចប្រតិបត្តិសកម្មភាពប្រតិបត្តិការទីផ្សារបាន គឺមិន គួរជ្រើសយកទេ។ ឧទាហរណ៍៖ ដូចជា ការផ្សព្វផ្សាយពាណិជ្ជកម្មតាមកាសែត មធ្យោបាយផ្សេងទៀតទៅកាន់ប្រជាជនដែលរស់នៅតំបន់ជិតមហាវិទ្យាល័យម ចំនួនតូចហើយមិនមែនជានិស្សិតនោះមានការពិបាកនឹងទៅដល់ពួកគេ។ ហេតុនេះ ភោជនីយដ្ឋានភ្នំពេញ របស់អ្នកមិនគួរព្យាយាមផ្សព្វផ្សាយទៅកាន់ពួកគេទេ។

**- លទ្ធភាពឆ្លើយតបទៅនឹងគោលដៅ និងធនធានរបស់ក្រុមហ៊ុន** (compatibility with the organization's objectives and resources) ការប្រតិបត្តិលើចំណែកទីផ្សារមួយគឺ ត្រូវតែឆ្លើយតបទៅនឹងគោលដៅ និងធនធានរបស់ក្រុមហ៊ុនផងដែរ។ បើអ្នកមិន មានឧបករណ៍សម្រាប់ធ្វើប៊ីហ្គីសម្រាប់អាហារពេលព្រឹកទេនោះ ហើយម្យ៉ាងទៀត ភោជនីយដ្ឋានរបស់អ្នកមិនមានគោលការណ៍ចំណាយលើឧបករណ៍បែបនេះទេ ហេតុនេះអ្នកមិនគួរព្យាយាមជ្រើសយកចំណែកទីផ្សារនៃអាហាពេលព្រឹកនោះទេ។

**.ជំហានទី៥៖ ការអនុវត្តន៍សកម្មភាពប្រតិបត្តិការទីផ្សារលើទីផ្សារគោលដៅ** (Take marketing actions to reach target markets)

នៅពេលដែលចំណែកទីផ្សារគោលដៅ ត្រូវបានជ្រើសរើសរួចហើយ អ្នកគ្រប់គ្រងប្រតិបត្តិការទីផ្សារ ត្រូវរៀបចំសកម្មភាពប្រតិបត្តិការទីផ្សារ មួយដើម្បីឆ្លើយតបទៅនឹងចំណែកទីផ្សារទាំងនោះ ដូចជាការបង្កើតសកម្មភាពប្រតិបត្តិការទីផ្សារចម្រុះសម្រាប់ទីផ្សារគោលដៅនីមួយៗ មានការផ្សាយពាណិជ្ជកម្ម ការជម្រុញការលក់ ការបែងចែកលក់ និងការផ្តោតទៅលើគុណភាពនិងថ្លៃនៃផលិតផលសម្រាប់ទីផ្សារគោលដៅ។

## ១១.៥.៣.វិធីសាស្ត្របែបវិទ្យាសាស្ត្រឬ 5 ជំហាននៃការនៃការស្រាវជ្រាវ marketing

វិធីសាស្ត្របែបវិទ្យាសាស្ត្រអនុញ្ញាតឲ្យជ្រើសរើសបានរបៀបដោះស្រាយត្រឹមត្រូវនិងសមស្រប។ វាមិនអនុញ្ញាតឱ្យសន្និដ្ឋានបែបអត្តនុម័តហ្នឹងដោយអព្ភន្តរញ្ញាណ។

វិធីសាស្ត្រមេប្រែជាសាស្ត្រត្រូវអនុម័ត។

អាជីវករដែលគ្មានវិធីសាស្រ្តបែបវិជ្ជាសាស្រ្តអាចសន្និដ្ឋានបានថាខ្ញុំដឹងថាអ្នកប្រើតើប្រះនិងចូលចិត្តផលិតផលរបស់យើង។ ចូលធ្វើការសង្កេតមើលខ្លះ៣។ ប្រសិនបើលទ្ធផលឲ្យឃើញថាទិញតិចបំផុត 60% ចូលចិត្តវាចង់នាំចេញទៅទីផ្សារសាកល្បង។ ប្រសិនបើអ្នកប្រើប្រាស់មិនចូលចិត្តនូវផលនោះលើកដឹកលើបង្ហំត្រូវកែច្នៃផ្លាស់ប្តូរវានឹងខិតខំធ្វើការសាកល្បងបន្ថែម 3 ដងទៀតឬត្រូវបោះបង់ចោលគំនិតនោះ។

ដូច្នេះវិធីសាស្រ្តបើវិទ្យាសាស្រ្តដោយសាកល្បងគឺឆ្លាតវៃនិងអនុម័តទាំងស្រុងដំណើរប្រព្រឹត្តនៃការស្រាវជ្រាវ marketing 5 ជំហានដូចខាងក្រោម

1. ជំហានទី ១ កំណត់បញ្ហា
2. ជំហានទី ២ វិភាគស្ថានការណ៍
3. ជំហានទី ៣ ប្រមូលព័ត៌មានសំខាន់បីថ្នាក់ទី 1 អំពីបញ្ហាត្រូវយកចិត្តទុកដាក់
4. ជំហានទី ៤ បកស្រាយព័ត៌មានវិនិច្ឆ័យ
5. ជំហានទី ៥ វិនិច្ឆ័យដោះស្រាយបញ្ហា

ជំហានទាំងនេះត្រូវបានសង្ខេបដូចខាងក្រោម

កំណត់បញ្ហា→វិភាគស្ថានការណ៍→ប្រមូលព័ត៌មានចម្បងអំពីបញ្ហាត្រូវយកចិត្តទុកដាក់→បកស្រាយព័ត៌មាន→វិនិច្ឆ័យដោះស្រាយបញ្ហា

**ក.ជំហានទី១៖ ការកំណត់បញ្ហា** (Define the Problem)

គឺជាជំហានដ៏សំខាន់ជាងគេក្នុង ដំណើរការស្រាវជ្រាវទីផ្សារ ហើយក៏ជាជំហានដ៏ពិបាកផងដែរ។ ការកំណត់បញ្ហាបានច្បាស់លាស់អាចនាំឲ្យការសម្រេចចិត្តទទួលបានលទ្ធផលល្អ ប្រសិទ្ធិភាពនៃការកំណត់បញ្ហាត ទៅលើ ៖

- **គោលបំណង** (**Objectives**)៖ គឺជាគោលដៅដែលអ្នកសម្រេចចិត្តចង់ទទួលបាននៅ ក្នុងការដោះស្រាយបញ្ហាអ្វីមួយ។ ឧទាហរណ៍៖ គោលដៅប្រតិបត្តិការទីផ្សារជាទទេ គឺបង្កើនប្រាក់ចំណូលប្រាក់ចំណេញ រកឱ្យឃើញនូវអ្វីដែលអ្នកប្រើប្រាស់ដឹង។ ចង់បាន និងរកឱ្យឃើញថាហេតុអ្វីបានជាផលិតផលលក់មិនដាច់។

- **ការកម្រិតកំណត់** (**Constraints**)៖ គឺសំដៅទៅលើការរាំងស្ទះទាំងឡាយដែលកើត មានចំពោះដំណោះស្រាយបញ្ហាដោយយោលទៅលើលក្ខណៈ និងសារៈសំខាន់នៃ បញ្ហានីមួយៗ។ បញ្ហារាំងស្ទះ ជាទូទៅនៅក្នុងការកំណត់បញ្ហាប្រតិបត្តិការទីផ្សារ ៖ច្រើនតែទាក់ទងទៅនឹងការកម្រិតកំណត់អំពីថវិការ និងពេលវេលាដែលមាន សា ដោះស្រាយបញ្ហា។ នៅក្នុងដំណោះស្រាយបញ្ហាគំនិត និងទស្សនៈយល់ឃើញ របស់មនុស្សក៏ជាបញ្ហារាំងស្ទះមួយដែរ។

-**ការសន្និដ្ឋាន** (**Assumptions**)៖ **ឧទាហរណ៍**៖ ដូចជាក្រុមហ៊ុនផលិតប្រដាប់ក្មេងលេងបានធ្វើការប៉ាន់ស្មានទៅលើកម្រិតនៃរយៈពេលមួយដែលក្មេងម្នាក់ៗអាចនឹងចំណាយ ក្នុងការលេងប្រដាប់លេងនីមួយៗ។

**- ការវាស់កម្រិតជោគជ័យ (Measures of Success)៖** ដើម្បីទទួលបានប្រសិទ្ធិភាពខ្ពស់ អ្នកសម្រេចចិត្តត្រូវបង្កើតឲ្យមាននូវកម្រិតស្តង់ដាមួយក្នុងការវាស់នូវកម្រិតជោគជ័យ នៃដំណោះស្រាយបញ្ហា ដែលគេបានដាក់ស្នើរឡើង។ ឧទាហរណ៍៖ បើសិនជា ក្រុមហ៊ុនផលិតប្រដាប់ក្មេងលេង (Toys_Manufacturer) កំណត់យកស្តង់ដានៃការ វាស់វែងជោគជ័យ គឺជារយៈពេលដែលក្មេងម្នាក់ៗចំណាយក្នុងការលេងប្រដាប់លេង នីមួយៗ ពេលនោះការវាស់វែងត្រូវបានគេធ្វើឡើងតាមរយៈការអង្កេតទៅលើក្មេង ដែលកំពុងលេងប្រដាប់លេងពីរ៖ មួយម៉ូតចាស់ និងមួយទៀតទើបបង្កើតថ្មី។ ឯលទ្ធផលនៃការវាស់នេះ គឺជាជោគជ័យមួយដែលនឹងបង្ហាញដូចខាងក្រោម៖

| លទ្ធផលនៃទិន្នន័យដែលអង្កេតបាន | សកម្មភាពប្រតិបត្តិការទីផ្សារ |
|---|---|
| ក្មេងទាំងនេះបានចំណាយពេលច្រើនក្នុងការលេងប្រដាប់លេងម៉ូតចាស់។ | បន្តធ្វើអាជីវកម្មម៉ូតចាស់ និងមិនចាប់ផ្តើមម៉ូតដែលទើបបង្កើតថ្មីទេ។ |
| ក្មេងទាំងនេះចំណាយពេលច្រើន ក្នុងការលេងប្រដាប់លេងម៉ូតថ្មី។ | ចាប់ផ្តើមធ្វើអាជីវកម្មលើប្រដាប់លេងម៉ូតថ្មី និងបោះបង់ចោលម៉ូតចាស់។ |

លទ្ធផលនៃការវាស់វែងតាមរយៈការអង្កេតនេះ តម្រូវឲ្យមានសកម្មភាពប្រតិបត្តិការទីផ្សារផ្សេងៗ អាស្រ័យនឹងទិន្នន័យដែលទទួលបាន។ បើសិនជាលទ្ធផលនៃការអង្កេតខាងលើ វានាំទៅដល់សកម្មភាពនៃប្រតិបត្តិការទីផ្សារដូចៗគ្នា មានន័យថាក្មេងៗទាំងនោះចូលចិត្ត និងចំណាយពេលនេះ អ្នកគ្រប់គ្រងត្រូវសម្រេចចិត្តបន្តអនុវត្តម៉ូតចាស់ដដែល ហើយការស្រាវជ្រាវនៅពេលនេះ គឺគ្រាន់តែជាការខាតបង់ពេល លុយកាក់ និងកិច្ចខំប្រឹងប្រែងរបស់អ្នកគ្រប់គ្រង។ បើសិនជាការកំណត់បញ្ហាត្រូវបានគេ យកចិត្តទុកដាក់បំផុតនោះ លទ្ធផលដែលទទួលបានហាក់ដូចជាជួយអ្នកគ្រប់គ្រងបាន ៥០% ទៅហើយ។ តែទោះបីជាយ៉ាងណាក៏ដោយ យើងនៅតែទទួលស្គាល់ថា ការកំណត់បញ្ហាគឺជាកិច្ចការដ៏លំបាកមួយសម្រាប់អ្នកស្រាវជ្រាវ ដោយហេតុថាបើបំណងដែលបានកំណត់ពីខាងដើមវាទូលំទូលាយពេក (Objectives are too broad) នោះការស្រាវជ្រាវបញ្ហាពិបាក និងអនុវត្តទៅរួចណាស់។ តែបើគោលបំណងនោះវាមានកម្រិតចង្អៀតពេក (Objectives are too narrow) ពេលនោះ អត្ថប្រយោជន៍ដែលនឹងទទួលបាន ពីការស្រាវជ្រាវនេះវាមានកម្រិតតិចតួចពេក។

ហេតុដូច្នេះហើយបានជាអ្នកស្រាវជ្រាវប្រតិបត្តិការទីផ្សារ ត្រូវចំណាយពេលដ៏ច្រើនក្នុងការកំណត់បញ្ហាប្រតិបត្តិការទីផ្សារឲ្យ បានជាក់លាក់នៅពេលដំបូង និងសរសេរនូវគម្រោងសំណើ ជាផ្លូវការមួយអំពីសកម្មភាពស្រាវជ្រាវប្រតិបត្តិការទីផ្សារ អ្វីខ្លះដែលត្រូវអនុវត្តបន្តទៀត។

**ខ.ជំហានទី២៖ ការវាយតម្លៃលក្ខណ្ឌ័នៃការសម្រេចចិត្ត** (Assess the decision factors)

នៅក្នុងជំហាននេះ អ្នកធ្វើការសម្រេចចិត្តត្រូវជួបបញ្ហាប្រឈមមុខផ្សេងទៀតក្នុងការកំណត់ឱ្យបានច្បាស់អំពីជម្រើសផ្សេងៗ (Alternatives) ដែលត្រូវបានគេគិតថាសមហេតុផលក្នុងការ ផ្តល់ដំណោះស្រាយដ៏សមរម្យមួយ និងភាពមិនជាក់លាក់ (Uncertainties) ទាំងឡាយដែល អាចជះឥទ្ធិពលទៅលើជម្រើសណាមួយ ក្នុងការសម្រេចចិត្តហើយនាឲ្យស។ ស្រាយបញ្ហាអាចមានផលល្អ និងផលអាក្រក់។

❖ **ជម្រើសផ្សេងៗ** (Alternatives)

ការសម្រេចចិត្តដ៏ល្អមួយ គឺត្រូវតែជាលទ្ធផលនៃការជ្រើសរើសពីក្នុងចំណោមជម្រើសដ៏សំខាន់ៗ ជាច្រើនទៀតនៃដំណោះស្រាយបញ្ហា ដែលអាចនឹងផ្តល់លទ្ធផលបានប្រសើបំផុត។ វិធីដែលគេនិយមប្រើក្នុងការកំណត់ យកជម្រើសណាមួយនៅពេលធ្វើការសម្រេចចិត្តនោះគឺ អ្នកសម្រេចចិត្តទាំងឡាយ តែងតែចោទសួរថា៖ · តើយើងអាចធ្វើតាមរបៀបណាផ្សេងៗទៀតទេ? -in what ways can we...?

**ឧទាហរណ៍៖** តើយើងអាចនឹងផ្សព្វផ្សាយកម្មវិធីសិក្សានៅមហាវិទ្យាល័យ របស់យើងទៅកាន់សិក្សានុសិស្ស ដែលទើបតែប្រឡងបញ្ចប់វិទ្យាល័យដោយរបៀប ណាខ្លះ? តើយើងមានវិធីអ្វីផ្សេងទៀតក្នុងការនាំយកផលិតផលម៉ូតចាស់របស់យើង ទៅកាន់អ្នកប្រើប្រាស់នៅកន្លែងថ្មីទៀត? ការផ្តួចផ្តើមគំនិតអំពីជម្រើសផ្សេងៗមិនមែន ជាកិច្ចការដ៏ងាយស្រួលមួយទេ អ្នកដែលមានគំនិតច្នៃប្រឌិតកម្រិតខ្ពស់ទើបអាចបង្កើត ឲ្យមានជម្រើសល្អៗក្នុងការសម្រេចចិត្ត។ មធ្យោបាយដ៏មានប្រសិទ្ធិភាពដែលពួកគេ និយមអនុវត្តគឺគេនិយាយជាមួយអ្នកប្រើប្រាស់ គេផ្លាស់ប្តូរគំនិតជាមួយសហការី របស់គេ គេបង្កើតឲ្យមានការជជែក ផ្តល់យោបល់ជាផ្លូវការ និងធ្វើការសិក្សាយ៉ាង យកចិត្តទុកដាក់អំពីសកម្មភាពរបស់គូប្រជែងទាំងឡាយ។ សកម្មភាពទាំងនេះអាច ផ្តល់លទ្ធភាពឲ្យអ្នកស្រាវជ្រាវបង្កើតបាននូវជម្រើសជាច្រើនក្នុងការសម្រេចចិត្តអំពីដំណោះស្រាយបញ្ហាអ្វីមួយ។

❖ **ភាពមិនជាក់លាក់** (Uncertainties)

គឺជាកត្តាជះឥទ្ធិពលលើការសម្រេចចិត្តទាំងឡាយដែលពិបាកនឹងកំណត់ឲ្យដឹងមុន។ ភាពមិនប្រាកដ ឬ មិនច្បាស់លាស់នៅក្នុងការ សម្រេចចិត្តអាចពាក់ព័ន្ធនឹងកត្តាជាច្រើនទៀតនៅក្នុងក្រុមហ៊ុន ឬ ពាក់ព័ន្ធទៅនឹង អ្នកប្រើប្រាស់គូប្រជែង កិច្ចការជាតិ និងអន្តរជាតិ ឬ បរិស្ថាន ឬ អាកាសធាតុដែលនៅជុំវិញការសម្រេចចិត្ត។ ឧទាហរណ៍៖ ដូចជាការសំរេចិត្តអំពីការតម្លើងម៉ាស៊ីនលាង រថយន្តស្វ័យប្រវត្តិនៅតាមស្ថានីយលក់ប្រេងទាំងឡាយ មិនមែនសុទ្ធតែជាការ សម្រេចចិត្តដែលនឹងផ្តល់ដំណោះស្រាយល្អទាំងអស់នោះទេ។ អ្នកគ្រប់គ្រងគិតថា គេអាចនឹងដណ្តើមអតិថិជនពីភ្នាក់ងារផ្តល់សេវាលាងរថយន្តជាច្រើនទៀត បើដំឡើងម៉ាស៊ីនលាងស្វ័យប្រវត្តិមួយនៅក្នុងស្ថានីយចាក់ប្រេងរបស់គេ ដោយយកតម្លៃសមរម្យ និងមិនតម្រូវឲ្យអតិថិជនរង់ចាំយូរឡើយ ប៉ុន្តែភាពមិនច្បាស់លាស់ គឺនៅត្រង់ថាអតិថិជនភាគច្រើនបែរជាគិតថាម៉ាស៊ីនលាងស្វ័យប្រវត្តិអាច នឹងធ្វើឲ្យឆ្កូតថ្នាំរថយន្តរបស់គេ ហើយលាងក៏មិនបានស្អាតផង។

### គ. ជំហានទី 3៖ ការប្រមូលទិន្នន័យ (Collect relevant Information)

ជាទូទៅ មានព័ត៌មានបីប្រភេទដែលសំខាន់ និងជួយដល់អ្នកគ្រប់គ្រងក្នុងការដោះស្រាយបញ្ហាម៉ាឃីតធីង ព័ត៌មានអំពីគំនិតផលិតផល (Product Concept) វិធីសាស្រ្ត (Methods) និង ទិន្នន័យ (Data)។

❖ **.គំនិតផលិតផល (Product Concept)**

គំនិតផលិតផល គឺជាគំនិតលំអិតអំពីផលិតផលដែលត្រូវបង្កើតឡើងហើយក្រុមហ៊ុនអាចនឹងលក់នៅលើទីផ្សារ។

ឧទាហរណ៍៖ ដូចជា គំនិតអំពីការបន្ថែមលក្ខណៈពិសេសទៅលើរថយន្តសេរីថ្មីៗ ដូចជាបន្ថែមប្រព័ន្ធសុវត្ថិភាព ពោងខ្យល់ (Airbag Systems) សម្រាប់ការពារអ្នកដំណើរ ដែលអង្គុយនៅកៅអីខាងក្រោយ។

❖ **.វិធីសាស្រ្ត (Methods)**

អ្នកប្រើប្រាស់រាប់លាននាក់ ត្រូវគេសួរសំណួរតាមរបៀប ដូចៗគ្នាអំពីផលិតផល និងសេវាកម្មរាប់លានប្រភេទ។ ដូច្នេះយើងគួរស្វែងរកនូវ វិធីសាស្រ្តល្អៗផ្សេងទៀត ដែលអ្នកស្រាវជ្រាវប្រតិបត្តិការទីផ្សារជាច្រើនបានអនុវត្ត ប្រកបដោយជោគជ័យ។ ព័ត៌មានអំពីវិធីសាស្រ្តដ៏មានប្រសិទ្ធិភាពទាំងនេះមាននៅ ក្នុងសៀវភៅពាណិជ្ជកម្ម (Trade Books) សៀវភៅសិក្សា (Textbooks) និងសៀវភៅដៃ (Handbooks)ផ្សេងៗទៀត ដែលពន្យល់អំពីប្រតិបត្តិការទីផ្សារ និងការស្រាវជ្រាវប្រតិបត្តិការទីផ្សារ។ ពេលខ្លះព័ត៌មានអំពីវិធីសាស្រ្តស្រាវជ្រាវនេះក៏រកបានផងដែរនៅតាមទស្សនាវដ្តីប្រតិបត្តិការទីផ្សារ ដូចជា ទស្សនាវដ្តីដែលសរសេរអំពីវិធីសាស្រ្ត និងការស្រាវជ្រាវប្រតិបត្តិការទីផ្សារ។ វិធីសាស្រ្តដែលគេនិយមប្រើក្នុងការស្រាវជ្រាវ ប្រតិបត្តិការទីផ្សារគឺការជ្រើសរើសគម្រ_ (Sampling) និងការសន្និដ្ឋានស្ថិតិជារួម (Statistical Inference)។ Sampling មានន័យថាអ្នកស្រាវជ្រាវបានជ្រើសរើសយក ក្រុមនៃអតិថិជនឬអតិថិជនគោលដៅណាមួយយកមកសួរសំណួរដែលទាក់ទង ទៅនឹងបញ្ហាដែលគេចង់ដឹង។

**ឧទាហរណ៍៖** ឧបមាថាមហាវិទ្យាល័យ ភូមិន្ទកសិកម្ម មាននិស្សិត ចំនួន១០០០នាក់ បានបញ្ចប់ការសិក្សាកាលពីឆ្នាំកន្លងទៅ ហើយអ្នកគ្រប់គ្រងមហាវិទ្យាល័យចង់ដឹងថា តើ និស្សិតទាំង១០០០នាក់នៅទីណា និងកំពុងបំពេញកិច្ចការអ្វីខ្លះ។ ដើម្បីបានព័ត៌មាននេះ តើមហាវិទ្យាល័យចាំបាច់ត្រូវធ្វើការទាក់ទងជាមួយនិស្សិតបញ្ចប់ការសិក្សាទាំង១០០០នាក់នោះ។ ការទំនាក់ទំនងជាមួយ និស្សិតទាំងអស់អាចនឹងចំណាយច្រើន។ វិធី Samplingអាចឱ្យមហាវិទ្យាល័យធ្វើការសន្និដ្ឋានអំពីកិច្ចការរបស់និស្សិតទាំង១០០០នាក់ គ្រាន់តែធ្វើទំនាក់ទំនងតែជាមួយនិស្សិតមួយចំនួនតូចប៉ុណ្ណោះ។ ភូមិន្ទកសិកម្ម សម្រេចធ្វើការ ទាក់ទងជាមួយនិស្សិតតែ៥០នាក់ប៉ុណ្ណោះ ដើម្បីទទួលបានព័ត៌មានទាំងនេះ។ បញ្ហាដែលសំខាន់នោះគឺនិស្សិតណាខ្លះដែលនឹងត្រូវទំនាក់ទំនងជាមួយ ដើម្បីឲ្យ

ចេះ... របស់គេអាចតំណាងឱ្យចម្លើយរបស់និស្សិត៩៥០នាក់ទៀតដែលមិនត្រូវបានគេទំនាក់ ជាមួយ។ ការជ្រើសគម្រូដោយចៃដន្យ (Probability Sampling) គឺជាវិធីមួយដែលគេ អនុវត្តដោយគ្រាន់តែដាក់ឈ្មោះនិស្សិតទាំង១០០០នាក់ ទៅក្នុងប្រអប់មួយ ហើយចា យកតែ៥០នាក់ពីក្នុងប្រអប់នោះ គឺស្រដៀងគ្នានឹងការចាប់យកសន្លឹកឆ្នោតផ្សងសំណាង ពីក្នុងធុងសន្លឹកឆ្នោតដូច្នោះដែរ។ យើងឃើញថា ឱកាសដែលនិស្សិតទាំង១០០០នាក់ អាចនឹងត្រូវបានជ្រើសរើសមករសំណួរមានស្មើៗគ្នាគឺ ៥០/១០០០ ឬ ០.០៥។ វិធី នេះអាចជួយឱ្យអ្នកគ្រប់គ្រងមហាវិទ្យាល័យជ្រើសរើសនិស្សិតគម្រូ (Simple) ៥០នាក់ដើម្បីធ្វើការទាក់ទងព័ត៌មានដែលគេចង់ដឹង និងធ្វើការសន្និដ្ឋានពីកិច្ចការរបស់និស្សិត ទាំង១០០០នាក់ (Population) នោះ។

**ការសន្និដ្ឋានស្ថិតិរួម (statistical inference)៖** គឺជាការសន្និដ្ឋានអំពី Population ឬ ក៏និស្សិតទាំង១០០០នាក់ ឬ ប្រជាជនទាំងមូល ឬ ផលិតផលទាំងអស់ ឬ អ្នកប្រើប្រាស់ ទាំងអស់ ដោយយោងទៅតាមព័ត៌មានដែលទទួលបានពីការសិក្សាទៅលើ Sample នៃ Population នីមួយៗ។ បើការជ្រើសរើសSample បានល្អដូចជាការប្រើវិធីជ្រើសរើស ដោយ ចៃដន្យខាងលើនោះ ការសន្និដ្ឋានអំពី Population ក៏មានប្រសិទ្ធិភាពខ្ពស់ដែរ។

❖ .**ទិន្នន័យ (Data)**

គឺជាអង្គហេតុ (Facts) និងតួលេខ (Figures) ដែលពាក់ព័ន្ធទៅនឹង បញ្ហាដែលត្រូវធ្វើការសិក្សា។ ទិន្នន័យចែកចេញជាពីរប្រភេទគឺៈទិន្នន័យប្រភេទទីពីរ (Secondary Data) និង ទិន្នន័យប្រភេទទីមួយ (Primary Data)។ មើលរូបភាព២៨៖

• **ទិន្នន័យប្រភេទទីមួយ (Primary Data)៖** គឺជាទិន្នន័យដែលមិនទាន់ចុះផ្សាយ និង ទើបតែប្រមូលបានថ្មីៗ។

• **ទិន្នន័យប្រភេទទីពីរ (Secondary Data)៖** គឺជាទិន្នន័យដែលកើតមានរួចហើយ និងត្រូវបានគេកត់ត្រាទុក និងចុះផ្សាយ។ គេអាចរកទិន្ន័យនេះបានពីប្រភពពីរគឺ ប្រភព ខាងក្នុង (Internal Secondary Data) ដែលមានកត់ត្រាទុកនៅក្នុងអង្គការ ឬ ស្ថាបន! អាជីវកម្មផ្សេងៗ។ ដូចជាទិន្នន័យអំពីការលក់របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍ស្រាវជ្រាវ សំបុត្រពីអតិថិជន របាយការណ៍លក់ បរិមាណទំនិញដែលអតិថិជនបញ្ជារ ទិញទំនិញដែលមាននៅក្នុងស្តុក ចំនួនទូរស័ព្ទដែលអតិថិជនហៅចូលមកក្រុមហ៊ុន។ ចំណែកឯប្រភពខាងក្រៅ (External Secondary Data) វិញ គឺទិន្នន័យដែលមាន ចុះផ្សាយនៅតាមឧបករណ៍ផ្សព្វផ្សាយផ្សេងៗដែលមិនមាននៅក្នុងក្រុមហ៊ុន ឬអង្គការទាំងនោះ។ ដូចជា ទិន្នន័យចុះផ្សាយនៅតាមកាសែត ទស្សនាវដ្តី វិទ្យុ ទូរទស្សន៍ព្រឹត្តិប័តព័ត៌មានពាណិជ្ជកម្ម និងក្រសួងស្ថិតិរបស់រដ្ឋាភិបាលតាម Internet។ ល។

មានតែមធ្យោបាយពីរប៉ុណ្ណោះដែលគេអនុវត្តក្នុងការប្រមូលទិន្នន័យប្រភេទនេះ គឺតាមរយៈការអង្កេត (Observing) និងសួរសំណួរ (Asking Questions) អតិថិជន ឬ អ្នកប្រើប្រាស់ ឬ មនុស្សទាំងអស់ដែលគេបានជ្រើសរើស។ ទិន្នន័យដែលបានពីការអង្កេតមានដូចជា ការអង្កេតមើលសកម្មភាពអាកប្បកិរិយារបស់អតិថិជននៅពេលទិញផលិតផលដែលភ្នាក់ងារអង្កេតអាចធ្វើឡើងដោយ

ផ្ទាល់ ឬ តាមរយៈឧបករណ៍ផ្សេងៗ ដូចជា TV កាមេរ៉ាថតរូបភាព ឬ បុគ្គលិកលក់ ឈរមើលសកម្មភាពរបស់អតិថិជនដោយផ្ទាល់នៅតាមកន្លែងលក់ទាំងឡាយ។ ចំណែកឯ ទិន្នន័យដែលបានពីការសួរសំណួរ (Questionnaire Data) គឺសំដៅទៅលើអង្គហេតុ និងតួលេខ ដែលទទួលបានពីការសួរអតិថិជន ឬ អ្នកប្រើប្រាស់អំពីឥរិយាបថ ការយល់ដឹងចំណាប់អារម្មណ៍និងអាកប្បកិរិយារបស់ពួកគេ។ ដោយហេតុថា សំណួរជាច្រើនអាចនឹងត្រូវបានគេសួរនៅក្នុងតារាងសំណួរ (Questionnaire) ដូចនេះអ្នកស្រាវជ្រាវគួរតែផ្តោតទៅលើសំណួរណាដែលឆ្លើយតបនឹងបញ្ហាប្រតិបត្តិការទីផ្សារដែលកំពុងតែចោទឡើង។ ការសួរសំណួរអាចធ្វើឡើងតាមរយៈការសម្ភាសដោយផ្ទាល់ ឬ តាមទូរស័ព្ទ ឬ សុំឲ្យអតិថិជនសរសេរចម្លើយនៅក្នុងតារាង គេបានរៀបចំទុក។ ជាទូទៅសំណួរមានលក្ខណៈជាសំណួរបើក (Open-end Question) សំណួរបិទ (Closed-end Question)។

ដើម្បីធ្វើឲ្យច្បាស់បញ្ហាកំណត់បានបុព្វហេតុត្រូវប្រមូលបន្ថែមទិន្នន័យ ពេលសហគ្រាសចង់ប្រមូលព័ត៌មានអំពីលក្ខណៈពិសេសកម្លាំងជំរុញអប្បកិរិយារបស់អ្នកប្រើប្រាស់ដែរតិចពេលណាស់នឹងអាចរកឃើញក្នុងឯកសារមានស្រាប់។ បាតុភូតដូចនេះគេត្រូវអនុវត្តវិធីសាស្ត្រស្រាវជ្រាវកើតឡើងពីការអង្កេតដោយជួបប្រាស្រ័យផ្ទាល់។ វិធីសាស្ត្រនេះយកចិត្តទុកដាក់ជាសំខាន់ប្រមូលព័ត៌មានអំពីគំនិតនិងឆ្លងតាមទំនាក់ទំនងផ្ទាល់ជាមួយពាណិជ្ជករនិងអ្នកប្រើប្រាស់។ តាមទ្រឹស្តីអង្កេតដោយផ្ទាល់អ្នកមិនគិតឃើញអាចវាយតម្លៃអ្នកប្រើប្រាស់ដោយការអង្កេតនិងស្រាវជ្រាវផ្នែកគំរូរបស់ពួកគេអ្នកប្រើប្រាស់។ តម្លៃតម្លៃរបស់ព័ត៌មាននោះពឹងផ្អែកជាសំខាន់ទៅនឹងគុណភាពឬលក្ខណៈពិសេសនិមិត្តរូបរបស់ផ្នែកគំរូ។

ដើម្បីអាចបង្កើតចេញជារូបរាងនៃផ្នែកគំរូដែលមានលក្ខណៈជាតំណាងនៃអ្នកប្រើប្រាស់ជាទូទៅជាដំបូងចាំបាច់ត្រូវកំណត់ច្បាស់លាស់អ្នកប្រើប្រាស់ទាំងមូលដែលសហគ្រាសយកចិត្តទុកដាក់ក្រោយមកគេដំណើរការជ្រើសរើសផ្នែកគំរូតាមវិធីសាស្ត្រជ្រើសរើសគំរូផ្សេងបីទៀតខុសគ្នា។ ក្នុងភាពជាក់ស្តែងគេតែងប្រើប្រាស់វិធីសាស្ត្រជ្រើសរើសចៃដន្យឬប្រូបាបបីលីទេនិងវិធីសាស្ត្រសមាមាត្រ។ ក្នុងវិធីសាស្ត្រស្រណោះណាអ្នកអង្កេតត្រូវគោរពរាល់សមាមាត្រត្រូវគ្នានៅក្នុងសមាមាត្ររួមឧទាហរណ៍ៈ សមាមាត្ររវាងបុរសនឹងនារី អាយុ......។

រាល់ឯកសារប្រមូលពីការអង្កេតដោយផ្ទាល់សុទ្ធតែមានកម្រិតលម្អៀងស្ថិតិ។ នោះគឺជាការលម្អៀងដោយចៃដន្យ។ ចាំបាច់ត្រូវកំណត់លីមីតរបស់កម្រិតលំអៀងនេះ។

វាអាស្រ័យចំនួនគំរូបានជ្រើសរើស។ ជាមួយលក្ខខណ្ឌដូចគ្នាចំនួនគំរូកាន់តែច្រើននោះលីមីតលំអៀងកាន់តែទាប។

ជាធម្មតា គេប្រើវិធីសាស្ត្រអង្កេតដោយផ្ទាល់ខាងក្រោមនេះ ដើម្បីប្រមូលទិន្នន័យប្រភេទនីមួយៗ។

### ក.វិធីសាស្ត្រអង្កេតអាចិន្ត្រៃយ៍

វិធីសាស្ត្រអង្កេតប្រមូលរកព័ត៌មានពិការតាមដាប់ជានិច្ចទម្លាប់ឬប្រតិកម្មរបស់អតិថិជនក្នុងឯកទេសជំនាញដោយឡែកណានោះនិងទទួលស្គាល់សេចក្តីសប្បាយឬការប្អូនតែងរបស់ពួកគេ។ ព័ត៌មាននេះអាចប្រមូលរើសឆ្លងការអង្កេតរបស់មនុស្សឬគ្រឿងម៉ាស៊ីន។

ឧទាហរណ៍ៈម៉ាស៊ីនអ្នកនាយស្វ័យប្រវត្តិដាក់នៅផ្លូវខ្វែងអាចកត់ត្រាបានបរិមាណរថយន្តទៅមកនៅពេលវេលាកំណត់។ អេក្រង់ក្នុងsupអនុញ្ញាតឲ្យអង្កេតការជ្រើសរើសរបស់អតិថិជនចំពោះផលិតផលមួយចំពោះផ្លាកសញ្ញាណានោះ។

វិធីសាស្ត្រអង្កេតមើលនេះរួចចាន់ផុតពីភាពគំនួសនិងច្បាស់លាស់គួរសម។ រាល់ឯកសារបានប្រមូលយ៉ាងឆាប់រហ័ស។ ប៉ុន្តែវាគ្រាន់តែអាចឲ្យដឹងបាននូវអ្វីដែលអតិថិជនកំពុងធ្វើតែមិនអាចពន្យល់បានសមហេតុផលថាហេតុអ្វីក៏ពួកគេធ្វើដូច្នេះឡើយពីព្រោះមិនអាចប្រមូលបានរាល់គំនិតឬកឃើញទស្សនៈអាកប្បកិរិយាឬមតិយោបល់របស់អតិថិជនទេ។

## ខ.វិធីសាស្ត្រដាក់សំណួរអង្កេត

វិធីសាស្ត្រនេះអាចដំណើរការដោយរបៀបធ្វើសំបុត្រតាមបែបឆ្លើយតបតាមទូរស័ព្ទឬធ្វើការសំភាសន៍ដោយផ្ទាល់។ របៀបដំណើរការ1/3 សិក្ខាមានគុណសម្បត្តិនិងគុណវិបត្តិរបស់វា។

### ➢ អង្កេតដោយសំបុត្រតាមប្រៃសណីយ៍

អង្កេតដែលសំបុត្រទាមទារត្រូវបង្កើតបានសំណួរហើយផ្ញើទៅអតិថិជនដែលបានជ្រើសរើសតាមទ្រឹស្តីជ្រើសរើសគំរូជាមួយចម្លើយសំណួរសំណួមពរគឺអ្នកនោះចូលឆ្លើយនឹងកត់ចូលក្នុងទំនេររួចហើយផ្ញើត្រឡប់មកនៅតាមតារាងសំនួរនោះ។

វិធីសាស្ត្រនេះមានគុណសម្បត្តិដូចខាងក្រោម

+ចំណាយទាបការអង្កេតទូលំទូលាយ

+អ្នកឆ្លើយអាចដោះស្រាយគ្រប់គ្រាន់សំណួរដោយរបៀបមួយស្ងាត់កំបាំងនឹងមានភាពងាយស្រួលចំពោះពួកគេ។

+អ្នកឆ្លើយឲ្យទទួលរងឥទ្ធិពលដោយភាពលម្អៀងតាមទស្សនៈរបស់អ្នកទៅសម្ភាស។

គុណវិបត្តិរបស់វិធីសាស្ត្រអង្កេតជាសំបុត្រតាមបៃប្រសណីយ៍គឺៈ

+អាចលេចចេញនៅស្ថានភាពសមាតចំនួនអ្នកឆ្លើយតបមានកម្រិតទាបប្រៀបជាមួយសំបុត្រផ្ញើសរុប។ ប្រការនោះនាំឱ្យច្រើនឡើងនៅចំណាយគណនាលើរាល់ការតារាងចម្លើយ។

+អ្នកឆ្លើយអាចបានពិតជាអ្នកតំណាងឲ្យភ្ញៀវទាំងអស់ពិសេសគឺពេលចំនួនអ្នកមិនឆ្លើយមានសមាមាត្រធំ។

### ➢ អង្កេតដោយរបៀបសម្ភាសផ្ទាល់

របៀបអង្កេតនេះមានគុណសម្បត្តិដូចខាងក្រោមៈ

+អនុញ្ញាតឱ្យអ្នកទៅសម្ភាសរៀបចំទៅតាមស្ថានភាពជាក់ស្ដែង។ ឧទាហរណ៍ គេអាចដាក់ឡើងវិញនូវសំណួរឬសួរបន្ថែមពេលចម្លើយមិនទាន់បំពេញបាន។

+កម្រិតពិតប្រាកដអាចទទួលបានខ្ពស់ព័ត៌មានបានជ្រើសរើសច្រើនជាងទៀតទៅនឹងការអង្កេតដោយសំបុត្រតាមប្រៃសណីយ៍។

គុណវិបត្តិរបស់វិធីសាស្ត្រសម្ភាសន៍ដោយផ្ទាល់គឺ

+ ចំណែកខ្ពស់និងស៊ីពេលវេលាច្រើនដើម្បីដំណើរការ

+គំនិតរបស់អ្នកទៅសម្ភាសន៍អាចមានឥទ្ធិពលដល់អ្នកបានគេសម្ភាសនិងអាចធ្វើឲ្យខុសពីលទ្ធផលប្រមូលបាន។

➢ **អង្កេតតាមទូរសព្ទ**

មានជាដំបូងនូវគុណវិបត្តិនិងគុណសម្បត្តិដូចគ្នានិងការអង្កេតសម្ភាសន៍ដែលផ្ទាល់ប៉ុន្តែរបៀបអង្កេតនោះជួយសម្រួលអត់ដែលចំណាយជាងនិងស៊ីពេលវេលាតិចជាង។ ម្យ៉ាងទៀតដោយមានពេលវេលាកំណត់ក្នុងការនិយាយឆ្លើយឆ្លងតាមទូរស័ព្ទ។ សៀវភៅពិសេសគឺទូរសព្ទនៅតាមផ្លូវវែង និងការអង្កេតក្នុងលក្ខខណ្ឌដែលប្រទេសយើងមានការលំបាកដោយការរៀបចំទូរសព្ទមិនទាន់បានជាសាធារណៈសូម្បីតែនៅក្នុងទីក្រុងក៏ដោយ។

## គ.វិធីសាស្ត្រអង្កេតស៊ីជម្រៅ

វិធីសាស្ត្រនេះបានប្រើដើម្បីប្រមូលព័ត៌មានខ្លឹមសារជាតិជាមួយការមានកម្លាំងជម្រុញការរារាំងមិនឲ្យទិញក៏ដូចជាមនោសញ្ចេតនាចំពោះសហគ្រាសជាមួយរូបរាងផលិតផល។ វិធីសាស្ត្រអង្កេតស៊ីជម្រៅមានរូបភាពដូចជាពិភាក្សាជាក្រុមលើចំណុចសម្ភារសន្និដ្ឋានបីទ្វារអតិថិជន...

ប្រការមួយចំនួនចាំបាច់ត្រូវយកចិត្តទុកដាក់ពេលបង្កើតការរាងសំនួរអង្កេតនិងពេលសម្ភាសដោយផ្ទាល់

+ ត្រូវចៀសវាងវាក្យស័ព្ទជំរៅពេក

+ ជានាងអក្សរមានន័យច្រើនវាស្រួលយល់

+ រាល់សំណួរពូសម្រាប់តែមានបញ្ហាមួយ

+ប្រសិនបើមានសំណួរមានលក្ខណៈបុគ្គលចូលទុកវានៅក្រោមតារាងរួម

+ជៀសវាងសំណួរមានចរិកបុគ្គលស្មុគស្មាញ

+បង្កលក្ខខណ្ឌសម្រាប់អ្នកឆ្លើយងាយស្រួលជ្រើសរើសពេលឆ្លើយ

ឧទាហរណ៍ ឆ្លើយ ល្អ ប្រសើរ ធម្មតាអន់ អានបំផុត គ្មានយោបល់ខាងក្រោមនេះគឺជាឧទាហរណ៍អំពីសំណួរក្នុងការអង្កេតផ្ទាល់ដើម្បីប្រមូលព័ត៌មានគំរូ តារាងសំណួររបស់អ្នកលក់ម្ហូបអាហារ ក្នុងតារាងសំនួរនេះចូលអ្នករីករាយគូរង្វង់មួយនៅលេខណាមួយរបស់គំរូសំណួរក្នុងសំណួរបួនខាងក្រោមកម្រិតតម្លៃពី 1 ដល់ 5 ជាមួយលេខមួយខ្សោយបំផុតនៅកម្រិតចុងក្រោយក្រោមគេហើយលេខ 5 ឬពិសេសបំផុតកម្រិតកំពូល។

តារាងទី១១២ សំណួរស្រាវជ្រាវ.

| |
|---|
| ១-អ្នកវាយតម្លៃការពេញចិត្តទាំងស្រុងរបស់អ្នកនៅក្នុងនៅក្នុងហាងលក់ម្ហូបអាហារយើងណា។ |
| ១ ២ ៣ ៤ ៥ |
| ២-អ្នកវាយតម្លៃគុណភាពផលិតផលអាហារយ៉ាងណា? |
| ១ ២ ៣ ៤ ៥ |
| ៣-អ្នកវាយតម្លៃការងារបម្រើយ៉ាងណា? |
| ១ ២ ៣ ៤ ៥ |
| ៤-ហាងលក់ទំនិញគប្បីធ្វើអ្វីទៀតប្រសិនបើចង់បែកដើម្បីបង្កើតនិងបង្កើនបន្ថែមរស់ជាតិដល់អ្នកដទៃ។ |
| ១ ២ ៣ ៤ ៥ |

**ឃ.ជំហានទី៤៖ ការបកស្រាយទិន្នន័យ (Interpreting the data)**

នៅពេលដែលទិន្នន័យ ប្រមូលរួចរាល់អស់ហើយ កិច្ចការបន្ទាប់គឺការបកស្រាយទិន្នន័យ។ ជាទូទៅទិន្នន័យត្រូវបានប្រមូលរួចរាល់អស់ដែលប្រមូលបានមកនៅមានលក្ខណៈ រាយប៉ាយ។

ឧទាហរណ៍៖ ដូចជាព័ត៌មានដែលមាននៅលើសំណួរដ៏ច្រើនសន្ធឹកសន្ធាប់ដែលភ្នាក់ងារស្រាវជ្រាវបានចុះសួរអតិថិជន។ ព័ត៌មាន អស់នេះអាចដូចៗគ្នាឬខុសគ្នាទៅតាមកម្រិតយល់ដឹងរបស់អ្នកឆ្លើយម្នាក់ៗ ហើយ ពត៌មានខ្លះមានតម្លៃ និងព័ត៌មានខ្លះមិនអាចយកជាការបាន។ អ្នកគ្រប់គ្រងប្រតិបត្តិការទីផ្សារ អាចមើលព័ត៌មានទាំងនេះហើយ ធ្វើការសន្និដ្ឋានអំពីការសម្រេចចិត្តរបស់គេបានទេ គឺ ទាមទារឲ្យអ្នកឯកទេសខាងបកស្រាយទិន្នន័យស្រង់ព័ត៌មានទាំងនេះ យកទៅតម្រៀប និងធ្វើការបកស្រាយដោយប្រើប្រក្រាមកុំព្យូទ័រជាជំនួយដើម្បីដកស្រង់យកអត្ថន័យនិងខ្លឹមសារពី ព័ត៌មានទាំងនោះ។ ប្រូក្រាមកុំព្យូទ័រដែលអ្នកវិភាគទិន្នន័យអនុវត្តក្នុងការបកស្រាយនេះមាន ដូចជា Microlab, Minitab, និង Excel។ ប្រូក្រាមកុំព្យូទរ័មាននាទីបកស្រាយព័ត៌មានដើម្បីឲ្យ ទៅជារូបភាពក្រាហ្វិក ឬភាគរយដែលមានលក្ខណៈសង្ខេបងាយយល់សម្រាប់អ្នកគ្រប់គ្រងប្រតិបត្តិការទីផ្សារយកមកវិភាគ ធ្វើការសន្និដ្ឋាន និងសម្រេចចិត្តអំពីដំណោះស្រាយបញ្ហា ប្រតិបត្តិការទីផ្សារ។ វិធីសាស្ត្រនៃការបកស្រាយទិន្នន័យនេះនឹងមិនពន្យល់នៅក្នុងសៀវភៅ នេះទេ ប៉ុន្តែអ្នកសិក្សាអាចធ្វើការស្រាវជ្រាវនិងស្វែងយល់នៅក្នុងផ្នែក ការគ្រប់គ្រងស្ថិតិជំនួញ (Business Statistics Management) ដែលមានពន្យល់យ៉ាងក្បោះក្បាយអំពីរបៀបនិងវិធីសាស្ត្រ ទាំងឡាយ នៃការបកស្រាយទិន្នន័យប្រតិបត្តិការទីផ្សារ។ តែទោះបីជាយ៉ាងណាក៏ដោយអ្នក គ្រប់គ្រងប្រតិបត្តិការទីផ្សារភាគច្រើនជាពិសេស គឺនៅតាមអង្គភាពអាជីវកម្មខ្នាតតូច (small business firms) តែងតែនិយមអនុវត្តវិធីបកស្រាយទិន្នន័យដ៏សាមញ្ញមួយគឺការវិភាគតាម តារាងខ្វែង (Cross tabulation analysis)។ យើងនឹងលើកយកវិធីសាស្ត្រវិភាគនេះ មកពន្យល់នៅពេលក្រោយគឺនៅត្រង់ចំណុចនៃការកាត់ចំណែកទីផ្សារ និងការកំណត់ទីផ្សារគោលដៅ។

**ង.ជំហានទី៥៖ វិនិច្ឆ័យព័ត៌មាន** (Analysing the information)

ក្រោយពេលព័ត៌មានចាំបាច់រៀបចំនិងវិភាគព័ត៌មានដោយប្រយ័ត្នប្រយែងនិងវិទ្យាសាស្ត្រ កំហុសធ្លងអាចកើតឡើងក្នុងដំណើរស្រាវជ្រាវប្រសិនបើការដោះស្រាយព័ត៌មានមិនបានប្រព្រឹត្តទៅបានត្រឹមត្រូវខ្វះវិធីសាស្ត្រវិទ្យាសាស្ត្រ។

បច្ចុប្បន្នការរៀបចំនិងបែងចែកប្រភេទវិនិច្ឆ័យព័ត៌មានអាចបានប្រព្រឹត្តទៅដោយការបង្កើតកម្មវិធីដាក់ចូលក្នុងម៉ាស៊ីនកុំព្យូទ័រ។ លើមូលដ្ឋានលទ្ធផលបកស្រាយប្រមូលបានចាំបាច់ដំណើរការវាយតម្លៃលទ្ធផលអង្កេតដោយផ្ទាល់នឹងដាក់ចេញវិធានការចាំបាច់។

ឧទាហរណ៍ៈលទ្ធផលបកស្រាយព័ត៌មាននៃការអង្កេតមួយអំពីអតិថិជនទិញរថយន្តថ្មីនៅទីក្រុងមួយក្នុងរយៈពេល 2ឆ្នាំ 1991 ដល់ឆ្នាំ 1992 ឲ្យដឹងថាក្នុងចំនួនអ្នកទិញរថយន្តថ្មី

- 89.4% ជាភេទប្រុស
- 85.9% មានគ្រួសារហើយ
- 88.9% ជាមេគ្រួសារ
- 70.6% ទិញរថយន្តថ្មីដើម្បីបើកទៅធ្វើការ
- 15.6% ដើម្បីបើកនាំកូនទៅរៀន

សមាមាត្រភាគរយអង្កេតតាមក្រុមអាយុនីមួយនីមួយប្រៀបធៀបជាមួយចំនួនអ្នកទិញរថយន្តថ្មីសរុបដូចខាងក្រោមៈ

| អាយុរបស់អ្នកទិញឬចេញថ្មី | សមាមាត្រ |
|---|---|
| ២០ឆ្នាំ | ២៨.០ |
| ២០-៣៤ឆ្នាំ | ២.២ |
| ៣៥-៤៤ឆ្នាំ | ២៨.៥ |
| ៤៥-៥៤ឆ្នាំ | ២០.៨ |
| ៥៥-៦៤ឆ្នាំ | ១២.០ |
| ≥៦៥ឆ្នាំ | ៤.៤ |

ឆ្លងតាមលទ្ធផលអង្កេតអាជីវករនិងនឹងដឹងថាគួរយកចិត្តទុកដាក់ចំពោះប្រភេទអតិថិជនណា?។ ត្រូវអនុវត្តសកម្មភាពម៉ាឃីតធីងចំពោះអតិថិជនគោលដៅយ៉ាងណា......,.។

➢ **ដោះស្រាយបញ្ហា**

នេះគឺជាដំណាក់កាលចុងក្រោយប៉ុន្តែមិនមែនជាផ្នែកមានសារៈសំខាន់។ ជាសំខាន់វាគឺជាមូលហេតុអតិភាពនៃដំណាក់កាលមុនទាំងអស់។

នៅដំណើរការនេះអ្នកគ្រប់គ្រងម៉ាឃីតជីងត្រូវចេះអនុវត្តលទ្ធផលស្រាវជ្រាវក្នុងការកសាងនិងកំណត់សម្រេកយុទ្ធសាស្ត្រ marketing មានលទ្ធផលល្អជ្រើសរើសបានទីផ្សារគោលដៅសម្របសម្រួលឧទាហរណ៍ចាំបាច់កែច្នៃផលិតផលយ៉ាងណា?។

ប្រសិនបើលទ្ធផលអង្កេតស្រាវជ្រាវមិននាំមកឲ្យសហគ្រាសនូវការណែនាំមានប្រសិទ្ធភាពដើម្បីកសាងយុទ្ធសាស្ត្រនិងផែនការម៉ាឃីតជីងក៏ដូចជាមិនដាក់ចេញបានសេចក្តីសម្រេចនិងវិធានការសមស្របដើម្បីលើកកម្ពស់ លទ្ធកម្មអាជីវកម្មឬទេនោះកម្លាំងពលកម្មនិងលុយកាក់ដែលបានចំណាយឱ្យការស្រាវជ្រាវគឺការខ្ជះខ្ជាយទាំងស្រុងហើយគោលដៅស្រាវជ្រាវមិនបានលទ្ធផល។ គេសុទ្ធតែយល់ថាកែវស្រាវជ្រាវគឺជាការចំណាយច្រើនបំផុត។ ការអង្កេតដោយផ្ទាល់ជាច្រើនចំណាយរាល់នារីរាប់ពាន់ដុល្លារ។ ប៉ុន្តែវាបានអនុញ្ញាតដោយបន្ថយបានគ្រោះថ្នាក់ច្រើនក្នុងអាជីវកម្មបង្កើនបានចំណូលអាជីវកម្ម និងនាំមកទិញប្រាក់ចំណេញយ៉ាងច្រើនឱ្យក្រុមហ៊ុននិងសហគ្រាសជាច្រើន។

## ១១.៥.៤.ការវិភាគចំណែកទីផ្សារដោយប្រើវិធីវិភាគតាមតារាងខ្វែង

( Analysing market segment using Cross Tabulations )

ឧបមាថា អ្នកចង់សិក្សាឲ្យបានលំអិតបន្ថែមទៀតទៅលើចំណែកទីផ្សារនៃភោជនីយដ្ឋាន ខាងលើរបស់អ្នក ដោយប្រើព័ត៌មានទីផ្សារដែលអ្នកបានស្រាវជ្រាវនៅក្នុងតារាងទី៥.២ខាងលើ។ ឬ ប្រើព័ត៌មានទាំងនេះ ក្នុងបំណងវិភាគឲ្យបានច្បាស់អំពីចំណែកទីផ្សារ និងបង្កើតយុទ្ធសាស្រ្តប្រតិបត្តិការទីផ្សារសម្រាប់ចំណែកទីផ្សារទាំងនោះ។ ជាដំបូងអ្នកត្រូវបង្កើតតារាងខ្វែង (cross tabulation) មួយសិនដែលតារាងបង្ហាញពីទិន្នន័យទាក់ទងទៅនឹងកត្តាកាត់ចំណែកទីផ្សារ ពីរ ឬ ច្រើន។ ចំណុចសំខាន់នៃតារាងខ្វែង គឺអ្នកត្រូវសម្រេចជ្រើសរើសយកកត្តាកាត់ចំណែកទីផ្សារពីរ (ឧ៖ អត្រាប្រើប្រាស់ និងអាយុ) មកផ្គូផ្គងគ្នាក្នុងតារាងមួយដើម្បីឲ្យយល់ពីស្ថានភាព និងលទ្ធផល។ តាមន័យនេះ បើផ្គូរផ្គងសំណួរទី៣ និង ទី៦យ នៅក្នុងតារាងទី៥.២ នោះអ្នកនឹងបានលទ្ធផលវិភាគតាមតារាងខ្វែងដូចក្នុងភាពទី៥.៣។ ការផ្គូរផ្គងនេះអាចធ្វើបានគ្រប់សំណួរទាំងអស់ប៉ុន្តែក្នុងករណីនេះអ្នកគ្រាន់តែ ដឹងថាតើនៅពេលដែលអាយុនៃអ្នកគ្រប់គ្រងគ្រួសារមួយកើនឡើង ពេលនោះការផ្គត់ផ្គង់ អាហារដូចជាប៊ីហ្គីសម្រាប់គ្រួសារនោះ នឹងត្រូវធ្លាក់ចុះដែរឬទេ? ដោយគ្រាន់តែប្តូរផ្គងសំណួរ ២ និងទី៦យ ក្នុងតារាងទី១ ដើម្បីអនុវត្តការវិភាគ តារាងខ្វែងហើយចម្លើយនៃសំណួរទី៣ត្រូវនៅក្នុងជួរឈរ និងចម្លើយនៃសំណួរទី ៦ ត្រូវចុះក្នុងជួរទឹងនៃតារាងខ្វែងដូចក្នុងរូបភាព ៥.៣។ ចម្លើយទាំងនេះ បានមកពីអ្នកឆ្លើយចំនួន៥៨៦នាក់។ តាមចម្លើយដែលបាននៅក្នុង បភាពទី៣៣ ក្នុងចំណុច ក នោះយើងឃើញថាមានគ្រួសារចំនួន ១៤៤ ដែលមានគ្រួសារ មាន អាយុ២៤ឆ្នាំ ឬ ក្មេងជាងបានញ៉ាំអាហារនៅភោជនីយដ្ឋានម្តង ឬច្រើនជាងម្តងក្នុងមួយសប្តាហ៍។ នៅក្នុងចំណុច ខ នៃរូបភាពទី៣៣ដដែលយើងឃើញថាចម្លើយត្រូវគិតជាភាគរយវិញ គឺក្នុង ចំណោមគ្រសារទាំង ២១៥ ដែលមានមេគ្រួសារអាយុ២៤ឆ្នាំ ឬក្មេងជាងនោះមាន ៦៧% ដែល ញ៉ាំនៅក្នុងភោជនីយដ្ឋានរបស់អ្នក យ៉ាងហោចណាស់ម្តងក្នុងមួយសប្តាហ៍ ហើយមានតែ ៨,៨% ប៉ុណ្ណោះដែលញ៉ាំម្តង ឬតិចជាងម្តងក្នុងមួយខែ។

### ក. ការបកស្រាយតារាងខ្វែង (Interpreting Cross Tabulations)

តាមការវិភាគនៅក្នុងរូបភាពទី៥.១ នោះបានបង្ហាញពីតម្រូវការម្ហូបអាហារនៅភោជនីយដ្ឋានរបស់អ្នក គឺទាក់ទងនឹងអាយុនៃមេមេគ្រួសារនីមួយៗ។ នៅពេលដែលអាយុនៃមេគ្រួសារនីមួយៗ កើនឡើងពេលនោះតម្រូវការម្ហូបនៅភោជនីយដ្ឋានបានធ្លាក់ចុះ ហេតុផលអាចបណ្តាលមកពី មេគ្រួសារក្មេងៗទាំងនេះមិនចង់ចំណាយពេលច្រើនដើម្បីរៀបចំអិនអាហារនៅក្នុងផ្ទះសម្រាប់ កូនៗរបស់គេ។ ដូច្នេះបើអ្នកចង់ផ្តោតទៅលើអតិថិជនដែលញ៉ាំអាហារនៅភោជនីយដ្ឋានរបស់ច្រើនជាងគេ (heavy users) នោះអ្នកគួរតែជ្រើសរើសយកអតិថិជន ដែលមានអាយុ ២៤ឆ្នាំ ឬ ក្មេងជាងធ្វើជាចំណែកទីផ្សារគោលដៅរបស់អ្នក។

### ខ. អត្ថប្រយោជន៍នៃតារាងខ្វែង (Value of Tabulations)

តារាងខ្វែងគឺវិធីសាស្រ្តនៃការតម្រៀប និងវិភាគទិន្នន័យប្រតិបត្តិការទីផ្សារមួយដែលគេ និយមប្រើច្រើនបំផុត ដោយហេតុថា វាផ្តល់នូវអត្ថប្រយោជន៍សំខាន់ៗច្រើន ដូចជាការផ្តល់ ភាពងាយស្រួលក្នុងការបកស្រាយទិន្នន័យ និងទំនាក់ទំនងទនិន្ន័យទៅនឹងអ្នកគ្រប់គ្រង។ វិធីសាស្រ្តនេះងាយហើយអាចបកស្រាយទិន្ន័យ ដែលទទួលបានពីការធ្វើពិសោធន៍ (experiment data) ទិន្នន័យដែលបានពីការអង្កេត (observational data) និងទិន្នន័យដែលបានមកពីការ (questionnaire data)។ ម្យ៉ាងទៀតវិធីសាស្រ្តតារាងខ្វែងនេះ ក៏អាចបង្កើតនៅក្នុងប្រូក្រាមកុំព្យូទ័រ ដែលមានសព្វថ្ងៃនេះបានដោយងាយផងដែរ។ អត្ថប្រយោជន៍ដ៏សំខាននៃតារាងខ្វែងនេះគឺ ជួយដល់អ្នកគ្រប់គ្រងប្រតិបត្តិការទីផ្សារក្នុងការស្វែងយល់បានច្បាស់អំពីតម្រូវការ និងចំណង់ចំណូលចិត្តរបស់អ្នកទិញ ហើយអាចកំណត់ចំណែកទីផ្សារគោលដៅសំខាន់ៗ និងកំណត់ យុទ្ធសាស្រ្តរក្សាស្ថានភាពផលិតផលនៅលើទីផ្សារបានយ៉ាងប្រសើរ។

**តារាង ១១៣៖..គម្រូវិភាគតារាងខ្វែងទាំងពីរបែបអំពីទំនាក់ទំនងរវាងអាយុនៃអ្នកដឹកនាំគ្រួសារ និងការផ្គត់ផ្គង់ម្ហូបអាហារពីភោជនីយដ្ឋានភ្នំពេញ**

| ក-គិតជាប្រេកង់ | ប្រេកង់ | | | |
|---|---|---|---|---|
| អាយុអ្នកគ្រប់គ្រងគ្រួសារ(ឆ្នាំ) | ចំនួនអ្នកញ៉ាំម្តងឬច្រើនក្នុងមួយសប្តាហ៍ | ចំនួនអ្នកញ៉ាំ២ ឬ. ៣ដងក្នុងមួយខែ | ចំនួនអ្នកញ៉ាំម្តងឬសរុប តិចជាងក្នុងមួយខែ | សរុប |
| ២៤ ឬ តិចជាង | ១៤៤ | ៥២ | ១៩ | ២១៥ |
| ២៤ ទៅ ៣៩ | ២១៥ | ៥៨ | ២៩ | ១៣៣ |
| ៤០ ឬលើ | ៨២ | ៦៩ | ៨៧ | ២៣៨ |
| សរុប | ២៧២ | ១៧៩ | ១៣៥ | ៥៨៦ |
| ខ-គិតជាភាគរយ | ប្រេកង់ | | | |

| | | | | |
|---|---|---|---|---|
| ២៤ ឬ តិចជាង | ៦៧,០% | ២៤,២% | ៨,៨% | ១០០% |
| ២៤ ទៅ ៣៩ | ៣៤,៦% | ៤៣,៦ | ២១,៨% | ១០០% |
| ៤០ ឬលើ | ៣៤,៤% | ២៩,០% | ៣៦,៦% | ១០០% |
| សរុប | ៤៦,៤% | ៣០,៦% | ២៣,០% | ១០០% |

### ១១.៥.៥. តួនាទីសំខាន់នៃការស្រាវជ្រាវទីផ្សារកសិកម្ម

ដើម្បីបានព័ត៌មានប្រតិបត្តិការទីផ្សារ គឺត្រូវធ្វើការស្រាវជ្រាវប្រតិបត្តិការទីផ្សារ (Marketing Research)។ អ្នកគ្រប់គ្រង ប្រតិបត្តិការទីផ្សារ ត្រូវការព័ត៌មានប្រតិបត្តិការទីផ្សារដើម្បីធ្វើការ សម្រេចចិត្តអំពីការធ្វើផែនការប្រតិបត្តិការទីផ្សារ ការដោះស្រាយនូវបញ្ហាប្រតិបត្តិការទីផ្សារ និងការត្រួតពិនិត្យមើលដំណើរការប្រព្រឹត្តទៅនៃសកម្មភាពប្រតិបត្តិការទីផ្សារ នៅក្នុងអង្គភាព អាជីវកម្មមួយ។ម្យ៉ាងទៀតការស្រាវជ្រាវប្រតិបត្តិការទីផ្សារ គឺជាដំណើរការនៃការកំណត់បញ្ហា និងឱកាសប្រតិបត្តិការទីផ្សារតាមរយៈការប្រមូលទិន្នន័យ វិភាគទិន្នន័យ និងការផ្តល់យោបល់ អំពីវិធានការនៃការកែលំអឲ្យកាន់តែប្រសើរនូវសកម្មភាពប្រតិបត្តិការទីផ្សារនៅក្នុងអង្គភាព អាជីវកម្មមួយ។ មធ្យោបាយទាំងឡាយក្នុងការកាត់បន្ថយការ ប្រថុយប្រថាន (Risk) និងភាព មិនពិតប្រាកដ (Uncertainty) ការវាយតម្លៃទៅលើតម្រូវការ និងចំណង់ចំណូលចិត្តរបស់អតិថិជន និងការផ្តល់ព័ត៌មានដែលអាចជួយក្នុងការរៀបចំនូវកម្មវិធីប្រតិបត្តិការទីផ្សារ ដើម្បីបំពេញ សេចក្តីត្រូវការរបស់ពួកគេ។ សកម្មភាពទាំងអស់នេះ គឺជាតួនាទីនៃការស្រាវជ្រាវប្រតិបត្តិការ ទីផ្សារ។ នេះមានន័យថា ការស្រាវជ្រាវប្រតិបត្តិការទីផ្សារ គឺជាការព្យាយាមរកឱ្យឃើញ និង កំណត់នូវបញ្ហា និងឱកាសនៃប្រតិបត្តិការទីផ្សារដើម្បីបង្កើតនិងវាយតម្លៃអំពីសកម្មភាព ប្រតិបត្តិការទីផ្សារ។ ទោះបីជាការស្រាវជ្រាវប្រតិបត្តិការទីផ្សារមិនអាចធានាផ្តល់នូវចម្លើយមួយរយភាគរយក៏ដោយ ប៉ុន្តែវាបានជួយកាត់បន្ថយការប្រថុយប្រថាន និងភាពមិនពិតប្រាកដ ក្នុងការសម្រេចចិត្តរបស់អ្នកគ្រប់គ្រងប្រតិបត្តិការទីផ្សារ និងជួយបង្កើនកម្រិតជោគជ័យក្នុងការសម្រេចចិត្តអំពីសកម្មភាពប្រតិបត្តិការទីផ្សារ ហើយជាពិសេសការស្រាវជ្រាវប្រតិបត្តិការទីផ្សារ បានជួយអ្នកគ្រប់គ្រងប្រតិបត្តិការទីផ្សារដ៏ច្រើនក្នុងការសម្រេចចិត្តចុងក្រោយ។

#### ក. ហេតុអ្វីការស្រាវជ្រាវប្រតិបត្តិការទីផ្សារដ៏ល្អមួយអាចនឹងធ្វើបានដោយពិបាក? Why is good Marketing Research difficult?

បញ្ហាដ៏គ្រោះថ្នាក់សម្រាប់អ្នកស្រាវជ្រាវប្រតិបត្តិការទីផ្សារ គឺនៅពេលដែលពួកគេ ព្យាយាមវាយតម្លៃអំពីបំណងដ៏ពិតប្រាកដរបស់អ្នកប្រើប្រាស់ក្នុងការទិញទំនិញ ឬ សេវាកម្មដោយពួកគេមិនបានគិតថាការស្រាវជ្រាវប្រតិបត្តិការទីផ្សារដ៏ល្អមួយ គឺទាមទារឲ្យមានការយក

ណាស់ជាពិសេស គឺបញ្ហាដ៏ពិបាកក្នុងការចោទសួរអ្នកប្រើប្រាស់ព្រោះចម្លើយដោយពួកគេមិនបានគិត ចិត្តទុកដាក់ខ្លាំងណាស់ជាតិ ដែលបានមកអាចពិត ឬមិនពិតបានមកអាចពិត ឬមិនពិតក្នុងកម្រិតណានោះគឺវាអាស្រ័យនឹងវិធីសាស្ត្រនៃការសួរសោភាការជ្រើសរើសពេលវេលា ទីកន្លែង ការយល់ដឹង សមត្ថភាព ឆន្ទៈ និងសេចក្តីស្មោះត្រង់របស់អ្នកឆ្លើយសំណួរ។

**ឧទាហរណ៍៖** ដូចជានៅពេលសួរសំណួរ តើអ្នកប្រើប្រាស់ប្រាកដជានឹងទិញផលិតផល -គេមិននឹកគិតដល់នោះដែរឬទេ? តើពួកគេអាចវាយតម្លៃពីគុណសម្បត្តិ និងគុណវិបត្តិនៃ ផលិតផលពេលចោទសួរភ្លាមៗនោះបានទេ? នៅពេលដែលពួកគេដឹងចម្លើយហើយ តើគេពិត ជាចង់បកស្រាយ ដែរឬទេ ចម្លើយដែលពួកគេផ្តល់នោះពិតឬអត់? តើអាកប្បកិរិយានៃការទិញ របស់គេ វាដូចគ្នានឹងអ្វីដែលពួកគេនិយាយថាចាប់អារម្មណ៍ និងចូលចិត្តទៅលើផលិតផល? ដើម្បីសំដែងនូវភាពជឿនលឿន អ្នកប្រើប្រាស់តែងតែឆ្លើយថាពួកគេនឹងទិញផលិតផល ទោះបីជា គេមិនប្រាកដថានឹងទិញក៏ដោយ។ ដូច្នេះយើងឃើញថា ការដ៏លំបាករបស់អ្នកស្រាវជ្រាវ ប្រតិបត្តិការទីផ្សារ គឺត្រូវខំប្រឹងកាត់បន្ថយនូវបញ្ហាចោទខាងលើនេះ។

## ១១.៥.៦.ការរក្សាស្ថានភាពនៅលើទីផ្សារ ( Market positioning )

នៅពេលដែលក្រុមហ៊ុនចាប់ផ្តើមធ្វើអាជីវកម្មផលិតផលមួយនៅលើទីផ្សារ ការសម្រេចចិត្តដ៏សំខាន់របស់អ្នកគ្រប់គ្រង ដើម្បីជានានូវជោគជ័យរយៈពេលវែងនោះគឺត្រូវរក្សាស្ថានភាព ផលិតផលនៅលើទីផ្សារ ដោយរបៀបណាដើម្បីឲ្យអ្នកប្រើប្រាស់ស្គាល់ និងចងចាំទុកនៅក្នុងអារម្មណ៍យកគេអំពីលក្ខណៈពិសេសៗនៃផលិតផលដែលគូប្រជែងមិនទាន់ធ្វើបាន។ មានវិធីសាស្ត្រមួយចំនួនក្នុងការរក្សាស្ថានភាពផលិតផលនៅលើទីផ្សារ ដូចជា

### ក.ការប្រកួតតទល់ជាមួយនឹងគូប្រជែង ( head-to-head positioning )

ការប្រកួតប្រជែងនេះ គឺតាមរយៈ ការផ្គត់ផ្គង់ផលិតផល ដែលមានលក្ខណៈដូចគ្នាទៅនឹងផលិតផលរបស់គូប្រជែងនៅលើចំណែកទីផ្សារគោលដៅដូចគ្នា។

ឧទាហរណ៍ដូចជា ក្រុមហ៊ុនលក់សាំងសព្វថ្ងៃ ជាពិសេសក្រុមហ៊ុនកាល់តិច សែល និងតូតាល់ កំពុងតែរក្សាស្ថានភាពពួកគេនៅលើទីផ្សារតាមរយៈការប្រកួតប្រជែងគ្នាទៅលើគុណភាពសេវាកម្មភាពផលិតផល ជាជាងការប្រកួតប្រជែងទៅលើថ្លៃ។

### ខ.ការប្រកួតប្រជែងទៅលើផលិតផលខុសប្លែកគ្នា ( differentiation positioning )

ក្រុមហ៊ុនខ្លះបានស្វែងរកចំណែកទីផ្សារមានកម្រិតប្រកួតប្រជែងតិចតួច ( less-competitive, smaller market niche ) ដើម -ចំណែកទីផ្សារទាំងនេះនូវផលិតផលដែលមានគុណភាព និងកេរ្តិ៍ឈ្មោះល្បីដែល ដែងមិនទាន់មាន។ ឧទាហរណ៍៖ ដូចជា ក្រុមហ៊ុន McDonald's បានប្រើយុទ្ធសាស្ត្ររក្សានៅលើទីផ្សារមួយតាមរយៈការផ្គត់ផ្គង់ ហែមប៊ឺហ្គឺពិសេសដែលជួយកាត់បន្ថយទម្ងន់at McLean Deluxe hamburger ) ទៅឲ្យចំណែកទីផ្សារអតិថិជនដែលបារម្ភខ្លាំងពីសុខភាពគេ ( health-conscious segment ) ដោយខ្លាចជាត់នឹងនាំឲ្យពួកគេមានបញ្ហាបេះដូង។

# សំណួរ និង លំហាត់ត្រួតពិនិត្យ
# មុខវិជ្ជា៖ ការវិភាគគោលនយោបាយកសិកម្ម

១.តើកម្មវត្ថុនៃគោលនយោបាយកសិកម្មមានអ្វីខ្លះ? ចូរពន្យល់រៀបរាប់ពន្យល់ឲ្យបានក្បោះក្បាយ។
(What is the Objective of Agricultural Policy? Please explain them clearly)

២.តើប្រភេទសំខាន់ៗនៃគោលនយោបាយកសិកម្មមានអ្វីខ្លះ? ចូររៀបរាប់ពន្យល់ពីប្រភេទនីមួយៗរបស់វា។ (What is the Major Types of Agricultural Policy? Please explain them in Detail?)

៣.តើតួនាទីកសិកម្មក្នុងការអភិវឌ្ឍន៍ខឿនសេដ្ឋកិច្ចជាតិមានអ្វីខ្លះ? ចូររៀបរាប់ពន្យល់ឲ្យបានក្បោះក្បាយ។ (What is the Role of Agricultural Policy in Development National Economy? Please explain them in Detail?)

៤.តើបញ្ហាប្រឈមសំខាន់ៗនៃគោលនយោបាយកសិកម្មមានអ្វីខ្លះ? ចូរពន្យល់រៀបរាប់ពន្យល់ឲ្យបានក្បោះក្បាយ។ (១០ពិន្ទុ)
(What is the major constraint of agricultural policy? Please explain them clearly)

៥.តើប្រភេទសំខាន់ៗនៃគោលនយោបាយកសិកម្មមានអ្វីខ្លះ? ចូររៀបរាប់ពន្យល់ពីប្រភេទនីមួយៗរបស់វា។ (១០ពិន្ទុ)
(What is the Major Types of Agricultural Policy? Please explain them in Detail?)

៦.តើទំនាក់ទំនងសំខាន់ៗនៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយស្បៀងមានអ្វីខ្លះ? ចូររៀបរាប់ពន្យល់ឲ្យបានក្បោះក្បាយ។(២០ពិន្ទុ)
(What is the major connection between the macroeconomic policy and food policy? Please explain them in Detail?)

៧.ហេតុអ្វីបានជាយើងត្រូវពាណិជ្ជកម្មអន្តរជាតិក្នុងវិស័យកសិកម្ម?

៨.ដូចម្តេចដែលហៅថាអត្ថប្រយោជន៍ប្រៀបធៀប (Comparative Advantage) និងដូចម្តេចដែលហៅថាអត្ថប្រយោជន៍ដាច់ខាត (Absolute Advantage) ចូរលើឧទាហរណ៍បំភ្លឺឲ្យបានច្បាស់លាស់?

៩.តើយុទ្ធសាស្រ្តទាំង៩ចំណុចក្នុងការធ្វើពាណិជ្ជកម្មអន្តរជាតិចំពោះវិស័យកសិកម្មមានអ្វីខ្លះ? ចូរបកស្រាយពន្យល់? (What is the 9 strategies to set up the international Trade)។ (១០ពិន្ទុ)

១០.ចូរបង្ហាញថា៖ $MC = \frac{w}{MP}$ ដោយ $MC$ ជាចំណាយលម្អៀង $w$ ជាអត្រាប្រាក់ឈ្នួល $MP$ ជាផលិតផលលម្អៀង។

១១.ក្រុមហ៊ុននាំចេញ-នាំចូលប្រកួតប្រជែងពេញលេញដ៏សុក្រិត្យមួយ (A Perfect Competitive Import-Export Firm) ប្រឈមមុខនឹងថ្លៃទីផ្សារមួយឯកតា $(P)$ ស្មើនឹង៤ដុល្លា។ ក្រុមហ៊ុននាំចេញ-នាំចូលនេះមានសមីការនៃអនុគមន៍ចំណាយផលិតកម្មសរុបមានរាង៖ $TC = Q^3 - 7Q^2 + 12Q + 5$ ។ ចូរគណនាបរិមាណផលិតផល $(Q)$ ដែលផ្តល់នូវប្រាក់ចំណេញ អតិបរមា។ បន្ទាប់មកចូរគណនាប្រាក់ចំណេញអតិបរមាចំពោះផលិតផល $(Q)$ ដែលរកឃើញខាងលើ ។

១២.សមីការអនុគមន៍ផលិតកម្មនៃកសិដ្ឋានចិញ្ចឹមមាន់មួយមានអនុគមន៍រាង៖

$Q = 5L - L^2 + LK + 4K - 3K^2$

ដែល $Q$ ជាបរិមាណផលិតផលមាន់ដែលផលិតបាន $L$ ជាចំនួនម៉ោងពលកម្ម $K$ ជាចំនួនម៉ោងម៉ាស៊ីន។ ម្យ៉ាងទៀតគេដឹង ថា៖ ថ្លៃពលកម្មក្នុងមួយម៉ោង $(P_L)$ ស្មើនឹង៥០ដុល្លា និងថ្លៃជួលម៉ាស៊ីនក្នុងមួយម៉ោង $(P_K)$ ស្មើនឹង៤០ដុល្លា ហើយថ្លៃលក់ ផលិតផលមាន់មួយឯកតា $(P)$ ស្មើនឹង ១០០ ដុល្លា។ តើម្ចាស់កសិដ្ឋានចិញ្ចឹមមាន់រិះរកគោលនយោបាយយ៉ាងណា ដើម្បីឲ្យគាត់ ទទួលបាននូវប្រាក់ចំណេញអតិបរមា។ ចូរគណនាប្រាក់ចំណេណអរតិបរមានៃកសិដ្ឋានចិញ្ចឹមមាន់នេះ?

(Chicken farm Production function: $Q = 5L - L^2 + LK + 4K - 3K^2$ where $Q =$ Output Quantity, $L =$ Labor, $K =$ Capital, $P_L = 50\$ =$ Wage Rate for Labor per hour, $P_K = 40\$ =$ Rent for Capital per hour, and $P = 100\$$: Market Price per unit of output. Calculate the profit maximization for the Chicken farm production?)

១៣.ឧបមាថាការធ្វើពាណិជ្ជកម្មអន្តរជាតិមួយបកស្រាយដោយទំនាក់ទំនងដូចខាងក្រោម:

1) $C = 0.80Y_d + 20$
2) $Y_d = Y - T$
3) $T = 0.25Y$
4) $I = 0.10Y + I_0$
5) $G = G_0$
6) $X = X_0$
7) $M = 0.20Y$

ដោយ៖ $C =$ បំរើបំរាស់ឯកជន, $Y =$ ប្រាក់ចំណូលជាតិសរុប, $Y_d =$ ប្រាក់ចំណូលគ្រួសារក្រោយបង់ពន្ធ, $T =$ ការយកពន្ធ ជាចាំបាច់, $I =$ វិនិយោគឯកជន, $G =$ ចំណាយសាធារណ:, $X =$ ការនាំចេញ, និង $M =$ ការនាំចូល។

ក).ដោយឧបមាថា ថវិកាជាតិស្ថិតក្នុងស្ថានភាពសមតាដោយៈ $I_0 = 100$ ឯកតា និង $X_0 = 50$ ឯកតា ចូរគណនាអំពីប្រាក់ចំណូលជាតិនៅក្នុងធ្វើពាណិជ្ជកម្មអន្តរជាតិនេះ ហើយនឹងទាញគណនាតម្លៃអថេរឥរិយាបទមួយចំនួនដូចជាៈ

$Y^*, C^*, I^*, G^*, T^*, M^*$ និង $Y_d^*$ កំណត់យកសម្រាប់លំនឹងសមតានេះ។ បន្ទាប់មកចូរគណនាមេគុណចំណាយសាធារណៈ(K) ក្នុងខឿនសេដ្ឋកិច្ចនោះ។

ខ).ស្ថានភាពបូរណ៍និយោជន៍ (Full Employment Situation) កើតមាននៅពេលដែលចំណូលជាតិមានចំនួន 720 ឯកតា តើរដ្ឋាភិបាលត្រូវបន្ថែមចំណាយរបស់ខ្លួនចំនួនប៉ុន្មានដើម្បីឲ្យស្ថានភាពបូរណ៍និយោជន៍កើតមានឡើង ហើយតើនៅពេល នោះលំនឹងថវិការដ្ឋនឹងទៅជាយ៉ាងណា?

១៤.ឧបមាថានៅប្រទេសកម្ពុជា អ្នកជំនាញខាងសេដ្ឋកិច្ចបានធ្វើការសិក្សាយ៉ាងល្អិតល្អន់ក្នុងសេដ្ឋកិច្ចបិតជិត ហើយបានបង្កើតឲ្យមានរូបមន្ត និងតួលេខដូចខាងក្រោមៈ

$Y = C + I + G = 20000$ $Y =$ ប្រាក់ចំណូលជាតិសរុបក្នុងខឿនសេដ្ឋកិច្ចបិតជិត

$C = cY_d + C_0$ $C =$ បម្រើបម្រាស់គ្រួសារ $C_0 =$ ចំណាយចាំបាច់ខានមិនបាន

$Y_d = Y - T + R$ $T =$ ការយកពន្ធជាចាំបាច់ $G =$ ចំណាយសាធារណៈ

$s = 0.25$ $Y_d =$ ប្រាក់ចំណូលជាតិក្រោយបង់ពន្ធ $R =$ ចំណាយផ្ទេរ

$i = 0.20$ $I =$ វិនិយោគឯកជន $i =$ អត្រាការប្រាក់

$k = \dfrac{1}{1-(c+i)}$ $s =$ Marginal Propensity to Save, $c =$ Marginal Propensity to Consume

ក) តើគេត្រូវការកំណើនវិនិយោគទុន $\Delta I$ ចំនួនប៉ុន្មានដើម្បីបំបាត់ស្ថានភាពឱននិយោជន៍ (Under Unemployment's Situation) បើគេដឹងថាប្រាក់ចំណូលជាតកើនឡើង១០% ថែមទៀតនោះ គេនឹងបានទទួលស្ថានភាពបូរណ៍និយោជន៍(Full Employment's Situation)?

ខ) ដោយផ្តើមចេញពីរូបមន្តៈ $Y = C + I + G$ តើប្រាក់ចំណូលជាតិមានចំនួនប៉ុន្មាន បើគេ ដឹងថាៈ $c = 0.80$, $C_0 = 1500$, $T = 1800$, $R = 1200$, $I = 1500$, $G = 2100$ ។

គ) តើផលបញ្ជ័យទៅលើប្រាក់ចំណូលជាតិទៅជាយ៉ាងណា បើរដ្ឋាភិបាលសម្រេចចិត្តថាបង្កើនចំណាយសាធារណៈចំនួន ៨០ ឯកតា?

ឃ) តើផលបញ្ជ័យទៅលើប្រាក់ចំណូលជាតិទៅជាយ៉ាងណា បើរដ្ឋាភិបាលសម្រេចចិត្តថាមិនបង្កើនចំណាយសាធារណៈទេ ប៉ុន្តែត្រូវបន្ថយពន្ធដារ $\Delta T$ ចំនួន ៨០ ឯកតាវិញ? តើហេតុអ្វីបានជាកំណើនប្រាក់ចំណូលជាតិត្រូវថយចុះ?

ង) តើផលបញ្ច័យទៅលើប្រាក់ចំណូលជាតិទៅជាយ៉ាងណា បើរដ្ឋាភិបាលសម្រេចចិត្តថាមិនបង្កើនចំណាយសាធារណៈទេ ហើយក៏មិនបន្ថយពន្ធដារដែរ ប៉ុន្តែត្រូវបង្កើនចំណាយផ្ទេរ $\Delta R$ ចំនួន ៨០ ឯកតាវិញ?

ច) ដើម្បីចៀសវាងនូវនូវឱនភាពថវិកា រដ្ឋាភិបាលមានវិធានការពីរព្រមគ្នាគឺបង្កើនចំណាយសាធារណៈចំនួន ៨០ ឯកតា និងបង្កើនពន្ធដារចំនួន ៨០ ឯកតាដែរ។ តើកំណើនប្រាក់ចំណូលជាតិប្រែប្រួលយ៉ាងណា? ហើយតើនៅពេលនេះ តើមេគុណ $k$ ស្មើនឹងចំនួនប៉ុន្មាន?

ឆ) រដ្ឋាភិបាលមានបំណងធ្វើនយោបាយសេដ្ឋកិច្ចថ្មី ដោយមានវិធានការពីរខុសគ្នាដូចខាងក្រោម៖

ក) បង្កើនវិនិយោគសាធារណៈចំនួន ២០០ ឯកតាដែលទទួលបន្ទុកដោយថវិកាជាតិ។

ខ) បង្កើនឧបត្ថម្ភធនសង្គមចំនួន ៤០០ ឯកតាដែលនៅក្នុងនោះ៖

- ចំនួន ២០០ ឯកតាដែលជាបន្ទុករបស់ថវិការដ្ឋដែលត្រូវជាប់ពន្ធ១០%
- ចំនួន ២០០ ឯកតាដែលបានមកដោយសារការដកពន្ធពីអ្នកដែលមានប្រាក់ចំណូលខ្ពស់។

ចូរបង្ហាញឲ្យឃើញ និងធ្វើការបកស្រាយនូវការប្រែប្រួលនៃប្រាក់ចំណូលជាតិដែលកើតឡើងដោយសារវិធានការនយោបាយសេដ្ឋកិច្ចថ្មីនេះ។ គេបានឲ្យដឹងថាមេគុណ $k = \frac{1}{0.40}$។

១៥.ឧបមាថាខឿនសេដ្ឋកិច្ចមួយបកស្រាយដោយទំនាក់ទំដូចខាងក្រោម: (០៤ពិន្ទុ)

1)$C = 0.84Y_d + 20$
2)$Y_d = Y - T$
3)$T = 0.25Y$
4)$I = 0.10Y + I_0$
5)$G = G_0$
6)$X = X_0$
7)$M = 0.23Y$

ដោយ $C =$ បំរើបំរាស់ឯកជន, $Y =$ ចំណូលជាតិ, $Y_d =$ ចំណូលគ្រួសារក្រោយបង់ពន្ធ, $T =$ ការយកពន្ធ ជាចាំបាច់, $I =$ វិនិយោគឯកជន, $G =$ ចំណាយសាធារណៈ, $X =$ ការនាំចេញ, និង $M =$ ការនាំចូល។

ក).ដោយឧបមាថា ថវិកាជាតិស្ថិតក្នុងស្ថានភាពសមតា ដោយ $I_0 = 900$ និង $X_0 = 45$ ចូរគណនាអំពីចំណូលជាតិនៅក្នុងខឿនសេដ្ឋកិច្ចជាតិនេះហើយនឹងគណនាតម្លៃដែលអថេរវេរិយាបទដូចជា៖

$Y^*, C^*, I^*, G^*, T^*, M^*$ និង $Y_d^*$ កំណត់យកសម្រាប់លំនឹងសមតានេះ។ បន្ទាប់មកចូរគណនាមេគុណ ចំណាយសាធារណៈក្នុងខឿនសេដ្ឋកិច្ចនោះ។

ខ).ស្ថានភាពបូរណ៍និយោជន៍ (Full Employment) កើតមាននៅពេលដែលចំណូលជាតិមានចំនួន ៦៥០ ឯកតា តើរដ្ឋាភិបាលត្រូវបន្ថែមចំណាយរបស់ខ្លួនចំនួនប៉ុន្មានដើម្បីឲ្យស្ថានភាពបូរណ៍និយោជន៍ កើតមានឡើងហើយតើនៅពេលនោះលំនឹងថវិកាជាតិទៅជាយ៉ាងណា?

# **បណ្ណាល័យសាស្ត្រ** ( Bibliography )


## ឯកសារយោងជាភាសាខ្មែរ៖

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ***ផែនការមេសម្រាប់ការស្រាវជ្រាវកសិកម្មជាតិ*** បោះពុម្ព អង្គភាពទ្រទ្រង់កម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម រោងពុម្ព ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០០៦

ឆាយ គង្គា ***វិទ្យាសាស្ត្រគ្រប់គ្រង*** បោះពុម្ពលើកទី៦ រោងពុម្ព មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ សាកលវិទ្យាល័យភូមិន្ទកសិកម្ម ឆ្នាំ២០១១

ឆាយ គង្គា ***គោលការណ៍គ្រឹះនៃការគ្រប់គ្រង*** បោះពុម្ពលើកទី៧ រោងពុម្ព សាកលវិទ្យាល័យបៀលប្រាយ សាខាខេត្តតាកែវ ឆ្នាំ២០១៨

ឆាយ រ័ត្នមុន្នី និងឈឿន សាវន ***គោលការណ៍នៃការគ្រប់គ្រង*** បោះពុម្ពលើកទី៣ រោងពុម្ព សាកលវិទ្យាល័យអាស៊ី អឺរ៉ុប ឆ្នាំ២០១៤

ណាំ ណារិទ្ធ ***មូលដ្ឋានគ្រឹះនៃការគ្រប់គ្រង*** បោះពុម្ពលើកទី១ រោងពុម្ព វិទ្យាស្ថានអន្តរជាតិអន្តរជាតិនៃកម្ពុជា ឆ្នាំ២០០៤

ពេជ្រ ភិរម្យ ***គោលការណ៍នៃការគ្រប់គ្រង*** បោះពុម្ពលើកទី៥ រោងពុម្ព សាកលវិទ្យាល័យជាតិគ្រប់គ្រង ឆ្នាំ២០១១

ពៅ សាមី ***វិទ្យាសាស្ត្រគ្រប់គ្រងទូទៅ*** បោះពុម្ពលើកទី១ រោងពុម្ព គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ ឆ្នាំ២០០៨

យិន ឆេងហ៊ន ***សហគ្រិនភាព និងធុរកិច្ចជោគជ័យ*** បោះពុម្ពលើកទី១ ២០១៧

រាជរដ្ឋាភិបាលកម្ពុជា ***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦ - ២០១០*** ឆ្នាំ២០០៥

ស៊ីវ វុទ្ធី ***គោលការណ៍គ្រឹះនៃការគ្រប់គ្រង*** បោះពុម្ពលើកទី១ រោងពុម្ព វិទ្យាស្ថានអន្តរជាតិអន្តរជាតិនៃកម្ពុជា ឆ្នាំ២០០៤

សួន ប៉ានី ***សហគ្រិន...ការគ្រប់គ្រងសហគ្រិនខ្នាតតូច និងមធ្យម*** បោះពុម្ពលើកទី១ រោងពុម្ព សាលាភូមិន្ទរដ្ឋបាល ឆ្នាំ២០១៩

## ឯកសារយោងជាភាសាបរទេស៖

Berkeley Hill, *Farm Income, Wealth and Agricultural Policy*, Fifth Edition, Avebury, Ashgate Publishing Limited, England, 2005.

Chhay Kongkea, *Agricultural Development Strategy in Cambodia*, Ph.D. Dissertation, Department of Agricultural Economics, Graduate School of Agriculture and Life Sciences, Chonnam National University, Gwangju City, 500-757, South Korea, 2006.

Chhay Kongkea, *Rice Supply-Demand and Improvement Strategy on Rice Industry in Cambodia*, Thesis presented for the Master′s Degree, Department of Agricultural Economics, Graduate School of Agriculture and Life Sciences, Chonnam National University, Gwangju City, 500-757, South Korea, 2003.

Department of Planning, Statistics and International Cooperation, **MAFF, STRATETEGIC PLAN 1997-2001**, Department of Planning, Statistics and International Cooperation, MAFF Publishing, 1996.

Eicher Carl K., and John M. Staatz, *International Agricultural Development*, Third Edition, The Johns Hopkins University Press, Baltimore and London, 1998.

F. Bailey Norwood and Jayson L. Lusk, *Agricultural Marketing and Price Analysis*, Pearson Education Inc., Prentice Hall, 2008.

Graham Hallet, *The Economics of Agricultural Policy*, Fourth Edition, Basil Blackwell, 2003.

Hayami Yujiro and Vernon W. Ruttan, *Agricultural Development: An International Perspective*, Revised and expanded edition, 1985.

Ingersent Ken A. and A.J. Rayner, *Agricultural Policy in Western Europe*, Edward Elger Publishing Inc., USA, 1999.

Jaeok Lee and Lim Song-Soo, *Agriculture in Korea*, Korea Rural Economic Institute, 1999.

Knutson Ronald D., J.B. Penn and Barry L. Flinchbaugh, *Agricultural and Food Policy*, Fifth Edition, Prentice-Hall, Inc., 2004.

Norton George W., and Jeffrey Alwang, *Introduction to Economics of Agricultural Development*, McGraw-Hill, Inc., 1993.

Norton Roger D., *Agricultural Development Policy: Concepts and Experiences*, John Wiley & Sons, Ltd., 2004.

Pranav K. Desei, *Agricultural Economics*, Biotech Books Delhi-110036, Publisher, 2010.

S. S. Acharya and N. L. Agarwal, *Agricultural Prices: Analysis and Policy*, Oxford & IBH Publishing Co. PVT. LTD., 1994

Sadhu & Singh, *Fundamentals of Agricultural Economics*, 3rd Edition, Himalaya Publishing House, 1993.

Stevens Robert D., and Cathy L. Jabara, *Agricultural Development Principle: Economic Theory and Empirical Evidence*, The Johns Hopkins University Press, Baltimore and London, 1988.